
គ្រួសារនិងទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ភគ្គជសុត្តវិយា


ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៥ លេខ ៣ ខែ កក្កដា
ព. ស. ២៥០៥ គ. ស. ១៩៦៣



រូបខាងលើនេះ ជាវត្តព្រះស៊ីហនុ នៅទេត្រយតនតិរី ទើបនឹងកសាងក្នុងរាជ្ជកាលសម្តេចព្រះនរោត្តម ស៊ីហនុ ព្រះប្រមុខរដ្ឋកម្ពុជា មានវិហារ
នឹងកុដិព្រះសង្ឃខ្នះហើយ ។ នឹងត្រូវសង្ឃឹម ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ។



អង្គុលិសន្ទេសា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

	ទំព័រ
ផ្នែកសាសនា	
- រឿងមនុស្សស្លាប់ តើវាត្រឡប់ទៅកើតជាអ្វី (ទែសារណកថា) លោក ផេង-ត្រីវ៉ា ប្បៀបរៀង (ត)	៦៦០
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ូ ប្រែប្បៀបរៀង (ត) . . .	៦៧២
- អាថិកំពាំងរបស់តុន្នសាសនា លោក ប៊ូ-ប៊ូ រៀបរៀង	៦៨០
- មហោសាថជាតក (ត)	៦៨៣
ផ្នែកអក្សរសាស្ត្រ	
- ទឹកភ្នែកយំមានឧបការគុណលើកូនមែនឬទឹកដីមែនឧទ្ទិសលោកថា) ផេង-ត្រីវ៉ា រៀបរៀង (ភាគចប់)	៦៨៤
- អក្សរសាស្ត្រខ្មែរ សិលាចារឹក ជីយ-នន្ទ ស្រាវជ្រាវ ដោយ ន-ជាង (ត) . .	៦៩៨
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ទាត់ រៀបរៀង (ត) . . .	៧០១
- រឿងសាមកុក លោកឧកញ៉ា ទូ-កន ប្រែប្បៀបរៀង (ត)	៧០៣
- ល្បើកឡាហ្វុងតែន លោកផេង-ត្រីវ៉ា ប្រែពីភាសាចាវ៉ាំង (ត) . . .	៧០៨
- រឿងចិងអូលីវែរ លោក វ៉ាយ-ប៊ុក ប្រែពីភាសាចាវ៉ាំង (ត)	៧១៦
- សំបុត្រទីមួយរបស់លោកនេះ ភៅប្តូរត្រីលោក តាមតាងសល្លី (សៀវភៅនៃធម្មជាតិ) លោក ឈន-អៀម ប្រែពីភាសាអង់គ្លេស	៧២២
- ប្រកាសប្រឡងប្រែនៃទំនៀមទំលាប់ខ្មែរ	៧២៨
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍	
- ប្រវត្តិវត្តឧណ្ណាមលោម , ...	៧៣១

មួយឆ្នាំមាន ១២ លេខ តម្លៃដាវ ២៣០រ៉ូ០

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការលាមក	ឲ្យធ្វើល្អទៅ
ឲ្យដុំសទាត់ចិត្ត	កុំឲ្យហ្មងសៅ
បីនេះលោកហៅ	ពុទ្ធសាសនា

វិទារណាកថា

រឿងមនុស្សស្លាប់កើតឡើងវិញជំងឺជាតិ (ត)

លោក ដេង - ទ្រីវ រៀបរៀង

ប្រវត្តិជំងឺជាតិរបស់នាង យ៉ាន (ឈ្មោះសព្វថ្ងៃហៅនាងសុទុម)

នាងនេះ សព្វថ្ងៃ អាយុ ១៣ ឆ្នាំ កើតនៅភូមិ - ឃុំព្រៃដើមថ្នឹង ស្រុកស្រីសិទ្ធិ-កណ្តាល ខែត្រព្រៃវែង ដែលបានដឹងកំណើតរបស់ខ្លួនយ៉ាងជាក់ច្បាស់ ។ ដើមដំបូង នាងនៅភូមិកំពង់បឹង ឃុំមៀន ស្រុកកោះសុទិន ខែត្តកំពង់ចាម មានកូនប្រុស ១ កូនស្រី ១ ហើយនាងស្លាប់នៅក្នុងអាយុ ២៤ ឆ្នាំ ដោយជម្ងឺគ្រុនក្តៅ ។ កាលដែលនាងស្លាប់នោះ បានទៅកើតអាស្រ័យនៅលើដើមឈើ អស់រយៈកាលចំនួន ១០ឆ្នាំ មានម្តាយថែរក្សា មានការរស់នៅដូចធម្មតា ហាក់ដូចជាគ្មានថ្ងៃគ្មានយប់ខែ មានតន្ត្រីភ្លេងជានិច្ច ។ បើនាងចង់បរិភោគអ្វី វេរស់នោះតែងអណ្តែតមកជិតនាង ហើយនាងក៏បរិភោគរបស់នោះ ។ ល ។ បើមានភ្ញៀងមួយ-

ដង់មួយកាលមក ជួនកាល នាងក៏ទៅជ្រកក្រោមសាលាឬក្រោមកុដិតុ
សង្ឃ ថើមានមនុស្សណាទៅកាប់ដើមឈើដែលនាងនៅ នាងក៏ថយ-
ចេញទៅដីដទៃទៀត ឥតមានទោមនស្សអ្វីនឹងគេទេ មានសេចក្តីគោរព
ខ្លាចមនុស្សជានិច្ច ។ កាលណាមានបង់ប្អូនធ្វើបុណ្យ ហើយគេហៅ
រកឲ្យទៅបរិភោគភោជនាហារ នាងក៏ទៅបរិភោគភោជនាហារ ដូចជុំជា
មួយនឹងញាតិមិត្រ ឃើញកិកុសង្ឃគង់នៅទីនោះដែរ តែហាក់ដូច
ជាពុំទាក់ទាថានឹងថ្វាយបង្គំលោកសោះ ។ កាលដែលនាងកើតទៅលើ
ដើមឈើនោះ មានពួកខ្លះ គ្មានអាហារបរិភោគទេ ឃើញទៅបេះស្លឹកឆាប់
ខ្លះ ស្លឹកព្រិចខ្លះ បរិភោគ ។

ថ្ងៃមួយ ម្តាយរបស់នាងដែលទៅជាមួយនោះ ប្រាប់ថា ឯងទៅកើត
ជាមនុស្សវិញចុះ ។ នាងក៏ដើរចេញពីទីនោះទៅ ឃើញម្តាយរបស់
ខ្លួនសព្វថ្ងៃ កំពុងប្រកបស្រែ នាងក៏ចូលទៅចាប់បដិសន្ធិនឹងម្តាយនោះ ។
លុះកើតឡើងបានអាយុ ៣ ឆ្នាំ នាងបាននិយាយប្រាប់ម្តាយថា
ខ្លួនពីដើម នៅភូមិកំពង់ចឹង ប៉ុមៀន ស្រុកកោះសុទិន ខេត្តកំពង់ចាម
ជាអ្នកមានទ្រព្យសម្បត្តិបង្គួរដែរ មានថ្មី ហើយមានកូនទៀតផង ។ ខណៈ
នោះ នាងនិយាយប្រាប់ដោយសំដីពុំសូវច្បាស់លាស់ តាមភាពជាកុមារី
តូចនៅឡើយ តែអាពុកម្តាយ ពុំយកចិត្តទុកជាកំនឹងសំដីនាង ។

កន្លងមកបានអាយុ ១០ ឆ្នាំ មានអ្នកភូមិព្រៃដើមថ្នឹង ទៅចិញ្ចឹមគោផ្សេង

ឯកូម៉ាំតង់ចំងឹ នាងក៏រត់តាមគេទៅ លុះទៅដល់ទីកូម៉ាំផ្ទះពីដើមរបស់ខ្លួនហើយ ក៏ដើរចូលទៅគ្នានឹងណាដឹកនាំ នាងនិយាយទៅរកបងប្អូនរបស់នាងដែលមានវ័យចាស់ ៗ ណាស់ទៅហើយ ហាក់ដូចជានាងមានវ័យស្មើ ៗ គ្នា ។ គេក៏បានបញ្ជាក់ពីសោធដោយហេតុផ្សេង ៗ មានយកទ្រព្យនេះខ្លះមោះខ្លះ ជារបស់ភ្ជាប់មានដំនាន់ដែលនាងរស់នៅពីដើមនោះ មកសាកសួរ នាងក៏ឆ្លើយប្រាប់គេសព្វគ្រប់ឥតខុស ឃើញថានាងនេះពិតជាជំងឺជាតិកំណើតរបស់ខ្លួនមែន ។

លុះកន្លងទៅបានអាយុ ១៣ ឆ្នាំ នាងមកកំពេញ ដើម្បីសួរកេរកូនប្រុសរបស់ខ្លួនពីដើមដែលមកនៅកំពេញ ចំណែកខាងគហបតីវេ-យានដែលត្រូវជាមារបស់នាងពីជាតិមុន បានជំងឺដូច្នេះហើយ ក៏ហៅនាងចូលទៅផ្ទះ ហើយបានសួរពិនិត្យសោធសព្វបែបយ៉ាងទៅ នាងក៏ឆ្លើយប្រាប់យ៉ាងនេះយ៉ាងនោះសព្វគ្រប់ឥតខុស ឃើញថានាងនេះពិតជាជំងឺជាតិកំណើតរបស់ខ្លួនមែន ។

ឥឡូវ នាងនេះឮថាឪពុករបស់ខ្លួនពីដើមមានអាយុ ៧០ ជាយឆ្នាំហើយ នៅផ្សារអូរកំឡុង មានជម្ងឺដោយកេតជក ក៏ទៅនៅចំរើឪពុកដើមឯផ្សារអូរកំឡុងសព្វថ្ងៃនេះ ។ នាងនៅមើលថែទាំគ្រួតគ្រាហែរហៃបង្គាប់បញ្ជាយ៉ាងស្និទ្ធទៅលើកូនទីងំប្អូន ឲ្យធ្វើកិច្ចដូច្នេះដូច្នោះ ហាក់ដូចខ្លួននៅជាម្តាយឬជាបងគេពីដើមដដែល ។

រឿងដំរីមកចាប់ជាតិជាមនុស្ស

តាមដែលយើងធ្លាប់ដឹងមក មានតែមនុស្សមកចាប់ជាតិជាមនុស្សវិញ ហើយដឹងជាតិ ឥឡូវយើញសត្វស្វាប់ទៅ មកកើតជាមនុស្ស ហើយដឹងជាតិដែរ ហេតុដែលដឹងជាតិនេះ មិនដឹងបណ្តាលមកអំពីអ្វី?

លោកចាប-ពិន អធិបតីក្រុមទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យឱ្យការណ៍ថា: នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម មានដំរីព្រះពជទ្រព្យមួយឈ្មោះ «មណី» ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង តម្រូវឱ្យអ្នកស្រុកនោះឃ្វាលនឹងថែរក្សា (មិនដឹងឈ្មោះអ្នកគង្វាល)។ ការឃ្វាលថែរក្សា នាំឱ្យមានការប្រើដំរីនោះផង។

មានមួយថ្ងៃ ដំរីឈ្មោះមណី មានជម្ងឺ ហើយក៏ស្រុតទៅ។ ព្រលឹងដំរីនោះ ចាមកចាប់ជាតិសន្ធិ ក្នុងផ្ទៃស្រីម្នាក់នៅស្រុកនោះ។

លុះពេញប្រសូតមក មានអាការៈជាច្រើនកន្ទុយ មានទំនង់ស្រដៀងនឹងដំរី: ក្បាលធំទ្រមឹង ស្រដៀងក្បាលដំរី ព្រោះចំកណ្តាល មានចង្អេរពង់ជាព្រែក ឯញាមានតែលើ ខាងក្រោមគ្មានទេ ម្រាមដើងម្រាមដៃខ្វិនគ្មួច។ ក្រចករបៀបក្រចកដំរី សំឡេងធំខ្លាំង។

ចាំនជាដឹងថាពេកនេះមកពីដំរី ព្រោះដល់ចាំនអាយុដឹងក្តីពេកចាំនមិយាយច្រើនប្រាប់ តែវេលាដែលពេកមានវ័យធំមែនទែន ប្រហែលជាខ្មាសក៏មិនដឹង ស្រាប់តែឈប់និយាយច្រើនប្រាប់ បើមានគេសួរ។

អាពុកម្តាយឲ្យឈ្មោះគាត់នេះថា « គុយ » ។ ឈ្មោះគុយបាន សិក្សារៀនសូត្រ ហើយបួសរហូតសព្វថ្ងៃ នេះហៅថាលោកគ្រូគុយ ។

លោកចាប៉-តិន បានឲ្យការណ៍ខ្មែរថា កាលលោកនៅជាសង្ឃ គង់វត្តទុណ្ណាលោម លោកគ្រូគុយនេះ បានធំមន្តមកសំណាក់នៅកុដិលោកម្តង ។ ហើយដំណឹងដឹងជាតិនេះ បានឮទៅដល់ចាវ៉ាំងម្នាក់ ឈ្មោះលោក ម៉ាំណាទ្រីយ (Minètrier) កាលនោះធ្វើជាគ្រូបង្រៀន នៅសាលាចាលីជាន់ខ្ពស់ ។ លោកម៉ាំណាទ្រីយបានធំមន្តលោកគ្រូគុយ ទៅឲ្យគេថតរូបលោក រួចចាក់ឆ្នោះបានផ្ញើរូបថតលោកគ្រូគុយ ឲ្យទៅឯប្រទេសចាវ៉ាំង កុងសំណាក់ក្រុមអ្នកប្រាជ្ញ ខាងការវិវត្តន៍សត្វ ព្រោះគេនិយមជឿថាមនុស្សស្ទាប់ទៅត្រូវកើតមកជាមនុស្សវិញ សត្វស្ទាប់ទៅត្រូវកើតមកជាសត្វវិញ ឯការធ្វេងជាតិគ្នាពីមនុស្សទៅសត្វ ឬពីសត្វមកមនុស្ស មិនមានទេ ឥឡូវស្រាប់តែមានសត្វបានមកកើតជាមនុស្ស ។ តែរឿងផ្ញើរូបថតលោកគ្រូគុយទៅប្រទេសចាវ៉ាំងនោះ ក៏ស្រាប់តែបាត់ស្ងាត់ទៅមិនឃើញបណ្តាលឲ្យមានត្រឹត្តិការណ៍អ្វីរហូតដល់សព្វថ្ងៃ ។ តាមពាក្យប្រើនអានុភាពនៃពុទ្ធសាសនា មានសំដែងថា:យថាសន្នកម្ម តថាអ្វី ។ ដែលមនុស្សដឹងស្ទាប់ត្រូវតែមាន មុនទើបដកវិញ្ញាណចេញផុតពីរូបបាស់ ។ ឯតែដែលមនុស្សដឹងស្ទាប់ត្រូវឃើញនោះ មានឈ្មោះកម្ម ๑ កម្មនិមិត្ត ๑ គតិនិមិត្ត ๑ ។ កម្មនោះ មានន័យថាអំពើអ្វីដែលខ្លួនកាលនៅជាគ្រាប់ប្រព្រឹត្ត

ឆ្លាប់ធ្វើ ។ ១. កាលនៅជា ខ្លួនឆ្លាប់ធ្វើទាន មានឲ្យចុយដល់សួមយាចក ជាក់ចាយចាត្រប្រគេនព្រះសង្ឃជាដើម ជិតស្លាប់ ស្រមៃឃើញ ដូចខ្លួនកំពុងយកចាយជាក់ចាត្រព្រះសង្ឃ បើកាលនៅជា ខ្លួនឆ្លាប់ធ្វើអំពើទុច្ចរិត មានការចាក់កជ្រក ឬអាកេមាន់ជាដើម លុះជិតស្លាប់ ស្រមៃឃើញដូចកំពុងចាក់កជ្រក ឬកំពុងអាកេមាន់ យ៉ាងនេះ ហៅថាកម្ម ។

កម្មនិមិត្ត មានន័យថា: អ្វីជានិមិត្តរូបនៃកម្មដែលខ្លួនឆ្លាប់ធ្វើ កាលដែលខ្លួននៅជា បើខ្លួនឆ្លាប់ជាក់ចាត្រព្រះសង្ឃ លុះជិតស្លាប់ ត្រូវស្រមៃឃើញព្រះសង្ឃស្ពាយចាត្រនិមន្តហូរហែនៅពីមុខ បើខ្លួនឆ្លាប់ចាក់កជ្រក លុះជិតស្លាប់ ក៏ស្រមៃឃើញជ្រកដើរពីមុខ ឬក៏ឮសូរជ្រូកស្រែកយ៉ាងនេះ ហៅថាកម្មនិមិត្ត ។

គតិនិមិត្ត មានន័យថា: កាលដែលនៅជា ខ្លួនឆ្លាប់ធ្វើបុណ្យ លុះជិតស្លាប់ត្រូវស្រមៃឃើញគេយកវេជ្រជាប់ដោយផ្កា ទឹមដោយសេះយ៉ាងស្អាតមកចាំខ្លួល ឬក៏ស្រមៃឃើញទេព្តាហោះពីទាងលើ ស្រែកហៅឲ្យខ្លួនទៅជាមួយ ។ បើកាលនៅជា ខ្លួនឆ្លាប់ធ្វើបាប លុះជិតស្លាប់ត្រូវស្រមៃឃើញអណ្តាតភ្លើង នាំឲ្យខ្លួនក្តៅក្រហាយ ឬឃើញមនុស្សរូបអាក្រក់ កាន់ជាវគាន់លំពែងមកបំរុងនឹងចាក់ នាំឲ្យខ្លួនភ័យតក់ស្លុតស្រែក យ៉ាងនេះ ហៅថាគតិនិមិត្ត ។

បណ្តាវត្ថុទាំងបីនេះ អ្នកជិតស្លាប់ ត្រូវតែឃើញវត្ថុណាមួយជាមិនខាន

ឬជាមនុស្សយើញតាំង ៣ តែម្តងក៏មាន ហើយចិត្តគោងយកណាជាអារម្មណ៍
របស់ខ្លួន ទើបវិញ្ញាណចេញផុតរូបកាយ បើចិត្តមិនគាន់គោងអ្វីជាអា
រម្មណ៍ទៅឡើយទេ វិញ្ញាណត្រូវទៅក្រាញទីដ៏រូបថាស់សិន មិនគាន់ហាន
លះបង់ចោលទេ ព្រោះមិនដឹងយកអ្វីជាតំនឹងក្នុងបរលោក ។ អំពីរឿង
ស្លាប់នេះ គេឧបមាចិត្តដូចជាដង្កូវចាក់ខ្នង ដង្កូវនេះ បើកចង់ក្លូនទៅទីណា
ដើងមុខក៏មិនគាន់ចាប់ទីនោះជាប់ទេ វាមិនហានលែងដើងក្រោយឡើយ
លុះតែដើងមុខចាប់ជាប់អ្វីហើយ ចាន់ក៏លែងដើងក្រោយ ឯចិត្តនៃមនុស្ស
ជិតស្លាប់ យ៉ាងដូច្នោះដែរ ពេលណាចិត្តមិនគាន់គោងជាប់អ្វីជាអារម្មណ៍
ទេពេលនោះ វិញ្ញាណមិនត្រូវយួយចេញពីរូបថាស់ឡើយ ។ នេះជាទ្រឹស្តី
នៃពុទ្ធសាសនា ចំពោះបុគ្គលដែលរៀបស្លាប់ ។ មានសេចក្តីបញ្ជាក់ថា
ពោះបើបុគ្គលនោះស្លាប់ដោយប្រកេទណា ស្លាប់តាមរបៀប ហៅថាអាយុ
ខេយក្តី ហៅថាកម្មខេយក្តី សាមីខ្លួន មុនឆ្នាំឬត ត្រូវតែដួបប្រទះវត្ថុណា
មួយ ក្នុងបណ្តាវត្ថុតាំង ៣ ដូចពោលមកខាងលើជាមិនខាន ដែលនឹងថា
មិនបានយើញវត្ថុណាមួយ ហើយឬតទៅដែរនោះ ឥតអត្ថិមានតាល់តែ
សោះ ។ សរុបសេចក្តីទៅ បើសត្វស្លាប់ ត្រូវតែចាប់កំណើតក្នុង
បដិសន្ធិដ៏ឡើយ ពោះបីទៅខាងសុគតិភពក្តី ទុគតិភពក្តី ដោយមានវត្ថុតាំង
ចិត្តនោះជាអារម្មណ៍ហើយ ។

តាមទ្រឹស្តីនៃយោគីឈ្មោះកមលករ: ដែលមានសំដែងក្នុងសៀវ-

ទៅ « រឿង ๘ ប្រការ » របស់ហ្លួងវិចិត្រភាពការ (តឹម-សៀង ព្យួនប្រែ-តា) ហើយដែលលោកឧកញ៉ាបុណ្ណចន្ទមង្គល ឧត្តមមន្ត្រីវិត្រត ប្រែមកជាភាសាខ្មែរថា: រូបមនុស្សយើងចែកជា ๗ ភាគធំ ដូចតទៅ:

๑) កាយ - ๒) ចេតកូត - ๓) ទ្រុបាណ - ๔) សញ្ញា - ๕) - បញ្ញា - ๖ -) ដួងចិត្ត - ๗) វិញ្ញាណ ។

ក្នុងបណ្តាភាគទាំង ๗ នេះ ខ្ញុំសើរយកតែភាគទី ๒ ដែលហៅថា « ចេតកូត » មកពិភាក្សាដោះស្រាយ ព្រោះភាគចេតកូត មានការពាក់ព័ន្ធដល់រឿងមរណភាពនៃសត្វ ។ យោគីចមកពោះ: អះអាងថា: « កាលណាកាយបែករលាយទៅ ដែលយើងហៅថាស្លាប់ ចេតកូតរកកាយទៅពុំទាន់បាន ក៏ត្រាច់ទៅ ដួងកាលទៅជួបមនុស្ស ក៏សំដែងឲ្យមនុស្សយើញ ដែលយើងហៅថា « ខ្មោចលង » (ឱសាច) ។ កាយនិងចេតកូតនេះ អាចប្រៀបធៀបនឹងខ្លួនយើង បីដូចយើងមានផ្ទះមួយ បានទៅយូរមកហើយ យើញថាផ្ទះនោះត្រាំត្រាណាស់ យើងនឹងទៅតទៅទៀតពុំបាន មុខជារលំពុំខាន យើងក៏រកសង់ផ្ទះបម្រុងទុកឲ្យហើយ បើផ្ទះចាស់រលំកាលណា យើងក៏ទៅនៅផ្ទះដែលយើងសង់ថ្មីនោះ មិនចាំដើររកផ្ទះ ឬទៅអាស្រ័យនៅនឹងបងប្អូនញាតិសាលោហិតនោះឡើយ បើប្រសិនផ្ទះយើងនៅមុនសុខ ។ មិនខាន់ចាស់ទ្រុឌទ្រោមទេ ហើយមានទេសកាល ជាខ្យល់ព្យុះឬភ្លើងឆេះក្តី មកលោយផ្ទះរបស់-

យើងដោយមិនដឹងខ្លួន រកផ្ទះនៅគ្មាន មានតែនៅជ្រកនៅនឹងញាតិប្អូ
កំព្រាជ្រកនៅតែខ្លួនឯងស់ដែលនៅសាសៅសិន ទំរាំរកផ្ទះនៅបាន សេចក្តី
នេះ ប្រៀបដូចខេតកូត ម៉េរូបកាយដែលមានជម្ងឺឈឺជាយូរ ខេតកូតដឹង
ថាកាយនេះនឹងត្រាំនៅយូរតែនៅទៀតក៏ពុំបាន ក៏សូងរកតែតែខ្លួនឯងពុកជាមុន
គាលណាកាយនេះរលាយទៅ ខេតកូតក៏ចេញពីកាយដោយស្រួល
ទៅនៅនឹងកាយឯទៀត ដែលរកពុកបានជាមុននោះ ។ ម៉េកាយនោះ
នៅសុខ ។ ហើយខ្លួលមានទុប្បត្តិហេតុដូចជាស្លាប់នឹងរនេះកិន ស្លាប់-
ដោយគេសម្លាប់ ឬស្លាប់ដោយអាការផ្សេង ។ ដែលឆាប់រហ័សនោះ
ខេតកូតមិនខាន់ដឹងខ្លួនទឹងចេញទៅរកកាយជ្រកមិនខាន់មិនដឹងជាទៅនៅ
ជ្រកឯណា ក៏ត្រាំនៅ។ ឯនោះឬក៏ទៅរកញាតិដែលស្គាល់រាប់អាន គាល
នៅក្នុងកាយមិនខាន់ស្លាប់នោះ ជួនកាលគឺធ្វើឲ្យឃើញនឹងក្អែកជាក់ស្តែង
ចំពោះអ្នកណាមួយ ដែលយើងហៅថា «បិសាច» ព្រោះហេតុនេះ មនុស្ស
ដែលមានជម្ងឺឈឺយូរ ស្លាប់ទៅ មិនសូវឃើញ បិសាច ឯមនុស្ស
ដែលស្លាប់ក្នុងបច្ចុប្បន្នខាន់ហាន់ដែលហៅថាស្លាប់តាយហោងនោះ ច្រើន
ឃើញបិសាច « មកយាយីរឿយ ។ ដែលពុកជាក់ថាជាខ្មោចតាម » ។

ចំពោះលទ្ធិរបស់យោគីកមកកេះ នឹងលទ្ធិពុទ្ធសាសនា តើយើង
ត្រូវនិយ័យយ៉ាងណា ? ពុទ្ធសាសនាថា សត្វស្លាប់ ត្រូវកើតក្នុង គ្មានយះ
គេលបង្ហាំងទេ ដូចជនក្លិវក្លាក់ខ្លួន តែដើងមុខគោងជាប់ហើយ លែង-

ដើងក្រោយភ្លាម ឃានសេចក្តីថា:ស្ងាប់កើតព្រមគ្នា មិនមុនមិនក្រោយ ។ ចំណែកលទ្ធិយោគីពមចរក: ថាជាពីរបែប: បើចេតកូត(ព្រលឹង) រកកន្លែងទុកឃានហើយ នោះស្ងាប់ភ្លាមកើតភ្លាម បើចេតកូតមិនដឹងខ្លួន ដូចជាមនុស្សត្រូវរនេះកិន នោះមិនទាន់កើតភ្លាមទេ ត្រូវដើរកកន្លែងសិន ។

អំពីរឿងនេះ ខ្ញុំសូមវិលទៅឯរឿងដើងជាតិមុនវិញ ។ តើយើងជឿថាកូនប្រុសអាចារ្យសុ ជាលោកគ្រូអាចារ្យសោម កាលកើងជាតិមុនឬទេ ? តើយើងជឿថា ចៅរូបជាកូនឆាងដូ ប្តីឈ្មោះផ្ទូ ជាឈ្មោះអឹមនៅភ្នំស្រួច ហើយជាប្តីរបស់ឆាងណាប់ នៅភូមិព្រែកឫស្សី កាលជាតិមុនវិមនឬទេ ? បើយើងមិនជឿថាមានមនុស្សស្ងាប់កើតមកវិញដើងជាតិមានតែកុមារនោះ ។ មានវិជ្ជាអ្វីមួយពីក់ណើតមក ហើយអាចពិនិត្យសង្កេតឃានថា កន្លែវត្តនេះ មានលោកគ្រូនេះសុគត នៅភូមិនេះ មានប្តីឆាងនេះស្ងាប់ ហើយវិជ្ជាហ្នឹងថែមទាំងធ្វើឲ្យដឹងជម្រៅអ្វីៗ ទាំងខាងផ្លូវចិត្តផង ទាំងខាងផ្លូវសម្ភារៈផងទើបសម បើមិនដូច្នោះ ធ្វើម្តេចនឹងដឹងរបស់របរផងទាំងពួង ធ្វើដូចម្តេចនឹងដឹងឈ្មោះឪពុកម្តាយបងប្អូន ?

ឥឡូវត្រូវយើងពិចារណាតទៅទៀតថា បើកើងនោះមានជាតិវិជ្ជានេះវិមន ហេតុអ្វីក៏មិនឲយចំពោះអ្នកនៅកើងភូមិជាមួយតែម្តងឲ្យហើយទៅ? ឬមួយកើងភូមិនោះ គ្មានអ្នកស្ងាប់ត្រូវនឹងកំណើតខ្លួន បើយល់ដូច្នេះ ហាក់ដូចមិនសម នេះមួយផ្នែក មួយផ្នែកទៀត ហេតុម្តេច ដល់ជំមានវ័យចំរើន

ឈ្មោះនោះមិនទៅដើរទៅយក្នុងស្រុកភូមិដទៃ ដើម្បីកែផលប្រយោជន៍? តើយើញនិយាយរឿងដឹងជាតិ តែគាល់ខ្លួនទៅវិញជាកុមារ? ម្យ៉ាងទៀត បើយើងសន្និដ្ឋានថាកុមារនោះមានវិជ្ជាពិសេសនេះពិតប្រាកដមែន ហេតុម្តេចក៏មិនដែលឮថាបានទាយនូវកំណើតជាតិមុន ឲ្យដល់ឈ្មោះណាម្តង?

បើយើងដឿថាកូនអាចារ្យសុិទ្ធិចេះរំលឹកដឹងជាតិមែន គួរលើកបញ្ហាមួយជាបញ្ហាសួរក្រស្នាញមកដោះស្រាយ គឺបញ្ហាវិញ្ញាណ (លទ្ធិពុទ្ធសាសនា) នឹងចេតកូត (លទ្ធិយោគីកមតវាទៈ) ។ លទ្ធិពុទ្ធសាសនាថាមនុស្សស្លាប់ វិញ្ញាណនៃមនុស្សនេះ កើតវិញភ្លាម ក្នុងភពណាមួយ ទោះបីស្លាប់ដោយប្រភេទណាក៏ដោយ លទ្ធិយោគីពោលជាតិវិផ្ទុយៈ ថាបើសាម៉ីខ្លួនឈឺយូរ រួចបានស្លាប់ ទោះចេតកូតដែលបានកេតិ៍តន្ទែងសម្រាប់ជ្រកហើយ ត្រូវតែកើតវិញភ្លាមដែរ តែបើស្លាប់តាយហោងមានរនេះកន់ជាដើម ហើយចេតកូតមិនដឹងមុន មិនទាន់បានកេតិ៍តន្ទែងទុកចេតកូតត្រូវ ឬមួយទៅសំណាក់ត្រង់តន្ទែងប្រចាស់សិន ឬមួយត្រាប់កេជ្រកក្នុងទីដទៃបណ្តោះអាសន្ន ចំរុះកេតន្ទែងត្រូវចិត្ត លុះកេបានហើយ ទើបចាប់កំណើតថ្មី ។ លទ្ធិយោគីទុកចេតកូត (ត្រលឹង) ជាបំសាច ជាខ្មោចដែលលង់មនុស្ស លទ្ធិពុទ្ធសាសនា ទិយមថាបំសាចក្តី ខ្មោចដែលលង់ក្តី ជាប្រេតអសុរកាយ រួចផ្សេងដទៃពីបុគ្គលអ្នកស្លាប់ មិនមែនបុគ្គលស្លាប់-ហើយត្រលឹងទៅដើរលង់មនុស្សទេ អើបើសាម៉ីខ្លួនអ្នកដែលស្លាប់ហើយ-

ទៅតើតជាថ៏សាចប្តូជាប្រេតអសុរកាយ នោះអាចជាខ្មោចលង់ចានដែរ តាមយថាកម្មរបស់ខ្លួន ។

ឥឡូវ ខ្ញុំរៀបមករកឿងដ៏ធំជាតិវិញ: កូនអាចារ្យសុថាខ្លួន កាលមិនទាន់ជួបនឹងអាចារ្យសុ ទៅដើរទៅដើរមក ក្បែរទីនោះ លុះតេលយប់ត្រូវទៅជ្រកនឹងចេតិយដែលគេសាងសម្រាប់ដាក់ឆាតុរបស់ខ្លួន ក្នុងវត្តអគ្គិសិង្ហ ទៅរួចថាដើរពីកុំស្រួចមក ចានជួបនឹងក្មេងម្នាក់ គឺយកធ្វើជាតូកនលុះដល់មកស្ថានកំពង់ទួល ប្រទះនឹងក្បៀងកំនាំគ្នាទៅជ្រកនឹងផ្ទះនាងដូ រឿងនេះមានសភាពស្របនឹងទ្រឹស្តីខែរយោគីមួយផ្នែកដែលថាចេតកូតដើរកន្លែងជ្រកមួយផ្នែកមួយផ្នែកទៀតដូចមិនសូវសមៗចុះដែលថាមិនសូវសមនោះយ៉ាងណា? មិនសមទៅត្រង់ស្តីពីស្លាប់ហូរហែនឹងស្លាប់តាយហោង ព្រោះលោកគ្រូសោមនឹងឈ្មោះអឹមមិនមែនស្លាប់តាយហោងទេ គឺស្លាប់ដោយជម្ងឺឈឺយូរ ដោយហោចណាស់ក៏ចំនួន ១០ ថ្ងៃឬ ៥ ថ្ងៃដែរទើបស្លាប់ ហេតុម្តេចក៏ចេតកូតមិនរកកន្លែងសម្រាប់តើតទុកឲ្យហើយ ក៏មែនជាទៅរៀបរៀលតែនឹងវត្ត ក៏មែនជាដើរពីកុំស្រួចមកស្ថានកំពង់ទួលធ្វើអ្វី? ហេតុម្តេច អាមួយទៀតជាតូកនក៏មិនដឹងជាតិផង ឬមួយអានេះមកពីបរទេសឬ មកពីភពដទៃក្រៅពីភពមនុស្ស? បើមកពីភពដទៃឬបរទេស ហេតុអ្វីក៏មិនចាប់កំណើតក្នុងមៅ?

(នៅមានត)

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៉ូ-ប៉ុ រៀបរៀង

(ភាគ)

---

៣ – អបភវិយវេទនីយកម្ម

ឯកិំ អត្ថវេ បន បញ្ចមជវនចេតនា អបភវិ-យវេទនីយកម្មំ នាម តំ អនាគតេ យតា ឱកាសំ លភតិ តតា វិបាកំ ទេតិ ។

លំដាប់នេះ សូមសិទ្ធន្តាកង្ខ័កម្មបច្ច័យ អធិប្បាយនូវអបភវិយ-វេទនីយកម្មជាអនុសន្ធិតទៅ ដំណើរសេចក្តីថា យំ កម្មំ កម្មឯណា ដែលបុគ្គលធ្វើហើយ ចាន់សោយផលក្នុងកាលខាងមុខ ។ មិនកំណត់ កាលដែលនឹងឲ្យផលក្នុងជាតិនោះ ។ ក្នុងភពនោះ ។ ទេ ចាន់នឹងចេតនា ដ៏ស្ទុះទៅជាតំបូង្គាំ (បញ្ចមជវនចេតនា) ក្នុងកណ្តាលនៃជវនចេតនា ទាំងពីរ កម្មនោះឈ្មោះថា អបភវិយវេទនីយកម្ម ។

តំ យតា លភតិ ឱកាសំ ឯអបភវិយវេទនីយកម្ម នោះ ឲ្យផលក្នុងភពខាងមុខ ។ ក្នុងជាតិខាងមុខ ។ បើចាន់នូវឧកាសក្នុង កាលណា ក៏ឲ្យផលក្នុងកាលនោះ បើចាន់នូវឱកាសក្នុងភពណា ក្នុង

ជាតិណា កំឲ្យផលក្នុងភពនោះ ក្នុងជាតិនោះ កាលបើសង្ឃវង្គវដ្តនៅមិនទាន់ជាច់អស់ទេ កម្មនេះមិនទៅជាអហោសិកម្មឡើយ ប្រៀបដូចជាសត្វសុនខដែលនាយព្រានពន្លែងឲ្យទៅទាំអម្រឹគនៅក្នុងដងព្រៃធំ ។ សេចក្តីពិតថា នាយព្រានចូលទៅក្នុងព្រៃធំបណ្តើរពន្លែទៅផង កាលឃើញម្រឹគនៅទីណា ក៏ពន្យុះពន្លែឲ្យដេញទាំម្រឹគនៅទីនោះ ។ តំពន្លិគ្គា ពន្លែនោះកំចុលដេញតាមម្រឹគជាប់ប្រកិតពីក្រោយទៅ បើវាដេញទាន់ម្រឹគក្នុងទីណា វាក៏ទាំម្រឹគក្នុងទីនោះភ្លាម ។ សេចក្តីនេះមានឧបមាដូចម្តេច ឯអហោសិកម្មវេទនីយកម្មក៏មានឧបមេយ្យដូច្នោះ គឺថាបើបានឱកាសក្នុងជាតិណា ក៏ឲ្យផលក្នុងជាតិនោះ ។

អហោសិកម្មវេទនីយកម្មនេះ ចំណែកខាងកុសលក៏មាន ខាងអកុសលក៏មាន ។ ខាងកុសល បើអកុសលកំពុងតែឲ្យផល អកុសលនៅមានកម្លាំង កុសលកម្មក៏មិនអាចឲ្យផលបានឡើយ ។ ខាងអកុសលកម្មវិញ បើកុសលកំពុងតែឲ្យផល កុសលនៅមានកម្លាំង អកុសលកម្មក៏មិនអាចឲ្យផលបានឡើយ ។

តេន មុត្តសត្តោ ជាម ឈ្មោះថាសត្វដែលបានធ្វើអកុសលកម្មចូមកហើយ មិនដែលផុតចាកអហោសិកម្មនោះឡើយ ដូចជាជដិលសេដ្ឋីបានធ្វើកុសលកម្មផ្សេង ។ ជាច្រើន ប៉ុន្តែកាលកុសលកម្មកំពុងតែឲ្យផល អកុសលក៏មិនអាចឲ្យផលបាន លុះផល់ជាតិជាទី

បំផុត ខ្ញុំឯងបានសម្រេចព្រះអរហត្តភូមិជាតិនោះ ទើបអកុសលកម្មតាមទាន់អកុសលកម្មនោះក៏ឲ្យផល មានសេចក្តីសង្ខេបក្នុងរឿងដដែលសេដ្ឋីនោះ ៧ ៖

ដដែលសេដ្ឋី កាលបច្ចុប្បន្នជាតិគឺជាតិជាទីបំផុត មកកើតជាបុត្រនៃស្រីពេស្យា ព្រោះហេតុអកុសលកម្មដែលខ្លួនបានធ្វើទុកអំពីកាលមុន ។ ធម្មតាស្រីពេស្យា បើមានកូនប្រុស តែងឲ្យគេយកទៅចោះចាល មិនទុកចិញ្ចឹមរក្សាទេ ទុកចិញ្ចឹមរក្សាតែកូនស្រី ព្រោះគិតថាកូនស្រីនឹងបានតវ៉ាប្រកៃលើទៅទៀត ឯកូនប្រុស មិនបានតវ៉ាទៅមុខទេ ។

ស្រីពេស្យា កាលសម្រាលព្រះដដែលនោះ ទើបប្រើឲ្យទាសីជាក់កូនឆ្នាំង យកទៅបណ្តែតចោលក្នុងមហានទី នេះចាត់ជាកម្មឈ្មោះថាអបាយវិយវេទនីយកម្មបច្ច័យខាងអកុសល ព្រោះអកុសលកម្មនោះតាមទាន់ឲ្យផលក្នុងបច្ចុប្បន្នជាតិ ។ ឯកម្មជាអកុសលឲ្យផលយ៉ាងនេះ មានមនុស្សជាច្រើននាក់ទៀត ។

ដូចអគ្គសម្ពោធព្រះបរមទសពលសម្មាសម្ពុទ្ធនៃយើង កាលព្រះអគ្គសោយព្រះជាតិ ជាបរមនោធិសត្វទ្រង់ទាមប្បញ្ញាត្តិថាមហាជនក សំពៅបែកខ្ទាយលិចលង់ក្នុងមហានទី ត្រូវបែលធ្លុងវារដល់ច្រាំតិរវៃថ្ម ។

កាលព្រះអគ្គសោយព្រះជាតិជាសុវណ្ណសាមតាបស ត្រូវសរវៃនស្តេចកបិលយក្ស កំពប់ចូលក្នុងអបាយវិយវេទនីយកម្មខាងអកុសល

ព្រោះហេតុថា កាលព្រះអង្គជាបរមពោធិសត្វ បួសជាតិក្តី ដេរចីវរឥត
រែកូនសោះ ចុងម្ជុលទៅចាក់ត្រូវចៃដែលពួនសម្ងំនៅក្នុងចីវរនោះ ។

សូម្បីព្រះអង្គបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធហើយក្តី អកុ-
សលកម្មជាអបរាបរិយវេទនីយ កំនៅតែតាមឲ្យផលដល់ព្រះអង្គទៀត គឺ
ក្នុងគ្រាដែលព្រះអង្គគង់នៅក្រុងសាវត្ថិ ទ្រង់ព្រះនាមវិសាខា ។ សាធ្លាយឲ្យ
ជាតុទ្ធធិកស គ្រានោះ ព្រះអង្គអស់ព្រះកាយពល ដោយអំណាចអកុ-
សលកម្មដែលព្រះអង្គបានធ្វើពីជាតិមុន ប៉ុន្តែក្នុងជាតិនោះមិនបានឲ្យផល
ក្នុងជាតិជាលំដាប់មកទៀត កំមិនបានឲ្យផល រហូតដល់ព្រះអង្គបាន
សម្រេចព្រះអនុត្តរសម្មាសម្ពោធិញ្ញាណជិតចូលកាន់ព្រះនិព្វាន កម្មនោះ
ទើបឲ្យផល ដូចមានសេចក្តីសង្ខេបថា ៖

ក្នុងអតីតកាល ព្រះអង្គសោយព្រះជាតិជាអ្នកចម្បាប់ មានព្រះ
សរីរកាយតូចតិចតឿ ប្រកបដោយកម្លាំងច្រើន ។ គ្រានោះ មានអ្នកចំបាប់
ម្នាក់ទៀត មានកម្លាំងច្រើនដែរ អ្នកចម្បាប់តាំងពីឆ្ងាយមិនអាចលេង
ចម្បាប់ឲ្យឈ្នះអ្នកចម្បាប់ម្នាក់នេះឡើយ ។ អ្នកចម្បាប់នោះ ដើរសួរ
លេងចម្បាប់រៀងមកតាមលំដាប់ គ្មានអ្នកណាលេងឈ្នះសោះ ។ លុះ
មកដល់សំណាក់ព្រះបរមពោធិសត្វ អ្នកចម្បាប់នោះនិយាយនឹងព្រះបរម
ពោធិសត្វថា ម្នាល ម្នាលអ្នកចម្បាប់តូចតិចតឿ អ្នកចូរមកលេងចម្បាប់
ជាមួយនឹងយើង ។ ព្រះពោធិសត្វឮសំដីអ្នកចម្បាប់ហៅដូច្នោះ ទើប

ចុះភ័លើនូវមកចាប់ចោកប្រហារនូវអ្នកចម្បាប់នោះ ឲ្យដល់នូវបពជ័យដួលចុះក្នុងទីខែនោះ ។ ព្រះអង្គប្រកបដោយសេចក្តីករុណា បរិមជ្ឈិត្តា ប្រចាំចំដៃប្រចាំចំដើង រឹតនូវអ្នកចម្បាប់នោះឲ្យចាត់ចុតចាប់ ហើយឲ្យដួតខ្លឹកដុសលាងខ្លួន ឲ្យបរិភោគភោជនាហារឆ្អែត ហើយឲ្យដើរចេញទៅ ។ ហេតុនៃអកុសលកម្មដែលព្រះអង្គបានធ្វើពុកមកតាំងតាមុនយ៉ាងនេះ បានជានៅត្រាដែលព្រះអង្គសម្រេចបរមាភិសេកជាព្រះពុទ្ធហើយ ទើបឲ្យផលបណ្តាលឲ្យព្រះអង្គអស់ព្រះកាយពល ក្នុងសេលដែលទ្រង់គន់គន់នៅក្នុងប្រាសាទនៃនាងវិសាខា ។

សូម្បីសម្តេចព្រះបរមសាស្តា នៅតែសោយផលនៃអបរាបរិវេទនីយកម្មជាអកុសល ទីឯហ៊ាប់ស្រដីទៅថ្វីដល់ពួកបេជាបុថុជ្ជន ដែលថាមិនសោយផលនៃអបរាបរិវេទនីយកម្មជាអកុសលនោះ ។ សូមលើកអតីតនិទានខ្លះនៃបុគ្គលដែលបានសោយផល អបរាបរិយវេទនីយកម្មខាងអកុសលមកសំដែងជាឧទាហរណ៍ ដូចតទៅនេះ ៖

សត្ត កិរ កិត្តូ មានដំណាលថា កិត្តូតាំងឡាយមានប្រមាណប្រាំពីរបួនដុំរំសៅទៅជាមួយពួកពាណិជ ដោយបំណងថានឹងទៅគាល់សម្តេចព្រះសម្មាសម្ពុទ្ធ ។ លុះសំពៅបើកទៅដល់កំពង់ កិត្តូតាំងប្រាំពីរបួនោះនាំគ្នាឡើងពីសំពៅទៅមន្តទៅតាមមាគ៌ា ដល់វេលាល្ងាចព្រលប់នាំគ្នាចូលទៅឈប់កន្លែងអាស្រមមួយទៅរកកិត្តូជាម្ចាស់អាស្រមសួរទៅសំណាក់ ។

កិក្ខុជាម្ចាស់អាវាសនោះ ច្រាប់ឲ្យកិក្ខុតាំងច្រាំពីរបូ ទៅសឹងកន្លងគោហា មួយមានត្រែច្រាំពីរ ។ កិក្ខុតាំងច្រាំពីរបូសឹងលើត្រែមួយ ។ មួយរូប ។ ។ កន្លងរាត្រីនោះ មានចង្កួយផ្លាំងរមៀលមកខ្ទប់ទ្វារគោហាជាប់ ។ លុះដល់ព្រឹកឡើង កិក្ខុតាំងច្រាំពីរបូចេញពីគោហាមិនរួច នាំគ្នាច្រានដុំថ្ម ក៏ច្រានមិនកម្រើកសោះ ។

នេកាសិនោបិ ឯកិក្ខុជាម្ចាស់អាវាសនោះគិតថា អាត្មាឲ្យកិក្ខុច្រាំពីរបូទៅសឹងក្នុងគោហា ដល់ពេលយប់ មានចង្កួយដុំរមៀលមកខ្ទប់ទ្វារគោហាជាប់ កិក្ខុតាំងនោះចេញមកមិនរួចដូច្នេះ អកុសលកម្មមុនជានឹងមានដល់អាត្មាមិនខានឡើយ កិក្ខុម្ចាស់អាវាសគិតខ្លាចយ៉ាងនេះហើយ ក៏នាំកិក្ខុតាំងឡាយទៅជួយប្រមៀលដុំថ្មចេញពីទ្វារ ។ ដុំថ្មនោះគ្មានកម្រើកបន្តិចសោះ ។ លោកគ្រូមេវត្តក៏តែតែកំយុំៗ ទើបវាយគង ប្រកាសច្រាប់អ្នកស្រុកកូមិទៅជិតវត្ត ឲ្យនាំគ្នាមកជួយច្រានដុំថ្ម ។ អ្នកស្រុកឆ្លើយតបទទួលមកជួយច្រានដុំថ្មជាមួយនឹងកិក្ខុតាំងឡាយ ទំប្រឹងគាស់កកាយរុញច្រានអស់ទំហឹង ។ ដុំថ្មនៅនឹងប្លែលដែល ឥតរង្គើរចិតចេញពីទីកន្លែងដើមបន្តិចបន្តួចសោះឡើយ ។

អន្តោ បវិដ្ឋាបិ សូម្បីកិក្ខុតាំងច្រាំពីរបូដែលចូលទៅទៅសឹងក្នុងគោហា ក៏នាំគ្នាជួយរុញច្រានថ្មពីខាងក្នុងដែរ ប៉ុន្តែដុំថ្មឥតកម្រើកសោះ។ កិក្ខុតាំងច្រាំពីរបូនោះ សោយផលនៃអកុសលកម្មជាអបាកចរិយវេទនីយ៍ អត់អាហារហូតដល់ច្រាំពីរថ្ងៃ ។ ក្នុងរាត្រីជាគំរប់ច្រាំពីរ ផ្លាំងសិលា

នោះគ្មានអ្នកណាក្រៅប្រាថ្នាសោះ ស្រាប់តែរមៀលចេញពីទ្វារគោហាលឯង ទៅស្ថិតនៅខ័ណ្ឌដើមវិញ ។ ចំណែកតំកូតាំងប្រាំពីរបួននោះនាំគ្នាចេញពីគោហាបួចមក ទើបនាំគ្នាទៅគាល់សម្តេចព្រះបរមសាស្តាចារ្យ លុះដល់ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន រួចអង្គុយក្នុងទីដ៏សមគួរមៀងខ្លួន ។ សម្តេចព្រះទេសនាលមានព្រះភ្នុដ៏ការគ្រាស់បដិសណ្ឋារៈ ។ តំកូតាំងឮថ្វាយបង្គំក្រាបទូលប្រត្តិះហេតុតាំងពីដើមមក ហើយទូលសួរនូវប្បុត្តកម្មនៃខ្លួន ដែលធ្លាំងសិលារមៀលមកខ្ទប់ទ្វារគោហាលិតជាប់ចេញមិនរួច អត់អាហារហូតដល់ប្រាំពីរថ្ងៃ ។

អថ តតក តង្គលំដាប់នោះ សម្តេចព្រះមានព្រះភាគទ្រង់គ្រាស់ព្យាករថា ឃុត្វេ អត្តជា តតតកម្មំ អ្នកឯងគ្នាបានសោយផលនៃអកុសលកម្មដែលខ្លួនបានធ្វើខុកមកអំពីជាតិមុន ព្រះអង្គគ្រាស់ប៉ុណ្ណោះហើយ ក៏ទ្រង់តង់ទៅស្ងៀម ។ តំកូតាំងនោះក្រាបទូលអាកង្ខា ។ ព្រះភគវាទើបទ្រង់នាំនូវរឿងព័ត៌ភង្គអតីតកាលមកប្រទានព្រះសទ្ធម្មទេសនាថា ៖

អតីតេ សត្តេ តោទាលតភាវកោ តុង្គអតីតកាលមានតាវកគង្វាលគោប្រមាណប្រាំពីរនាក់ជាសម្លាញ់ខ្ពង្គ ។ តាវកទាំង ๗ នាក់នោះ តៀងគោទៅឲ្យស៊ីស្មៅទៅទីមួយកន្លែង ๗ ថ្ងៃ មិនទៅទីណាទៀតទេ ។ ឯកទិវសំ វិធាវេត្តោ ថ្ងៃមួយ តាវកទាំង

៧ នាក់នោះគៀងគាវៅឲ្យស៊ីស្មៅនៅកន្លែងដដែលបាន ៦ ថ្ងៃហើយ ក្នុងថ្ងៃជាគំរប់ ៧ បានឃើញខន្សែមួយធំ ទើបបបួលគ្នាដេញតាមចាប់ខន្សែ ប៉ុន្តែចាប់មិនបាន ។ ខន្សែនោះ ភ្លាមគេចចូលរូងក្នុងដំបូកមួយភ្លាមមុខសម្ងំបាត់ទៅ ។ ក្មេងតង្វាលគោទាំង ៧ នាក់និយាយគ្នាថា ពេលនេះព្រលប់ជិតយប់ហើយ យើងនឹងចាប់ខន្សែមិនបានទេ ចាំដល់ព្រឹកស្អែកយើងនឹងមកចាប់វាទៀត ថាហើយគាចំមែកឈើម្នាក់មួយមែក យកមកចុកចំរូងម្នាក់មួយរូងគ្រប់ទាំង ៧ រូង ដើម្បីកុំឲ្យខន្សែចេញទៅណារួច លុះចុករូងជិតជាប់ហើយ នាំគ្នាដេញគោទៅផ្ទះវិញ ។ លុះដល់វេលាព្រឹកស្អែកឡើង ក្មេងទាំងនោះក្រោកឡើងដល់ខន្សែដែលខ្លួនចុកពុកកន្លងដំបូក នាំគ្នាដេញគោទៅឲ្យស៊ីស្មៅនៅទីកន្លែងដដែរទៀតរហូតដល់ប្រាំពីរថ្ងៃ ។ ឯខន្សែនោះតត់អាហារ ៧ ថ្ងៃ ព្រោះនៅតែក្នុងរូងចេញទៅរកស៊ីណាមិនរួច ។ ចំណែកក្មេងតង្វាលគោទាំង ៧ នាក់ លុះកន្លង ៧ ថ្ងៃទៅហើយ ដល់ថ្ងៃជាគំរប់ ៨ នាំគ្នាគៀងគាទៅឲ្យស៊ីស្មៅនៅទីកន្លែងពីមុននោះក៏បានឃើញដំបូក ទើបនឹករលឹកឃើញថា ពួកយើងចុករូងខន្សែ ១ កយូរថ្ងៃហើយ តើខន្សែនោះជាយ៉ាងណាទៅ ហ្ន៎រួចនាំគ្នាទៅដកមែកឈើចេញពីរូងដែលខ្លួនបានបុកគ្រប់គ្នា ។

(នៅមានត)

អាថ៌កំបាំងរបស់ពុទ្ធសាសនា (១)

លោក ប៊ូ-ប៊ូ រៀបរៀង

ព្រះពុទ្ធសាសនាដែលមានអាយុរស់ទៅបាន ២ ៥០០ ឆ្នាំហើយ មិនមែនសុទ្ធតែចំរើនរុងរឿង ឬ សុទ្ធតែអាប់ឧនគ្រប់សម័យទេ ។ មានសម័យខ្លះរុងរឿង មានសម័យខ្លះអាប់ឧន តែងប្រែប្រួលទៅតាមព្រឹត្តិការណ៍របស់ប្រទេស ដែលបានសុខសាន្តគ្រាណា ឬ ដែលកើតសឹកសង្គ្រាម ។ សូមស្រង់យកសម័យខ្លះមកបញ្ជាក់ក្នុងទីនេះ ដោយសំអាងទៅលើពុទ្ធសកពជ ទំព័រខ្ចីសកពជដូចតទៅនេះ ៖

– ទី ១ មុនគ.ស ៥៨៣ ឆ្នាំ មានព្រះសង្គហបវេតិយ៍ក្នុងពុទ្ធសាសនា ៨ តន្លែង ក្នុងមជ្ឈិមប្រទេស (ឥណ្ឌា) ជាដំបូង ។

ព្រះសង្ឃបរិស័ទ នៅកាន់លទ្ធិសាសនា តាមបែបជាមួយគ្នា ។

– ព.ស. ១០០ ឆ្នាំ មុនគ ស. ៤៤៣ ឆ្នាំ ព្រះសង្ឃក្នុងឥណ្ឌាបែកគ្នាជា ២ ពួក គឺពួកដើម ទំព័រពួកវជ្ជបុត្រ ។

– ព.ស. ២០៥ ឆ្នាំ មុនគ ស. ៣៣៨ ឆ្នាំ ពួកតិរ្ថីយ៍ចូលឈ្លួមបួសក្នុងព្រះពុទ្ធសាសនាជាច្រើន ព្រះសង្ឃបែកគ្នាយ៉ាងធំ ។

១– ស្រង់ពីច្បាប់ ដំណាលភាវៈចេតិយ៍ លេខ ៥, ១០ របស់បណ្ណាល័យ នៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

- ព.ស. ២២១ ឆ្នាំ មុនគ.ស. ៣២២ ឆ្នាំ ព្រះបាទធម្មាសោកពាជ ទ្រង់តំពាត់ពួកបួសឲ្យមកចេញ ហើយទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាឲ្យភ្លើងរុងរឿងរៃលែងជាងគ្រាណាៗទាំងអស់ ។

- ព.ស. ២៣៣ ឆ្នាំ មុនគ.ស. ៣២០ ឆ្នាំ ក្នុងរជ្ជកាលព្រះបាទធម្មាសោកពាជ កើតមានព្រះស្តេចតេឝ៍យ ដែលសាងដោយឥដ្ឋ ខឹងឋ្ងាច្រើន (ឥណ្ឌៀកណ្តាល) ។

- ព.ស. ២៣៦ ឆ្នាំ មុនគ.ស.៣០៧ ឆ្នាំ ក្នុងរជ្ជកាលព្រះបាទធម្មាសោកពាជ ព្រះពុទ្ធសាសនា ផ្សាយចេញពីប្រទេសឥណ្ឌៀចូល ទៅក្នុងប្រទេសនានា ។

- ព.ស. ២៣៨ ឆ្នាំ មុនគ ស ៣០៥ ឆ្នាំ ក្នុងរជ្ជកាលព្រះបាទទេវ៉ានម្ប៉ាយតិស្សៈ ព្រះពុទ្ធសាសនា លុទ្ធិហ៊ានយាន ទៅប្រតិស្ឋាននៅលង្កាទ្វីប ហើយចំរើនរុងរឿងអស់កាលជាយូរអង្វែង ។

- ព.ស. ៤០០ ឆ្នាំ មុនគ.ស ១៤៣ ឆ្នាំ ក្នុងរជ្ជកាលព្រះបាទអាឡែកសង់ដ្រ ព្រះពុទ្ធសាសនា ទៅចំរើនរុងរឿង នៅប្រទេសគន្ធារ ហើយកើតមានព្រះពុទ្ធរូបឡើងជាដំបូងក្នុងលោក (ឥណ្ឌៀលើ) ។

- ព.ស. ៥០០ ឆ្នាំ មុនគ ស. ៤៣ ឆ្នាំ ក្នុងសម័យនេះ ព្រះពុទ្ធសាសនាលុទ្ធិហ៊ានយាន មកប្រតិស្ឋាននៅនគរភ្នាកវតី ហើយចំរើនរុងរឿងអស់កាលជាយូរអង្វែង ។

ក្នុងសម័យនេះ កើតមានបែបពុទ្ធបេតិយ៍នៅខេត្តកាវតិ (សារ អំពីដើម) ។

- ព.ស.៦២០ឆ្នាំ គ.ស. ៧៧ឆ្នាំ ក្នុងរជ្ជកាលព្រះបាទកនិស្កមហាកជ កើតមានព្រះពុទ្ធរូបធ្វើពីថ្ម ផ្សាយទូទៅក្នុងប្រទេសឥណ្ឌាជាច្រើន ។

ក្នុងសម័យនេះ កើតមានរូបព្រះអាទិពុទ្ធ រូបព្រះធ្យានិពុទ្ធ ខ្ចីងរូបព្រះពោធិសត្វ ក្នុងលទ្ធិមហាយាន (ឥណ្ឌា) ខ្ចីងកើតមានព្រះប្រាជ្ញាណ៍ ក្នុងពុទ្ធសាសនាម្ចាស់ខ្ចីងខ្មែរ (ឥណ្ឌា) ។

សម័យនេះ លទ្ធិអាចរិយវាទ (មហាយាន) ទៅចំរើនរុងរឿង នៅប្រទេសគន្ធារ ។

- ព.ស. ៩០០ ឆ្នាំ គ ស ៣៥៧ ឆ្នាំ ក្នុងរជ្ជកាលព្រះបាទចន្ទ្រគុប្ត កើតមានព្រះពុទ្ធរូបនៅនគរមេគធៈ (ឥណ្ឌាកណ្តាល)

តាំងពីត្រឹមសម័យនេះមក ព្រះពុទ្ធសាសនា ក្នុងប្រទេសឥណ្ឌារឿរាកយចុះរហូតដល់សព្វថ្ងៃនេះ ។

- ព.ស. ១ ១០០ឆ្នាំ គ.ស ៥៥៧ ឆ្នាំ កើតមានពុទ្ធបេតិយ៍បែបលទ្ធិមហាយាន នៅនគរស្រីវិជ័យ (ជ្វា) ។

- ព.ស.១.៦០០ ឆ្នាំ គ.ស. ១៥៧ ឆ្នាំ សៀមទំនងខ្មែរកាន់លទ្ធិមហាយាន (យ៉ាងសម័យលពុរី) ហើយចំរើនរុងរឿងរហូតមក ។

(នៅមានត)

(តមក)

ទស្ស នោះប្រឹមច្រើយ មានស្មើល្អដូចផ្ទៃដៃមាសថាស់ពុំញញឹមប្រឹមប្រើយ
ស្រដីមុខតួស្រឡាញ់ មានថ្ពាល់នោះពេញផូរផង់ មានវង់ព្រះខេត្រ
សោតដូចកែកព្រាប កបខ្លួចក្នុប្រសាទដ៏ខ្ពៅយង់ល្អល្អះជ្រះយល់ឆ្ងាយ
ពណ្ណាយពេក ។ សោភនកុមារា ។ មហារាជអើយ ព្រះនាងនន្ទា
ទេវី មានព្រះកូមោនោះកោងទ្រខេសទ្រខួយដូចចន្ទ្រយកៅខណ្ឌ ។ ន៏
ឃសុត្តា តេសា អសិតា មហារាជអើយ ព្រះនាងមានព្រះ
កេសាខោះឆ្មារវែងអន្លាយរំសាយសព្វាកបត្រាបលើព្រះបិដ្ឋ មានស្មើខ្មៅ
ញាប់ដូចស្លាបកន្ធង់ ។ ន្ឋិសភក្កបវេល្លិតា មានចុងខោះង
ឆ្កែឆ្លួយទ្រខួយឡើងដូចចុងក្រឹស មហារាជអើយ នាងមានដំណើរល្អ ។
កុដ្ឋក្កលដ្ឋីវ បើដូចលំពង់ចុងត្រួយតោធ៏ល្អតលាស់ខ្លឹ តឹងល្អប់
លំពែនទៅ មហារាជអើយ នាងនន្ទាទេវីអគ្គមហេសី ថាបើន៏ងមិល
ទៅម្តង មិកឆ្ងាបិវ ដូចកូនម្រឹតទៅហានមួយជាប្រក្រតី កំល្អសម
សព្វព្រះរាជហឫទ័យណាស់ហោង មហារាជអើយ នានាងនន្ទាសម្តេច
ព្រះអគ្គមហេសី ព្រះអង្គទ្រង់នូវរូបល្អដូច្នោះ ។

ន៏តោ ន៏តា មហារាជ បពិត្រមហារាជអើយ ខ្ញុំឲ្យដំ-
ណើរមហាសុត្រតាង ៤ ព្រះអង្គនឹងព្រះបាទវិទេហរាជអម្ចាស់ខ្ញុំ សមដល់

មិចិលានតរោយ ឥយបម្បិលមិញ្ជរហ៊ីយ ព្រះអង្គគិតជានាងគង់នៅនា
អាយទេហ៊ីះ ។

ឯវំ មហាសត្តេ តសញ្ញ រូបសិរី វណ្ណោឆ្ពេយ្យោ
សោ តេន បុព្ពេ អនិដ្ឋបុព្ពោ វិយ អហោសិ ។

ព្រះមហាសត្វអ្នកប្រាជ្ញ អាចសរសើរនូវលំអសិរីសួស្តីនៃព្រះនាងនន្ទា
ទេវីដោយនូវព្រះប្រាជ្ញាចិត្តពិសេសដូច្នោះហើយ ព្រះបាទបុប្ផវតីមហា
ក្សត្រសព្វព្រះរាជហឫទ័យក្រៃ ទៅនឹងលំអនាងនន្ទាប្រាកដ មិនយល់ជា
នាងទៅលំទៅមួយជាព្រះអគ្គមហេសី សព្វថ្ងៃប្រក្រតិ អំពីមុនរៀងមក
ឡើយហាក់ដូចមហាក្សត្រទើបមកបានយល់នាងតែម្តងនោះ ព្រះមហា
ក្សត្រសោកស្តាយនាងមហាមាតេក ស្រេចនឹងទាំងព្រះកន្ត្រក់ទាំងសង្វារ
ពីព្រះហស្តជាម្តង ។ កាលនោះ ព្រះមហាសត្វអ្នកជ្រាបសភាពជាមហា-
ក្សត្រសោកអាល័យព្រះអង្គនាងណាស់ហើយ អ្នកតែងតួលចំអន់ព្រះហឫ
ទ័យមួយសារៅ ដោយនូវបទគាថាដូច្នេះ:

ឧដ្ឋា ន្ទន មរណេន ឧន្ទសិ សិរីតាមន
អមាញ្ញ ន្ទន ឧដ្ឋា ច កច្ចាមិ យមសាទនន្តិ ។

បពិត្រមហាក្សត្រដ៏ចម្រើន នូវកម្ចាត់ចម្រើនដោយសិរីកំពូលអស់មហា
ក្សត្រទាំង ១០១ ហើយព្រះអង្គមានព្រះអំណារអានឹងចង់ឲ្យ
នាងនន្ទាទេវីស្រីត្រឹមតែក្តីស្រណុកព្រះជន្មាប្រាសពីព្រះអង្គប៉ុណ្ណោះ ព្រះអង្គចង់

សម្លាប់ខ្ញុំនេះឬ មហាកដ បើព្រះអង្គសម្លាប់ខ្ញុំហើយ សមព្រះបាទវិរៈទេហ-
កដអម្ចាស់ខ្ញុំ ព្រះអង្គអត់អ្វីដល់អង្គាល់ឡើយ ព្រះអង្គនឹងសម្លាបនាងនេះ
ទេតើថ្លាកដក្លាត់ កុំបីព្រះអង្គសន្ធុះឡើយ បពិត្រមហាកដ នាងនេះ
ក្សត្រីស្រីត្នៃថ្លៃក្សត្រិយព្រះជន្ម បពិតែខ្ញុំសោតស្លាប់អសារ ថាគេសព៌ាងនេះ
នូវ ជាពៀរទៅមុខ កំយើងចាំងពីរនឹងបណ្តើរគ្នាទៅកាន់ព្រះយមកដ
ព្រមល្មមជាមួយនឹងគ្នា ព្រះយមកដនឹងដណ្តឹងមកយើងចាំងពីរថាស្រីនឹង
ប្រុសខុសកលអ្វីក៏ស្លាប់ដូច្នេះអេះ ម្ល៉ោះហើយខ្ញុំឆ្លើយថា អញខ្ញុំអត់ឮ
ស្លាប់ ដ្បិតតែនាងនេះក្សត្រីស្រីត្នៃប្រសើរដំណើរដូច្នេះ ហើយនាងនេះ
សោត ឆ្លើយថា ខ្ញុំនេះស្លាប់ ដ្បិតតែចៅមហាសថប្រសប់ណាប់នេះឯង
ព្រះអង្គ ទើបព្រះយមកដដណ្តឹងមកខ្ញុំទៀតថា ប្រុសនោះតើឈ្មោះអ្វីហ៊ុះ,
ខ្ញុំថ្លាប់ថា ឈ្មោះចៅមហាសថអម្ចាស់ អើ! ចុះស្រីនោះតើឈ្មោះអ្វី
សោតហ៊ុះ ទើបនាងឆ្លើយថា ខ្ញុំឈ្មោះនាងនេះ ព្រះអង្គ ព្រះយមកដ
នឹងបង្គាប់យើងចាំងពីរថា អង្គាល់បើនាងនេះស្លាប់ព្រោះតែមហាសថ
មហាសថនេះស្លាប់ ដ្បិតតែនាងនេះ ម្ល៉ោះហើយលោកឲ្យខ្ញុំនឹងនាងនេះ
ឲ្យយកគ្នាជាប្តីប្រពន្ធ ព្រះអង្គសម្លាប់ខ្ញុំឲ្យធាប់ទៅនឹងបានទៅទៅជាប្តី
ក្សត្រីស្រីត្នៃប្រសើរ តិតម្តង់ទៅហាក់នឹងចង់រស់ បើនឹងតិតឲ្យសព្វគ្រប់
ទៅ បើនឹងស្លាប់ក៏ហាក់មានតិត្ថវែរហ៊ុះ បពិនឹងបាននាងនេះក្សត្រីស្រី
ប្រសើរជាប្រពន្ធទៅនាស្រុកខ្មែរនោះ មហាកដអើយ ឥឡូវនេះ ខ្ញុំ

ចន់ស្ដាប់ពាក្យហ៊ះ មហាកដ មកសម្លាប់ខ្ញុំឲ្យឆាប់ហ្ន៎ ខ្ញុំនឹងបានទាន់ខន្ធ
ជាប្រពន្ធខ្ញុំហោង ។

ឥតំ មហាសត្តោ ឯត្តកេ ឋានេ វណ្ណោសិ ឯ
ឥតរេ តយោ ឋានេ វណ្ណោសិ ។ ព្រះមហាសត្វ អ្នកសរ-
សើរលើអាទាន៍ខន្ធ នាឋានទោះ ដោយខ្លួវប្រកាអម្បាលនោះហោង មិន
សរសើរដន់ដៃបន្តាក់ណាឡើយ ។ ការណា ហេតុអ្វីព្រះមហា-
សត្វ អ្នកមិនសរសើរខ្លួវអ្នកដទៃ គឺទាន៍សលាកទេពី ចៅបញ្ចាលចន្ទ-
កុមារ នឹងទាន៍បញ្ចាលចន្ទ័នោះ វិសជ្ជនាន្លើយថា នាម៎ហៅសត្វទាំង
ឡាយ តែប្រាសលែងតែយោសំឡាញ់ហើយ តំនឹងត្រេកម្ដាយក្ដី កូនស្រី
កូនប្រុសក្ដី ពុំអាល័យឡើយ អាល័យត្រេកតែតយោសំឡាញ់នោះឯង
ហេតុនោះ ព្រះមហាសត្វសរសើរតែទាន៍ខន្ធទេពី មិនសរសើរព្រះពុទ
ម្ចាស ហេតុទាន៍មានព្រះអង្គទាន៍បំណាស់ហើយ ហេតុនោះហោង ទើប
ព្រះមហាសត្វប្រកបខ្លួវប្រាជ្ញាញាណ មានសម្ងេនោះមជ្ឈមូលផ្ដែមតាំងេ
ឆ្ពោះសរសើរខ្លួវលើអទាន៍ខន្ធទេពី ហាក់បីដូចទាន៍មកតដំបិតទាន៍
បរិស្ដាយចំពោះព្រះតន្ត្រៃនៃមហាសុត្រឯង ។ ព្រះមហាសុត្រ ភាលណា
យើញព្រះមហោសថខ្លួលសរសើរអំពីលំអទាន៍ខន្ធទេពី ហើយព្រះអង្គនឹង
ត្រេកស្រឡេងអាខ្លោះអាល័យសោកស្ដាយ ទុនសញ្ជប់ក្រាបស្រឡាយលើ

តថាដ៏វិសេសនោះ លំដាប់នោះ ស្តេចគគ៌តថា បើអញរៀវរែលដែនមហោសថ
ហើយ នាំបើហៅអ្នកជាខែនឹងអាចនាំមកនូវប្រពន្ធសំឡាញ់យកមកឲ្យ
អញនោះអង្គីមានឡើយ លំដាប់នោះ ព្រះមហោសថ អង្សាស្រ័យ
ឃើញព្រះរាជមហាក្សត្រសោកស្តាយខាងនន្ទាទេពីណាស់ហើយ អ្នកទូល
លោមស្តេចថា បពិត្រមហាកាជអើយ កុំបីព្រួយព្រះកាជហឫទ័យពេកឡើយ
ទោះព្រះកាជទេពីក្តី ព្រះកាជបុត្រាបុត្រីព្រះវរកាជមាតាក្តី ខ្ញុំនឹងឲ្យនាំក្សត្រ
ចាំងបីនោះវិលមកថ្វាយព្រះអង្គវិញមិនខានទេឡើយ បើខ្ញុំចាន់ទៅដល់ម៉ិថិ
លានគរនោះហើយ ខ្ញុំនឹងឲ្យដំណើរមហាក្សត្រចាំងបីព្រះអង្គ ឮដូចាល
ខ្ញុំទៅដល់នោះឯង ចូរអម្ចាស់ចាន់ដកដង្ហើមចេញចូលឆ្ងាសប្បាយហោង។

អថ ភដា ចិន្តេសិ លំដាប់នោះ នាអញឲ្យរក្សាព្យាបាលព្រះនត្តវអញនេះ ប្រយ័ត្នប្រយែងហើយនៃ ទើបលើកមកពាមមួយអន្លើ
ដោយទូវរៀតលសតលយោធាសេនាច្រើនមហិមា មកពាមស្ពាត់បិតហាននេះដុំវិញ ម្ល៉ោះសមព្រះមហោសថនេះ ឲ្យនាំបុត្រកំរើយអញឲ្យទៅ
ដៃព្រះចាតាវិទេហរាជនៅនាហានឯណាហ្ន៎ ឬមួយមហោសថនេះ មានមន្ត
អាយាតិញ្ញ តាត់បង្កើងក្នុង យ៉ាងនេះដឹងអើយ ព្រះអង្គទ្រង់ព្រះចិន្តានូវប្រ
ការអម្បាលនោះរៀម, ស្តេច ឆ្លើយទៅតាន់ព្រះមហោសថនោះ នូវ
បទគាថាជូនថ្វាយ:

ទិដ្ឋំ អធិយេសេ មាយំ អកាសិ ចក្ខុមោហនំ
យោ មេ អម្ចំ មាតុកំ វិនេហិ បរិមោចយិ តំ ។

ម្នាលបាមរហាសថអើយ បានន៎ះឱ្យនាំព្រះបាទវិទេហរាជដួចចេញ
ទៅតាក់ណាម់ដៃយើងជាសត្រូវនោះ តើដោយនូវហេតុម្តេច ឬមួយបាបានរៀនន្ទូវរបៀនមន្តមាយាទិព្វ មកបាំងបិទភ្នែកយើងឱ្យវង្វេងឬម្តេចហ្ន៎ ។

ព្រះមហាសថស្តាប់ព្រះបន្ទូលហើយទូលតបវិញថា មហារាជ បពិត្រមហារាជអើយ ខ្ញុំបានរៀនចេះន្ទូវរបៀនមន្តមាយាទិព្វនោះហោង បពិត្រមហារាជអើយ ប្រាជ្ញាអ្នកឯងតាំងឡាយណា តែបានរៀនយកន្ទូវមន្តមាយាទិព្វហើយ បើមានភ័យនឹងមកដល់នោះ អាចដោះអាត្មាឯងក្តី អ្នកដទៃក្តី រួចពីទុក្ខបានហោង បពិត្រមហារាជអើយ ឯអ្នកប្រាជ្ញផងតាំងឡាយនាលោកនេះ ពុំដែលវង្វេងភ្លាយដោយពាក្យអ្នកណាជាដៃឡើយ អ្នកដែលបានរៀនមន្តមាយាទិព្វនោះ ជាអ្នកមានចំណេះចេះន្ទូវរបៀនផ្សេង ៗ ផងច្រើន ក៏ដោះរួចអាត្មាអំពីទុក្ខនោះហោង បពិត្រមហារាជអើយ ព្រះបាទវិទេហរាជ ស្តេចទៅគាន់មិថិលានគរដោយន្ទូវផ្លូវទន្លេដ៏ប្រជាប់ គឺកូនអាមាត្យផងសឹងត្រាតតែក្តាត់ ខ្ញុំឱ្យប្រជាប់ទន្លេនោះឯងហោង ។

ឯព្រះបាទបុឡាទិ កាលណាបើឮថា ព្រះបាទវិទេហរាជទៅដោយន្ទូវទន្លេប្រជាប់ដូច្នេះ ស្តេចគិតថា តើ ដូចអញឮនោះហើយ ទន្លេប្រជាប់នោះ តើគេយល់ថាម្តេចអេះ អញចង់ដឹងបន្តិចហ៎ ។ លំដាប់នោះ ព្រះមហាសថ បានដឹងអធ្យាស្រ័យព្រះហឫទ័យនៃព្រះមហាក្សត្រនោះ

ហើយគិតថា ស្តេចនេះមានចំណង់ចង់ឃើញមន្តអញហើយហ្ន៎ បើដូច្នេះ
គួរអញចង្អុលមហាក្សត្រនេះហោង កាលណាបើព្រះពោធិសត្វគិត
ម្ល៉ះហើយ ក៏ពោលនូវបទព្រះគាថាដូច្នេះ:

ឥច្ឆ បស្ស មហារាជ ឥមញ្ចិំ សារុ មាបិតំ
ហត្ថិនំ អថ បស្សានំ រថានំ អថ បត្តិនំ
អលោកភូតំ តំជន្តិំ ឥមញ្ចិំ សារុ ឯឡិក្ខ ។

មហារាជ បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ ពោះយោមរ
អម្ចាស់មានព្រះចំណង់ខ្លឹងចង់ឃើញមន្ត តែអញខ្ញុំណាប់ប្រពៃសម្រេច
ស្រេចចិត្តនៅក្នុងរឿងល្អ ប្រដាប់នូវរូបភាពចាំងឡាយ គឺរូបដីរ សេះ
នៅរូបពាសវាយក្រាកដនៃពលថ្មើរជើង ព្រះមហាសត្វអ្នកថាអម្បាលនោះ
ហើយ អ្នកឲ្យបើកទ្វារ (ទ្វារគារ) ហើយអ្នកនូវមហាក្សត្រថា
ដូច្នេះ. បពិត្រមហារាជអើយ ព្រះអង្គមានហឫទ័យស្មោះសរមួយអន្ទឹងនឹង
ខ្ញុំហើយ ចូរអ្នកអម្ងាស់ឃើញតាមដើមលើមនូវមណ្ឌលព្រះចន្ទ ព្រះអាទិត្យ
បិតឮដំហានឯលើ ដោយនូវក្រាជ្ញានៃខ្ញុំប្រដាប់នូវទ្វារធំនោះ ៨០ សម្រាប់
នូវទ្វារតូចនោះ ៦៤ ឮដំមហាមន្តនោះ នៅលើងក្រឡាបន្ទំមួយរយមួយ
នៅលើងប្រទីបច្រើន រៃក្រលែងរយ ។ បពិត្រមហារាជអើយ ចូរអញ្ជើញ
ព្រះអង្គមកគាន់ទ្វារគារនៃខ្ញុំ មួយអន្ទឹងនូវបរិវារនៃព្រះអង្គហោង ។
កាលនោះស្តេចបុព្វនីព្រហ្មទត្តរាជចូលទៅមួយអន្ទឹងនឹងព្រះមហាក្សត្រ

១០១ ជាបរិវារ ។ ព្រះមហាសត្វជុះមកអំពីច្រាសាទហើយ ថ្វាយបង្គំព្រះមហាសត្វ អញ្ជើញស្តេចមួយអង្គ្ខែនូវបរិពារត្រកាលចូលទៅកាន់ទម្ពង្គ ។ កាលស្តេចចូលយល់ទម្ពង្គប្រដាប់ល្អដូចទេវសភាសាលានៃឥន្ទ្រ សួគ៌ក្រែ ស្តេចសរសើរគុណព្រះពោធិសត្វថាដូច្នេះ ។

លោកា វត ទិនេហាធំ យស្សដ្ឋមេ ឆវិសោ បណ្ឌិតា
ឃរេវសន្តិ ទីឃិតេ (រដ្ឋ) យថា ត្វមសិ មហោសធាតិ ។

មហោសធ ម្នាលមហោសធអើយ ចារនេះជាលាភប្រសើរមានទាវស្តេចវិទេហរាជផងតែហោង ។ អ្នកប្រាជ្ញតាចយល់មកច្រាតដូចទៅ មានទៅឮដីស្រុកស្តេចឯណា ហៅជាលាភប្រសើរមានទាស្រុកស្តេចនោះហោង ។

លំដាប់នោះ ព្រះមហាសត្វអ្នកបង្ហាញនូវលែងត្រឡាបខ្ញុំ ១០១ ថា បពិត្រមហាកដអើយ រ៉ាត្រា ថាបើនឹងបើកតែត្រាមួយ ក៏បើកអស់ត្រាតាំងពួននោះឯង ថាបើនឹងកំនែតែត្រាមួយ ក៏កំនែប្រអស់ត្រាតាំងពួននោះហោង ។ ស្តេចខត្តទម្ពង្គនោះហើយ ដើរទៅជាមុន ឯព្រះមហាសត្វអ្នកប្រាជ្ញដើរដោយក្រោយហោង អស់សេនាតាំងពួន សឹងចូលទៅក្នុងទម្ពង្គនោះហោង ។ បណ្ឌិតោ តសរ្ជ ឯកង្គំ ភាវញ្ញូ ។ ស្តេចចេញអំពីទម្ពង្គនោះទៅ ចៅមហោសធអ្នកប្រាជ្ញដឹងនូវសភាពជាស្តេចក៏ចេញរួចហើយ ខ្លួនព្រះមហាសត្វឯងក៏ចេញរួចហើយ អ្នកដ៏ទៃ

មិនអាចដើម្បីនឹងចេញបានឡើយ ទើបអ្នកជាន់គន្ធៈរខុកយន្តសង់ភាន
រាំងព្រះមន្ត្តីចាំង ៨០ ទូរព្រះមន្ត្តីតួច ៦៤ ក្តី ព្រះក្រឡាព្រះបង្គំទុត្តម
១០១ ក្តី ស្លែងតែងនឹងខុកប្រទីបច្រើនក្រៃលែងរយក្តី សឹងព្រមតែម្តង
មិនមុនក្រោយ ។ អស់សកលទ្រព្យមន្ត្តីចាំងពួងនោះ កងនឹតល្អបជួបលោ-
កន្តនរកហោង អស់មហាជនផងសឹងតែកតតក័យខ្លាចនោរមហិមា ។
បពិត្រអើយ កាលអំពីម្រលមិញនោះ អ្នកខុកទូរជាវហើយ អ្នកចូលទៅ
ក្នុងព្រះមន្ត្តី ទើបអ្នកយកជាវនោះគាន់ត្រីលោត អំពីកូមប្រថពីឡើង
ទៅកណ្តាលអាកាស មានកំពស់ ១៨ ហត្ថ ហើយមហាសត្វអ្នកផ្ទះចុះ
មកវិញ ត្រីជាវតំរាមបន្ទាចចាប់ព្រះហស្តស្តេចចុឡនី ដណ្តើងថាដូច្នេះ
បពិត្រមហាពរអើយ រីពរសម្បត្តិអស់ពាំងសកលជម្ពូទ្វីបនេះតើ ជាពរ
សម្បត្តិរបស់អ្នកឯណា ។ ស្តេចចុឡនីនោះក័យកតភ្ញាចអំណាច
មហាសត្វ ហើយឆ្លើយថា ម្នៃចៅមហាសថអ្នកប្រាជ្ញអើយ ពរសម្បត្តិ
នេះជារបស់ចៅនោះហោង ។ ម្នៃចៅអ្នកប្រាជ្ញអើយ ចូរចៅអភ័យ
ទោសអញ្ជើហោង ។ ព្រះមហាសថអ្នកប្រាជ្ញទូលថា បពិត្រមហាពរ
អើយ កុំបីព្រះអង្គភ្ញាច នាខ្ញុំស្ទាបមុខជាវនេះហេតុចង់សម្ងាប់ព្រះអង្គនោះ
ឥតអង្គឹមានឡើយ អញខ្ញុំស្ទាបមុខជាវនេះ ដើម្បីនឹងសំដែងនូវអានុភាព
ប្រាជ្ញានៃអញខ្ញុំកូវ ហើយអ្នកហុចជាវទៅគាន់ស្តេច ទើបមហាសត្វទូលថា
បពិត្រមហាពរអើយ នាព្រះអង្គព្យាយាមបង្កើតនូវចម្ងាំងពាំងម្ន៏ះ

ព្រះអង្គនឹងចង់សម្លាប់ខ្ញុំប្អូ ឥឡូវនេះ ចូរព្រះអង្គសម្លាប់ខ្ញុំទៅដោយដាវ
នេះចុះ ស្តេចបន្ទូលថា អញពុំសម្លាប់ចៅឡើយ ដ្បិតចៅមានគុណខ្លួន
ជាតែអញ កុំបីចៅបាត់ម្តេះឡើយ ។ អ្នកទាំងពីរនោះចាប់យកខ្លួនដាវហើយ
ធ្វើខ្លួនសំបថ ដោយភាពជាអ្នកមិនទ្រុស្តគ្នាទៅវិញទៅមក ។ អណ្តាប់
នោះ ស្តេចជណ្តើងទៅពោធិសត្វថា ម្នាលចៅអ្នកប្រាជ្ញអើយ! ចៅប្រ
កបខ្លួនកម្ទាំងប្រាជ្ញាប្ញទ្ធិអានុភាពច្រើន ហេតុអ្វីក៏ចៅមិនដណ្តើមយកពរជ
អញធ្វើជាស្តេចហ៊ុនៈ? ពោធិសត្វអ្នកទូលតបវិញថា បពិត្រមហាពរជអើយ
អញខ្ញុំពោះនឹងចង់យកពរជសម្បត្តិក្តី សម្លាប់ក្សត្រពាំងសកលជម្ពូទ្វីបនា
ថ្ងៃនេះក៏បានហោង ហើយថ្ងៃនឹងទៅសម្លាប់អ្នកដទៃ ដ្បិតប្រយោជន៍ចង់
បានយសសក្តិជាធំនោះហ៊ានៈ! មហាពរជអើយ អ្នកផងលោកពុំដែលសរ-
សើរឡើយ ។ លំដាប់នោះ ស្តេចបន្ទូលនឹងព្រះមហាសត្វថា ម្នាល
ចៅអ្នកប្រាជ្ញអើយ អស់មហាជនផង ពុំបានចេញមកបួច ទៅកន្លែងនោះ
សឹងតែខ្លួញយំបាម្តេះទៅ ចូរចៅអាសូរបើកទ្វារទម្លុងឲ្យពានផង ខ្ញុំ
នឹងមានដំរៃសង់នឹងអស់មហាជនផងតាំងពួងនោះហោង ។ ព្រះមហា
សត្វ អ្នកបើកទ្វារទម្លុងនោះ សឹងមានពន្ធឹតែមួយ អស់មហាជនផងក៏
បានដកដង្កើមចេញចូលឆ្ងរសប្បាយ ឯអស់ស្តេចផងតាំងពួងនោះ សឹង
តែចេញមកមួយអន្ទឹងនឹងសេនា ចូលទៅគាន់សំណាក់នៃព្រះមហាសត្វ
អ្នកប្រាជ្ញ ព្រះមហាសត្វនោះ បិតនៅឱសាលាសំណាក់មួយអន្ទឹងនឹង

ស្តេច លំដាប់នោះ មហោសថក្តុលស្តេចថា បពិត្រមហាកដអើយ អញ្ញុំ
ដឹកល់នាងបញ្ចាលចន្ទីលើផ្ទៃតត្ត នាហានេះឯង ខ្ញុំឲ្យដំណើរទៅហើយ
ខ្ញុំក្តុលព្រះបាទវិទេហរាជថា អម្ចាស់សង្ឃឹតមកនេះ ហេតុតែស្តេចចង់
បានតាងនេះឯង តាងនេះចូរបានជាអគ្គមហេសីនៃអង្គស់ហោង ។
លំដាប់នោះ អស់ស្តេចផងបន្តុលនឹងព្រះមហាសត្តថា ម្នាលចៅមហោសថ
អ្នកប្រាជ្ញអើយ រឿងតែយើងនេះ មានហេតុអាស្រ័យនឹងចៅនេះហោង
បើនៅបន្តិចទៅហើយ ចៅមិនត្រមបើកទ្វារទេម្តងនោះឡើយ អស់យើង
តាំងពួងកំនឹងស្លាប់នៅនាហាននោះមិនខេឡើយ។ ពោធិសត្តោ អាហ
លំដាប់នោះ ពោធិសត្តអ្នកក្តុលថា បពិត្រមហាកដអើយ តាខ្ញុំឲ្យតាន
ដឹកនៃអ្នកតាំងឡាយនោះ អង្គឺតែឥឡូវនេះឡើយ កាលអំពីមុន អ្នកតាំង
ឡាយមានដឹកនោះ ហេតុតែអាស្រ័យនឹងខ្ញុំឯងហោង ។ អស់ស្តេច
ផងតាំងនោះដណ្តឹងថា ម្នាលចៅអ្នកប្រាជ្ញ ចៅដោះដឹកយើងឲ្យដំកាល
ឯណាហ៊ុ ។ ពោធិសត្តអ្នកថា ចូរអម្ចាស់ស្តាប់ហោង បពិត្រមហាក
អើយ នាកាលអម្ចាស់ចាប់យកអស់ស្តេច អស់កដសម្បត្តិ អស់តាំង
សកលដម្ពូទ្វីបនេះ រៀវតែនគរយើង ហើយអម្ចាស់ចូលមកកន្លងនគរតត្តរ
បញ្ចាលនេះ ឧឹងទៅកាន់ទន្សាយដឹកស្រាជ័យបាន រីអម្ចាស់ភ្ញាក់រឭក
ចាំនាកាលនឹងរណ្តាប់ស្រានោះ អស់ស្តេចផងតាំងពួងថា ហៃចៅអ្នក
ប្រាជ្ញអើយ យើងសឹងចាំហោង ។ (នៅមានត)

អក្សរសាស្ត្រខ្មែរ	ខ្មែរត្រូវចែកចូន
ឱ្យបានខ្លាប់ខ្ជួន	គង់វង្សតទៅមុខ
ព្រោះអក្សរជាតិ	ដោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ប. ព.

[វិចារណាកថា]

ទុំពុកម្ដាយមានឧបការគុណលើកូនមែនឬមិនមែន

(តទៅ)

លោក ផេង - ដ្រើវ រៀបរៀង

លោកឡេនីន (Lénine) ជាមេបដិវត្តន៍ខាងលទ្ធិកុម្មុយនិស្ត អន្តរជាតិ ក៏យល់ឃ្លាសំដុកមាតាបិតាជាអ្នកមានឧបការគុណលើលោកដែរ ព្រោះនៅពេលដែលលោកចាប់ធ្វើកិច្ចបដិវត្តន៍ជាដំបូង កាលនេះលោកមិនទាន់បានប្រមូលគ្នាបានច្រើន ពួកអ្នកជាតិនិយមនៅមានកម្លាំងជាង តែងតែរកចាប់លោកយកមកធ្វើទោស លោកត្រូវតែរត់កៀសខ្លួនសិន ទម្រាំរកគ្នាបានគ្រប់គ្រាន់ដើម្បីទប់ទល់ ។ ដំណាលថា ម្ដាយលោកបានឱ្យកូយមួយដល់លោកទុកសម្រាប់ដណ្ដប់ ដ្បិតប្រទេសរុស្ស៊ីវរ៉ាណាស់ នៅរដូវសៃសិរៈ (រដូវទឹកកកធ្លាក់) លោករត់ទៅពីណា ក៏មិនចោលកូយម្ដាយលោកឡើយ ទោះបីកូយនោះកញ្ជ្រោលយ៉ាងណាក៏ដោយ តែងតែទៀតលោកចោលបាន ឯត្រង់កូយម្ដាយ លោកស៊ូទុបឱ្យជាប់នឹងខ្លួន

លោកមិនបោះបង់ចាល់តែសោះ ។ តើដោយប្រការម្តេច ឬនជា លោកស៊ូនឹងកួយម្តាយលោក? ព្រោះលោកគោរពម្តាយលោក ដោយ ពុកកួយដូចជាម្តាយ ។ សព្វថ្ងៃ កួយលោកឡើងទ័ន តេជំតល់ពុកនៅ សារមន្ទីរជាតិ ឯក្រុងម្ចាស់ ពុកជាអនុស្សាវរីយ៍តទៅ ។ ចាំងនេះសឲ្យ យើញថាមហាបុរសធំ ។ ក្តី អ្នកគ្រូជ្ជដ៏ឆ្នើមក្នុងលោក មានព្រះពុទ្ធជាដើម ក្តី និយមពុកឪពុកម្តាយថាជាអ្នកមានគុណ ហើយគុណនោះ ធំក្រៃ លែងធំទៅទៀត មិនងាយនឹងសងរួច ។

ចុះចំណែកអ្នកបញ្ជាន្តនឹងអ្នកវិទ្យាសាស្ត្រសម័យថ្មីៗវិញ ដែលពោល ប្រដៅសិស្សថាឲ្យពុកឪពុកម្តាយជាមនុស្សគ្មានគុណលើកូន ពុកការ បង្កើតនឹងការចិញ្ចឹមបីបាច់ថែរក្សាកូន ជាការធម្មតា តើមាតាបិតាត្រូវតែធ្វើ ដូច្នេះ ដូចជាមេតិរច្ឆានដែរនោះ ដោយអាងអ្វី? បើពួកនេះមិនពេញ ចិត្តនឹងពុទ្ធសាសនា ខ្លួនមានសិទ្ធិសព្វគ្រប់ទេតើ? ម្យ៉ាងទៀត មិន មែនតែពុទ្ធសាសនាឯណា ដែលប្រដៅឲ្យកូនត្រូវគោរពឪពុកម្តាយ ត្រូវ ជំនឿគុណឪពុកម្តាយ សាសនាដទៃទៀត ក៏យល់ស្របដូច្នេះដែរ ។

អ្នកគ្រូជ្ជាងនឹតិសាស្ត្រ ឬនចាំងចែងក្នុងមាត្រា ៦ នៃក្រមរដ្ឋប្បវេណី បញ្ជាក់ថា កូនត្រូវចិញ្ចឹមមាតាបិតា បើប្រើយកន្តើយនឹងអ្នកមានគុណ បណ្តាយពុកឲ្យលោករងទុក្ខវេទនា រហាមរហាម កូនត្រូវមានពាស ជាបទមជ្ឈឹមថ្នាក់ទី ១ ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

តាមការពិចារណានឹងការត្រិះរិះឲ្យមឺត់ចត់ យល់យើញថា អ្នកគ្រូជ្ជ

ពាំងឆ្ងាយខាងសាសនា មានព្រះសាក្យមុនីសម្ពុទ្ធបរមគ្រូជាដើមគ្គី អ្នកវិទ្យាសាស្ត្រប៉ាស្ទ័រ (Pasteur) គ្គី មហាវង្សប្អូរសពាំងឆ្ងាយ មានសម្តេចព្រះនរោត្តមសីហនុ នឹងលោកខ្សែនីន ជាដើមគ្គី ប្រហែលជាមានសមត្ថភាពខាងបញ្ញាមិនជាអន់ថយជាងពួកបញ្ញវន្ត ឥឡូវអ្នកវិទ្យាសាស្ត្រខាងលើនេះប៉ុន្មាន ហើយលោកពាំងនោះនិយមមុតម្ភុតម្ភាយ ជាអ្នកមានឧបការគុណដ៏ធ្ងន់លើសលប់ដល់លើកូនជាតិច្រើនដ ។ ដោយហេតុមានមនុស្សប្រកបដោយការយល់ ច្រើនសាកសេចក្តីពិតដូច្នេះហើយ បានជាលទ្ធិពុទ្ធសាសនាបែងចែកមនុស្សជាបួនក្រុមដូចតទៅ ដើម្បីពញ្ញាក់ស្មារតីឲ្យបែរមកកែផ្លូវត្រូវ ទី ១- មនុស្សបេតា ទី ២- មនុស្សនិរយបាល ទី ៣- មនុស្សតិរច្ឆានោ ទី ៤- មនុស្សមនុស្ស ។

សួរថា: មនុស្សបេតានោះដូចម្តេច ? គឺសត្វនោះមានរូបកាយជាមនុស្ស តែអាការដែលប្រព្រឹត្តប្រកាន់និយមមុតជាគោលរបស់ខ្លួន មានសភាពដូចសត្វប្រេត ។ សួរថា: មនុស្សនិរយបាលនោះដូចម្តេច ? គឺសត្វនោះមានរូបកាយជាមនុស្ស តែអាការដែលប្រព្រឹត្តប្រកាន់និយមមុតជាគោលរបស់ខ្លួន មានសភាពដូចសត្វនរក ។ សួរថា: មនុស្សតិរច្ឆានោនោះដូចម្តេច ? គឺសត្វនោះមានរូបកាយជាមនុស្ស តែមានអាការដែលប្រព្រឹត្តប្រកាន់និយមមុតជាគោលរបស់ខ្លួន មានសភាពដូចសត្វតិរច្ឆាន ។ សួរថា: មនុស្សមនុស្ស នោះដូចម្តេច ? គឺសត្វនោះមានរូបកាយជាមនុស្ស ហើយអាការដែលប្រព្រឹត្តប្រកាន់និយមមុតជាគោល

របស់ខ្លួន មានសភាពជាមនុស្សទៀត ជានេះសេចក្តីថាអនុលោមទៅតាមធម្មសញ្ញា ។

សូមបញ្ជាក់ថា : ដែលយើងឃើញមនុស្សមានតាសតេញទៅលើផែនដីមួល គ្រាចំរកស៊ីប្រកាត់ ខ្វាត់ខ្វែងទៅមក មិនមែនមនុស្សទាំងអស់នោះ សុទ្ធសឹងជាមនុស្សមនុស្សាឡើយ ។

ដូច្នេះ សូមពួកបញ្ញាវន្តនឹងអ្នកវិទ្យាសាស្ត្រខាងលើ កុំប្រឡំយកធម្មសញ្ញាជាសភាវគតិ បើយល់គាន់ហើយ មុខតែខ្លួនត្រូវគេកប់បញ្ចូលក្នុងពួកសភាវគតិហើយ ។ ត្រូវដឹងឲ្យច្បាស់ថា ពួកសភាវគតិ គឺពួកតិរច្ឆានមានឆ្អែជាដើមនេះឯង ។

ខ្ញុំមានសេចក្តីស្តាយពន់ពេក ចំពោះពួកបញ្ញាវន្តនឹងអ្នកវិទ្យាសាស្ត្រខ្លះដូចបានពណ៌នាមកនេះ ដែលមានសមត្ថភាពដ៏ធំអាចប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់បាន ជាសញ្ញាប័ត្រដែលមនុស្សភាគច្រើន កម្រនឹងរកបានហើយត្រឡប់ជាយល់ឆ្គើងថាឪពុកម្តាយមិនមានគុណលើកូនទៅវិញ ។ ចំពោះរឿងគុណមាតាបិតានេះ សូមកុំសួរអ្នកដែលបានសិក្សាជ្រៅជ្រះក្រែងថា ព្រោះតែបានសិក្សាទើបបានដឹងថាឪពុកម្តាយមានគុណ សូមអញ្ជើញទៅសួរអ្នកស្រែសាមញ្ញ នាពុងកាត់មាត់ញាក ដែលពន្លឺវិជ្ជាពុំអាចផ្សាយទៅដល់ដោយបរិបូណ៌ អំពីគុណមាតាបិតាល្ងឹងមើល ខ្ញុំអាចសន្មតជាន់ជាន់បានភ្លាមថា គេនឹងមានការឆ្ងល់ចំពោះអ្នកសួរវិញជាមិនខាន ឆ្ងល់ថាអ្នកសួរនេះប្រហែលទើបតែនឹងភ្ញាក់មកពីព្រះចន្ទ្រខែដឹង បានជាមកសួរយ៉ាំងនេះ ។

អក្សរសាស្ត្រខ្មែរ

សិលាចារឹកជ័យ - ជន្ម

ស្រាវជ្រាវដោយ ឌុ - គាម

តេជៈអញខ្ញុំថ្វាយ ស្បង្គ៌ចកាយកបហត្ថា លុតលើកអស់អង្គា ថ្វាយវន្ទា
សូវេចហោង ។ ៦) ថ្វាយហើយខ្ញុំខ្ញុលប្តីង សូមឲ្យដឹង់អស់អាចិផង
ជាតិសញ្ញាណហោង(១) កុំកំចាំងភ្លាំងភ្លេចឡើយ ។ កើតបានប្រាំពីរ
ឆ្នាំ ប្រាជ្ញាចាំហើយចេះឆ្លើយ អស់អាចិធមិត្រប់ហើយ ត្រើយបឹតកវត
មាត់ទេ(២) ។ ឥតខ្វះសង្ខឹង់ដល់តិច ថ្ងៃង់ពាក្យតេចន៍ស្រេចឯង់ឯង
គោះឆ្លើយទៅនឹង់គេ ដោះប្រស្នាអ្វីក្រុតាល់សល់ ។ ៧) សូមចេះចប់
ត្រៃកេទ សិល្បសាស្ត្រសេដ្ឋឥតខើសតាល់ ធុតធាប់ជាអស្ចារ្យដូចព្រះបរ
មេស្វរនៃ ។ សូមតាន់ព្រះស្រីអារ្យ មានបរិតារច្រើនក្រាស់ ក្រៃជារយ
តាន់ហ្នឹងនៃល្អប្រពៃដោយប្រាថ្នា ។ ៨) សេតជនស្រីតៅបួស ខ្សើង់ផល
ផ្ទួសល្អថ្លៃថ្នូ សំណាក់ព្រះសាសនា បានព្រះពុទ្ធទំនាយទុក ។ ព្រះ
ស្រីអារ្យតាយថា អ្នកនេះណាត្រាស់ឯមុខ ជាព្រះពុទ្ធសោយសុខ
ត្រាស់ធម៌ទុកនាំសត្វនៃ ។ ខ្ញុំសូមនោះរៀង់មក ជាតន្ទុកសពើជ្ញថ្លៃ
អង្គខ្ញុំនេះឯង់នៃ ដោយនាមម័យហៅជ័យនេះ ។ រីនាង់ជាកន្យា
ឈ្មោះពីរនៃម៉ង់បែនសន រូបឆោមទន់អែនអន ស្ម័គ្រស្នេចតេស្រី ។

១- ជាតិសរណាញាណ ។ ២- ត្រើយបឹងការត់មាត់ទេ ។

๙) លះព្រះបាទកជា ឲ្យសក្តាធ័ខៃខ្ញុំ ជ័យនន្ទុសេនាធិបតី ហើយឲ្យ
ធ័ព្រៃក្តីហោង ។ ដល់ទៅធ័ត្បូងឃ្មុំ នាមុំនដំឯកឯងហោង លុះជា
យោមកជាង នោះឯងហោងសាងគ្រឿសូរ ។ ឯម៉ងវែងនោះណា
ឃសសក្តាដោយតំនូរ ឈ្មោះនោះយល់បរិបូណ៌ ជាដំណាវពេញសុពណ៌។
១០) រីអ្នកនេះតាំងពីរ ដោយរមិលយល់អស្ចារ្យ ជាតិនេះឮខ្ញុំវែ កើត
ក្នុងព្រៃតាំងជាឆាយា ។ ជាតិនេះពុំបរិបូណ៌ ប្រាសពុំមូលច្រើនឃ្វាតឃ្វា
នោះកើតសព្វ។ ជាតិ កុំគ្រាឃ្វាតដល់តិចឡើយ ។ វិបាកនេះជង់គ្នា
មកច្រើនគ្រាពុំគ្រាស្បើយ អំពីជាតិនេះហើយ ខ្ញុំវៀរគ្រង់វិបាកប្រាណ។
១១) នោះលែងជាតិនេះទៅ វិលមកនៅកើតរួមស្ថាន ត្រង់ក្នុងអាស្រូវ
ប្រាណ កុំគ្រាមានភិតភ័យ ។ កាលឥតនឹងព្រះពុទ្ធ សោតលើស
លន់ខន់ឥន្ទ្រិយ បើយកព្រះចេតិយ ទុកជាតុន៍បីនឹងកូន ។ រីកូនតាំង
ពីរអង្គ អាត្មាកន្ទង់ធ្វើបុណ្យជូន ប្រកបម្តាយនឹងកូន អ្នកអឺមទង់នៅមួយ
ស្ថាន ។ ១២) ហើយសាងព្រះចាក់បែក ចាក់ដាំភ្លោកបែកអង្គប្រាណ
ខ្ចាត់ខ្ចាយអន្តរធាន ចាក់អស់ប្រាណជាកំណាត់ ។ ឯខ្លះចាក់សុវង
ព្រះកេសជង់ភ្លាក់ចេញចាត់ ព្រះចាក់ជាកំណាត់ ព្រះហស្តចាត់ជាច់
ខ្ចាត់ខ្ចាយ ។ ទំរែសរកប្រមូល ហោះភ្ជាប់ចូលមូលរូបកាយ ចិត
មាសអស់តាំងខ្លាយ ជាតណ្ហាភយល្អមានទ្រង់ ។ ១៣) រីកប់អស់
តាំងខ្លាយ មួយរយថ្ងៃយ ៣០ ព្រះអង្គ សាងព្រះបពិត្រផង់ គួរត្រប់

អង្គរបូតូចធំ ។ ហើយបួសធ្វើរចតីយ ព្រះសាង់ថ្មីនោះធ្វើក្តុំ ធ្វើរូបចាំងតូចធំ ជាឧត្តមបួសស្រេចហោង ។ ស្រដីតែខៅនេះ ពុំរៀបរាប់ពីដើមផង ធ្វើបុណ្យនោះច្រើនហោង បួសច្រាំងផងទឹងនេះណា ។ ១៤) កាលបុះព្រះមាសមួយ សាង់ត្រីសូរនោះមួយគ្រា សិតព្រះសីហិង្គ ណា បុះព្រះមាសច្រាក់ច្រើនផង ។ ធ្វើបុណ្យពីមុនណា សង់សាលាវិហារហោង បំបួសកូនគ្រប់ផង ច្រើសខ្ញុំហោងបញ្ចុះសីមា ។ ទឹងតិតដោយស្មាន ចាំពុំបានបទច្រើនគ្រា ឲ្យខានខ្លះបានគ្រា ដោយគណនាតិតចារចង ។ ១៥) ស្រដីដោយចារកាត់ ពុំរៀបកប់ពីដើមផងបើតិតឲ្យខានសង្ឃ នោះច្រើនណាស់ចាំពុំបាន ។ ដោយតិតធ្វើបុណ្យណា ទឹងគណនាច្រើនសព្វស្ថាន ទឹងចាំនោះពុំបាន បទដោយស្មានច្រើនដងណា ។ សូត្រតីនេះខៅហើយ សូត្របង្ហើយបុះខៅល្បាសូត្រប្លែចអស់នេះណា សូត្រសំណូមសំរេចហោង ។

វិបានានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំ ង - ខាត់ រៀបរៀង

(តមក)

អទែគិក គុ. ដែលមិនមានមគ្គុទ្ទេសក៍ ដែលពឹងអ្នកដឹកនៃ ។

អទោគ្ធ ភា. ន. អ្នកមិនខាប្រយោជន៍ អ្នកមិនព្រួយ ។

អទោមយ គុ. ដែលសម្រេចហើយដូច្នោះ ។

អទោម គុ. ដែលមិនមានទោស ។ – ជ្ញ គុ. ដែលមិនស្គាល់ទោស ។

អទ្ធា ក្រ. វិ ដោយពិត ។

អទ្ធិសិ ពហុ: នៃ អចិ ។

អទ្ធុព គុ ដែលមិនមាន ដែលចំឡែក ដែលអស្ចារ្យ ។ ប៊ុ. ខេះក្តីអស្ចារ្យ: ឈ្មោះនៃដង្ហែក់ក្នុងរឿងព្រេង ។ ខប៊ុ. ការចំឡែក ។ ក ប្លែកពី-ធម្មតា ។ – សូត្តិ ស្ត្រី. កំណើតចំឡែក ។ អទ្ធុតាការ គុ. ដែលមានអាការអស្ចារ្យ អទ្ធុតាកតិ គុ. ដែលមានអាការប្លែក ។ អទ្ធុតាចិ គុ. ដែលមានអាចិអស្ចារ្យ ។ អទ្ធុតោបម គុ. ដែលមានរឿងប្លែ-ជាឧបមា ។ អទ្ធុតោបមា ស្ត្រី. សេចក្តីឧបមាដោយរឿងអស្ចារ្យ ។

អទ្ធ្យសិ ឯគុ. បញ្ច. ពហុ. នៃ អចិ ។

អទ្យ អទ្យ. ថ្ងៃនេះ; ឥឡូវនេះ ។ អទ្យៃ ក្នុងថ្ងៃនេះឯង ។ អទ្យប្រភតិ អទ្យាភ្យ ពីឥឡូវនេះទៅ ចាប់ពីពេលនេះទៅ ។

អទ្យ គុ. (<អទ៌) ដែលកំពុងស្មើ ។

អទ្យតន ឬអទ្យតិន គុ. ដែលមានក្នុងថ្ងៃនេះ ដែលទើបមានថ្ងៃនេះ ។ អទ្យតនីយ គុ. ដែលមានក្នុងថ្ងៃនេះ ។ ឧបុំ. ឈ្មោះរឹក្ត ។

អទ្រវ្យ គុ. ដែលមិនមានទ្រព្យ ។ សិស្សល្ងង់ ។

អទ្រម្ម៑ ៣. ន អ្នកមើលមិនឃើញ មនុស្សខ្វាក់ ។

អទ្រី ប៉ុំ ភ្នំ ។ – ភូត ប៉ុំ. កំពូលនៃភ្នំ ។ – កតស្តលី ស្រ. ឈ្មោះនាងអប្សរ ។ – បតិកន្យា ស្រ. នាងបវ៌តី សក្តិព្រះគិរិ: ។ – ភោគន ឧបុំ. កិរិយាទំលាយភ្នំ ។ – អូធិនី ប៉ុំ. កំពូលនៃភ្នំ ។ – ភវ ប៉ុំ ភ្នំហិមាល័យ ។ – សារមេយ គុ ដែលជាវិការៈនៃដែក ។

អទ្រិកា ស្រ. ឈ្មោះនាងអប្សរ ។

អទ្រោហ ប៉ុំ. កិរិយាមិនទាស់ទែង កិរិយាមិនគុំគួន សេចក្តីចំណងល្អ សេចក្តីប្រាថ្នាជាពិសេស ។ គុ. ដែលមិនមែនជាទោស ដែលជាគុណ ។ – សមយ ប៉ុំ. សម័យនៃកិរិយាមិនទាស់ទែងគ្នា សម័យព្រមព្រៀងសន្ធិសញ្ញាមិនទាស់គ្នា អទ្រោហសម័យ ។

អទ្វយ គុ. ដែលមិនមែនទីពីរ ឯក ។ ឥ. ឧបុំ. ភាវនៃ . . . ឯក ។ អទ្វយានន្ទ គុ. ដែលមានសេចក្តីរីករាយមិនមានទីពីរ ។ ឈ្មោះអាថរ្វម្នាក់។

រឿងសាមកុក

ឧកញ៉ាវិបុលពជសេនា ឆួ - តេង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃ្លាសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងដេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

យួរ-អ៊ុន

ចាំដ៏ឋដ៏តំសួរហួតចេដ៏ថា ផ្លូវដែលយើងនឹងចូលទៅស្រុកឡុកសៀ នោះ ជាផ្លូវតែមួយឬមានផ្លូវបែក ហួតចេដ៏ឲ្យយកដែនទីដែលខៀវសុង ធ្វើឲ្យនោះ មកសាមើល ចាំដ៏ឋដ៏ក៏ពាក្រែះមើលដែនទី ឃើញមានផ្លូវ បែកជា ២ អន្ទើ ផ្លូវតួចដែលនឹងកាត់តម្រង់ទៅតាមប្រកត់ ជាផ្លូវហ៊ាស ផ្លូវធំ គោដ៏ឋង ទើបនិយាយនឹងខ្លៅពីថា ដែលនឹងលើកចូលទៅស្រុក ឡុកសៀគ្រានេះ ខ្ញុំបាទនឹងសុំនាំគាហានទៅតាមផ្លូវតួច សុំឲ្យលោក លើកទៅតាមផ្លូវធំចុះ ខ្លៅពីថា ឯផ្លូវតួចនោះ ជាប្រកបដ្បិតពីចាកណាស់ ខ្លាចសត្រូវនឹងលើកគាហាន មកចាំស្ទាក់បង្កប់ទៅពីនោះ ខ្លួនអ្នកមិនចំ ណាននាងចាញ់ឆ្លងផង ឃើញថាជាការលំបាកណាស់ ក្រែងថ្នស់នឹងស ត្រូវខេដឹង គួរតែអ្នកលើកគាហានទៅតាមផ្លូវធំ ចូលខាងក្នុងឯកើត ខ្លួនខ្ញុំ ចំណាននាងចាញ់ឆ្លង នឹងលើកទៅតាមផ្លូវតួចវិញ ពោះបើជួបនឹងសត្រូវ ក៏ ត្រូវតែស៊ូគ្នាឲ្យខាល់តែបានដ៏យជ័យដំនះ ។

ចាំធំថធ្លាថា ឯផ្លូវធំនោះ ខ្ញុំបានឃើញថា សត្រូវទឹងលើកទាហាន
មកចាំជាច្រើន បើខ្ញុំបានទឹងលើកទៅ ត្រូវតទល់ដោយកម្លាំងមិនបាន
បានជាសុំទៅខាងផ្លូវតូចវិញ ដោយឃើញថាសត្រូវស្តើងស្តួចខ្លះ ល្មម
កម្លាំងខ្ញុំបានទឹងតស៊ូបាន ឯផ្លូវធំនោះ អ្នកដទៃទឹងលើកទៅ មុខជាថ្នល់ការ
ហើយ គួរលោកលើកទៅខ្លួនលោកទើបស្រួល ឡៅតីថា អ្នកចូរទៅ
តាមផ្លូវធំតាមខ្ញុំថាចុះ កុំទៅតាមផ្លូវតូចនោះឡើយ ព្រោះតើយប់មិញ
ខ្ញុំយល់សប្តិអាក្រក់ណាស់ បេះតែបែកកង់ចិត្តថា មានទៅតាមយួយអង្គ
យកឈើដំបងដែតមកពយត្រូវជើងធ្វេងខ្ញុំ ឈឺពើតចាប់យ៉ាងខ្លាំងគាល់
តែក្បាក់ឡើងក៏មិនទាន់ជាត់ឈឺ ខ្ញុំតិកាល់ក្នុងចិត្តណាស់ បានជាចង់ឲ្យអ្នក
ទៅតាមផ្លូវធំវិញ ចាំធំថធ្លាថា កើតមកជាទាហានធ្វើការសង្គ្រាម បើ
មិនស្លាប់ ក៏គង់ត្រូវមានរបួសជាប្រពៃណី ហេតុម្តេចលោកមកតែក្តក្តៀក
ហាយដោយសេចក្តីយល់សប្តិដូច្នេះ មិនត្រូវទេ ។

ឡៅតីថា អ្នកនិយាយនោះត្រូវហើយ តែឥឡូវខ្ញុំមានសេចក្តីតែក្ត
ព្រោះខ្ញុំងឹបេធ្វើសំបុត្រមក ខ្លាចក្រែងមានថ្នល់ការ បានជាមិនខុកចិត្ត
ដូច្នេះគឺតទឹងឲ្យអ្នកទៅកក្រាបន្ទាយ ដោយស៊ីគួនវិញទៅចុះ ខ្លួនខ្ញុំទឹងលើក
ទាហានទៅធ្វើការតែម្នាក់ឯងក៏បាន អ្នកកុំបាច់ទៅឲ្យកង្វល់ឡើយ ចាំធំ
ថធ្លាសើចហើយថា ដៃលខ្លួនបេធ្វើសំបុត្រមកនោះ ដោយឫស្សាទេ តិ-
ព្រោះឃើញថា ខ្ញុំបានមកធ្វើការជាមួយទឹងលោក បើបានស្រុកសែ

ឈ្លួនហើយ កំមានសេចក្តីគាប់ប្រសើរជាង ចានជាថាមកដូច្នេះ ច្រាំថ្ម
នឹងឲ្យលោកសង្ស័យចិត្ត មិនឲ្យធ្វើការហូត ខ្ញុំចាកំមិនច្រាំថ្មនឹងរក
សេចក្តីគាប់ប្រសើរនោះប៉ុន្មានទេ ដែលលោកនិមិត្តនោះ ជាការល្អទេតើ
កុំសង្ស័យចិត្តធ្វើអ្វី ខ្ញុំចាមកធ្វើការជាមួយនឹងលោកនេះ គឺតាំងចិត្តនឹង
យកអាសាឲ្យដល់ខ្នាត ច្រាំថ្មនឹងយកលោហិតលាបដែនដីពុកឲ្យច្រាកដ
ដៅខាងមុខ គោះបីនឹងអន្តរាយដល់ជីវិតក៏មិនចានគិត ដែលព្រឹកនេះ
សូមឲ្យលោករៀបលើកតាហានដៅចុះ ។

ខ្លៅពីស្តាប់ហើយក៏យល់តាម ទើបចាត់ឲ្យអ៊ុយអៀនជានាយកងមុខ ខាងចុងឆង ឲ្យហានគុនជានាយកងមុខ ខាងខ្ពស់ លុះតាហាន
តាំងពួនជុំព្រមគ្នាហើយ ខ្លៅពីនឹងចុងឆងក៏ឡើងសេះទំនគ្នា លើកចេញ
ចាកបន្ទាយ ពីពេលព្រឹកត្រហាមស្រាង សេះដំនិះចុងឆងនោះ បណ្តាល
ឲ្យដើរក្លាត់ដើនជួលដៅ ចុងឆងក៏របួតធ្លាក់ពីលើខ្នងសេះដៅដី ខ្លៅពី
ឃើញដូច្នេះ ក៏លោតចុះពីលើខ្នងសេះ ដៅគ្រាហ៍ចុងឆងលើកឡើង
ហើយថា ហេតុម្តេចសេះអ្នកចានជាដូច្នេះ ចុងឆងថា សេះខ្ញុំធ្លាប់ដំរ
ធ្វើការចម្បាំងមកយូរហើយ មិនដែលដូច្នេះឡើយ ដែលសេះកបណ្តាល
ដូច្នេះ មកអំពីការប្រមាទ ខ្លៅពីថា បើសេះអ្នកមិនស្រួលដូច្នេះហើយ
នឹងចូលតតាំងច្បាំងនឹងសត្រូវធ្វើម្តេចចាន នឹងមិនថ្លស់ការទេឬ អ្នក
ចូរផ្លាស់យកសេះខ្ញុំដំរដៅចុះ ខ្ញុំនឹងយកសេះរបស់អ្នកមកដំរវិញ ចុងឆង

តំនាប់ឡៅតាវហើយថា គ្រានេះយើញថាលោកមានគុណនឹងខ្ញុំជាខនឹង
រកខ្លឹបផុតមិនមានឡើយ ចាំឯថង់ក៏ស្រួតលើកតាហានទៅមុនឡៅតាវក៏
លើកខ្លែតាមទៅ ចេះតែមានសេចក្តីរីករាយដល់ចាំឯថង់ គ្មានសប្បាយ
កន្លងចិត្តសោះ ។

ឯឯីអ៊ុនឯងឡៅកុយ ដែលនៅក្បាស្រុកឡុកសៀនោះ ដឹងថាឡេង
ឡៅខលួសអនិច្ចកម្មក៏ប្រឹក្សាគ្នា ខៀវយ៉ែមក៏ចូលទៅនិយាយថា ឥឡូវ
ឡៅតាវលើកតាហានមកធ្វើអន្តរាយយើងហើយ ខ្ញុំយើញថា ផ្លូវគាត់ច្រក
ភ្នំដែលនឹងមកត្រង់ស្រុកឡុកសៀនោះជាផ្លូវតូចចង្អៀតណាស់ ខ្ញុំសូម
អាសាលើកតាហានទៅស្កាត់បង្ខំប់នៅត្បែរផ្លូវនោះ បើឡៅតាវលើកមកក៏
នឹងចេញតខ្លាំងុក កុំឲ្យមកបាន សុំឲ្យអ្នកទាំងពីរនៅក្បាស្រុកចុះ ចរចា
គ្នាមិនខាន់ផុតមាត់ មានបំរើបួលមកប្រាប់ថា ឥឡូវឡៅតាវលើកកងទ័ព
មកជាពីរផ្លូវ ខៀវយ៉ែមឮដូច្នោះក៏ស្រួតលើកតាហានទៅចាំស្កាត់ទៅទីនោះ
លុះយើញអ៊ុយអឿនជានាយកងមុខលើកមក ក៏បង្គាប់តាហានចាំងអស់
ឲ្យសម្ងំទៅសឿម ហើយចង្អុលប្រាប់ថា ដែលលើកទ័ពមកខាងក្រោយ
ជិះសេះសនោះគឺឡៅតាវ យើងប្រុងចាំចាប់ខ្លួនឲ្យបាន លុះចាំងថងមក
ដល់ផ្លូវច្រកបង្កុំ យើញផ្លូវនោះតូចចង្អៀតណាស់ ហើយមានព្រៃឈើ
ស្បាតញឹកចាំងសងខាងផ្លូវ ក៏គិតតក់ស្លុតកង់ចិត្ត តាញាសេះឈប់
ហើយសួរថា ដំបន់នេះឈ្មោះអ្វី ? តាហានស្រុកសៃឈ្លួនដែលជា

ឈ្មោយឆ្លើយប្រាប់ថា ពីនេះឈ្មោះឡុកហង៍ហោ ។

ចាំង៍ថង៍ឮដូច្នោះក៏គិតថា ខ្ញុំនយើង៍នេះ លោកអាចារ្យតាំង៍តាមទុកឲ្យឈ្មោះថាហង៍ស្ងួ ឯផ្លូវដែលទំង៍ចេញពីប្រកក្តុំនេះជាផ្លែវល ដម្ងូតាហង៍បើទំង៍ធ្លាក់វលហើយ កំមិនអាចហើរទៅបាន ខ្ញុំនយើង៍ឈ្មោះហង៍ទំង៍ធ្លាក់ចុះត្រង់ផ្លែវលនេះក៏ទំង៍មានអន្តរាយ គិតតក់ស្លុតរន្ធត់ចិត្តដូច្នេះហើយ កំឲ្យតាហានថយវិលចេញមកវិញ ខ្លួលតាហានខ្មៀយើមអុជជាវឡើង ហើយស្រែកហៅ ចាញ់ឆ្លងចុះត្រង់មកតាំង៍សង៍ខាង ផ្លូវគឺត្រូវចាំង៍ថង៍ធ្លាក់ពីលើសេះស្លាប់ តាហានតាំង៍ពួង៍ក៏បែកចាក់ព្រាត់ព្រាយទៅអស់ ខណកាលចាំង៍ថង៍ខ្លួលអង្គុតម្នាក់ អាយុបាន ៣៦ ឆ្នាំ តាហានតាំង៍ពួង៍ដែលបែកតាមទៅដល់អ៊ុយអៀនហើយ ក៏ស្រែកប្រាប់ថា ឥឡូវ សត្រូវលើកមកស្លាក់ស្លាត់ច្រើនណាស់ ចាញ់ត្រូវចាំង៍ថង៍អាចារ្យយើង៍ស្លាប់ទៅហើយ អ៊ុយអៀន ឮដូច្នោះ កំភ័យខ្លាំង៍ណាស់ទំង៍លើកតាហានត្រឡប់ចុះមកវិញ ខ្លួលតាហានខ្មៀយើម លើកចេញមកស្លាត់ពីមុខពីក្រោយ កំតាំង៍ច្បាំង៍គ្នាជាចលាចល ទំង៍ចេញក៏ពុំរួចលុះទំង៍ថយក្រោយ ខ្មៀយើមក៏ស្លាក់ជាប់ តាលអ៊ុយអៀនតច្បាំង៍ទៅក្នុង៍ចំណោមដូច្នោះ តាហានក៏ស្លាប់វិនាសជាច្រើនណាស់ អ៊ុយអៀនតាល់ប្រក មិនដឹង៍គិតយ៉ាង៍ណា ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន

លោក ដេង-ទ្រីវ ប្រែរៀបរៀង

(តមក)

៦១- ស្រីក្រមុំរើសប្តី

ស្រីក្រមុំខ្លះ ប្រកាន់ឫកសង្ហាហួសពេក ច្រាច្មាចង់បានតែប្តីខៅក្នេង រួចពេញលេញហើយអ្នក ឫកពាក៏ឲ្យល្អ កុំឲ្យចេះតែធ្ងន់ ។ នឹងកុំប្រ-ច័ណ្ឌច្រើន ។ កញ្ញានោះចង់ឲ្យប្តីជាអ្នកមានទ្រព្យ មានឫទ្ធិដង្ហើម មានវិជ្ជាជីវៈ គឺថាត្រូវឲ្យមានត្រម ។ តែ តើមនុស្សណាមានត្រម ? វាសនាទំរាំនឹងយកចិត្តទុកជាក់ជួយរកឲ្យទាន់ដែរ គឺសុទ្ធសឹងអ្នកមានទ្រព្យ នឹងអ្នកមានកេរ្តិ៍ឈ្មោះ ដែលចូលមកដល់ក្តីនឹងនោះ ។ នាងស្រីស្រស់ថា អ្នកខាងលើនេះ មានសភាពមិនមរិបូណិហើយគិតថា « អ្នកចាំងអស់ខេះមក រកអញដូចម្តេចហ្នឹង ! អញស្មានទៅ គឺសុទ្ធតែអ្នកឋេកឋយ អីគេបំរុងតម្រាមនុស្សបែបហ្នឹងមកឲ្យអញ ! ទុកម្អាយ ! អាណិតគ្នាពេក ចូរមើលមើលចុះ បែបភាគល្អអ្វីម្ល៉េះទេ ! » ។ នាងថា អាមួយមានវិជ្ជាល្អដែរ តែមិនហ្មត់ចត់ អាមួយទៀត មានច្រមុះមិនសម ចាំងអស់សុទ្ធតែខាស់ឯចេះ ខាស់ឯចុះ រួមសេចក្តីទៅគឺខាស់ចាំងអស់ ។ ព្រោះស្រីជម្រើសប្តី តែងធ្វើឫកដំទើតដំទើងទៅលើតែគ្រប់យ៉ាងអីចឹង ។

លើកនេះ អ្នកធំកណ្តាលចូលមកដណ្តឹងម្តង ។ នាងស្រីស្រស់ចំអកមើលងាយឲ្យគេថា «អើ! ខ្លួនខ្ញុំច្រាកដជាសម្រាប់តែបើកភ្នែកឲ្យអ្នកកល់គ្នាចូលលេងហើយ! អ្នកកល់គ្នាគិតស្មានថា ខ្ញុំកើតពុត្តខ្ចាំងអំពីខ្លួនខ្ញុំណាស់ទៅប្រហែល! ទុទេព្តាអើយ! ខ្ញុំខលួលពានដំណោកគ្មានព្រួយសោះ ថ្ងៃក្រឹតតែនៅស្ងាត់ម្នាក់ឯង» ។

នាងស្រីស្រស់ ចូលចិត្តតម្រូវយកតាមតែគំនិត ដែលខ្លួនយល់ម្នាក់ឯង ។

រំយោចេះតែកន្ទង់ទៅ ធ្វើរូបនាងនោះឲ្យនុនថយចុះដរាប ។ ពួកអ្នកមើលឈប់ត្រូវការអស់ ។ បន្តិច ឆ្នាំមួយកន្ទង់ទៅ បន្តិច ឆ្នាំពីរកន្ទង់ទៅ ព្រមទាំងចិត្តក៏ពុំសូវស្ងប់ ចេះតែខ្វល់ ។ ថែមទាំងសេចក្តីព្រួយគឺមានបន្ថែមកខ្លៃត: នាងនោះដឹងថា សេចក្តីសប្បាយតែកយ ខឹងការតម្រេកកាន់តែឃ្លាតចេញពីអាត្មាកល់ថ្ងៃ គឺថាសោកនាដកាងក្រៅ ចេះតែខាស់ហើយមិនល្មមនឹងចិត្ត ម្ល៉ោះហើយចេះតែរកមេម្ដាយកែក្រមមកជួយ ។ ទោះបីនាងទំប្រើនតែកុនដូចម្តេច ក៏ស្មុះមិនចេញពីចោរបង្រៃ គឺកាលវេលានេះបាន ។ ផ្លុះចាក់បែក គេអាចតែឡើងវិញបាន ចុះមុខថាស់ហួសម្តេចក៏មិនឲ្យតែឡើងវិញបានផង! នាងដំរើសប្តីនេះ សម្លឹងកំប្រៃខ្លៃត ។ កញ្ចក់និយាយប្រាប់នាងថា: «ចូរអ្នកនាងយកប្តីឲ្យខាប់» ។

ដល់អីចឹងទៅ នាងស្រីស្រស់តាំងជ្រើសរកប្តី ជ្រើសទៅជ្រើសមកនៅទីបំផុត ទៅប្រទះលើអាដែងមនុស្សខ្វិនមោង ។

៦២- ស្រីក្មេងមេម៉ាយ

ការបាត់បង់ប្តី តែងបណ្តាលឲ្យមានសេចក្តីទុក្ខព្រួយអនេក គឺថា រមែងធ្វើឲ្យមានការកើបញ្ជាប់ញ័រពេនតែក តែរួចពីនោះទៅ គេរមែងមានសេចក្តីកែកយមកវិញ ។ សេចក្តីទុក្ខព្រួយតែងសោតហើរទៅជាប់ជាមួយនឹងពេលវេលា គឺថា តេលវេលាតែងតែនាំសេចក្តីកែកយមកវិញ ។

សេចក្តីផ្សងគ្នាធំណាស់ រវាងស្រីមេម៉ាយមួយថ្ងៃ នឹងស្រីមេម៉ាយមួយឆ្នាំ គេស្មើតែមិនដឿថា ស្រីមេម៉ាយនោះ ជាតួរូបមនុស្សតែមួយ ។

ស្រីមេម៉ាយថ្មី កំពាត់មនុស្សឲ្យថយចេញ ស្រីមេម៉ាយយូរ នាំឲ្យមនុស្សរួមចូលមកជិត គឺថាស្រីមេម៉ាយថ្មី រមែងបណ្តាយខ្លួនឲ្យភ្លាត់ទៅក្នុងសេចក្តីទុក្ខព្រួយ ពោះបើសេចក្តីទុក្ខព្រួយនោះមែនប្តូចខ្លំ្លកំដោយ ។

គេតោលថា គេកើតទុក្ខមិនអាចកែបាន អើគេថាដូច្នេះ តែតាមការណ៍ពិត គឺមិនមែនសោះ ។

យើងសូមដួនតាហារណ៍ដូចតទៅនេះ ៖

ប្តីនាងកញ្ញាម្នាក់មានរូបជាស្អាត បានទៅការនៅលោកដទៃ ។ នាងនោះស្រែកយំក្តៃគ ។ នៅក្បែរភ្នោចប្តីថា : « ចាំខ្ញុំទៅផង អ្នកបង ! ខ្ញុំតាមអ្នកបងទៅដែរ ។ ព្រលឹងអូនរៀបហើរទៅជាមួយនឹងព្រលឹងអ្នកបងឥឡូវហើយ ។ ចំណែកប្តីនាង ធ្វើដំណើរទៅតែម្នាក់ឯងព្រងើយ ។ ឯពុកនាងស្រីស្អាត ជាមនុស្សប្រកបដោយគតិបណ្ឌិត ហើយជាអ្នកយល់

ហេតុការណ៍សព្វគ្រប់ គាត់បណ្តោយឲ្យទឹកភ្នែកកូនស្រីគាត់ ហូរសន្ធឹកៗ ដល់ពេលក្រោយ ដើម្បីលួងកូន គាត់និយាយដូច្នេះថា : « នែកូនស្រី នាងបង្អែកទឹកភ្នែកប៉ុណ្ណឹងល្មមហើយ ប្រយោជន៍អ្វីនឹងមនុស្សស្លាប់នោះ វានាំតែធ្វើពណិសាច់ឈាមឲ្យខូចខាតឥតអំពើទេ ! ដ្បិតមនុស្សរស់នៅមានតរៀងគោក ឈប់លែងតែតវៅរកខ្មោចទៀត ឥពុកមិនទាន់តែត ពេលនេះ ព្រោះកូនឯងនៅមានពុក តែកូនត្រូវដឹងថា ក្នុងពេលណាមួយ ឥពុកនឹងរកប្តីមានរូបយ៉ាងស្អាត ហើយនៅក្មេងជាងខ្មោចប្តីមុន ឲ្យកូនឯងទៀត » ។

នាងស្រីស្អាត ឆ្លើយតបវិញភ្លាមថា « ល្អើយ ! បើយកប្តី ស្ទើរៀបរួសធ្វើយ៉ាងដូច្នេះជាងនឹង » ។

ឥពុក បណ្តោយពុកឲ្យកូនស្រីបន្ធើយសេចក្តីព្រួយសិនចុះ ។ សេចក្តីដូចអធិប្បាយមក ចាននឹងនៅពេញមួយខែ ។ ដល់ខែក្រោយ គេឃើញមានការប្រែកលៀងថ្មី ប្រែពាំងសំលៀកបំពាក់ ពាំងសំពត់ផ្សេង ។ ពាំងមួកដែលពាក់ លុះខ្ចីបំផុត សញ្ញាគាន់ពុក ត្រឡប់ទៅជាសំពត់សំពាប់តែងកាយជាមួយនឹងគ្រឿងលំអដទៃទៀត ។ សេចក្តីតម្រេកត្រប់រីស័យ ត្រឡប់វិលមករកនាងមេម៉ាយវិញ : ល្បែងត្រប់យ៉ាង ការសប្បាយតែកយ ការរាំលេង ក៏វិលមកកាន់វេនវៀនខ្លួនវិញ ព្រឹកល្ងាច នាងមេម៉ាយក្មេង គិតតែតែងខ្លួនមិនចេះឈប់ឈរ ។

ឪពុកមិនមែនភ្ញាក់ផ្អើលដែលជាទីស្នេហារបស់កូនស្រីនោះសោះ ហើយដោយឃើញឪពុកមិននិយាយអ្វីនឹងខ្លួនឯង ក៏សួរគាត់ថា «ឯណាឃើញប្តីយ៉ាងក្មេង ដែលលោកឪពុកបានសន្យាថា រកឲ្យខ្ញុំនោះ» ។

៦៣- ប្រយោជន៍នៃវិជ្ជា

ក្នុងកាលកន្លងទៅហើយ មានមនុស្សពីរនាក់ នៅក្នុងស្រុកជាមួយគ្នា ម្នាក់ក្រីក្រ តែមានចំណេះ ម្នាក់ទៀតមានទ្រព្យ តែល្ងង់ ។ ជនទាំងពីរ ចេះតែជជែកគ្នា ដណ្តើមយកជាញឹកញាប់ អ្នកនេះ ដោយចង់ឈ្នះក៏នោលថា «ធម្មតាមនុស្សមានចំណេះ ត្រូវតែគោរព ត្រូវតែកោតក្រែងខ្លាមនុស្សមានសម្បត្តិ» ។

តើមនុស្សត្រើលទេតើ ដែលតែងនោលថាអ៊ីចឹង ដ្បិតថា ហេតុអ្វីក៏ត្រូវឲ្យទៅគោរព ឯទ្រព្យដែលជាវត្ថុគ្មានខ្វិមសារវិញ? ចំពោះយោបល់បែបហ្នឹង ខ្ញុំថាដូចជាតូចពេកណាស់ ។

អ្នកមានទ្រព្យ តែឆ្កួតយោយជាញឹកញាយនឹងអ្នកប្រាជ្ញដូច្នេះថា «បើខ្លួនអួតថាខ្លួនជាមនុស្សសំខាន់ លះទៅស៊ីជាយមួយតុមើល! ពួកមិត្រភក្តិខ្លួនដែលចេះតែអានសៀវភៅមិនឈប់ឈរ តើមានជាន់ការអ្វី? ទីកន្លែងសំរាប់អាស្រ័យនៅក៏ចង្អៀត សំលៀកបំពាក់ខែចែត្រដូចខែកត្តិក បើដើរទៅណា មានតែស្រមោលអាត្មាជាអ្នកបៀរហម ពាក្យមានត្រូវការអ្វី

ប៉ុន្តែនៅមានមនុស្សដែលមិនមានការចំណាយច្រឡូង ហើយយល់ឃ្លាសំដីថា មនុស្សដែលមានប្រយោជន៍ គឺមនុស្សណាដែលមានការចែកចាយច្រឡូង ខ្ញុំពុំក៏ដឹងដែរ អំពីសេចក្តីសប្បាយរបស់យើង ចំពោះអ្នកធ្វើការ អ្នកលក់ដូរ អ្នកធ្វើសំពត់នឹងអ្នកប្រើប្រាស់ ចំណែកខ្លួនអ្នកមានចំណេះ គឺតែធ្វើសៀវភៅឥតប្រយោជន៍ សំពាប់លក់ឲ្យអ្នកមាន » ។

សំដីទាំងនេះ ពេញដោយសេចក្តីចាក់ដោតដែលមុខជានឹងត្រូវមានសៀវភៅមកផ្តន្ទាមិនខាន ។

អ្នកច្រាជ្រនៅតែស្ងៀម មិនធ្វើយថាអ្វីសោះ ព្រោះគេនិយាយច្រើនពេក ។ ទុកឲ្យចម្បាំងសងសឹកអ្នកច្រាជ្រ ល្អប្រសើរជាងការធ្វើយតបទៅវិញទេ ។

លុះស្រុកកើតសង្គ្រាម ។ ចានបំផ្លាញទំលាំទៅអ្នកទាំងពីរគ្មានសល់។ អ្នកទាំងពីរ តោងតែចេញពីស្រុករៀងខ្លួន ទៅស្វែងរកទីកន្លែងដទៃទៀត។ អ្នកលួងរកទីកន្លែងល្អជ្រកពុំបាន ទៅទីណា តែងមានតម្រាប់មើលងាយ ចំណែកអ្នកច្រាជ្រ ទៅទីណា តែងមានគេទទួលដោយសេចក្តីគួរសម ។ រឿងនេះហើយជាសេចក្តីវិនិច្ឆ័យនៃការដណ្តើមគ្នា រវាងជនទាំងពីរ។

ត្រូវបណ្តោយឲ្យមនុស្សលួងនិយាយតែម្នាក់ឯងចុះ ព្រោះវិជ្ជាមានតម្លៃរួចស្រេចហើយ ។

អាយវាធឹងក្រពះ

ពួកអាយវៈដៃដើង ខាំធំប៉ុន្មាន សឹងអស់កម្លាំងតែរឿងខ្លួន ព្រោះធ្វើការផ្តល់ប្រយោជន៍សម្រាប់តែក្រពះមួយប៉ុណ្ណោះ ។ អាយវៈគិតសាមគ្គីគ្នា ចង់ធ្វើបែបអ្នកមានទ្រព្យម្តង គឺកុំធ្វើអ្វីឲ្យសោះ យកតម្រាប់តាមក្រពះវិញ ។ អាយវៈជំនុំគ្នាថា : « តែអត់ពីយើងតាលណា អាឯងមុខជាស៊ុះឡល់ហើយ យើងធ្វើការចែកគ្រឿសហូរគ្រឿស ទំរឹងដូចជាសត្វពាហនៈ តើសម្រាប់អ្នកណា ? មិនគឺសម្រាប់តែក្រពះម្នាក់ឯង យើងឈប់រវល់ឲ្យសោះ ការនឿយហត់របស់យើង បើសរុបសេចក្តីទៅនៅត្រង់រកសម្រាប់តែកម្នាក់ បើដូច្នេះ ចូរយើងកល់គ្នាឈប់ » ។

– ថាហើយ ឈប់ភ្លាម : ដៃលែងគាន់តាអ្វី ដើងឈប់ដើរទៅណាមកណា ។

អាយវៈប្រាប់ក្រពះថា « ចូរឯងរកស៊ីដោយខ្លួនឯងចុះ » ។

រឿងនេះ គឺជាការគាន់ប្រឡំយ៉ាងធំ ដែលអាយវៈត្រូវតែមានសេចក្តីក្តៅក្រហាយស្តាយក្រោយ ។ មិនយូរប៉ុន្មាន ដៃដើងដួលស្តិកៈ រកកម្លាំងគំរើតគ្មាន ព្រោះភ្លាំចាន់បង្កើតឈាមថ្មីទៅបេះដូង ដើម្បីយកមកចិញ្ចឹមដើងដៃឲ្យមានកម្លាំង ។ គ្រប់អាយវៈសឹងតើតខ្លួ ដូតកម្លាំងទៅណាចាត់អស់ រកគំរើតមិនរួច ។

ហេតុនេះហើយ ទើបពួកអ្នកខ្លះ ដែលឃើញមនុស្សម្នាក់ដែលគេស្មានថាខ្លិល ថាមិនជួយធ្វើការអ្វី ដើម្បីប្រយោជន៍ដល់មនុស្សពាំងឲ្យមនុស្សនោះ ទៅជាសំខាន់ជាងគេឯងពាំងអស់គ្នាទៅវិញក៏មាន ។

៦៥- មេសិង្ហគឺងមេខ្លាឃ្មុំ

មេសិង្ហមួយថាត់កូន ព្រោះព្រានចាប់យកទៅ ។ មេសត្វកំព្រាព្រាត់កូន ស្រែកយំរំពងពេញព្រៃពាំងមូល រកសត្វដទៃធ្វើអ្វីមិនកើត គឺគ្មានសត្វណាមួយដេកជាន ។ ដោយវាចេះតែស្រែកគ្មានឈប់សោះ មេខ្លាឃ្មុំអត់ព្រាំពុំជាន ទើបមានភាពទៅកាន់មេសិង្ហថា : „នែនាងសំឡាញ់ អញសូមសួរនាងតែមួយម៉ាត់ : ចុះកូនសត្វពាំងឲ្យាយដែលប្រព្រឹត្តទៅតាមចន្ទោះធ្មេញនាងពាំងបុំន្មាន តើគ្មានផុកម្ហាយទេឬ ? ។ មេសិង្ហតបថា : „ ច័ពគ្មាន „ ។ – អើបើដូច្នេះ មិនដែលឃើញមានមេសត្វណាមួយ ធ្វើឲ្យអញសង្ឃឹមខ្លះក្បាលសោះ ហើយបើមេសត្វពាំងនេះទៅស្រឡាំមស្លាត់ ចុះហេតុអ្វី នាងឯងក៏មិនស្រឡាំមដូចគេផង ! ។

– ថាដូចម្តេច ? ឲ្យខ្ញុំស្រឡាំម ! ខ្ញុំមានទុក្ខណាស់ ! ឧទ្ទោកអើយ ! ខ្ញុំព្រាត់កូនសំឡាញ់ ដល់ចាស់ទៅ មិនដឹងសំបុកវែងខ្លីឯណាទេ ! „ ។– „នែ ! នាងឯងប្រាថ្នាអញមើល តើនរណាបង្ខំធ្វើខ្លួនឯងឲ្យវេទនា ? „ ។– „អ្នកណាធ្វើ ! គឺព្រះឈ្មោះនិះខ្ញុំ „ ។

សំដីនេះ មានតាំងពីដើមរហូតអស់ឡូវនេះ ជាសំដីរបស់តែមានទៅក្នុងមាត់នៃមនុស្សគ្រប់រូប ~

៣- រឿងបឹងអូលីវ៉ៃយេរ

(តមក)

Le lac des oliviers

រឿងព្រេងជាតិហាន់

Conte de la Nationalité Han

មាណពតន់តមួយស្រុកក់ មានចិត្តព្រួយជាម្តងៗពេក ។ បញ្ហា-
រវស់ខ្លួនមានសារសំខាន់ណាស់ដែរ តែបញ្ហាអ្នកឯទៀត ក៏មានផល
ប្រយោជន៍មុតមាំណាស់ដែរ ។

ដោយមាណពត្រូវយកបញ្ហាតែប៉ុណ្ណឹង ទៅសួរព្រះអាទិទេពនៃ
ទិសបស្ចិម មាណពក៏ប្តេជ្ញាក្នុងចិត្តថា នឹងក្រាបបង្គំទូលសួរព្រះអង្គតែ
បញ្ហាប៉ុណ្ណឹង ថាៈបន់ចោលបញ្ហារវស់ខ្លួនចេញ ។

ព្រះអាទិទេពនៃទិសបស្ចិម ទ្រង់ជាមានមានព្រះហឫទ័យច្រាប់សត្វ
ត្រប់ហើយ ។ មាណពក៏វិលត្រឡប់មកកាន់គេហដ្ឋានវិញ ។

លុះមកដល់មាត់ទន្លេ មាណពជាន់ជួបនឹងនាគ ។ សួរមាណពថាៈ
តើបណ្តាំខ្ញុំយ៉ាងដូចម្តេចទៅ ? ។

មាណពច្រាប់នាគថាៈ « ព្រះអាទិទេព មានព្រះបញ្ជាថាៈ« ត្រូវ
ឲ្យបងនាគឯងបំពេញកុសលពីរដងទៀត ទើបហោះទៅលើអាកាសបាន។
នាគសួរមាណពថាៈ » តើត្រូវឲ្យធ្វើអ្វី? ។ « មាណពតបទៅនាគថាៈ
កុសលទី ១ គឺត្រូវបងនាគឯងបម្លងខ្ញុំទៅត្រើយម្ខាង ។ កុសលទី ២

បង់នាគឯង់ចាប់កន្ត្រាក់ដកគជពីថ្ងាសបង់ឯង់ ។ បើបង់នាគឯង់បានចំពេញ
កុសលចាំង់ពីរយ៉ាង់នេះបាន ទើបបង់នាគឯង់ហើរលើនអាលយ័យបាន ។
នាគកំចម្ងង់មាណពពីត្រើយអាយទៅកាន់ត្រើយនាយ ។ លុះ-
មាណពទៅដល់ត្រើយម្ខាង់ទៀហើយ មាណពនឹង់នាគកំពុងព្យាយាមដក
កន្ត្រាក់ខ្លួនគជចេញពីថ្ងាសនាគ ។ ដល់ដកគជភ្លាក់ចុះហើយ មាន
ស្នែង់ពីរដុះចំកន្លែង់នេះឡើង នាគក៏ហោះទៅលើអាកាសបាន ។ ក្រោយ
ដែលបានហោះឡើង់ទៅលើ កប់ពពក នាគក៏បែរក្បាលត្រឡប់មក
ក្រោយទ្រាប់មាណពថា:

មាណព! មាណព! ដើម្បី សំដែង់ខ្លួនកែតញ្ញាតាធម៌ចាំង់ជ្រាល
ជ្រៅចំពោះប្អូនដែលមានគុណូបការៈដ៏លើសលប់ ចំពោះខ្ញុំ ។ សូមប្អូន
គជរបស់ខ្ញុំទៅប្អូន ចុះជាអនុស្សាវរីយ៍ចុះ ។

មាណព កំដាក់គជនាគទៅក្នុង់ហោប៉ៅ រួចបន្តដំណើរទៅទៀត ។
លុះមកដល់គេហដ្ឋានតាចាស់ ។ សួរមាណពថា: « តើអ្នកបាននាំពាក្យ
ខ្ញុំទៅដំកបព្រះអាទិត្យពេតមែទិសបស្ចិមឬទេ ? ។ មាណពតបទៅ
តាចាស់ថា: « បាទ លោកតា! ព្រះអង្គទ្រង់មានព្រះបញ្ជាថា: ទៅក្រោម
ស្រះនៃបម្ពាតា មានអាង់ទឹកប្រាំបួនតេញដោយមាស អាង់ទឹកប្រាំបួន
តេញដោយប្រាក់ ។ ចូរតាបង្ហូរទឹកអាង់នេះមកក្នុង់ស្រះហើយយកទឹក
ស្រះនេះស្រោច ដល់តែដលភូចធំគ្រប់យ៉ាង់ រួចជាតិចាំង់នោះនឹង់មាន

ផ្លែឆ្លាមិនខាន ។ ។

តាចាស់ហៅកូនប្រុសម្នាក់របស់គាត់មក អ្នកចាំងតីរ ទំព្យាយាមចាប ទឹកចេញពីស្រះតាល់តែងែ ។ រួចមាណពនឹងអ្នកចាំងតីរ ព្យាយាមដឹក ដៃជាតស្រះអស់កាលយ៉ាងយូរ ទើបប្រទះឃើញអាងទឹកធ្វាំបួន អាង ទឹកមួយ គេញៀវដោយមាស អាងទឹកមួយទៀត គេញៀវដោយ ប្រាក់ ។ ដល់ទឹកអាងចាំងតីរហូរមកជ្រាក់ស្រះ ។ នោះវៀវជាមានទឹកថ្នាំ ។ តាចាស់ក៏យកទឹកថ្នាំនោះមកស្រោចដើមក្រូចពោធិ៍សាត់ ក៏មានផ្លែភ្លាម ។ តាចាស់មានចិត្តសោមនស្ស ដោយក្រឡេកវៀវឃើញដើមក្រូចពោធិសាត់ មានផ្លែសំបុរក្រហមដូចមាសជាច្រើន ។ តាចាស់ ឃាត់មាណពឲ្យស្នឹតនៅលេងតំសាន្តសប្បាយ អស់យូរថ្ងៃ ។

មាណពក៏បន្តដំណើរវៀវទៀត ។ តាចាស់ក៏ចែកមាសជ្រាក់ដែលទំដឹកគេឃើញវៀវមាណព ។ លុះមាណពមកដល់ យាយចាស់ ។ ក៏សួរមាណពថា : « ណែវៀវ តើព្រះអាទិទេពនៃទិសបស្ចិម លោកមានពាក្យថាយ៉ាងណាវៀវ ? » ។

– ព្រះអាទិទេពនៃទិសបស្ចិម ព្រះអង្គជ្ញានមានទេវរាជថា : « បុត្រីលោកយាយទឹងនិយាយថាន លុះត្រាតែនាង ប្រទះបុរសណាដែលនាង ពេញចិត្ត » ។

ក្នុងពេលនោះ បុត្រីយាយចាស់ក៏ចូលវៀវក្នុងបន្ទប់នោះ ។ នាង

មានចិត្តអៀនខ្មាសជាខ្លាំង ដោយនាងបានឃើញបុរសម្នាក់អង្គុយនៅជិ-
នោះ ។ នាងមានសាច់មុខឡើងក្រហមដូចបុប្ផាកុលាប ហើយនាង
ញញឹម ហាមាត់ ស្រាប់តែវាចាលាន់ចេញមកថា :

« ម៉ែ ! តើបុរសនេះមកពីណា ? » ។

យាយចាស់មានចិត្តសោមនស្ស សប្បាយរីករាយឥតឧបមា » ។ ក-
បុត្រីគាត់ មុខស្រស់ញញឹម ហើយងឺតក្បែរគាត់ហៀរដោយខ្ជួលខ្ជាវសុក
មង្គលបែបនេះ ។ យាយចាស់គិតថា : « បុរសនេះសភាពធំជាត់ ,
មានចិត្តស្មោះស្ម័គ្រ » ។ យាយចាស់ពោលទៅកាន់បុត្រីគាត់ថា :

« កូនស្រី កូនបានពោលវាចាដ៏លើកដំបូង ! នេះជាកិច្ចសំណាង
កូន ។ ម៉ែសូមឲ្យថ្ងៃនេះជាថ្ងៃនៃវិវាហមង្គលការនៃកូនស្រីចុះ » ។

មាណពនឹងនាងកញ្ញាក៏បានរៀបវិវាហមង្គលការគ្នានឹងគ្នាបានសេចក្តី
សុខសាន្តគ្រាណារហូតអស់អាយុជីវិត ។

« កាយបន្ទន់ ចួលបន្ទប់ ឃើញប្រុសនាង
មុខស្រស់ស្រាយ អាការស្រាង ញញឹមស្រួល
នាងក្រហល ភក្ត្រក្រហម ខ្ទួនរំជួល
ចិត្តខ្មាសអៀន រអាក់រអួល អឹមអៀមចិត្ត ។
ដ្ឋាកុលាប កុលាហល រចលន
រីកក្រអូប ផ្សាយគន្ធ គួរនៃបនិស្ស

នាងញញឹម ទំពោលពាក្យ ស្រាប់ចេញពិត
មួយមាត់មក គួអតីត ពីព្រៃនាយ ។
នាងសួរម្តាយ ថា « ម៉ែអើយ ប្រុសនេះណា
ត្រូវជាអ្វី គួសង្ឃ តាមទំនាយ
យល់ទំនុក តាមទំនៀម គិតវែងឆ្ងាយ
ម៉ែប្រគាស ប្រុសប្រាជ្ញប្រាយ គួព្រៃកូន ។

ស្វាមីកវិយោ ចាំងពីរោងក៏ស្រឡាញ់គ្នាអស់ កាលដំបូរហូតមួយជីវិត។

មាណពក៏លាយាយចាស់ ហើយនាំយកតជមាសប្រាក់ទឹងកវិយា ធ្វើដំណើរតមក ។

លុះមកដល់គេហដ្ឋាន មាណព បានឃើញមាតាវេស់ខ្លួនដែលយំខ្លួញសោក ព្រោះកូនប្រុសធ្វើដំណើរទៅប្រទេសឆ្ងាយ ចាត់សូន្យឈឹងគ្មានដំណឹងសោះឡើយ យំចាល់តែភ្នាក់ភ្នែកចាំងពីរ ។ មាណពមានចិត្តបំណងចង់ឲ្យមាតាឃើញកូនប្រសាស្រី តែបំណងនោះមិនបានដូចសេចក្តីប្រាថ្នា ។ មាតាយកដៃបបោសអង្អែលក័ត្រ កូនប្រសាស្រី ។ មាណពចង់ឲ្យមាតាឃើញមាសប្រាក់ដែលខ្លួនទាំមក តែមាតាបានតែសួរមាសប្រាក់នោះ ។

មាណព បានយកតជដែលក្តីចាំងថ្ងៃ - យប់មកគ្រវីចំពីមុខមាតា តែមាតាមិនបានឃើញស្មើតជនោះយ៉ាងណា គឺឃើញតែយប់ងងឹតទៅស្រអាប់ ។

មាណពគិតថា : « បើមាតាយើងមិនខ្វាក់ភ្នែកទាំងពីរ ម្ល៉េះសមយើងសប្បាយ សែនសប្បាយ ! » ។ ក្នុងពេលនោះ ស្រាប់តែមាតាមាណព មានភ្នែកភ្លឺ មើលទៅយើញច្បាស់ ។

មាណពនឹកឆ្លៀតថា ពាក្យដែលអញសុំ ទាំងប៉ុន្មាន ស្រាប់តែបានដូចសេចក្តីប្រាថ្នា ។

ក្នុងពេលនោះ មាណព ក៏គោលថា : « បើមិនមានពួកសេដ្ឋីឬស្តេចក្រៅពីដែនទេ ប្រហែលជាយើងទាំងអស់គ្នាបានសុខស្រួលហើយក៏ពួកនោះ វិនាសសាបសូន្យអស់គ្នាទេសល់ ។ ដើមមាណពដឹងថា តជាតិនាគនេះ មានឥទ្ធិរិទ្ធិដាក់ស្តែងប្រាកដមែន ។ តជាតិនេះជាតេនវត្តិថ្លៃកអស្ចារ្យណាស់ ព្រោះមានរស្មីភ្លឺច្រឡត់ពេលយប់ ហើយថែមទាំងអ្នកណាចង់សុំអ្វី បានដូចសេចក្តីប្រាថ្នា ។

តាំងតាំងពីថ្ងៃដែលមាណពមកដល់គេហដ្ឋាន ទឹកបឹងអូលីវ៉ាយេវ កកស្អុតប្រែទៅជាថ្លាដូចកញ្ចក់ អ្នកផងដងគាស្រែយបានស្រួល ហើយពួកទុំរ៉ូក្ស អត់ឃ្លានលំហែកគោកយ៉ាក មានដីវិតរស់ទៅ ដោយសុខស្រួលសប្បាយលុះអវសាន ។

ចប់រឿង « បឹងអូលីវ៉ាយេវ » ទៅមានរឿងបែងចំណែកតទៅទៀត ។

សំបុត្រទីពីរ

សៀវភៅនៃធម្មជាតិ

– តើប្រវត្តិសាស្ត្រជាន់ដើមត្រូវបានកត់ត្រាដូចម្តេច?

ក្នុងសំបុត្រមុនៗ ខ្ញុំបានបញ្ជាក់ថា យើងត្រូវសិក្សាប្រវត្តិជាន់ដើមនៃផែនដី អំពីសៀវភៅរបស់ធម្មជាតិ។ សៀវភៅនេះ ធ្វើពីវត្ថុសព្វយ៉ាងគំរប់អស់ ដែលកូនឃើញនៅជុំវិញខ្លួន: ថ្ម ក្រួស ដី ខ្សាច់ សមុទ្រ ភ្នំភ្លើង។ សៀវភៅនេះ តែងបើកត្រជាំជានិច្ចនៅពីមុខយើង តែមានមនុស្សតិចណាស់ដែលចាប់ភ្ជឹកដល់ ហើយល្បងអានសៀវភៅនេះ! បើយើងបានដឹងថា តើត្រូវអានហើយយល់សៀវភៅនេះដែរឬទេណា។ ម៉្លេះសមសៀវភៅនេះ អាចប្រាប់យើងបានខ្លះៗ ប្រវត្តិគំនឹងល្អាយដ៏មានសារសំខាន់យ៉ាងច្រើនដូចម្តេចខ្លះ? ប្រវត្តិគំនឹងល្អាយដែលយើងអាចបានអានក្នុងទំព័រនៃថ្មរបស់សៀវភៅធម្មជាតិ មុខជាមានសារសំខាន់ជាងរឿងព្រេងខេត្តនិទានទៅទៀត។

ហើយអំពីសៀវភៅនៃធម្មជាតិនេះទៀត យើងមុខជាបានដឹងវត្ថុខ្លះ ក្នុងសម័យដ៏យូរលង់ហើយនោះ គាលដែលគ្មានមនុស្ស ឬសត្វរស់នៅលើផែនដីយើងនេះ។ នៅគេលដែលយើងអានបន្តទៅ យើងនឹងឃើញបឋមសត្វគំនឹងល្អាយ ហើយក្រោយមក សត្វគំនឹងល្អាយជាច្រើន

ចានកើតឡើង ។ រួចបន្តមក ទើបមានមនុស្សប្រុស-ស្រីកើតឡើង ប៉ុន្តែ
មនុស្សប្រុស ស្រីនោះ ជាមនុស្សប្លែក អំពីមនុស្សប្រុស-ស្រី ដែល
យើងឃើញសត្វថ្ងៃនេះ ។ គេជាមនុស្សសាហាវ មិនខុសគ្នាពីសត្វតាំង
ព្រៃយេ ។ បន្តិចម្តង ។ គេទិតខំប្រមូលការពិសោធន៍ ហើយចាប់ផ្តើម
គិតពិចារណា ។ អំណាចនៃការគិតពិចារណា ធ្វើឲ្យគេមានសភាពប្លែក
អំពីសត្វតាំងព្រៃយយ៉ាងពិតប្រាកដ ។ នេះគឺជាអំណាចមួយយ៉ាងសក្តិ-
សិទ្ធិ ដែលធ្វើឲ្យគេមានកម្លាំងលើសសត្វដែលធំ ហើយការចសាហាវចំ
ឆុតឆង ។ ឥឡូវនេះ កូនតែងឃើញមនុស្សម្នាក់យ៉ាងតូច អង្គុយលើក្បាល
ដំរីដ៏ធំសម្បើមមួយ ហើយប្រើវាឲ្យធ្វើអ្វីបានតាមប្រាថ្នា ។ ដំរីជាសត្វធំ
ហើយខ្លាំង ជាងហ្វូងម៉ែកដែលអង្គុយលើកវាឆ្ងាយណាស់ ។ ប៉ុន្តែ
ហ្វូងចេះគិតពិចារណា ហើយដោយសារគេចេះគិតពិចារណា គេក៏បានទៅ
ជាម្ចាស់ ឯដំរីវិញ គឺជាអ្នកបំរើរបស់គេ ។ ដូច្នេះ កន្លងពេលដែលការ
គិតពិចារណាចំរើនជុះដាលឡើងនៅក្នុងមនុស្ស មនុស្សក៏ចំរើនតែកន្លងវែ
ហើយមានគតិបណ្ឌិតខ្លាំងឡើង ។ ។ គេបានរកឃើញវត្ថុជាច្រើន :
បង្កាត់ភ្លើងយ៉ាងម៉េច ភ្ជួរស្រែហើយដាំដំណាំយ៉ាងណា ធ្វើសំពត់
ស្លៀកពាក់ ទីធ្លាធ្វើផ្ទះនៅអាស្រ័យយ៉ាងណា ។ មនុស្សប្រុស-ស្រីជា
ច្រើនតែងបានរស់នៅផ្ទុំគ្នា ហើយដោយហេតុនេះ យើងបានមានទីក្រុង
ជាដំបូងឡើង ។ មុនទីក្រុងតាំងឡើងកកើតឡើង ខ្ញុំនឹងជាស្មាក់អា-

ស្រ័យក្នុងលំនៅដូចជាខ្ទុះស្បូកុដ (tente) ។ គេពុំមានចេះដាំដំណាំនៅលើដីទេ ។ គ្មានបន្លែបង្ការទេ ហើយភាគច្រើននៃវត្ថុតាំងឡាយដែលកូនបរិភោគសព្វថ្ងៃ គេពុំដែលបានស្គាល់ទេ ពេលនោះ ។ ទំនងជាមានត្រាប់ឪពុកម្តាយខ្លះ ដែលមនុស្សបរិភោគបានដែរ តែភាគច្រើន គេត្រូវបានរស់នៅ ដោយសារសោចសត្វដែលគេសម្លាប់ ។

នៅពេលដែលទ័ព្រុងតាំងឡាយចំរើនដុះដាលឡើង ប្រជាជនក៏បានចេះដឹងនូវសិល្បៈដ៏ល្អ ៗ ជាច្រើន ។ គេចេះតាំងបានចេះដឹង ដើម្បីសរសេរតត្រាដូចម្តេចផង ។ ប៉ុន្តែអស់កាលយ៉ាងយូរ ពុំមានក្រដាសសម្រាប់សរសេរទេ ហើយប្រជាជនបានប្រើសម្រាប់សរសេរតត្រានៅលើសំបកឈើឈ្មោះ «កោដបត្រ» – ឪពុកគិតថា នេះកាសាអង់គ្លេសហៅ (Birch) [1]– ឬក៏គេសរសេរនៅលើស្បឹកតែ ។ សូម្បីឥឡូវនេះ កូនគង់ឃើញនៅក្នុងបណ្ណាល័យខ្លះ នូវសៀវភៅតាំងមួលដែលសរសេរសម័យ នៅលើស្បឹកតែ ។ ក្រោយមក ទើបមានក្រដាស ហើយក្រដាសស្រួលសរសេរតត្រាជាង ។ ប៉ុន្តែ ពុំមានពុម្ពបោះអក្សរទេ ហើយសៀវភៅតាំងឡាយពុំអាចបានបោះពុម្ពកប់តាន់ក្បាលដូចសត្វថ្ងៃនេះដែរ។ គេអាចសរសេរម្តងបានតែសៀវភៅមួយប៉ុណ្ណោះ រួចហើយចំឡងចេញដោយដៃ ដោយសេចក្តីប្រឹងប្រែង ។ តាមពិត ពុំសូវមានសៀវភៅច្រើនទេ

១– ដើមឈើម្យ៉ាងដែលមានសម្បកាស្តើងហើយស្តើង ។

ពេលនោះ ។ កូនពុំអាចដើរទៅកន្លែងលក់សៀវភៅ ឬបណ្ណាគារដើម្បីទិញសៀវភៅបានទេ ។ កូនត្រូវរកអ្នកណាម្នាក់ បម្លែងសៀវភៅនោះឲ្យហើយ ការបម្លែងនេះ ត្រូវប្រើពេលអស់យ៉ាងយូរ ។ ប៉ុន្តែប្រជាជនក្នុងសម័យនោះ សរសេរអក្សរល្អណាស់ហើយសព្វថ្ងៃនេះយើងមានសៀវភៅសរសេរច្រើន នៅក្នុងបណ្ណាល័យជាង្រាយរបស់យើងដែលគេបានសរសេរដោយដៃយ៉ាងស្អាត ។ ក្នុងប្រទេសវៀតណាម យើងមានជាតិសាសសៀវភៅជាង្រាយសរសេរជាភាសាស្រីត ជាភាសាពាក្យ ខឹងជាភាសាអៀរឌូ ។ មនុស្សអ្នកបម្លែងសៀវភៅ ប្រើនតែគួរជាប្រជ្ញា ខឹងរួមគំនូរ នៅកៀនចំព័រសៀវភៅ ។

ដោយការចំរើនដុះដាលនៃទីក្រុងជាង្រាយ ប្រទេសនីមួយៗជាតិជាង្រាយ ក៏បានកើតឡើង ។ ប្រជាជនដែលរស់នៅជិតខាងគ្នា ក្នុងប្រទេសជាមួយគ្នា គេតែងស្គាល់គ្នាទៅវិញទៅមកយ៉ាងជាក់លាក់ ។ គេស្មានថា គេជាអ្នកមានសមត្ថភាពគ្រាន់បើ ជាងអ្នកឯទៀតដែលរស់នៅក្នុងប្រទេសជាង្រាយឯទៀត ដោយរបៀបលំតុលំបំផុត គេតយប្រហារជាមួយប្រទេសជាង្រាយនោះ ។ គេពុំបានដឹង ហើយសូម្បីតែប្រជាជនសព្វថ្ងៃនេះ ក៏នៅតែមិនដឹង ថាការច្បាំងនឹងការសម្លាប់គ្នាទៅវិញទៅមក ជាការមួយកំណៀចបំផុត ដែលប្រជាជនអាចធ្វើបាន ។ អំពើនេះពុំហុចផលល្អ ដល់បុគ្គលណាមួយឡើយ ។

ដើម្បីរៀនទូវប្រវត្តិនៃសម័យបុរាណរបស់ទឹក្រុង ទឹដ្ឋប្រទេសចាំង-ឡាយ ពេលខ្លះយើងបានពីសៀវភៅចាស់ៗ ។ ប៉ុន្តែសៀវភៅចាំងនោះ ពុំមានច្រើនទេ ។ តែតុំងឡាយផ្សេងពីនេះអាចជួយបាន ។ ព្រះពុទ្ធទឹដ្ឋ ព្រះអធិកជនៃសម័យបុរាណ តែងបានឲ្យគេកត់ត្រាទុកទូវកំណត់ការណ៍ចាំងឡាយក្នុងរាជ្យព្រះអង្គ នៅលើផ្ទាំងសិលាទឹដ្ឋលើស្តម្ភសិលា ។ សៀវភៅ ពុំអាចចិតបៅរៅយូរបានទេ ។ ក្រដាសសៀវភៅ រមែងពុករលួយទឹដ្ឋត្រូវកណ្តៀស៊ី ។ ឯថ្មវិញ រមែងតាំងនៅបានយ៉ាងយូរ ។ កូនប្រវៃលជានៅចាំបាន ស្តម្ភសិលាដ៏ធំរបស់ព្រះបាទអសោក ក្នុងកំងនៅស្រុកអល្លាហាបាដ ។ នៅលើនេះ គេឆ្លាក់នៅលើថ្ម ទូវសេចក្តីប្រកាសរបស់ព្រះបាទអសោកដែលជាព្រះមហាក្សត្រមួយព្រះអង្គនៃប្រទេសឥណ្ឌៀ កាលពីច្រើនរយឆ្នាំ កន្លងទៅហើយ ។ បើកូនទៅសារមន្ទីរនៅឡុកណូវ (Luknow) កូនទឹដ្ឋយើញផ្ទាំងសិលាជាច្រើន ដែលមានតាក្យតេចន៍ចាំងឡាយឆ្លាក់នៅទីនោះ ។

ការសិក្សាប្រវត្តិសាស្ត្របុរាណនៃប្រទេសផ្សេង ។ នាំឲ្យយើងបានដឹងទូវតុំងឡាយដ៏មានតម្លៃ ដែលគេបានសាងឡើងនៅប្រទេសចិន ទឹដ្ឋប្រទេសអេហ្ស៊ីប តាំងពីយូរមកហើយ កាលដែលប្រទេសចាំងឡាយនៅអ៊ីរុប នៅពោរពេញទៅដោយកុលសម្ពន្ធព្រៃផ្សៃនៅឡើយ ។ យើងបានដឹងម្យ៉ាងទៀត ទូវសម័យដ៏រុងរឿងរបស់ប្រទេសឥណ្ឌៀ កាលដែល

រឿងភមាយណៈ ខ្ញុំរឿងមហាភារតៈ ត្រូវបានសរសេរឡើង ហើយ
ប្រទេសឥណ្ឌាជាប្រទេសមួយដ៏សម្បូរសប្បាយ ខ្ញុំមានតេជានុភាព ។
សព្វថ្ងៃនេះ ប្រទេសយើងក្រណាស់ ហើយដនបរទេសត្រួតត្រាយើង(១)។
សូម្បីតែក្នុងប្រទេសរបស់យើង ក៏យើងពុំមានសេរីភាពផង ហើយយើង
ពុំអាចធ្វើអ្វីបាន តាមយើងប្រាថ្នាឡើយ ។ ប៉ុន្តែមិនមែនយ៉ាងនេះរហូតទេ
ហើយបើយើងខិតខំឲ្យមែនទែន ប្រហែលជាយើងអាចធ្វើឲ្យប្រទេស
យើងមានឥស្សរភាពជាថ្មីវិញ ដើម្បីយើងអាចបង្កើនខ្លួនភ័ព្វាសនារបស់
អ្នកក្រ ហើយធ្វើឲ្យប្រទេសឥណ្ឌា គួរជាទីរីករាយខ្ញុំរស់នៅដូចជាប្រ-
ទេសចាំងឡាយនៅអឺរុបសព្វថ្ងៃនេះ ។

ក្នុងសំបុត្រក្រោយ ខ្ញុំពុកនឹងចាប់ផ្តើមប្រវត្តិដ៏គួរចាប់អារម្មណ៍នេះ
របស់ផែនដី តាំងតែពីដើមមក ។

១- សំបុត្រនេះសរសេរតាំងតែពីកាលប្រទេសឥណ្ឌានៅក្រោមអាណាព្យាបាលបរ-
ទេសម្ល៉េះ ។

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរឱ្យឃ្លាង សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

នៅឆមាសទី ១ គឺពីខែមករា ដល់ខែមិថុនា ឆ្នាំ ១៩៦៣ នេះ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានបើកនូវកាលប្រឡងប្រជែងជ្រើសយកឯកសារទំនៀមទម្លាប់ខ្មែរ ២ មុខគឺ

១ – អំពីរឿងព្រេងទាក់ទងដោយប្រវត្តិសាស្ត្រ និងភូមិសាស្ត្រខ្មែរ ;

២ – អំពីជំណឿយោនខ្មែរ ។

ដើម្បីប្រមូលឯកសារចាំង៉ាពីមុខនេះ មកក្សាទុកជាគោលចារឹកសម្រាប់ជាតិតទៅអនាគត ។

ក្នុងរយៈ ៦ ខែ ក្រោយពេលដែលបានប្រកាសហើយ ក្រុមជំនុំ បានទទួលឯកសារចាំង៉ាពីរ ២ មុខនេះចំនួន ៤៨ រឿង អំពីបេក្ខជន ៣៤ រូប ជាបញ្ជីតខ្លះ គ្រហស្ថខ្លះ ដែលបានសរសេរមកដាក់ប្រឡង ។

ក្រុមដំនុំបានជួបជុំពិនិត្យឯកសារចាំងនោះដោយហ្មត់ចត់ទៅ ក៏បានសម្រេចលទ្ធផលពិតប្រាកដដូចតទៅនេះ :

ក – ផ្នែករឿងព្រៃងទាក់ទងដោយប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ:

១– លោក ភ័ន-គួ នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បានជាប់លេខ ១ ត្រូវបានរង្វាន់ ១០០រៀល ។

២– លោក សុះ-នៅ នៅឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល បានជាប់លេខ ២ ត្រូវបានរង្វាន់ ៨០០រៀល ។

៣ – លោក ឃស់-ហ៊ុន សិស្សថ្នាក់ទី ៤ ទំនើប នៃអនុវិទ្យាល័យព្រះកែវនិម្ម « អង្គប្រីយ » ខេត្តតាកែវ បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៦០០រៀល ។

៤ – សាមណេរ លី-ឆ្លួន គង់នៅវត្តសុវណ្ណារង្សី ឃុំអង្គរបានស្រុកតឹមាស ខេត្តកំពង់ចាម បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០រៀល ។

ខ – ផ្នែករឿងជីលយោនខ្មែរ

១ – លោក កង-កែម នៅឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល បានជាប់លេខ ១ ត្រូវបានរង្វាន់ ១០០រៀល ។

២ – លោក សាំង-ឡុង គ្រូបង្ហាត់នៅសាលារៀនប្រាមយ៉ាម ឃុំប្រាមយ៉ាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម បានជាប់លេខ ២ ត្រូវបានរង្វាន់ ៨០០រៀល ។

๓ - លោក គៀត-តឺ នៅឃុំតំពនដំហួន ស្រុកតញាញ ខេត្ត-
តណ្ដាល ជាន់ចំនួន ๓ ត្រូវបានទ្រព្យ ๖๐๐,๐๐ ។

๔ - លោក សេត-សៃ នៅឃុំតាំងក្រសាំង ស្រុកសន្ទុក
ខេត្តតំពង់ធំ ជាន់ចំនួន ๔ ត្រូវបានទ្រព្យ ๘๐๐,๐๐ ។

ក្រៅពីនេះ ក្រុមដំនុំបានទទួលឯកសារផ្សេង ។ គៀតជារឿង
អំពីសមាជិកផ្ទៃយទួនជាបញ្ជីឈ្មោះ ត្រហស្ថះ ដែលបានយកព្រះយ៉ែ
យកចិត្តទុកដាក់ជួយឈឺឆ្អាល កិច្ចការរបស់ក្រុមដំនុំ ដោយយល់ឃ្លាស់
ខ្លះៗតួមប្រយោជន៍នៃប្រវត្តិសាស្ត្ររបស់ជាតិពិត ។ ហើយបានសរសេរឯក
សារមកជូនអំណោយជូនក្រុមដំនុំ ក្នុងធម្មាសនៈ ๑ ឆ្នាំ ๑๙๖๗ ។
ក្រុមដំនុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះអស់លោកជាសមាជិក
ទាំងនោះជាទីបំផុត ។

នៅធម្មាសនៈ ๖ នៃឆ្នាំកុរ ជូនខែធ្នូ ឆ្នាំ ๑๙๖๗ ក្រុម
ជំនុំបានបើកទិវាសប្រឡងប្រជែងចំនេះដឹងខ្លាប់ខ្លួន ๖ រឿងគៀត ស្តីអំពី
របៀបប្រើគៀនក្នុងមន្ត្រីលផ្សេង ។ នឹងផ្ញើរជូនតាមប្រវត្តិសាស្ត្រខ្លះ ។
ប្រទាសប្រឡងនេះបានចែកជូនខ្លួនហើយ ប៉ុន្តែអស់លោកអ្នកបាន
ជ្រាបហើយត្រូវការប្រឡង សូមសរសេរឈ្មោះទៅជាក់ប្រឡង តាមកាល
បរិច្ឆេទដូចគោលទាន់ហើ ។

ក្រុមដំនុំសូមសង្ឃឹមទុកជាមុន ។

ប្រវត្តិនៃវត្តឧណ្ណាលោម

ក្រុងភ្នំពេញ

រៀបរៀងដោយសម្តេចព្រះមហាសុមេធាធិបតី

ជួន - ណាត

ជោគញ្ញាណា

ប្រវត្តិនៃវត្តឧណ្ណាលោម មានការខាត់ខ្នង់គ្នាទឹងព្រះពុទ្ធសាសនានៃប្រទេសកម្ពុជាខ្លះផង បើលុះតែស្រង់យកឯកសារចាស់ក្នុងក្រុងកម្ពុជាដោយសង្ខេបខ្លះ មកសៀបរៀងហើយ ទើបប្រវត្តិនៃវត្តឧណ្ណាលោម អាចបង្ហើលហេតុការណ៍ខ្លះឲ្យជាក់ច្បាស់ឡើងបាន រៀវលងតែប្រព្រឹត្តិការណ៍ខ្លះ ពីក្នុងអតីតកាលយូរអង្វែងហើយ ដូចយ៉ាងកំណើតនៃ មហាវេតិយឧណ្ណាលោម ជាដើម ដែលពុំដឹងជាកើតមានពីកន្លងសម័យណា ព្រោះព្រះពុទ្ធសាសនាពុំបានចែងច្បាស់ ។

ក្នុងព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា មានសេចក្តីថ្លែងថា ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់គ្រប់គ្រងរាជសម្បត្តិគង់នៅក្នុងព្រះបរមរាជវាំង មហានគរ (នគរធំ) បាន ១៩ ឆ្នាំ លុះដល់ឆ្នាំតំរប់ ១៦ នៃរជ្ជកាលរបស់ព្រះអង្គ ទើបទ្រង់មានព្រះឃោបល់យល់ថា ទឹងត្រាំនៅក្នុងមហានគរនេះ តទៅខ្មៀតពុំកើត ក៏មានព្រះរាជបញ្ជាឲ្យ



នេះព្រះវិហារថ្មី វត្តឧណ្ណាលោម ដែលទើបកសាងនឹងសម្ពោធនៅថ្ងៃទី ១-២-៣-៤ មិថុនា ១៩៦៣ ក្នុងសម័យសម្តេចមុនី នឹង
សមេចព្រះមហាសុមេធាធិបតី សង្ឃនាយកព្រះនាម ជួន - ណាត (ជោតញ្ញាណ) ។

គសាន៍ព្រះពន្លកំនិច្ចរៀ ជួលថាគារ ណា ក្នុងខែត្រស្រីសឈរ តំក្នុង
ស្រុកស្រីសន្ធរ ខែត្រកំពង់ចាមសព្វថ្ងៃនេះ ។

នៅថ្ងៃ១៣រោចខែមិគសិរ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ១៩៧៦
ចុល្លសករាជ ៧៩៦ គ្រិស្តសករាជ ១៤៣៤ ព្រះបាទសម្តេចព្រះបរមរាជា
(តញ្ញាយ៉ាត) ទ្រង់ស្តេចយាងចេញចាកមហានគរ មួយមាខ្ញុំដោយយាន
សៅគាមាត្យនាម៉ឺនសព្វមុខមន្ត្រីជាដើម ដោយព្រះពិធីតាំងនាគរាមដល-
មាគាមក លុះថ្ងៃ១៥កើតខែបុស្ស ឆ្នាំជូតទោស័កទុះឯង ទើបស្តេច
យាងដល់ជួលបាសាណ ស្តេចគង់នៅជាសុខសម្រាន្តក្នុង ព្រះពន្ធភំព
មាសាណ នោះបានត្រឹមតែជាង ១ ឆ្នាំប៉ុណ្ណោះ ដោយទឹកខ្យែចេះតែ
ខ្សែងលិចទីនោះកាល់ឆ្នាំ ទើបព្រះអង្គមានព្រះរាជបញ្ជាឲ្យ សម្តេច
ចៅពញា (កែវ) ខឹង ឧកញ៉ាហោរាធិបតី(ខៀវ) ព្រម
ដោយមន្ត្រីឯទៀតខ្លះផង ដែលស្គាល់ទីដីមានជយភូមិ ឲ្យទៅពិនិត្យមើល
ទីដីនៅជិត ក្នុងចន្លោះពេញ ឃើញថាទីដីនៅខាងទិសឥសាន្តយ៉ៅ ក្បែរភូមិ
មានជយភូមិល្អ ព្រះអង្គក៏មានព្រះរាជបញ្ជា ឲ្យតសាន៍ព្រះពន្លកំនិច្ច
ត្រង់ទីនោះ ។

នៅថ្ងៃ៨កើត ខែពិសាខ ឆ្នាំទាសធស័ក ព.ស. ១៩៧៨ ច.ស.
៧៩៦ គ.ស. ១៤៣៤ ព្រះបាទសម្តេចព្រះបរមរាជា (តញ្ញាយ៉ាត)
ស្តេចយាងចេញចាកព្រះពន្លកំនិចបាសាណ នៅថ្ងៃ១៥កើត ខែពិសាខ

ខ្ទុះឯង ស្តេចយាងចូលគង់ក្នុងព្រះរាជវាំងថ្មី នៅទិសអគ្នេយ៍ក្នុងដូនពេញ។

នៅថ្ងៃ១១ កេះ ខែពិសាខ ឆ្នាំម្សាញ់ទស័ក ព.ស. ១៨៨១ ច.ស. ៧៨៩ គ.ស. ១៤៣៧ ព្រះអង្គប្រទានឱ្យក្រុងថ្មីនេះថា ក្រុងចតុម្មុខមង្គល ឯខេត្ត ៤ មុខដែលគេភ្ជាប់ហៅថា ខេត្តច្រាប-ឈាម មកយូរហើយ ទ្រង់ប្រទានឈ្មោះថា ខេត្តចតុម្មុខបូកាំ វិញ ។ ល ។ ព្រះអង្គមានព្រះបញ្ជាឱ្យ ឧកញ៉ាតេជោ (ស្រី) ចៅហ្វាយស្រុកសំរោងខេត្ត ជាអ្នកកាន់តាម លើកដីចាក់លុបបំពេញគ្រែក្នុងថ្មី ទាំងឱ្យយកដីចាក់បំពេញក្នុងដូនពេញ ឱ្យកែងខ្ពស់ឡើងផង ។ គ្រែ-ហ្លួងជ្រៅ ដែលកើតពីការដីកយកដីនោះ ជាប់មានឈ្មោះថា បឹងតេជោ រៀងមក គឺទឹកត្រង់ផ្សារថ្មីសព្វថ្ងៃនេះ ។ ល ។ ទ្រង់មានព្រះរាជបញ្ជាឱ្យ ឧកញ៉ាដុង ចៅហ្វាយស្រុកបាទី កាន់តាមដីកព្រែក ១ ជាប់ហៅថា ព្រែកឧកញ៉ាដុង លុះចំណេរកាលតមក ហៅថា ព្រែកតាម ដុង គឺត្រង់កន្ទែងសួនវែងសព្វថ្ងៃ នៅខាងកើតព្រះសាក្យមុនីចេតិយ សព្វ ថ្ងៃនេះ ។ ល ។

ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់មានព្រះរាជបញ្ជា ឱ្យកសាងវិហារ លើទីដ៏ខ្ពស់ ដែលចាក់ថែមថ្មី ត្រង់កន្ទែងវិហារចាស់របស់ ដូនពេញ ឱ្យកសាងចេតិយធំ ១ ពីខាងក្រោយវិហារ ។ ល ។ ទ្រង់ បញ្ជាតឱ្យហៅវត្តកុំដូនពេញថា វត្តព្រះចេតិយបតិត ដូច្នេះវិញ



ព្រះពុទ្ធរូបធំអង្គនេះ គង់នៅជាន់ទី ៣ នៃព្រះវិហារវត្តឧណ្ណាលោម តំណាងព្រះពុទ្ធរូបព្រះនាម
ព្រះស្រីការលេញ កសាងឡើងក្នុងរជ្ជកាលសម្តេចព្រះបរមរាជា ពញាយ៉ាត ព.ស. ១៩៩១
គ ស.១៤៣៧

(លុះចំណែកាលតមក មហាជនមែរជាហៅវត្តនេះថា វត្តក្នុងដួងពេញ ផ្នែកខ្លះហៅថា វត្តក្នុងពេញ ជាប់តរៀងមក) ។ ព្រះចំមានព្រះរាជបញ្ជាឲ្យកសាងវត្ត ៦ ដងវែរៀតគឺ ១- វត្តកោះ នៅត្រចំទិសខាងកើតដៀងអន្លង់ កំដួងពេញ ។ ២- វត្តលង្កា នៅត្រចំទិសខាងតែតដៀងឆ្ងាំសាន កំដួងពេញ ។ ៣- វត្តព្រះពុទ្ធយោសា នៅត្រចំខាងត្បូងត្រែកចំនងដំដែក ខាងទិសខាងជើង កំដួងពេញ ។ បានជាព្រះរាជទានមកវត្តទាំង ៣ នេះដូច្នេះ ដើម្បីឲ្យសមនឹងដំណើរឈ្មោះថាព្រះពុទ្ធយោសាចារ្យ នៅចម្ងាយតម្លាត់ពីកោះសើរលង្កា ។ ៤- វត្តតាមន្ទុល នៅខាងទិសអន្លង់ កំដួងពេញ ដែតជាប់នឹងមាត់ត្រែកទុកញ៉ាំទូនឲ្យបន្តិច ពីវត្តកោះ ។ ព្រះពុទ្ធរូបអង្គធំ ដែលដំកល់តនឹងវិហារវត្តតាមន្ទុលនេះ មានព្រះនាមថា ព្រះស្រែកោលេញ ព្រោះតែមានសាសនាសណ្ឋានរំលេចស្រែរៀងនឹងស្រែកត្រែលេញ[1] ។ ៥- វត្តឧណ្ណាលោម

១- ព្រះស្រែកលេញអន្លង់នេះហើយ ដែលលោកាចារ្យភក្តីសង្គ្រាម (ហុក) ជាអមិទ្ធមានក្តៅឈ្លោះប្តឹងប្តូច ជាទូលទៅកោះសំរួងសង្ឃនៅពេលយប់ ម្តងនឹងចុះហែលទឹកទៅលិបអញ្ជើញស្តេច សម្តេចព្រះសង្ឃត្រឹងជាព្រះជនន៍ ៣ ព្រះដោយសម្តេចព្រះដែយបេស្តាឲ្យជាន្យូងចុះតែតណ្តាប់ដៃនៃសង្ឃនៅត្រើយបង្ហិ ក្នុងភូមិសង្កាត់ទី ២៣ ។ លុះចំណោកាលមកខាងមុខ ព្រះពុទ្ធរូបស្រែកលេញអន្លង់នេះ បានផុតប្រឹស្តាំស្ពានក្នុងវត្តឧណ្ណាលោម តំព្រះពុទ្ធរូបអន្លង់ធំ ក្នុងវិហារវត្តឧណ្ណាលោមសព្វថ្ងៃនេះ ដែលជាន្យូងដុំលអស់ជាង ៣ ជើងហើយ ឯព្រះនាមថា ព្រះស្រែកលេញនេះ ចំណុចជាតំទៅ ឥតមានលេចឮឡើយ ។

ដែលមានឧទាមនេះ ស្រេចស្រាប់មកយូរហើយ ជាឧទាមនៃចេតិយធំ ចំកណ្តាលចេតិយចាំង ៤ ទៅខាងលិចវិហារវត្ត ១ ណ្ណាលោមសព្វថ្ងៃនេះ ។

៦- វត្តឧបតាយ៉ង ដោយយកឧទាមតាម្នាក់ឈ្មោះ យ៉ង ដែលជាអ្នកដឹកនាំ លុះចំណេរកាលមកខាងមុខ វត្តឧបតាយ៉ងគឺវត្តបទុមវតីសព្វថ្ងៃនេះ ។

ថ្ងៃ ១១ កើតខែពិសាខ ឆ្នាំចចត្វាស័ក ព.ស ១៩៨៦ ច.ស.៨០៤ គ.ស.១៤៤២ ព្រះចុងសម្តេចព្រះបរមកជា (ពញាយ៉ាត) ព្រមដោយខ្ញុំពុជការត្រួតដំណែង ខណ:សង្ឃ មានសម្តេចព្រះសុគន្ធាធិបតី ជាប្រមុខ បានធ្វើបុណ្យបញ្ចុះសីមា ត្រួតវត្តចាំង ៧ មានវត្តព្រះចេតិយបពិតជាដើមទីព្រះពុជពិធី ជាការកុសលផ្សេង ។ (១) ។ ល ។

វត្តឧណ្ណាលោម ក្នុងសម័យតមក

ឧណ្ណាលោម ជាពាក្យបាលី ពាក្យសំស្ក្រឹតថា ឧណាលោម ប្រែថា «រោមប្រដុំចិញ្ចើម» គឺរោមដែលដុះត្រង់ប្រដុំចិញ្ចើមចាំងពីរផ្សេងគ្នាពីរោមចិញ្ចើមប្រក្រតី ។ ក្នុងព្រះពុជពង្សាវតារច្រាប់ថា ព្រះចុងសម្តេចព្រះបរមកជា (ពញាយ៉ាត) ទ្រង់ប្រទានឧទាមវត្តនេះ តាមឧទាម

១- ឆ្លៀតឱកាសរៀបរាប់ដោយព្រះពុជពង្សាវតារច្រាប់ព្រះនាមនៃសម្តេចព្រះសុគន្ធាធិបតី ខំងតាមព្រមទាំងសមណស័ក្តិនៃព្រះពុជាគណ ហាតានុក្រមសង្ឃ ខំងណោះចៅអធិការនៃវត្តទាំង ៧ ក្នុងរជ្ជកាលនេះហើយ ។

ព្រះចៅសំបួកឯណើត សម្តេចព្រះនាតួន ស៊ីហនុ ទទួលភ្ញៀវ ព្រះប្រមុខរដ្ឋកម្ពុជា ទ្រង់គាំទ្រដាក់ពាក្យបណ្តឹងទៅតុលាការយុត្តិធម៌ព្រះសង្ឃ ព្រះនាតួន
អាវ - ១៨ ក្នុងការបិទបញ្ចប់សៀវភៅរបស់ព្រះអង្គ នៅថ្ងៃទី ១-៦-៣-៤ ម៉ឺនិ ១៩៦៣ ។

ដើមស្រាប់ ជានាមនៃចេតិយធំ ដែលឋិតក្នុងព្រះទណ្ឌារាមនៃ ព្រះអស្សដិតន្តេរ ។ រឿងនេះ សម្តេចព្រះមហាសង្ឃរាជព្រះជាម:ធៀង (ស៊ុំណាគសារ) មានព្រះបន្ទូលថា ចេតិយធំ ឥដ្ឋព្រះពុទ្ធរូបអង្គធំ ដែលប្រតិស្ឋានក្នុងឆ្នេរខាងក្រោមនៃមហាចេតិយនោះ មានភាសាបរម្បរកតរាមកថា នេតកសាន តាំងពីកន្លងសម័យដែលព្រះពុទ្ធសាសនាផ្សាយចូលមកកាន់ប្រទេសកម្ពុជានេះ ជាដំបូងបង្អស់ ទីដែលនេតកសាន៍ចេតិយធំនេះ កាលព័ដើម ជាជិត្តសំជាងធំដ៏ដឹងខ្ពស់ ក្នុងតំបន់នេះផ្ទួជាគោរពបូជាមួយ ។ គ្រានោះដែលថាបង្កុះព្រះទណ្ឌារាមនៃព្រះអស្សដិតន្តេរនោះ សម្តេចព្រះមហាសង្ឃរាជ មានព្រះបន្ទូលថា ជាពាក្យបរម្បរកតរាមកដែរ តាំងពីជាព្រះអស្សដិតន្តេរនោះ កន្លងផុតកាលនៃព្រះមហាក្សត្រអង្គណា កន្លងសម័យណាទេ តាំងចេតិយធំនឹងព្រះពុទ្ធរូបអង្គធំនោះ ក៏តាំងពីជាព្រះមហាក្សត្រិយ៍អង្គណា ឬលោកណា ឈ្មោះអ្វីគេសោះឡើយ ។

តួអស់លោកអ្នកអានប្រវត្តិនេះ សង្កេតពិនិត្យមើលសណ្ឋានទ្រង់ទ្រាយចេតិយធំកណ្តាល ដែលហៅថា ចេតិយ ឧណ្ណាលោម ក៏គង់អាចជ្រាប ព្រមទាំងស្មានបានទៀតថា ក្នុងប្រទេសកម្ពុជាតាំងមួល ឬនោះតាំងក្នុងប្រទេសតូចសាសនិគមដទៃទៀតក៏ដោយ មានតែចេតិយឧណ្ណាលោមនេះឯង ដែលមានរូបរាងតែមានពីរ ។ ចំណែកមានព្រះពុទ្ធរូបអង្គធំ ដែលប្រតិស្ឋានចំកណ្តាលរង្វង់មានគ្រែម នៃចេតិយធំនេះ

កំមានទ្រង់ទ្រាយដូចគ្នា នឹងព្រះពុទ្ធរូបថ្មតាំងឆ្ងាយ ក្នុងសម័យបុរាណ ត្រង់នាយនោះដែរ ។

ប្រវត្តិនៃវត្តទណ្ឌាលោម មានរឿងកំប៉ាំងខាងដើមដូចពណ៌នាមកនេះឯង ។ លុះចំណេរកាលតទៅមក ទើបប្រវត្តិនៃវត្តនេះ មានរូបភាពត្រូវថ្លង់បាន តាមលំដាប់កាល ដូចមានសេចក្តីរៀបរាប់តទៅនេះ ៖

លុះមកដល់ពុទ្ធសករាជ្យទី ២៣ គឺកាលព័ន្ធចចត្តាស័ក ព.ស. ២២៣៨ ច.ស. ១០៥៦ គ.ស. ១៦៩៤ ក្នុងរជ្ជកាលនៃ ព្រះបាទសម្តេចព្រះជ័យចេស្តា ក្នុងព្រះរាជពង្សាវតារខ្មែរ មានថ្លែងប្រាប់ថា ព្រះពោធិវង្ស(ឯក) ចៅអធិការវត្តទណ្ឌាលោម នឹងព្រះស្រីសង្ឃាមមុនី (អឺ) ចៅអធិការវត្តព្រះចេតិយបព៌ត បានថ្វាយព្រះពរព្រះរាជាថា ខ័ដ៏ខ្ពស់ព្រះស្រីនេះ ចង្អៀតណាស់ ពុំសមល្មមនឹងកសាងព្រះរាជវាំង តាមព្រះរាជហឫទ័យផ្ដងនោះទេ បើសព្វព្រះរាជហឫទ័យនឹងកសាងព្រះរាជវាំងថ្មី ខុកជាខ័ស្តើក ដល់ការមានជ័យ ឈ្នះបច្ចាមិត្រនោះគួរកសាង នៅខ័ដីតបំផឹងក្បែនវិញ ព្រោះមានខ័ដ៏ខ្ពស់ល្អ ។ ព្រះបាទសម្តេចព្រះជ័យចេស្តា ក៏សព្វព្រះរាជហឫទ័យយល់ស្របតាម ហើយព្រះអង្គមានព្រះរាជបញ្ជា ឲ្យកសាងព្រះរាជវាំងមួយ នៅដីតបំផឹងក្បែន ហៅថា ព្រះរាជកំផង់បំផង់ក្បែន នៅខាងទិសពាយព្យនៃក្រុងកំពេញសព្វថ្ងៃ ប៉ុន្តែឥឡូវនេះ ព្រះបរមរាជវាំងនោះ រលំរលាយបាត់បែកបាក់



កំពូលព្រះវិហារវត្តចណ្ណាលោម ក្នុងរាត្រីដែលមានតាំងភ្លើងអគ្គិសនី នៅពេលពិធីបុណ្យបញ្ចុះ
ខណ្ឌសីមា និងសម្ពោធ ពីថ្ងៃទី ១-២-៣-៤ មិថុនា ១៩៦៣ ។

អស់ទៅហើយ ។ ក្នុងវដ្តកាលនេះ ព្រះសោធិវង្ស (ឯក) នោះ ជាទី
ប្រឹក្សា ក្នុងការផ្ទៀងផ្ទាត់ច្បាប់សម្រាប់តុលាការ ដែលចាស់ទុំហៅថា
ក្រមច្បាប់ព្រះជ័យជេស្ឋា នោះឯង តាំងច្បាប់វិន័យខាងព្រះពុទ្ធ-
សាសនា ក៏បានតាំងផ្ទៀងផ្ទាត់តម្រឹមតម្រង់ផងដែរ ។

សេចក្តីឲ្យយើញថា តាំងពីវដ្តកាលនៃព្រះបាទសម្តេចព្រះបរម-
កជា (ពញាយ៉ាត) រៀងរហូតមកដល់សម័យបច្ចុប្បន្ន វត្តទណ្ឌាលោម
រមែងតែមានតក្កសង្ឃ នៅជាប់ មិនដែលដាច់ដកបមក គ្រាន់តែពុំច្បាស់ថា
តំណទៅអធិការពីមួយមកមួយទៀតតៗគ្នារៀងមក តើមានប៉ុន្មានតំណ
ហើយ ? មាននាមអ្វីខ្លះ ? សុទ្ធតែមានសមណស័ក្តិជាអ្វីខ្លះ? ឬរបៀបខ្លះឥត
មានសមណស័ក្តិជាអ្វីទេ ប៉ុណ្ណេះឯង ។ ក្នុងព្រះពុទ្ធសាសនាវារ មាន
សេចក្តីបញ្ជាក់ច្បាស់ត្រឹមតែ ព្រះសោធិវង្ស (ឯក) មួយរូបប៉ុណ្ណោះ
ក្នុងវដ្តកាលនៃ ព្រះចាន្ទសម្តេចព្រះជ័យជេស្ឋា (ព.ស.២២៣៨
ច.ស. ១០៥៦ គ.ស. ១៦៩៤ គិតមកដល់ ព.ស. ២៥០៥ នេះយើញ
៦៦៧ឬ ៦៦៨ ឆ្នាំហើយ) ។ លុះមកវដ្តកាលនៃ ព្រះចាន្ទសម្តេច
ព្រះនរោត្តម (បរមកមទៅវិតារ) ដែលព្រះអង្គស្តេចយាងចេញចាក
ក្រុងទៅជួន្តមានជ័យ មកគង់ក្នុងក្រុងកំពង់ចេញ ទើបប្រវត្តិនៃវត្តទណ្ឌាលោម
ជាក់ច្បាស់ តាមលំដាប់កាលរៀងរហូតមក ដូចមានសេចក្តីរៀបរៀងត
ទៅនេះ ។

(ទៅមានត)

សេចក្តីជូនដំណឹង

ដោយទស្សនាវដ្តីយើងលេខ ៧ នេះ មានអត្ថបទខ្លះត្រូវបោះបញ្ចប់ហើយមិនគួរនឹងយកអត្ថបទផ្សេងមកបន្ថែមបន្ត ព្រោះមានដំណើរវឿងខ្លះគ្នា ទើបយើញមានចំនួនទំព័រមិនសមល្មមដូចលេខមុន ។ ។ ក្នុងលេខ ៨ យើងនឹងបន្ថែមទំព័រឲ្យហួសពីចំនួនធម្មតា ដើម្បីបង្រួបបង្រួមការខ្វះខាត ក្នុងលេខ ៧ នេះ ។

ពុទ្ធសាសនបណ្ឌិត្យ

ភ័ទ្ធជសទិយា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៥ លេខ ៨ ខែ សីហា


ព. ស. ២៥០៥ គ. ស. ១៩៦៣

- ភ្នំពេញ -



ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ កសាងនៅ ព. ស. ២៥០១ គ. ស. ១៩៥៨ ភ្នំពេញ សម្រាប់ឧត្តមសិក្សាខាងព្រះពុទ្ធសាសនា

ស.ព.ស ២៥៦០-២០១៦



វត្ថុសិទ្ធិ

ទស្សនាវដ្តី ផ្សាយខាងសាសនា ធំឯអក្សរសាស្ត្រ

បេឡាពាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា	ទំព័រ
– រឿងមនុស្សស្លាប់ កើតឡើងរស្មីដឹងដាតិ (វិចារណកថា) លោក ផេង-ជ្រឿ តែងរៀបរៀង (តបច់)	៧៣៩
– ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ី ប្រែរៀបរៀង (ត)	៧៤៥
– អាថ៌កំបាំងរបស់ពុទ្ធសាសនា លោក ប៊ូ-ប៊ី រៀបរៀង (ត)	៧៥២
– មហោសាថិដាតក (ត)	៧៥៧

ផ្នែកអក្សរសាស្ត្រ	
- ទឹពុកម្តាយមានទេបការគុណលើកូនមែនឬទឹមិនមែន? (វិចារណកថា) ផេង-ជ្រឿ រៀង (តបច់)	៧៧៥
– អក្សរសាស្ត្រខ្មែរ សិលាចារឹក ន័យ-នន្ទ ស្រាវជ្រាវ ដោយ ន-តាម (តបច់)	៧៨៦
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជឹង-ទាត់ រៀបរៀង (ត)	៧៩៥
– រឿងសាមកុក លោកអ្នកឧកញ៉ាវិបុលរាជសេដ្ឋី ទួ-ពេ ប្រែរៀបរៀង (ត)	៧៩៨
– ល្បើកឡាហ្វុងតែន លោក ផេង-ជ្រឿ ប្រែពីភាសាយួនជាភាសាខ្មែរ (ត)	៨០៧
– រឿងព្រៃងពួកតុង លោក ភ័យ-ប៊ុក ប្រែពីភាសាយួនជាភាសាខ្មែរ (ត)	៨២៤
– សំបុត្រទី ៣ ទី ៤ របស់លោកឧកញ៉ាអ្នកនាំទៅប្រគល់លោក តាមចាងលស្ស៊ី (សៀវភៅនៃធម្មជាតិ) លោក ឈរ-អៀម ប្រែពីភាសាអង់គ្លេស	៨៣៣
– ឯកសារចំរៀមរម្លាប់ខ្មែរ រឿងដំណាលបាន	៨៤៥

ផ្នែកកំណត់ទឹងប្រវត្តិការណ៍	
– ប្រវត្តិវត្តឧណ្ណាមលោម (ត)	៨៥៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃដាវ ៤៣០រ៉ូ០០

ភាសិតនៃទេវតា ធ្វើការអាក្រក់
ដោយសាមគ្គី ឲ្យធ្វើល្អទៅ
ឲ្យចុះចាញ់ជំនួស កុំឲ្យហ្នឹងសៅ
ប៉ះរហែកហៅ ពុទ្ធសាសនា

វិចារណាកថា

រឿងមនុស្សស្លាប់កើតឡើងវិញជាដំបងជាតិ (តបប់)

លោក នេង ទ្រីវ រៀបរៀង

ដូចរឿងមួយក្នុងតម្ពីរសោតត្តសង្គហៈ តណិនាថា ៖ មានបុរសម្នាក់ចាន រៀបការប្រពន្ធ រួចយកមកនៅឯផ្ទះឪពុកម្តាយខ្លួន ។ បុរសនេះមានប្អូនប្រុសមួយ ចិត្តមិនស្មូតត្រង់ ក៏ទៅលបសហាយស្មន់នឹងភរិយារបស់ខ្លួនដែលជាស្រីក្បត់ចិត្តប្តី ។ ដោយស្រឡាញ់ប្អូនថ្លៃពេក មិនដឹងគិតយ៉ាងណា ដើម្បីបំបែកប្តីចេញពីខ្លួនបាន នាងចិត្តគំរើយ លួចធ្វើឃាតកម្ម ចំពោះប្តីអាត្មាស្ងាប់ទៅ ។ ដោយមានសេចក្តីស្នេហាជាប់ព័ន្ធព័ទ្ធទៅលើភរិយាក្រែពេក បុរសស្វាមី លុះស្ងាប់ទៅ មកកើតជាសត្វតុកកែដែលតែងតែសំឡឹងចំពោះភរិយា ដោយចិត្តប្រតិព័ទ្ធជាពស់ថ្លែ ។ ថ្ងៃមួយ តុកកែចំនោតឮដង្ហឹមផ្ទះ សំឡឹងមកភរិយាដែលអង្គុយសន្ទនាកំសាន្តជា

មួយប្តីក្រាយ កំស្រាប់តែក្មេចស្មាតើ រលេះដើងពីធ្លឹម ភ្ញាក់មកលើនាង
ភរិយា ។ ក្តៅចិត្ត យកដំបងវាយតុកតែនោះស្លាប់ទៅ ។ មិនអស់សេចក្តី
ស្នេហាក្នុងភរិយា តុកតែស្លាប់ទៅ មកកើតជាកូនឆ្កែក្នុងផ្ទះនោះ ។
តាំងពីដើងក្តីកាលណា កូនឆ្កែ តែងដើរតាមនាងភរិយា រហូតដល់ធំ ។
គេះមៅនុះក្តី គេះទៅស្រែក្តី ឆ្កែនោះតែងដើរតាមនាង ហើយលោត
ប្រឡែងជាមួយនង ។ មានមួយថ្ងៃ ព្រឹកក្មេងកំព្រោះ និយាយចំអកចំ-
អន់ឲ្យនាងភរិយាថា: « យើងចាំមើលគ្រានឆ្កែដែលទៅបរបាញ់ ខៀង
តែបានសាច់យកមក ហើយពួកយើងនឹងត្រូវបានខួលភាននោយសារជា
មិនភាន » ។ ពាក្យចំអកចំអន់នេះ តែងឮជាញឹកញយ នាងភរិយា
នឹកអៀនខ្មាស ខ្លាចក្រែងគេជាខ្លួនស្រឡាញ់ឆ្កែ ទើបសម្លាប់ឆ្កែនោះទៀត
ទៅ ។ សេចក្តីស្នេហាក៏ទៅមិនជាន់អស់ ឆ្កែ លុះស្លាប់ទៅ មកកើត
ជាកូនគោ ក្នុងផ្ទះនាងនោះដដែល ។ កូនគោក៏ដូចឆ្កែទៀត តែងតែ
ដើរតាមនាងភរិយា នាងនេះ បានខួលពាក្យចំអកឡកឡឺយដូចមុនទៀត
រអៀសខ្លួនក៏សម្លាប់គោចោលទៅ ។ ឆ្នង់នេះ ស្លាប់ពីគោ បុរសនោះ
មកកើតជាកូនភរិយាបេស់ខ្លួន ។ តាំងតែកើតមក ពាក្យប្តី តែងតែស្រែក
យំ គាលណាម្តាយមកចាប់ពាល់ គឺថាម្តាយពាល់មិនបានសោះ ។
ឃើញដូច្នោះ ជីដូនយកទៅទៅចិញ្ចឹមបីបាច់ថែរក្សារហូតដល់បានដឹងក្តី
ពេនិយាយស្តាប់បាន ជីដូនលួចសួរទៅថា ហេតុម្តេចក៏មិនព្រមឲ្យម្តាយ

តាល់សោះ ? ។ កុមារនោះច្រណែនថា នាងនេះបានសម្លាប់ខ្លួនបី - បួន ជាតិហើយ : គឺកាលនៅជាកូនតូច ជាតុកតែកម្ពង់ ជាឆ្កែម្ពង់ ជាគោម្ពង់ ចុងក្រោយចំផុត ។

ចំពោះរឿងនេះ យើញថាអ្នកដែលដឹងជាតិ ច្រើនតែអ្នកស្លាប់ហើយកើតមកវិញនៅទីស្សរ។ នោះ មិនឆ្ងាយពីទីកន្លែងដើមប៉ុន្មានឡើយ ។

អំពីមនុស្សស្លាប់ យោបល់របស់ខ្ញុំដូចេ្នះ : សត្វដែលស្លាប់ហើយត្រូវតែទៅកកើតថ្មីទៀតដើម្បីកើត ក្នុងពេលដែលខ្លួនមិនទាន់សម្រេចព្រះនិព្វាន ។ ចំពោះវិញ្ញាណរបស់សត្វដែលស្លាប់ហើយ តាមសេចក្តីក្នុងព្រះអភិធម្មថាត្រូវកើតភ្លាម ក្នុងភពណាមួយ តាមកម្មរបស់ខ្លួន ។ តាមលទ្ធិយោគីភមចរកៈ ថាកើតភ្លាមខ្លះ ថាត្រូវទៅគ្រាច់រៃលាល់ស្សរ។ នោះខ្លះ។ ចំពោះភពៈទាំងពីរនេះ បើសង្កេតន្ទៅអត្ថន័យយ៉ាងជ្រៅទៅគឺហាក់ដូចជាស្របគ្នាដែរ ព្រោះពុទ្ធដីកាទប្រកាសថា អ្វី។ ក្នុងលោក សុទ្ធសឹងជាវត្ថុមិនទៀង ទើងសម្រេចថាសុទ្ធតែឯចេះ ឬ សុទ្ធតែឯចុះ នោះឥតអត្ថិមានតែបានជាព្រះអភិធម្មថាសត្វស្លាប់កើត ព្រោះរឿងនេះជាកាគច្រើនអនេកម្ចាំះហើយមិនចាប់យកការតិសេស មកបញ្ជាក់ឡើយ ឯមនុស្សស្លាប់កើតមកវិញដឹងជាតិ ជាកាគតិចពន់ពេក ប្រៀបដូចយកអំបិលមួយចីបទៅបោះក្នុងសមុទ្រយ៉ាងនោះ ។

អត្ថន័យនិងសុខុម ខ្ញុំលោកគ្រូគុយដែលថាបានដឹងជាតិដែរ ដូចជាបានពោលខុសប្លែកមកហើយ ខ្ញុំគ្រាន់តែចង់បញ្ជាក់ដល់អ្នកអានថាលោកដែលមានមែនឬមិនមានតែប៉ុណ្ណោះ ព្រោះលោកគ្រូអាចារ្យ ខៀវ-ដុំ ក្នុងសៀវភៅ «បញ្ហានេះ-សូត្រ» របស់លោក មានខ្លឹមសារត្រង់ចំណុចបំផុតថា: «ខ្ញុំណាមានចម្បាំង ខ្ញុំនោះជានេះក ខ្ញុំណាមានសេចក្តីសុខ ខ្ញុំនោះជាសូត្រ ខ្ញុំណាមានសេចក្តីសន្តិភាពខាងផ្លូវចិត្ត ខ្ញុំនោះជានិព្វាន» ។ បើតាមការពិនិត្យទ្រឹស្តីយរបស់តាត្សាំងនេះ យើញថាលោកគ្រូអាចារ្យ ខៀវ-ដុំ មានបំណងចង់ឲ្យអ្នកអានយល់ថា គ្មាននេះក គ្មានសូត្រ គ្មាននិព្វានឯណា ត្រាតែខ្ញុំដែលមនុស្សនៅសព្វថ្ងៃនេះឡើយ ។ យើងត្រូវដោះស្រាយបញ្ជាក់តទៅទៀតថា: បើដូច្នេះ ផែនដីមួលយើងជានេះកផង ជាសូត្រផង ខ្លឹងជានិព្វានផង សូម្បីតែបាននដែលអាស្រ័យនៅលើដីមួល ក៏ពាក្យថាននេះក បើគាល់ណាភាំង ពាក្យថាសូត្រ បើគាល់ណាវានៅសុខសប្បាយក្នុងសង្គមរបស់ក ពាក្យថានិព្វាន បើគាល់ណាវាស្លាប់ ដូចជាផ្លែក្តី ឬ ផ្លាក្តី ដែលម្ចាស់ឲ្យចំណីវាបរិភោគត្រប់គ្រាន់ត្រមាំងទីដេកទំនេរសមរម្យ បរិភោគហើយ វាដេកសម្រាន្តដ៏ស្រួលបួលក្នុងចិត្តវាជាទម្លាប់ គ្មានប្រុស្រយ័ទន់ភាវម្នាក់ត្រូវដែលធ្វើឲ្យចិត្តវាតក់ស្លុត ។ រួមសេចក្តីទៅ លោកគ្រូអាចារ្យ ខៀវ-ដុំ ហាក់ដូចយល់ថា ផែនដីមួលយើងនេះហើយ ដែលជាកន្លែងនេះក សូត្រនិងនិព្វានគឺថាលោកដែលមិនមាន

តទៅវិញ ខ្ញុំបែរមកជាអ្នកស្រាយដែលថា នាងសុខុម ទើងលោកត្រូវនុយ ចាងដើងជាតិម្តងវិញ ។ យើងមិនមានទទ្បីកណាដែលអាចយកទៅតិយោដរឿងដើងថាតិនេះចានឡើយ ព្រោះនាងសុខុមចានចាំទើងស្គាល់តូម កូន ចងប្តូនព្រមទាំងអាពុកម្តាយជាតិមុនយ៉ាងច្បាស់លាស់ ហើយនាងចានប្រាប់ថា កាលស្លាប់ក្លាមទៅ។ កើតទៅដើមឈើអស់រយៈពេល ១០ឆ្នាំ បើចងចំបរិភោគរបស់អ្វី បេះនោះអណ្តែតមកឱ្យបរិភោគ ហើយទីកន្លែងដែលនាងទៅ ភ្លឺដាន់ចូហាក់ដូចគ្មានយប់ ទាំងនេះបញ្ជាក់ឱ្យយើញថាពិតជាមានលោកដទៃដែរ ក្រៅពីផែនដីមួល សមតាមលទ្ធិពុទ្ធសាសនាថាមានរុក្ខទេព្តា ភូមទេព្តា បើទេព្តានេះមានហើយ អាកាសទេព្តាទៀតតែមានឥតសង្ស័យ បើហានទេព្តាមានហើយ ហានរកត្រូវតែមានដែរ ហានតិរច្ឆានត្រូវមានទៀត មិនមែនហានទាំងបីគឺ នរក សួគ៌ និងនិរ្វាន នៅច្របូកច្របល់ តែលើផែនដីមួលនេះឡើយ ។

ឯពួកអ្នកខ្លះនិយមថ្វីស្តីថាមនុស្សស្លាប់ទៅកើតជាមនុស្សវិញ សត្វតិរច្ឆានស្លាប់ទៅកើតជាតិរច្ឆានវិញ តាមយោបល់ខ្ញុំថាជាថ្វីស្តីពិសេសចំពោះតែសាម៉ីខ្លួនប៉ុណ្ណោះ ទើងបានជាថ្វីស្តីមានការណ៍ពិតតូចៗដូចថ្វីស្តីពុទ្ធសាសនាឡើយ ព្រោះដោយយកឫរឿងដើងជាតិនេះមកជាសំអាង ជាសាក្សីចំពោះដែលថាលោកដទៃមាន សត្វស្លាប់ទៅ មិនមែនសុទ្ធតែកើតមកជាសត្វនោះ។ ដដែល។ ឡើយ ។ ឧទាហរណ៍ : នាងសុខុមស្លាប់

ឥមនុស្សទៅកើតជារក្ខសេត្តា ពីរក្ខសេត្តា មកកើតជាមនុស្ស លោកគ្រូ គុយស្វាប់ឥដ្ឋ មកកើតជាមនុស្ស ។ រឿងនាំនេះអាចទុកថាលោកដរៃ ពិតជាមានប្រាកដដើម្បីសម្ងាប់នូវទ្រឹស្តីអ្នកខ្វះដែលតែងពោលថា បើមាន ហានេត្តា ហេតុម្តេចអ្នកដែលទៅកើត កំមិនដែលឃើញចុះមកប្រាប់ឲ្យគេ ប្រាន់ដឹងឆន ឃើញតែស្លាប់ទៅបាត់ទៅ ស្លាប់ទៅបាត់ទៅ ដូចគេទៅ សុំក្តីនឹងឃ្លាដូច្នោះ ។ ចំណែកអ្នកវិទ្យាសាស្ត្រ តែគេថាមានអ្វី គឺគេចាប់ ប្តូរឥរបស់នោះ យកមកបង្ហាញជាកស្តែងតើអ្នកពុទ្ធសាស្ត្រមាន អ្វីជាកស្តែងតាង ? ខ្ញុំសូមយករឿងនាងសុខុម មួយគូបជាកស្តែងតាង ។

សារុបសេចក្តី អ្នកពុទ្ធសាស្ត្រ និងអ្នកវិទ្យាសាស្ត្រ ចេះតែមាន យោបល់បែកខ្ញែកគ្នា ។ ឯការបែកមតិនេះ មិនមែនមានតែក្រៅពីដំឡឹ ជួនស្រាល និងការប្រតិបត្តិជួនស្រាលទេ: អ្នកពុទ្ធសាស្ត្រ ងប់ទៅខាង ចិត្តសាស្ត្រនិយម អ្នកវិទ្យាសាស្ត្រ ងប់ទៅខាងសម្ភារៈនិយម ដែលចំរើន និងអន់ខ្សោយតាមកាលសម័យ ។ ប្រសិនបើយើងតុបណ្តោយឲ្យថាស ដញ្ជីនឹងជួនម្ខាង ។ ពេក ខ្ញុំយល់ថាអ្នកវិទ្យាសាស្ត្រ និងអ្នកពុទ្ធសាស្ត្រ និង អាចមានមតិស្របគ្នាបាន ។

សូមអ្នកអានចាំងឡាយមានសុភនិច្ឆ័យ មេត្តាជួយវិនិច្ឆ័យអំពីរឿង ដ៏ជាតិវិញ្ញាណដ៏ចេតកូត ហើយនឹងលោកដរៃឆងចុះ ។

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៊ុ រៀបរៀង

(តមក)

ឯកលយា ខន្ធ៍នោះ លែងអាឡោះអាល័យស្តាយដីតែ ហេតុតែអត់អាហារដល់ ៧ ថ្ងៃ មានខ្លួនញ័រចង្រៃប់ វាវេចញ្ចឹមកតីរូងក្នុងដំបូកស្តាំងស្តម នៅតែស្បែកជណ្តប់ឆ្អឹង ។ ក្មេងចាំង ៧ នាក់ ចាន់យើញខន្ធ៍ស្តមដូច្នេះ គំរើតចិត្តអាណិតមេត្តានិយាយគ្នាថា ពួកយើងកុំបៀតបៀន កុំធ្វើបាបវាឡើយ ហើយនាំគ្នាបបោសអង្ករខ្លួនខន្ធ៍រួចលែងទៅ ។ ខន្ធ៍នោះក៏វាចូលទៅកន្លែងព្រៃ ។

ឯរយេ អង្គភ្លុត្តិត្តា ពារកចាំង ៧ នាក់នោះ លុះក្បួយដីតែហើយ មិនទៅកើតកន្លែងកេ ។ កម្មដែលខ្លួនធ្វើនោះ មិនបានឱ្យផលតីមិនបានទាំបដិសន្ធិជាឧបបជ្ជវេទនីយ៍ គ្រាន់តែជាអបរបរិយវេទនីយ៍តាមឱ្យផលតតំណត់កាល ។ ឯពារកគោចាលចាំង ៧ នាក់នោះ អត់អាហារមួយលើក ។ ៧ ថ្ងៃ ។ កប់បាន ១៤ ជាតិ រួមចាំងជាតិជាកិកុ នោះ ។

កិរិយាដែលកិកុ ៧ រូបអត់អាហារ ៧ ថ្ងៃ ទីឥន្ទ្រាំងថ្ងៃមៀលមកខ្លប់ថ្ងៃគោហាជាប់ ៧ ថ្ងៃនោះ កប់ថាជាអបរបរិវេទនីយកម្មភាន-

អកុសល ។ អ្នកមានបញ្ញាគប្បីយល់ថា បុគ្គលធ្វើអកុសលកម្ម ។ នោះ ឲ្យផលគ្មានកំណត់កាលទេ បើបានឧកាសតាលណា ក៏ឲ្យផលកាលនោះ ចាត់ជាអបរាបរិយវេទនីយកម្មជាំងអស់ ។

ចំណែកខាងកុសលកម្មវិញ បើកុសលដែលបុគ្គលធ្វើក្នុងជាតិនោះ មិនបានឲ្យផលក្នុងជាតិជាលំដាប់ទេ បានឧកាសណា ក៏ឲ្យផលកាលនោះ ចាត់ជាអបរាបរិយវេទនីយកម្មខាងកុសល ដូចព្រះនាងមល្លិកា ក៏ដូចជា ជាអគ្គមហេសីនៃព្រះបាទបសេនទិកោសល ។ ព្រះពជទេវីនេះជាអ្នកចាត់ចែងអសទិសទាន ថ្វាយដល់ព្រះកកុសន្ធ ។ មានសម្តេចព្រះភុទ្ធអគ្គជាប្រធាន ។

ឯអសទិសទាននោះ ព្រះពុទ្ធជាម្ចាស់ត្រាស់ក្នុងលោកមួយព្រះអង្គ មានតែមួយលើកប៉ុណ្ណោះ មិនដែលមានពីរលើកទេ ។ ព្រះនាងមល្លិកាពជទេវីនោះ បានជាអ្នកចាត់ចែងអសទិសទាន លុះរលត់បញ្ចក្ខន្ធ ក៏មិនបានទៅកើតក្នុងឋានសួគ៌ទេ ឆ្ងាត់ទៅក្នុងនរក ៧ ថ្ងៃ ឆុតពី ៧ ថ្ងៃ ទើបបានទៅកើតក្នុងឋានសួគ៌ ។

កាលព្រះនាងមល្លិកាពជទេវី រលត់បញ្ចក្ខន្ធនោះ ព្រះបាទបសេនទិកោសល មានព្រះកមលហឫទ័យទោមនស្សុះលត់សេចក្តីសោកមិនបានទ្រង់ព្រះកន្សែងពីលាបទ្រឹកទ្រូលស្តាយ ព្រោះហេតុ ព្រះនាងជាសម្លាញ់ក្នុងការចំពេញព្រះពជកុសល លុះដល់វេលាសមគួរល្អ ទ្រង់ស្តេចយាង

ទៅកាន់សំណាក់សម្តេចព្រះទសពល ដើម្បីនឹងក្រាបទូលសួរពីបវរលោកនៃព្រះនាងមល្លិកា ។

អនុវាទកថា តាំងតែសម្តេចព្រះបរមសាស្តាទ្រង់ធ្វើឲ្យព្រះមហាក្សត្រនឹងក្សត្រីមិនឃើញ តែធ្វើឲ្យស្តេចក្មេចសួរពីរឿងព្រះនាងមល្លិកាអស់ដងវែងហើយ ចាន់ទៅកើតនៅឋានណា ព្រោះនាងមល្លិកាជ្ញាក់ទៅនរកបើព្រះមហាក្សត្រទូលសួរព្រះអង្គ ។ ត្រាស់ប្រាប់តាមពិតថា នាងមល្លិកាជ្ញាក់ទៅដូច្នោះ មុខជាព្រះមហាក្សត្រចោះបង់ចោលទូកាកុសលចាំងអស់ លែងធ្វើតទៅទៀត ព្រោះទ្រង់ជ្រាបថា ព្រះនាងមល្លិកាធ្វើការកុសលច្រើនណាស់ គ្មានស្ត្រីណាលើផ្ទៃប្រថពីប្រៀបស្មើឡើយ ។ ត្រាន់តែព្រះបាទបសេនទិកោសល គិតនឹងទូលសួរពីនាងមល្លិកា អស់រយៈ ៧ ថ្ងៃ ព្រោះទ្រង់ចូលទៅគាល់ព្រះពុទ្ធអង្គ ។ ចេះតែទ្រង់ធ្វើឲ្យក្មេចនឹកមិនឃើញកាល់ថ្ងៃ ។ លុះដល់ថ្ងៃជាគំរប់ ៨ ព្រះនាងមល្លិកាអស់ផលនៃអកុសលកម្មហើយ រួចពីនរក ចាន់ឡើងទៅកើតទៅជាន់តុសិត ព្រះមហាក្សត្រ ទើបចាន់ទូលសួរព្រះសាស្តា ។ ទ្រង់ត្រាស់ប្រាប់ថា ម្នាលមហាបពិត្រ នាងមល្លិកាចាន់ឡើងទៅកើតទៅជាន់តុសិត ។ ព្រះបាទបសេនទិកោសល ក្រាបទូលថា កាលបើព្រះនាងមល្លិកាមិនចាន់ទៅសួគ៌ហើយ គ្មានបុគ្គលណាក្រៅពីព្រះនាងមល្លិកាទៅសួគ៌បានទេ ព្រោះថាព្រះនាងមល្លិកានោះ មានចិត្តជាកុសលកន្ត្រើដទៃមានសទ្ធាស្មើគ្មាន តាំងពីព្រះនាងមល្លិកាក្សយព្រះជន្មទៅ

ខ្ញុំព្រះអង្គ មិនអាចអត់សង្កត់សេចក្តីសោកបានឡើយ ។

ក្នុងលំដាប់នោះ សម្តេចព្រះបរមសាស្តា ទ្រង់ត្រាស់ទេសនាជាព្រះគាថាថា៖

បិយតោ ជាយតេ សោ តោ
បិយតោ ជាយតេ ភយំ
បិយតោ វិប្បមុត្តស្ស
នត្ថិ សោ តោ កុតោ ភយំ ។

សេចក្តីថា សេចក្តីសោក តែងកើតអំពីសត្វទើសង្វារជាទីស្រឡាញ់ ភ័យតែងកើតអំពីសត្វទើសង្វារ ជាទីស្រឡាញ់ កាលបុគ្គលផុតចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកទើភ័យតើគ្មាន ។

ព្រះបាទបសេនទិកោសល ទ្រង់ព្រះសណ្ឋាប់ព្រះសទ្ធម្មទេសនានៃព្រះបរមសាស្តាចប់ហើយ កំអស់សេចក្តីសោកតព្រះកមលសន្ធាន ក្រាបថ្វាយបង្គំលាត្រឡប់ទៅកាន់ព្រះពដាំនវិញ ។

អ្នកប្រាជ្ញតម្បីសន្និដ្ឋានថា ការដែលត្រះនាងមល្លិកាបានកើតក្នុងឋានសួគ៌ជាន់តុសិតនោះ ក៏ពាល់បញ្ចូលកុងបញ្ចវិញ្ញាវេទនីយកម្មជាងកុសល តើមិនបានសោយផលនៃកុសលកម្មក្នុងជាតិនោះ ទើមិនបានសោយផលកុងជាតិជាលំដាប់បន្ទាប់អំពីជាតិជាបច្ចុប្បន្ន ពាល់បញ្ចូលកុងកម្មបច្ច័យ ២៤ ប្រការដូច្នេះ ។

អបរាបរិយវេទនីយកម្ម សង្ខេបប៉ុណ្ណោះ ។

៤ - គរុកកម្ម

កុសលាកុសលបភេទេសុ បឯ យំ តវុកំ តំ គរុកគរុកម្មំ ជាម តនេតំ កុសលមហគ្គតំ អកុសលបភេទេបញ្ចានន្តរិយកម្មំ វេធិតព្ពន្តិ ។

ក្នុងលំដាប់នេះ សូមសែដ្ឋនាក្នុងកម្មបច្ច័យ អធិប្បាយនូវគរុកកម្ម តទៅ ដំណើរសេចក្តីថា កុសលា កុសលវសេន កម្មដែលឈ្មោះថាគរុកកម្មនោះមាន ២ ប្រការ គឺកម្មដ៏ធ្ងន់ដោយអំណាចនៃកុសលកម្ម ១ កម្មដ៏ធ្ងន់ ដោយអំណាចនៃអកុសលកម្ម ១ ។

គរុកកម្មនោះ បើខាងកុសល បានន័យឈានដ៏ជាមហគ្គតកុសល បើខាងអកុសលវិញ បានន័យបញ្ចានន្តរិយកម្ម ។ ឯឈាននោះ សំដៅយកឈានជាលោកិយ ។ កាលបើគរុកកម្មគឺឈានន័យអនន្តរិយកម្មនៅហើយ កម្មជាកុសលន័យអកុសលក្រៅពីគរុកកម្មនោះ មិនអាចឲ្យផលបានឡើយ ។

ឯគរុកកម្មនោះវិមង្សជដ៏សន្ធិ គឺថា បើបុគ្គលបានធ្វើគរុកកម្មខាងកុសលហើយ គរុកកម្មជាកុសលនោះ ក៏ឲ្យបដិសន្ធិក្នុងសុគតិ ។ បើបុគ្គលបានធ្វើគរុកកម្មខាងអកុសលហើយ គរុកកម្មជាអកុសលនោះ ក៏ឲ្យបដិសន្ធិក្នុងទុគ្គតិភព ប្រៀបដូចដុំថ្មដែលបុគ្គលចោះចុះទៅក្នុងទឹកស៊ីឆ្ងាសប្បមាណាបិ ដុំថ្មបែកជាចំណែកតូចល្អិតសូម្បីតែប៉ុនគ្រាប់-

សណ្តែកចាយក្តី ដុំត្រួសថ្មដុំដែកដ៏ល្អិតក្តី ដែលបុគ្គលចោះចុះទៅក្នុងទឹក មិនអាចអណ្តែតក្រឡប់ឡើងមកលើទឹកវិញបានឡើយ ហោដ្ឋ ៗ បវិសតិ ចេះតែលិចចុះទៅខាងក្រោមជាដរាប សេចក្តីនេះដូចម្តេច ។ ឯគុរុកម្មខាងកុសលក្តី ខាងអកុសលក្តី ដែលបុគ្គលណាបានធ្វើរួចហើយ បុគ្គលនោះរមែងបានសោយនូវផលនៃគុរុកម្មនោះដូច្នោះ ។ គុរុកម្មនោះ តែងឲ្យបដិសន្ធិក្នុងភពជាលំដាប់ ប្រហែលគ្នានឹងទុបជ្ជវេទនីយកម្មដែរ ។

តាបសឫសីដែលបានអភិញ្ញាច្រាំ ទើបបានសមាបត្តិច្រាំបីប្រការ ដូចព្រះអត្តិតាបសទើបព្រះកេសវតាបសជាដើម សុទ្ធតែបានចំរើនឈានជាមហគ្គតកុសល ចាត់ជាគុរុកម្មខាងកុសល ។ ឯបុគ្គលចំរើនឈានហើយអស់ជីវិត ក៏បានឈ្មោះថាធ្វើគុរុកម្មជាមហគ្គតកុសល គុរុកម្មនោះនាំបដិសន្ធិកន្លងភពជាលំដាប់ ដូចសម្តេចព្រះពុទ្ធជាម្ចាស់នៃយើងកាលសោយព្រះជាតិជាបរមពោធិសត្វ កសាងសន្សំព្រះបារមី មានសេចក្តីដូចតទៅនេះ ៖

រឿងពីសីលាប់ឈាន

អតីតេ តាលេ កន្លងកាលកន្លងទៅជាយូរអង្វែងហើយ ព្រះបរមពោធិសត្វ ជួសជាតាបសឫសី នៅក្នុងព្រៃហិមពាន្ត លុះនៅយូរទៅខឹកចង់តាន់អាហារមានរសជូរនឹងរសប្រៃ ទើបចេញមកអំពីព្រៃហិមពាន្ត

ចូលទៅកន្លែងតរោកណាសី ដើម្បីនឹងត្រាច់បិណ្ឌបាតតាមលំដាប់ ទៅតាមមុខព្រះលោកនៃព្រះចុន្ទភាកណាសី ។ ព្រះមហាកស្សបត្ថេរ ទតឃើញព្រះតាបស ក៏ជ្រះថ្លាក្នុងតិរោបថចាំឆ័ន្ទបួន ទើបឲ្យភជបុរសទៅនិមន្តឲ្យឆាន់មកលើប្រាសាទ អង្គាសដោយអាហារបិណ្ឌបាតដ៏ឧត្តម ។ លុះព្រះតាបសធ្វើភត្តកិច្ចស្រេចហើយ ព្រះមហាកស្សបត្ថេរអាចធាឲ្យតង់ទៅកន្លែងព្រះពុទ្ធដ្ឋាន ឲ្យភជបុរស ធ្វើទីសេនាសនៈ ប្រគេនតង់ជាសុខសប្បាយ ចាំឆន្ទៈយប់ចាំឆ័ន្ទថ្ងៃ ហើយអាចធាឲ្យនិមន្តមកឆាន់ក្នុងព្រះពុទ្ធនិវេសន៍ជានិច្ច ។ ព្រះតាបសក៏ទទួលអាចធាព្រះមហាកស្សបត្ថេរ ធ្វើតាមកិច្ចដែលត្រង់អាចធា មកតង់ទៅកន្លែងព្រះពុទ្ធដ្ឋានតាមភជបញ្ញា លុះដល់វេលាកិរិយាចារ ក៏និមន្តចូលទៅកាន់ព្រះរាជវាំង ទទួលអាហារបិណ្ឌបាត ក្នុងថ្ងៃជានិច្ចកាល ។

(នៅមានត)

ព្រះធម៌គួរប្រតិបត្តិ ដ្បិតជីវិតយើងមិនទៀង
មរណៈមានតែមួយ ប្រាណសព្វសត្វក្នុងភពត្រៃ។
ម្រឹត្យុមានប្រាកដ មិនកំណត់ថាយប់ថ្ងៃ
កូនអើយគួរលះកិលេ ខុតពេលខ្លះចំរើនធម៌ ។

អាថ៌កំបាំងរបស់ពុទ្ធសាសនា

លោក ប៊ី-ប៊ូ រៀបរៀង (តចប់)

រឿងអាថ៌កំបាំងមួយចំនួនទៀត

ដែលអស់លោកអ្នកអានគួរតែជ្រាប

១-តើមកពីហេតុអ្វី ចានជាព្រះពុទ្ធសាសនាចុះអាប់ឧន ប្លែកសាបសូន្យ ចាត់ពីប្រទេសឥណ្ឌា ?

ចម្លើយ: មកពីហេតុមានសាសនាជាច្រើន ចូលជ្រៀតជ្រែកចំរើនបំផ្លាញ តាមរឿងរ៉ាវដែលសរសេរដោយសង្ខេប ដូចតទៅនេះ ៖

តាំងពីព្រះពុទ្ធចរិនិព្វាន កន្លងទៅចាន៩០០ឆ្នាំ គ.ស. ៣៥៧ឆ្នាំ ព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌា រឿរកេយអាប់ឧន ចុះជាលំដាប់រហូត ។ មកដល់ ព.ស. ១៥០០ឆ្នាំ គ.ស. ៩៥៧ ឆ្នាំ ព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌាចុះអាប់ឧនជាខ្លាំង មកពីហេតុពួកអ្នកកាន់សាសនា(១)ព្រាហ្មណ៍ មានអំណាចជាធំក្នុងប្រទេសឥណ្ឌា បៀតបៀនព្រះពុទ្ធសាសនា ។ សូម្បីតែពួកភិក្ខុសង្ឃដែលជាអ្នកទ្រទ្រង់ នូវព្រះពុទ្ធសាសនា ក៏បែរទៅនិយមកាប់អាន មន្តអាគមគាថា ដោយមានក្រុមច្នា នឹងឲ្យមនុស្សចាំងឲ្យចុះចូល ដើម្បីស្វែងរកភិត្តគុណ នឹងលាភសក្ការៈប្រកួតប្រណាំងនឹងពួកអ្នកកាន់សាសនាព្រាហ្មណ៍ ។ ព្រះសង្ឃចាំងនោះចុះបង់ចោលធម៌

១- ជាសាសនាចាស់បរមបុរាណ កើតមានឡើងក្នុងប្រទេសឥណ្ឌាមុន ព.ស. ប្រហែលជា៥ឬ៦ពាន់ឆ្នាំហើយ ។

វិន័យតាគខ្លះ ដែលជាខ្នាតបន្ទាត់ដើមរបស់ខ្លួន គាំងនិកាយហីនយានគាំង
និកាយមហាយាន ។

សម័យក្រោយមកទៀត ពួកអាក៉ាប់មានអំណាច នាំគ្នាលើកកងទ័ពដើរច្បាំង ដណ្តើមយកអាណាខែត្រទាទា ហើយបញ្ចុះបញ្ចូលមនុស្សគាំងឲ្យចូលសាសន៍ តាន់សាសនា[1]អ៊ីស្លាម ជាមួយនឹងខ្លួន ។ ម្យ៉ាងហើយ សាសនាអ៊ីស្លាមក៏សាយអាយកាយមកតាមលំដាប់ផកបដល់ប្រទេសប៊ីស៊ី ប្រទេសអាហ្វហានីស្ថាន ។

នៅទីបំផុត ពួកអាក៉ាបនេះមកបានជាធំក្នុងប្រទេសឥណ្ឌាពី ព.ស. ១៧០០ គ.ស. ១.១៥៧ ។ ឯតតិជមិទាងសាសនាអ៊ីស្លាមនោះ ប្រដៅគ្នាឲ្យតាន់ថា តារំលោភយបំផ្លាញរូបជាទីគោរពគាំងពួងចោលចេញ ទោះជារូបរបស់សាសនាណាក៏ដោយ គេចាត់ថាជាការកុសលមានផលច្រើនណាស់ ។

អស្រ័យពាក្យប្រៀនប្រដៅបែបនេះហើយ បានជាពួកអ៊ីស្លាមនាំគ្នារុះរើចេតីយដ្ឋាន ភយបំបាក់បំបែកព្រះពុទ្ធរូបចោលអស់ ហើយថែមទាំងបៀតបៀនអ្នកពុទ្ធសាស្ត្រ ដោយអាការគាចរោរយ៉ាងផ្សេង ។ ទៀតផង ពាល់តែ ពួកពុទ្ធបរិស័ទ ក្នុងប្រទេសឥណ្ឌាគ្រាំគ្រុំបាន ក៏វិនាស

---

១ សាស្ត្រាគាម (មហាម៉ាត់) កើតនៅក្រុងមេក្កះ ដែនអារ៉ាប់ ក្នុង ព.ស. ១.១១៣ ឬ ១៤ ព.ស. ៥៣០ ឬ ជាមេលទ្ធិ បង្កើតសាសនាអ៊ីស្លាម ។

សាបសូន្យបាត់អស់ទៅ មុខតួរឱ្យអាណោចអធម្មពេកណាស់ ។

ការដែលព្រះពុទ្ធសាសនាត្រូវពួកអាក៉ាប់ញាំញីគ្រានោះ មិនតែក្នុងតំណៀមួយប្រទេសប៉ុណ្ណោះទេ នៅមានអាក៉ាប់ មួយពួកទៀត ចុះសំទៅបើកតាមផ្លូវសមុទ្រត្រហាម ដើរកេតត្បាតច្បាំង បង្ខាំងបង្ខាលមនុស្សតាំងពួនដែលនៅស្រុក តាមជួរមាត់សមុទ្រ តាំងពីតំណៀរៀងរហូតមកដល់ម៉ាឡៃយូ កោះស៊ូមាត្រា កោះជ្វា ទឹងប្រទេសចាម នៅមាត់ខ្នេរមេគង្គ ។ ពួកអាក៉ាប់នេះ បានជាធំ មានអំណាច នៅប្រទេសណា តំបន់ផ្ទៃចំបង់ញាញព្រះពុទ្ធសាសនាដែលមាននៅក្នុងប្រទេសនោះ ឲ្យវិនាសបាត់ទៅ ។

- ព. ស. ១.៤០០ឆ្នាំ គ. ស. ៨៥៧ឆ្នាំ កើតមានពុទ្ធចេតិយ បែបលង្កា ហីនយាន ទឹងមហាយាន នៅនគរសុរីវិជ័យ ។

ព. ស. ១.៦០០ឆ្នាំ គ. ស. ១០៥៧ឆ្នាំ ព្រះពុទ្ធសាសនាក្នុងលង្កាខ្វិចអាប់ខ្មួន ។ ក្នុងរជ្ជកាលព្រះបាទ អនុរុទ្ធមហាពាជ (ភូមា) ព្រះពុទ្ធសាសនាលទ្ធិហីនយាន ចំរើនរុងរឿងក្នុងក្រុងភូគាម (ភូមា) ទឹងក្នុងរដ្ឋឆែន (លាវ) ។

សម័យនេះ កើតមានពុទ្ធចេតិយ បែបលង្កាហីនយាន នៅនគរដ្ឋឆែន (លាវ) ។

- ព. ស. ១៦០៨ឆ្នាំ គ. ស. ១០៦៥ឆ្នាំ ក្នុងរជ្ជកាលព្រះបាទ វិជយពាហុជាដើម ព្រះពុទ្ធសាសនាក្នុងលង្កាទ្វីប ត្រឡប់ចំរើនរុងរឿង ឡើងវិញ ។

- ព. ស. ១៦៦៣ គ. ស. ១១២០ឆ្នាំ ព្រះពុទ្ធសាសនាក្នុង លង្កាទ្វីប ចុះអាប់ខ្សោយទៀត ។

ព. ស. ១៦៨៦ឆ្នាំ គ. ស. ១១៨៣ឆ្នាំ ក្នុងរជ្ជកាលព្រះបាទ បរក្កមពាហុ ព្រះពុទ្ធសាសនា ក្នុងលង្កាទ្វីប ត្រឡប់ចំរើនរុងរឿងឡើង វិញ ។

- ព. ស. ១ ៨០០ ឆ្នាំ គ. ស. ១២៥៧ឆ្នាំ កើតមានពុទ្ធចេតិយ ក្នុងលង្កាទ្វីបមហាយាន បែបលង្កាវង្ស ឈ្មោះគរសុភោជ័យ (សៀម) ។

ក្នុងសម័យនេះ សៀមនឹងខ្មែរកាន់លទ្ធិហីនយាន តាមបែបលង្កា ទ្វីប ។

- ព. ស. ១ ៨៨៣ ឆ្នាំ គ. ស. ១ ៣៤០ឆ្នាំ ព្រះពុទ្ធសាសនា ក្នុងលង្កាទ្វីប ចុះអាប់ខ្សោយទៀត ។

ព្រះពុទ្ធសាសនាលទ្ធិហីនយាន ក្នុងនគរស្រីអយុធ្យា រៀងខាង ដើម ចំរើនរុងរឿងជាបង្អែ ដល់រៀងខាងចុង រៀរៃកេរយ៉ាងចុះ ។

- ព.ស. ១៨៥០ ឆ្នាំ ស. ស. ១ ៤០៧ ឆ្នាំ ព្រះពុទ្ធសាសនា លទ្ធិហីនយាន ចំរើនរុងរឿងក្នុងប្រទេស ដៀនសែន (លាវ) ។

- ព.ស. ២ ៦០០ ឆ្នាំ គ.ស. ១ ០៥៧ឆ្នាំ ព្រះពុទ្ធសាសនាក្នុងប្រទេស ដៀងសែន (លាវ) អាចនឹងចុះដោយលំដាប់ដកចេញមក ។

- ព.ស. ២ ៣២៥ ឆ្នាំ គ.ស. ១ ៧៨២ ឆ្នាំ ត្រឹម ព.ស. ប៉ុណ្ណោះ ជាដើមមក ព្រះពុទ្ធសាសនាក្នុងក្រុងរតនកោសិន្ទ (សៀម) ចុះអាប់ទន ។

តាំងពីត្រឹមរដ្ឋកាល ព្រះបាទសម្តេច ព្រះចមក្លៅជាដើម ព្រះពុទ្ធសាសនា ក្នុងប្រទេសសៀម ចំរើនរុងរឿង រហូតដល់សព្វថ្ងៃនេះ ។

> ការឲ្យកុដង្គនាគធឹតឧកដោះ បានន័យឲ្យចំរើនពិសាចចន្ទមឡើងតែប៉ុណ្ណោះ ឧបទេសដែលគេឲ្យដល់មនុស្សល្ងង់ ត្រូវក្រោធច្រើន មិនបានសេចក្តីសួរទេ បានតែក្រោធវិញមកវិត ។
>
> មានតែអ្នកប្រាជ្ញទេ បុគ្គលគប្បីឲ្យឧបទេសបាន ឯមនុស្សល្ងង់ ក្នុងកាលណាក៏ដោយ បុគ្គលមិនគប្បីឧបទេសឡើយ សត្វបក្សី (ត្រសេង់ត្រសោង) បានឲ្យឧបទេសដល់ស្វាល្ងង់ ត្រូវស្វាចោចកេចសំបុកចោលហិនហោចអស់ ។

អស់ស្តេចផងបានស្តាប់ពាក្យនោះហើយ សឹងតែមានចិត្តលុះខ្ជូសង្វែត អនិច្ចា ហើយក៏ទូលព្រះបាទចុឡនីថា បពិត្រអម្ចាស់អើយ ដូច្នោះ តិត្រហ៎ាំ ។ ព្រះបាទចុឡនីថា អើពិត្រមែនដូច្នោះហោង ។ ហើយ ព្រះបាទចុឡនីថា នុអម្ចាស់ អំពើអញធ្វើនោះ ហេតុតែអញយកនូវពាក្យ អាចារ្យកេវដ្ដព្រាហ្មណ៍នោះហោង ។ រីព្រះមហោសធអ្នកជ្រាបថា មែនពិត្រដូចព្រះបន្ទូលនេះឯងហោង ។ តេ សព្វេបិ មហាសត្តំ អាលិង្គិត្វា ។ អស់ស្តេចផងពាំងនោះ សឹងទុបអង្អែលពោធិសត្វ ហើយថា ម្នាលចៅអ្នកជ្រាបអើយ រីចៅនេះជាហានពំនាក់នៃស្តេចផងពាំង ឡាយ យើងខ្ញុំពាំងនេះបានរួចជីវិត ហេតុអាស្រ័យនឹងចៅហោង ។ ស្តេចផងពាំងនោះ សឹងធ្វើបូជានៃពោធិសត្វនូវគ្រឿងប្រដាប់ប្រដាផង ពាំងឡាយច្រើន ព្រះមហោសធអ្នកជ្រាបផងអ្នកទូលថា បពិត្រក្សត្រផង ពាំងឡាយអើយ កុំបីអម្ចាស់គិតទោសនោះឡើយ ហេតុព្រះអង្គប្រសព្វ គប់នូវមិត្តបាបនោះឯង ចូរអម្ចាស់ពាំងនេះអត់ទោសចៅហោង ។ ព្រះ បាទចុឡនីមានបន្ទូលទៅនឹងអស់ស្តេចពាំងនោះថា ចូរអ្នកអត់ទោសដល់ អាត្មាអញចៅហោង ។ អំពើទោសនៃអញធ្វើដល់អ្នកពាំងឡាយនេះមាន សភាពអាក្រក់ហេតុតែអញអាស្រ័យនឹងបុរសកំណាច គឺអាចារ្យកេវដ្ដ

ព្រាហ្មណ៍នោះឯង ចូរអ្នកចាំឯង្ឃាយអត់ទោសដល់អញនេះហាង ។ មួយទៀតសោត អំពីនេះទៅ រីអំពើទោសមានអានុភាពដូច្នេះ អញពុំធ្វើទៀតឡើយ ។ ឯអស់ស្តេចផងចាំងនោះ សំដែងនូវទោសនឹងគ្នាទៅវិញទៅមកហើយ ក៏មានចិត្តនោះត្រអាលសាទរស្មោះសរត្រេកអរផងគ្នា ។ លំដាប់នោះ ស្តេចឱ្យទៅនាំនូវចំណីភោជនាហារ នូវគន្ធមាលា ឆ្លាក្រចេះក្តីផងជាដើម ហើយឱ្យលេងក្រសាលជាសុខសប្បាយនាឋានមួយខែនោះអស់ ៧ ថ្ងៃ ស្តេចនាំគន់នាកណ្តាលផ្លែកេងធំ ជំនុំនឹងអស់ស្តេចផងជាបរិវារ រួចហើយស្តេចបន្ទូលទៅនឹងព្រះមហាសត្វ នាំពោធិសត្វមួយអន្លើ នឹងមហាក្សត្រចាំង ១០១ ជាបរិវារ ស្តេចបូជាគ្រឿងសក្ការដល់ព្រះមហាសត្វ រីព្រះបាទបុឡន ស្តេចបន្ទូលទៅនឹងព្រះមហាសត្វប្រយោជន៍ដើម្បីនឹងឃាត់ឱ្យពោធិសត្វអ្នកទៅឰដំណាក់អាត្មាព្រះអង្គថាដូច្នេះ អញសូមឃាត់បានៅអាយហើយ ។

រាជ្ជំ បរិហារញ្ច ទ្វិក្ខត្តុំ ភត្តវេតនំ
ឧភាមិ រិបុលេ ភោគេ តុយ្ហ តាមេ រមស្សុ ច
មា រិនេហិ បទុក្ខមា តីរិនេហោ ភរិស្សតីតិ ។

ម្នាលបាមហាសព្វអើយ អញឱ្យចំញឹមដីវិត នឹងយកស្រុកតួចនូវស្រុកធំ ប៉ុន្មែនជាយទឹកអាហារចំណីផងច្រើន នូវទ្រព្យអំណោយអញនឹងឱ្យឃុសក្តិបរិពារបានជាខ្ញុំគុណ រីភោគទ្រព្យសម្បត្តិផងធំតួលាយ

ចូរបានទៅតាយសេតសោយទូវបញ្ចាតាមគុណ តាំងឡាយ ឲ្យសុខសប្បាយ
កុំបីបានវិលទៅតាន់ស្រុកព្រះបាទវិទេហរាជ ព្រះបាទវិទេហរាជត្រូវជាអ្វី
ខ្ញុំដល់ទៅហ៊ុន ។

ព្រះមហាសត្វអ្នកប្រាជ្ញ ខំឆន់បញ្ជាប់ស្ងួរស្តេច ហើយទូលថា
ដូច្នេះ ។

យោ ចវេទ មហារាជ កត្តារំ ឆនការណា
ទុកិន្នំ មោគតិ តារេយ្យោ អត្តនោ ច បរស្ស ច
យាវ ជីវេយ្យ វេនេមោ ជាញស្ស បុរិសោ សិយំ
យោ ចវេទ មហារាជ កត្តារំ ឆនការណា
ទុកិន្នំ មោគតិ តារេយ្យោ អត្តនោ ច បរស្ស ច
យាវ តិដ្ឋេយ្យ វេនេមោ ជាញស្ស វិដិតេ វសេតិ ។

បពិត្រមហារាជ បើអ្នកឯណាមួយប្រាសលះបង់ទូវអម្ងាស់ ហេតុ
វិសបង់បានទ្រព្យនោះ ទំនងមានដំនៀលពីរដំពូកនៃអាត្មាឯងក្តី នៃអ្នក
ដទៃក្តី ថាបើព្រះបាទវិទេហរាជ ស្តេចមានព្រះជន្មអស្ចារ្យមាណ កំឡុ
មិនអាចនឹងមកជាឱព្រះអង្គនេះបានឡើយ ។

លំដាប់នោះ ព្រះបាទបុប្ផនី ស្តេចបន្ទូលទៅនឹងព្រះមហាសត្វថា
ដូច្នេះ ។ បណ្ឌិត ម្នាលចៅអ្នកប្រាជ្ញអើយ ទោះយោបល់ដូច្នោះ
ចូរចៅប្តេជ្ញាដើម្បីនឹងមកគាន់ហានយើងនេះអង្កាល់ ។ ព្រះមហាសត្វ

ខ្ញុំសូមថា បពិត្រមហាភន្ត ចាំបើព្រះជាទាវិទេហភន្ត តាំងព្រះជន្មនៅ
នោះ ទើបខ្ញុំបានមកជាស្វាមីនៃព្រះជាទេអម្ចាស់ហោង ។ លំដាប់
នោះ ស្តេចធ្វើសក្ការៈដ៏ធំចំពោះពោធិសត្វជាតំរាប់ ៧ ថ្ងៃហើយ នាគាល
ពោធិសត្វនឹងលាទៅនោះ ស្តេចមានបន្ទូលជាគាថាដូច្នេះថា :

ធម្មំ និក្ខសហាសេរ្ឆ តាមាសីតញ្ច កាសិសុ
ធាសីសតានិ ចត្តារិ ធម្មំ ករិយាសតញ្ច តេ
សត្វំ សេធាច្ឆមានាយ សោត្ថិ កច្ច មហោសធាតិ

មហោសធ ម្នាលពាអ្នកប្រាជ្ញ រាត្រីឲ្យអំណោយអញឲ្យបានខ្សាច
មាសឆ្នាំនួន ១០០០តម្លឹង ខ្សាច្រកធំ ៨០ នៅខៀបស្រុកកាសិការដ្ឋ ខ្សាប្រ
ពន្ធ ១០០ ខ្សាខ្ញីស្រី ៤០០ ជាមរតកនៃបា ចូរបាយកហោង អស់សេនា
តាំងពួង តាមចំណង់ចិត្ត បាយកទៅដោយខ្សាស្រីសួស្តីប្រសើរហោង ។

ព្រះមហាសត្វនោះ អ្នកខ្ញុំសូមស្តេចថា បពិត្រមហាភន្ត កុំបីព្រះអង្គ
ព្រួយព្រះហឫទ័យបារម្ភត្រង់ព្រះពុទ្ធសន្តានឡើយ តាលខ្ញុំនឹងឲ្យ
ដំណើរទៅនោះ ខ្ញុំឆ្លាក់ទុកនឹងស្តេចថា បពិត្រមហាភន្ត រាជានុជ្ញា
ទើ ចូរអម្ចាស់តម្កល់នាហានជាព្រះមាតា ហើយខ្ញុំអតិសេកនាងបញ្ចាល
ចន្ទីដ៏ជាព្រះពុទ្ធធីតានៃអម្ចាស់ តម្កល់ទុកហាន:ជាសម្តេចព្រះប្អូន ហើយ
ទើបខ្ញុំឲ្យដំណើរទៅ តាមខ្ញុំនឹងនាំមហាសត្វត្រង់ឯ ឲ្យព្រះអង្គឲ្យមក
ថ្វាយបង្គំព្រះជាទេអម្ចាស់នាប៉ុ ! នេះ កុំបីព្រះអង្គព្រួយបារម្ភឡើយ ។

ពជា សាធុ បណ្ឌិតានំ ។ បណ្ឌិតអើយ ចៅអ្នកប្រាជ្ញគប់តិត
ចោទ អស់ព្រះពជទ្រព្យស្តេចខឹងធ្វើចៅថ្វាយជាអំណោយនៃព្រះពជ
ជិតា មានទ្រព្យបេស់ខ្លះនៃបតីខ្ញុំស្រី ខ្ញុំប្រុស គោ ក្របី ខ្លូវសំពត់សារ
អាវស្បែគ្រឿងប្រដាប់មកុដ អាពាមអន្ទាមព្រះសូរឆត្តកុណ្ឌល អំតល់ខ្លូវ
ពាហុត្តែ ប្រដាបសម្រាប់ខ្លូវគ្រឿងប្រតៃ ម្លូវសេះ ដំរី រទេះចង ហើយ
បង្គែរឲ្យមកព្រះមហាសត្វដូច្នេះថា ម្នាលមហាសថអើយ អស់ទ្រព្យ
ធនទាំងឡាយនេះ ចូរបាំពៅឲ្យនាងបញ្ចាលចន្ទីកូនអញហោង ។
លំដាប់នោះ ស្តេចតំបារណាកិច្ចការធឹងអស់យោធាដំរី យោធាសេះ
រទេះទាងឡាយថាដូច្នេះ :

យោ ធនន្តុ ហាត្ថីនំ អស្សានំ ទ្វិបុណាំ វិនំ
តាសេន្តុ អន្ធកាឆេន រថិនោ បតិតាវតោតំ ។

ម្នាលអាមាត្យទាងឡាយ ចូរអ្នកឲ្យស្មៅខ្លូវចំកកងថ្ងៃទីមួយ ឲ្យន
ព័រដងជលដំរី សេះ គោ ក្របីធងដកបពៅ ចូរចំអែតខ្លូវចុយទំកដល់
សេនាដំរី សេនារទេះ ខ្លូវសេនាពលថ្មើរដើង ពលបានការទាំងឡាយ
កុំឲ្យលំបាកកណ្តាលផ្លូវឡើយ ស្តេចបង្គាប់អម្បាលនោះហើយ ទើងឲ្យ
ដំណើរព្រះមហាសត្វថាដូច្នេះ :

ហាត្ថីនំ អស្សេ រថេ បត្តិ តច្ឆេកាយ បណ្ឌិត
បស្សត្តុ តំ មហារាជា រោទេហោ មិថិលំ តតន្តិ

បណ្ឌិតៈ ម្នាលចៅអ្នកប្រុងដូរអើយ ចូរចៅទូលយកខ្លួរសេនាដ៏រី សេនាសេះ សេនារទេះ សេនាពលថ្មើរជើង ចូរចៅទៅគាន់ស្តេចវិទេហរាជជាស្តេចធំ តំនឹងបានយល់ចៅទៅស្រុកមិថិលានាយហោង ។

ឥតិ សោ បណ្ឌិត ឬ មហាឆ្នំ សក្ការំ កត្វា ឧយ្យោជេសិ ស្តេចឲ្យធ្វើរង្វាន់សក្ការៈជាច្រើនដល់ព្រះមហាសត្វស្រេចហើយ ឲ្យដំណើរទៅ ។ អស់ស្តេចទង់តាំងឡាយ ១០១ គឺបូជាសក្ការៈដ៏ធំនូវគ្រឿងបណ្ណាការដ៏ច្រើនដល់ព្រះមហាសត្វនោះ ។ ឯអស់ទេពលិក្ខិត្តបុរសទៅគាន់សំណាក់នៃស្តេចតាំងឡាយនោះ ហើយគឹមកចោមរោមព្រះមហាសត្វឯង ។ ឯព្រះមហាសត្វនោះ ធ្វើដំណើរទៅគាន់ផ្លូវដោយបរិវារជាបេប៉ាតលសកលរយោធាសេនាដ៏ច្រើន អ្នកយកខ្លួរអាទត្យបម្រើអាត្មា ដើម្បីនឹងឲ្យទៅមាំអស់បណ្ណាការជាដង្ហើយអំពីស្រុកទត្តបញ្ចាល ខ្លួរអស់ស្រុកព្រះបាទបុប្ផនីឲ្យនោះ ដ៏លវង្វែកផ្លូវនោះឯង ស្រេចហើយ ត្រឡប់ទៅគាន់ស្រុកព្រះបាទវិទេហរាជនោះវិញហោង ។

សេនកោបិ កិរ បុរិសំ បេសេត្វា ចុទ្ទនីរញ្ញោ អាគមនំ ឯ អនាគមនំ ឯ ជានិត្វា យស្សកស្សចិ អាគមនញ្ច មយ្ហំ អាវេ ចសីតិ អាណាបេសិ ។

បពិត្រអើយ ឯាទញ្ញមកថា នាគាសព្រះបាទវិទេហរាជ ស្តេច

មកអំពីស្រុកទក្ខវបញ្ញាលនោះ អាចារ្យសេនកៈគាត់នាំពុកនូវប្អូនសម្រេច
អាត្មាឲ្យចាំនូវលង្វែកផ្លូវនោះហើយថា ម្នាលអ្នកចាំងឡាយអើយ ចូរ
ព្រះស្តេងតែតចាំនៅហាទនេះ ចូរឲ្យដំណឹងដំណើរអ្នកមកកុំ អ្នកទៅកុំ ហើយ
ត្រែងបម្រើស្តេចចុឡនីតាមមកនោះ ចូរព្រះស្តេងទៅជ្រាបអញហោង ។
ឯបុរសនោះ កាលណាបើបានឃើញដំណើរព្រះមហាសត្វ អ្នកមកមួយ
អន្លើនឹងសេនាផងច្រើន មានចំប៉ុនចឹងផ្លូវនោះបើយោងន៍ ឯបុរសនោះ
ក៏ទៅជ្រាបអាចារ្យសេនកៈថា ស្រីតព្រះមហាសថអ្នកជ្រាជ្ញមកមួយអន្លើ
នូវមពលច្រើន ។ អាចារ្យសេនកៈកាលណាបើបានឮនូវពាក្យនោះហើយ
ក៏ចូលទៅគាន់ពាជត្រកូល ។ លុះដាច់នោះ ស្តេចឃើញ
នោលើផ្ទៃប្រាសាទធំ ហើយទតទៅក្រោយ ដោយនូវចន្លោះសីហបញ្ជរ
បរិវេច្ឆិចនោះ ឃើញនូវពលសេនាយេ ងារនៃចៅមហោសថអ្នកជ្រាជ្ញជា
ច្រើន ក៏មានព្រះហឫទ័យតក់ស័យនោះមហិមា ទើបទ្រង់មានព្រះបន្ទូល
ថា រីសេនាពលនៃចៅមហោសថអ្នកជ្រាជ្ញនោះហាក់ដូចតែចេ ឥឡូវ
សេនាយប់ជ្រាកដមកនេះច្រើនក្លាត ប្អូមួយសេនាស្តេចចុឡនីលើកទ័ព
មកតាមប្អូអេះ ព្រះអង្គទ្រង់ពិចារណានូវប្រការអម្បាលនោះហើយ ស្តេច
ជណ្តើរទៅអាចារ្យសេនកៈថាដូច្នេះ :

ហន្ទ្តី អស្ស្ត រថា បត្តី សេនា សា វិស្ស្តតេ មហា
បត្តុដ្ឋិនី កិសរូបា កិន្នុមញ្ញតិ សេនកាតិ ។

សេនកៈ ម្នាលអាចារ្យសេនកៈអើយ រីសេនាយោធានោះច្រើនក្ដាត់ មានអង្គនោះ ៤ ដំពូក មានសេនាដ៏រី សេនាសរ សេនាពាហ្នរើដើង មានសភាពគួរខ្លាចពេក យល់ច្បាក់ដូច្នេះ តើអ្នកចាំងខ្លាយនឹងតតម្ដេចហ៊ុនៈ ។ លំដាប់នោះ អាចារ្យសេនកៈ ទូលស្ដេចនោះថាដូច្នេះ :

អានន្ទោ តេ មហារាជ ខត្តមោ បដិនិស្សតិ
សព្ពំ សេនាឧទាយេ រសាតិប្បត្តោ មហោសធោតិ។

មហារាជ បពិត្រក្សត្រៃលោកប្រសើរអើយ អានន្ទោ រ័ក្ដីព្រះអំណារតុត្តមនឹងមានច្បាកដ យល់មកដល់ព្រះបាទអម្ចាស់ឯង ព្រះមហាសថអ្នកច្បាជ្ញគប្រមាំអស់សេនាធនឹងខ្លាយ មកដោយខ្លួវស្ដួចហើយ ព្រះបាទវរិទេហរាជ ស្ដេចស្ដាប់ពាក្យអាចារ្យសេនកៈនោះហើយបន្ទូលថា:

សេនកៈ: ម្នាលអាចារ្យសេនកៈអើយ រីឯមហាសថអ្នកច្បាជ្ញមានសេនានោះតិចពេ រីសេនាទេះត្រូវប់ជាច្រើនពេកក្ដាត់រឹញ បពិត្រមហារាជអើយ ស្ដេចចុះឲ្យនិនោះ ចៅដោយអញ្ជឹងតែនេះ យលជាលុះដោយខ្លួវអានុភាពច្បាជ្ញានៃព្រះមហាសថអ្នកច្បាជ្ញនោះហើយ មហារាជ ឯសេនាចាំងពួងនោះ តែស្ដេចចុះឲ្យនឹងព្រះមហាសថនោះឯង កុំបីព្រះអង្គព្រួយបារម្ភឡើយ ។ ឯណា ឯតរេ តេវិជ្ជា ភវេសិ លំដាប់នោះ ស្ដេចឲ្យខ្លួងស្ដេរតេវិជ្ជា ដ៏ច្បាមច្បាប់ថង្គាប់ឲ្យរៀបប្រដាប់ព្រះនតរហើយ ឲ្យនាំគ្នាទៅទូលមហាសថអ្នកច្បាជ្ញ ។ អ្នក

ខនវេនឆាំងឡាយ ស្តាប់ចំពាមនោះហើយ សឹងតែត្រេកអរសោទរ ទាំង
គ្នាទៅទូលព្រះមហោសថ ដូចបង្គាប់នោះហោង ។ ព្រះមហោសថ
អ្នកប្រាជ្ញដួលមកកន្លងព្រះខនរនោះហើយ ក៏ឡើងទៅគាន់ស្តេចស្រេចគ្រាប
ថ្វាយបង្គំ ហើយក្រាស្រ័យសួរមហាក្សត្រនោះហើយហោង ។ លំដាប់
នោះ ស្តេចខនតីយលំនោចជិសត្វមហាបុរសវត្តិសេសហើយ មាន
ព្រះពរជាហ្មឺយនោះត្រេកអរសោមនស្ស ស្តេចទំនឹងតំរិះលើព្រះពរ
បញ្ហាមាសនោះតុំចានឡើយ ស្តេចបុះទៅនូបអង្គែលថ្នមព្រះមហោសថ
អ្នកប្រាជ្ញ ហើយធ្វើក្រាស្រ័យសួរទូលថាដូច្នេះ :

យថា មេតំ សុសានស្មឹ ឆន្ទេត្វា ចក្ខុកេ ឥធ
ឱរំ តេមិសំ យេ ក្ស្ហា ឆឌ្ឌយិត្វា ឥធាគតា
អថ តុំ តេន វណ្ណេន តេន ភ បឯ ហេតុនា
តេន ភ អត្ថជាតេន អត្តានំ បរិមោចយីតិ ។

មហោសថ ម្នាលមហោសថអើយ ក្សត្រទាំង ៤ ព្រះអង្គ
ស្តាប់បង់នូវយសបរិពារ សឹងមានទុក្ខទញ៉ាចំប្រប់ប៉ីដូចភ្លោចគេយកទៅ
ចោះបង់ចោលនៅព្រៃស្មសាន មុខតួរឲ្យអាសូរកុណានោះម្តេចមិញ រី
យើងចោលបង់បាឫដ៏ស្រួកកបិលពាស្តុអាហានឲ្យនោះ ឧបមាគុណនា
ដូច្នោះហោង ប្រការមួយទៀតសោត រំបាអាចដោះយើងឲ្យរួចនូវអាត្មាយើង
ដោយនូវហេតុក្រាជ្ញាណាបាជាប្រយោជន៍ម្តេចហ៊ុនេះ ។ លំដាប់នោះ

ព្រះមហាសត្វអភិលាសស្តេចថាដូច្នេះ:

អត្ថិ អត្តេន វោទេហំ មត្តិ មន្តេន ខត្តិយ
បរិភារយិ សំឃ ភជាឯ ឥមុនិបិវ សាគរោតិ ។

បពិត្រមហាកប្បជាក្សត្រដ៏ឧត្តមប្រសើរអើយ តម្រិះនៃស្តេចធំ
ខ្លាំងឡាយ ក៏ចាមភេមតំនិតនៃអញខ្ញុំ ឯអញខ្ញុំសោត រិះគិតចាមភេម
ស្មាក់តំនិតស្តេចធំខ្លាំងឡាយនោះ ដូចមហាសមុទ្រចាមភេមជម្ពូទ្វីប
នោះហោង ។ ស្តេចស្តាប់ពាក្យនោះហើយ មានព្រះហឫទ័យត្រេក
អរក្រៃពេក ។ លំដាប់នោះ ព្រះមហោសថអភិបាលក្សត្រ ទំនិសវែងនូវ
ក្រុងនូវគ្រឿងបណ្ណាការ ដែលស្តេចបង្គ្រាទ្រឹងមកអាត្មាអភិបាលថាដូច្នេះ:

ទិដ្ឋំ ឯកូសបាសឡំ មេ តាមាសីតញ្ច តោសិសុ
ឆាសីសតានិ ចត្តារិ តរិយោសតញ្ច មេ
សព្ពំ មេ សេដ្ឋឆ្ឌមាទាយ សោត្ថិនមិំ ឥជាតគោតំ។

នេះ បពិត្រមហាកប្ប រមាសមួយតាន់ ទឹងស្រុក ៨០ ទឹងតរិយា
មួយរយ នូវខ្ញុំស្រី ៤០០ គឺស្តេចឲ្យអញខ្ញុំ អញខ្ញុំយកអស់សេនាចាំង
ពួងនោះ មកកាន់ស្រុកម៉ិថិលានគរនេះ ដោយនូវស្រីសួស្តីហោង ។

ស្តេចនោះត្រេកអរនឹងព្រះមហាសត្វ ហើយសរសើរគុណព្រះ
មហាសត្វដូច្នេះ:

សុសុខិ វត សំភិសោ បណ្ឌិតេហិតិ សេដ្ឋភាវ

ปกฺกิตฺวา ฯเปฯ ตาวเทว มญฺเจ ฉาลกเตวาติ

อภิสมฺพุทฺธกาเล มหาชโน ฉนฺโน มโหสเธนาติ

ម្នាលអាចារ្យសេនកៈអើយ ក៏ទៅមហោសថអ្នកប្រាជ្ញ កំអាច
ដោះយើងឲ្យរួចអំពីកណ្តាប់ដៃនៃសត្រូវ ដូចគេដោះសត្វបក្សីឲ្យរួចពី
ទ្រុងគេទាំងកំពង់ជាប់នោះ ពុំនោះសោត ដូចគេដោះគ្រឿងអំពីសំ-
ណាញ់ ឬស្តេចគោ រស់អ្នកប្រាជ្ញដូចទៅមហោសថនេះ សុខាវហោ
សីឆនំ ឲ្យសុខនៃអ្នកផងទាំងពួង ។បមាដូច្នោះឯងហោង ។ ម៉ែអា-
ចារ្យសេនកៈសោត សឹងសរសើរគុណនៃពោធិសត្វ ដូចស្តេចនោះឯង
ហោង ។ លំដាប់នោះ ស្តេចឲ្យទូងស្គរតេរ៉ែប្រាប់ប្រជុំជនទៅអស់
អ្នកផង ឲ្យចូលមូលមកលេងទូវល្បែងមហោស្រពតំរង់ជា ៧ ថ្ងៃ ហើយ
ថាដូច្នេះ បើអ្នកឯណាមានចិត្តស្រឡាញ់អញ ជាស្តេចជាអម្ចាស់អស់
អ្នកទាំងពួងហើយ ចូរអស់អ្នកទាំងនោះ មកបូជាសក្ការៈដល់ព្រះមហោ
សថ ជាបុត្រស្ងួនសម្លាញ់អញហោង ។

สมนนฺตา ปกาเสนฺตา สตฺตาหา อาหา ។ ตทา ตาวเทว
ម្នាលកុក្កុធទាំងពួងអើយ រាត្រីធម៌ឯណាពុំទាន់ចែងចាំបាច់ លុះ
ព្រះចន្ទគ្រាស់ហើយ កំនាំរាត្រីធម៌នោះមកប្រកាសឲ្យជាក់ច្បាស់
រហើយពោលគាថាដូច្នេះ :

อาหญฺจ สพฺพปาณา เตวิชฺชา เจวฺหิมานิ ๓

ឧបដ្ឋ មាកដា សង្ខា វក្ខ ឧទដ្ឋ ឧដ្ឋភីតំ ។

ចូរអ្នកចាំដង្ហាយ ដេញទូវតីណាធំតីណាតូចឆន់ចាំដួង ចូរដំទូវស្គរកេរី ទូវសម្ភោរហ្គុកផងមានសំឡេងនោះមធ្យមូលពីកេះ ចូរផ្លុំទូវស័ង្ខ ភាយទូវគាំង គោះតន់ផងសឹងមានសព្ទនោះ លេងគគ្រែងកងមិ.ចំលានតរនោះហោង ។ លំដាប់នោះ រីពួកអ្នកនគរនឹងអ្នកជនបទចាំងនោះ សឹងមានចំណង់ចង់ធ្វើបូជាសក្ការ ចំពោះចៅមហាសង្ឃអ្នកប្រាជ្ញជាប្រក្រតី កាលណាបើបានឮកេរីបំពាមនោះហើយ សឹងតែមិតមូលចូលមកច្រើនវិក្រៃពេកហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ កិត្តកវេ ម្នាលភិក្ខុផងចាំដង្ហាយអើយ រីព្រះបរមសាស្តាចារ្យនៃយើង ព្រះអង្គទ្រង់ប្រកាសទូវអាថ៌ប្រស្នានោះហើយ ទើបតោលទូវគាថាដូចតទៅនេះ:

ខត្តិយោ ច ព្រាហ្មណោ ច វេស្សិយោ ច ព្រាហ្មណោ
ពហុំ អន្នញ្ច បានញ្ច ។ លភិត្ថ សក្ការំ យុំ

។ ល ។

ពហុដ្ឋនោ បសន្នោសិ កិស្ស បណ្ឌិតមានតេ
បណ្ឌិតម្ហិ អនុប្បត្តេ ចេលុក្ខេបោ បវត្តិថាតិ ។

អស់ព្រះស្តេក្រមការ មានទាង១ខត្តកវេរីជាប្រធាន អស់ពាជត្រកូលកុមារទូវអស់ព្រាហ្មណ៍ព្រឹទ្ធាចារ្យ ទូវឈ្មួញដើងចំកណ្ឌញដើងគោក

ខ្លះសង្ខិតខាងឡាយក្តី នាយដំរី នាយសេះ នាយរទេះ នាយពលថ្មើរជើងខ្លាំងក្លាជាដរាបតទៅក្តី សឹងនាំនូវជ័យទឹក ចំណីគ្រឿងសាច់ ញាំក្ងាសាមកច្រើន ឯអស់អ្នកស្រុកធំនិគមស្រុកក្រៅលំនៅជនបទ អស់អ្នកជង្គាំជាំងខ្លាយនោះ កាលណាបើយល់ព្រះមហាសថអ្នកប្រាជ្ញជាន់ខ្ពស់មកហើយ មានចិត្តនោះត្រេកអរ សឹងតែរំកាយកន្ទេលវែង មាលាបូជាសក្ការៈដល់ព្រះមហាសថ អ្នកប្រាជ្ញជានិន្ទ័រុំដែលជាចាស់ឡើយ ។

កាលនោះ ព្រះពោធិសត្វ អ្នកឡើងទៅគាន់ពាដត្រកូល ហើយអ្នកខ្លួលថា បពិត្រមហារាជអើយ គួរអម្ចាស់បញ្ជូនព្រះរាមាតានូវនាងនន្ទាទៅ នូវព្រះពាជបុត្រទៅឲ្យព្រះបាទបុប្ផវតីធាប់ឯង ។ ស្តេចទ្រង់ព្រះសណ្តាប់ពាក្យពោធិសត្វនោះហើយ ទ្រង់ស្តាយកថាតាប់ហោង ។ ចូរបាបញ្ជូនមហាក្សត្រទាំង ៣ ព្រះអង្គទៅហោង ។ ឯព្រះមហាក្សត្រកំបានបូជាគ្រឿងសក្ការៈជារបើនទៅមហាក្សត្រទាំងបីព្រះអង្គនោះ ហើយឲ្យផ្ងារន់ជាគ្រឿងសក្ការៈដល់សេនាផង ដែលជូនមកជាច្រើន ទើបអ្នកបញ្ជូនមហាក្សត្រទាំង ៣ ព្រះអង្គឲ្យទៅ មួយអន្ទើនធំបរិវារជាច្រើន ទាំងបុរសបំរើតាំងឯង ។ ពោធិសត្វឲ្យដំណើរប្រពន្ធស្តេចទាំង ១០១ នូវពុំស្រុ ៤០០ គឺព្រះបាទបុប្ផវតីទៀងនោះ មួយអន្ទើនធំអស់សេនាដែលមកមួយអន្ទើ ទាំងអាត្មាអ្នកក្តី សឹងឲ្យជូនដំណើរទៅជាមួយ ទាំងក្សត្រទាំង ៣

ព្រះអង្គនោះហោង ។ ឯស្តាចនោះ ដឹងនូវ អាលិង្គិត្វា សីសំ ចុម្ពិត្វា អាឃុដ្ឋាមិ តុវំ អម្ម កមិសច្ឆាមិ អម្មាតំ វដ្ដា មហាន្តេន សទ្ទេន បរិទេវី ។ រីនាងនន្ទាទេវីនាងជាម្តាយនៃបក្រសោបអង្អែលព្រះរាជធីតា ហើយថើបព្រះកេសាទួញទ្រនំព្រះកន្សែងថ្វែងពាលបអាណិតអាទាថមុខតួឲ្យអាសូរកុណា ហើយនាងថាអ្នកមាសម្តាយអើយ ចូរនាងទៅអាយ ម្តាយនឹងលានាងទៅហើយ ។ ឯនាងបញ្ចាលចន្ទីថ្វាយបង្គំព្រះវរមាតា ហើយទួញទ្រនំព្រះកន្សែងមានស័ព្ទខ្ទេញយោចំនោះភ្ញាំងថា បពិត្រព្រះមេអម្ចាស់ខ្ញុំអើយ កូនធ្លាប់រែងទៅជាមួយនឹងអ្នក ឥឡូវនេះ អ្នកឃ្លាតទៅលែងទៅវិញហើយ អម្ចាស់កូនអើយ អ្នកលះបង់កូនដែលងាំហើយ កូនស្រណោះណាស់ហោង ។ ឯមហាសត្វត្រាំងថ្វាយព្រះអង្គនោះលីលាទៅជាមួយនឹងអស់បរិវារយេហ៍ពលសកលយោធាធងន់ច្រើន ចូលទៅដល់ខនារុតត្តរបញ្ចាលរដាយលំដាប់ ស្តេចឡើងលើព្រះរាជមន្ទីរ ។ ក្នុងណានោះ ព្រះចុន្ទបុប្ផនីបន្ទូលដល់ឆន្នឹងស្តេចព្រះវរមាតាហើយថា បពិត្រអ្នកព្រះមេអើយ សេចក្តីសង្រ្គាះដែលស្តេចវិលមកវិញ ធ្វើចំពោះអម្ចាស់នោះតើដូចម្តេចហ៊ុ ។ ព្រះរាជមាតាតបថា តាត ម្នាលកូនអើយ ទ័ន្ធស្រដីអ្វីឡើយស្តេចវិលមកវិញ អ្នកតម្កល់វត្តប្រតិបត្តិ ស្មើហ៊ានទៅតាដ៏ប្រសើរ ហើយធ្វើបូជាសក្ការដល់យើងជាច្រើន ហើយដំណើរត្រឡប់

ស្តាពបរិត្តនោះនៃអាត្មាទាំងជាហានៈជាសម្តេចព្រះអយ្យិកាហោង ។ ឯទាំងខ្ញុំតម្កល់ហានៈជាព្រះវរមាតា ហើយស្តេចតម្កល់ខ្ញុំបញ្ចាលចន្ទីកុមារកុង៑ហានៈជាប្អូន ។ តំ សុត្វា រាជា អតិវិយ តុស្ស-ន្តោ ។ ស្តេចស្តាប់ពាក្យនោះហើយ មានព្រះហឫទ័យត្រេកអរសោ-ទរក្រៃពេក ទើបស្តេចឲ្យដូនខ្ញុំបណ្ណាការត្រកាលឧត្តមនោះទៅព្រះពជបុត្រជាច្រើន ចាប់ដើមអំពីថ្ងៃនោះទៅ មហាក្សត្រទាំងពីព្រះអង្គ គឺស្តេចវិទេហរាជ និងព្រះចុតុបុត្តទីព្រហ្មទត្តរាជ សឹងមានព្រះហឫទ័យស្មោះសរនឹងគ្នាទៅមកតាំងដែលជាច់ឡើយ ។ មហាឧដ្ឋិំ កស្សាំ ជិដ្ឋិតំ ។ ដំណើរដំណាលកណ្តាមហាទម្ងន់នេះមិញ ស្រេចខ្ញុំប្រការអម្បាលនោះហោង ។

បញ្ចាលចន្ទី រញ្ញោ ចិយា មជាតា អហោសិ ។ បតិត្រអើយតទៅនេះ យើងនឹងពណិនាដំណើរអំពីព្រះនាងបញ្ចាលចន្ទីក្សត្រីស្រីវរលក្ខណ៍អយ្យិកាយាប្រសើរវិញ កាលណាបើនាងបានរួមហានលំនៅជាមួយនឹងព្រះចុតុរាជហើយ សឹងជាសំឡាញ់ពេញព្រះពជហឫទ័យមហាក្សត្រនោះហោង ។ លុះនាងបិតទៅជាតំរប់ឆ្នាំពីរហើយ នាងទ្រង់គតគំរប់ខែ ១០ ត្រប់ហើយណាំពុំយូរឡើយ នាងប្រសូតព្រះពជបុត្រប្រុសមួយ មានរូបនោះប្រពៃល្អបរិសុទ្ធ ទើបនាងសន្មតហៅព្រះនាមឈ្មោះថៅដេដ្ឋទីយាវុកុមារហោង ។ រីថៅដេដ្ឋទីយាវុកុមារនោះសោតកាលណា

ចម្រើនធំឡើងបរិបូណ៌ជាគំរប់១០ខ្នាំហើយ ក្សត្រីណានោះមិនយូរឡើយ ព្រះ
ចាទរំខេហាកដស្តេចទ្រង់ព្រះដម្ងឹអាតាធនោះធ្ងន់ពន់ប្រមាណ ឱនឥប់ពុំបាន
ឡើយ ព្រះអង្គរសោយទំវង្គតផុតព្រះជន្មាជាសូរវេច នាកាលនោះហោង។
ព្រះពោធិសត្វមហាបុរសត្រុំវិសេស ខ្លួរអស់មុខមន្ត្រីសេនាបតីធំតូចផង
សឹងតែផ្តង់ផ្តាប់រណ្តាប់លើកសពសសោះ ព្រះបរមសពព្រះចាទរំខេហាកជ
ជាទ្បាវិកអាធ៌តស្រេចបរិបូណ៌ពុំយូរឡើយ ។ ទើបពោធិសត្វបង្វែរ
ស្មូតច្ចត្រភជសម្បត្តិ អភិសេកទ្បៀតដង្ហែយាវុំកុមារសោយរាជ្យ
ស្តិតស្នងត្រែងប្រពៃណីអំពីសម្តេចព្រះវរបិតា ជាក្សត្រប្រសើរប្រកបជា
ឥស្សរកំពូលអស់អ្នកមិថិលមហាទេវនោះហោង ។ ស្រេចហើយ ទើប
ព្រះពោធិសត្វទូលអង្វរលាចៅដង្ហែយាវុំកុមារថា ឆេះ បពិត្រអម្ចាស់
អើយ អញខ្ញុំនេះនឹងលាអម្ចាស់ទៅគាន់សំណាក់ព្រះចាទុឡ្ឍទ្រហ្មទត្ត
រាជ ជាសម្តេចព្រះអយ្យកោអម្ចាស់ឯនាយវិញហោង ។ ឯចៅដង្ហែ-
យាវុំកុមារនោះសោត អ្នកលោមយាត់ទ្បៀពោធិសត្វថា បណ្ឌិត
វៃព្រះមហោសថអ្នកប្រាជ្ញអើយ ឥឡូវនេះ អញនៅក្មេងឡើយ ពុំគាន់
ជឹងធ្ងន់ស្រាល អ្នកកុំអាលចោះបង់អញឡើយ អ្នកអើយ អញនឹងតម្កល់
អ្នកទុកស្មើនឹងពុកអញហើយ អញនឹងធ្វើសក្ការបូជាសព្វថ្ងៃជាប្រក្រតីទៅ
ហោង ។ ព្រះទាងបញ្ជាលចន្ទីសោតមានបន្ទូលថា ម្នាលជាមហោសថ
អើយ កាលបើចៅទៅគេហើយ ចៅអើយនៅឯអាយនេះ គ្មានអ្នកប្រាជ្ញ

ណាខ្ញុំដឹងអាចតម្រង់ដៃថ្លៃក្រោម ព្រះមហាក្សត្រឲ្យជាតំនឹងតំនាក់ដូចខៅនេះ
ក្នុងខ្លួយ ខៅអើយ កុំបីខៅខៅនាយឡើយ ចូរខៅខៅឯអាយនឹង
យើងវិញហោង ។ សេចប៉ិ មហោសធោ ។ ឯព្រះមហោសធ
អ្នកប្រាជ្ញទូលវិញថា បពិត្រអម្ចាស់ខ្ញុំអើយ ខ្ញុំនេះបានដាសន្ធតប្តេជ្ញា
នឹងព្រះបាទចុឡនី ខ្ញុំពុំអាចដើម្បីនឹងខានខៅអាយនេះបានឡើយ អម្ចាស់
ខ្ញុំអើយ ខ្ញុំក្រាបលាអម្ចាស់ខៅហោង ។ បពិត្រអើយ កាលនោះ
អស់មនុស្សម្នាមហាជនជងតាំងឡាយឮសុសសាយខៅថា តោធិសត្វ
អ្នកនឹងលីលាចេញខៅនគរទុត្តរបញ្ចាលជូរច្នោះកូវ អស់អ្នកជងតាំងឡាយ
នោះ សឹងតែមកយំទួញនឹងព្រះមហោសធអ្នកប្រាជ្ញ អាធិកតន្ទឹកមហិ-
មាមុខត្តរឲ្យអាស្សូរកុណាតេកហោង ។ លំដាប់នោះ តោធិសត្វអ្នក
យកតែបុរសអាមាត្យអម្បាលដៃលបំរើអាត្មាវិញមានប៉ុន្មាន ។ ហើយអ្នក
លីលាចេញខៅអំពីមិថិលាមកោនគរ ខៅថ្ងាននគរទុត្តរបញ្ចាលនោះវិញ
ហោង ។ កាលបើតោធិសត្វ អ្នកលីលាខៅទៀបហៀបដល់នគរទុត្តរ
បញ្ចាលនោះហើយ ព្រះចាទចុឡនីព្រហ្មទត្តរាជ ស្តេចឮតតិមានថា
ដំណើរព្រះមហោសធអ្នកប្រាជ្ញអ្នកនឹងចូលមកនគរអាត្មាជូរច្នោះកូវ ស្តេច
ឲ្យខៅទទួលតោធិសត្វចូលមកកុងព្រះនគរហើយ ស្តេចឲ្យបូជាទូរគ្រឿង
សក្ការៈតោធិសត្វនោះច្រើន ហើយស្តេចឲ្យផ្ទះប្រសើរឲ្យខៅព្រះមហាសត្វ
អ្នកតន់ខៅហោង អស់ស្រុកប្រសើរ ៨០ សម្រាប់ការអំណោយ ស្តេច

ឲ្យអំពីមុនយើងមិនស្រដីឡើយ យើងស្រដីតែឲ្យអំណោយស្តេចវិញ
ទៀតហោង ព្រះគោធិសត្វមហាបុរសវត្ថុវិសេស អ្នកតែងចំរើនបដ្ឋាក
នូវព្រះបាទបុប្ផនីជាប្រក្រតីសព្វថៃ្ងទៅហោង ។

តទា កេរី ជាម បរិព្វាជិ រាជកេហេ បរិភុញ្ជតិ។
សោ បណ្ឌិតោ វត្តា ។ តាយ មហាសត្តោ ឯ
កិដ្ឋបុត្តោ ។ កាលនោះ មានឥសីជាមួយឈ្មោះ កេរីបរិព្វាជិកា
នាងតែងនិមន្តទៅឆាន់ចង្ហាន់នៅលើព្រះរាជមន្ទីរ នៃព្រះបាទបុប្ផនីព្រ -
ហ្មទត្តនោះហោង ។ នាងជាសោត មានប្រាជ្ញាឈ្លាសជំនាញធម៌អាថ
ប្រស្នាផង ឥតខ្វេសខាល់សល់ដំណាក់កំបាំងនឹងប្រាជ្ញានាងនោះបាន
ឡើយ ។ នាងកេរីបរិព្វាជិកា នាងគិតដូច្នេះថា ឯចៅមហោសថ
អ្នកប្រាជ្ញ អំពីមុនមកនោះ អញខ្ញុំពុំដែលឃើញស្គាល់ដល់ម្តងឡើយ ។
អញឮដោយពាក្យគេថា ឥឡូវនេះចៅមហោសថបណ្ឌិតមកបម្រើជាខ្ញុំ
ព្រះបាទបុប្ផនីព្រហ្មទត្តរាជហើយ អញខ្ញុំធ្វើម្តេចនឹងបានឃើញស្គាល់
ម្តងអេះ ? ព្រះមហោសថសោត អ្នកថាៈដោយអញឮមក គេប្រាប់អញ
ថា មានឥសីជាឈ្មោះនាងកេរីបរិព្វាជិកា នាងតែងទៅឆាន់ចង្ហាន់លើ
ព្រះរាជមន្ទីរសព្វថៃ្ង អញធ្វើម្តេចនឹងបានឃើញស្គាល់នាងនោះម្តងអេះ ?
ឯអ្នកទាំងពីរនោះ សឹងតែងមានចំណងចំងើយលាន់គ្នាទៅវិញទៅមក ដោយ
នូវប្រការដូច្នោះហើយ នាងនន្ទាខេពីរសោត នាងឃើញព្រោធិសត្វតែង

អាពាហ៍ពិពាហ៍

(វិចារណកថា)

លោក ដេង - ត្រើវ តែងរៀបរៀង

អាពាហ៍ពិពាហ៍ ជាប្រពៃណីរបស់មនុស្សក្នុងលោក ឯការផ្សេងគ្នា
ទៅត្រង់តែជាតិនេះប្រកាន់ ឬ ទំយមរបៀបធ្វើបែបនេះ ជាតិនោះទំយម
របៀបធ្វើបែបនោះ ដោយអនុលោមទៅតាមប្រទេសទំនៀមការយល់ឃើញ
រៀងៗខ្លួន ។

ឯអាពាហ៍ពិពាហ៍ដែលខ្ញុំត្រូវលើកយកមកពិចារណាក្នុងអត្ថបទនេះ
គឺជាអាពាហ៍ពិពាហ៍ខ្មែរ ។

អាពាហ៍ពិពាហ៍គឺជាអ្វី? អាពាហ៍ពិពាហ៍ (រៀបមង្គលការ) គឺជា
ពិធីចុះកិច្ចសន្យាមួយ រវាងបុរសទំនឹងស្ត្រីពីរនាក់ ដើម្បីវៀញខ្សែដៃរឹតបញ្ចូល
គ្នាឲ្យបានមានសភាពដ៏យ៉ាងម៉ាំ យ៉ាងជាប់ ក្នុងការធ្វើដំណើរទៅអនាគត
របស់ខ្លួន ព្រោះយល់ឃ្លាស់ថា ដីវភាពរុងរឿង ដីវភាពសុខដុមមេនា
ដីវភាពប្រកបដោយសុភមង្គល សម្រេចទៅលើគូនៃខ្សែដីវិតនៃជនទាំង
ពីរនេះឯង បើខ្សែគូណាមួយធូរ ឬ រលា មិនក្តាប់ម៉ាំស្អិតទំនឹងខ្សែគូមួយ
ទៀតទេ ដំណើរដីវភាពនៃគ្រួសារនោះ ត្រូវតែមានការអាក់អួលជាពិត
ប្រាកដ ។ មានពាក្យទាយបស្ចិមប្រទេសមួយម៉ាត់ហៅប្តី ឬ ប្រពន្ធថា

អឌ្ឍភាគ (moitié) (ភាពពាក់កណ្តាល) : ពាក្យនេះ តាមការពិចារណា ទៅ ឃើញថាត្រូវពិតណាស់ៗនៅអឺរុប បើមានគ្រឿមកលេងផ្ទះ គេច្រើនយកពាក្យនេះមកប្រើ ដើម្បីចំអន់ចំពោះអ្នកណាដែលថ្ពើបុប្រពន្ធមិនឃើញមកជាមួយគ្នាថា: អឌ្ឍភាគអ្នកឯងទៅណា មិនឃើញអញ្ជើញមកផង? ចុះសេចក្តីថាប្រពន្ធ ឬ ប្តីទៅណា ក៏មិនឃើញជាប់គ្នាមក ឃើញមកតែម្នាក់ឯង? នៅបស្ចិមប្រទេស ប្រពន្ធប្តីតែងទៅណាជាំជានគ្នា ។ ដូច្នេះ នៅពេលជាបឋម ដែលបុរស ស្ត្រី រៀបការរួមដំណេកជីវិតបញ្ចូលគ្នានេះ គេហៅថា «អាពាហ៍ពិពាហ៍» ពាក្យសាមញ្ញថា «រៀបមង្គលការ» ឬ «រៀបការ» ។

នៅតុការសនៃពិធីអាពាហ៍ពិពាហ៍ខ្មែរយើង មានការណ៍ឃើញកិច្ចមួយដែលបងប្អូន ឬ សាច់ញាតិដឹងឆ្ងាយ ត្រូវតែបំពេញ ។ ឯការណ៍ឃើញកិច្ចនេះ ហៅថាចំណងដៃ ។

សួរថាចំណងដៃនេះ ដូចម្តេចក៏ត្រូវឲ្យមាន? តាមការពិសោធន៍ការពិចារណា ខំឆ្ងល់តឹងទៅ ឃើញថា មុនដំបូងឡើយ ចំណងដៃនេះគឺជាជំនួយទេតើ! ព្រោះមុនដំបូង កូនប្រុសកូនស្រី បានរស់នៅក្នុងបន្ទុកឪពុកម្តាយ គឺខ្លួនជាសមាជិកនៃគ្រួសារដែលមានមាតាបិតាជាប្រធាន ការខុសត្រូវគ្រប់វិស័យ ត្រូវធ្លាក់ទៅលើមាតាបិតាទាំងអស់ ។ ពេលតែថ្ងៃអាពាហ៍ពិពាហ៍ទៅ គឺខ្លួនទាំងពីរនាក់នេះហើយ ដែលត្រូវទទួលខុសត្រូវលើខ្លួនទាំងស្រុង មាតាបិតា ឈប់មានការពាក់ព័ន្ធអំពីរឿងនេះទៀត ។

ពាក្យខ្មែរបុកណា តែគេនៅប្រើសព្វថ្ងៃថា : ឥឡូវកូនដុះស្អាបគេញ
សេញហើយ ត្រូវលែងកំភៅ ចានន័យថាកូនធំហើយ ត្រូវរៀបការ
ឲ្យរៅ រួចឲ្យរកស៊ីចំពោះខ្លួនវិញ ។ កុំថាឡើយដល់ទៅមនុស្សនឹងសត្វ
សូម្បីតែឈើជាតិ បើគេត្រូវការបំបែកពីដើមមក ទឹងយកទៅដាំតែម្នាក់
ឯតែម្តង ក្រែងជាតិនោះនឹងអាចដុះលូតលាស់ល្អបាន ដោយលំបាកណាស់
ប្រសិនបើគ្មានយកឈើអ្វី ទៅដោតអបជាដំបូយបណ្តោះអាសន្នសិន ។ ឯ
ចំណងដៃ ទុកដូចជាដំបូយ សម្រាប់គាំពារដំណើរដើរកាត នៃតួស្រីតវថ្មី
នេះដែរ ។

ដំបូងឡើយ តើចំណងដៃមានសភាពជារបៀបណា ? តាមការ
ពិចារណា ចំណងដៃ ត្រូវនិយមតាមមជ្ឈដ្ឋាននៃតួស្រីតវថ្មី គឺគេមិនមែន
ចងដៃដូចសម័យយើងឥឡូវនេះទេ គេច្រើនចងជារបស់ប្រើប្រាស់ ដូចជា
ឆ្នាំង ចាន សំពត់ អាវ រនេះ គោ ក្របី ខ្លែ រនាស់ ។ល។
ព្រោះរបស់ទាំងនេះហើយ ដែលសម្រាប់អបដំណើរដើរកាតប្តីប្រពន្ធថ្មី
កុំឲ្យឃ្លេងឃ្លោង កុំឲ្យអាក់អួលពេក មានខ្វះគេចងជាប្រាកដែរ តែ
ចំនួនតិច ព្រោះគេយល់ថាប្រាក់ទឹងវិទាសធាប់ហ៊ាស ជាងវត្ថុទាំងនេះ
ល្មះបានសម្ភារៈសព្វគ្រប់ដូច្នេះហើយ ដំណើរដើរកាតថ្មី ទឹងអាចប្រព្រឹត្ត
ទៅស្រួលបាន ចំពោះតួស្រីតវថ្មីនឹងដៃដើង ។ រឿងចំណងដៃនេះ បើពិនិត្យ
ឲ្យម៉ត់ចត់ទៅ មិនខុសគ្នាពីរឿងតុងទឹន សព្វថ្ងៃនេះឡើយ ។ ហេតុដូច

ម្តេចបានជាគេបង្កើតអង្គការតុងឆីនេះ ? គោលបំណងដើម គឺប្រពៃណាស់ គឺថាសម្រាប់សង្គ្រោះអ្នកដែលខ្វះប្រាក់ដើមទុន ក្នុងការរកទទួលទាន តែធ្វើម្តេចលោកវិល ចោលហើយ ការមិនទៀងត្រូវមានជាដរាបបានជាសព្វថ្ងៃ ខ្លះធ្វើមេតុងឆីនេះ ដើម្បីរកផលប្រយោជន៍ពីកូនទៅវិញ គឺថាឲ្យសមាជិកគោរពប្រធាន ដឹងគុណប្រធាន ផ្ទុយពីគោលបំណងដើមដែលប្រធានត្រូវគោរព ឧឡឹងដឹងគុណសមាជិក ដ្បិតខ្លួនមានដើមរកស៊ីដោយសារគេ ឥតមានបង់ការអ្វី ។

ឯរបៀបចំណងដៃនេះ ក៏ល្អាយ ។ ដូចជាតុងឆីនដែរ : ដំបូងចងជារនេះ ជាគោ ជាឆ្នាំង ជាចាន ។ល។ និយាយឲ្យខ្វិតជាសម្ភារៈ ។ បន្ទាប់មក អ្នកដទៃចងជាប្រាក់ បងប្អូនជិត ចងជារបស់ ។ តមកទៀត ចំណងដៃ ក្លាយទៅជាប្រាក់ស្មើរតង្ឹអស់ ។

ឯការដប់លៀង ក្បៀវត្រូវមានជាធម្មតា គឺថ្ងៃកំណត់ឆីនថ្ងៃសំពះ ។ ឯថ្ងៃចូលភេង មិនមានការដប់លៀងទេ ។ សម័យនោះ គោះប៉ាមានការដប់លៀងដល់ពីរថ្ងៃ តែឥឡូវនៅមានផលប្រយោជន៍គ្រាន់បើជាងការដប់លៀងសម័យបច្ចុប្បន្ន ដែលមានតែ ១ លើក ព្រោះការសូដណ្តាំក្តីការធ្វើនំក្តី អាចកើតមានបាន ដោយសារការពឹងគ្នាទៅវិញទៅមក ហើយប្រាក់ដែលត្រូវដាក់ទៅលើដៃបរទេស មានភាគតិច ។ បើតាមការពិចារណាទៅ ឃើញថា ចំណងដៃអាចនៅមានរូបភាពជាជំនួយបានខ្លះ

ដ្បិតការចំណាយក្នុងពិធីជប់លៀង មិនសូវជាច្រើនប៉ុន្មាន ។ តែគោះជាយ៉ាងនេះ កំប្លុំនៅតែចូលចិត្តថាការនិយមជប់លៀង គួរតែប្រើតែចៀសវាងឬបន្ថយ ព្រោះជប់លៀងវាមែងញ៉ាំងជំនួយ ឬ ចំណងដៃ ឲ្យឃ្លាតចាកអត្ថន័យរបស់ខ្លួន ។

សព្វថ្ងៃ តិតមែនតែការអាពាហ៍ពិពាហ៍ថយចំនួន គឺថាខ្លះគេបន្ថយមកនៅត្រឹមតែ ១ ថ្ងៃ ដោយយកពិធីកំណត់ ឧទ្ធពិធីសំពះចង់ដៃកូនប្រុសស្រី រួមបញ្ចូលគ្នា ឯចំណែកជប់លៀង វែរជាវែតធំលើសលប់ ។ យើងឈប់ចេះស្គាល់ណាហើយ ។ ទៅតែលវៀបការកូន យើងនិយមផ្ទៀងគ្រានឆ្នាំងទៅលើចន្លោះអស់ ជួនកាល តែមិនចាំងធ្វើពិធីជប់លៀងទៅផ្ទះការធន តែផ្ទេរទៅជប់លៀងទៅលើផ្ទះចិនវិញ ។

តែបញ្ហា ដែលត្រូវលើកយកមកដោះស្រាយ ក្នុងអត្ថបទ ស្តីពីអាពាហ៍ពិពាហ៍នេះ គឺបញ្ហាជប់លៀង ។

កាលជាន់ដើម ប្រាជ្ញាក្នុងសាសវៀបមង្គលការកូន មានធ្វើពិធីជប់លៀងតូចៗខ្លះ មកតាមលទ្ធិខ្លួន ខ្លាចចិត្តគ្នាវៃ ព្រោះគេធ្វើល្អដល់កូនខ្លួន ឧទ្ធឲ្យគេមកអង្គុយស្រៀម ។ គ្មានមានអ្វីជាគ្រឿងកំដរមាត់ ដូចម៉ិនសមគួរ

ម្ល៉ះហើយ ត្រូវតែមានទំនិញ ទឹកតែឬស្រា អ្វីខ្លះ ជាការថ្លែងអំណរគុណ
ចំពោះគ្នា ដែលគេយកដំណួយមក តែប៉ុណ្ណោះ ។ រឿងនេះ មិនថ្លែកគ្នាពី
រឿងតុងទីនទេ ។ ការណ៍ពិត ដែលខ្ញុំធ្លាប់បានដឹងមក គឺប្រជានតុងទីន
ការប្រមូលប្រាក់បានពីសមាជិកគ្រប់ចំនួន សព្វគស់ហើយ តែងតែទិញ
ទំនិញឬអ្វី ១ ជាអាទិ៍គឺទំតែលាវឬ សាច់ជ្រូក ១ ទាល ឬ កន្ទុះគីឡូ
តាមទំហំទឹកប្រាក់ច្រើនតិច យកទៅចែកជូន ដល់សមាជិកនៃតុងទីន
ជានិមិត្តរូបនៃការថ្លែងអំណរគុណ ព្រោះគេមានចិត្តសប្បុរស ហានឲ្យ
ប្រាក់ដល់ខ្លួនយកមកកេស៊ី ដោយឥតមានគិតការ ។

ដូចអស់លោកធ្លាប់ជ្រាបស្រាប់ មនុស្សត្រប់ប្រៃ តែងត្រូវការរឿង
ខ្លះមុខ តែងតែពេញចិត្តចំពោះការសរសើរ ម្ល៉ះហើយ ឃើញគេមាន
ត្រឹមនំ ខ្លួនចង់ឲ្យប្រសើរជាងគេ ត្រូវឲ្យមានទឹកតែផង អ្នកក្រោយឃើញ
ដូច្នោះ ត្រូវឲ្យមានស្រាថែមទៀត លុះឃើញគេមានទំទឹកតែនឹងស្រា
ហើយ ខ្លួនត្រូវឲ្យបរិភោគអាហារផង ព្រមទាំងមានភ្លេងជាគ្រឿងកំដរ
បរិយាកាសទៀត ការដេញដោងគ្នានេះ យូរ ។ ៗ ក៏ក្លាយបន្តិចម្តង ។
កើតបានជាការដប់លៀងធំឡើង ហើយជាចាំបាច់ផង ។

ដើមដំបូង អ្នកម្ចាស់ការទេ ដែលត្រូវខ្លួលបង់ខាត តួងការដប់
លៀងតែឯ ឯក្បែរវិញ ធ្វើអំណោយតាមតំឡាំងធនធាន បានជាមាន
រឿងដំណាលតៗគ្នាថា លុះរៀបការហើយ មានទាំងកូនមួយកូនពីរ

ក៏នៅតែសងប់ណាលការ ពុំខានខ្លួច ។ សុះបានឃើញការដប់លៀង ចេះតែរីកធំ ក្បៀកក៏ជួយព្រួយក្នុងរឿងនេះ ដែលត្រូវធ្លាក់ខម្ងូនមក លើខ្លួនទាំងស្រុងតែម្តង ។ ហេតុអ្វីក៏យ៉ាងនេះ? សូមអស់លោក តាមណាជាមួយនឹងខ្ញុំម្តងមើល ។ មុននឹងអញ្ជើញក្បៀវៅពិសាដប់ លៀងអាពាហ៍ពិពាហ៍ គេវៅសួរតម្លៃតុះមុនហើយជាស្រេច ដើម្បីឲ្យ ស្របតាមចំនួនក្បៀ ដែលគេបានដៅទុក។ ដំបូងឡើយ មួយតុះតែ ៥០០រ យ៉ាងថ្លៃ ក្បៀនិយមចងដៃម្នាក់ ១០០រ-២០០រ យ៉ាងច្រើន បើតុះមានកៅអី ៨ ត្រូវបានចំណងដៃ ៨០០រ បើអ្នកចាំ យកកៅអី ១០ ត្រូវបាន ១០០០រ ជាត់ឲ្យទៅចិន ៥០០រ នៅសល់ ៣០០រឬ ៥០០រ ទុកជាតម្លៃកេសជ្ជៈ ព្រោះមានក្បៀខ្លះពិសាស្រាបានណាស់ ឃើញថាល្មមគ្រប់គ្រាន់ អ្នកការ បានប្រតន្ទឬ បានប្តី ប្រាក់ដំនួយត្រូវបានចិន ។

តម្លៃជីវភាពឡើង អ្នកណាក៏ដឹងគ្រប់គ្នា ចិនត្រូវតម្លើងថ្លៃ ខ្មែរ: មុន ៥០០រ ត្រូវឡើងជា ៦-៧-៨-៩ ឬ ១០ រយ ជួនកាល ដល់ ១២ រយ ក៏មានកន្លង ១ តុះ។ ម្ល៉ោះហើយ ក្បៀវគោងតម្លើងដំនួយតាម ពោះបីថាគាត្រូសារខ្ទន់ខ្ទាយយ៉ាងណា ក៏ត្រូវតែរត់តាមគេ កុំឲ្យគេថា ស្លយ ។ ពីដើមបង់ ១០០រជាន តម្លៃមួលជាខនៃដំនួយអាពាហ៍ពិពាហ៍ ឡើងដល់ ២០០រ បើឈ្មោះណាមានចិត្តក្លាហាន ហ៊ានហុច ១០០រ អ្នក ខ្លួលដំនួយគោងតែមើលមុខ ដោយសន្និដ្ឋានថាអ្នកនោះមិនចុះសម័យ ។ សារុបសេចក្តីទៅ យើញថាគោលបំណងដើមស្តីពីចំណងដៃឬ ដំនួយ

ដល់គូស្រករថ្មី ដើម្បីទុកឲ្យគ្នាធ្វើជាជនួលសម្រាប់តាំទ្រដំណើរជីវភាព
ដំបូង ផ្ទាស់ប្តូរលក្ខណៈអស់រលីង : មិនដួយដល់គូស្រករថ្មី ក៏ត្រឡប់ជា
ដួយចិនទៅវិញ ។ ដោយឃើញក្នុងឧកាសរៀបមង្គលការម្តង ។ មានចំ-
ណេញច្រើន ចិនតែងតែឧនឱ្យបង្ហាប់ខ្មែរ ដែលស្គាល់ថា ចេញឯង លោក
ឯង យកការមកឲ្យខ្ញុំមួយ ខ្ញុំនឹងជូនវង្វាន់ ។ សព្វថ្ងៃ មានខ្មែរច្រើននាក់
ចានឧលួសវង្វាន់នេះពីចិន ឃើញថាគួរសមដែរ ព្រោះចេះតែខ្វះភាគលុយ
ពីហោប៉ៅចិនបានខ្លះ ជាលុយដែលចិនខ្វះយកពីហោប៉ៅខ្មែរនោះ តែ
លុយវង្វាន់ហ្នឹង ត្រមស់ងំនៅកងហោប៉ៅខ្មែរចានប៉ុន្មានថ្ងៃ ? សូមមិត្តអ្នក
អានគាំងល្បាយ ដួយវិនិច្ឆ័យផង !

បើស្ថានការណ៍អាពាហ៍ពិពាហ៍បច្ចុប្បន្ន មានសភាពឆ្ងន់ឆ្ងល់ដូច្នេះ គួរ
គប្បីតទ្រឹងស្មារតី ឆ្ពោះទៅរកគោលដៅដើមវិញឬយ៉ាងណា ? ចំពោះ
រឿងនេះ ខ្ញុំមានយោបល់ពីរដូចតទៅ :

ទី ១) គួរយើងតាំងចិត្តភ្លាមានឡើង ទំពាំងបាត់ការដប់លៀងតាម
របៀបសម័យនិយមចោល យើងតាំងស្មារតី ឈោងកវាចាប់គោលបំណង
ដើមមកវិញ ទើបជាការគាប់ប្រសើរ - ទី ២) គួរយើងចំបាត់ចោលនូវ
រឿងចំណងដៃចេញ ។ កាលណាត្រូវរៀបអាពាហ៍ពិពាហ៍កូន យើងគប្បី
អញ្ជើញតែចាស់ព្រឹទ្ធាចារ្យណា ដែលចរិយាបរិសុទ្ធ គួរឲ្យគួរសាមីភិរិយា
ថ្នាក់ដឹកនាំចុងជាគម្រូ ក្នុងនាគដីវិតអនាគតរបស់ខ្លួនបាន ឲ្យមកធ្វើជា
អធិបតីតង្កាំពិធី រួចសុំព្រឹទ្ធាចារ្យនោះ ឲ្យដំបូន្មានដល់កូនប្រុសស្រី ។ ជាអវ

សានសុំ ឲ្យលោកតាព្រឹទ្ធាចារ្យ ព្រមទាំងមាតាបិតា ចាបផ្តាឲ្យតាសត្វសារ
ពុតារ ដល់អ្នកដំណើរថ្មី ខុកជាការស្រេច ។ រួច យើងស្វះស្វែងណ្តាំដោយខ្លួន
ឯង ទូរម្ភូបចំណីបានប្រមាណខតុ: ជូនលោកតាចាស់ព្រឹទ្ធាចារ្យព្រមទាំង
មាតាបិតា ពិសាកំសាន្ត បញ្ចប់តិចអាពាហ៍ពិពាហ៍កូនប្រុសស្រី ។ តែ
សូមមេត្តា កុំយកសុភមកលាយឡំក្នុងពិធីនេះឲ្យសោះ ព្រោះអានុភាព
សុភ តែងតែទន្ទឹស ប្តូ បន្តយយោបល់ធម្មតាវបស់មនុស្ស តែងតែធ្វើស្មារតី
ធម្មតាវបស់មនុស្ស ឲ្យច្រាសចាកការពិតប្តឹង ។ រួច ដើម្បីចៀសវាងការ
រិះគន់ ថាវៀបការកូនលួចលាក់ គប្បីយើងធ្វើសំបុត្រ ជូនដំណឹងដល់ញាតិ
មិត្រ ស្តីពីកាលបរិច្ឆេទនៃពិធីអាពាហ៍ពិពាហ៍ តែប៉ុណ្ណោះ ខុកជាការស្រេច។

សូមមិត្តអ្នកអាន ជួយពិចារណា អំពីការដប់លៀងអាពាហ៍ពិពាហ៍
សម័យឥឡូវ ។ បើដល់វេរវៀបការម្តង ។ ព្រោះខ្មែរប្រកាន់រឿងខែ
ឈ្មោល ខែញី ថាវៀបការក្នុងខែញីទើបបានសុខ ក្នុងខែឈ្មោល គូស្រ
ករត្រាត់គ្នា ហើយ ក្នុងវេរដែលព្រះតេក្ខុសង្ឃចូលព្រះវស្សា ទាំងបីខែ
ហ្នឹងក៏មិនវៀបការខែត ដោយនិយមគោរពព្រះសង្ឃដែលចូលព្រះវស្សា
តើសេដ្ឋកិច្ចខ្មែរ ហៀរហូរទៅចូលហោជ្ឈ៍អ្នកណា ក្នុងមួយឆ្នាំ ។ ? សព្វ
ថ្ងៃ មិនមែនតែនៅទីក្រុងទេ នៅតាមស្រុកភូច ស្រុកជំ និគមជនបទ
ពិធីដប់លៀងនេះ សឹងមានសភាពស្ទើរប្រហែលគ្នាទាំងអស់ គឺថា ពាក្យ
ថាចំណងដៃ មានន័យដ៏ពិតប្រាកដ ជាតម្លៃដប់លៀងទៅវិញ ព្រោះមាន
ខ្លះ រអៀសខ្មែរដោយចងដៃតិចថា មិនសមចងដៃប៉ុណ្ណោះប៉ុណ្ណោះសោះ

ដ្បិតឯងរលេងច្រើនតែវណាស់ (Dose) ។ បើយើងយកចំនួនខែញ៉ាក្នុង ១ឆ្នាំមកគិត ឃើញថាមួយឆ្នាំមានប្រាំមួយខែ ព្រោះគេកប់ឈ្មោលមួយ ញីមួយ ឆ្នាស់គ្នាជាលំដាប់ទៅ គឺខែពិសាខជាខែញីមួយ អាសាធមួយ កន្ទ្របទមួយ កត្តិកមួយ បុស្សមួយ ផលគុណមួយ ត្រូវជាប្រាំមួយ តែត្រូវកាត់ចោលនូវខែអាសាធពាក់កណ្តាល នឹងខែកន្ទ្របទចេញ ព្រោះជារដូវចូលវស្សា ត្រូវនៅសល់ខែរៀបការ តែបួនខែកន្លះ ។ កង់បួនខែកន្លះ មានរៀបការប៉ុន្មានដង? ចំពោះរឿងនេះ យើងនឹងអាចដឹងបានដោយលំបាក តែអាចយល់បានថាមានចំនួនច្រើន ។ ត្រូវសន្មតជាមធ្យមថា កង់មួយខែត្រ មានអាពាហ៍ពិពាហ៍ដប់កង់មួយខែ ។ កង់កម្ពុជាមានខែត្រ ១៧ រាប់បញ្ចូលទាំងក្នុងពេញផង ត្រូវជា ១៨: យក ១៨ ខែត្រគុណនឹង ១០ ការ គុណនឹង ៤ ដងកន្លះ ត្រូវជា ១៨ × ១០ × ៤ ½ = ៨១០ ការ ។ ឥឡូវត្រូវគិតជាមធ្យម គឺការមួយមាន ២០គូ: កង់ ១ គូ: មានកៅអី ៨ ហើយក្បៀវម្នាក់ចងដៃ ១០០វ ចូករួមទឹកប្រាក់ កង់ការ ១ ត្រូវជា = ១៦.០០០វ បើ ៨១០ ការ ត្រូវជា (១៦.០០០វ × ៨១០) = ១២ ៩៦០ ០០០វ – (១២ លាន ៩៦០ ពាន់រៀល) ។

តាមការគិតលេខខាងលើ ឃើញថា កង់ ១ ឆ្នាំ ជាតិខ្មែរត្រូវចំណាយ ១២ លាន ៩៦០ ពាន់រៀល កង់តិដដប់លឿងអាពាហ៍ពិពាហ៍ ហើយចំនួនទឹកប្រាក់ចំណាយនេះ មិនចូលកង់ហោប៉ៅជាតិទេ គឺហូរចូលកង់ហោប៉ៅបរទេស គឺថាកង់មួយឆ្នាំ យើងត្រូវចំណាយប្រាក់ប៉ុណ្ណោះដើម្បី

ជំនាញមហាវិទ្យាល័យ ព្រោះតែត្រូវការចង់ចាប់ខ្ចីសម្លៀកបំពាក់ ឥតប្រយោជន៍ ។

តួរយើងគិតមើល ខ្ចីសម្លៀកបំពាក់ ក្រមក្រៃ ទឹងមិនខ្ចីសម្លៀកក្រនែណេន យើងយកណា ? បើជាខ្ញុំវិញ គឺយកក្រពះណេន ជាងក្រពះក្រៃ ព្រោះសុខភាពមិនមែនកើតពីខ្ចីសម្លៀកទេ ពិតជាកើតពីមានអាហារបរិភោគគ្រប់គ្រាន់ មានសំលៀកបំពាក់មិនខ្វះ មានដីលំនៅសមសួន ។

១៣ លានរៀលនេះ (គោលដោយច្រើន) តែទឹកឡើង តួរឲ្យព្រឺរោមឡើងសម្បុរតើងគត់ ហើយយើងមានសេចក្តីភ្ញាហានបង្ហូរពីហោប៉ៅយើងបញ្ចូលទៅក្នុងហោប៉ៅគេ យើញថាតួរឲ្យគេតណាស់ តួរឲ្យស្តាយណាស់ ព្រោះកូនខាវតែ ១ រៀលប្តូរ ៤ រៀលយកទៅធឹកទឹកកក មិនព្រមឲ្យទេ ជួនកាលគំហកឲ្យគ្នាប្តូរកន្ត្រាត់ដេញថែមទៀត ថាចាយអ្វីក៏ច្រើនម្ល៉េះ ។

សូមពិចារណាមួយផ្លូវទៀតថា សុភមង្គលនឹងអនាគតដ៏ភ្លឺស្វាង ត្រូវស្ថិតនៅលើអ្វី ? នៅលើខ្ចីសម្លៀកមួយ ២ណា: ហើយក្រៃក្រពះហូតទៅ ? ឬក៏នៅលើក្រពះណេន ទឹងមានសុខភាពបរិបូណ៌ទៅអនាគត ?

តាមការពិចារណារបស់ខ្ញុំ យើញថា ពិធីដប់លៀងអាពាហ៍ពិពាហ៍ជាពិធីមួយខាងការពារនាំគ្នាបង្កិនចំការគ្រួសារ ដែលហុចលទ្ធផលដ៏អាក្រក់ចំពោះសេដ្ឋកិច្ចជាតិមួយដែរ ។

ដូច្នេះ តួរគប្បីកែទម្រង់អាពាហ៍ពិពាហ៍ ដោយបំបាត់ចោលនូវពិធីដប់លៀង ឬ យ៉ាងណា ? សូមអស់លោកពិនិត្យ ជួយវិនិច្ឆ័យផង ។

សិលាចារឹកជ័យ - ៦ដ្ឋ

ស្រាវជ្រាវដោយ ឃ - តាម (តចប់)

បទវិភាជន៍ដ្ឋលីលា

១៦) នេះបទកូដន្ត៍លីលា លើកដោយភាព្យា ជាល្បាតំង ឡាយ ។ លាអស់លោកគោសសម្ងាយ លាតំយអន្តាយ ព្រាត់ ព្រាយច្រាសគ្នា ។ ខ្ញុំក្រាបទូលព្រះពុទ្ធា ព្រះហើយខ្ញុំលា ត្រង់ ណាទុក្ខសោក ។ ខ្ញុំលាត្រង់កំណើតថោក តើតមកអស់លោក សើចដៀលសន្ធាន ។ ១៧ –) ខ្ញុំលាសព្វជាតិពៀរស្ដាន ក្តីអស្រូវ ស្ដាន កុំមានឡើយណា ។ ខ្ញុំលាត្រង់ឥតច្រាជ្ញា ឆ្លៀវឡៅមោហាខ្ញាស់ តេអៀនប្រៀន ។ ខ្ញុំលាត្រង់ឥតរៀន ចូលដំទុំស្ងៀម តុំចេះឆ្នើយថា ។ ខ្ញុំលាពិសព្យាធ៍រោគា ច្រាសបុត្រកំយោ ស្ងាប់ទាំងច្រាណ ។ ១៨ –) ខ្ញុំលាវិជាតបក្ខាណ ជាទុក្ខក្នុងច្រាណ ស្រែកហ្មងនោះ ផង ។ ខ្ញុំលាអស់ជាបពៀរហោង ចតុកជាយផង បួនកុលៀសោយ ។ ខ្ញុំលាត្រង់តំនិតន្លាយ លាឆ្ងៃលក់សោយ ហើយស្មារតីតិច ។ ខ្ញុំលាតុំចេះតសិតិច្ច សិល្បៈសាស្ត្រការស្រេច ពាក្យពេចន៍នោះណា ។ ១៩ –) ខ្ញុំលាត្រង់ឥតច្រាជ្ញា តុំចេះតាសា ស្រដីនឹងគេ ។

ខ្ញុំលាត្រង់ឡូត៌ខ្លួនខ្ញុំ ត្រមោចឯងឯង ឥតប្រៀនខ្លួនភ្លា ។ ខ្ញុំលាឥត
ខ្មែរភាសា ទាស៊ីទាសា ពុំមានដល់ម្ចាក់ ។ ខ្ញុំលាត្រង់ចិត្តប្រត្យក្ស
ស្រដីឱ្យគាក់ អន់អៀនចិត្តគេ ។ ខ្ញុំលាត្រង់ពាក្យស្រាលស្រែ ស្រ-
ដីដូចគេ មមើឆ្គងណា ។ ២០ -) ខ្ញុំលាត្រង់ឱនតភាសា ស្រដីទៅថា
ពាក្យឥតការណ៍ ។ ខ្ញុំលាខ្លៅអន្ធពាល ស្រដីសាធារណ៍ ឥតគេយកពាក្យ។
ខ្ញុំលាត្រង់ណាគោកយ៉ាក ខួយស៊ីពិបាក ពុំត្រើសសប្បាយ ។ ខ្ញុំលាត្រង់
ល្ងង់កំប្លាយ ឆ្លៀតធ្លាក់យមាយ ជ្រងោឥតការណ៍ ។ ២១ -) ខ្ញុំលា
ស្មារតីសាធារណ៍ ស្រដីកិច្ចការណ៍ ពុំចាំនោះហោង ។ ខ្ញុំលាពំនោល
សូរសេង ស្រដីពាក្យគ្គធ ពុំត្រូវចិត្តគេ ។ ខ្ញុំលាគេស្អប់សព្វគ្រែ ត្រង់
ណាខ្លាស់គេ ខ្ញុំលានោះហោង ។ ខ្ញុំលាអស់ពែរផង តឿរត្រែង
ចំណង កុំយល់ឡើយណា ។ ២២ -) ខ្ញុំលាអស់ក្តីមោហា វង្វែង
ឃ្លាតភ្លា ក្លេចភ្លាំងប្រមាទ ។ ខ្ញុំលានោះសព្វ ។ ជាតិ ស្រដីប្រមាថ
ពិយោគសព្វផង ។ ខ្ញុំលាសរពើក្តីគ្គធ គិតខុសរំលង ទើបឃើញឯក្រោយ។
ខ្ញុំលាត្រង់ក្តីទំលោយ គិតខុសហើយក្រោយ ទើបឃើញក្តីតាប់ ។
ខ្ញុំលាត្រង់ណាអកតួ រស់ទៅពុំស្ងាប់ ជាខុទ្ទម្ចាក់ឯង ។ ២៣) ខ្ញុំលា
ត្រង់ណាវង្វែង ស្រដីឥតត្រែង ចាំម្តេក្រោយឡើយ ។ ខ្ញុំលាជាតិនេះ
ឃើញហើយ គិតយល់ឥតត្រើយ ពំនាក់ឡើយណា ។ ខ្ញុំលាត្រង់
ក្តីមោហា ប្រមាថមេបា គ្រូបាធ្យាយផង ។ ខ្ញុំលាត្រង់ក្តីធ្ងន់គ្គធ ប្រមាថ

សង្ឃផង ព្រះពុទ្ធព្រះធម៌ ។ ខ្ញុំលាត្រង់ក្តីសាហាវ (១) ស្រដីឡែងខ្មាស់
អន់អៀនព្រះទយ៌ ។ ២៤ -) ខ្ញុំលាតុំប្រកបនៃ ខូវអម្ចាស់ថ្លៃ
ប្រពៃទ្រង់ធម៌ ។ ខ្ញុំលាត្រង់ចិត្តសាហាវ សាហាវអស្ចារ្យ បន្ទុនក្រចាន ។
ខ្ញុំលាមនុស្សណាបៀតប្រាណ ស្រដីបង់ខាន ញុះញង់ចែចូវ ។
ខ្ញុំលាត្រង់ក្តីអាស្រូវ ស្រដីចែចូវ តិះដៀលប្រមាថ ។ ២៥ -) ខ្ញុំលា-
នោះសព្វ ។ ជាតិ សរតើបង់ឃ្មាត បង្ហានលាភយស ។ ខ្ញុំលាត្រង់ណា
ហៅថ្នល់ យសយកត្បិះថស់ ខ្ជាត់ខ្ជាយបាត់បង់ ។ ខ្ញុំលាត្រង់ណាញុះញង់
បង់ខានចំណង បង្កុសឃ្មាតឃ្មា ។ ខ្ញុំលាត្រង់កយ៌វេក ត្រមោច
កំព្រា ឥតគ្នាគាមក្រោយ ។ ខ្ញុំលាត្រង់ខ្ជាចកុំសោយ តិតកយ៌ប្រៃក្រោយ
តតើកចំប្រប់ ។ ២៦ -) ខ្ញុំលាត្រង់កយ៌ក្តីថប់ តិតញ៉ាំរចំប្រប់ រន្ធត់-
អស់អង្គ ។ ខ្ញុំលាគេចោមជាកង តិតកយ៌ល្ងីតល្ងង់ ឥតគ្នាជួយហោង ។
ខ្ញុំលាសព្វ ។ ជាតិធង់ តើតជាសែនដង លាត្រង់សត្រូវ ។ ខ្ញុំលា
ក្បាលចំពែកសក់ស្កូវ ដើងសូកអាស្រូវ ឆ្នេញជាក់ខ្ជាក់ឃ្លង់ ។
២៧ -) ខ្ញុំលាវែកស្រែងឃ្លង់ ដំបៅអស់អង្គ ជាពុកឥតស្បើយ ។
ខ្ញុំលាតើតឡើងឥតត្រើយ រូបអាក្រក់ហើយ ខ្ញុំទក្តាស់ឆ្អែងឆង (២) ។
ខ្ញុំលាអស់ទាំងនោះហោង សរតើត្តាំគ្គង ហៅអកុសល ។ ខ្ញុំលា

---

១ - អាសថា. សាហាស៍ កែពាក្យប្រែវានោះគឺ សាហស កាយសាហារ ។
២ - ទ្វីនក្រដាស់

នោះកុំគ្រាយល់ ឥដ្ឋតនេះដល់ រៀនទៅឯមុខ ។ ២៨-) ខ្ញុំលាកវែយ
អាក្រក់ នៅស្ថានឥតសុខ ជាខ្ពុងឯងហោង ។ ខ្ញុំលាបើមានទ្រព្យផង
អាក្រក់នោះហោង កុំគ្រាយល់ឡើយ ។ ខ្ញុំលាសត្វជាតិហើយ
ត្រង់ខ្ពុងឥតស្បើយ កុំគ្រាយល់ហោង ។ ខ្ញុំលាស្រែចសត្វត្រង់ផង
តើតសត្វជាតិហោង កុំគ្រាយល់ឡើយ ។ ២៩-) ខ្ញុំលានេះជាបង្ហើយ
ជាបពៀរខ្ពុងអើយ កុំមានឡើយណា ។ ខ្ញុំលាវែរកយ៉ាវែរ តើតឡើង
តាលណា ថ្ងៃល្អស្រែចផង ។ តើតខុសនឹងចំណង លាត្រង់នោះហោង
កុំតើតមកឡើយ ។

បទកាកគតិ

៣០-) បទដើមនេះក្តី ហៅកាកគតិ ដោយថាឡីថា លើក
ជាសំណូម ខ្ញុំសូមប្រាថ្នា សូមចិត្តសទ្ធា កាត់អំណោយទាន ។
អញ្ជាខ្ញុំនេះនៃ នាមដើមឈ្មោះជ័យ រៀរកយ៉ាបុពណ សូមបានត្រាស់
ត្រែច សរពេជ្ឈាញាណ សូមបានឱញ្ញាន ឆាំអស់សត្វផង ។
៣១-) ជាតិមុខច្រើនពៃក្រៃ តើតជាអសង្ខ្វៃ ឆ្នាំនៃកប្បហោង
ខ្ញុំសូមប្រាថ្នា សទ្ធាទានផង តាមដោយគន្ធង ព្រះសិរីអារមេត្រី ។
នោះគេប្រាថ្នា សុំអស់អង្គា សាច់បញ្ចាតន្ត្រី សួតថ្លើមបេះដូង តុង
តោះឈាមថ្នី ក្បែកឆ្អឹងខ្ញុំក្តី ឲ្យទានគេហោង ។ ៣២-) ខ្ញុំសូមប្រាថ្នា
ត្រែកអាសទ្ធា ចំណាស្មោះផង ដូចព្រះជនក ឲ្យទានប្រតហោង

ឆ័សាច់ឈាមផង អស់ឥតសំណល់ ។ ខ្ញុំសូមប្រាថ្នា ឲ្យតាន់តាលណា
ខេពតាដួយយល់ សូមអស់ឥន្ទ្រហ្ម ជ្រោមជ្រែងពន្យល់ កើតកោលា
ហល ដួយចំពេញមាន ។ ៣៣-) ខេពតាចំលាក់ ព្រះខ័ន
យល់ជាក់ ស្តែងជាប្រជាន យកព្រះខ័ននោះ អារសាច់ឲ្យតាន
ប្រែតធីដោយឃ្វាន ឆ្អែតប្រាណនោះហោង ។ ខ្ញុំសូមប្រាថ្នា ខួល
ព្រះកគរ៉ា គ្រាស់ធម៌កន្ធង ខ្ញុំសូមដូចព្រះ សិអារ្យឯងហោង
វិរៈយោធិកផង នោះនៃខើចំបាន ។ ៣៤-) ខ្ញុំថ្វាយបង្គំមា សម្តេចកគរ
ស្រោចស្រង់ប្រោសប្រាណ ខ្ញុំកាន់បុប្ផា វត្ថាស្រេចបាន ឧបជ្ឈាយ៍បួស
ប្រាណ សូត្រកម្មាចហោង ។ ខ្ញុំបួសនេះនៃ សំណាក់ព្រះត្រ័យ សរណា
គមន៍ផង ខ្ញុំសូមឲ្យដឹង កំណើតសត្វហោង តាមដោយតន្ធង នៃព្រះពុទ្ធ
គ្រាស ។ ៣៥-) ជាតិនេះនៅឆ្ងាយ តុំពាន់តណ្ហាយ ជាក់ជឿនស្តែង
ច្បាស់ ខ្ញុំសូមជាតិក្រោយ ពង់ដូចព្រះគ្រាស ប្រាជ្ញាបុណ្យច្បាស់
ឥតអ្នកផ្ចឹមផង ។ ខ្ញុំសូមប្រាជ្ញា ចេះឆ្លើយប្រស្នា ដោះស្រាយសាសង
ដូចព្រះនាគសេន ឆ្លើយប្រស្នាផង នៅក្រុងមលិន្ទហោង ដោះឥត
ជំពាក់ ។ ៣៦-) ខោះឆ្លើយប្រស្នា សរតើប្រាថ្នា ទ្រព្យធនយសសត្តិ
កុំបីមានក្រ នៅរកដល់អ្នក ខៀតមកពំនាក់ ជាកំលាំងឡើយ ។
សូមកើតមកឯង ដោយផលពីត្រង់ បួរណាជាត្រ័យ សឹងចូលមកដួយ
ពុំឲ្យត្រួយឡើយ តិតត្រង់ណាហើយ ខេត្តាចំពេញ ។ ខ្ញុំសូមប្រាថ្នា

ជាតិក្រោយមកណា កុំគ្រាកំណាញ់ សូមចិត្តខ្ជិល សង្ឃថ្វាយតេ
តេសូមអ្វីមិញ ឲ្យទានឥតលោះ ។ ៣៧-) មួយសូមប្រាថ្នា
ដូចព្រះកាលដ៏ ធនញ្ជ័យបុរស ធ្វើយប្រស្នាផង ទន្ទីយកូនិព្យស
ប្រាថ្នាស្រេចស្រស់ ដោយចារមើថ្លៃ ។ ហើយតំនោះស្រេច ការអាយុស
ស្តេច រួចជាប្រពៃ ទាំនទ្ទីយកូ សំណាក់នៅផ្ទៃ ជាបរិវារនៃ
ក្រញាក្រាបខ្ញុបខ្ញាច ។ ៣៨) រៀងមកតំនោះ ចាប់ស្តេចមួយឈ្មោះ
អតិតីភ ហើយឈ្មោះស្តេចមួយ ឈ្មោះវិកេចភ ព្រះទីកឯងអាច ហៅម្ចាច
យក្ស(១) ។ នេះស្រដីកាត់ ពុំបានរៀបចប់ តំដើមមកណា មើស្រដី
អស់ ច្រើនណាស់សត្វគ្រា បង្ហើយបានជា ១បកដងដង ។
៣៩-) ខ្ញុំសូមអំណត់ ចិត្តល្អស្រួតត់ ដូចព្រះតេមេយ ព្រះវេថតា
ឲ្យល្បងឥតធ្វើ ព្រះអង្គអត់តេ ឆេទសង្ឃាតត់ ។ ៤០-) ខ្ញុំសូមប្រាថ្នា
ដូចព្រះកាលណា កើតជាមហាសត្វ ឈ្មោះអស់អាចារ្យ ផ្ចាលផ្ចាញ់តេវ៉ៃ
ប្រាថ្នាច្រើនក្តាត់ ព្រះចុល្លណី ។ ខ្ញុំសូមឲ្យបាន តាត់អំណោយទាន
ដូចព្រះមួយទី ព្រះវេសន្តរ នៅទាន់មេទ្រី ឲ្យទានជាលី ក្រស្នាតោះ
ហោង ។ ទានវែងនោះនៃ កើតជាកន្សែ តាមកើតដោយដង
ដូចទានចញ..... ដូចអំមកផង ខ្លួនទានមេទ្រី ។ ៤១-) សីឆតាម
សត្វជាតិ កើតពុំដែលឃ្លាត រួបបញ្ចូតទ្រូ ហើយល្អតឆ្ងាំម ទោមធាយធរី

១-) ហៅអំណាចយក្ស ។

ឆ្លាប់ចាំងសុមាតី ឥតអ្នកតើតដល់ ។ ខ្ញុំសូមសព្វជាតិ កើតកុំគ្រាឃ្លោត
ទីវែមណ្ឌល គោះពៅតើតសួគ៌ ខ្ញុំសូមឱ្យឃល់ គោះកើតក្រវល់
ពៅអាយកើតផង ។ ៥២ -) ជាតិនេះខ្ញុំឃ្លាត ខ្ញុំសូមសព្វជាតិ
កុំឃ្លាតដល់ម្តង គោះកើតជាសត្វ ជាមនុស្សក្តីហោង ខ្ញុំសូមកើតឧត
ដូចខ្ញុំប្រាថ្នា ។ ខ្ញុំសូមបង់ប្អូន ញាតិផៅអស់កូន សំឡាញ់ករិយា
បងរស់ទាងវែន សូមតើតមូលគ្នា ខ្ញុនខ្ញុំនេះណា សូសពៅអិមៗង
៥៣ -) ខ្ញុំសូមមានម្ចាច ឫទ្ធិអំណាច អានុភាពដោយបង
ខ្ញុំសូមសិល្បៈជប់ ធុតដូចព្រះអង្គ ព្រះឥសូរស្តេចទ្រង់ ជប់ទាងតតវតី ។
សូមម្ចាចឫទ្ធិយ ដូចកាលព្រះនកយណ៍ ចុះចាកអំពី សួគ៌មកកើតជា
ព្រះកមរខេត្តី ផ្តាញ់អស់តិរ្ថីយ អសុរលង្កា ។ ៥៤ -) ខ្ញុំសូមមួយទី
ដូចព្រះចាខស្រី ស្រីក្រមណា ឆ្ពោះពៅកែលាស ព្រះឥសូរ
បានដូចប្រាថ្នា ចំឡាចោខបង ។ បានសិល្បៈសាស្ត្រស្រេច រៀមក
ជាស្តេច ដូចចិត្តបំណង អ្នកបានមេហួ ប្រាំបួនព្រះអង្គ អតិសេកបាន
ទ្រង់ សោយរាជ្យមួយសែនឆ្នាំ ។ ៥៥ -) ខ្ញុំសូមកំលាំង អានុភាព
បែងខ្លាំង សិល្បៈសាស្ត្រគុតចាំ ដូចព្រះហនុមាន បួកណាយចាំ
កើតមកជាតំ លាំងព្រះកមរខេត ។ សូមមានសំការ ជាម៉ែត្រកាល
ចេះសិល្បៈសាស្ត្រសេត ចេះការសង្គ្រាម ដូចព្រះកមរខេត សិល្បៈឆ្លងឯង
ឯក ឥតអ្នកស្មើឆង ។ ៥៦ -) លែងដាតិនេះពៅ បើរៀមមកនៅ

តើតវិធីស្តេចហោង ឃានដូចចៅតេត មាលាហោះផ្សង ៗសួតនាយ
ហោង ជាកូនព្រះឥន្ទ ។ ហើយមកជាស្តេច សាងនគរស្រុច
នៅទាងតំរិទ្ធ ព្រះតិស្សការ រៀបឡើងៗរៀញ អ្នកតើតឯងមិញ
សោយរាជ្យនៅអាយ ។ ខ្ញុំសូមសំឡឹង តំរោះប្លែកផ្សឹង (១) ឮខ្ញុំចាំងឡាយ
ពាក្យដូចតរៀក ក្រលួចត្រីសាយ ប្រាថ្នាពណ្ណរាយ ចេះប្លែងឥតខ្វះ ។
๔๗ -) ខ្ញុំសូមទ្រព្យធន មាសប្រាក់តន្តែនន់ តែរមណីជោតជ្រះ
ទៀនព្រៃតាសា ចៀមព្រំរាតញ្ជះ ឆ្នូតពិតានមន: ដូចជោតិតសេដ្ឋ ។
ខ្ញុំសូមបរិពារ អស់ស្រីស្រឹង្គារ ត្រគាលច្រឹមប្រិយ រូបល្អលើសលន់
ទន់ភ្លន់មានស្រី សប្បុរសទៀវិទ្ធ ដូចឆ្មាស្វាតេត ។ ๔๘ -) សូម
ចេះញាតិគុណ ឆុតនាប់លើសលន់ មែនចប់ត្រៃកេទ សន្ធប់ត្រប់អង្គ
មិរសុទ្ធព្រះនេត្រ ខ្យល់តិចសង្កេត គ្រាន់រស់ជីវិត ។ សប្បាយត្រគាល
ត្រអែមពិស្តារ ត្រេកត្រប់ឥន្ទ្រិយ ព្រឹព្រួចតាមា ចិន្តាសួតស្រី ភ្ញឹកភ្ញេច
ស្តារតើ ប្រឹងប្រែងតុំបាន ។ ๔๙ -) ស្នេហាត្រប់ត្រាន់ ជារយជាពាន់
តុំតិតភ្ញាក់ប្រាណ លុះតែដល់ស្រាយ នោះនៃនើបបាន ជាស់ឡើងប្រែ
ប្រាណ តុំបាត់សប្បាយ ។ សូមខ្ញុំប្រុសស្រី ជារយពាន់ក្តី ច្រើនប្រៃ
ពណ្ណរាយ រូបឆោមសឹងល្អ សឹងចេះតិប្រាយ ស្រដីដោះស្រាយ ពីរោះ
ឥតខ្ចូង ។๕๐ -) សូមសេះដ៏រ៉ បោក្របីក្តី ល្អភ្លាំងកន្ធង រះចេះកូបអាន

---

๑ - ផ្សឹង (ផ្សឹក ឬប្លែក នឹកស៊ប់ប្លឹងពាន)

ត្រៃយោនមាសផង ខ្លែកសាមួងហោង ដោយតែយាត្រា ។ ល្អត្រប់ប្រដាប់ ចរិតារស្រោចស្រាប់ កាន់ត្រឿងត្រប់គ្នា សំពាប់ដង្កែ ដោយតែយាត្រា ដូចកុនផលា លេលាសត៌សែង ។ ៥១ -) សូមបានប្រាសាទ ប្រាំបួនល្អស្អាត ជិតមាសព្រាសខែង គាងឃ្លាយតើតឆាយ ពណ្ណរាយយលស្តែង ដាំត្បូងត្មុះចែង ល្អត្រប់ប្រការ ។ មានផ្សារដុំវិញ បីជាន់ខ្ពាក់ពេញ រួចត្រប់ពិស្តារ មានជានិយាយ សឹងក្លាយត្រចង្វារ ខាតលើកតភារ ចាំដើងដើរកាច់ ។ ៥២ -) ភោះទឹងមានផ្ទះ បើល្អស្រឡះ សឹងមានមុខជាច់ ទទឹងរោងជ្រែក បន្ទន់ផ្សារស្រេច រាំងដុំខានកាច់ រោងដំរីសេះ ។ មានចន្លុះបាយ មណ្ឌលសាលា ធ្លុងស្តាំសឹងស្រោះ ផ្សារជាំសឹងផ្តាំ ចំប៉ាបានបេះ ខ្ញុំនដូចក្រមែះ តិជោរស្រេចហោង ។ ៥៣ -) ឆ្នាំមមីពេញបូណ៌មី ខែផល្គុណនោះ បានជាទុតញ្ញា សុរិន្ទ្រាធិពជ លុះដល់ឆ្នាំវក ពេញបូណ៌មី ខែពិសាខ នោះ បានជាចៅហ្វាំ ចាំងខ្សត់បួន ។

កង់តាលខ្លះ សេចក្តីអត់ធន់ ជាគ្រឿងលំអ នៃបុរស ដូចសេចក្តីអៀនខ្មាស ជាគ្រឿងលំអនៃស្ត្រីទាំងឡាយ តែក្តីក្លាហាន ជាគ្រឿងលំអនៃបុរស កង់ពេលដែលគេមើលងាយ ដូចការមិនអៀនខ្មាស ជាគ្រឿងលំអនៃស្ត្រី កង់ការសេពសន្តវៈដូច្នោះដែរ ។

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង-ខាត់ រៀបរៀង

(តមក)

អទ្វារ ស្ត្រី. អទ្វារ នបុំ (វត្ថុ) ដែលមិនមានទ្វារ ទីហានដែលមិនមានទ្វារ ឬប្រក ។

អទ្វិជ គុ. ដែលមិនមែនកើតពីរដង ដែលមិនមែនជាព្រាហ្មណ៍ ។

អទ្វិតីយ គុ. ដែលមិនមានទីពីរ ដែលមិនមានសហាយ ដែលប្រៀបផ្ទឹមមិនបាន ។

អទ្វិមត្តិ កាលមិនស្គប់ ។

អទ្វេមវាគិនិ គុ. ដែលមិនមានព្យាបាទនឹងភាគៈ ។

អទ្វេឞ្ដ្ឫ ក. ន. អ្នកមិនស្គប់ ។ – ឫ. នបុំ. ភាវនៃធនមិនមានព្យាបាទ ។

អទ្វៃធ នបុំ ធម្មជាតិមិនមានពីរ ធម្មជាតិមានតែមួយ ឯកភាព ។ គុ. ដែលមិនមានពីរ ដែលឯកឯង ។

អទ្វៃធ គុ. ដែលបែកគ្នាមិនយូរ ដែលមិនព្រមព្រៀងគ្នា ។

អធន គុ ដែលមិនមានធនធាន ដែលក្រីក្រ ដែលមិនត្រូវបាន ។

អធន្យ គុ. ដែលមិនមានទ្រព្យ ដែលខ្សត់គត ។

អធម គុ. ដែលមិនខ្ពង់ខ្ពស់ ដែលថោកទាប (ថ្នាក់ ឋានៈ តម្លៃ) ដែលថោកថយណាស់ ។ – បេម្ត គុ. ដែលមានចរិយាថោកទាប ។ – ធី, គុ.

ដែលក្រាន្ដិទន់ខ្សោយ ។ - យោនិដ គុ ដែលកើតពីមាតាថោកទាប។ អធមណ៌ ឬ អធមណ៌ក ប៉ុ. ក្លែបំណុល ។ អធមាធម គុ. ដែលថោកទាបជាងគេ ។

អធរ គុ ដែលមិនទ្រៃ ដែលនៅពីក្រោម (និយាយពីរបស់ពីរ) ដែលជាខាងក្រៅ ។ ប៉ុ ពពីរមាត់ខាងក្រោម ពពីរមាត់ទាំងពីរ ។ - វុបក ឧប៉ុ លំអនៃពពីរមាត់ ។ អធរាម្ពុរ ឧប៉ុ. អំពៅខាងក្នុង អាវុទ្ធទាប់។ អធរោត្តរ គុ. ដែលនៅមុខនឹងនៅក្រោយ ដែលរៃហមមុខក្រោយ ដែលល្អនឹងអាក្រក់ ដែលឋិតនៅនុ៎ះឯង ដែលនៅពីលើពីក្រោម ដែលចាញ់នឹងឈ្នះ (ឬជាក្តី) ។ ឧប៉ុ ខ្ពស់នឹងទាប ឬជួនឹងវិសេដ្ឋនា ។ អធរោត្តរ ឬ អធរោត្តរ ឧប៉ុ. ពពីរមាត់ទាំងពីរ ។

អធរយតិ ប្រសើរកន្ងង អធរិត គុ. ដែលប្រសើរកន្ងង ។

អធរាញ្ជ គុ ដែលបែរទៅខាងក្សេង ។

អធរេយ គុ ដែលគិបជាង ។

អធម ប៉ុ. អធម៌. សភាវមិនស្មើភាពគ្នា ទោស ជាប ។ អធមិត្ត គុ. ដែលមិនតាំងនៅក្នុងធម៌ អយុត្តិធម៌ វិសភាគ ។ - ជ្ញ. គុ. ដែលមិនដឹងធម៌ ដែលមិនស្គាល់សិទ្ធិ ។ - ទណ្ឌ ន. ឧប៉ុ ទណ្ឌកម្មដោយអយុត្តិធម៌ ។ - ពហុល គុ ដែលច្រើនទៅដោយអធម៌ ឬ អយុត្តិធម៌ ។ - ជ្ញ ក ន. អ្នករីកាយដោយអយុត្តិធម៌ ។ - ឆរណ គុ ដែលមានអយុត្តិធម៌ជាទីពឹង ។ - សង្គ គុ. ដែលប្រាំងគ្នាដោយអធម៌ ។ - អធម៌ាត្តរតា ស្ត្រី. ភាវនៃកិរិយារំលោភដោយអធម៌ ។

រឿងសាមកុក

ទេសនាដ៏ប្រសើរ ដែលព្រះសាស្តាទ្រង់ប្រារព្ធនឹងភិក្ខុ ឈ្មោះ ឧត្តរៀបរៀង

(តទៅ)

រឿងសាមកុកពុកដាំយូទូសាស្ត្រ
អ្នកជាងដែលឆ្លាសបើបានអាន
ខឹងបេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាដាតិ ។

ឃ្លោ-អ៊ុន

ពួកគាហានស្រុកសែលួនដែលទៅជាមួយក៏និយាយថា លោកនឹងតល់ទៅខ្ញុំនោះមិនជានេះ ព្រោះសត្រូវបួលរួបជិត មកចាំងសង្ឃានប្រើនណាស់ សូមឲ្យកាយខ្មាយត្រង់មាត់ផ្លូវទៅខាងស្តាំដៃ គេបត្រង់ទៅផ្លូវធំ បួលឲ្យជួបគ្នានឹងកងខ្ញុំតាខ្មៅតែពុះ អ៊ុយអៀនយល់ឃើញត្រូវ ក៏បង្គំគាហានកាយខ្មាយត្រង់មាត់ផ្លូវចេញរួចទៅ បានប្រហែល ៣០ សិន (១២០០ម) ប្រទះនឹងលុយតង ដឹឡាន់ ឃុំគាហានលើកមកស្មុកតែមុខ ខៀវយើមក៏បង្គំជេញគាហានឲ្យទន្ទ្រានតាមទៅពីក្រោយអ៊ុយអៀនត្រូវខ្មៅកងចំណាមខៀត ឧទ្ធវទៅមុខក៏មិនរួចទៅក្រោយក៏មិនរួចទើបបរសេះបួលតស៊ូទៅមុខ គេបត្រលុកមកក្រោយវិលកងខ្ញុំនោះ, ខ្មួលហាងតុងលើកជាកងមុខ ខ្មៅតែមកតាមផ្លូវធំ មកដល់ខ្ញុំមនឹងផ្លូវកាត់

ដែលនឹងឡាន់ លុយតង លើកទៅនោះ ក្រខ្សែកយើញតាហានខាង
ក្រោយនឹងឡាន់ស្រែកហៅគឺតតង កំគិតថា ប្រហែលអ៊ុយអឿនលើកមក
ដល់ទីនេះ សត្រូវស្គាក់ផ្លូវខេដឹង ហង៍តុងក៏ចំចោលសេះរយសង្កុញពី
ក្រោយចូលទៅហើយស្រែកថា អ៊ុយអឿនកុំខ្លាច យើងមកជួយហើយ
អ៊ុយអឿនទើងហង៍តុងកំព្រួតគ្នាវាយប្រសព្វពីមុខពីក្រោយនឹងឡាន់ លុយតង
តទល់តុំឈ្នះកំប្រាស់តេ់ខ្លាយទៅ តាហានក៏ស្លាប់ ទៅតរលើគ្នាច្រើន
ណាស់ ។

ហង៍តុងនឹងអ៊ុយអឿនបានចំណាប់ កំដេញតាហានចូលប្រគាប់ប្រ
ចាក់ទៅដល់ជើងកំតែងប្រសព្វគ្នានឹងតងទ័ពឡៅពី ឡៅកុយដែលនៅ
រក្សាស្រុកនោះ កំឲ្យតាហានបាញ់ធ្នូចំរុះខប់ពីក្នុង ឡៅពីនឹងវាយខម្ចាយ
ចូលទៅកំពុងបាន ទើបលើកតាហានត្រឡប់ក្រោយចូលទៅក្នុងបន្ទាយប្រក
បង្ក្រឹត, ឯឡាន់នឹងឡៅកុយយើញដូច្នោះ កំបរពលចូលប្រយុទ្ធគ្នា
ខ្លួនខ្លៀវយឺមលើកត្រឡប់ក្រោយតាមប្រកកុំទៅតាន់ឡៅពី កំចូលប្រ
សព្វគ្នានឹងតាហានឯឡាន់ ឡៅកុយ ដួយព្រួតគ្នាដេញសង្កុញចូលទៅ
ឡៅពីតាល់ខ្លួននឹងចូលបន្ទាយប្រកអង្រឹតនោះពុំបាន កំរត់ត្រឡប់ទៅ
តាមផ្លូវតែយបន្ទាយចោ៉ាយស៊ីគួន ។

ខណៈនោះ សេះឡៅពីនឹងបណ្តាពួកតលតាហានកំជយកម្ចាំងខន់
ប៉ុះ នឹងចូលតស៊ូនឹងតាហានខ្លៀវយឺម ឯឡាន់ ឡៅកុយមិនបាន កំ

ថយក្រែបាណ្តាយទៅដល់បន្ទាយចោរយ៉ាយស៊ីតួន តួនបើងទឹងឡៅហាងដែល
ឡៅតាឱ្យទៅក្បាបន្ទាយនោះដឹង កំលើកគាហាន ៣ ម៉ឺនចេញមកជួយ
ចូលវាយទ័ពធំខ្លាំង ឡៅតុយឡៃយើមបែក ហើយចេញដាប់តាមទៅបាន
កាប់សម្លាប់ពួកសត្រូវស្លាប់ជាច្រើន រើសយកបានគ្រឿងសស្ត្រាវុធច្រើន
ណាស់ហើយក៏អញ្ជើញឡៅតាចូលទៅក្នុងបន្ទាយចោរស៊ីតួន, ឡៅតាក៏សួរ
ដំណឹងទាំងពួងថា ចាំងថងនោះនៅឯណា ជាប្រការដូចម្តេចខ្លះ គាហាន
ក្នុងកងទ័ពចាំងថងដែលបែកមកនោះឆ្លើយថា ឥឡូវចាំងថងត្រូវព្រួញដល់
ខ្លួនសេចក្តីស្លាប់ហើយ ឡៅតាឮដូច្នោះ កំយ៉ាសោកាល័យគាល់តែដួល
សន្ធប់ទៅ គាហានទាំងពួងក៏ទាំគ្នាខ្លួញយំ អាល័យចាំងថងត្រប់ៗគ្នា
ហើយឡៅតាក៏ឱ្យរៀបចំគ្រឿងសែន បញ្ជូនទៅឱ្យចាំងថងតាមប្រពៃណី ។

ហាងតុងថា អាចារ្យរបស់យើងខ្លួលអនិច្ចកម្មហើយ ឡៃយើមក៏
ទឹងមានចិត្តកំរើកលើកមកវាយយើងជាប្រាកដ ទឹងកែម្ចាងឯណាជាធំទឹង
ជួយគិតការតទៅបាន សុំឱ្យលោកទៅអញ្ជើញពុងប៉ងមកទឹងបានជួយ
រិះគិតធ្វើសង្គ្រាមដើម្បីទឹងយកស្រុកសែឈួនខេះ និយាយមិនទាន់ផុត
មាត់ មានបំរើសេះចូលមកប្រាប់ថា ឥឡូវឡៃយើមលើកគាហានមក
ដល់ជើងកំពែងហើយ, ហាងតុងទឹងអ៊ុយអឿនក៏និយាយទឹងឡៅតាថា ខ្ញុំ
បាទទឹងសូមអាសាលើកគាហានចេញទៅតស៊ូទឹងឡៃយើម ឡៅតាក៏
ឃាត់ថា ដែលអ្នកតាំងពីរទឹងលើកគាហានចេញទៅតស៊ូទឹងឡៃយើមនោះ

មិនចាន់ស្រួលទេ ព្រោះគ្រានេះ សត្រូវមានកម្លាំងច្រើនណាស់ យើង ត្រូវតែការពារបន្ទាយទុកសិន ចាំប្រើប៉ះទៀរទៅអញ្ជើញទុះបេងមកជួយ រិះគិតធ្វើការសិន ។

ឮពាក្យតែងសំបុត្រឲ្យគួនប៉េងស្រួតរួតមាំសំបុត្រ ទៅអញ្ជើញទុង បេងឯស្រុកកេងជាវ គួនប៉េងគំនាប់ឈាឮពាក្យស្រួតទៅចាំងយប់ចាំងថ្ងៃ ឯឮពាក្យកំចាត់ចៃងរក្សាគយ ខឹងបន្ទាយប៉ាស៊ីគួនជាមាំមួនណាស់ មិន ចានលើកចេញចាំងខឹងទៀយើម ។

កាលថ្ងៃដែលចាំងថងស្អាប់នោះ ជាខែស្រាពណ៌៨កើតត្រូវទេសកាល អាណាប្រជាជនតែងតុលៀងអាហារជាសប្បាយ តាមប្រពៃណី ទុងបេង អង្គុយបរិភោគអាហារជាមួយនឹងនាម៉ឺនមុខមន្ត្រី ទៅយូតណ្តាលវាលពេល យប់ស្រាប់តែឃើញផ្កាយទុដួងធំ ប្រមាណ ៤ ឆ្នាប់ ធ្លាក់ចុះពីលើអាកាស វៀរាស៍ជាខាងទិសបស្ចឹម ទុងបេងកំភ័យធ្លាក់ផ្តាច់ថ្លើមដកដង្ហើមធំ ហើយ ភ្លាត់មាត់ស្រែកថាស្តាយណាស់ ដៃនោះក៏ចុះចាលតែងស្រាឲ្យធ្លាក់ចុះ ទៅហើយយកដៃទប់ក្បែក ស្រែកយំអណ្តឺតអណ្តក, ពាហានចាំងតួងក៏ សួរថា លោកយំដោយហេតុអ្វី ? ទុងបេងថាពីដើមយើងឃើញផ្កាយ ទុដួងតាចណាស់ ប្រាកដត្រង់ទិសបស្ចឹមចំស្រុកឡុកសៀ នោះកំពុលចំភ្លឺ ជា ដែលនាយទៅហ្នាយើងលើកកងទ័ពទៅពេលនេះ ខឹងឃើញនាយ ទ័ពឬនាយកងឬទ័ប្រឹក្សាឯណាទ័មួយជាប្រាកដ យើងក៏ចានមានសំបុត្រ

ឲ្យដំណើរទៅដល់ស្រុកតិ ឲ្យប្រុងប្រយ័ត្នរក្សាខ្លួនទឹងភួតក្រុមកុំឲ្យសប្រមាទ
គួរឬមិនឲ្យមានគិតប្រុងប្រយ័ត្នការភ័យអន្តរាយនោះ បណ្តាយឲ្យមានហេតុ
ដល់យ៉ាងនេះសោះ ឥឡូវនេះ យើងយើញផ្កាយ ១ ដួងធ្លាក់ចុះមក ប្រ
ហែលជាំងថងខ្លួលអនិច្ចកម្មទៅហើយដឹង ខ្ញុំពីចៅហ្វាយយើងជាច់
ដើងម្ខាងទៅហើយ, គាហានតាំងភួងភ្ញុខុនបេងថាដូច្នោះ កំទួលក្នុងចិត្ត
គិតមិនគាន់ជឿជាក្រាកដ, ខុនបេងយើញអ្នកកាលគ្នាមានសេចក្តីសង្ស័យ
ដូច្នោះកំនិយាយថា អ្នកតាំងភួងចូរស្តាប់មើលចុះ ២-៣ ថ្ងៃទៀត កំតង់
ដឹងដំណឹងហើយគាហ្មែនតាំងអស់នោះកំតំនាប់លាខុនបេងពេញទៅ ។

លុះកន្លងមក ៥-៦ ថ្ងៃ ខុនបេងនឹងគួនអ៊ូអង្គុយនិយាយគ្នា ខ្លួល
គួនប៉ើងចូលទៅតំនាប់ ហើយហុចសំបុត្រទៅឲ្យ ខុនបេងមើលឃើញ
សេចក្តីថា ជាងថងខ្លួលអនិច្ចកម្មហើយ ខុនបេងកំទួញយំអាណិតជាំង
ថងតាន់ប្រមាណណាស់ គាហានតាំងភួងក៏សោកយំតាំងអស់គ្នា ខុនបេង
ថា ឥឡូវទៀតីនាយះចៅហ្វាយយើងតាំងទៅដំបន់ជាយស៊ីគួន ឯសត្រូវ
ក៏លើកទៅតំទ្ចុំញាជាខ្លាំងណាស់ លុះនឹងឃុយចំលាយទៅខាងណាក៏
មិនជាននឹងឋយក្រោយចេញមកក៏មិនស្រួល ជាចិចរ្ញៀតចង្អល់ចាល់ខ្លួន
ណាស់ ប៉ែយើងនឹងមិនលើកទ័ពទៅជួយទេ រៀលនេះមុខជានាយរបស់
យើងនឹងឆ្ងោះការដោយសត្រូវពួកនោះពុំខាន ។

គួនអ៊ូថា ដែលលោកនឹងលើកទ័ពទៅនោះកំស្រួលហើយ តែថា

ស្រុកកេងដីវនេះជាទីសំខាន់ណាស់ ហើយមិនមាននរណាជាធំនៅត្រង់
គ្រងរក្សាទេ តើលោកទិងយល់ឃើញដូចម្តេច, ខុងបេងថា ដែលឡៅ
ឥឲ្យមានសំបុត្រមកទិងឲ្យបើងនៅដួយនោះ យើងក៏ដឹងថា ឡៅឥឃើញ
តែអ្នកមួយទិងនៅរក្សាស្រុកនេះឯង តែខ្លួនអ្នកឯងស្បថស្បែទិងឡៅឥ
ជាបងប្អូនដោយសុចរិត ក៏កុំបីគិតរវាងគ្នាសសង្ស័យអ្វីឡើយ ឯស្រុកកេងដីវ
ដែលអ្នកនៅរក្សាតែម្នាក់ឯងនោះ មុខជាទិងកមុខរកគ្រាយឲ្យលំបាក
តែអ្នកត្រូវយកសេចក្តីស្វាមីភក្តិដល់ឡៅឥជាប្រធាន កុំបីមានចិត្តគិតតែ
ព្រងើយកន្តើយឡើយ គួនអ៊ូឮខុងបេងទិយាយដូច្នោះហើយ ក៏តំទាប់
ខ្លួលប្រសាសន៍ លុះវេលាព្រឹកឡើង ខុងបេងតិឲ្យរៀបតុលៀងអាហារ
ហើយក៏យកគ្រាសម្រាប់ទីពៅហ្វាយខែត្រនោះមកប៉ង ប្រគល់ឲ្យគួនអ៊ូតាម
ប្រពៃណី គួនអ៊ូលើកដៃឡើង តំទាប់រៀបទិងលូកចាប់យកគ្រានោះ ខុង
បេងក៏មិនទាន់ប្រគល់ឲ្យ ហើយថាបើអ្នកខ្លួលយកគ្រានេះហើយ កិច្ច
ការអ្វី ។ ក្នុងស្រុកកេងដីវ ក៏ត្រូវធ្លាក់មកជាធុរៈលើអ្នកទាំងអស់ ។

គួនអ៊ូថា ខ្លួនខ្ញុំបាទជាប្រុសជាតិតាហាន នោះបើសេចក្តីស្វាប់ទិង
ត្រឡប់មកដល់ខ្លួន ក៏មិនមានគិតទិងនឹងប្រែប្រួលពាក្យសន្យាឲ្យបង, ខុង
បេងឮពាក្យគួនអ៊ូចរចាដល់សេចក្តីស្វាប់ដូច្នោះ ក៏ទឹកកន្ត្រឹចក្តីថា ពីដើម
យើងប្រុងទិងប្រគល់គ្រាសម្រាប់ងារពៅហ្វាយខែត្រឲ្យជាមង្គល ដែលមក
ចរចាជាពាក្យអតមង្គលដូច្នេះមិនគួរសោះ ខុងបេងក៏តន្ទើនសួរថា ខ្លួនអ្នក

ខ្ញុំនៅក្បាស្រុកខ្លួន ធុរៈទាំងពួងដូច្នេះ បើប្រសិនជាចូរធ្វើលើកខ្ញុំតមក រួយយកស្រុកកេងដីវ៉ា តើអ្នកទាំងត្រូវគិតការពារដូចម្តេច, គួនអ៊ូឡើយ ថា ខ្លួនខ្ញុំបាទជាទាហានគ្មានខ្លាចដល់សត្រូវសោះ ទោះបីចូរធ្វើលើកខ្ញុំតមក ខ្ញុំបាទក៏ត្រូវស៊ូច្បាំងឲ្យតេញកម្ចាំង ត្រាតែចាញ់ទាំងឈ្នះមិនឲ្យអប្បយស ។

ខុងបេងសួរថា បើស៊ុនគួនទាំងចូរធ្វើលើកខ្ញុំតប្រសូត្តាចូលមកវាយដណ្តើមយកស្រុកនេះ តើអ្នកទាំងគិតប្រការម្តេច គួនអ៊ូថា បើយ៉ាងដូច្នេះ ខ្ញុំបាទទាំងញែកទាហានចេញជា ២ កងច្បាំងទាំងសងខាង បើគាលណាខ្លួនខ្ញុំបាទស្លាប់ហើយ ទើបស៊ុនគួនទាំងចូរធ្វើយកស្រុកកេងដីវ៉ាចុះ បើមិនទាន់ស្លាប់ទេ លោកកុំសង្ឃឹមឡើយថា ស្រុកកេងដីវ៉ានេះជារបស់អ្នកដទៃនោះមិនមែនទេ, ខុងបេងថា បើការសង្គ្រាមមានមកហើយ អ្នកមិនបានរិះគិតប្រើឧបាយច្រើនជា យកតែកម្ចាំងហៅហ៊ានទន្ទ្រានតាប់យកកម្ចាំងគេដូច្នេះ យើងយល់ឃើញថា ស្រុកកេងដីវ៉ានឹងចូលជាច្រកដ ដែលអ្នកទាំងនៅក្បាស្រុកកេងដីវ៉ានេះ ចូរចាំស៊ីដីយើងទុកចុះ ទោះបីអ្នកទាំងប្រត្តិត្តតាមហើយ ស្រុកកេងដីវ៉ាគង់ទាំងមិនអន្តរាយឡើយ, គួនអ៊ូសួរថា លោកទាំងធ្វើប្រការម្តេច? ។

ខុងបេងប្រាប់ថា អ្នកនៅក្បាស្រុកជាក្រោយយើងនោះ ចូរចាត់ការក្បាស្រុកឲ្យមួនមាំ គឺប្រយ័ត្នខាងទិសឯជើងចាំតទល់នឹងចូរធ្វើឲ្យបាន

ឯទីសងាងគ្នងនោះ អ្នកត្រូវធ្វើចិត្តឲ្យល្អតស្ថានមេត្រូវនឹងស៊ុខគួនឲ្យបាន
ជាប្រក្រតី ទើបស្រុកគេងជីវិតនេះនឹងបានសេចក្តីសុខ គួនអ៊ូកមានចិត្តត្រេក
អរណាស់ថា តាក្សាបស់លោកដែលរំលឹកនេះ ខ្ញុំបានរៀកដាក់ក្នងដើម
ទ្រូងពាក់អាវត្រៃប់ខ្ពុកមិនក្ងេចឡើយ, ខុងបេងប្រដៅគួនអ៊ូសព្វត្រប់ហើយ
ទើបយកត្រាសម្រាប់ងារចៅហ្វាយខែត្រនោះប្រគល់ឲ្យគួនអ៊ូ ហើយកំ
រើតណ្ឌាហានទីងនាយតាហានតីអ៊ុចៀ មាំលៀង អៀងឡង ប៊ីតុកខាង
រដ្ឋបាល៤នាយ, ប៊ីហង ខ្មៅហង គួនប៊ង ជីវធង ៤នាយខាងតាហាន
ឲ្យនៅរក្សាស្រុក ក្រោមបង្គាប់គួនអ៊ូស្រេចហើយ ទើបចាត់ឲ្យខៀវហុយ
ឃុំតាហាន ១ ម៉ឺនជាទីពាគាត កំណត់ឲ្យលើកចេញទៅចាទួលទីហ្នង
ត្រង់ភ្នំរបន្ទាយទិសឯលិចស្រុកឡុកសៀ ចាត់ដូឡុងឲ្យឃុំតាហាន១ម៉ឺន
ជាកងមុខទីពីក ខ្លួនពុងៈបេងឃុំតាហាន ១ ម៉ឺន ៥ ពាន់ ជាកងហ្នង
លុះបានកំណត់ប្រុកល្អ កំឲ្យលើកទីតទីកទីពគាកទៅព្រមគ្នា ខាងខៀវ
ហុយលើកទៅដល់ដែនស្រុកជ៉ាកុនហើយ កំកជាប់តាហានមិនឲ្យធ្វើ
អន្តរាយដល់អ្នកឯណាតាមតាក្សាពុងៈបេងបង្គាប់ត្រប់ប្រការ ។

ខណៈនោះ ចំរើសេះគឺនាំយកសេចក្តី ភាប្តីនងៀមង៉ាន ថាចៅហ្វាយ
ស្រុកជ៉ាគុនថា ឥឡូវខៀវហុយលើកកងទ័ពកន្ទុងចូលមកក្នុងដែនហើយ
ងៀមង៉ានឮដូច្នោះកំពាត់តាហានឲ្យប្រុងប្រយត្ន័ រក្សាស្រុកមាំមួនណាស់
ព្រោះតាំដើមនោះដឹងថា ខ្មៅតីលើកតាហានមកភយយកបន្ទាយចាំយ
ស៊ីគួនបាន កំមានចិត្តខឹងជាប់ជាប ទើបឲ្យកេណ្ឌាហានលើកទៅទីង

ឯយខ្លៅដែរខ្លៃ តែថាទៅជាមេភ្លើងក្រោយ ខ្លាចក្រែងកងទ័ពខ្លៅពីនឹងលើកមកប្រជនខាងផ្លូវស្រុកចាំកុន ជាន់ជាបង្ខិតកងទ័ពទុកមិនទាន់លើកទៅច្បាំងនឹងខ្លៅពី លុះដឹងថាខ្លៃហ៊ុយលើកទៅដល់ក៏តេណ្ឌាជាន់ប្រចាំការក្បាយស្រុកមិនជាន់ឲ្យលើកចេញទៅចំណុះ ព្រោះឆ្មែងដាំនោះជាមនុស្សមានថ្វីដៃខ្លាំងពូកែ ខោះច័ថាខ្លួននោះ មានអាយុជាកណាស់ហើយក៏មែន តែថាគង់ទៅមានកម្លាំងច្រើន អាចតស៊ូនឹងពលមួយម៉ឺនជាន់ដោយឈរលំពែងធំសម្រាប់គាន់នោះ ។

ខ្លៃហ៊ុយដឹងថា ឆ្មែងដាំនឹងតស៊ូដូច្នោះ ក៏ឲ្យតាំងបន្ទាយយ៉ាងមាំទុកចំរុងការ ហើយឲ្យគាហានចូលទៅស្រែកដេរ ត្រង់មុខភ្នំស្រុកថាអាកញ្ជាសំដកចូរប្រញាប់ចេញមកតំទាប់អញដោយស្រួល, បើខំតែរឹងខ្ចឹងទៅ អញនឹងលើកគាហានចូលទៅជាន់សង្កត់ឲ្យល្អិតអស់ពាំងស្រុក សូម្បីតែគាកេទៅក្នុងអង្រឹង ក៏មិនទុកឲ្យសល់ទឹងសម្លាប់ឲ្យអស់, ឆ្មែងដាំឮដូច្នោះកំរើងណាស់ គួរចាត់ចែងរៀបគាហានចេញទៅច្បាំងហេតអ្វីគាហានឆ្លើយមាត់ថា លោកកំអាលលើកចេញទៅច្បាំងសិនខ្ញុំបានដឹងថា ខ្លៃហ៊ុយនោះមានថ្វីដៃខ្លាំងពូកែណាស់ ត្រូវតែប្រុងប្រយត្ន័គិតរក្សាបន្ទាយឲ្យមាំមួនទៅជាជាង ព្រោះគាហានដែលលើកមកនោះសុទ្ធតែមកពីចម្ងាយ គង់ទឹងជាចង់ស្បៀងអាហារមិនខាន មួយទៀតខ្លៃហ៊ុយនោះជាមនុស្សចិត្តរហ័សបើយើងទៅសម្លុំ ទំនៃការពោតក៏ក្នុងកំ

ទីដែលកខ្ញុំយកចូលមិនបានដោយស្រួលទេ មុខជាទីដ្រខ្លាតទ្រឹងប្រឹងកយដំបង្គំគាហានឲ្យបានសេចក្តីក្តៅក្រហាយ, គាហានតាំងព្យាយកតទីដែលប្រែចិត្តគិតដោះខ្លួនចេញអស់ យើងទីងគិតរឿការយកដំយដំនះបានដោយងាយ, ដៀមងាំនយល់ឃើញត្រូវកំឲ្យគាហានប្រុងប្រយ័ត្នការរក្សាទីសើនបន្ទាយមិនឲ្យដំលាយចូលបាន ។

ខណៈនោះ ខ្មៀវហ៊ុយចេះតែបន្ថែមប្រើគាហានឲ្យទៅហៅឲ្យបើកទ្វារ ដៀមងាំនកឹបង្គាប់ឲ្យ បើកទ្វារឲ្យគាហានម្នាក់ចូលទៅ គាហាននោះកំនិយាយថា តួឯងខ្មៀវហ៊ុយប្រើខ្ញុំបាទឲ្យមកជំរាបលោកឲ្យបើកទ្វារទទួលដោយល្អទៅ បើរឺទទីងនៅដូច្នេះ នោះបើគាហានវាយទម្លាយចូលមកបាន ទីងសំឡាប់ឲ្យអស់មិនឲ្យមានសល់ដល់ម្នាក់ឡើយ, ដៀមងាំនខឹងណាស់ថា អាចោរម្សៀតហ៊ានមកនិយាយត្រហឹនមាក់ងាយអញដល់ម្ល៉ះ អាឯងគិតថាអញខ្លាច ខ្លួនអញជាមនុស្សចាស់ពុំប៉ុណ្ណោះហើយ ទីងងាកមុខចេញទៅតំនាម់នាយឯងមីងឬ អញសុំឲ្យមាត់ឯងឲ្យឯងចេញទៅប្រាប់នាយឯងចុះថាអញស៊ូតែស្លាប់ មិនចេញទៅតំនាម់ឯងទេ ហើយកំឲ្យគាត់មាត់ប្រមុះគាហានខ្មៀវហ៊ុយនោះអស់ ហើយបើកឲ្យចេញមកវិញ, លុះគាហាននោះទៅដល់តំស្រែកយំប្តូប់ខ្មៀវហ៊ុយ តាមសំដីដៀមងាំនថាត្រម់ប្រការ ។

ខ្មៀវហ៊ុយខឹងខ្លាំងណាស់ កំលើកគាហានប្រមាណ ២០០ឡើងសេះ

ហើយចូលទៅដល់ដើងកំផែង, ពាហានឆ្មើមដាំនដែលទៅលើសើនបន្ទាយ
តែមិនបានចេញមកតស៊ូ តាំងតែស្រែកដេរៗទៀហ៊ុយជាពាក្យទ្រគោះអស្ចារ្យ
ផ្សេងៗ, ទៀហ៊ុយតែតែខឹងណាស់ បើដូចគ្នើងនេះកណ្តាលដើមទ្រូង ទើបហែរសេរបំពារចូលទៅក៏ទើសនឹងគួកំផែងចូលទៅពុំបាន បាន
តែតំរាមស្រែកមិនឈប់ពាល់តែត្រលប់ក៏ត្រឡប់រំលែទៅបន្ទាយវិញ លុះ
ព្រឹកឡើងលើកពាហានចូលទៅស្រែកដេរទៀត ឆ្មើមដាំនក៏យកធ្នូបាញ់
ទៅត្រូវមួកទៀហ៊ុយ, ឯទៀហ៊ុយខឹងណាស់ក៏លើកដៃចង្អុលដេរថា
អាកញ្ជាស់បើអញចាប់បានខ្លួនឯង អញនឹងវែនខ្លួនសាច់ឲ្យអស់ទៅ
តែម្តង ស្រែកដេរពាល់តែត្រលប់ទើបត្រឡប់ទៅបន្ទាយវិញ ។

លុះព្រឹកឡើងជាថ្ងៃគំរប់ ៣ ទៀហ៊ុយលើកពាហានត្រឡប់ចូល
ទៅស្រែកដេរជុំវិញកំផែងតាមភ្លារ ឃើញឆ្មើមដាំនមិនបើកភ្លារលើកពា
ហានចេញមកច្បាំងសោះ ក៏ពាហានដំរះសេរឡើងទៅលើគ្នរហើយសំឡឹង
មើលទៅក្នុងស្រុកឃើញ ពាហានតាំងពួន តែងខ្លួនពាក់គ្រោះកាន់អាវុធ
ត្រៀមចាំព្រមគ្នា ទៀហ៊ុយក៏ឲ្យពាហានត្រឡប់ចុះមកវិញ ហើយធ្វើជា
ដេកលក់ស្កាត់អស់ ក្រុថ្នាំងឲ្យឆ្មើមដាំនឃើញថាអស់កម្លាំងនឹងលើក
ចេញមកច្បាំង ក្រោយទោះក៏មិនបានឃើញឆ្មើមដាំនចេញមក, លុះវៃ
លាល្ងាចក៏ត្រឡប់ចូលបន្ទាយវិញ ទើបគិតថា ឆ្មើមដាំនេះមានអំណត់
អត់កំហឹងបានមិនចេញច្បាំង លុះព្រឹកឡើង ក៏ឲ្យពាហានចូលទៅស្រែក

ដេរដួចវៃមុនខៀតតំរង់ជាញវៃ, ដើមងាំនក៏មិនបានចេញចាំងសោះ ខៀវហ៊ុយកំភ្លើងធ្វើកលឲ្យទាហានដើរលេងកយគ្នាទៅរក១សន្ទុះ ឲ្យស្រួលរកផ្លូវដែលនឹងលើកចូលទៅក្នុងស្រុកនោះខ្លះ ។

ដើមងាំនឃើញទាហានខៀវហ៊ុយបែកខ្ញែកគ្នាទៅដូច្នោះ ក៏មិនបានដឹងថានឹងគិតធ្វើការម្តេច ទើបចាត់ទាហានឲ្យបន្ទុំចេញទៅស៊ើបយកការពាំងតួង លុះវេលាល្ងាច ទាហានដែលទៅស្រួលរកផ្លូវនោះវិលមកប្រាប់ខៀវហ៊ុយថា ដួចបើញផ្លូវដែលនឹងចូលទៅក្នុងស្រុកប៉ាកុនជាផ្លូវតូចនៅតែរួចដោយក្នុង, ខៀវហ៊ុយក៏មានអំណរណាស់ បង្គាប់ទាហានថាអស់ឲ្យដាំបាយស៊ីតាយចាំកំណាត់នឹងលបលើកទ័ពទៅ កុំឲ្យដឹងខ្លួនថាន់ឲ្យកងប៉ុំមាត់រេះកុំឲ្យស្រែកឮសម្លេងបាន ឯខ្លួនយើងនឹងទៅមុខ ឯទាហានដែលលើកតាមទៅជាក្រោយនោះ ឲ្យប្រុងប្រយត្ន័ខ្លួនកុំឲ្យប្រមាទ ខៀវហ៊ុយដាក់កំហិតបង្គាប់បញ្ជាទាហានសព្វគ្រប់ហើយក៏ឲ្យណាត់តេលដែលនឹងលើកចូលទៅនោះនៅក្នុងយាម ៣ ។

ឯទាហានដើមងាំនដែលបន្ទុំចេញទៅនោះក៏ដឹងរឿងក្តី ទើបត្រឡប់ចូលទៅប្រាប់ដើមងាំន ។ ក៏មានរឿងក្តីត្រែកអរណាស់ និយាយថាដៃលខៀវហ៊ុយ នឹងលើកតេលចូលមកតាមផ្លូវតូចខាងយើងនឹងលើកទាហានចេញទៅចាំកាត់ស្ទៀង ហើយនឹងរយត្ន័ចូលមកត្រួតចាប់យកខ្លួនខៀវហ៊ុយឲ្យបាន ដើមងាំនរៀបចំទាហានត្រមៃហើយក៏លបលើក

ចេញមកពីក្នុងតំណែងស្រុក ក្នុងពេលនាក់កណ្តាលអន្ទាក់ទៅបង្កប់ចាំ
ត្រប់ប្រាក ។

លុះដល់យាម ៣ ខៀវហ៊ុយក៏ឲ្យគាហានម្នាក់តែងខ្លួនពាក់គ្រោះធំធ
ប្រដាប់គាវៅដូចខៀវហ៊ុយ ហើយក៏ឲ្យដំរះសេះបរចេញទៅមុន ខ្លួន
ខៀវហ៊ុយលើកគាហានតាមទៅជាក្រោយ, ឆៀមង៉ាន់ដែលបង្កប់គាហាន
ចាំក្បែរផ្លូវនោះ ក្រឡេកឃើញគាហាន ដំរះសេះមុខនោះដូចខៀវហ៊ុយក៏
សំគាល់ថាដូចជារូបខៀវហ៊ុយប្រាកដឲ្យគាហានសម្ងំចាំ លុះកន្លងទៅ
ឆ្ងាយហើយ ទទួលកងស្បៀងលើកមកដល់ទីនោះ មិនដឹងថាខៀវហ៊ុយ
បន្ទំមកជាមួយ ក៏អុជផ្លាវជាសញ្ញាឡើង ហើយពួយគងឃ្លោះស្គរលើក
គាហានចេញពីសងខាងផ្លូវមកប្រកាប់ប្រទាក់គ្នាជាច្រួលច្របល់ ។

ខណៈនោះ ខៀវហ៊ុយក៏ញាក់សេះដាកមកឃើញឆៀមង៉ាន់ទៅពី
មុខ ក៏ស្រែកគំហកដោយសម្លេងយ៉ាងខ្លាំងថា អាសត្រូវកញ្ជាស់ ទីនេះ
អ្នកកុំតែមិនរួចពីដៃអញទេ ឆៀមង៉ាន់ឮសម្លេង, ដាកមើលមកក្រោយ
ឃើញខៀវហ៊ុយក៏ស្ទុះស្ទាំងកាំង ត្រឡប់ញាក់សេះមកតយុទ្ធនឹងខៀវ
ហ៊ុយបាន១០ក្នុង, ឆៀមង៉ាន់បានការក៏លើកដាវឡើងគាប់, ខៀវហ៊ុយ
ក៏គេចរងាន់ កន្ត្រាក់សេះត្រឡប់ទីមគ្នាទឹងសេះឆៀមង៉ាន់ ចូលទៅកៀក
បានខ្លួនក៏បូតថ្នាក់ពីលើសេះ, គាហានទាំងពួងក៏ស្ទុះស្រែចូលទៅជួយព្រួត
ចាប់ខ្លួនឆៀមង៉ាន់បានក៏ចងដឹកយកទៅ, គាហានឆៀមង៉ាន់ក៏ចែកចាក់

ភ្លក់ភ្លុយទៅអស់ ខ្លះកំត្រឡប់ចូលមកខាងខៀវហ៊ុយជាច្រើនខៀវហ៊ុយ
ក៏បរតលចូលទៅវាយស្រុកចាំកុនបាន ទើបកំដាប់ខាហានតាំងតួងមិនឲ្យ
ធ្វើអន្តរាយដល់បណ្តារាស្ត្រអកស្រុកនោះ ។

ពួកខាហានក៏នាំយកខ្លួនឆៀមងាំន់ចូលទៅឲ្យខៀវហ៊ុយ ។ ឃើញ
ឆៀមងាំន់មិនបានគំនាប់តាមប្រពៃណីក៏ខឹងនាំមាត់ហើយស្រែកថា ខ្លួន
អញជាខាហានឯក លើកទ័ពចូលមកដល់ទីនេះ ហេតុម្តេចបានជាមិន
ចេញមកគំនាប់អញ ត្រឡប់ហ៊ានតស៊ូនឹងអញទៀត ឆៀមងាំន់ធ្វើឃតប
ថា ខ្លួនឯងជាមនុស្សអាក្រក់គ្មានសេចក្តីស័ត្យសុចរិត លើកទ័ពមកប្រទូស
ព័យតែឲ្យអាណាប្រជាខុរាស្ត្របានសេចក្តីក្តៅក្រហាយ អញត្រូវការអ្វី
នឹងទៅគំនាប់ឯង ថ្វីដ្បិតតែឯងចាប់ខ្លួនអញបាន អញមិនត្រូវខ្លាចស្លាប់
ចើកឡើយ អញនឹងជាប់ចេញក៏មិនសុំគំនាប់ឯងឡើយ ខៀវហ៊ុយខឹងណាស់
បង្គាប់ឲ្យខាហាននាំយកខ្លួនឆៀមងាំន់ទៅសម្លាប់,ឆៀមងាំន់ថា ឯងនឹង
សម្លាប់អញក៏សម្លាប់ចុះ ចាំខឹងក្តៅក្រហាយធ្វើអ្វីទៀត ។

ខៀវហ៊ុយឃើញអាការកិរិយាឆៀមងាំន់មានចិត្តមិនតក់ស្លុតខ្លាំនឹង
សេចក្តីស្លាប់ដូច្នោះ ក៏ដូចជារសាយកំហឹងអស់ទើបគ្រាតចុះទៅស្រាយចំ
ណងដែលចងឆៀមងាំន់ចេញហើយ ក៏កៀកខ្លួនឡើងទៅជិតលើកៅអី
ទឹមគ្នាហើយនិនាំថា ខ្ញុំដឹងថាអ្នកជាមនុស្សចាស់ មានអធ្យាស្រ័យ
ប្រកបទៅដោយសតិបញ្ញាមតាយូរហើយ ដែលខ្លួនខ្ញុំទៅក្លែងមិនបាន

គាវ៉ះ ដល់ចាស់ហើយ ថែមមកពោលពាក្យ ទ្រគោះប្រមាថដូច្នេះមិនគួរ
សោះ ខ្ញុំក៏ខុសល្មើសលើសលោះណាស់ទៅហើយ សូមឲ្យអ្នកអត់ទោស
សន្ទោសដល់ខ្ញុំទៅចុះ ។

ឆ្មែងាំនំបានស្តាប់ដូច្នោះ ក៏គិតដល់គុណបកាវខ្មៅហ៊ុយ ពន់
ប្រមាណណាស់ ទើបនិយាយថា តើដើមខ្ញុំឮគេនិយាយថា ខ្លួនអ្នកនេះជា
មនុស្សចិត្តអាក្រក់កាចសាហាវណាស់ មិនដឹងក្តីមិនដឹងចាស់សោះ
ឡើយ តែឥឡូវខ្ញុំឃើញហើយថាអ្នកជាមនុស្សសុភាព ដឹងខុសចងខុស
ត្រូវស្រួលល្អណាស់ ទោះជីខ្លួនអ្នកនៅក្មេងយ៉ាំងណា ក៏គួរឲ្យខ្ញុំជាចាស់
កោតខ្លាចអាចនឹងគោរពតាមគួរសម, ឆ្មែងាំនំនិយាយហើយក៏ក្រោក
ឡើងទទួលគំនាប់ខ្មៅហ៊ុយ ដោយប្រក្រតីកប់អានថាជាអ្នកមានគុណ
ដល់ខ្លួន ។

ខ្មៅហ៊ុយសួរថា តែឥឡូវខ្លួនខ្ញុំនឹងលើកទ័ពចូលទៅស្រុកឡុកសៀ
នោះ តើនឹងលើកទៅតាមផ្លូវណា, ឆ្មែងាំនំ ឆ្លើយថា ឯស្រុកឡុកសៀ
នោះ មានគយតាមរយៈផ្លូវជារច្រើនដំបន់ណាស់ កម្រនឹងទៅឲ្យបាន
ស្រួល តែថាខ្លួនអ្នកមានទុបការៈដល់ខ្ញុំបានដែលបានរួចជីវិតដល់ប៉ុណ្ណេះ
ហើយខ្ញុំត្រូវតែតបស្នងសងគុណអ្នកឲ្យដល់ខ្នាត គឺខ្ញុំជាអ្នកនាំផ្លូវទៅកាន់
ស្រុកឡុកសៀ ខ្ញុំសូមលើកទាហានទៅជាមុខ បណ្តាគយល្បាតដែល
មានទៅតាមរយៈផ្លូវនឹងទៅនោះ សុទ្ធតែទៅក្រោមបង្គាប់ស្តាប់ខ្ញុំជាអ្នក

ត្រួតត្រាគ្រប់ដំបន់, ខ្មៀវហ៊ុយមានសេចក្តីសោមនុស្សសោកវេរស្មោះសរពន់ប្រមាណណាស់ ទុនតំនាក់ហើយ កំពត់ឲ្យឆៀមងាំន់លើកតព្វាហៈទ័ពចេញទៅជាទ័ពមុខ, ខ្លួនខ្មៀវហ៊ុយកំលើកទាហានទៅតាមក្រោយលុះឆៀមងាំន់លើកទៅដល់ដំបន់ណា បណ្តាក្នាក់ងារជាមេគយល្បាតនៅដំបន់នោះ សឹងតែចេញមកតំនាក់លុតគ្រាបឆៀមងាំន់តាមប្រក្រតី ឥតបីមានទទឹងរឹងត្រប់ដំបន់ ខណៈដែលមេគយល្បាតទាំងបានចុះចូលដល់ឆៀមងាំន់ហើយ ក៏ចុះចូលដល់ខ្មៀវហ៊ុយជាមេទ័ពធំដែរបៅ, ខ្មៀវហ៊ុយក៏លើកទ័ពទៅកន្លែងនោះដោយស្រួលបួលគេកណាស់ សូម្បីក្របីម្តងវាក៏មិនបានហួតចេញពីស្រោមសោះ ឆ្កែមិនបានដំឡើងខ្សែនឹងព្រួញ ព្រោះឆៀមងាំន់ជាទ័ពមុខទៅ ។

សាមកុកខ្សែ៣

តាំងតាំងពីលើកទ័ពទៅវាយបែកបន្តាយខ្មៀវយិន ។ រត់ទៅចូលទៅក្នុងស្រុកឡុងសៀរហូតទៅដល់ភ្លើងធ្វើសំបុត្រទៅដល់ខ្មៀវឡុងឡើកទ័ពមកនួយក្តាំងនឹងខ្មៅពី ។

ឯខ្មៅពីកំយកសំបុត្រដែលឧត្តរបេង ឲ្យកំណត់ ទៅនោះមកតាំគ្រោះនឹងហង្គតុងថា ឧត្តរបេងប្រាប់មកយើងថាទ័ពលើកកងទ័ពមកជួយយើងនោះតាំងពីខែស្រាពណ៌៩កើតមកដល់ឥឡូវ មើលតាមសំបុត្រកំយូរថ្ងៃណាស់ ហើយប្រហែលទ័ពលើកកងទ័ពមកដាច ដល់ហើយដឹង យើងកំ

មិនត្រូវទៅសៀម ត្រូវតែរិះគិតចាត់ការលើកទាហានទៅប្រសព្វគ្នានឹងកងទ័ពខុងបេងឯស្រុកឡុកសៀ ហើតុដូចជា ឥឡូវទាហានខ្មែរយើងយើញយើងមិនទាន់ចេញច្បាំង គង់តែឯងបានចិត្តកំរើកឡើងខ្មែរ យើងត្រូវចាត់ទាហានលើកទៅចោមរោយប្តូន យកបន្ទាយក្នុងពេលអន្ត្រាត្រយប់ខេះបុះ ខ្មែរយើងយើញថា យើងខ្លាចហើយក៏ងឹតព្រងើយកន្តើយធ្វេសប្រមាទ យើងនឹងព្រួតយកឱ្យបែកតែម្តងរួចសឹមលើកកងទ័ពហួសទៅប្រសព្វគ្នានឹងទ័ពខុងបេង, ខ្មៅពីយើញត្រូវដូង ក៏ឱ្យបំរុងតាំងត្រៀមទាហានទុកជាស្រេច លុះដល់ពេលយប់ប្រមាណយាម ២ ជាយ ខ្មៅពីយើញស្ងាត់បានការ ក៏លើកពលទាហានចេញពីបន្ទាយ ចូលទៅចោមរោយទ័ពខ្មែរយើងជា ៣ ប៉ែក ឱ្យទាហានបំបែកដុតភ្លើងឡើងត្រប់កន្លែង, ខ្មែរយើងនឹងទាហានតាំងនោះមិនទាន់ដឹងខ្លួនក៏ភ្ញាក់ឡក់ស្ទុតជា ប្រួលប្រួលបែកខ្ញែកគ្នាជារកាលហាលពេញបន្ទាយ រត់ពារទំលាយចេញទៅអស់គ្មានសល់ខ្លះក៏រត់រិលរាលចូលព្រៃ ខ្លះក៏រត់កាត់សំដៅទៅស្រុកឡុកសៀខ្មៅពីក៏លើកពលដេញតាមតាច់សម្លាប់យកបានគ្រឿង សស្ត្រាវុធជារាប្រើន ទាហានខ្មែរយើងរត់ចូលទៅក្នុងបានជារាប្រើន ខ្មៅពីតាមទៅមិនកំលាយយកបន្ទាយមិនបាន ក៏ឱ្យទាហានថយមកតាំងបន្ទាយឆ្ងាយពីស្រុកនោះប្រហែល ១០០សិន (ង.គ ម.) ។

លុះកន្លងមកពីរថ្ងៃ ខ្មៅពីក៏លើកទាហានព័ទ្ធស្រុកឡុកសៀជុំវិញ ឯ

ខ្លៀវយើមក៏មិនបានចេញតវៃ ឲ្យគាហានប្រុងប្រយត្ន័គិតរក្សាតែតាក្តន ខ្លៅ
តាក៏លើកគាហានចូលកាច់យកគយទំសឯលំច បើកចំហាមិនតខ្ជិទំសឯ
ដើនទំនឹទំសឯស្លឹន ប្រាថ្នាទំនឹឲ្យមនុស្សក្នុងស្រុកវត់ចេញ កំបង្គំគាហាន
ឲ្យខន្ទ្រានចូលបំពារឲ្យខាងតែបាន, ខ្លៀវយើមខ្លើនលើសើនបន្ទាយក្រ
ខ្លៅកមើលឃើញខ្លៅតាដំរសេះដើរត្រួតត្រាគាហាន តាំងតាមោំង ៣ ត្រឹក
រហូតដល់ថ្ងៃរសៀលគាប គាហានគាន់នោះតំខ្លើយណាស់ជាច្រើនខ្លៀ
យើមឃើញបានការកំឲ្យគាហានចុះពីលើសើន កេណ្តាឲ្យអ្នកស្រុកខ្លើន
ទៅប្រចាំការដំនួស ហើយឲ្យដញ្ជូនថ្នូរខុកសម្រាប់ចាំដំនឹគាហានខ្លៅ
តាហើយក៏លើកគាហានចេញតាមផ្លូវទំសឯស្លឹន កេចមកខាងលិចចូល
រាយទំតខ្លៅតា ឲ្យលុយតងឹនឹងនឹខ្លាន់លើកគាហានចេញតាមភ្នូវទំស
ខាងដើង កេចទៅព័ទ្ធទំពាក់អ៊ុយអៀនឹដហងតុង ។

ខ្លៅតាចាត់គាហានឲ្យត្រួតការ ចំណាយចូលមិនបានគាល់តែកេលថ្ងៃល្ងាច ហើយក៏បន្តយគាហានចេញទៅវិញ ស្រាប់តែឮសំឡេងដាវអុជខ្លើន, ខ្លៀវយើមលើកគាហានផ្ងួនចូលមកវាយ, គាហានខ្លៅតាក៏យណាស់ ក៏បែកខ្ញែកគ្នាជាចលាចល អ៊ុយអៀនឹដហងតុងឃើញដូច្នោះក៏ដេញគាហានឲ្យទៅជួយខ្លៅតា, ខ្លួលលុយតងឹនឹខ្លាន់ លើកគាហានចេញមកស្កាត់ខឹតាមុខនឹងរុកចំការទៅមិនរួច គាហានចាំងសងខាងក៏ត្រួតប្រកាប់គ្នាជាប់ដៃ ខ្លៅតាឃើញគាហានស្លាប់ច្រើនណាស់លើស

កម្ទាំងខ្លួនគ្រាំគ្រាតពុំបាន កំញាក់សេះវ៉ះរត់តាខ្មៅយើងមៅតាមផ្លូវតួចប្រកក្ខ
ខ្មៅយើងក៏សង្កត់ញាបន្ទុំដេញតាមមៅ ។

ខណៈនោះ ខ្លួលខ្មៅហ៊ុយលើកមកជល់ដីតស្រុកឡុកសៀ
យើញផង់ជួលីហុយគ្រលោមពីខាងមុខប្រហែល១០០ម៉ែន (៤គ.ម) ក៏
សំគាល់ថា កងខ័ពស្រុកកេងដ៏ខ្លាំងតន្ទានឹកងខ័ពស្រុកឡុកសៀ ទើបបំ
បោលសេះស្ទុះចូលមៅប្រញាប់ ខ្មៅតាឮសំឡេងមនុស្សគ្រហឹងមកពីខាង
មុខមិនដឹងថាជាខ័ពខ្មៅហ៊ុយលើកមក ក៏យកដៃតត់ទ្រូងហើយស្រែកថា
ខ្មៅតាអើយជីវិតខ្ញុំម្ចាស់នេះ ត្រូវគេប្រហារម៉ង់ផ្ទាញឲ្យស្លាប់ជាប្រាកដហើយ
ខ្លួលក្រឡេកមៅយើញខ្មៅហ៊ុយបំបោលសេះចូលមកនៅតាមុខភាន
កាន់លំពែងនៅដៃ ខ្មៅតាក៏ត្រេកអរណាស់ស្រែកថា ខ្មៅហ៊ុយជួយបង
ផង, ខ្មៅហ៊ុយយើញខ្មៅយើងមដេញខ្មៅតាជាម៉ប្រកិតមកក៏បរសេះសំ
រុកចូលមៅជួយខ្មៅតា ស្គាត់ខឹងតាមុខខ្មៅយើងហើយក៏ចូលប្រយុទ្ធគ្នា
ឮឯខ្មៅយើងមបាន១០ក្នុង ខ្លួលឆៀមឆាំមបរសេះតាមក្រោយខ្មៅហ៊ុយ
ចូលមៅជល់ខ្មៅត ខ្មៅយើងមយើញដូច្នោះក៏ញាក់សេះថយរត់ ខ្មៅហ៊ុយ
ក៏ដេញតាមប្រកិតមៅដីតៈដីឯកំផែង ខ្មៅយើងមចូលមៅក្នុងស្រុកបាន ក៏
ឲ្យបិទទ្វារជាប់ហើយឲ្យភាភានបាញ់ធនូរម្រុះមកពីក្នុង ខ្មៅហ៊ុយក៏ញាក់
សេះវ៉ះថយក្រោយមកកេខ្មៅតីមានសេចក្តីត្រេកអរណាស់ ក៏នាំខ្មៅ
ហ៊ុយចូលមៅបន្ទាយ ខ្មៅហ៊ុយតំនាប់តាមប្រពៃណីហើយដំកបថា ឥឡូវ

អាចារ្យខ្ញុំបេងលើកកងព័ត៌មកតាមផ្លូវស្ងួត តែមកាំងនៅមិនទាន់មកដល់ខ្ញុំបាទមកដល់មុនក៏ត្រឡប់បានសេចក្តីតាប់ប្រសើរទៀត, ឡៅពីសួរថាផ្លូវនេះជាប្រកជ្រោះប្រលងរំលោងព្រៃភ្នំដ៏ញឹកញាត់ស្ងាតណាស់ ទឹងដើរដោយលំបាក មានទាំងតយស្ងាតជារច្រើនសន្ធាត់ជាខ្លាំងផ្អើត ហេតុម្តេចបានជាប្អូនឯងមកដល់មុន ខ្ញៀវហ៊ុយឆ្លើយថា ផ្លូវនេះមានតយស្ងាតដល់៤៥អន្លើ ជាខ្លាំងផ្អើតលំបាកពិតមែន តែថាខ្ញុំបាទបានអ្នកចាស់ឆ្លៀវឆាំនេះមានសេចក្តីកក្តៅដោយសុចរិតជួយជួនដំណើរមកឆាប់ ប៉ុន្មែរដល់ខ្លាំងដំបន់ណា ក៏គាចបេះនិយាយឲ្យក្លាក់ជារនៅខ្លាំងដំបន់នោះត្រមុះចូលដោយស្រួលទាំងអស់ មិនហានខ្លាំងឆ្លៀតនឹងខ្ញុំបាទសោះបានជាមកដោយស្រួល ឯសេចក្តីតាប់ប្រសើរបែបនេះ ជាប្រសើរលើសលុបគ្មានខ្លាំងផុត ហើយខ្ញៀវហ៊ុយក៏ពណិនារឿងការដែលបានច្បាំងគ្នានឹងឆ្លៀវឆាំនោះឲ្យឡៅពីស្តាប់ត្រប់ប្រការ ។

ឡៅពីដឹងសេចក្តីដូច្នោះក៏ត្រេកអរណាស់ និយាយនឹងឆ្លៀវឆាំថា គ្រានេះបើកុំបានអ្នកជាចាស់មានសេចក្តីមេត្តាជល់ប្អូនខ្ញុំ សង្ឃាំងាំផ្លូវមកក៏តង់មានកយន្តភយពុំខាន ហើយបើគ្មានអ្នកជួនដំណើរមកទេ គាលណាប្អូនខ្ញុំនឹងមកបានដោយស្រួល គុណអ្នកមានជល់ខ្ញុំនឹងរកខ្លាំងផុតគ្មាន និយាយហើយឡៅពីក៏ដោះក្រោះមាសចេញតង្វាន ហុចឲ្យទៅឆ្លៀវឆាំនាំជារង្វាន់តាមសេចក្តីតាប់ ហើយសួរគាហានទាំងពួងថានរណាអាចដឹងថា អ៊ុយអៀនឆ្លៀវឆាំតុងទាំងពីរនាយនៅឯណាជាប្រការម្តេចខ្លះ ។

(នៅមានត)

រឿងល្បែកទ្បាហ្មុងតែង

លោក ដេង - ទ្រីវ ប្រែរៀបរៀង

(តមក)

៦៦- សត្វលាដឹកនាំព្រះសារីរិកធាតុ

សត្វលាមួយដែលគេផ្ទុកព្រះសារីរិកធាតុ ទឹកស្មាខថា គេគោរពខ្លួន ។ លុះតិតដូច្នោះ លាដើរវាយឫកយ៉ាងក្រអឺត ប្រកាន់ពុតកង់ចិត្តដោយស្មាន ថា គ្រឿងក្រអូប ទឹងក្លែង ដែលគេលេងថ្វាយព្រះសារីរិកធាតុ គឺគេបូជាចំពោះខ្លួន ។

មានមនុស្សម្នាក់ ឃើញលាយល់គាន់ដូច្នោះ ក៏លើកថា នែលោកបង សូមជ្រាប កុំគិតក្លៀ ។ ការគោរពបូជាចាំងនេះ មិនមែនសំរាប់លោកបងទេ គឺសំរាប់ព្រះអង្គទេតើ ហើយកិច្ចកិត្តិយសនោះ តើតមានមក តែដោយសារអ៊ីចឹងទេ ។

គេមិនមែនគោរពសាមីខ្លួនអ្នកកាជការទេ គឺគេគោរពជាសក្តិទេតើ កុំសង្ហាពេក ។

៦៧ - គោខ្លឹងកពីរនឹងកង្កែប

គោខ្លឹងកពីរ ជល់គ្នាដណ្តើមនាងគោក្រមុំមួយ ព្រមទាំងកូនតូចៗ ឃើញដូច្នោះ នាងកង្កែបមួយ ចេះតែកេងឆ្លើមធំ ។ មានកង្កែបមួយ សួរថា: នាងឯងឈឺអ្វី? ។ នាងកង្កែបឆ្លើយថា «អ៊ីមិនដឹង! អ្នកឯងមិន

ឃើញខេ តែហើយតិចម្យ៉ាងហ្នឹង អាមួយត្រូវខ្លាតចេញមិនខាន ហើយ អាមួយខៀតខៀនតែ ដេញវាចេញតិវាលស្មៅ វាច្រាកដជាឈប់ខាន ថានៅវាលស្មៅ មុខជាវាមកអាស្រ័យនៅក្នុងត្រពាំង លើបបុសតាំង ឡាយ ជាមិនខាន រួចវាំនឹងជាន់យើងកប់ក្នុងទឹកស្លាប់មួយម្ដងៗ យើងត្រូវ ខ្លួលគ្រោះថ្នាក់នេះ មកពីចម្ការដែលបណ្ដាលឡើង ព្រោះតែនាងគេ ក្រមុំនេះឯង ។

ការភ័យខ្លាចនេះ ជាសេចក្ដីយល់ត្រូវ ។ អាឡើងកមួយចាញ់ ត្រូវ ឃ្លាតចេញពីទីលំនៅ ហើយមកលាក់ខ្លួនតួនអាគ្នាក្នុងត្រពាំង ជាន់កង្កែប ស្លាប់ក្នុងមួយម៉ោង២០ ។

រឿងនេះជាការណ៍ពិតណាស់ គ្រប់តែសម័យ គេឃើញថាអ្នកគួច វិនាសខ្លួន ដោយសារតែការត្រេកនៃអ្នកធំ ។

៦៨- សំដីលោកសុក្រាត់ (១)

ថ្ងៃមួយ សុក្រាត់រកគេឲ្យជួយសង់ផ្ទះ អ្នកគ្រប់គ្នា ចេះតែយល់ថាស់ ខឹងសំណង់របស់លោក: ខ្លះថា របៀបរៀបចំខាងក្នុង មិនសមគួរ ដល់ហាន: របស់លោក ដែលរ៉ែនន់នេះ គឺនិយាយដោយស្មោះត្រង់ ខ្លះ ទៀត យល់ថាស់ខឹងកន្ទបហាលខាងមុខ សរុបសេចក្ដីទៅ អ្នកចាំងអស់ ព្រមគ្នាយល់ថា ផ្ទះលោកគួចពេក ។ លោកធ្វើផ្ទះអ៊ីចឹងនេះ រកតែងាកខ្លួន

(១) អ្នកគ្រាដ្ឋិជាតិក្រោក ខាងទស្សនវិជ្ជា ៣៩៩ ឆ្នាំមុនព្រះគ្រិស្ត

ស្ទើរមិនបាន ។

សុក្រាតឆ្លើយតបវិញថា «ក្នុងផ្ទះប៉ុណ្ណឹង ឲ្យតែបានកល្យាណមិត្រ អង្គុយពេញ អរព្រះគុណហើយ» ។

សុក្រាតយល់ថា ផ្ទះលោកធំពេកផង សម្រាប់មិត្រខាងលើ ឃោចល់លោកនោះ ពេញហៅត្រូវ ។

អ្នកពាល់គ្នាគិតតាំងខ្លួនថាជាមិត្រ តែតឹមនុស្សគួរតទេ ដែលគិតថាជួញ្ជាះ ជ្រែតសំដីនិយាយ ថាងាយ តែត្រង់បេស់ ពក្រ ។

៦៩-ស្បែង

ថ្ងៃមួយ ព្រះមានបន្ទូលទៅកាន់សតូតាំងឡាយថា : ត្រូវសតូតាំងអស់មកខៀបព្រះបាទព្រះអង្គ ហើយបើសតូណាមួយមិនពេញចិត្តនឹងរូបកាយខ្លួន ក្រែងមិនសមរម្យដូចម្តេច ត្រូវតែកាំឡើង កុំបីកោតញាញើតព្រះអង្គនឹងតែឲ្យ ។

អាស្បា ! ចូលមក ចូរឯងនិយាយមុនគេ តើព្រោះហេតុអ្វី អាក្រក់ពេកឬ រូបកាយ? ចូរក្រឡេកមើលសតូដទៃ ចូរធៀបលំអរបស់គេនឹងលំអរបស់ខ្លួនមើល តើឯងពេញចិត្តនឹងរូបសព្វថ្ងៃប៉ុណ្ណឹងឬ ? ។

ស្បាក្រាបបង្គំទូលថា « ខ្ញុំ? ហេតុអ្វីមិនពេញចិត្ត? ខ្ញុំមិនមានដើងប្លែកស្អាតដូចសតូដទៃ? ខ្ញុំគ្មានខាស់ចិត្តអ្វីសោះ នឹងរូបខ្ញុំ តាំងពីដើមមក តែមើចំណែកបងខ្ញុំឃ្មុំ ខោះគួរតក៏ដែរ ព្រោះរូបគាត់ ដូចជាគេធ្លាក់ខ្ទុះ

គាត់មិនព្រមជឿខ្ញុំ ថែមទាំងមិនព្រមឲ្យគេធ្វើតែសាជាច្បាស់។ ។

លុះត្រូវត្រង់ឈ្មោះភូ ខ្វាយ៉ូដើរចូលមក គេស្មានថា មុខជាវាំនឹងគ្មានកន្លែងអំពីរូបវាមិនខាន ។ តែគេមើលយ៉ាងណាក៏ដោយ ខ្វាយ៉ូនៅតែសរសើរថាល្អ ថាសមរម្យ រាត្រឡប់ទម្លាក់កំហុសទៅលើដំរី ហើយគោលថាគេត្រូវបន្ថែមត្រង់តន្ទុយឲ្យដំរី ហើយត្រូវគាត់ស្ទឹកត្រៀកបន្ថែចចេញ ព្រោះដូចជាដុំមួយ គ្មានភាំនឹងគ្មានលំអអ្វីសោះ ។

ដំរីឮដូច្នោះ គេមើលភ្លាប់ជាសត្វស្លូត លោមន្តនេះ ចេះគោលដូចគេទាំងលើ ហើយថា តាមយោបល់របស់វាថា: អ្នកស្រី«(១)ចាំខ្សែន»ធំពេក។

ចំណែកអ្នកស្រីស្រមោចយល់ថា ស្រមើលតូចពេក ហើយស្មានថាខ្លួនជាសត្វធំសម្បើម ។

ព្រះកឹបញ្ជូនឲ្យត្រឡប់ទៅវិញ ព្រោះពិនិត្យទៅឃើញថា សត្វទាំងអស់សុទ្ធតែសុខចិត្តនឹងរូប រឿង ។ ខ្លួន ហើយឃើញតែកំហុសសត្វដទៃ ។

បណ្តាមនុស្សឆ្គួតទាំងអស់ សុទ្ធតែលើកកំពស់ខ្លួនឯង ហើយបង្អាប់អ្នកដទៃ ត្រង់ខ្លួនឯងនេះតែត្រូវ អ្នកគ្រាចេះតែគាស់ គោសខ្លួនឯង មើលឃើញតែភ្នែកម្ខាង បើគោសគេ មើលឃើញ ដោយភ្នែកទាំងពីរ ។

ព្រះចន្ទើតអួតការខ្មៅងងឹត ដូចគ្នាទាំងអស់ ជាខ្លះដើមក៏ដូចជាខ្លះឥឡូវ តឹស្បាងកំហុសខ្លួនឯងស្តាយដាក់ខាងក្រោយ! ស្បាងកំហុសអ្នកដទៃស្តាយដាក់ពីមុខ ។

១–សត្វទឹកមួយប្រភេទ ស្រដៀងត្រីឆ្លាក់ តែ ធំបណ្តាយប្រមាណ ២៥ ម៉ែត្រ ទម្ងន់មានដល់ ១៥០.០០០ គីឡូ និយមនៅសមុទ្រឥណ្ឌូនេស៊ី (ប៊ីលូ)

៣០ - ឆ្កែពីរនឹងខ្មោចសត្វលា

ឆ្កែតាក្រសឡែតមើលតាមច្រាយ ឃើញខ្មោចលាអណ្តែតទឹក ឱ្យលំ ចេះតែបក់ជាត់ខ្មោចលានោះបន្តិចម្តង ។ ឆ្ងាយចេញពីឆ្កែយើង ។

អាមួយគ្រាប់ថា «អាសំឡាញ់ ! ឆ្កែកងឯងដូចជាគ្រាន់បើជាងឆ្កែអញ ចូរឯងក្រឡែតមើលទៅកណ្តាលទឹកនោះ អញឃើញដូចជាមានអ្វី អណ្តែតទៅនោះ តើខ្មោចគោឬខ្មោចសេះ ? ។

អាមួយទៀត ឆ្លើយតបវិញថា សត្វអ្វីក៏ដោយ គង់ជាអាហារយើងទេ ការសំខាន់ ត្រង់ដែលឆ្លើយដូចម្តេចឱ្យបានមក ដ្បិតដូចជាវាសាត់ទៅឆ្ងាយណាស់ហើយ មួយទៀត ត្រូវហែលច្រាស់ទឹកផង ត្រូវយើងទំហែល ទោះចឹងក៏ទឹកខ្លះក៏ដោយ ទំនាំទាញឱ្យបានមក លុះខ្មោចនោះស្ងួត ស្រស់ទឹកវិលាណា មុខនឹងបានជាអាហារយើងមួយអាទិត្យ។

មើលចុះ ! ឆ្កែទាំងពីរទំហែល ទាំតាំទាំទាំងឈ្លក់ទឹក ខ្លួវខ្មោចលានោះ ក៏ទំប្រឹងតាលែតផុតដង្ហើម ហើយផុតជីវិតបណ្តោយ ។

គ្រប់មនុស្សតែងតែដូច្នេះ កាលបើតែណាមួយត្រូវចំណង់ហើយ ការតែបាក ការធ្វើមិនកើត បាត់អស់ហើយ ។ គេទំបន់ទេភ្លា មិនដឹងអស់ប៉ុន្មាន ធ្វើទៅ មានភ្នាត់ដៃភ្នាត់ជើង ក៏មិនដឹងអស់ប៉ុន្មាន ស៊ូតែទំប្រឹងតាលែតហួសកំម្លាំង ដើម្បីគ្រាថ្ងាសម្បត្តិ ជ័យដំនះ ទឹងក្តីឈ្នះ ។

ស្តេចចង់បានឆែនដី អ្នកតំណាញ់ តែងតែប្រមូលគ្រាក់ជាក់ហិប

អ្នកប្រាជ្ញ ប្រាថ្នាចង់ចេះវិជ្ជាគ្រប់យ៉ាង វត្ថុតាងអស់នេះ គឺជាទីតវែលធ្វើឲ្យឈ្លក់ ហើយគ្មានវត្ថុអ្វីដែលអាចធ្វើឲ្យមានការលួម ដល់មនុស្សបានឡើយ ។

៣១-សត្វទទាធឹងមាន់ឈ្មោល

សត្វទាមួយ គេចិញ្ចឹមនៅបណ្តាពួកមាន់ឈ្មោលតាំងពីក្មេយ ដែលគ្មានសេចក្តីគួរសម កាចអាក្រក់ ចូលចិត្តតែជល់គ្នា ។ ទាមានសង្ឃឹមថា ខ្លឹងបានជ្រកនៅស្រួលជាមួយនឹងមាន់អស់នោះ ដែលជាសត្វមានជាតិជាអ្នកចេះដឹង ងាយប្រាប់សំណាក់អាស្រ័យ ហើយដោយសារខ្លួនមានជាតិខ្ទុសគ្នាផង ។ ព្រោះមាន់ឈ្មោលជាលំអស្ងួស្តីនៃទីជ្រាចិញ្ចឹមសត្វបក្សី ។

ប៉ុន្តែ មាន់ឈ្មោលជាសត្វខឹងច្រើន មិនសូវគួរសមនឹងសត្វទាចេះតែចឹកទាស្ទើរនឹងស្លាប់ ។ ដំបូង ទាព្រួយចិត្តអំពីការកាចសាហាវអាក្រក់នោះ តែលុះឃើញពួកមាន់ពេញចិត្តតែខឹង ជល់តែគ្នាឯងឥតឈប់ គ្នាទៅវិញទៅមកនឹងគ្នាល ត្រង់ឆ្អឹងជំនីរ ចេញឈាមហូរច ទាត្រឡប់ជាជាប់ព្រួយ រាគិតថា: ធ្វើម្តេចទម្លាប់គ្នាតែដូច្នេះ កុំប្រកាន់ទោសថ្នី ត្រូវជួយអាណិតគ្នាទៅវិញ ព្រះជាម្ចាស់ មិនបានតាក់តែងតំនិតឲ្យដូចគ្នា គឺតំនិតមាន់ឈ្មោលដោយខ្លួន តំនិតទាដោយខ្លួន បើតាមខ្ញុំជាសត្វទាខ្ញុំបង់ចែកគ្នារកស៊ីជាសុខ ក្នុងសង្គមតែមួយ ។

៣២ – រឿងឯស្រែមោប (La cigale et la fourmi)

សត្វរៃ គាល់យកតែច្រៀងសប្បាយ អស់តេញមួយរដូវស្រូវ ស្រាប់តែអស់ស្បៀងអាហារលើង កាលណាឡើងរដូវលំហើយឆ្អែតមក គឺតែរុយឬជង្រុនមួយដុំតូចក៏គ្មាន ។ រៃទៅឯលំនៅស្រមោចអ្នកជិតខាងខ្លួន ប្រាប់ថាខ្លួនបិតនៅក្នុងទុរគតភ្លៀ ហើយសុំខ្ចីពីស្រមោច ខ្លះអាហារខ្លះ ដើម្បីតាំងជីវិតជន្មរហូតដល់រដូវថ្មី ។

រៃនិយាយប្រាប់ស្រមោចថា: ដោយយកសច្ចៈសត្វជាប្រមាណ ខ្ញុំសូមសងអ្នក មុនខែសីហា ពាំងការពាំងងើម ។

ស្រមោចជាអ្នកមិនមានចំលាប់ខាងឲ្យខ្ចី នេះហើយជាគុណវិបត្តិរបស់ស្រមោច ។ ស្រមោចសួរទៅរៃអ្នកខ្ចីថា: នៅពេលក្តៅ អ្នកអាល័យធ្វើអ្វី ? ។

រៃធ្វើយប្រាប់ថា ពាំងយប់ពាំងថ្ងៃ ត្រប់ពេលវេលា ខ្ញុំច្រៀង ចំរៀងនេះ ធ្វើឲ្យអ្នកសប្បាយកែកយដែរ!

ស្រមោចតបថា: ខ្ញុំ! អ្នកឯងច្រៀង ? ខ្ញុំគំសប្បាយណាស់ដែរ អំពីចំរៀងហ្នឹង ដូច្នេះ សូមអ្នកពាំងឥឡូវទៀតទៅ ។

(នៅមានត)

៨ – រឿងបែងចំណែក

8— Le partage

រឿងព្រេងតួកតុង

Conte de la nationalité Tong

តាំងពីបុរាណកាលមក នៅក្នុងភូមិមួយ មានបងប្អូន ២ នាក់ រស់នៅជាមួយគ្នា បងនាមថាឡាងធំ ប្អូននាមថាឡាងតូច ។ បីតាមាតា អនិច្ចកម្មទៅ ទុកកេរ្តិ៍មតិក ឲ្យកូនប្រុសទាំងពីរនាក់ នូវដីតូចមួយ នៅទំនេរមិនទាន់បានកាប់គាស់កន់នៅឡើយ គោរឈ្មោលមួយ និងឆ្កែសម្បុរលឿងមួយតែប៉ុណ្ណោះ ។

បងប្រុសឡាង ឡាងធំ ជាមនុស្សចិលខូច ខ្ជិលច្រអូស តែងតែបិតនៅឯគេហដ្ឋាន មិនដែលទៅចម្ការនោះទេ ។ ឯឡាងតូច ទៅគាស់កន់ចម្ការនោះរាល់ ៦ ថ្ងៃ ហើយមើលគោឲ្យស៊ីស្មៅផង ។

មានមួយថ្ងៃ ឡាងធំក៏ពោល ទៅកាន់ឡាងតូចជាប្អូនថា:

„ បើដើមឈើវាធំហើយ កមានមែកច្រើន បើកុងចម្រើនយ៉ាងណា ការធំឡើង ត្រូវតែរស់នៅផ្សេងគ្នា ដើម្បីទទឹងតាំងគ្រួសារជាថ្មី ។ ឥឡូវយើងតាំងពីរធំហើយ យើងត្រូវតែបិតនៅផ្សេងគ្នា „ ។

ឡាងតូចតបទៅ ឡាងធំជាបងថា:

„ ទេបង យើងរស់នៅជាំងពីរនាក់ នៅទីនេះ ជាសុខសប្បាយ យើងមិនត្រូវទៅឃ្លាតពីគ្នាទេ „ ។

ឡាងធំជាបងប្អូន ក៏តបមកប្អូនដោយទឹងថា :

« ត្រូវតែយើងរស់នៅឃ្លាតពីគ្នា ព្រោះអញ្ជាអ្នកធ្វើម្ហូបអាហារដាំ ជូនទៅផ្ទះ ដល់ម្ហូបក្តិន ឯងមកដល់ចាំតែស៊ី អញ្ជាមិនចង់ធ្វើដូច្នេះ តទៅទៀតទេ » ។

ឡាងតូចមិនចង់ឈ្លោះក្រែកទឹងបង ក៏បល់ព្រមចែកគ្នាំងពាន ពីគ្នា ។ ឡាងធំដណ្តើមយកគោ ទឹងទីដែលឲ្យផលល្អជាងគេ ហើយ ឲ្យឡាងតូចជាប្អូន នូវទីដែលឲ្យផលអាក្រក់ជាងគេទឹងខ្នែលឿន ។

លុះថែងចំណែកបួចហើយ ឡាងធំក៏នៅតែឯលប្រមូសជួចសព្វ ដង ។ ឯគោក៏មិនទាំងៅឲ្យស៊ីស្មៅ ទាល់តែគោខោះថមថយកំឡាំង ស្គាំងស្គមដើរស្ទើរមិនរួច ។

ឯចំណែកឡាងតូចជាប្អូន ទំថែទាំខ្នែលឿនខោះ មានសាច់ជាតំធំ ហើយមានកេមភ្ញី ឡាងតូចបានទាំខ្នែខោះ ទៅចម្ការ ហើយក៏តាំងបួកដី តាប់តាស់ប្តូតទៅតាប់ឈើឯក្តុ ។ ឡាងតូចទឹងខ្នែ ក៏រស់នៅដោយ សុខស្រួល ។

តេលខំតាយៈវដ្តវ ៖ ថ្ងៃមួយ ឡាងតូចព្រួយបារម្ភជាខ្លាំងទឹងទ្រាលត់ ទៅតាមុខដើងក្រាន ។ ខ្នែរបស់គាត់ ព្រុសខ្លាង ទាល់តែគាត់ភ្ញាក់ ។ ឡាងតូចក្រោកឡើងពីដំណេក ប្រញាប់ប្រញាល់កាន់ចបដំរះទឹងតណ្តៀ ហើយធ្វើដំណើរទៅកាន់ចម្ការគាត់ ដោយមានខ្នែរត់ពីក្រោយ ។

តែមែនតែកំដៅថ្ងៃមានចំហាយខ្លាំង គាត់ក៏នៅតែចូលដេកម្ភារ ដឹកគាស់គ្រប់ខែកន្លែង រួចខើបអង្គុយ ។ មួយស្របក់ ស្រាប់តែឆ្កែនោះព្រុសទៀត ។

ឡាងតូចសោលទៅគាន់ឆ្កែថា: « ឆ្កែលឿងខ្ញុំ ហេតុម្តេចក៏ឯងព្រុសដូច្នេះ ប្រមែលជាឯងដួយក្លែកស់ដីចម្ការបានឬ ? ។

ឆ្កែនោះរត់ចុះឡើង តាសតេញចម្ការ ទៅមកដូចជាវង្វេងអូសទន្លីលដូច្នោះ ។ ឡាងតូចសប្បាយចិត្តណាស់ ដោយឆ្កែនោះជួញចិត្តឈឺឆ្អាលគាត់ ។

ឡាងតូចកិរិយាធ្វើទន្លីលតូចមួយ ហើយពាល់ព្រឹក គាត់យកឆ្កែនោះទំមទន្លីល ។

ឡាងធំខឹងឆ្ងល់ ដោយក្រឡែកទៅឃើញចម្ការឡាងតូចក្លែកស់បានដូច្នេះ ហើយក៏សួរទៅឡាងតូចជាប្អូនថា:

« ឧឡាងតូចប្អូន តើអ្នកណាក្លែកស់ដីចម្ការឯង ?

ឡាងតូចតបទៅឡាងធំជាបងថា:

« ខ្ញុំនេះឯង ជាអ្នកក្លែកស់ដីចម្ការ » ។

ឡាងធំសួរថា: « តើឯងបានគោតីណាទំមទន្លីលឯង ? » ។

ឡាងតូចតបទៅបងថា:

« ខ្ញុំទំមឆ្កែខ្ញុំ ! » ។

ឡាងធំរមើលកែកធំខឹងឆ្ងល់ក្នុងចិត្តថា: « ម្តេចក៏យកឆ្កែទៅទំម

ខន្ធ័លជាន ថ្លែកអស្ចារ្យ ! » ។

ឡាងធំខ្ចីថ្លែឡាងតូច យកទៅក្សត្រចម្ការខ្លួន ។ ថ្លែនោះគាញ ខន្ធ័លជន្ទិចទៅ តំឈប់សៀមលែងដើរតទៅទៀត ។ ឡាងធំមានចិត្ត ទោមនស្សជាខ្លាំង ដេរផង ភយថ្លែនឹងរំពាត់ផង ទាល់តែថ្លែនោះក្ស័យ ជីវិតទៅ ។

ដល់ពេលយប់ ឡាងតូចមិនឃើញថ្លែនោះវិលត្រឡប់ទៅគេហដ្ឋាន វិញ ទើបតត់ទៅកាន់ផ្ទះឡាងធំ ជាបង រួចសួរថា:

« បងឯងឃើញថ្លែខ្ញុំទេ ? » ។

ឡាងធំតបទៅឡាងតូចវិញថា « អ្នកណាដឹងថាថ្លែឯងវាទៅងាប់នៅ ទីណា ! » ។

ដោយឃើញមុខបងខ្លួនក្រហមខឹងខ្លាំង ឡាងតូចគេចពីទីនោះ ទៅ ។ គាត់ទំព្យាយាមស្វែងរកទាល់តែឃើញសាកសពថ្លែនោះនៅ ទាន់ចង ។ ឡាងតូច យំខ្សឹកខ្សួលអួលអាល័ ចំពោះសពថ្លែ ហើយកំប័ សពថ្លែយំបណ្តើរ ដើរបណ្តើរ ហើយរោលថា:

« នៅពេលបែកក្តីម្តាយតគ្រាស្ម័យ
ខ្ញុំអត់ឮបានតែរូបថ្លែមួយ
ថ្លែដួយក្លួរកេរស់ឥតមានព្រួយ
ស្រឡាញ់ស្ងួយដូចបុត្រពីមំសា ។

អ្នកណាអើយហ៊ានសម្លាប់ឆ្កែ
ព្រួយប្រាណឥតស្លែយូរមាសា
សុនខមានគុណដ៏ថ្លៃថ្លា
ខ្ញុំតប់ស្មារតង់ទង្វាន ។

ឮដូច្នោះហើយ ក៏ប៉ឺឆ្កែនោះ យកទៅកប់ក្នុងសួនបា្ល ផ្លុះខ្លួន ហើយយកដៃប្រម៉ូលដីដាក់ពួកដូចចេតិយ រួចកាល់ពីរកត្រី តែងយកធូបខៀន ទៅអុជនៅទីនោះឆ្លើសការបូជា ។

ព្រឹកមួយ ឮដូចបានឃើញផ្នូរឆ្កែនោះប្រែ ស្រាប់តែមានដើមឫស្សីមានពណ៌លឿង ជុះចេញពីទីប្រែនោះ ។ ពេលសាយណ្ហសម័យដើមឫស្សីនោះ ស្រាប់មានដើមធំត្រសុំសាខា ។ ឮដូចមានចិត្តសោមនស្សត្រេកត្រអាក ឃាតមកតាបមែកឫស្សីអង្រួន ហើយច្រៀងថា :

ឫស្សី គុណឥតបី ធ្មឹមមិនឃាន
សុនខា តែកែលា្អណា តេនា
ព្រឹកឱ្យមាស ល្ងាចឱ្យប្រាក់ ណាថ្លៃថ្លា
រំសេវពិត គួរគោរព តែពត្រី ។
ឫស្សី ទេវ អង្រួនមក ផ្លុះមាសប្រាក់
សោភណា ចិត្តស្មោះស្ម័គ្រ ល្អដែនដី
ព្រឹកឲ្យប្រាក់មាស ល្ងាចឲ្យប្រាក់ប្រាក់ តបស្នេហ៍

ចេញក្រៅ ជាសេដ្ឋី តាមឋានា ។

ឡាឆ័តូច ក្រោយដែលព្រឿង មិនខាន់ចប់ ស្រាប់តែឿងមាស ភ្លឿងច្រាក់ ជ្រុះពីលើមែកឫស្សីឮសូរបណ្តើរ ។ ឡាឆ័តូចយក ក្រមាមកដាក់មាសច្រាក់រៀបចៀសគេចាស់ខ្លួន ។ ហេតុដូច្នេះ កាលណា ឡាឆ័តូចទៅទស្សនាចូបដ្ឋាន ដែលកប់សុទ្ធតែនោះ គាត់ក៏អង្រួនមែកឫស្សី ហើយព្រឿងបន្ដួចខាងលើ ។ ដល់គាត់ព្រឿងរួច ស្រាប់តែឿងភ្លឿង មាសភ្លឿងច្រាក់ ជ្រុះពីលើមែកឫស្សីនោះជានិរន្តរ៍ ។

កាលឡាឆ័ធំ បានឃើញដោយម៉ឺងចក្ខុ ថាប្អូនខ្លួនមានកោតទ្រព្យ ច្រើនជាអនេកប្បកា ក៏សួរប្អូនថា :

– ឡាឆ័តូចប្អូន តើឯងលួចច្រាក់មាសតាំណា

– ឡាឆ័តូច តបទៅឡាឆ័ធំជាបងថា : « ខ្ញុំឥតបានលួចប្អូនអ្នក ណាទេ ។ មាសច្រាក់តាំងនេះ គឺជ្រុះពីមែកឫស្សីដែលទៅកន់ សួនច្បារខ្ញុំ » ។

ឡាឆ័ធំឆ្ងើយ ទៅឡាឆ័តូច ជាប្អូនថា :

ដូច្នេះមែនឬអ្ន ? តើមាសច្រាក់នោះមានទៅឡើយឬ ? » ។

ឡាឆ័តូចតបទៅបងថា : បង ! ទៅមានទៀត ! គ្រាន់តែអង្រួនមែក ឫស្សី មាសច្រាក់នោះជ្រុះមកទៀត ! » ។

ឡាងធំសួរ ឡាងតូចជាប្អូនថា: "តើអូនឯងធ្វើម្តេច ទើបបាន មាសច្រើនោះ?" ។

ឡាងតូចបានឥឡូវ បំភ្លឺឡាងធំជាបង អំពីបទដែលខ្លួនប្រឹងនឹងអង្រួនមែកឫស្សី ។ ឡាងធំក៏ធ្វើតាមឡាងតូច ដែលពណ៌នាឲ្យធ្វើហើយបានទៅយកកញ្ជើពីរជង មកដាក់ក្រោមដើមឫស្សី រួចក៏ធ្វើតាមឡាងតូច ។ ស្រាប់តែជ្រុះសុទ្ធតែដង្កូវជាច្រើនមកលើខ្លួន ។ ដង្កូវនោះ ភ្ជាក់មកលើសក់ មុខ ដៃឡាងធំ ។ ដង្កូវទាំងនោះ កំចូលទៅកន្ទេញអាវឡាងធំ ទាំងគាត់ទៅកើតជាប្អូនបាម កមរមាស់ សាច់រលាកដូចភ្លើង ។

ឡាងធំមានចិត្តខឹងឡើងភ្លាំង ក៏ស្ទុះទៅយកពូថៅ មកកាប់ដើមឫស្សីរលំទៅ ។

ឡាងតូច ដល់វិលត្រឡប់មកសួនឫសខ្លួន ឃើញដើមឫស្សីរលំ ក៏លីដើមឫស្សីនោះយកមកដាក់មុខផ្ទះ ។ តាមផ្លូវឡាងតូច ច្រៀងជាបទថាដូច្នេះ: ។

"កាលចែកគ្នាមកបានតែម្នាក់ឯង
សុខចិត្តដួយភាញនឹស
ក្លួរកស់ចង្កាអស់រួចកល់
អ្នកវាយតែគាល់តែមរណា ។
តើអ្នកណាសម្លាប់សុខ

ធ្វើឲ្យឡាឯតក់កមណា

ព្រួយប្រាណមិនត្បាន្តកើតទុក្ខា

ខ្ញុំយតសុនខាកប់ក្នុងសួន ។

លើថូបង្គានដុះប្លុស្សី

បានតបស្នងស្នើរចនាខ្ញុន

ឲ្យមានមាសប្រាក់ប្រើនឧឡើងផ្ទួន

សេដ្ឋីមាំមួនឧឡើងកេរ្តិ៍ ។

តើអ្នកណាកាប់ប្លុស្សីខ្ញុំ

ធ្វើឲ្យចិត្តក្រមរំជើនតឹតបី

ឡាឯតូចព្រួយប្រាណមិនចេញស្តី

ចូលប្រាប់រឹងខ្ញុំសោះសង្ស័យ ។

ឡាឯតូច ក្រោយដែលរៀបរឿងចំខ្មុកនេះរួចហើយ កំយកឫស្សីនោះមកតុសជាបន្ទះតូច ។ ហើយធ្វើជាទ្រុងមាន់ ។ ឡាឯតូចយកទ្រុងមាន់នោះដាក់លើដំបូលផ្ទះសិន ចាំនឹងយកទៅលក់ឯផ្សារ ។ មាន់ភ្ញី-អ្នកដឹតខាងនឹងមាន់ទៅ ហើរមកតឯកទ្រុងនេះ ។

ឡាឯតូច បានយកតឯនោះដាក់ក្នុងកន្ត្រកភ្លើរធំពីរ ហើយរែកទៅលក់ឯផ្សារ ។

ឡាឯធំជាបង កាលបានដឹងខ្លួរតែមាននោះ ក៏តេះទៅកាន់ គេមាដ្ឋាន

ឡាន់តូចជាប្អូនហើយសួរថា :

ឡាន់តូច ! តើឯងលួចពងមាន់ពីណា យកទៅលក់ឯផ្សារ ? » ឡាន់តូចតបទៅបងវិញថា : « ខ្ញុំមិនបានលួចអ្នកណាទេ គឺមាន់ញីនឹងមាន់ទោញី ពួកគេងក្នុងទ្រុងខ្ញុំ ដែលដាក់លើដំបូលផ្ទះ » ។

ឡាន់ធំឆ្លើយទៅឡាន់តូចថា : « ឡាន់តូច ! ចូរអូនឲ្យទ្រុងនេះមកបងខ្ចីមួយរៃសិន » ។

ឡាន់តូច តបទៅបងវិញថា : « ចាន ! បងឯងយកទៅចុះ » ។

ឡាន់ធំ យកទ្រុងនោះទៅដាក់លើដំបូលផ្ទះខ្លួន ។ ក្នុងមួយរំពេចមាន់ញី មាន់ទោញីហើរមកដល់ ហើរទៅហើរមក យំអឺងកង ។

ឡាន់ធំ ស្ទុះទៅមើលទ្រុង មិនឃើញមាន់ពងសោះឡើយ ឃើញតែលាមកមាន់ញី នឹងមាន់ទោញី ។ ឡាន់ធំ ខឹងណាស់ ក៏យកដើងដាន់ទ្រុងនោះគៀចអស់ ហើយចោលទៅក្នុងភ្លើង ឆេះអស់ទៅតែផង ។

ឡាន់តូចព្រួយចិត្តឥតឧបមា ឃានតើបយកផងនោះដាក់ក្នុងតែមួយ ហើយក៏យកទៅទុកក្នុងផ្ទះ រួចយំខ្សឹកខ្សួលសំណោះសំណាលថា :

(នៅមានត)

សំបុត្រទីបី

លោក ឈ ន - អៀម ប្រែព័ត៌សាអង់គ្លេស

កំណើតនៃផែនដី

កូនដឹងថាផែនដីរំលឹកព្រះអាទិត្យ ហើយព្រះចន្ទរំលឹកផែនដី ។ ប្រហែលជាតូនដឹងទៀតថា មានតារាដទៃទៀតជាច្រើន ដែលដូចជាផែនដីដែរ តែរំលឹកព្រះទិត្យ តារាទាំងអស់នោះ ពាក់ព័ន្ធផែនដីយើងផង មានឈ្មោះថាផ្កាយព្រះគ្រោះ (Planets) របស់ព្រះអាទិត្យ ។ ព្រះចន្ទហៅថា ផ្កាយរណបរបស់ផែនដី ពីព្រោះលោកជាប់ទាក់ទងទៅនឹងផែនដី ។ ផ្កាយព្រះគ្រោះឯទៀត ក៏មានផ្កាយរណបដែរ ។ ព្រះអាទិត្យ នឹងផ្កាយព្រះគ្រោះ ត្រូវទាំងផ្កាយរណបរួមផ្តុំជាគ្រួសារមួយយ៉ាងច្រើន ។ គ្រួសារនេះ ហៅថា សុរិយប្រព័ន្ធ (solar system) ។ ពាក្យ (solar) មានន័យថាជារបស់ព្រះអាទិត្យ ហើយព្រះអាទិត្យគុកជាចំណែងផ្កាយព្រះគ្រោះទាំងអស់ ក្រុមគ្រួសារទាំងមូលមានឈ្មោះថាសុរិយប្រពន្ធ ។

នៅវេលាយប់ កូនរមែងមើលឃើញផ្កាយតាប់តាន់នៅលើមេឃ ។ បណ្តាផ្កាយទាំងនោះ ផ្កាយខ្លះ ជាផ្កាយព្រះគ្រោះ ហើយផ្កាយព្រះគ្រោះនេះ ពុំមែនឈ្មោះថាផ្កាយទេ ។ កូនអាចពិនិត្យឃើញប្លែកគ្នារវាងផ្កាយព្រះ

គ្រោះទឹកឆ្ងាយបានទេ ? ឆ្ងាយព្រះគ្រោះតួច។ តេកណាស់ ដូចជាផែនដី យើង បើប្រៀបផ្ទឹមទៅនឹងឆ្ងាយតំបន់ឆ្ងាយ ពុំនៃឆ្ងាយព្រះគ្រោះតំនោះ មើលទៅឃើញហាក់ដូចជាជំ ខៅលើមេឃ ពីព្រោះលោកនៅជិតយើងណាស់ ។ តួយ៉ាងព្រះចន្ទ ផែលតាមពិត គឺជាភពមួយយ៉ាងតូចតែមើលទៅឃើញហាក់ដូចជាធំណាស់ ពីព្រោះលោកនៅជិតយើង ។ ឯមធ្យោបាយដ៏ពិតប្រាកដ សម្រាប់ពិនិត្យឲ្យឃើញប្លែក រវាងឆ្ងាយនឹងឆ្ងាយព្រះគ្រោះ គឺត្រូវមើលថាតើភាពធំនោះមានពន្លឺចាំងជះត្រូច ឬអត់ ។ ឆ្ងាយមានពន្លឺចាំងជះត្រូច។ ឆ្ងាយព្រះគ្រោះ ពុំមានពន្លឺចាំងជះត្រូច។ ល ។ នេះគឺដោយហេតុតែឆ្ងាយព្រះគ្រោះគ្រាន់តែមានពន្លឺភ្លឺប៉ុណ្ណោះ ពីព្រោះលោកបានខ្ចីពន្លឺភ្លឺអំពីព្រះអាទិត្យ។ គឺជាពន្លឺភ្លឺរបស់ព្រះអាទិត្យទៅលើឆ្ងាយព្រះគ្រោះ ឬលើព្រះចន្ទទេតើ ផែលយើងមើលឃើញ ។ ឆ្ងាយដ៏ពិតប្រាកដ គឺដូចជាព្រះអាទិត្យយើងឯចឹង ។ លោកមានពន្លឺភ្លឺចាំងចេញពីខ្លួនលោកតែម្តង ពីព្រោះលោកជាដុំភ្លើងក្តៅពេកណាស់ ហើយឥន្ទេសន្ធោសទ្បើជាទិច្ច ។ តាមពិត ព្រះអាទិត្យយើងហ្នឹងឯងគឺជាឆ្ងាយមួយ គ្រាន់តែលោក មើលទៅឃើញធំជាងឆ្ងាយនានាពីព្រោះលោកនៅជិតយើង ហើយមើលឃើញលោកហាក់ដូចជាដុំភ្លើងមួយយ៉ាងធំ ។

ដូច្នេះ ផែនដីរបស់យើង ជារបស់ត្រួសារនៃព្រះអាទិត្យ: សុរិយ

ប្រព័ន្ធ ។ យើងស្មានថាផែនដីធំណាស់ ហើយផែនដីនេះជាតិមែន បើយកទៅប្រៀបផ្ទឹមនឹងខ្លួនប្រាណដ៏តូចរបស់យើង ។ តើគេត្រូវចំណាយពេលប៉ុន្មានអាទិត្យ ទើបអាចដើរ ទៅជុំវិញផែនដី សូម្បីនៅក្នុងអ្នកដែលមានជំនឿនឹងឫទ្ធិតាំងលើសមនុស្សក៏ដោយ ។ តែទោះជាផែនដីហាក់ដូចជាធំណាស់ ចំពោះរូបយើងក៏ដោយ ក៏ផែនដីនេះ ហាក់ដូចជាធុលីមួយគ្រាប់ដែលអណ្តែត នៅក្នុងអាកាសដូច្នោះ ។ ព្រះអាទិត្យបែតនៅឆ្ងាយពីលានម៉ាល់ (mile) ឯណាយឯទៀត បែតនៅឆ្ងាយជាងនេះទៅទៀត ។

អ្នកតារាសាស្ត្រពាន់ឆ្នាំ តែពួកអ្នកសិក្សាអំពីផ្កាយ ប្រាប់យើងថា តារាពីរបីរយោលាសមកហើយ ផែនដីនឹងផ្កាយព្រះគ្រោះពាល់អស់តែជាបំណែករបស់ព្រះអាទិត្យ ។ តារានោះ ព្រះអាទិត្យ ដូចជាកន្ទេលឥឡូវនេះដែរ តែជាដុំនៃភ្លើងដែលឆេះសន្ធោសន្ធៅ ក្តៅយ៉ាងមហិមា ។ ស្រាប់តែមានហេតុអ្វីមួយ បណ្តាលឲ្យបំណែកតូច ។ របស់ព្រះអាទិត្យរបើកចេញ ហើយពាក់ព័ន្ធនោះបានខ្ចាត់ចេញ ទៅក្នុងអាកាស ។ ប៉ុន្តែ ដុំពាក់ព័ន្ធនោះពុំអាចផ្តាច់ចេញឲ្យផុតអំពីបីតា តែព្រះអាទិត្យបានពាក់ព័ន្ធស្រុងទេ ។ តែហាក់ប៉ាដូចជាមានម្សៃមួយចង្កៀតបំណែកតូច ។ ពាក់ព័ន្ធនោះឲ្យទៅវិលជុំវិញព្រះអាទិត្យ ។ កំឡាំងដ៏អស្ចារ្យនេះ ដែលនឹងកបានប្រៀប

(១) មួយម៉ាល់ = ១.៦០៩,៤៣៤ម

ទៅទីឆ្ងាយ តើជាអានុភាពអ្វីមួយដែលតែងទាញវត្ថុគួចតាចចាំងឡាយក្លាប់ទៅទីដ៏វត្ថុធំនេះ តើជាកំលាំងដែលធ្វើឲ្យវត្ថុចាំងឡាយ តែងធ្លាក់ចុះដោយខ្លួនឯងវិញ ។ ផែនដីគឺជាវត្ថុមួយធំបំផុតនៅជិតយើង តែងទាញភ្ជាប់នូវវត្ថុសព្វយ៉ាងដែលយើងមាន ។

តាមតន្ត្រីនេះ ផែនដីយើងក៏បានឆ្លាតចេញពីព្រះអាទិត្យមកដែរ ។ កាលនោះ ផែនដីនេះក្តៅពេកណាស់ ត្រមាំងមាមៗស្ទឹមនឹងអាកាសយ៉ាងក្តៅក្រៃលែង ស្រោចជុំវិញផង ប៉ុន្តែដោយសារផែនដីមានទំហំតូចជាងព្រះអាទិត្យយ៉ាងច្រើន ក៏បានផ្តើមត្រជាក់បន្តិចម្តងៗ ។ ព្រះអាទិត្យក៏កំពុងតែអន់ក្តៅសន្សឹម ។ ដែរ ប៉ុន្តែដើម្បីឲ្យត្រជាក់ស្ងប់ទៅបានល្អត្រាតែអស់ពេលកប់លានឆ្នាំតទៅមុខទៀត ។ ផែនដីបានប្រើអស់ពេលតិចជាង ដើម្បីទៅជាត្រជាក់បាន ។ ទៅពេលដែលផែនដីកំពុងក្តៅ ពុំមានអ្វីអាចរស់នៅលើផែនដីនេះបានឡើយ : គ្មានមនុស្ស ឬរុក្ខជាតិឬដើមឈើ នៅលើផែនដីទេ ។ រីឯសព្វយ៉ាងត្រូវបានឆេះទៅជាឆេះនៅពេលនោះ ។

ចំណែកមួយរបស់ព្រះអាទិត្យ ខ្លាតចេញមកក្រៅ បានទៅជាផែនដីយ៉ាងនេះឯង ដូច្នេះ ចំណែកមួយរបស់ផែនដីខ្លាតចេញមកក្រៅ ក៏បានទៅជាព្រះចន្ទដែរ ។ មានមនុស្សជាច្រើន ស្មានថា ព្រះចន្ទបានខ្លាតចេញពីក្រហូងដ៏ធំ ដែលឥឡូវនេះ គឺជាមហាសមុទ្រប៉ាស៊ីហ្វិក នៅចន្លោះទ្វីបអាមេរិក និងប្រទេសជប៉ុន ។

ផែនដីបានផ្តើមត្រជាក់ ដោយបែបនេះ ។ តែត្រូវអស់ពេលយ៉ាងយូរចំពោះហេតុនេះ ។ បន្តិចម្តង ។ ផ្ទៃផែនដី ក្លាយទៅជាត្រជាក់ ទោះជាតានភាពក្តី នៅតែឈាស់កំដៅ ។ សូម្បីសព្វថ្ងៃនេះកំដៅ បើកូនឯងចុះទៅក្នុងអណ្តូងវែង ផែនដីតែងតែក្តៅឡើង ។ ទៅពេលដែលកូនចុះជ្រៅទៅ ។ តាមស្មានទៅ បើកូនអាចចុះឲ្យជ្រៅទៅក្នុងដីមែនទែន ទៅ កូនមុខជាឃើញផែនដីនេះក្រហមឆ្អៅមិនខាន ។ ព្រះចន្ទក៏បានផ្តើមត្រជាក់ដែរ ហើយតាំព្រោះព្រះចន្ទតូចជាងផែនដីទៅទៀត ព្រះចន្ទក៏បានត្រជាក់ឆាប់ជាងផែនដី ។ ព្រះចន្ទ មើលទៅឃើញដូចជាត្រជាក់ស្តួចស្តើកយ៉ាងណាស់ មែនទេ? នេះគេហៅថា «ស៊ីតចន្ទ» (cold moon) ប្រហែលជាព្រះចន្ទនេះ តាសពេញទៅដោយដុំទឹកកក ទឹងទាំលទឹកកក។

កាលដែលផែនដីបានត្រជាក់ហើយ ចំហាយទឹកនៅក្នុងអាកាសទាំងអស់ បានផ្តុំទៅជាទឹក ហើយទំនងជាបានធ្លាក់ចុះមកជាទឹកភ្លៀង ។ ពេលនោះ មុខជាត្រូវបានភ្លៀងធ្លាក់យ៉ាងសម្បើម ។ ទឹកទាំងអស់នេះចំពេញក្រហូងធំ ។ ទាំងឡាយនៅក្នុងដី ហើយមហាសាគរទើងសមុទ្រទាំងឡាយក៏បានកកើតឡើងដោយប្រការដូច្នេះឯង ។

ទៅពេលដែលផែនដីបានត្រជាក់ឡើង ឯមហាសាគរ ក៏បានត្រជាក់ឡើងដែរ នេះអាចឲ្យវត្ថុមានជីវិតទាំងឡាយ រស់នៅលើផ្ទៃផែនដី នៅក្នុងសមុទ្របាន ។ យើងនឹងដាក់ជូនគ្នា អំពីការផ្តើមដាបឋមនៃជីវិត ក្នុងសំបុត្រក្រោយទៀត ។

(នៅមានតទៅសំបុត្រតី ៤)

សំបុត្រទីប្រាំ

តើតំណាយដែលមានជីវិតមុនគេ

យើងបានឃើញក្នុងសំបុត្រមុនៗថា ផែនដីត្រូវបានទៅជាកពីមួយក្តៅយ៉ាងខ្លាំង អស់កាលយ៉ាងយូរ មិនអាចដើម្បីឲ្យតើមានជីវិតណាមួយរស់នៅលើបាន ។ ចុះពេលណាទើបជីវិតបានចាប់ផ្តើមមានលើផែនដី ហើយតើអ្វីខ្លះជាតើមានជីវិតមុនគេ ? នេះគឺជាសំនួរមួយមានសារៈសំខាន់ក្រៃលែង តែប៉ុន្តែជាសំនួរមួយពិបាកនឹងឆ្លើយណាស់ដែរ ។ ដំបូង ចូរយើងពិចារណាថាតើជីវិតជាអ្វី ? ។ កូនប្រៃលជានិយាយថា មនុស្សតំណាងឲ្យគឺជាសត្វមានជីវិត ហើយសត្វតំណាងរស់តែមានជីវិតដែរ ។ ចុះដើមឈើ ចុលព្រឹក្ស ផ្កា ឧទ្ធិកូតតាមតំណាងឲ្យ ជាអ្វីដែរ ? ពិបាកណាស់ របស់តំណាងនេះតែមានជីវិតដែរ ។ ភក្តុះធំឡើង ស្រូបយកទឹក ផកដង្ហើមយកខ្យល់អាកាស ហើយផាត់ទៅវិញ ។ សេចក្តីផ្សេងគ្នាដ៏សំខាន់រវាងដើមឈើហើយនឹងសត្វ គឺថាដើមឈើតុំចេះតែរើកដើរទៅនេះទៅនោះ ។ បើប្រសិនជាកូនទៅទឹកឃើញរុក្ខជាតិខ្លះដែលទុតុកបានបង្ហាញនៅក្នុងឧទ្យានក្សត្រ (Kew gardens) នៅក្រុងឡុងដ្រ ។ រុក្ខជាតិតំណាង - គឺរុក្ខជាតិឈ្មោះអ័កឃីត និងកិតឈ័រ (orchids and pitcher plants) – តែងស៊ីរុយតែសត្វថ្លា ។ រួចមានសត្វខ្លះទៀត, ដូចជាសត្វតពុះទឹក (éponges), ដែលរស់នៅឯ

ចុតសមុទ្រ ហើយដែលតុំកំរើកដើរទៅណាបាន ។ ជួនកាលគិតឃើញមែនទែន ថាតើវត្តជាសត្វឬក៏ជារុក្ខជាតិ ។ កាលណាកូនរៀនរុក្ខសាស្ត្រ គឺវិជ្ជាដែលចាត់ចង់ទៅនឹងរុក្ខជាតិ ឬក៏រៀនសត្តសាស្ត្រគឺវិជ្ជាដែលចាត់ចង់ទៅនឹងសត្វ កូនទើបឃើញវត្តដ៏ចំឡែកពាន់នេះ ដែលតុំមែនជាសត្វ ឬជារុក្ខជាតិជាច់ខាតឡើយ ។

មនុស្សខ្លះនិយាយច្រាប់យើងថា សូម្បីតែឫស្សីក៏មានជីវិតមួយចំហៀងដែរ ហើយវាចេះ ឈឺចាប់ចំហៀងវាមែនៗ ប៉ុន្តែតាំងពីនឹងមើលឃើញណាស់ៗ ប្រហែលជាកូនទៅទឹកឃើញសុភាពបុរសម្នាក់ ដែលបានជួបយើងនៅក្រុងហ្សឺណែវ។ លោកឈ្មោះស៊ែរហ្សាហ្គាដិសបូស (Sir Jagadish Bose) តាមការពិសោធន៍លោកបានបង្ហាញថា រុក្ខជាតិមានជីវិតភាគច្រើនហើយលោកស្មានថា សូម្បីតែថ្មក៏មានជីវិតខ្លះដែរៗ

ដូច្នេះ កូនឃើញថា មិនស្រណុកនឹងនិយាយថាវត្តណាមានជីវិតហើយវត្តណាគ្មានទេ ។ ប៉ុន្តែ ពេលនេះ ចូរយើងទុកថ្នរដោយឡែកចុះ ហើយចូរពិចារណាតែពីរុក្ខជាតិ ហើយនឹងសត្វប៉ុណ្ណោះចុះ ។ សត្វ-ថ្ម យើងមានវត្តមានជីវិតមានចំនួនច្រើន ។ វត្តមានជីវិតពាន់នោះ មានគ្រប់បែប ។ មានមនុស្សប្រុស នឹងមនុស្សស្រី ហើយភាគខ្លះនៃមនុស្សពាន់នេះ ជាមនុស្សក្រនឹងណាស់ ហើយខ្លះទៀតជាមនុស្សល្ងីល្ងើ ។ រួចមានសត្វពាន់ឆ្ងាយ ហើយកន្លះចំណែកនៃសត្វពាន់នោះ


ទៀត កូនយើញសត្វទ្រុងទ្រាតវាន់ដែរ ដូចជាដំរីឬ ស្វា ឬកំស្រមោច; កូនយើញសត្វទ្រុងទៀត ដែលជាសត្វលង់ទៀៅទៅវិញ ។ ត្រីហើយ ខ្លះវាតែងទៀតជាច្រើន នៅក្នុងសមុទ្រ ឯតនៅខាងក្រោមជាងគេ គឺតង់-នៅក្នុងថ្មកំនៃដីវាតដែរ ។ ហើយនៅឯជាតនៃថ្មកំនេះទៀត កូន-រមែងយើញសត្វពពុះទឹក (éponges) ខ្លះត្រីមានរាងដូចឆ័ត្រ (សត្វ-សមុទ្រម្យ៉ាងគ្មានឆ្អឹងមានខ្លួនរាងដូចឆ័ត្រ មានព្រួយជាប់ចុះក្រោម) ហើយ វាតទាំងនោះ ពាក់កណ្តាលជាសត្វ ពាក់កណ្តាលជារុក្ខជាតិ ។

យើងត្រូវល្បងរកមើល តើសត្វដែលមានបែបផែង ។ គ្នានេះ ឬន កើតឡើងភ្លាមក្នុងពេលតែមួយ ឬក៏កើតឡើងមួយម្តង ។ តាមលំដាប់ ? តើយើងត្រូវរកឲ្យឃើញ ហេតុនេះ យ៉ាងដូចម្តេច? យើងគ្មានសៀវភៅ ដំទៀងពាត់នៃសម័យបូរាណនោះទេ ចុះសៀវភៅនៃធម្មជាតិ អាចជួយ យើងបានឬទេ? ជួយបាន ។ យើងឃើញមានឆ្អឹងសត្វនៅក្នុងថ្មរាស់ ។ ជាំនឿយ ។ ឆ្អឹងជាំនេះហៅថាជាសាណីភូត កាលណាយើង ឃើញជាសាណីភូត យើងអាចនិយាយបានថា កាលដែលថ្មរនោះបាន ចាប់កកើតឡើងជាយូរយារមកហើយ សត្វដែលយើងបានឃើញឆ្អឹងនោះ ក៏មុខជាបានរស់នៅក្នុងកាលនោះដែរ ។ កូនបានឃើញជាសាណីភូត ប៉ែបនេះជាច្រើន ជាំនតួបជាំនធំ នៅសារមន្ទីរគេនស៊ុនគុនខាងសួន (The South Kensington Museum) នាក្រុងឡុងដ្រ ។

គាលណាសត្វស្លាប់ផ្លែកខ្ទេ ។ ហើយទឹងសាច់របស់វា តែងរិនាស
ចុះបង់ទៅយ៉ាងឆាប់ ប៉ុន្តែឆ្អឹងវាវិញវែមងសល់នៅអស់គាលយ៉ាងយូរ ។
តែឆ្អឹងទាំងនេះហើយ ដែលយើងរកឃើញ ហើយដែលប្រាប់យើងនូវរឿង
អ្វីមួយរបស់សត្វទាំងនោះ កន្លងសម័យដ៏យូរលង់ហើយ ។ ប៉ុន្តែចបមាជា
សត្វតូចមានឆ្អឹងវិញ ដូចជាត្រីដែលមានកងដូចតំត្រៃនៅក្នុងសមុទ្រ (Jelly
- fish) ។ គេលក់ស្លាប់ទៅ ទឹងតូចមានអ្វីសល់នៅទាងក្រោយឡើយ ។
គាលបើយើងពិនិត្យ មើលឬទាំងឡាយដោយយកចិត្តទុកដាក់
ហើយយើងប្រមូលផ្តុំ សំណល់ឆ្អឹងចាស់ ។ ទាំងអស់ ដែលយើងរក
ឃើញ យើងអាចយល់បានថា សត្វមានប្រភេទផ្សេង ។ គ្នា បានរស់
នៅក្នុងសម័យផ្សេង ។ គ្នា ។ សត្វទាំងឡាយនោះមិនមែនបានមកដល់
ព្រមគ្នាទាំងអស់អំពីណាមួយទេ ។ ដូចមានសត្វយ៉ាងសាមញ្ញបំផុត
ដែលគ្រាន់តែមានសំបក គួយ៉ាងដូចលៀស ។ សំបក (លៀស ឬង..)
ល្អ ។ ដែលកូនលើសបានទៅមាត់សមុទ្រ គឺសុទ្ធតែជាសំបកឆ្អឹងទាំងអស់
របស់សត្វដែលបានស្លាប់ទៅ ។ ក្រោយមក យើងឃើញមានសត្វ
ដែលមានកងកាយសាំញ៉ាំ មានតស់ មានសត្វធំសំបែមជាងដំរី
ទៅទៀត មានបក្សី ទឹងមានសត្វដែលប្រហាក់ប្រហែលទឹងសត្វសត្វ
ថ្ងៃនេះដែរ ។ ក្រោយបន្តិស យើងរកឃើញសំណល់ឆ្អឹងមនុស្ស ។
ដូច្នេះ យើងឃើញថា ហាក់ដូចជាមានលំដាប់ថ្នាក់ណាមួយក្នុងការលេច

ខ្សែនៃសត្វទាំងឡាយ - ដំបូងបំផុត សត្វធម្មតា បន្ទាប់មក សត្វដែលមានបែបផែនខ្ពង់ខ្ពស់ ហើយដែលកាន់តែមានភាពកាយ សាំញ៉ាំខ្សែនៅរហូតមកដល់ សត្វដែលមានបែបផែនខ្ពង់ខ្ពស់ចំផុត គឺមនុស្ស ។ សត្វពពុះទឹកធម្មតា (the simple éponge) ខ្លឹមសៀសដែលបានរកចំរើន បានផ្ទាស់កេន ហើយបានធ្វើខ្លួនភាពឲ្យរឹងរឹតតែប្រសើរខ្សែនៅយ៉ាងដូចម្តេចខ្លះនោះ គឺជាការសិក្សាមួយដ៏មានសារៈចំផុត ហើយប្រហែលជាថ្ងៃណាមួយ ខ្ញុំពុកនឹងនិយាយប្រាប់កូនអំពីរឿងនេះ ។ ប៉ុន្តែក្នុងពេលឥឡូវនេះ យើងខាត់ខ្លះតែជាមួយនឹងសត្វទាំងឡាយដែលមានជីវិតមុនគេបំផុតនោះ ។

កាលដែលផែនដីបានស្ងួតក៏ដោយ សត្វដែលមានជីវិតមុនគេគឺជាតួកសារជាតិខ្ទះ ដែលដូចជាត្រីមានភាពដូចត្រី គ្មានសំបកឆ្អឹងទេ ហើយរស់នៅក្នុងសមុទ្រ ។ យើងពុំមានសំណល់ឆ្អឹង នៃសត្វពួកនេះទេ ពីព្រោះវាពុំមានឆ្អឹង ដូច្នេះយើងត្រូវស្មានទើបបាន ។ មានសត្វដូចជាត្រីមានភាពដូចត្រីច្រើនណាស់ នៅក្នុងសមុទ្រសត្វថ្ងៃនេះ ។ វាមានភាពមូល តែសណ្ឋានរបស់វាតែងតែងាស់ប្តូរជានិច្ច ពីព្រោះវាគ្មានឆ្អឹងឆ្អឹងសំបក ។ សណ្ឋានទ្រង់ទ្រាយមានខំនងដូចនេះ :



ជូរកូនកត់សំគាល់ស្នាមមូលត្រង់កណ្តាល ។ នេះគេហៅថា

នុយស្តិ (Noyau) គឺជាបេះដូងមួយបែប ។ សត្វពួកនោះ គោះជាដូចម្តេចក៏ដោយ តែងមានមេឡាថ្មមួយយ៉ាងខ្លាំងតាត់ សម្រាប់បែកខ្លួនវាទៅជាពីរផ្នែក ។ ពាក់ព័ន្ធនឹង ដ្ឋិតិវន្តស្តើង ។ ត្រង់កន្លែងមួយហើយបន្តធ្វើយ៉ាងនេះ រហូតទាល់តែដាច់ចេញជាពីរដែលមានសណ្ឋានដូចជាត្រីមានពងដូចធ្លុង ហើយវត្តពាំងវ៉ាន់នេះ មានទ្រង់ទ្រាយដូចជាវត្តដើមសុទ្ធសាធ ។ ការបែងភាគនេះ មានទំនងបៀបនេះ :



កូនទឹងយើញថា នុយស្តិ ប្តូរបែរដូង ក៏ត្រូវបានបែងភាគដែរ ហើយផ្នែកនីមួយ តែងបាននុយស្តិមួយដុំ ។ តាមគន្លងនេះ សត្វពួកនេះចេះតែបន្តបែងភាគ ហើយរកចំនួនច្រើនឡើង។ ។

វត្តមានទំនងបែបនេះ ត្រូវបានជាវត្តមានដ៏វិតមុនគេលើផែនដីយើងនេះ ។ តើជាបែបយ៉ាងធម្មតាមួយរបស់ដីវិត! ទោះពេលនោះពុំមានអ្វីគ្រាន់បើ ឬខ្ពង់ខ្ពស់ជាង នៅលើផែនដីទាំងមូលឡើយ ។ សត្វពិតប្រាកដពុំទាន់មានទេ ហើយមនុស្សក៏មិនទាន់មានរាប់លានឆ្នាំក្រោយមកទៀត ។

វត្តមានទ្រង់ទ្រាយដូចជាធ្លុងនេះ បានកើតមានឡើង ទើបកើតមានស្មៅសមុទ្រ ស្លែ ភ្លាម ជង្គង់ជាខាងក្រោយ ។ តមកទើបមានត្រី ។ យើងស្គាល់សត្វពួកនេះច្រើន ព្រោះវាមានផ្នែក

ឆ្អឹងរឹង ឬ កំមានសម្បក ហើយវាបានខុកឆ្អឹង ឬសម្បកទាំងនោះឲ្យយើង
ឃើញអស់កាលដ៏យូរជាខាងក្រោយមក ហើយយើងក៏បានសិក្សាខ្លួវ
ឆ្អឹងឬសម្បកទាំងនោះ ។ សម្បកបានសល់នៅក្នុងតក់លើខ្សាច់ខា
សមុទ្រ ។ វាត្រូវបានតក់សើមហើយនឹងខ្សាច់ក៏គ្របពីលើហើយបិត
នៅយ៉ាងជូចេះដោយស្រួល ។ តក់ក៏បានក្លាយទៅជារឹង ដោយសារ
ខមូន នឹងការសង្កត់នៃខ្សាច់នឹងតក់ដែលនៅពីលើ ។ តក់នោះបាន
ក្លាយទៅជារឹងខ្លាំងឡើង ពាល់តែក្លាយទៅជាថ្ម ។ តាមរំនឹងបែប
នេះ ថ្មទាំងឡាយក៏បានផ្ទុំកើតឡើង នៅបាតសមុទ្រ ។ ការរញ្ជួយ
ផែនដី ឬ ហេតុអ្វីមួយបានបណ្តាលឲ្យថ្មផ្ទុះឡើងពីផម្រៅសមុទ្រ ឲ្យក្លាយ
ទៅជាភូមិភាគស្ងួតទៅវិញ ។ តមក ថ្មស្ងួត ។ ត្រូវបានស្ងឹងទាំងឡាយ
ហូរនាំយកទៅ នឹងដោយទៅតាមទឹកភ្លៀង ហើយសម្បកដែលកប់នៅក្នុង
ថ្មអស់កាលយ៉ាងយូរហើយ ក៏បានបែកខេញមកក្រៅ ។ នេះហើយ
ហេតុដែលនាំឲ្យយើងជួបនឹងសម្បក ឬ ឆ្អាសាណីកូត (fossils) ទាំងនោះ
ហើយ ក្រោយពីបានសិក្សាវត្ថុទាំងនោះមក យើងក៏បានរកឃើញថាផែនដី
រមស់យើងជូចជាអ្វីក្នុងសម័យដ៏យូរលង់មុនមនុស្សកើតឡើងទៅទៀត ។

យើងនឹងពិចារណានៅក្នុងសំបុត្រក្រោយ ថាតើសត្វដ៏សាមញ្ញទាំង
ឡាយ បានចំរើនដុះដាលឡើង ហើយក្លាយទៅជាមានរូបកាងជូចសត្វ
ថ្ងៃនេះ យ៉ាងជូចម្តេចខ្លះ ។

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

ជ័យយាន

សហជីវិន កង - តែម

នៅឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល

រៀបរៀង

ជាឯកសារលេខ ១ ក្នុងការប្រឡងទំនៀមទម្លាប់ខ្មែរ នៅឆមាសទី ១ ឆ្នាំ ១៩៦៣

១- ជ័យយានខ្មែរបុរាណមានប្រើនប្រភេទជាអាទិ៍ ខ្ញុំសូមពណ៌នាអំពីសំពៅ ។

សំពៅ- សំពៅជាជ័យយានបុរាណ តាំងពីជំនាន់ដើម, តាមកន្លងគម្ពីរ ឬ សាស្ត្រាចារ្យ ហៅថា «កេត្រា» កេត្រាគឺសំពៅនោះឯង សម្រាប់ដឹកនាំទំនិញនឹងមនុស្ស ពីប្រទេសមួយទៅប្រទេសមួយតាមដើងសមុទ្រ ដូចជាកប៉ាល់សមុទ្រសព្វថ្ងៃនេះដែរ ប៉ុន្តែសំពៅពុំមានគ្រឿងម៉ាស៊ីនទេ, លឿនទៅបានអាស្រ័យដោយខ្យល់ត្រជាក់ត្រជុំវិល ។

សំពៅនោះ បើតាមស្តាប់តៗមកធំៗ ណាស់ ដូចកន្លងសាស្ត្រាបុកណាច្រើនថ្ងៃថា តាយឈ្មួញ ៥០០ ចុះសំពៅចេញទៅដួញជាដើម។ យើញថាសំពៅមានទំហំធំផុតមនុស្សនឹងទំនិញបានច្រើនណាស់ ។

សំពៅនេះ មានរូបពាង់ប្រហែលគ្នានឹងសត្វពុង បានជាបុកណាប្រដូចថា « ពុងលយសំពៅ » ពាក្យថាលយ បានសេចក្តីថាបណ្តែត គឺសត្វពុងបណ្តែតខ្លួនក្នុងទឹក ខ្លួនពុងនេះពុកជាសំពៅ ។

ក្នុងគំនូរបុកណាកំយើញថារូបសំពៅ ស្រដៀងនឹងរូបសត្វពុងនោះដែរ ប្លែកតែសត្វពុងគ្មានក្តោងដូចសំពៅប៉ុណ្ណោះ ។

ក្នុងប្រទេសខ្មែរយើងនេះ តាមពង្សាវតារខ្មែរកន្លងផុតកាលព្រះបាទសម្តេចព្រះហរិរក្សរាមា (ព្រះអង្គឌួង) ទ្រង់ឲ្យសាងសំពៅ ដើម្បីទាក់ទងសេដ្ឋកិច្ចជាតិនឹងបរទេស ប៉ុន្តែមកដល់សម័យបច្ចុប្បន្ននេះ សំពៅសាបសូន្យបាត់ទៅវិញ ដោយមានកប៉ាល់សមុទ្រជំនួស ។

សំពៅសព្វថ្ងៃនេះ មានតែកិត្តិស័ព្ទរបស់ខ្លួនរស់នៅដោយសារតំនូរ ដោយសារចម្រៀង ដោយសារតែបទភ្លេង ឯរូបសំពៅមែនទែននោះពុំមានសោះឡើយ ដោយស្ថានការណ៍ឥឡូវនេះ គេលែងប្រើអស់ទៅហើយ នៅសល់តែសំពៅដែលធ្វើដោយក្តាសប្លាស្ទិច ។ មានស្រុកបរទេសកាដើម សម្រាប់ផ្ទុកនំ-ចំណីជូនដួងតា ឬ បន្លោះផ្ទៃ ឬក៏ដាក់ប៉ាស្ទាប៉ុណ្ណោះ ។

(ប្លាប់ដើមមានតំនូរសំពៅ)

សំរៅ មានសណ្ឋានដាក់ក្បូកលើកក្តារ មានឃ្មុបពីលើតាំងពីក្បាលដល់កន្ទៃ្ន នៅលើឃ្មុបមានបង្អាន់ដៃពីរផ្នែក ផ្នែកខាងមុខ ១ផ្នែក, ផ្នែកខាងក្រោយ ១ផ្នែក ប្រដាប់ដោយក្តោងទឹងដងក្តោង ៣ តាមតែឯ្យល់មកតឹងណាអាចលឿនទៅមុខបានចាំងអស់ ក្នុងឃ្មុបគេសម្រាប់ផ្ទុកមនុស្សទឹងចំនួនញាវផ្សេង ។ កាលពីដើមពួកយួនធ្វើក្បូក ១ថែម សម្រាប់នាំចំគ្រឿងពីស្រុកយួនមកក្នុងប្រទេសខ្មែរយើង ក្បូកនេះមានឃ្មុបមានក្តោងដូចសំរៅ យួនហៅថា តែថ្មៅ ខ្មែរហៅថា កាប្លូ តែថ្មៅ គឺក្បូកសំរៅនេះហើយ ប៉ុន្តែភាសាយួនហៅថា តែថ្មៅ ដូច្នេះ គឺក្បូកនេះធ្វើក្លាយចេញពីសំរៅ ។ តែថ្មៅជាជលយានធុនតូចល្មមតែជាកំទេចញាបានចំនួន ១៥គោន ឯសំរៅសមុទ្រធំ ។ ណាស់ ដូចបានពណ៌នារួចហើយ ។ ជាដំនួយសំរៅ គឺសំប៉ាន តទៅនេះទៀតឯងពណ៌នាអំពីសំប៉ាន ។

សំប៉ាន- សំប៉ានដូចជាសំរៅដែរ, តែសំប៉ានតូចមានឃ្មុបដំបូលទឹងតឹងដូចជាសំរៅទេ សំប៉ានមានចំណុះជាក់មនុស្សបួនដប់នាក់(១) ព្រមទាំងចំនិញបន្តិចបន្តួច សម្រាប់ជាដំនួយសំរៅ ព្រោះថាកន្ទៃ្នដែលសំរៅចូលទៅតូចដូចជាទីទឹកកក់ ឬច្រកចង្អៀតនោះត្រូវមានសំប៉ានជាដំនួយ ហេតុនេះហើយបានជាបុកណាបានចងជាកាសិត ១ ទុកមកថា :

អ្នកមានតក្លាឡត់ ដូចសំពត់ព័ទ្ធពីក្រៅ

១- នេះគិតតាមចំនួនចំណុះសំប៉ានសមុទ្រ ។ ឯសំប៉ានទន្លេតិចជាងនេះ ។

អ្នកច្រាជូរក្បាខ្លៅ ដូចសំពៅនឹងសំប៉ាន ។

សំប៉ាន់គេច្រើជាជំនួយសំពៅ ដូចជាលុនបុត្រដែលគេនិយមប្រើសម្រាប់ជាជំនួយកប៉ាល់សម្រុកជូរចោះដែរ ។

(ក្បាច់ដើមមានតំណូរសំប៉ាន)

នៅពេលសត្វថ្លា គេឃើញសំប៉ាន់ខ្មែរមានកងកៅល្អកំយក តំរូសំប៉ាន់នេះ ធ្វើជាសំប៉ាន់ប្រណាំងជាមួយទូកងថ្មីមកពីតផង គេធ្វើសំប៉ាន់នោះឲ្យវែង ។ មានចំណុះតាំ ១៨ នាក់អង្គុយអុំឡើង ។ នៅពេលព្រះរាជពិធីអុំទូក(១) គេអាចសង្កេតឃើញមានទូកសំប៉ាន់ខ្លះ ស្រែកហៅថា «គាសំប៉ាន់ ។» ដូច្នេះផង ។

ហេតុនេះសំប៉ាន់ខ្មែរ នៅមានស្ថានភាពរស់នៅសត្វថ្លាក្នុងប្រទេសខ្មែរយើង ពុំមែនបាត់បង់រូបរោមដូចជាសំពៅទេ គឺនៅតែរីរាំតែសត្វថ្លានៅខាងស្រុកគៀនស្វាយខ្ញុំធ្លាប់ឃើញមានសំប៉ាន់នេះ ។ គេសម្រាប់អុំប្រណាំងលេង នៅពេលមានពិធីបុណ្យទាន ដូចជាបុណ្យកឋិន ឬបុណ្យលយប្រទីបនៅថ្ងៃចេញព្រះវស្សា តួយ៉ាងគឺវត្តគៀនស្វាយគ្រា ។

ទូកី- ទូកនោះបុកណាពីដើមសម្បូរឈើ គេយកឈើពាំងមូលមកធ្វើជាទូកតែម្តង គេសន្មតថាទូកមាន គឺថាគេយកឈើ ១ ដើមយ៉ាង

១- ព្រៃងក្នុងរដ្ឋកាលណា ។ មិនដឹង តែក្នុងរដ្ឋកាលនេះ ឆ្លងជាមិនដែលឃើញគេយកសំប៉ាន់មកអុំប្រណាំងនឹងទូកងក្នុងព្រះរាជពិធីអុំទូកទេ ។

ធំហើយយកដីឥដ្ឋមកចាំងជាកងសត្វក្រពើដែលជាសត្វទឹក ធ្វើជាក្បាលកន្ទៀនទឹកតួ រួចគេលុងត្រង់តួខ្លួកតែតាដើមគេនិយាយថាចរដោយដឹង សំអាតដោយពីង រួចគេជាក់ចន្ទុលវាយបើកតែម្តង ។ ខ្លួកក្បាយចេញមកពីសត្វក្រពើ និយាយនិទានបុរាណ « ពពែនឹងខ្លាយដុះក្រពើ » ។

(ប្លាប់ដើមមានគំនូរខ្លួកមានរូបនេះ)

ក្រោយមកគេធ្វើខ្លួនលើកភ្លើង គឺថាគេយកឈើមកចាំងធ្វើជាកុងកោង ។ បន្ទាប រួចខើរយកភ្លើងវាយភ្ជាប់នឹងឈើកុងខ្លឹងជាកងខ្លួក ហៅថាខ្លួកលើកភ្លើង ។

(ប្លាប់ដើមមានគំនូរបួបខ្លួកលើកភ្លើងនេះ)

ពាក្យថាខ្លួក ១ មាត់នេះ តាមដែលពិចារណាទៅឃើញថា តុំមែនមានតែដល់យានទេ ដូចជាមានខ្លួទៅដល់ដល់យាន (យានដើងគោន) ផងដែរ ដូចជារនេះគោ ។ រនេះគោមានឈើ ១ ផ្នែក គេសន្មតហៅថាខ្លួកដែរ ដូចជាឈើ ១ គួដែលទៅសណ្តាក់ក្រោមខ្នងរនេះនោះហៅថាខ្លួករនេះ ។

តាមយោបល់ខ្ញុំថា : ខ្លួកមកពីពាក្យថាខុក ឬ ផ្លុក ក្លាយមកជាពាក្យថាខ្លួកដូច្នេះ ។ តែក្នុងន័យនេះ ខ្ញុំនឹងសូមពណ៌នាចំពោះតែខ្លួកដែលជាដល់យាន « យានដើងទឹក » ខ្លួកនោះមានច្រើនប្រភេទតទៅទៀតគឺ: តែហៅ, ប៉ុកចាយ, ខ្លួកវ៉ែត, ខ្លួកឆ, ខ្លួកមួង, ខ្លួកកឹង,

ខ្លួកតំពេល, ខ្លួកដ, ខ្លួកក្តោង, ខ្លួកចែវ, ខ្លួកអុំ ។ តពីនេះ ខ្ញុំនឹងសរសេរតែរបៀបខ្លួកមួយ ។ តទៅទៀតតាមដែលចេះចាំ ។ មើលឃើញដោយកម្លាំងបញ្ញា ស្មារតីដ៏ស្ងួចស្តើង ។

ក្តែប្រៅ- តែហៅគឺជាផលយានមួយមានបណ្តាយប្រវែងជាង ១៥ម. មិនខុសគ្នាពីខ្លួកធម្មតាទេ ។ ខ្មែរយើងហៅឡាយ ។ មកថាគ្រហើយ ឬ គហៅ, គេសម្រាប់ប្រើជាយានដ៏ខ្ពង់ខ្ពស់អាចរស់យកវៃថ្វាយព្រះរាជា ។ បើជាដំនិះវិញ យ៉ាងតូចបំផុតមានត្រឹមចៅហ្វាយខេត្ត ។ ព្រោះតែហើយនេះក៏ស្តែប្រជាធម្មតាពុំមានឧរណាមានប្រើ មានចំពោះតែលោកអ្នកមានបណ្តាស័ក្តិ ឬ ព្រះរាជាតែម្តង បើតាមសម្ភោកចុះណាវិញឃើញថាមានសម្រាប់តែព្រះរាជាតែម្តង ។

ហេតុនេះបានជាចាស់ ។ បានជាពាក្យបណ្តាំឲ្យរកជួបមានតទៅនេះ:

ឯកអង្គទ្រង់នាមមហាក្សត្រ
មានទេពីថ្នាត់សេនាទាំ
អស្ត្រតបមុខខ្ញាំ
តហៅបតាំ
មានត្រីជាស្តេចខ័ពស្រួច ។

(ល្បែងចតុរង្គ ឬ ឈើក្រុង)

តែតាមយោបល់ខ្ញុំបាទ តែហៅ ខំនង់ជាភាសាយួន ព្រោះតែ ។ យួនហៅថាខ្លួក ហៅ ។ យួនថាគាល់កើ ខ្មែរយើងច្រើននិយាយថា :

យួនឡើងហៅ ។

ព្រះមហាក្សត្រខ្មែរយើងពីដើមមានព្រះឥន្ទ្រិយលក្ខ័ណ្ឌ ប្រទេសនានាជិតខាងគោរពខ្លាច តួកវៀតណាមឃ្មាងនាំសួយឡើងថ្វាយតាមទូកនោះ ចានជាយានមួយប្រភេទនោះហៅថាតែហៅ គឺថាទូកសម្រាប់ឡើងហៅ។

តែហៅជាទូកលើកក្តារឬទូកមាឌ មានដំបូលតាំងពីក្បាលដល់កន្ទុយ ប៉ុន្តែត្រង់អ្នកគាន់ចង្កូតនោះដំបូលខ្ពស់ជាងខាងមុខបន្តិច, នៅសង្កាត់កណ្តាលមានបន្ទប់ ១ សល់ពីនោះមានជាន់ថែមទៀត ១ ក្រោយ ១ នៅក្រោមដំបូលដូចជាព្រះទីនាំងតែហៅដែលមានន័យថា : ព្រះទីនាំងប្រចាំខ្លួន ចតនៅព្រះទីនាំងផែចតុមុខ ។

ប៉ុកចាយ- គឺជាទូកលើកក្តារមួយបែប ដែលក្តាយចេញមកពីសំពៅដែរ តែទូកនេះមានក្តោងតែមួយ មានដំបូលចាប់ពីដងក្តោងទៅកន្ទុយ មានថែវនឹងដើងថែវ ៥ ចាប់ពីដងក្តោងទៅមុខ ខាងកន្ទុយមានតែចង្កូតឥតមានថែវនឹងដើងថែវទេ គេសម្រាប់ដឹកនាំទំនិញស្រូវអង្ករពីខេត្តមួយទៅខេត្តមួយ មានចំណុះបើដាក់ស្រូវបានចំនួនពី ២០០ ហាំង ទៅ ៥០០ ហាំង ។ ចិន ។ ចូលចិត្តប្រើប៉ុកចាយសម្រាប់ដឹកនាំស្រូវ ។ បច្ចុប្បន្នសម័យខ្មែរយើងពួកអ្នកដំនួញស្រូវ- ខ្មែរយើងហៅថាដង្កៀស្រូវ គេក៏និយមប្រើទូកប៉ុកចាយនេះជាដលយានដឹកនាំ, ប៉ុកចាយនេះសព្វថ្ងៃនៅមានច្រើនណាស់ ដូចជាលោក តាន់ ចាំ ជាដើម កំពុងចូលចិត្តប្រើ

ប៉ុកចាយនេះ សម្រាប់ដឹកនាំស្រូវផាដើមតាមដើងទឹក ។

ទួកវ៉ែត- ទួកនេះមិនខុសគ្នាពីគែហើយប៉ុន្មានទេ ប្លែកតែទួកវ៉ែតនេះមានដំបូលខ្ពស់ត្រង់ចង្កឹតប៉ុណ្ណោះ គឺដំបូលតាំងពីក្បាលដល់កន្ទៃមានបន្ទប់កណ្តាល, មានចែវ ៦ មុខ ៦ ក្រោយ ដូចគែហើ, ទួកវ៉ែតសម្រាប់ដឹកនាំព្រះពជបរិតារព្រះពជា ឬ ព្រះពជវង្សាទុវង្សប៉ុណ្ណោះ ។

ទួកឯ- ទួកនេះសម្រាប់អ៊ុំប្រណាំងមានបណ្តោយវែង មានក្បាលទឹងកន្ទៃខ្ពស់ ។ មានចំណុះអ្នកអ៊ុំតាប់ពី ១៨ នាក់ឡើងទៅ ។

ទួកម្ជួឯ- ទួកនេះសម្រាប់ចែវប្រណាំងដូចជាទួកឯដែរ មានបណ្តោយវែង ។ ឯក្បាលទឹងកន្ទៃពុំសូវខ្ពស់ដូចជាទួកឯទេ, ព្រោះទួកម្ជួឯនេះត្រូវមានចង្កឹត, ចំណុះពួកអ្នកចែវ តាប់ពី ១៨ នាក់ឡើងទៅដូចគ្នា ។

ទួកកឹឯ- ទួកនេះក៏មិនខុសគ្នាពីទួកគែហើ ទួកវ៉ែតដែរ ប្លែកគ្នាតែទួកកឹឯនោះ, គេធ្វើដំបូលកឹឯទៅកណ្តាលទួកប៉ុណ្ណោះ ទួកកឹឯនេះកាលពីដើមគេច្រើនតែធ្វើសម្រាប់ព្រះសង្ឃផាចៅអធិការវត្ត គួយ៉ាងដូចជាព្រះឥន្ទាឯម្ភ ចតទៅព្រះឥន្ទាឯផែចតុម្ភ ។ ព្រះឥន្ទាឯម្ភនេះសម្រាប់តែជាក់ព្រះបដិមាករ នៅពេលដែលព្រះពជាស្តេចយាងតាមជលយាន ។

ក្នុងរជ្ជកាលព្រះចុលសម្តេចព្រះនរោត្តម ទ្រង់ពជ្យទៅក្រុងកំពេញនេះ, តែសម័យនោះសម្តេចព្រះវរជនឱព្រះអង្គទៅព្រះបរមពជកំឯចាស់

ឯកុត្តដ្ឋិមានដ័យ ។ នៅពេលនោះព្រះមហាក្សត្រខ្មែរស្តេចទៅថ្វាយបង្គំ
សម្តេចព្រះវរជនីនោះ បើស្តេចយាងតាមព្រះទីនាំងជលយានវិញ
មានរបៀបរៀបយ៉ាងដូច្នេះ ។

ទី ១ - យួន ១ ក្រុមដែលសន្មតថាយួនចំណាងព្រះហស្ត ក្រុមយួន
នេះចែវទូកយោងមុខ ១ ចម្ងាយពីព្រះទីនាំងប្រហែលតន្ទុះតែម្តងត្រែ ពួកយួន
នេះត្រូវស្រែកតាមព្រះពជបញ្ជាជានិច្ចថាហូខ្លាង ១(*) , តែយួននេះ
ស្រែកហៅខ្លាងដូច្នេះ ប្រជាពស្ត្រដឹងច្បាស់ថា យួនហៅខ្លាងមកដល់
ហើយ ព្រះករុណាស្តេចត្រង់យាងមកដល់តែម្តង កំប្រុងប្រៀបរៀបចំ
ខ្លួនចាំធ្វើតាវកិច្ចតាមប្រពៃណីខ្មែរ, ឃានចន្តិចព្រះទីនាំងកចាំលំ តាម
រាជបក្សីសណ្ឋាន ព្រះទីនាំងម្ខាងដែលតំកល់ព្រះឆត្តរូប ចន្តិព្រះទីនាំងប្រ-
ចាំខ្លួបដែលព្រះករុណាស្តេចគង់ ទើបចាប់បន្តទូកវែតតាមក្រោយទៀត ។
(វេជ្ជកាលនេះខ្ញុំឃានស្គាល់ត ។ ពីដើមជួនខ្ញុំធ្លាប់ខ្ញុំ ។

ទូកកំពោល - ទូកតំពេលខ្លះនិយាយថា ទូកចែវ ៤ ឬ ទូកចែវ ៣
គេហៅថាទូកតំពេល ហើយពេះមានដំបូលក្តី ឥតដំបូលក្តី ។

តែបើតាមយោបល់ខ្ញុំវិញថា ទូកតំពេលគឺគេធ្វើអំពីឈើទាំងមូលតែ
ម្តង ហើយតុំឃានជាស្អាតឃាតប៉ុន្មានទេ ដូចជាពាក្យបុរាណថា : គានេះ
និយាយមកទាំងកម្រោលតែម្តង ។ ពាក្យដែលថាតំពេល ១ ម៉ាត់នេះ

(*) - ហូខ្លាងជាភាសាយួនវិញ បើពោលឲ្យត្រូវតែអ្នកខ្លាង: ប្រែថាព្រះរាជាព្រះមហាក្សត្រ ។

ចានដល់សភាពមិនស្អាតមិនសមរម្យដូចជាខូកកំពេលដូច្នោះដែរ ។

ទ្ងូកជ្ង – ខូកនេះគេសម្រាប់ចម្ងងមនុស្ស ពីត្រើយម្ខាងទៅត្រើយម្ខាងទៀត គេហៅថាខូកជ ។ (១) ខូកជនេះមិនចំពោះទៅលើខូកបែបណានោះទេ ឲ្យតែខូកសម្រាប់ចម្ងងហៅថាខូកជទាំងអស់ ព្រោះពាក្យថាជមកពីពាក្យថាតរប្រែថាចម្ងង ប៉ុន្តែខូកជគេច្រើនប្រើខូកលើកក្តារ ធ្វើរបៀបដូចជាសំប៉ានក្បាយជាក់ចែវបី តែចែវត្រើយមួយ ចែវមុខ ២ ។

ទ្ងូកក្តោង – ខូកក្តោងខ្មែរយើងហៅចំពោះទៅលើខូកមួយប្រភេទដែលធ្វើជាខូកលើកក្តារកងដូចជាខូកសំប៉ានក្បាយដែរ តែមានដំបូលធ្វើអំពីឫស្សីច្រក់ស្លឹក មានចែវមុខ ២ ត្រើយ ១ មានជងក្តោងសម្រាប់ជាក់ក្តោង ហៅថា « ខូកក្តោង » ខ្លះគេធ្វើខូកនោះដូចកងខូកប៉ុកចាយ ហៅថាកូនប៉ុកចាយ ។

(ច្បាប់ដើមមានតំនូរខូកក្តោង)

ខូកក្តោងនេះ គេសម្រាប់ដឹកនាំនំនិញគួចតាចដូចជាចេក, អំពៅ ត្រាវ, ដំឡូង, ដូង, ស្វាយដើម ទៅលក់ដូរទៅមីជនបទផ្សេង ។ ក្នុងប្រទេសខ្មែរនេះ តាមដើងទឹក ដើងកំពង់ គេមានត្រួសារគេទៅជា

១– តាមពិត មិនគួរចាប់ចាលក្នុងប្រភេទខូក ដ្បិតតាមតែខូកផ្លិចផ្តើចក៏អាចយកធ្វើជាខូកជបាន ហើយពាក្យ (ជ) នេះទៀត ក្នុងវចនានុក្រមថាពាក្យឃ្លង មិនមែនភ្លាយមកពីពាក្យ (តរ) ប្រែថាឆ្លងឡើយ ។

ធម្មតាកន្ត ប៉ែប្រសិនជាពុំមានខ្សល់អាចត្រូវក្តោងទេ គេចំលាក់ក្តោងចេញ រួចគេដាក់ចែវឡើង គេចែវធ្វើដំណើរបានដោយសេរីឥតបារម្ភអ្វីឡើយ ។

ទូកចែវ- ទូកចែវនោះ សំដៅយកតែទូកចែវតូច ។ មានចំនួនចែវតែមួយ ចែវពីរឬចែវបី សម្រាប់ប្រើជាផលយោធជាតិ ។ នឹងប្រកបការចន្តិចចន្តួចមានធ្វើនេសាទជាដើម ។

ទូកអ៊ុំ- ទូកអ៊ុំនោះសំដៅយកតែទូកអ៊ុំតូច ។ ដែលមានចំណុះពី ១ នាក់ ទៅ ២ នាក់ សម្រាប់ប្រើជាផលយោធបណ្តោះអាសន្នកន្លះជាតិ ។ ។

ក្បួន- គ្រៅពីទូក មានតែក្បួនទេដែលអាចថាជាផលយោធបានដែលហៅថាក្បួនខោះ គេយកឈើស្រាល ។ អណ្តែតទឹកជាគាទឹតឬស្សីដើមចេក, ឫ, រកា ប៉ុន្តែគេនិយមប្រើដើមឫស្សី គេយកដើមឫស្សី ១ ដើម ។ ចងជាបាច់ឲ្យបានចំនួន ២ បាច់ ក្នុង ១ បាច់ប្រមាណឫស្សី ៤ ឬ ៥ ដើម, រួចគេយកបាច់ឫស្សីពាំងពីរចងភ្ជាប់គ្នា រួចគេដាក់ថែមក្តារ ១ សន្លឹក ឬ ២ សន្លឹកគ្រាលពីលើអង្គុយអ៊ុំដូចទូកបណ្តោះអាសន្នបាន ។ ក្បួននេះខ្ញុំពុំបានឧណាឱ្យអំពីក្បួនម្យ៉ាងដែលគេហៅថា ពោធាយ សម្រាប់បណ្តែតមនុស្សឆ្លងទៃ ត្រាលកាលណា ដូចជាគេពោលក្នុងសា-

ស្ត្រីភ្លុកណានោះទេ ពោលតែក្បូនដែលជាដុសយានសម្រាប់ដឹកជញ្ជូន-យោធន៍ប៉ុណ្ណោះ ។

ក្រៅអំពីក្បូននេះ ខ្មែរយើងធ្វើទូកដើមត្នោត ទូកដើមត្នោតនេះគឺគេយកដើមត្នោតដ៏ល្អមួយមកកាត់ប្រវែងចំនួន ៣ ម. គេយកត្រង់គល់ធ្វើក្បាល ចាំងសម្រួលដូចជាក្បាលកប៉ាល់ រួចលុងតួដើមត្នោតនោះឲ្យស្អាតខាងក្រោយគេស្ទះឈើ ១ បន្ទះជិត ទឹកពុំអាចជ្រាបចូលបាន គេប្រើបានដោយសេរី ដូចជាទូកគុំដែរ ។

(ឃ្លាប់ដើមមានគំនូរទូកដើមត្នោត)

ខ្មែរយើងមានមធ្យោបាយធ្វើដុសយានប្រើប្រើនប្រការយ៉ាងនេះ ។

(នៅមានត)

ប្រវត្តិនៃវត្តឧណ្ណាលោម

ក្រុងកំពង់ចាម

រៀបរៀងដោយសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក

ជួន - ណាត

ជោតញ្ញាណ

វត្តឧណ្ណាលោមក្នុងបច្ចុប្បន្នសម័យ

នៅថ្ងៃព្រហស្បតិ៍ ៤ កើតខែបុស្ស ឆ្នាំឆ្លូវសប្តស័ក ព.ស. ២៤០៩ ម.ស. ១៧៨៧ ច.ស.១២២៨ គ.ស.១៨៦៥ វេលាម៉ោង៨ព្រឹក ព្រះចានសម្តេចព្រះឧភោគ្គមៈ (បរមកាមខេវាតារ . .) ស្តេចយាងចេញចាកព្រះបរមរាជវាំង ស្រុសាវតើយុត្តក្រុង១ដុង្គមានជ័យ មកគង់ឯក្រុងកំពង់ចាម ចតុម្ភ១ខនរ (ជាគ្រាទី២ តពីគ្រាទី១ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះបរមរាជាតញ្ញាយ៉ាត)។ល។ សម្តេចព្រះមហាសង្ឃរាជ ព្រះនាមទៀង ទីធ ព្រះពាជាគណៈ ថានានុក្រមច្រើនរូប មានព្រះមហាវិមលធម្មនាម ភួយ ទីធ ព្រះពុទ្ធឃោសាចារ្យនាមច្រាក់ ជាដើម ក៏បានចេញចាកវត្តច្រាង្គក្រុង១ដុង្គមានជ័យ មកគង់នៅវត្តឧណ្ណាលោមនេះ ។

វត្តឧណ្ណាលោម មានបែរគធិការស្រាប់មក មានតាមថា លោកក្រុកង់ តមក មានសមណសក្តិពីពាជាគណៈ ជាព្រះឧម្មុំដ្ឋ

គេច្រើនហៅលោកថា លោកតាកង់ព្រះធម្មវង្ស លោកមាន
កុដិប្រក់ស្បូវ ១ ខ្នង ជាប់ចំទៅរបស់លោក ទៅត្រង់ទិសខាងជើង មហា
ចេតិយ ១ ណ្ណោះឡោម ។ លុះសម្តេចព្រះមហាសង្ឃរាជ មកគង់ទៅវត្តនេះ
លោកតាគង់ក៏សូមថ្វាយហាន:ចៅអធិការវត្ត ១ ណ្ណោះឡោម មកសម្តេច
ប៉ុន្តែសម្តេចមិនព្រមទទួល ។ លុះចំណេរកាលតមក លោកព្រះធម្មវង្ស
គង់ ទទួលអនិច្ចធម្មៗ ហាន:ចៅអធិការវត្ត ១ ណ្ណោះឡោមក៏រំលងដីមក
លើសម្តេចព្រះមហាសង្ឃរាជ ព្រោះសម្តេចជាប្រមុខនៃសង្ឃស្រាប់ ។

តំណាងចៅអធិការវត្ត ១ ណ្ណោះឡោម

ក្នុងបច្ចុប្បន្នសម័យ

ចាប់ដើមតាំងពី ព្រះជាទេសម្តេចព្រះនរោត្តម ស្តេចមកគង់ទៅក្រុង
ភ្នំពេញ រៀងរហូតមកដល់សម័យបច្ចុប្បន្ននេះ វត្ត ១ ណ្ណោះឡោមមាន ៧
អធិការ ៥ តំណាគឺ:

១- ព្រះធម្មវង្ស កង់

២- សម្តេចព្រះមហាសង្ឃរាជ ព្រះនាម ឆៀង (សុ
វណ្ណកេសរ:)

៣- សម្តេចព្រះធម្មលិខិតព្រះនាម អ៊ុក ជាព្រះសង្ឃនា-
យកគណ: មហានិកាយ ។

៤- ព្រះមហាវិមលធម្ម តែវ កង់ ជាមន្ត្រីសង្ឃពីរឿ



សម្តេចព្រះមហាសង្ឃរាជ ព្រះនាម ខៀង (សុវណ្ណកេសរ) សង្ឃនាយកគណៈមហានិកាយ
ជាអធិការវត្តឧណ្ណាលោម បន្ទាប់ពីព្រះធម្មវិស្សា ព្រះនាម គង់ ទ្រង់ប្រសូតថ្ងៃសៅរ៍ ខែកត្តិក
ឆ្នាំវក ឆស័ក ព.ស ២៣៦៦ ទ្រង់សោយព្រះទីវង្គតនៅថ្ងៃព្រហស្បតិ៍
ខែកើត ឆ្នាំឆ្លូវ បញ្ចស័ក ។

ហ្គួន ។

.៩-ព្រះពុទ្ធយោសាចារ្យ ជួនណាត (ដោតតាណោ) តមក មានសមណសក្តិជា ព្រះគោដិវង្ស ជាចាងហ្វាន សាលាចាលីជាន់ខ្ពស់ផង ជាអគ្គឥសីខែវថ្នាសាក តណៈមហានិកាយ ផង តមកទៀត មានសមណសក្តិជា ព្រះមហាសុមេធាចិបតី សង្ឃរាជាយក្ក តណៈមហានិកាយ (នៃប្រទេសកម្ពុជា) រដ្ឋ-តំបូលសហភាពភូមា ជានស៊ុតាំងជា អគ្គមហាបណ្ឌិត តមក ជានស៊ុតាំងឡេខ្លីនជាអគ្គឧដ្ឋមហារដ្ឋគុរុ ជាសមណស័ក្តិខ្ពស់បំផុតនៃ ពុទ្ធប្រទេសភូមា ។

បរិមាណនៃទឹកដីវត្តខ្ពុណ្ណាលោម

វត្តខ្ពុណ្ណាលោម មានផ្ទៃដីរាងជាចតុរង្គ តុំស្មើភាគខ្លះ ជួចខាងក្រោម នេះ:

១-ផ្នែកខាងត្បូង ពីទីជុតកំពែងខាងកើត ដល់ទីបំផុតខាង លិច ១៤៩ ម៉ែត្រ ។

២-ផ្នែកខាងលិច ពីទីបំផុតកំពែងខាងត្បូងដល់ទីបំផុតខាង កើត ១៦៨ម៉ែត្រ (រែងលើសាវផ្នែកទី ១-៣-៤ ចំនួន ៦០ម៉ែត្រ)

៣-ផ្នែកខាងជើង ពីទីបំផុតកំពែងខាងលិច ដល់ទីបំផុតខាង កើត ១៤៩ ម៉ែត្រ

៤-ផ្នែកខាងកើតពីទិសបំផុតកំពែងខាងជើង ដល់ទិសបំផុតខាងត្បូង ១៤៨ ម៉ែត្រ ។

កាលពីដើម ទីដីខាងមុខវត្តនេះ តាំងពីត្រពាំងវត្តរហូតដល់មាត់ទន្លេ (ស្មើគ្នានឹងត្រពាំងវត្ត) ជាដីឧរណីសង្ឃ គឺជាទីសម្រាប់វត្តទុណ្ណាលោម តាំងអស់ហៅថា លាកសីមា ប៉ុន្តែ ដីចំណីវត្ត ប៉ុន្តែឥតដែលបានផលប្រយោជន៍អ្វីបន្តិចបន្តួច ដល់វត្តទុណ្ណាលោមទេ ។ លុះចំណេរកាលតមក ទីដីខាងមុខវត្តនេះ ក៏ក្លាយជាដីរបស់ក្រុងកំពត ទៅវិញអស់ទៅ ។ លុះដល់មកសម័យប្រទេសកម្ពុជាឯករាជ្យអធិបតេយ្យ រាជការក្រុងកំពតបានបង្វែរទីដីមាត់ទន្លេខាងមុខវត្ត ប្រវែង ២០ ម៉ែត្រ ឲ្យជាកំពង់សម្រាប់វត្តទុណ្ណាលោម ។ល។

ការរៀបចំវត្តទុណ្ណាលោម

ដើម្បីកុំឲ្យប្រវត្តិនៃវត្តទុណ្ណាលោម មានសេចក្តីពិស្តារវែងពេក លំដាប់តទៅនេះ សូមតាណែនាំដោយសង្ខេប ព្រោះក្នុងសម័យបច្ចុប្បន្ននេះ អស់លោកអ្នកគាន់ប្រវត្តិនេះ សុទ្ធតែបានឃើញ បានជ្រាបអស់ហើយ ។ កាលដែលសម្តេចព្រះមហាសង្ឃរាជ ព្រះនាម ទៀង មកគង់ក្នុងវត្តទុណ្ណាលោម វត្តនេះមានទីដីក្រហោងក្រហូង ខ្ពស់ខ្លះ ទាបខ្លះ ពុំទាន់បានស្អាតល្អ សមរម្យនៅឡើយទេ លុះចំណេរកាលតមក វត្តទុណ្ណាលោមក៏មានសភាពចំរើនតាមលំដាប់កាល ដូចរៀបរាប់ដោយសង្ខេបតទៅនេះ ៖



សម្តេចព្រះធម្មលិខិត ព្រះនាម អ៊ុក សង្ឃនាយក គណៈមហានិកាយ បៅអធិការ
វត្តឧណ្ណាលោម បន្ទាប់ពីសម្តេចព្រះមហាសង្ឃរាជាព្រះនាម ទៀង

១- គ្រោយតាំតេលដែលព្រះគុណាជាម្ចាស់ដីវត្ត ព្រះជាទសម្តេចព្រះនរោត្តម ស្តេចទៅគង់ឯណឹង ព្រះបរមកដកំដរចតុម្មុខ តែព្រះបរមកដកំដរសព្វថ្ងៃនេះព្រះជាទសម្តេចព្រះនរោត្តមទ្រង់មានព្រះរាជបញ្ជាឲ្យពួកមេការុះរើព្រះដំណាក់នៅ ព្រះរាជកំដរតែក (ព្រះរាជកំដរសំចត) នៅខាងជើងវត្តទ្រណ្ណាលោម ឲ្យយកមកសង់ជាដំណាក់ផង មានជាន់ ២ ថ្វាយសម្តេចព្រះមហាសង្ឃរាជ តែកុដំមួយខ្នងនៅខាងសាលាធម្មវិហារ (កុដិដែលព្រះពុទ្ធឃោសាចារ្យ ខែន-ប៉ុល នៅគ្រប់គ្រងកាលសព្វថ្ងៃនេះ) ។ លុះតមក ព្រះពុទ្ធឃោសាចារ្យ ឆែន-ប៉ុល បានជួសជុលឡើងជាថ្មី ធ្វើឲ្យមានថ្លុកចូលតាមជើងវិញ ។

២- សម្តេចព្រះមហាសង្ឃរាជ នឹងពុទ្ធបរិស័ទ បានតសាងវិហារនឹងចេតិយ ៩ ដុំវិញ ភ្ជាប់នឹងមហាចេតិយទ្រណ្ណាលោម ព្រមទាំងបានឲ្យជាងធ្វើនក្រែត ជាក់លើកំពូលនៃមហាចេតិយផង ។ល។

៣- បានតំកល់ព្រះបរមសារីរិកធាតុ នៃព្រះសក្យមុនីសម្មាសម្ពុទ្ធបរមគ្រូ ដែលសមណៈខ្មែរឈ្មោះ រតនសារៈ ជាតំណាងនៃសម្តេចសង្ឃរាជព្រះនាម សិរីសុមង្គលៈ នៅវត្តវិទ្យាធរយបរាវណ ក្រុងតាសុម្បូរ ស្រុកលង្កាទួច នាំយកមកថ្វាយព្រះជាទសម្តេចព្រះនរោត្តម នឹងមានអគ្គរាជទូតនៅលើមាត់ភ្នំខាងកើតនៃមហាចេតិយទ្រណ្ណាលោម ជាកន្លែងស្រាប់ៗគ្នាផង នៃចេតិយទាំង ៩ ដុំវិញមហាចេតិយ ដែលតំកល់ព្រះបរមសារីរិក-

ជាតុនោះ សុទ្ធតែមានព្រះពុទ្ធរូបមួយអង្គ ។ រួមទាំងព្រះពុទ្ធរូបថ្ម ពីបុរាណ ដែលឋិតនៅក្នុងវត្តកណ្តាលផងជា ១ ព្រះអង្គ ។ ល ។

៤- ឯចេតិយចាំងឡាយ នៅទីជិតចន្លោះក្រោមជុំវិញមហាចេតិយនោះ សុទ្ធតែពុទ្ធបរិស័ទបានតសាងតំកល់ប្រដិស្ឋានអដ្ឋិធាតុ នៃអ្នកមានគុណរបស់ខ្លួន ដោយបានអនុញ្ញាតអំពីសម្តេចព្រះមហាសង្ឃរាជ ។ ល ។

-លុះចំណេរកាលតមក លោកអ្នកឧកញ៉ាអគ្គមហាសេនា (ប៉ុក) ជាប្រមុខនៃពុទ្ធបរិស័ទ បានសូមអនុញ្ញាតសម្តេចព្រះមហាសង្ឃរាជ ហើយបានជួសជុលវិហារជាថ្មី ដណ្តាំងឥដ្ឋចាស់ស្រាប់គ្រឿងឈើ ប្រក់ក្បឿងតណ្ឌ ប៉ុន្តែនៅតែវិហារ ខុតឲ្យនៅដូចដើម ។ ល ។

៦- គឺកាលនៃ ព្រះមហាវិមលធម្ម (តែក-កង់) ជាអធិការ សេនាសនៈផ្សេងៗ មានទុជង្ឃនសាលា ទីឆាសាលាចាស់រងដើម បានកើតមានខ្លឹងក្នុងវត្តទុណ្ណាលោម វត្តនេះមានការលូតលាស់ចំរើនរឿយៗ រៀងរាល់ឆ្នាំតាមលំដាប់កាល ។ សាលាធំ ១ ខ្នងនៅទិសខាងកើត ធ្វើឲ្យល្អសានវិហារ ដែលលោកអ្នកឧកញ៉ាអគ្គមហាសេនា (ប៉ុក) កាលនៅជាក្រែងឬហោម បានតសាង ទីឆាសាលាធំ ១ ខ្នងទៀត នៅជាប់ទីដំណាក់សម្តេចព្រះមហាសង្ឃរាជ ដែល លោកអ្នកឧកញ៉ាក្រែងឬហោម (សៅរ) បានតសាង ក៏បានត្រូវរុះរើយកគ្រឿងសម្ភារៈមកលៃផ្សំធ្វើជាសាលាចាស់រងទីឆាសនៈ ដទៃទៀត



ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ព្រះនាម កែវ-គង់ ជាអគ្គាធិការ វត្តឧណ្ណាលោម
បន្ទាប់ពី សម្តេចព្រះធម្មលិខិត ព្រះនាម អ៊ុក

ទៀត ឲ្យជាស្ថានតរៀនៈ៧ ។ល។

៧-ពុទ្ធបរិស័ទបានតំសាងកុដិ១ខ្នង ហៅថា មហាតរុដិ នៅខាងជើងវិហារ។ អ្នកឧកញ៉ាអតីតៈទៈ(តាន់មៀ) មានសទ្ធាជ្រះថ្លា ចំពោះការតសាង ឈាបនដ្ឋាន (ទីសំរាប់រំលាយសព) សំពះវត្តទុណ្ណាលោម ដោយចៅអធិការបច្ចុប្បន្នគឺ ស.ស.ជ.ណ.ដោតញ្ញា ឃ្មោ បានយល់ស្រេបផង បានសូមព្រះបរមកជាឧញ្ញាតព្រះករុណាជាម្ចាស់ដីវិត ហើយបានតសាងឈាបនដ្ឋានដ៏ប្លែក ដែលប្រទេសកម្ពុជា ពុំធ្លាប់ដែលមានឈាបនដ្ឋានបែបនេះ សោះនៅឡើយ ដោយពុទ្ធបរិស័ទភាគច្រើនបានជួយតសាងដែរ ជាបរិវេណ ទីធំត្រឿងបរិក្ខារផ្សេងៗ ផង ។ល។

៨-ដោយចៅអធិការបច្ចុប្បន្នគឺ ស.ស.ជ.ណ.ដោតញ្ញា ឃ្មោ ទីធំពុទ្ធបរិស័ទភាគច្រើន មានៈលោក ជាដុំធ ជាដើម យល់ឃើញថា វិហារវត្តទុណ្ណាលោមនេះ មានដំបូលទីធំតិចតួច តាន់តែទ្រុឌទ្រោមណាស់ទៅហើយ ទីធំដំអត់បណ្តោយខុកឲ្យនៅយូរទៅទៀត ពុំកើត ក៏ព្រមព្រៀងគ្នាបានសូមព្រះបរមកជាឧញ្ញាតព្រះករុណាជាម្ចាស់ដីវិត ហើយរុះរើវិហារចាស់ បានតសាងវិហារថ្មីសព្វថ្ងៃនេះឡើង ។ល។

បំផ្លូងភិក្ខុសាមណេរនិងយុវជន

តាំងពីកន្លងសម័យ នៃសម្តេចព្រះមហាសង្ឃរាជ ព្រះនាម ខៀង

រឿងដកឋមក ពស់ធំ វត្តទុណ្ណាលោម មានតិក្ខុសាមណេរជាង ៤ រយ ឬ ជួនកាលជាង៥រយរូប សុទ្ធសឹងតែមកពីខេត្តក្រៅ ស្ទើរពាំងអស់ច្រើនតែមករៀនបរិយត្តិធម៌ គោះបីមានការលំបាកដោយអាហារបិណ្ឌបាតយ៉ាងណា ក៏ចេះតែត្រាំនៅ ។ ចំណែកខាងកុមារនិងយុវជន (គ្រហស្ថ) ក៏មានចំនួនច្រើនណាស់ ស្ទើរតែស្មើភាគគ្នានឹងតិក្ខុសាមណេរដែរ ជួនកាលធ្ងន់ខ្លះ ច្រើនលើសជាងតិក្ខុសាមណេរទៅទៀតក៏មាន ។ តាមការណ៍ពិត កូនចៅអ្នកក្រីក្រពាំងភ្នាយនៅខេត្តក្រៅ ដែលឥតទីពំនាក់នៅក្នុងក្រុង គ្មានប្រាក់ជួលផ្ទះនៅ គ្មានអាហារបូកណ៌ ព្រះពជ្ឈាតិថាល ក៏និងពុំអាចជួយ ចំនុកចំរុងបានឡើយ ព្រោះមានចំនួនច្រើនគ្មាណាស់ពាប់រយពាន់ បានប្រាក់ថវិកាពីណានឹងលែលកជួយផ្គត់ផ្គង់កើត? ដោយហេតុនេះ បើកុំតែបានវត្ត អាចម ក្នុងក្រុង ជាទីជ្រកវៀនសូត្រនោះ កុមារនិងយុវជនអស់នោះ ពុំអាចនឹងញ៉ាំងខ្លួនឲ្យជាអ្នកមានចំណេះវិជ្ជាគួរដល់ការបានឡើយ កូនចៅអ្នកក្រីក្រ ក៏មុខជានឹងសុទ្ធតែជាពលរដ្ឋល្ងង់ខ្លៅតពូជតវង្សពុំខាន ។ តាមការណ៍ពិតមួយយ៉ាងទៀត វត្តទុណ្ណាលោមនេះក្តី វត្តពាំងភ្នាយឯទៀតក្នុងក្រុងភ្នំពេញនឹងក្នុងក្រុងឆ្ការគួច នៅក្នុងខេត្តក្រៅក្តី សុទ្ធតែជាទីហាន់សំពាប់ជួយសំកលសេចក្តីតានតឹងនឹងការដ៏ធ្ងន់ខ្លះ របស់ប្រទេសជាតិមាតុភូមិ ឬនឹងពាប់ថាវត្តអាចម ពាំងនេះជា កិលាសដ្ឋាន សំរាប់ជួយរម្ងាប់ជម្ងឺល្ងង់ខ្លៅ ស្រាវត់

ស្រុកខ័ណ្ឌប្រឡាំ ដែលជា បដិច្ចឆ្នាពាច «ជម្ងឺកន្ទាំង» នៃកុមារ ខិនយុវជនចាំនួនច្រើនជាងគេ ជាងកន្លែងទៅអ្នកកំសត់ទុគ៌តផងទៀត គឺសឹងតែមាន។ អាស្រយ័យហេតុទាំងនេះ បានជាអស់លោកគ្រប់កុដិ ពលវត្តកន្លងក្រុង ខោះជាចង្អៀតចង្អល់ខ្លាំងណាស់ ក៏ខោះតែអត់ទ្រាំខ្លួលចន្ទុកជួយសង្គ្រោះកុមារខិនយុវជនកំសត់ទុគ៌ត ជាប់ជាប្រពៃណី ដោះដៃពុំរួច បដិសេធចោលពុំកើត។ មានជនខ្លះយល់ថា ការនៅជ្រកអាស្រយ័យក្នុងវត្ត គេច្រើនតែមើលងាយថា កុមារខិនយុវជនអ្នកនៅជ្រកក្នុងវត្ត សុទ្ធតែមនុស្សសាបសោច។ល។ ការយល់យ៉ាងនេះ ពិតខ្លះមិនពិតខ្លះ តួរអស់លោកអ្នកមានវិចារណញ្ញាណរិះរេរមើល ដោយល្អិតល្អន់ហ្មត់ចត់ផងចុះ។

បរិភាពនៃវត្តទុណ្ណាលោម

វត្តទុណ្ណាលោម បើនិយាយតាមប្រវត្តិនៃមហាចេតិយកណ្ដាល ខាងលិចវិហារសព្វថ្ងៃនេះ ខិនតួរបូជាអគ្គិធំក្នុងរួនៃមហាចេតិយខោះ ពុំដឹងជាកើតមានតាំងពីកន្លងរជ្ជកាល នៃព្រះមហាក្សត្រអង្គណា តាំងពុទ្ធសតវត្សរ៍ប៉ុន្មានទេ ប៉ុន្តែ បើនិយាយតាមត្រឹមរជ្ជកាលនៃព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ដែលព្រះអង្គមានព្រះរាជបញ្ជាឲ្យកសាងវត្តនេះឡើងវិញទៀត ហើយទ្រង់ធ្វើបុណ្យបញ្ចុះសីមានៅថ្ងៃ១១កើត ខែពិសាខ ឆ្នាំចត្វាស័ក ព.ស. ១៨៨៦ គិតតាំងពីឆ្នាំខោះ មកដល់ឆ្នាំខាលចត្វាស័ក

ព.ស.២៥០៥ នេះ ឃើញថាមានចំរើនកាល៥១៨ឆ្នាំ ប្តូ៥២០ឆ្នាំហើយ ។

វិហារប្តីវត្តឧណ្ណាលោម

វិហារថ្មីវត្តឧណ្ណាលោម ចាប់ផ្តើមស្ថាបនាក្នុងឆ្នាំរកាសប្តីស័ក ព.ស. ២៥០០ គ.ស ១៩៥៧ បានស្ថាបនារហើយស្រេចក្នុងឆ្នាំជូតរំកាសស័ក ព.ស. ២៥០៣ គ.ស ១៩៦០ ដល់មកឆ្នាំថោះបញ្ចស័ក ព.ស ២៥០៦ គ.ស ១៩៦៣ ទើបបានធ្វើបុណ្យឆ្លងអស់រយៈពេល ៣ យប់៤ថ្ងៃ គឺនៅថ្ងៃទី១-២-៣-៤ មិថុនា ១៩៦៣ ។

កាលដែលព្រះបរិស័ទចាំងបព្វជិតចាំងគ្រហស្ថ មានក្តីខ្វល់ខ្វាយ (សម្តេចព្រះមហាសុមេធាធិបតី ជ-ណ ជោតញ្ញាណោ) ជាប្រមុខ បានប្រជុំប្រឹក្សាគ្នាទីនឹងស្ថាបនាវិហារថ្មីនេះ ក្រុមសទ្ធិជាតមានយោបល់ស្រេចគ្នាថា វត្តឧណ្ណាលោមនេះ មានទីដ៏ចង្អៀតណាស់ ទីនឹងលែលកស្ថាបនាសាលសំពាប់មហាសទ្ធិជាតចាំងព្រះពុទ្ធសាសនាមួយ ។ ដែលជាការចាំបាច់នោះពុំតើត ដោយហេតុនេះ ត្រូវតែសាងសង់វិហារក្នុងវត្តនេះឲ្យធំទូលាយជាងវិហារចាស់ ត្រូវធ្វើឲ្យមានភាជ្ជាក់ ដើម្បីឲ្យងាយប្រើប្រាស់តទៅ កាលបើបានស្ថាបនារួចស្រេចហើយ ត្រូវយកថ្មាក់ក្រោមជាសាលមហាសទ្ធិជាត ថ្មាក់កណ្តាលសំពាប់ប្រើការដូចវិហារវត្ត ចាំងពួងឯទៀត ថ្មាក់លើបំផុត សំពាប់តំកល់ព្រះពុទ្ធរូប អង្គធំធំងឺព្រះពុទ្ធរូបអង្គតូចចាំងពួង ។ល។

វិហារនេះ មានបរិណាយ ៦៨ម.៤០ ដោយមិនគិតជញ្ជាំងវិហារ ផ្ទះណ្តើរផងទេ មានទទឹង ៦១ម.៤០ កំពស់ពីផែនដីដល់កំពូល ៣៨ ម៉ែត្រ។ ដោយវិហារនេះ មានទ្វារតូចធំបណ្តាយតុំស្របគ្នា ជួចវិហារទាំងពួង ទើបធ្វើឲ្យមានមុខ ៤ មានកំពូលផង ។ល។

ក្នុងទ្វារខាងមុខវិហារ ទំហំ៥ម.៣៩ បន្ទោះទ្វារ ៣ម.៦៤ កំពស់ពីផែនដីដល់កំពូលខាងម៉ែត្រ ។

ការស្តាបនាវិហារមួយទាំងការជួសជុលព្រះពុទ្ធរូបអង្គធំ គឺការទំបាសព្រះពុទ្ធរូបត្រង់ព្រះអង្គផង មានតម្លៃ ៥.០៣៨.៨៨៦រៀល ដោយមិនគិតតម្លៃក្បឿងណាប្រក់ជំពូល នឹងឥដ្ឋតាំងដែលត្រង់ល្អងត្រឹមថ្នាក់កណ្តាលផងទេ ព្រោះសម្ភារៈទាំងពីរមុខនេះ ជាបេស់វិហារចាស់។ តម្លៃក្នុងទ្វារ ចំនួន១៦៩.៨៧៦ រៀល ។ តម្លៃការជួសជុលមហាចេតិយ ១ណ្តាសោម និងចេតិយបន្តាប់ទាំង៥ ព្រមទាំងការលាបថ្នាំចេតិយធំតូចទាំងអស់ នឹងការក្រាលឥដ្ឋនឹងស៊ុមទឹកត្រី លើទីលានវិហារចេតិយទាំងនោះផង អស់ចំនួន១០៣.៣៦៣រៀល ។ បូកបញ្ចូលតម្លៃនៃការស្តាបនាទាំងអស់ទាំងពីរនេះ មានចំនួនប្រាំលានបីសែនប្រាំពីរពាន់ប្រាំពីររយដប់ប្រាំបួនរៀល (៥៣០៧.៧១៩រៀល ០០) ។

ចេតិយទាំងពីរមើលឃើញខ្លឹម មានដៃជាច្រើនជាប់ស៊ក់ជាប់សង្ឃាស។ នឹងគៅ

អ៊ីឈើទ្វីមអតដៃទ្រនាប់ រួមគៅអ៊ីតាំងពីប្រភេទនេះ មានចំនួន៨៥០ ដែលពុទ្ធចរិស័ទតាំងបញ្ជាដតាំងត្រហស្ថ ជានកសាងជាក់ក្តងវិហារ ថ្មាក់ខាងក្រោម មានតម្លៃរួមតាំងអស់ ចំនួន១២១.៥០០រៀល យកមកបូក ផ្សំជាមួយផង (ព្រោះជារថស់កើតមានឡើងជាមួយខ្លួនឯងការស្ថាបនាវិហារ វែង) នេះឃើញច្រាំលានបួនសែនពីរម៉ឺនច្រាំបួនបានពីរយ ដប់ច្រាំបួន រៀល ៥.៤២៩.២១៩រុ០០ ។

ការស្ថាបនាសេនាសនៈនេះ ជាសមិទ្ធិខាងវិជ្ជកព្រះពុទ្ធសាសនាកើត មានឡើងក្នុងសម័យ នៃសង្គមកស្ត្រនិយម ដោយមាន សម្តេច ព្រះ ឧភេត្តម សីហនុឧបយុវាជ ព្រះប្រមុខរដ្ឋ ភក្តីជា ជាព្រះអក្តមក្តុន្ទេសក៍ អក្តពុទ្ធសាសន្ទូបត្ថម្ភក៍ ។ ក្នុង ការស្ថាបនាវិហារនេះ សម្តេចព្រះមហាកសត្រិយានី ជាព្រះមាតាជាតិ និង សម្តេចព្រះប្រមុខរដ្ឋ ព្រះអង្គបានបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ចំនួនមួយសែនច្រាំពីរម៉ឺនរៀល (១៧០.០០០រុ០០) ជាព្រះរាជកុសលដ៏ ខ្ពង់ខ្ពស់ ដួយខុបគ្គមជាមួយនឹងពុទ្ធបរិស័ទជាបុត្រ-ធីតា-នគ្គារថស់ព្រះអង្គ ។

ថ្ងៃ ៩-៧-៦ ឆ្នាំថោះសប្តស័ក ត្រូវនឹងថ្ងៃទី ១៦ ខុសភា ព.ស. ២៥០៦ គ.ស.១៩៦៣ ។



សម្តេចព្រះមហា សុមេធាធិបតី ជួន - ណាត (ដើតភ្នំពេញ) សង្ឃនាយកគណៈមហានិ-
កាយ (នៃប្រទេសកម្ពុជា) ជើអធិការៈ បច្ចុប្បន្នវត្តឧណ្ណាលោម បន្តាប់ពីព្រះមហាវិមល
ធម្ម ព្រះនាម វែរ - ជង់

អនុស្សរណោវាទ (ផ្សេងៗពីប្រវត្តិ)

ចំពោះយុវជនអ្នកនៅវត្ត

ហៃពួកយុវជនអ្នកកំសត់ ចើកុំបានវត្តជ្រកអាស្រ័យ
សមអ្នកនឹងឥតមានតម្លៃ យប់ថ្ងៃហួសទៅឥតប្រយោជន៍ ។
គួរអ្នកកុំក្បែរវត្តលំនៅ ពោះអ្នកចេញទៅឆ្ងាយស្រឡោះ
គួរដើនគុណវត្តកុំបង្អាប ប្រយោជន៍នឹងផលផ្តល់ពុំមាន ។
ចើមានគេសួរពីកាលរៀន ចំពោះរបៀនទាំងប៉ុន្មាន
អ្នកកុំនិយាយចង្អៀងជាន ត្រូវប្រាប់ថាបានចេះព្រោះវត្ត ។
កុំពោលបង្អួតពួកស្រី ។ ត្រូវស្តីតាមត្រង់កុំបំភ្លាត់
បំផ្លែងបំផ្លើសបំភ្លេចវត្ត ក្រែងពោសពាញពាត់ឲ្យវិនាស ។
ចាយវត្តជារោគនឹងមានព្រលឹង គួរនឹកចិត្តឹងកុំខ្ជិលឆាស
នាម៉ឺនមន្ត្រីមកពីក្រុង គឺកស្តេចឡើងទៅជាមន្ត្រី ។
ចាយផ្ទះចាយវត្តដូចជាគ្នា ចំអែតអាត្មាមានដើរ
ផ្អែតហើយរៀនសូត្រចេះខ្ពូចខ្ពី មុខើកើតមានដោយសារវត្ត ។
សាធុ ! សូមឲ្យអ្នកបានសុខ ខ្លាចក្នុងនរកយ៉ាងក្រៃ
ជាជនសប្បុរសរបស់វត្ត មានមែបមានបទច្រើរហោង ។

ភាវនាសុទ្ធិយា


ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣៥ លេខ ៩ ខែ កញ្ញា
ព. ស. ២៥០៥ គ. ស. ១៩៦៣

- ភ្នំពេញ -

ន.ស.វ.ប្ត ១៣. ១៤-២៣



ប្រាសាទអង្គរសៃ នៅភ្នំព្រះវាលប្រុស (ខេត្តឧត្តរមានជ័យ) ជណ្តើរឡើងពីខាងលើង ។



អង្គុលិសន្ទេស

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ចរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

	ទំព័រ
ផ្នែកសាសនា	
– អំពីពុទ្ធសាសនា ដែលត្រូវគេបង្ហាប់បង្រួម (វិចារណកថា) លោក ផេង-ត្រីវ តែងរៀបរៀង	៨៣០
– ពាលបណ្ឌិតសេរីនៃកថា លោក ហេង-សមអាន ធ្វើការនៅកងវិរៈសេនាតួចមហាធនខ្មែរប្រជើង លេខ ១០ ខេត្តព្រៃវែង តែងរៀបរៀង	៨៣៨
– អាថ៌កំបាំងរបស់ពុទ្ធសាសនា លោក ចូ-ច្វី រៀបរៀង (តបបំ)	៨៥៧
– ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ចូ-ច្វី ប្រែរៀបរៀង (ត) . . .	៨៦២
– មហោសថជាតក (ត)	៨៦១
ផ្នែកអក្សរសាស្ត្រ	
– អ្នកជាតិនិយម (វិចារណកថា) លោក ផេង-ត្រីវ តែងរៀបរៀង	៨៣៤
– ប្រវត្តិខេត្តកំពង់ចាម ស្រាវជ្រាវ ដោយ ន-ចាម	៨៤១
– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហាចាំង-ខាត់ រៀបរៀង (ត) . . .	៨៤៥
– រឿងសាមកុក លោកអ្នកឧកញ៉ាវិបុលរាជសេនា គួ-កន ប្រែរៀបរៀង (ត) . .	៨៤៧
– ល្បែកប្លាហ្វុងតែន លោកផេង-ត្រីវ ប្រែពីភាសាយ៉ាងកាំង (ត)	៨៥៥
– រឿងព្រេងភូកតុង (ការបែងចែក) លោក កាំយ-ប៊ុក ប្រែពីភាសាយ៉ាងកាំង (តបបំ) .	៨៦០
– សំបុត្រ ទី ៥ របស់លោកនេះ ផ្ញើទៅបុត្រីលោក នាមនាងលក្ស្មី (សៀវភៅនៃធម្មជាតិ) លោក ឈន-អៀម ប្រែពីភាសាអង់គ្លេស	៨៦៤
– ភ្នំព្រះពន្ធព្រឹទ្ធនឹងវិហារអង្គរសេ (ទំនៀមទម្លាប់ខ្មែរ)	៨៦៩
ផ្នែកកំណត់ទីន្លឹកប្រវត្តិការណ៍	
– ជាតុកម្មខាងព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា	៨៨១

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ
ឲ្យដុំសទាត់ចិត្ត កុំឲ្យហ្មងសៅ
ប៊ីខេះលោកហៅ ពុទ្ធសាសនា

ប.ព.

វិចារណាកថា

អំពីព្រះពុទ្ធសាសនា ដែលត្រូវគេបង្អាប់បង្អោន

លោក ខេង ជ្រឹវរៀបរៀង

ព្រះពុទ្ធសាសនា ជាសាសនាធំមួយក្នុងលោក ដែលខ្ចាននឹងប្រដៅសត្វឲ្យដឹកម្មនឹងផល ហើយនឹងឲ្យមានការស្នេហាគ្នាជានិច្ចកាល កុំថាឡើយចំពោះមនុស្សនឹងមនុស្ស សូម្បីចំពោះមនុស្សនឹងសត្វតិរច្ឆាន ក៏ត្រូវឲ្យមានសេចក្តីស្នេហារវាងគ្នាដែរ ។ បើតាមទ្រឹស្តីនេះ យើញថាព្រះពុទ្ធសាសនាគួរទទួលការពាប់រក ការគោរព ពីសំណាក់នៃមនុស្សលោកគ្រប់ជាន់ថ្នាក់ជាពន់ពេក ។ តើមកពីហេតុអ្វី ក៏មានការខ្វះព្រះពុទ្ធសាសនាត្រូវគេដិះជាន់ គេបដិសេធ គេកំទេចចោល ? ចំពោះសំនួរនេះ យើញថាមិនគិចក៏នឹងដោះស្រាយទេ ។ មានវេស់ប្លែកក្នុងលោកដែលធ្វើឲ្យមនុស្ស គោរបីមានហ៊ានខ្ពង់ខ្ពស់ក្តី មានបញ្ញាវៃឆ្លាតក្តី តាមក្លាយទៅជាបុគ្គលវង្វេងស៊ីង ឈប់ស្គាល់ការខុស ការត្រូវបាន ។ ឯវេស់ប្លែកនោះគឺទ្រព្យសម្បត្តិ ១ អំណាច ១ ស្ត្រី ១ បក្សពួក ១ ។

ចាប់តាំងព័ទ្ធនិញនៃព្រះបរមគ្រូសម្មាសម្ពុទ្ធមកដល់ ព. ស. ៩០០ ឆ្នាំ គ. ស. ៣៩៧ ឆ្នាំ សាសនាបស់ព្រះអង្គក្នុងប្រទេសឥណ្ឌា មានរស្មីចម្ងាំ លុះដល់ (១) ព. ស. ១៩០០ ឆ្នាំ គ. ស. ៨៩៧ ឆ្នាំ ព្រះពុទ្ធសាសនា ក្នុងប្រទេសឥណ្ឌាចុះអាប់ឧនយ៉ាងខ្លាំង ព្រោះសម័យនោះ សាសនាព្រាហ្មណ៍ ដែលជាសាសនាចាស់ពីបរម្បរាណមក ត្រូវគេលើកស្ទួយដំកំដើរឡើងវិញ ម្ល៉ោះហើយព្រះពុទ្ធសាសនាត្រូវតែអាប់ឧនចុះ តាំងពីនមហាយាន តាំងពីមហាយាន ។

នៅ ព. ស. ១៧០០ ឆ្នាំ គ. ស. ១.១៥៧ ឆ្នាំ ពួកអាភ័ព្វមានអំណាច ដើរចាំងដណ្តើមយកប្រទេសនានាជាច្រើន ដោយមានមហាម៉ាត់ជាមេដឹកនាំ ។ កាលបើតម្រិបស្រុកទេសបានសព្វគ្រប់ ធ្វើឲ្យបួលនៅក្នុងបក្រវបស់ខ្លួនស៊ប់ហើយ ពួកនេះចាប់សង្កត់សង្កិនសាសនា ជាអាទិ៍ព្រះពុទ្ធសាសនា ជាសាសនាដែលនិយម ប្រដៅឲ្យមានចិត្តស្លូតបូត ឲ្យមានក្តីសន្តោស ទឹងត្រូវតែពាប់ពេកគ្នាដោយខ្លាំកមុខញញឹម តោះបីសាសនិកដទៃក៏ដោយ ។ ព្រះពុទ្ធសាសនាទឹងអាចរុងរឿងបាន នៅសម័យណាដែលសត្វលោកត្រូវការទឹងតាប់ចិត្តចំពោះការគត់ឧនគ្នា ទឹងស្នេហាគ្នាខ្លាកដូចជាបងប្អូន ។ ពួកមហាម៉ាត់ មិនភតត្បាត់តែប្រទេសឥណ្ឌា សម័យនោះ ថែមទាំងភតអាណាចក្រហ្លួត

---

១ – តាមសេចក្តីនៃអត្ថបទសោក ប៊ូ-ប៊ូ ដែលដកស្រង់ចេញមកពី ។ ដំណាលពុទ្ធចេតិយ

ដល់មាត់សមុទ្រក្រហម នឹងកោះនានាក្នុងមហាសាគរជ្រោះស៊ីហ្វ័ក មាន
ឥណ្ឌូណេស៊ីជាដើម ។ ម្លោះហើយព្រះពុទ្ធសាសនាដែលថយចេញពី
ប្រទេសឥណ្ឌៀជាកន្លែងដើម ហើយមកតាំងនៅប្រទេសជាច្រែ គឺត្រូវ
ពួកអាព័ប់ចំផ្ទេចចំផ្លាញ ស្ទើរលើងពីផែនដីសាកលលោក ។ ឥស្សរ
សាសនា និយមបញ្ចូលចិត្តនឹងពន្យល់ប្រជាកស្ត្រីថាបើឈ្មោះណាប្រព្រឹត្ត
រំលំរំលើង បូជនីយដ្ឋានក្នុងព្រះពុទ្ធសាសនា ឈ្មោះនោះនឹងបានបុណ្យ
អនេកអនន្ត ដូចជាព្រះពុទ្ធសាសនាប្រដៅឲ្យធ្វើមានដូច្នោះ ។

តែទោះជាយ៉ាងនេះក៏ដោយ ព្រះពុទ្ធសាសនាមិនរលត់សូន្យឡើយ។
តមក អ្នកមានបញ្ញាល្អ នាំគ្នានិយមបន្តិចម្តងៗ ព្រះពុទ្ធសាសនាក៏ត្រូវ
មានរស្មីរះបែរ ។ ឡើងវិញ ហើយក្តីចំណែងពេញបន្ទុកគ្នានអ្នកណាអាចដុះ
ជាន់បាននៅសតវត្សទី ២៥ នៃ ព. ស. សតវត្សទី ២០ នៃ គ. ស.
ព្រោះសម័យនេះ មនុស្សក្នុងសាកលលោក ស្ទើរតែគ្រប់ប្រទេស មាន-
សេរីភាពបរិបូណ៌ ព្រមទាំងមានបង្កើតអង្គការអន្តរជាតិដ៏ធំបំផុត ១ ហៅថា
« អង្គការសហប្រជាជាតិ » មានទីសំណាក់ការនៅសហរដ្ឋអាមេរិក ។
អង្គការនេះអាចទទួលឲ្យប្រទេសជាច្រែចូលជាសមាជិកបាន ឲ្យតែប្រទេស
នោះ ។ មានឯកភាព មានអធិបតេយ្យ មានបុណ្យភាពសព្វគ្រប់ ។
អង្គការសហប្រជាជាតិ ក្នុង ១ ឆ្នាំ បើកសម័យមហាសន្និបាតសាមញ្ញម្តង
នៅខែកញ្ញា សម្រាប់ត្រួតពិនិត្យនឹងដោះស្រាយបញ្ហាដ៏ស្មុគស្មាញ

អន្តរជាតិ ហើយមានចាំងបង្កើតច្បាប់អន្តរជាតិមួយហៅ « ធម្មនុញ្ញសហប្រជាជាតិ » ។ ក្នុងធម្មនុញ្ញនេះ មានមាត្រា ១ ចែងពីសេរីភាពខាងជំនឿគឺថាមនុស្ស មានសិទ្ធិជឿនឹងគោរពសាសនាណាបានដោយសេរី កុំឲ្យតែជំនឿរបស់ខ្លួនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិជនដទៃ ។

ដូច្នេះ ចាប់តាំងពីមានអង្គការអន្តរជាតិនេះមក ឃើញថាជីវិលដែលមនុស្សលោកជ្រកអាស្រ័យនៅ មានដំណើរប្រព្រឹត្តទៅស្រួលគួរសមការរគាត់អួលតែងតែមានខ្វះ ដូចពាក្យចចាមណាថា « បានក្នុងវាតង់មានរណ្តៅគ្នា » តែមិនសូវធ្វើឲ្យសាកលលោកភ្ញាក់ផ្អើលនឹងភិតភ័យពេកចាំងខាងផ្លូវលោក ចាំងខាងផ្លូវសាសនា ។

មិនដឹងទេសកាលអ្វី នៅថ្ងៃ១៥ កើតខែពិសាខ ឆ្នាំថោះបញ្ចស័ក ព.ស. ២៥០៦ ត្រូវនឹងថ្ងៃទី៨មិថុនា គ.ស.១៩៦៣ គ្រោះកាចស្រាប់តែធ្លាក់មកលើព្រះពុទ្ធសាសនាខ្មែរ នៅប្រទេសយៀកណាមខាងត្បូង (កម្ពុជាក្រោម) ។ ដូចមានដូចជាក្នុងភូមិមួយ មនុស្សកំពុងដេកលក់ស្រួលកណ្តាលយប់ ស្រាប់តែមានអគ្គីភ័យផ្ទុះឡើង ។ ថ្ងៃ ១៥ កើតខែពិសាខ រៀងរាល់ឆ្នាំ ពុទ្ធសាសនិកចាំងខាងហីនយាន ចាំងខាងមហាយាន តែងធ្វើបុណ្យមួយហៅថា « វិសាខបូជា » ដើម្បីរំលឹកដល់ថ្ងៃដែលព្រះបរមសម្ពុទ្ធទ្រង់ប្រសូត្រ ទ្រង់ត្រាស់ ទ្រង់ព្រះបរិនិព្វាន ។ ទុកាសនោះ នៅយៀកណាមខាងត្បូង (យៀកណាមចែកជាពីរ : យៀកណាមខាង-

ដើងកុម្មុយនិះ យៀកណាមខាងត្បូងលោកសេរ) នាក្រុងវ៉ៅ កងខ័ពនៃ
វដ្តការ ង្វឹ ឌិន យ៉ែម ប្រធានាធិបតី មកជួញ់សម្ងាប់ពុទ្ធសាសនិកយៀក
ណាម កំពុងធ្វើបុណ្យដំឡាកែនោះ ។ តាមដំណឹងថាបានជាមាន
ការឃោរឃៅព្រៃផ្សៃនេះ គឺបណ្តាលមកពីកំហឹងផ្ទាល់ខ្លួននៃលោក
« ង្វឹ ឌិន ធុក » ត្រូវជាបងលោក ង្វឹ-ឌិនយ៉ែម មានឋានៈជាអាស្ចី
វែក (archevèque) ខាងសាសនាកាតូលិក នៅយៀកណាម
ដោយហេតុ កាលដែលមានធ្វើពិធីរួបរបស់លោក អ្នកធំខាងពុទ្ធសាសនា
ពុំមានលិខិតអ្វីបន្តិចនៅថ្ងៃនេះសោះក្តីគួរសមចំពោះរូបលោក ។ តែបើតាម
ការសង្កេត ហើយប្រហែលជាពិតជានោះ ព្រះពុទ្ធសាសនានៅយៀក
ណាមខាងត្បូង ពិសេស ផ្នែកខាងហីនយាន (ព្រះសង្ឃខ្មែរ) បាន
ទទួលការរំលោភជិះជាន់បៃបនេះមកជាយូរហើយ តែជាមានការកាប់
សម្ងាប់ព្រះសង្ឃខ្មែរ ខ្លាំងដូតវត្តអារាមជាច្រើន ។ កន្លងពេលដែល
វដ្តការ យ៉ែម ធ្វើជាបតែព្រះសង្ឃខ្មែរ ខ្លាំងដូតវិហារផ្សេង ។ នៅកម្ពុជា
ក្រោមនោះ មានតែប្រទេសកម្ពុជាទេ ដែលចិតនៅក្រោមការដឹកនាំដ៏ឆ្លាត
វៃ នៃសម្តេចព្រះនរោត្តមសីហនុ បានស្រែកអំពាវនាវឲ្យពិភពលោក
ភ្ញាក់រលឹក តែប៉ុន្តែគ្មានប្រទេសណាអើពើចាល់តែសោះ សូម្បីនៅឯស
ហប្រជាជាតិក៏ដោយ ។ ត្រង់នេះជាអតិមួយដ៏ធំនៃសោកនាដកម្មលោក រក
តែខឹងពុកចត្តនៅថ្ងៃមុខទៀតពុំកើត ។ តាមស្មាន ប្រហែលដោយអាងថា-

ភ្ជាប់អាចធ្វើបាបពុទ្ធសាសនិកខាងខ្មែរកម្ពុជាក្រោមបាន ទើបរដ្ឋការក្រុងវៀតនាម ញ៉ាំមហិនរំលោភមកលើពុទ្ធសាសនិកជាតិរបស់ខ្លួនទៀត ។ រឿងរ៉ាវពុទ្ធសាសនា ចេះតែរីកចំរើនឡើងតាំងពីឆ្នាំ ៦ មកដល់ឆ្នាំ ៩ (ពេលខ្ញុំកំពុងសរសេរនេះ) តែមានស្រាកស្រាន្តឡើយ ។ ពុទ្ធសាសនិកជាតិយៀកណាម តាមការពិរដ្ឋការ ង្វឹ-ឌិនយ៉ឹម ដែលមាន ង្វឹ-ខ័នញូ ជាទីព្រឹក្សា ខិតខំយាយជំនួមរបស់លោកអមជន (មតិ-ស្រីជាន់ មតិអ្នកចាំងពីរ) ឲ្យរសាត់ពីសាសនា ។ ឯការតាមការនេះ ខាងពុទ្ធសាសនិក ចាត់បង្កើតជាចាតុកម្មដោយសន្តិវិធី រហូតដល់ព្រះសង្ឃជាតិយៀកណាមខ្លះដុតខ្លួនសម្លាប់ ខ្លះកាត់ដៃខ្លួនឯងដើម្បីប្រជាំងនឹងអំពើកាចសាហាវនៃបក្សពួក តែទោះជាយ៉ាងនេះ ក៏រដ្ឋការក្រុងវៀតនាមនៅតែធ្វើដដែលមិនភ្ញាក់ មានតែរុញច្រាន យ៉ឹម ខិតញូ ព្រមទាំងការយាយដែលក្តាប់អំណាច ឲ្យធ្វើទុក្ខបុកម្នេញដល់ពុទ្ធសាសនិកកាន់តែខ្លាំងឡើង គឺថាចាញ់ការប៉ះសម្លាប់ ចាប់ដាក់ពន្ធនាគារចាំងរយៈចាំងពាន់ ។ ង្វឹ-ឌិនយ៉ឹម ស្មានថាខ្លួនអាចដុះជាន់ពុទ្ធសាសនាពេលនេះបាន ដូចការសាសនាព្រាហ្មណ៍ ខិតខំសាសនាឥស្លាម ដែលបានដុះជាន់កន្លងសម័យសតវត្សមុន ។ ។

តាមការសង្កេត ជំនាន់នោះ គេអាចធ្វើអ្វីបានតាមអំពើចិត្តខ្លួនមែន ដ្បិតសាកលលោកវស់ខៅដោយខ្សែក ។ ពីគ្នា គ្មានការរួបរួមគ្នាដូច-

សម័យនេះគឺថាបើអ្នកណាមានវិជ្ជាខ្ពស់ជាងគេ អាចប្រើអំណាចផ្តាច់ការបាន។ ជួយទៅវិញ ក្នុងសម័យនេះ អំណាចផ្តាច់ការដូចយ៉ាងហ៊ីត្លែរ (hitler) រកច្រកចេញពុំរួចឡើយ ។ គ្រាន់តែ ង៉ឹ - ឌិនយើម នឹងគ្រួសាររបស់លោក ប្រព្រឹត្តរំលោភលើពុទ្ធសាសនា ដែលមានសក្តានុពលជួយពិភពលោកឲ្យមានអត្ថភាពសហប្រជាជាតិ ពុទ្ធសាសនិកក្នុងពិភពលោក ជាអាទិ៍ ពុទ្ធសាសនិកនៅប្រទេសកម្ពុជា ត្រូវការប្រជុំគ្រប់ទីកន្លែង ស្រែកតវ៉ាយកឧត្តមភាពសិទ្ធិមនុស្ស ដែលគេឈប់លើកយកមកអនុវត្តជាច្រើនសតវត្សណាស់ហើយនោះ ។ មិនត្រឹមតែអ្នកពុទ្ធសាសនាប៉ុណ្ណោះទេ សាសនាដទៃទាំងអស់ក្នុងលោក ជាអាទិ៍គឺសាសនាកាតូលិកដែលបងរបស់ ង៉ឹម ជាអ្នកគ្រប់គ្រងនិ៍សព្វថ្ងៃ សាសនាឥស្លាមដែលក្នុងសតវត្សប្រាណស់មក ហើយបានបំផ្លេចបំផ្លាញពុទ្ធសាសនា តំនាំគ្នាជួយគ្រប់គ្រងនិ៍ស្រែកតវ៉ាទិសាទុទិសសុំឲ្យ ង៉ឹ - ឌិនយើម ឈប់ប្រព្រឹត្តបែបនេះតទៅទៀត មិនសមរម្យ មិនប្រសើរទេ ជាអំពើហួសសម័យហើយ ។ តែ ង៉ឹ - ឌិនយើម មុខក្រាស ដោយគាន់ខ្លួនមានអានុភាព មិនព្រមស្តាប់ពាក្យអង្វរ ពាក្យយំស្រែកជាតិខ្លួន នឹងពាក្យបំយសាសនានៃខ្លួនឡើយ ។ អំពើរបស់ ង៉ឹ - ឌិនយើម នឹងគ្រួសារខ្លួននេះ ប្រាកដជានឹងនាំខ្លួននឹងក្រុមបក្សពួកទៅរកវណ្ណៈជ្រោះយ៉ាងជ្រៅគឺហាយនភាពជាខ្លាំងប្រាកដ ព្រោះការនិច្ចយនៃសាតលលោកធំណាស់ ។

រឿងរ៉ាវព្រះពុទ្ធសាសនានៅយៀកណាមខាងត្បូង អាចចាត់ទុកជាការរំលេចលើព្រះពុទ្ធសាសនាលើកទី ៣ ដែលមានឈ្មោះ ង៊ឺ - ឌិន យ៉ឹម ជាមេនាំគាច ធ្វើក្នុងសតវត្សទី ២៦ នៃ ព.ស. សតវត្សទី ២០ នៃ គ.ស. ។ តែយើងនៅសង្ឃឹមថារស្មីដ៏ត្រចះត្រចង់នៃពុទ្ធសាសនានៅយៀកខាងត្បូង ទីបំផុតត្រឡប់មានឡើងវិញជាពិតប្រាកដ ដោយពឹងផ្អែកទៅលើមតិប្រកបដោយយុត្តិធម៌ និងសុភនិច្ឆ័យនៃសាកលលោក ទីអាទុកាតនៃអង្គការសហប្រជាជាតិ ។ ៩ - ៩ - ៦៣

ប៉ុន្តែទោះជា .. នៅថ្ងៃទី ១ ខែវិច្ឆិកា ១៩៦៣ រដ្ឋប្រហារកំចាត់ផ្ទះឡើង នៅប្រទេសយៀកណាមខាងត្បូងដោយមានលោក ទួតម សេនីយ "ដួងយ៉ុងម៉ាញ" ជាមេដឹកនាំ ។ រដ្ឋប្រហារនេះចាប់ផ្តើមពីរសៀលថ្ងៃទី ១ - ១១ - ៦៣ ទៅចប់នៅពេលម៉ោង ៩ ព្រឹកនៃថ្ងៃទី ២ - ១១ - ៦៣ គឺថារបបគ្រប់គ្រងផ្តាច់ការនៃលោកប្រធានាធិបតី ង៊ឺ ឌិន យ៉ឹម ចាន់ត្រូវរលំរលាយហើយផ្ទាស់យក លង់ថ្មីមកដន្ទឹស ។ តាមដំណឹងផ្សាយតាមវិទ្យុថាលោក ង៊ឺ ឌិន យ៉ឹម ទំនងលោក ង៊ឺ ឌិន ញូ ជាប្អូន ចាន់ត្រូវស្លាប់ទាំងពីរនាក់ ឯប្រពន្ធលោក ង៊ឺ ឌិន ញូ រួចខ្លួន ព្រោះអាល័យតែទៅធ្វើកិច្ចសម្បទានឯសហរដ្ឋអាមេរិក ។

ក្នុងរយៈពេលតែ ៦ ខែ ព្រះពុទ្ធសាសនា នៅយៀកណាមខាងត្បូងត្រូវមានសេរីភាពឡើងវិញ ។

ហោង-សមអាន

ធ្វើការនៅតាំងវាសេនាតូចថាហានខ្មែរប្រដេញលេខ ១០ នៃត្រៃត្រែវែង

តែនឆ្នាំរៀបរៀន

សេចក្តីផ្តើម

ឧមភ្តុ រតនត្តយស្ស

ខ្ញុំសូមបន្ទន់កាយ ហត្ថាថ្វាយបង្គំផ្តន់
ដោយចិត្តស្និទ្ធស្មោះត្រង់ ចំពោះអង្គព្រះត្រៃរ័ត្ន ។
ដែលមនុស្សនឹងខ្ពាំ តាំងព្រហ្មតែងប្រណិប័តន៍
ជានបុណ្យច្រានកំចាត់ ជាត់បង្ក្រុចចង្រៃឆ្ងាយ ។
ដោយតេជានុភាព មុញ្ញលាភវាតផ្សព្វផ្សាយ
សូមសុខសាន្តសប្បាយ កើតមានដល់យើងខ្ញុំណា ។
តទៅសូមប្រមុំ ប្រមូលផ្តុំពុទ្ធដីកា
ទ្រង់ព្រះសាស្ត្រាស់ទេស្នា អំពីការនឹងបណ្ឌិត ។
ខ្ញុំសូមតែងឥឡូវ ឲ្យត្រឹមត្រូវតាមកំរិត
នៃពុទ្ធដីកាពិត កុងតម្ពរ ខុទ្ទកៈ ។

ឯកាយ សុត្តនិបាត ល្អសុខសាធមានឃ្លាគ្គ

សុតន្តចិដកជាគ់ ដែលលោក-អ្នកជានជ្រាបច្បាស់ ។
ដកស្រង់ផ្សំភៅហារ តម្រៃការលោកក្មេង-ចាស់
មានចិត្តចង់ដឹងច្បាស់ ខ្ញុំបាទ៖ពាលខ្ញុំងបណ្ឌិតនេះ

ការសេពគប់ពាលបណ្ឌិត

តទៅនេះ ខ្ញុំសូមលើកយកអត្ថបទខាំងឆ្លាយជាពុទ្ធដីកាខ្ញុំងអគ្គកថា ដែលសំដែងអំពីការចូលសេពគប់ពាលខ្ញុំងបណ្ឌិត មកអធិប្បាយកំចាយសេចក្តីឲ្យងាយយល់ ដើម្បីលោក-អ្នកពុទ្ធសាសនិកដែលមានចំណង់ក្នុងការស្វែងរកទ្រព្យសម្បត្តិ យសសក្តិ-សុខសរសើរ គួរតិចារណាច្បាស់ខ្ញុំបាទ៖ច្បាប់តាលបណ្ឌិតនេះដោយខ្លួនឯង ហើយប្រតិបត្តិតាមដំនឿលោក អ្នកដែលយល់ឃើញគួរឬមិនគួរនោះចុះ ។

ការសេពគប់ ជានសេចក្តីថា ការរាប់រក ចូលជិតស្និទ្ធ-ស្នាលសមគំនិត យកជាមិត្តសម្លាញ់ រួមរក្សា ស្និទ្ធស្នាគម ស្រឡាញ់ស្មើប្រាណ ប្រព្រឹត្តតាម ចូលដៃ ។

ការសេពគប់ នេះជាមូលហេតុនៃសេចក្តីសុខចំរើនខ្ញុំងវិនាស-អន្តរាយ ព្រោះថាការសេពគប់នេះ លោកប្រៀបដូចជាកំណាត់សំពត់ស បើបុគ្គលយកកំណាត់សំរកត់ស ទៅជ្រលក់លើទក្រហម ក៏ប្រែក្លាយពីសទៅជាក្រហម បើជ្រលក់លើខៀវ ក៏ក្លាយទៅជាខៀវ ។ បើសេពគប់ពាលខ្ញុំងក្លាយទៅជាពាល បើសេពគប់បណ្ឌិត ខ្ញុំងក្លាយទៅជាបណ្ឌិត ។

ការធ្វើខ្លួរសេចក្តីស្និទ្ធស្នាលយ៉ាងជិតស្និទ្ធជាមួយបណ្ឌិត យកធ្វើជាមិត្តឬ ជាគ្រូ ស្តាប់ពាក្យដំបូន្មានប្រៀនប្រដៅ ហើយប្រតិបត្តិតាមរមែងបានខ្លួរសុគតមង្គលគ្រប់យ៉ាង ព្រោះបណ្ឌិតលោកចេះដឹកនាំជនដែលកប់ប្រសព្វជាមួយឲ្យមានស្មារតីរឭកដល់ធម៌ដែលគួរប្រតិបត្តិនឹងមិនគួរប្រតិបត្តិ ឲ្យស្គាល់គុណ-ទោស មានប្រយោជន៍ ឥតប្រយោជន៍ ទើបឥឡូវឲ្យចេះពិចារណាកេហេតុ-ផល ល្អអាក្រក់ដោយខ្លួនឯងក្នុងការសែ្វងរកទ្រព្យសម្បត្តិ ចិញ្ចឹមជីវិត ដើម្បីរស់នៅជាសុខក្នុងលោកនេះ ទើបលោកខាងមុខ ។ ផ្ទុយទៅវិញ ការចូលទៅធ្វើខ្លួរសេចក្តីមេត្រីរួមក្បែរជាមួយជនពាលយកធ្វើមិត្ត ធ្វើគ្រូ រមែងខូចខ្លួនខ្លួរឯកន្លែងទោសវិនាសអន្តរាយដល់ខ្លួន ព្រោះពាលតែងតែឥឡូវប្រៀនប្រដៅដឹកនាំដល់ជនដែលមកកប់ប្រសព្វជាមួយឲ្យធ្វើខ្លួរអំពើខុសច្បាប់ មានលួចបន្លំដណ្តើមទ្រព្យសម្បត្តិគេ ប្រព្រឹត្តការមេដឹកសុក ដក់កញ្ឆា អាកៀន ញៀនថ្នៃអាប៉ោង-ជួ ជាដើម ជាហេតុនាំឲ្យវិនាសអន្តរាយដល់ជីវិតនឹងទ្រព្យសម្បត្តិ រងទុក្ខវេទនា ក្នុងលោកនេះ ទើបលោកខាងមុខ ។

ការសេពគប់ នេះ ជាអំពើមានអានុភាពខ្លាំងក្លាក្រៃលែងអាចញ៉ាំងមនុស្សល្អស្លូតត្រង់ឲ្យប្រែក្លាយទៅជាមនុស្សអាក្រក់កោងកាចមនុស្សព្រហើនកោងកាច ឲ្យប្រែក្លាយទៅជាមនុស្សត្រឹមត្រូវស្លូតត្រង់ទៅវិញ ។ ការសេពគប់ពាលបណ្ឌិត គឺធ្វើខ្លួរសេចក្តីស្និទ្ធស្នាលរួមក្បែរជា

មួយពាល-បណ្ឌិត ហើយប្រគំបត្តតាម ។

ក្នុងករណីនេះ ខ្ញុំសូមធ្វើអត្ថាធិប្បាយពន្រឹកសេចក្តីអំពីគុណទោស នៃការសេពគប់ពាល ទើប បណ្ឌិតឲ្យរឹងរឹតតែច្បាស់ខ្លួនខ្លាយជាយស្តាប់ដូចតទៅ ៖

ការសេពគប់ពាល

គប់ពាលកាលចាប ធាបមកដល់
គប់ពាលកន្ទុល ខ្វល់ប្រក្រតី
គប់ពាលអបយស ទ្រុស្តគ៌ាយ
នាំឆ្ងាត់អវិជ្ជ សោយសោកសៅ ។

ជនដែលធ្លាប់តែងតែឆ្លៀលប្រអូស រស់នៅដោយសារតែម្ចាស់អ្នកដទៃ គឺរស់គ្រាន់តែដឹងនូវការដកដង្ហើមចេញ-ចូលប៉ុណ្ណោះ ឬ ជាជនត្រហឹង គោងការប្រព្រឹត្តនូវអែបាយមុខ ពេញបន្ទុកឥតអៀនខ្មាស់ ហៅថាជនពាល ។ ក៏ជនពាលនេះ មានលក្ខណៈ ត្រយ៉ៅស្វាកឬចាំន ជាគ្រឿងសម្រាប់សំគាល់ ដើម្បីងាយចំណាំ ឲ្យស្គាល់ថានេះជនពាលនោះ មានលក្ខណៈ ៣ យ៉ាងគឺ :

១- ទុច្ចិន្តិតចិន្តី ជនពាលបើគិតការអ្វី ។ ក៏គិតតែការដែលអាក្រក់ ។ ប្រកបដោយមនោទុច្ចរិត ៣ ប្រការគឺ: ចិត្តគិតតែសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ ដោយមានបំណងចង់បានមកជារបស់ខ្លួន ១ ចិត្តចង

តំនុំតុំគួនចង់ឲ្យអ្នកដទៃដល់នូវសេចក្តីវិនាស ១ តំនិតយល់ឫសហើយប្រកាន់ខ្ជឺឆ្ងាជាត្រូវ ១

២ - ធុញ្ញាសិតកាសី ជនពាលចេះនិយាយអ្វី ។ កំនិយាយតែសំដីគ្រក់ ។ ប្រកបដោយវាចីទុច្ចរិត ៤ ប្រការគឺ: និយាយកុហកកូតកាវបោកបញ្ឆោតអ្នកដទៃ ១ និយាយញុះញង់ អុជអាល សិកសៀតពីនេះពីនោះ ចាក់រុកដុកជាន់ បំបាក់បំបែកអ្នកដទៃ ១ និយាយទ្រគោះបោះបោកជេរប្រមាថ ប្រទេចផ្តាសា អ្នកដទៃ ១ និយាយពាក្យរោយរាយ ឡេះឡោះប៉ាច់ប៉ូច ឥតប្រយោជន៍ ១ ។

៣ - ធុក្កដកម្មការី ជនពាលចេះធ្វើការងារអ្វី ។ កំធ្វើតែការដែលគ្រក់ប្រកបដោយកាយទុច្ចរិត ៣ ប្រការគឺ: សម្លាប់សត្វដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ ១ លួចប្លន់ឆក់ដណ្តើមទ្រព្យអ្នកដទៃ ដោយខ្លួនឯង ឬប្រើគេ ១ ប្រព្រឹត្តល្មើសកូនកាមខាំងឡាយមានកូនប្រពន្ធប្តីគេជាដើម ១ ។

កុដិធម្មបទដកថាត្រង់ពាលវគ្គសំដែងថា មនុស្សល្ងីល្ងើងងឹតមិនដឹងប្រយោជន៍កុងជាតិនេះនឹងប្រយោជន៍ជាតិមុខ ហៅថាពាល

កុដិប្រស្នាវបស់នាងខាតមាណវិកាប្រឿនសួរទត្តមាណពថា បុគ្គលដែលហៅថាពាល ដោយហេតុដូចម្តេច? ទត្តមាណពឆ្លើយថា បុគ្គលដែលត្រេកត្រអាលហួសប្រមាណកុងកាមគុណខាំង ៥ គឺ រូប

សម្ដែង ក្នុង វេន នឹង សម្លួស្ស ហៅថា ពាល ។

ឬគ្គលណា ពោះប្រុសក្ដី-ស្ត្រីក្ដី ក្មេងក្ដី ចាស់ក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ដែលប្រកបដោយលក្ខណៈទ័យដូចសំដែងមកនេះ ឬគ្គលនោះ ឈ្មោះថាពាល ។

តាមពិត ជនពាលនោះ បើជនណា បានបួសចេតបព្វជ្រសព្វយកជាមិត្រសម្លាញ់ឬជាគ្រូហើយ ពោះបើទាប់ធ្វើល្អតាដើមគំដោយ ក៏គង់តែជននោះប្រែក្លាយទៅជាពាលបាន ព្រោះជនពាលតែងតែដឹកនាំអ្នកដែលសេពគប់នឹងខ្លួននោះ ឲ្យមានឫកពា សណ្ដាប់ធ្នាប់ គំនិតមារយាទ អាក្រក់ដូចខ្លួនឯង ។

ក្នុងតម្ដៃរមង្គលត្ថទីបនី លោកប្រៀបជនពាល ពុកដូចជាវត្ថុមិនស្អាត មានលាមកជាដើម បើឬគ្គលយកវត្ថុណាដែលស្អាត មកវ៉ៃប់លាមក វត្ថុដែលស្អាតនោះ ក៏នឹងប្រែក្លាយជាមានក្លិនស្អុយដូចលាមកនោះមិនខាន ការសេពគប់នឹងជនពាលក៏ដូច្នោះដែរ គឺប្រែក្លាយចិត្តគំនិតពាលតាមទៅ សុទ្ធសោធ ។

ការសេពគប់នឹងពាល ពុកដូចជានៅជាមួយនឹងសត្រូវដែលមានជាវកងដៃឬពុកដូចនៅរួមជាមួយតាស៊ីស្ដេជាដើម រមែងនាំមកនូវទុក្ខទោសជានិច្ច ព្រោះទោស ទុក្ខ ភ័យ អន្តរាយ នឹង ឧបស័គ្គ តែងកើតឡើងពីជនពាល ។ សេចក្ដីតម្ដៃរមង្គលត្ថទីបនី លោកហាមមិនឲ្យសេពគប់

ហើយលែមតាំងចន្លាប់ថា បើបានធ្វើបុណ្យកុសលអ្វី ណាមួយ ឲ្យធ្វើ
សេចក្តីប្រាថ្នាថា៖

ដោយតេជាខ្ញុំកាត បុញ្ញាលាភតាំងនេះណា
យើងខ្ញុំសូមប្រាថ្នា កើតជាតំណាងប្រុសស្រី
សូមកុំឲ្យមេរក្សៀ រួមប្រឡាក់ស្នេហ្គ្រមេត្រី
ខំឆាលអន្សត់រៃយ មេក្រមីឲ្យសោះឡើយ ។

ដូចរឿងដំណាលថា កាលតាអតីត មានបណ្ឌិតម្នាក់ឈ្មោះលោក
អកិត្តិ ជាបុត្រព្រាហ្មណ៍មហាសាល ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម
ប្រមូលក្នុងក្រុងពាពណាសី។ ទ្រព្យរបស់អ្នកមានតាំងឡាយនៃក្រុងពាពណាសី
មិនអាចនឹងគូរថ្លឹងឲ្យស្មើនឹងទ្រព្យរបស់លោកបណ្ឌិតអកិត្តិបានឡើយ។

មែនពិត លោកមិនគ្រាន់តែមានទ្រព្យប៉ុណ្ណោះទេ លោកមានតាំង
សន្ដានចិត្តស្នេហាជាតិមាតុភូមិយ៉ាងជាតស្ទឹងថែមទៀត លោកតែងតែ
ចូលទៅសួរយេស នឹង សេចក្តីសរសើរតម្កើងព្រះគុណជាម្ចាស់ដ៏វិសេស-
ត្បូងជាច្រើនលើក តាំងប្រជាកស្ត្រួ តស្រឡាញ់កម្ចាន់លោកគ្រប់។
គ្នា ព្រោះលោកជាអ្នកមានសទ្ធាយ៉ាងខ្លាំងខ្លួន បានចំណាយទ្រព្យក្រប់
សែនរៀល ជាក់តានដល់ប្រជាកស្ត្រក្រីក្រ នឹងចំណាយជាសាធារណ
តាន មានសង់សាលារៀន - មន្ទីរពេទ្យ - ស្ពាន - ផ្លូវថ្នល់ជាដើម ។

ថ្ងៃមួយ លោកបានសញ្ជឹងគិតពិចារណាការកុងលោក ដែលមាន

ការមមាញឹក ឃើញប្បាសន្ទូវគោសនៃការមគុណ ខ្ចីគោសនៃការ
សេពគប់ស្និទ្ធស្នាលជាមួយពាល ក៏ហៅកវិយោបុត្តធំតាមកប្រដុំ ហើយ
ចែកទ្រព្យសម្បត្តិឲ្យស្មើៗគ្នា ។ កាលបើលោកចែករួចហើយ ក៏លា
បុត្តធីតាទឹងកវិយា ទៅបួសជាឥសីទៅកន្លែងព្រៃ មិនយូរប៉ុន្មាន ក៏ញ៉ាំង
ឈានទឹងអភិញ្ញាឲ្យកើតឡើង ហើយហោះទៅកាន់នាគទ្វីប ធ្វើបណ្ណ
សាលានៅក្បែរដើមដង្កៀបក្តាម ១ ។

ដោយអភិតិ្តបណ្ឌិតតាបស ជាអប្បិច្ចបុគ្គល លោកក្រាញ
ទៅទីនោះ មិនព្រមនិមន្តទៅកាន់ទីដទៃទៀតឡើយ លោកតែងតែបេះ
ផ្លែដង្កៀបក្តាមទឹងបេះស្ទឹកស្ងោនាន់ពល់ៗថ្ងៃ តែប៉ុណ្ណោះ ។

អានុភាពនៃសីលរបស់តាបស បណ្តាលឲ្យក្តៅដល់អាស្នាព្រះឥន្ទ្រ
ក៏ដំណែងកេងជាព្រាហ្មណ៍សម្ងឹម មកកាន់ទីនោះភ្លាម ។ ឯព្រះតាបស
កាលបើឃើញឥន្ទ្រព្រាហ្មណ៍ ក៏មានព្រះទ័យជ្រះថ្លារីករាយសប្បាយ យក
ចិត្តដង្កៀបក្តាមស្ងោដែលខុកបំរុងនាន់ខ្លួនឯងនោះ ជាក់ខាន់ឲ្យឥន្ទ្រ
ព្រាហ្មណ៍ចាំងអស់ ហើយក៏ត្រាំអត់មិនព្រមស្ងោនាន់ទៀតឡើយ ។

ឥន្ទ្រព្រាហ្មណ៍ ចាន់ធ្វើន្ទូវការល្បងដូច្នេះអស់ពារៈ ៣ ដង ឥសី
ចេះតែជាក់ខាន់ឲ្យអស់ ។ កាលថ្ងៃ សុខចិត្តអត់ខ្លួនឯង ។ ដោយទ្រង់
ឃើញដូច្នោះ សម្តេចទេវរាជ ទ្រង់និម្មិតជាព្រះឥន្ទ្រវិញហើយប្រគេនពរ
ដល់ព្រះឥសី ។ ក៏ធ្វើន្ទូវសេចក្តីប្រាថ្នាៈ

«បពិត្រសក្កវេវកឯ: អាត្មាភាព គ្មានប្រាថ្នាអ្វេ សូមប្រាថ្នាកុំឲ្យឃើញ កុំឲ្យជួប កុំឲ្យឮ ថាពាលទៅឯណោះឯណោះ កុំឲ្យខ្ញុំភ្លាត់ទៅសេពគប់នឹងជនពាលត្រង់ ។ ជាតិ .. ។

ព្រះសហស្សនេត្រ ឮដូច្នោះ ក៏សួរទៀតរណ្តៅនោះជាលំព្រះឥសីថា :

បពិត្រព្រះតាបស ព្រះកំណែស្រស់ល្អដោយសីល
តើពាលគាចខូចចិល គំនិតលែមុខគ្រាស់ ។
ការធ្វើខុសត្រូវតែ ញោម ញាតិមិត្តប្តូរលោកម្ចាស់
បានជាស្អប់ខ្ពើមណាស់ មិនចង់ជួបមិនចង់ឃើញ ។

ព្រះមហាឫសី សំដែងថ្វាយព្រះឥន្ទ្រ ខ្លះហេតុដែលស្អប់ពាលមិនចង់ជួបមិនចង់ឃើញថា :

បពិត្រទេវិន្ទ្រឥន្ទ្រកោសី ទ្រង់ជ្រាបសេចក្តីនៃហេតុការណ៍
ពីពាលកំណាចគាចអស្ចារ្យ ប្រកបការងារយ៉ាងអាស្រូវ ។
ពាលច្រើនខ្នះខ្នែងសែងទ្រាយទ្រលំ ច្របូកច្របល់វល់ទុសថ្នូរ
ពាលធ្វើការអ្វីឥតមានត្រូវ ជួយតែតម្រូវក្រមូរខឹង ។
ជនពាលតំរេះល្ងីតល្ងង់ខ្លៅ អ្នកប្រាជ្ញប្រជៅនៅទ្រមឹង
មិនរៀបស្តាប់ត្រាប់ឲ្យដឹង ខាងតែកួរទឹងរឹងតែខ្លួន ។
ជនពាលកំចាបដាបកេលកាល ឆាបឆាលកេលដាលដល់គេឯង
ដូចស្វាយប្រមេះបើស្តីយ៉ងនៃស្រែង រមែងតែងធ្វងដល់ប្រុសស្រី ។

ហេតុនេះបានជាមិនចង់ឃើញ មិនចង់ឮឮឡើយសោះដើ
មិនចង់ឲ្យដួចរួមមេត្រី ខ្លឹងតាលតែរៃយរៀងរាល់ជាតិ ។

ជនតាលពុកជាបាបមិត្ត បុគ្គលអ្នកស្វែងរកនូវសេចក្តីសុខចំរើន
ត្រូវចៀសវាងកុំឲ្យដួចប្រទះ កុំសេពគប់នឹងជនតាលឲ្យសោះ ព្រោះ
តាលតែងញុំាងខ្លួនឯងឆង ញុំាងអ្នកដទៃដែលមករួមរស់ជាមួយឆង ឲ្យ
ដល់នូវខ្វះខាតសោសរីមាសអន្តរាយ ក្តៅក្រហាយស្តាយក្រោយ ។ តាហារណ៍
ដូចជា៖

រឿងទេវទត្ត

កាលសម័យពុទ្ធកាល មានភិក្ខុ១រូប ឈ្មោះ ទេវទត្ត ជាព្រះរាជ
បុត្រានៃព្រះបាទ សុប្បពុទ្ធ ខ្លឹងព្រះនាងអមិតា ព្រះរាជក្រុងទេវទហៈ
នៃប្រទេសកោសិយ បានចូលបួសក្នុងសំណាក់ព្រះសាស្តាជាមួយព្រះ-
អង្គុរុទ្ធ ព្រះអានន្ទ ព្រះភគុ ព្រះកិមិ្ពលៈ ខ្លឹងព្រះភទ្ទិយៈ។
ព្រះភទ្ទិយៈ បានសម្រេចវិជ្ជាភិប្រការក្នុងវេស្សានោះ ។ ព្រះអង្គុរុទ្ធ
បានចំពូកុញ្ញាណ ក្រោយមកបានស្តាប់ព្រះមានព្រះភាគទេសនាពី
មហាបុរិសវិតក្កសូត្រ ក៏បានសម្រេចអរហត្តផល ។ ព្រះអានន្ទ
បានសម្រេចសោតាបត្តិផល ។ ព្រះភគុខ្លឹង កិមិ្ពលៈ ចំរើនវិបស្សនា
បានសម្រេចអរហត្តផល ។ ព្រះទេវទត្ត បានសម្រេចឫទ្ធិជាបុថុជ្ជន ។
កាលព្រះសាស្តាយាងទៅក្រុងកោសម្ពី មហាជនតាំយកផ្កាមកថ្វាយ

តំណាងត្រកូលតែព្រះពុទ្ធម្ចាស់ និងអស្ចារ្យមហាសារក ត្រង់ខេត្តគ្មានតែណាស្មើរកសោះ ។ ខេត្តនឹកអន់ចិត្ត តំណៅសំដែងជូនថ្វាយព្រះជ្ញាយោគប្រទេសមគធៈព្រះអង្គជ្រះថ្លានឹងបូជារបស់ខេត្ត បានឱមន្តមកកន្លងព្រះដំណាក់ជាពាល់ថ្ងៃ ។ ដោយឈាកសក្ការៈគ្រប់សង្កត់ផង ចិត្តជ្ញាបរបស់ខេត្ត តំកើតឡើងច្រាកដ គឺចង់គ្រប់គ្រងព្រះសង្ឃដោយខ្លួនឯង បានចូលទៅសុំពុទ្ធានុញ្ញាត តែព្រះបរមគ្រូនៃយើង ទ្រង់ពុំអនុញ្ញាតឱ្យ ខេត្តកើតតំនុំតូចក្បាច្បាទព្រះអង្គជានិច្ច ។

ថ្ងៃ១ ខេត្តបានចូលទៅនិយាយបញ្ចុះបញ្ចូលណែនាំព្រះអង្គម្ចាស់អជាតសត្រូវ ឱ្យធ្វើគត់ព្រះបាទពិម្ពិសារ ដើម្បីឡើងគ្រប់គ្រងពាជ្យឯខ្លួនឯងនឹងធ្វើគត់ព្រះពុទ្ធ ដើម្បីតាំងខ្លួនព្រះជាតុទ្ធវែរ ។

ព្រះពាជកុមារ តំទ្រង់ធ្វើតាមបង្គាប់ខេត្តតាំងអស់ បានសៀតកាំបិតបង្គប់ យាងចូលទៅចំរុងធ្វើឃាតព្រះបិតា តែពេលនោះព្រះពាជង្គភ្ញៀតាប់បាន នាំយកទៅថ្វាយព្រះទៅ ។ ទ្រង់ត្រាស់សួរបញ្ជាក់ថា «ម្នាលកូនប្រុសសម្លាញ់ស្មើជីវិត! តើកូនត្រូវការចង់បានអ្វី បានជាកូនសម្លាប់បិតា ?» ។ ព្រះពាជបុត្រក្រាបទូលថា «បពិត្រព្រះវរបិតា ខ្ញុំលព្រះបង្គំចង់សោយរាជ្យ» ។ ព្រះបាទពិម្ពិសារ តំទ្រង់ប្រទានពាជសម្បត្តិឱ្យទៅព្រះពាជបុត្រគ្រប់គ្រង ចាប់តាំងពីថ្ងៃនោះ ។

ខេត្ត តំខំប្រឹងព្យាយាមធ្វើគត់ព្រះមានព្រះភាគជាពាល់ថ្ងៃតំបាន

ប្រើភ្នាន់ធ្វើឲ្យចាំបាញ់ព្រះអង្គ ឡើងលើកំពូលភ្នំប្រមៀលថ្មធ្លាក់លោហិត-តុប្បាទកម្មដោយខ្លួនឯង ប្រើហ្មដ៏ឲ្យទាំដ៏រឈ្មោះ ជាឧប្បាតិរ៉ៅត្រូចព្រះអង្គ នៅតែមិនបានសម្រេចដូចចំណង ហើយលាភសក្ការៈតំណាងសូន្យទៀត ។

កាលបើអស់ចំណេះកន្លងការអ្វើតព្រះសព្វញ្ញាតទ្ធហើយ ទេវទត្តក៏ចូលទៅក្រាបថ្វាយបង្គំសុំអនុញ្ញាតនូវវត្ត ៥ ប្រការគឺ :

១- សូមឲ្យភិក្ខុចាំឆ្ងាយនៅកន្លងព្រៃអស់ ១ ជីវិត

២- សូមឲ្យភិក្ខុចាំឆ្ងាយប្រព្រឹត្តបិណ្ឌបាតអស់ ១ ជីវិត

៣- សូមឲ្យភិក្ខុចាំឆ្ងាយប្រព្រឹត្តចង្រ្កូលអស់ ១ ជីវិត

៤- សូមឲ្យភិក្ខុចាំឆ្ងាយនៅក្រោមគល់ឈើអស់ ១ ជីវិត

៥- សូមកុំឲ្យភិក្ខុចាំឆ្ងាយឆានំសាច់អស់ ១ ជីវិត ប៉ុន្តែព្រះអង្គមិនទ្រង់អនុញ្ញាត ។

អាស្រ័យហេតុនេះ ទើបទេវទត្តព្យាយាមចំបែកសង្ឃដោយដល់បានសម្រេចដូចចំណង ។ ក្រោយមកក៏មានជម្ងឺឈឺជាប់ ៩ ខែ ហើយមានចំណង់ចង់ឃើញព្រះសម្មាសម្ពុទ្ធ ក៏ឲ្យសាវ័កបង្ហែរខ្លួនលើកដាក់លើគ្រែស្នែងសែនទៅវត្តជេតពន លុះដល់ស្រះក្បែរវត្ត បង្គាប់ឲ្យសាវ័កដាក់ចុះ ដើម្បីដុះកាយ គេលនោះព្រះធរណីមិនអាចនឹងទ្រទេវទត្តជាមនុស្សតាលក់ជាបយ៉ាងសែនធ្ងន់ជាន ក៏បើកចំហស្រូបយកទៅ ដោយអវិចី

ខៅវេនពុទ្ធវេនាចាល់ដល់សត្វថ្ងៃនេះ ។

រីឯព្រះបាទអជាតសត្រូវ ដែលជាមិត្តសំឡាញ់ស្មោះរួមគំនិតគ្នាជាមួយ ទេវទត្តនោះ ទោះព្រះបិតាផ្ទេរពាជ្យសម្បត្តិឲ្យមកហើយ ទ្រង់ខៅតែគឿ ពាក្យទេវទត្តថា « ត្រូវតែសម្លាប់បិតាឲ្យបានជាមុនសិន ទើបផុតពីការដល់ ដណ្តើមយកវិញ » ក៏ទ្រង់បញ្ជាឲ្យពួកជនបុរសចាប់បិតាយកខៅធ្វើ ការុណកម្មមានវិនព្រះបាទ ហាន់ដង្ហើមមាំសាបង្អត់ក្រយា ត្រាតែចូលទីវង្គត ។ ពេលជាបន្ទាន់គ្នានោះ លោចឮដំណឹងថា ទេវទត្តផែនដីស្រូបហើយ ក៏ទ្រង់តិតក័យជាខ្លាំង ខ្លាចក្រែងព្រះធរណីស្រូបព្រះអង្គដូចទេវទត្តដែរ បណ្តាលឲ្យក្តៅក្រហាយស្តាយក្រោយជាយទឹកយើញ កំហុស ទើបទ្រង់យាងចូលខៅគាល់ព្រះមុនិន្ទ្រតិនលោកត្រៃ កន្លងវត្ត វេឡុវនៃ ។ គ្រានោះ ព្រះបរមគ្រូទ្រង់ត្រាបថា « ព្រះបាទអជាតសត្រូវ ធ្វើបិតុឃាតកម្ម បើបែកធ្លាយកន្លងកាយខៅបរលោក ច្រាកជាខៅកើតកន្លងរក លោហាកម្ពី ជាមិនខាន ប៉ុន្តែបើបានស្តាប់ធម៌ទេស្នាបស់ តថាគត ទំរឹបានតាំងខៅក្នុងត្រៃសរណគមន៍ ហើយក្នុងអនាគតកាល ខឹងបានជាព្រះបច្ចេកពុទ្ធ ១អង្គ ព្រះនាម ដីវិតវិសេស » ហើយ ទើបទ្រង់សំដែងសាមញ្ញផលសូត្រប្រាសព្រះរាជា ។

លុះចប់ព្រះធម្មទេសនា ព្រះបាទអជាតសត្រូវសោបសូន្យសោតាបត្តិផល ខៅត្រឹមតែសរណគមន៍ ៣ ប៉ុណ្ណោះ នេះគឺដោយអានុភាពនៃ

ปริภุญฺชกกมฺมฺ ฯ

មែនពិត បើតាមទំនៀមទំលាប់នៃសាសនារបស់ព្រះពុទ្ធជាម្ចាស់ ត្រូវបានសម្រេចសោតាបត្តិផលក្នុងពេលនោះឯង ប៉ុន្តែបែរជាអន្តរាយចាកមគ្គផលសោកុត្តរធម៌វិញនោះ ក៏ព្រោះតែទោសសេពគប់នឹងខ្មាំងជាជនពាលនាំឲ្យធ្វើអនន្តរិយកម្ម ฯ

ការសេពគប់នឹងជនពាល ជាប្រធាននៃសេចក្តីវិនាសដូចពុទ្ធភាសិតក្នុងបាកវគ្គសូត្រថា

អសន្តស្ស ปิยา โหนฺติ สนฺตេ กุพฺพนฺติ ปิยํ
อสตญฺจ ธมฺมา ภาเวนฺติ ตํ ปภากรโต มุขํ

អ្នកមិនស្រឡាញ់ចូលចិត្តរួមរក្សា មេត្រីស្មោះស្ម័គ្រនឹងអ្នកសប្បុរស
ស្រឡាញ់ស្និទ្ធស្នាលពេញចិត្តជាំងអស់ នឹងអសប្បុរសអបយសដូចគ្នា
ស្រឡាញ់ពេញចិត្តជាប់តគ្ងាតឃ្វាតឃ្វា តាប់នឹងធម្មឫម្ហូយរបស់
ត្រង់គ្រាប់ប្រតិបត្តិតាមអសប្បុរស ហេតុនោះទាំងអស់នាំឲ្យវិនាស ฯ

ជនពាលញាំងខ្លួនឯងឲ្យដល់នូវកិយន្តកិយគ្រប់យ៉ាង ហេតុនេះ គួរចៀសវាងឲ្យឆ្ងាយកុំនិយាយរក កុំឲ្យឃើញ កុំស្និទ្ធស្នាល កុំភក់ពាក់ កុំរួមគំនិត កុំសេពគប់នឹងជនពាលឲ្យសោះ ដើមសុកមគ្គលកើតមានដល់ខ្លួន ដូចពុទ្ធភាសិតថា

អาเสวนา จ พาลานํ ការមិនសេពគប់នឹងជនពាលទាំងឆ្កួយ

ចាត់ជា មង្គលដ៏ឧត្តម ។

ការសេពគប់បណ្ឌិត

សេពគប់បណ្ឌិត ចិត្តថ្លាឆ្ងាជាំ
នាំដើរដំរើ ត្រង់ទៅទេត្រកក្សាន្ត ។
សេពគប់បណ្ឌិត ជាមិត្តចំណាន
យ៉ាត់យោងនាំប្រាណ ទៅហានសួគ៌ា ។

មនុស្សឈ្លៀសវាងវៃ ចេះដឹងឮស្តាប់ផ្លូវលោកផ្លូវធម៌ រកស៊ីចិញ្ចឹមជីវិតតាមកម្លាំងកាយកម្លាំងបញ្ញា ជាមនុស្សមានសីលធម៌ទៅកន្លងផ្លូវប្រកបដោយកុសលកម្មបថ ១០ ប្រការ ហៅថា បណ្ឌិត ។

កំជនជាបណ្ឌិតនេះ មានលក្ខណៈសំគាប់សំគាល់ ៧ យ៉ាងគឺ :

១- មានាបតិកវំ ចិញ្ចឹមក្សត្តិយ-ឥតុកបស់ខ្លួនឲ្យជាសុខ

២- កុលេជេដ្ឋាបចាយិនំ គោរពមនុស្សចាស់កន្លងក្រកូលរបស់ខ្លួន ។

៣- សណ្ហាំសខិលសម្ភាសំ និយាយតែពាក្យសំដីផ្អែមពីរោះ

៤- បេសុណាយ្យបហាយិនំ លះបង់ពាក្យសិកសៀតចាក់ចុចអុជអាល ។

៥- មច្ឆេរវិនយេ យុត្តំ រកឧបាយកំចាត់បង់នូវសេចក្តីកំណាញ់

៦- កោសជ្ជកិលេសុំ សង្គ្រន្តសេចក្តីខ្ជិលច្រអូសក្រោធបាន ។

៧ សច្ចំ មានសច្ចៈពៀងត្រង់ ។

ន័យមួយទៀតសំដែងថា ជនដែលប្រកបដោយប្រយោជន៍ ២ យ៉ាង គឺ : ប្រយោជន៍យើញតាមភ្នែកក្នុងជាតិនេះ ១ ប្រយោជន៍ដែលត្រូវបានក្នុងអនាគត ១ លោកហៅថា បណ្ឌិត ។

ប្រយោជន៍យើញតាមភ្នែកមាន ៤ យ៉ាងគឺ :

១- ឧដ្ឋានសម្បទា បរិបូណ៌ដោយវិរិយភាព ចំពោះកិច្ចការដែលត្រូវធ្វើ ដកឋដល់បានសម្រេចផលដែលកើតអំពីហេតុ ដែលខំធ្វើមោះ ។ ។

២- អារក្ខសម្បទា បរិបូណ៌ដោយការចេះថែរក្សាទុកទ្រព្យសម្បត្តិដែលរកមកមោះ មិនឲ្យវិនាសមិន ដោយហេតុផ្សេង ។ មានរបងស្រី ល្បែងភ្នាល់ជាដើម ។

៣- សមជីវិតា ចេះចាយទ្រព្យសម្បត្តិ ចិញ្ចឹមជីវិតល្មមសមគួរដល់កម្លាំងធនធានដែលរកបាន ។

៤- កល្យាណមិត្តតា សេពគប់រកតែគល្យាណមិត្រ គឺមិត្រដែលប្រព្រឹត្តត្រូវល្អដោយកាយ-វាចា-ចិត្ត ។

ប្រយោជន៍ត្រូវបានក្នុងអនាគតមាន ៤ យ៉ាងគឺ :

១- សទ្ធាសម្បទា បរិបូណ៌ដោយសទ្ធា គឺការជឿចំពោះវត្ថុ

ដែលគួរដឿ មានន័យថា៖ ធ្វើល្អបានល្អ ធ្វើអាក្រក់ប្លាន់អាក្រក់ ទើបដឿ
ចំពោះគុណត្រកូលតែមួយតែជាដើម ។

២- សីលសម្បទា បរិបូណ៌ដោយសីល គឺរក្សាកាយ វាចាចិត្ត
ឲ្យរៀបរយមិនឲ្យយើសយ៉ង មានរក្សាសីល ៥-៨ ជាដើម ។

៣- ចាគសម្បទា បរិបូណ៌ដោយការលែកទ្រព្យសម្បត្តិឲ្យជា
ទានឥតរើសមុខ ចំពោះមនុស្សទុគ៌តប៉ុចំពោះពាស់ព្រឺក្នាពារ្យ អ្នកមាន
សីល ព្រះសង្ឃ ទើបល្អាយនុពុតជាដើម ។

៤- បញ្ញាសម្បទា បរិបូណ៌ដោយការរៀនសូត្រចំណេះដឹងផ្លូវ
លោក-ធម៌ ទើបស្គាល់ពាក្យប្រឿនប្រដៅរបស់បណ្ឌិត ដើម្បីឲ្យកើត
បញ្ញា ចេះពិចារណាស្គាល់គុណទោស ត្រូវខុសល្អអាក្រក់ដែលស
ចំពោះមុណ្យបាប ឬចេះពិចារណាសង្វាសេពួសត្វឲ្យឃើញថា ធម្មជាត
តាំងមៅកន្លែងត្រៃលក្ខណ៌ជាដើម ។

បុគ្គលណា ខ្ពើរប្លុសក្តី ស្រើក្តី ត្រួចស្តក្តី បព្វជិតក្តី ក្មេងក្តី
ចាស់ក្តី ឲ្យតែប្រកបដោយលក្ខណៈដូចសំដែងមកនេះ បុគ្គលនោះឈ្មោះ
ថា បណ្ឌិត

ជនជាបណ្ឌិតនេះ ជាមនុស្សថ្លៃថ្លូតង់សាកលលោក ។ លោកយក
ចិត្តទុកដាក់ ជួយស្រោចស្រង់ យកយោងប្រទេសជាតិមាតុភូមិ ឲ្យឡើង
ទៅកាន់ឯកភាព ឥស្សរភាព ថ្កុំថ្កើងរុងរឿង ទើប សង្ខិត្តភាព ។

អ្នកដែលស្រឡាញ់សន្តិភាព ត្រូវធ្លុះចម្ងល់យកបែបទំនឹងការចេះដឹងអំពីលោក កុំបង្អែបង្អន់ ឲ្យកាលវេលាកន្លងទៅដើម្បីរកងប្រទេសជាតិសាសនា ទឹងព្រះរាជបល្ល័ង្ក ។

មែនពិត ជនជាបណ្ឌិតនេះ បើបានយើញថាខ្លួនស្គាល់ច្បាស់ហើយគួរតែចូលទៅសូមធ្វើជាមិត្ត ជាគ្រូ ព្រោះបណ្ឌិតតែងតែជឹកនាំឲ្យធ្វើអំពើល្អជាប្រយោជន៍ដល់ខ្លួន ទឹងប្រយោជន៍ខ្លួនទៅ ។ បើចូលទៅសេពគប់ហើយ ត្រូវប្រឹងស្តាប់តាក្យប្រៀនប្រដៅរបស់លោក យកមកពិចារណាឲ្យដឹងថា នេះល្អ នេះអាក្រក់ នេះបុណ្យនេះបាបដោយខ្លួនឯងឲ្យយល់ច្បាស់ ហើយប្រតិបត្តិតាមចុះ ទឹងតាមលក្ខណៈយ៉ាងនេះចំគួរ ដូចព្រះពុទ្ធភាសិតថា :

មហាត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
តិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។

អ្នកមានប្រាជ្ញា កាលណាចូលទៅ
ស្និទ្ធស្នាលនឹងទៅ ជាមួយបណ្ឌិត ។
អាចដឹងរសធម៌ បានពិតពិត
ដូចអណ្តាតលិទ្ធ ដឹងរសសម្ល ។

បណ្ឌិត លោកតែងតែជឹកនាំប្រៀនប្រដៅ អ្នកដែលមកសេពគប់ជាមួយ ឲ្យមានអាកប្បកិរិយាឫកពារមារយាទសុភត្រឹមកាយខ្លួន

ទៅជាបណ្ឌិត ។ បណ្ឌិតលោកប្រៀបដូចជាគ្រឿងក្រអូប មានក្រឹស្នា
ទីឥតរម្ងឹងផ្កាជាដើម ឯអ្នកដែលចូលទៅសេពគប់ ប្រៀបដូចជាស្មឹកឈើ
ឬសំពត់រុំខ្ចប់គ្រឿងក្រអូប ទោះស្មឹកឈើឬសំពត់មិនមែនជាគ្រឿងក្រ-
អូបសោះ តែនឹងប្រែក្លាយទៅជាមានក្លិនក្រអូបឈួយឈប់តួរឲ្យពេញចិត្ត
យ៉ាងណាមិញ ការចូលទៅសេពគប់នឹងបណ្ឌិត ក៏យ៉ាងនោះដែរ ។

បណ្ឌិតនេះលោកឥឡូវបង្ហាញប្រាប់ផ្លូវទៅកាន់ស្ថានសួគ៌ និព្វាន
នឹងបង្ហាញផ្លូវទៅកាន់ទេត្តកប្បន្ត ក្នុងបច្ចុប្បន្ននេះ ដែលយើងយើញជាក់
ច្បាស់នឹងភ្នែក គឺឥឡូវឲ្យចំប្រឹងរៀនសូត្រចំណេះវិជ្ជាផ្លូវលោក . ធម៌
ឲ្យចំប្រឹងស្វែងរកទ្រព្យសម្បត្តិ ឲ្យចេះស្រឡាញ់គ្នានឹងគ្នាជាសាមគ្គី ឲ្យ
ចេះស្រឡាញ់ម្តាយ-ឪពុក បងប្អូន មាមីងជីដូនជីតា ឲ្យចេះស្រឡាញ់
ជាតិ សាសនា ព្រះពុទ្ធបច្ចុប្បន្ន ។

បណ្ឌិត លោកដឹកនាំប្រៀនប្រដៅអ្នកដែលចូលមកកាប់ច្រស្តូវជា
មួយឲ្យបានសុខចំរើនថ្កុំថ្កើងរុងរៀងក្នុងបច្ចុប្បន្ន ឃើញជាក់ស្តែងនឹងភ្នែក
នេះ។ ឧទាហរណ៍ដូចជា ៖

រឿងព្រះសីហផ្ទុរ្ជ័ន

សេចក្តីពិតថា កាលពីមុន ប្រជាពស្ត្រកង្ហែក្នុងប្រទេសកម្ពុជាវង្សក្តុវៀ-
ន្នាជាអនេកដោយអំពើព្រៃផ្សៃនៃពួកចរទេស មានក្រុមចោរឈ្លើដែន
នឹងពួកយៀកមិញ ជាដើមហេតុ ។

ដោយទ្រង់យើញខ្លួនពុំគួរវេទនានៃប្រជាជនខ្មែរដូច្នោះហើយ ព្រះបាទសម្តេចព្រះឧភោគ្គមៈ សីហនុ ព្រះចៅផែនកម្ពុជា ទ្រង់យកព្រះបញ្ញាញាណដ៏ថ្លាមុត ប្រយុទ្ធតាមមាគ៌ាឯកភាជ្យដោយសន្តិវិធីប្រកាន់ជាលក្ខណៈខ្មែរ ។ មុនដំបូង ទ្រង់បង្កើតខ្លួនផែនការ ហៅថា « ផែនការព្រះសីហនុ » ដោយមានតង់ជីវពលនឹងនាំក្លាហាន តាន់តាំងក្លិនឈើតាន់ ហៃតាមក្រោយព្រះអង្គ ដើម្បីតាមមាគ៌ាឯកភាជ្យសម្រួលណាត់បាក់ឆ្នាំសែស ។ ដោយបុញ្ញានុភាពនឹងព្រះបញ្ញាញាណរបស់ព្រះអង្គ បាក់ឆ្នាំតក់ស្លុតញ័របន្ទមខ្លាចព្រះចេស្តាបារមី លើកអំណាចតាំងអស់ថ្វាយដល់ព្រះមហាវីរក្សត្រយើង ។

ប្រទេសកម្ពុជាបានខួលហានៈជារដ្ឋឯកភាជ្យពេញលក្ខណៈចាប់តាំងពីថ្ងៃនោះមក គឺថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ក្រោមការដឹកនាំដ៏ឆ្នៃសរបស់ព្រះករុណាព្រះបាទសម្តេចព្រះឧភោគ្គមៈ សីហនុ ដោយគ្មានញាំងតំណក់ឈាមមួយតក់ឲ្យស្រក់ឡើយ ។

ព្រះពជកិត្តិនាម តំណាលក្បាញ្ញាន្ធីភ្នសុសាយផ្សាយពេញពិភពលោកថា ព្រះអង្គជាស្តេចសឹក សន្តិភាព ។

តមក ទ្រង់ចេញព្រះតបត្តិការសាមគ្គី តំបាត់ពួកយៀកមិញ មានលោកខ្ពស់ខ្ពមសេនីយឯក លង់-ល្ងាល អគ្គមេបញ្ជាការបច្ចុប្បន្ននៃកងយោធពលខេមរភូមិន្ទ ដឹកនាំកងទ័ព នាំក្លាហាន ទង់កងជីវពលហៃតាម

ស្រោយព្រះអង្គ ពួកទាំងមូលបានតស៊ូយ៉ាងក្លាហានបញ្ចេញផុតពីដែនដីនៃប្រទេសកម្ពុជាបានសុខសាន្តស្រាណាហើយ ទើបសម្តេចព្រះបិតាឯកជ្យវាតិ ទ្រង់ដឹកនាំរដ្ឋនេះ - បាស់ជាអ្នកនយោបាយ ដោយគតិបណ្ឌិត គឺ: ទ្រង់សំរុះសំរួលបង្រួបបង្រួមឲ្យចេះស្រឡាញ់គ្នា រួមគ្នាជាតួន ១ កងចលនាសង្គមកស្ត្រនិយម ដើម្បីសាងប្រទេសជាតិ សាសនា ព្រះពុទ្ធបច្ចុប្បន្ន ។ លុះរដ្ឋនៃនេះស្រឡាញ់គ្នារួបរួមគ្នាហើយ ព្រះមហាវីរក្សត្រយើង ព្រះអង្គទ្រង់ដឹកនាំប្រទេសកម្ពុជាចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ដែលជាអង្គការឆ្នាំមួយក្នុងពិភពលោកស្វែងរកសន្តិភាព ដើម្បីជួយពលរដ្ឋក្នុងសាកលលោក កុងហាន:ជារដ្ឋអព្យាក្រឹត ។

ដោយប្រទេសកម្ពុជា នៅរួមភាគថ្ងៃជាតិ សម្តេចទ្រង់ដឹកនាំប្រឿនប្រដៅអ្នកពាក់ព័ន្ធ ទាហាន ស៊ីវិលនឹងប្រជាពលរដ្ឋ ឲ្យចេះស្រឡាញ់ការហត្ថកម្ម ។ ដោយព្រះអង្គធ្វើជាគំរូ ទ្រង់ជីក កាប់ ចូក សែងដីដាល់ព្រះហស្ត ។ ប្រជាពលរដ្ឋឃើញព្រះពុទ្ធគំរូដូច្នោះ ក៏ឈមមុខទៅរកកសិកម្ម ទំប្រឹងព្យាយាមពេញកម្លាំង កំហានខ្លួនវិលខ្លួនឈឺនពេញចិត្ត គឺមានប្រាក់ចាយសប្បាយចិត្ត ។

ដោយការហត្ថកម្ម ផលដំណាំគ្រប់គ្រាន់
បង្កើតផលជាក់ស្តែង គ្រប់គ្រាន់ស្រែចំការ ។

អ្នកក្រទៅជាមាន ទ្រព្យធនធានមានខ្លឹមសារ
បរិភោគសុទ្ធតែអាហារ មានរសឆ្ងាញ់ពាល់ ។ ថ្ងៃ ។
មានឡានមានកង់ដំរិះ យានជំនិះសុទ្ធតែថ្មៃ
សប្បាយកាយចិត្តក្រៃ ស្នាព្រះហស្តព្រះបិតា ។

មិនតែប៉ុណ្ណោះឯង ព្រះបណ្ដិតដ៏ឆ្នើមនៃប្រទេសខ្មែរ ព្រះអង្គយាងទៅដោះស្រាយនូវបញ្ហាដ៏ស្មុគស្មាញនៃប្រទេសលាវបានទៀត ។ ព្រះអង្គទ្រង់នាំនូវសុខ - សន្តិភាពប្រទានដល់ស្តេចលាវទាំងពីអង្គ គឺព្រះអង្គម្ចាស់ សុវណ្ណភូមា – ប៊ុនអ៊ុំ – សុជាឯវង្ស ទឹងប្រជាពស្ត្រទាំងមូល ។ ប្រទេសលាវរលត់ភ្លើងសង្គ្រាម ជានសន្តិភាពក្សេមក្សាន្តសព្វថ្ងៃ ដោយស្នាព្រះបញ្ញាញាណដ៏មុះមុតនៃសម្តេចព្រះបិតាឯកពជ្ឈ នៃយើងដោយពិត ។

រឿងនេះបញ្ជាក់ថា ការសេពគប់នឹងបណ្ឌិត ជាហេតុនាំមកនូវសុភមង្គលគ្រប់យ៉ាង ឃើញជាក់ក្រឡែតនឹងភ្នែក ដូចជាខ្មែរដែលបានគប់ប្រសព្វស្និទ្ធស្នាលត្រង់ត្រាចស្តាប់ឱវាទ ហើយប្រតិបត្តិតាមសម្តេចឪ ក៏បានទទួលនូវឯកពជ្ឈ ឥស្សរភាព រីឯខាងនឹងសន្តិភាពយ៉ាងពេញចិត្ត ។ យើងឃើញច្បាស់ហើយ ប្រជាពស្ត្រខ្លះ ដែលធ្វាប់ក្រលំបាកពីដើម ឥឡូវនេះប្រែក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិ មានសំលៀកបំពាក់សមរំជាពលរដ្ឋឯកពជ្ឈពិតពិត អ្នកធ្វាប់ខ្វិលច្រអូស ក៏ប្រែក្លាយ

ទៅជាទុស្សហ៍ អ្នកគ្មានផ្ទះសំបែង ស្រែចំការ កំទៅជាអ្នកមានផ្ទះ
មានស្រែចំការគ្រប់ៗគ្នា ។ សូម្បីប្រជាជាតិលាវតាំងមូលក៏ខ្ពួលខ្ពប់
សុខក្សេមក្សាន្តដែរ ព្រោះហេតុអ្វី ? ក៏ព្រោះតែស្តេចលាវតាំងបីអង្គ
នឹងប្រជាពស្ត្រតាំងមូល ខ្ពួលប្រតិបត្តិតាមព្រះដំបូន្មានដ៏ខ្ពង់ខ្ពស់នៃសម្តេច
ព្រះប្រមុខផ្ទះយើង ដែលជាអង្គបណ្ឌិតដ៏ឆ្នើមក្នុងសាគលលោកប្រកប
ដោយករុណា អាណិតអាសូរដល់មនុស្សជាតិ គ្រប់ប្រទេស ឥតរើសមុខ រើសសាសន៍ ឥតរើសលទ្ធិ ថាសាសន៍នេះ សាសន៍នោះ លទ្ធិនេះ
លទ្ធិនោះឡើយ ។ ព្រះអង្គស្នេហ៍តែ សច្ចៈភាព គឺចង់ឲ្យតែពិភព
លោកចេះស្រឡាញ់គ្នាតែប៉ុណ្ណោះ ។ ដូច្នេះបានជាទ្រង់មិនដឹងណាយ
ក្នុងការយោងទៅតែចំណងមិត្តភាព រវាងមហាអំណាចដើម្បី សច្ចៈភាព
សាកលលោក ។

បុគ្គលណា ដែលធ្លាប់ប្រព្រឹត្តអំពើឈ្លានពាន សាហាវកោងកាច
អំពើដើមកំដោយ ឲ្យតែបានចូលមកស្ថិតស្ថាលកប់ប្រសព្វជាមួយបណ្ឌិត
ហើយប្រឹងស្តាប់ពាក្យប្រៀនប្រដៅទាំមកប្រតិបត្តិតាម បុគ្គលនោះនឹងប្រែ
ក្លាយទៅជាមនុស្សស្លូតត្រង់វិញបាន ។ ការសេពគប់នឹងបណ្ឌិតបាន
សម្រេចលោកុត្តរធម៌ស្គាល់ផ្លូវទៅនិព្វានទៀតក៏មាន ។ ពាក្យជាដូចជា ៖

រឿងព្រះអង្គុលីមាលត្ថេរ (១)

សេចក្តីដំណាលថា កន្លងវង្សកាលព្រះបាទបសេនទិកោសល មានហេតុដ៏អស្ចារ្យ ១ បានកើតឡើង គឺកន្លងថ្ងៃដែលលោកស្រីជាភរិយា នៃមហាបវេហិតប្រសូតបុត្រ ។

ពេលនោះ បណ្តាលឲ្យគ្រឿងសស្ត្រាវុធទាំងអស់នឹងព្រះខន្ធកជ្ឈរបស់ព្រះចៅកោសលឆេះក្រហមច្រាល ឆ្អឺនផ្សែចេញអណ្តាតសន្ធោសន្ធៅ ។ រាជបវេហិត ដឹងថាកូនត្រូវថ្កូរដាវចោរ កំទាំរឿងនោះទៅទូលថ្វាយព្រះបាទបសេនទិកោសល ព្រះចៅក្រុងសាវត្ថីនៃប្រទេសកោសលថា « បពិត្រព្រះសម្មតិទេព ! កូនខ្ញុំព្រះបង្គំត្រូវថ្កូរដាវមនុស្សកាច តែមិនធ្វើឲ្យអន្តរាយដល់រាជសម្បត្តិឡើយ» ។ ព្រះរាជាទ្រង់មានព្រះរាជបន្ទូលថា « បើដូច្នេះខ្ញុំអនុញ្ញាតឲ្យទៅបាន តែត្រូវលោកទំអប់រំប្រៀនប្រដៅឲ្យប្រែក្លាយទៅជាមនុស្សស្លូតត្រង់វិញណា ! » ហើយក៏សន្មត់ឲ្យឈ្មោះដល់កូនថា « អហិំសកុមារ » ។ លុះអហិំសកុមារមានវ័យចំរើនឡើង មហាបវេហិតជាឪពុក បញ្ជូនឲ្យទៅរៀនសិល្បសាស្ត្រ ក្នុងសំណាក់លោកអាចារ្យទិសាបាមោក្ខ ក្រុងតក្កសិលា ។ អហិំសកុមារ ជាក្មេងមានបញ្ញាលើសក្មេងទាំងអស់ដែលទៅរៀនសូត្រជាមួយ ។ ទស្សាហ៍រៀនសូត្រ ធ្វើខ្លួនកិច្ចវត្តមានគត់ច្រណែនជើងដៃ ប៉ាវ

១= អង្គុលីមាលសូត្រ ពាក្យមេរដ្ឋមជ្ឈិមនិកាយ ។

ទឹកភ្លៀងទឹកត្រជាក់ជាដើម ដល់អាចារ្យ ខ្ញុំនិងគោរពប្រណិប័តន៍ដល់ចាស់-ទុំ ចាំឯងពួន តែតែងតែសរសើរប្រាប់លោកសាស្ត្រាចារ្យជារឿយៗ។ អហិសកកុមារ ក៏ទៅជាសិស្សស់ណាប់នៃលោកអាចារ្យ ខ្ញុំឯងជាសិស្សប្សឯងលើសសិស្សចាំឯទ្បាយក្នុងសាលាទីសាបាមេក្នុងឯង ។

ឯសិស្សាទុំសិស្សចាំឯទ្បាយ កើតចិត្តឫស្យាឈ្នានិះញុះញុងលោកសាស្ត្រាចារ្យ ឲ្យស្អប់អហិសកកុមារ។ លោកគ្រូជឿតាមពាក្យញុះញុងរបស់សិស្សចាំឯអស់នោះ ក៏ស្អប់អហិសកកុមារ រកឧបាយឲ្យអ្នកស្រុកសម្លាប់ចោល ។

ថ្ងៃមួយ លោកសាស្ត្រាចារ្យហៅអហិសកកុមារមកប្រាប់ថា :

« ម្នាលអហិសក: ! តើបាចង់បានសម្រេចមន្តដ៏វិសេសឬទេ ? បើបាចង់បានបួរទៅរកគ្រាមដែមនុស្សឲ្យបានគ្រប់ចំនួនមួយពាន់(១០០០) ក្នុងមនុស្សម្នាក់ៗ ត្រូវកាត់យកតែគ្រាម ១ » ។ អហិសកកុមារ ឮដូច្នោះ ក៏ឱនក្បាលសំពះ « តុហ្មិ ! អាត្មាអញ ជាតព្រាហ្មណ៍មិនត្រូវសម្លាប់មនុស្សឲ្យទុំសប្រវែណីព្រាហ្មណវង្សសោះ តែធ្លាម៉ែច បើមិនសម្លាប់ឃើញថាមិនបានសម្រេចន្តវ៉ា ទិស្មុមន្ត » ហើយក៏ជំរាបលោកគ្រូអាចារ្យថា :

ឋតិត្រលោកគ្រូដ៏មានគុណ ! ខ្ញុំបាទទទួលធ្វើតាមបង្គាប់ចាំឯអស់ឲ្យតែបានសម្រេចមន្តដ៏វិសេស » ។

ចាប់តាំងពីថ្ងៃនោះមក អហិសកកុមារ ផ្តើមសម្លាប់មនុស្សយកម្រាមដៃទៅតរុកក្រោមដើមឈើ ឲ្យស្គុះស្គាយលួយចោលខ្លះៗជាច្រើន ។ ក្រោយមកទើបចាប់ផ្តើមសម្លាប់មនុស្សកាត់យកម្រាមដៃ បន្ទុកជាកម្រងពាក់នឹងក ក៏បានចំនួន ៩៩៩ ម្រាម ។

អ្នកស្រុកគ្រប់និគមជនបទតក់ស្លុតខ្លាចអហិសកកុមារ តែងតែថ្កាប់ត្មាថា នែវ៉ើយប្រយ័ត្ន អង្គុលីមាលចោរ នៅទិសភាគឯណោះ ភាគឯណោះ ដំណឹងនៃមរណភ័យនេះ លេចឮខ្ទីផ្សាយដល់ពួជនសាវត្ថី ។ ព្រះបាទបសេនទិកោសលទ្រង់ជ្រាប ក៏បញ្ជាឲ្យកងទ័ពទៅចាប់អង្គុលីមាលចោរសម្លាប់ចោល ។

ឯខាងព្រាហ្មណីជាមាតា បានដឹងថាអន្តរាយនឹងកើតមានដល់កូន ក៏ប្រញាប់ប្រញាល់ទៅប្រាប់មុន ដើម្បីឲ្យកូនចៀសចេញពីទីនោះ ។

ពេលនោះ ព្រះមានព្រះភាគគង់នៅវត្តជេតពន ព្រះអង្គប្រមើលឧបនិស្ស័យនៃសត្វលោក ជ្រាបថាអង្គុលីមាលមានឧបនិស្ស័យត្រូវបានសម្រេចអរហត្តផល បើមិនទៅប្រាស មុខជានឹងធ្វើមាតុឃាតកម្មឃ្លាតចាកមគ្គផលមិនខាន ទើបទ្រង់យាងទៅប្រាសក្នុងវេលាថ្ងៃរះចំព្រាង ។ ។ អង្គុលីមាលចោរ ក្រឡេកឃើញព្រះសាស្តាចារ្យក្លាម ស្ទុះទ្វារដេញតាមសម្លាប់យកម្រាមព្រះហស្ត តែដោយអំណាចនៃព្រះបាដិហារ្យ អង្គុលីមាលដេញពុំទាន់ឡើយ ។ ខឿយហត់ពេកកំស្រែកប្រកូកហៅព្រះអង្គ

ថា នែស្រមណ៍ ! ឈប់សិន ឈប់សិន ។ ព្រះសម្ពុទ្ធគ្រាសថា តថាគតឈប់ តើលះបង់គាប់តតួថៅដបង់ប្រនង់យូរណាស់ហើយ នៅតែអ្នកឯងនេះតើ មិនទាន់ឈប់សម្លាប់សត្វដូចតថាគត អង្គុលីមាលចោរឮពុទ្ធបន្ទូលដូច្នោះ ក៏ភ្ញាក់ស្មារតីនឹកយើញទោសរបស់ខ្លួន ហើយដោះកម្រងម្រាមដៃនឹងគ្រឿងអាវុធ ត្រវែងចោលទៅញាកក្តុំអស់ ដើរចូលទៅក្រាបថ្វាយបង្គំសូមបួស ។ ព្រះសាស្តាទ្រង់អនុញ្ញាតឲ្យបួសជាភិក្ខុដោយឯហិភិក្ខុបសម្បទាហើយនាំយកទៅវត្តជេតពន ។

ចាប់តាំងពីថ្ងៃដែលបានឧបសម្បទាមក អង្គុលីមាលភិក្ខុ ទំាងវិទាសមថកម្មដ្ឋាន មិនខ្វល់ប្រអូសឡើយ តែចិត្តរវើរវាយមិនកើតសមាធិ ព្រោះចេះតែស្រមៃឃើញមនុស្សដែលលោកធ្វើបាប់សម្លាប់ពីមុន ។ ជានិរន្តរ៍ត្រូបសង្កត់ឲ្យក្តៅក្រហាយជាទិច្ច ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ជ្រាប ក៏ពន្យល់ឲ្យលះបង់គាម្មណ៍ដែលកន្ទងហួសនឹងមិនឲ្យនឹកអារម្មណ៍ដែលមិនទាន់មកដល់ ទ្រង់ឲ្យពិចារណាតែកិច្ចការដែលមានប្រាកដចំពោះមុខ ។ អង្គុលីមាលភិក្ខុដំណល់សតិពិចារណា តាមព្រះដំនូលស្រី ហើយទំាចំរើនកម្មដ្ឋាន ត្រាតែបានសម្រេច អរហត្តផល ជាមហាសាវក ១ អង្គក្នុងព្រះពុទ្ធសាសនា ។

រឿងនេះបញ្ជាក់ឲ្យឃើញច្បាស់ថា ការសេពគប់នឹងមិត្តល្អិត តែងបានផ្លូវសេចក្តីសុខចំរើនក្នុងលោកនេះនឹងលោកខាងមុខ រហូតដល់បាន

សម្រេចអរហត្តផល ដូចព្រះអង្គលិមាលត្ថេរជាអាទិ៍ ។

គួរឱ្យស្ញើចដល់គុណសម្បត្តិ របស់ព្រះមហាសាវកនេះពន់ពេក ដែលលោកធ្លាប់ជាមនុស្សកាចអាក្រក់អំពីដើម ហើយត្រឡប់ទៅជាមនុស្សស្លូតត្រង់ ជាទីគោរពមនុស្សទេព្តា ជាមហាសាវកដ៏ឆើតឆៃនៃព្រះសម្មាសម្ពុទ្ធ ទៅវិញថ្មាន កំដោយសារតែព្រះសព្វញ្ញុពុទ្ធដែលជាកំពូលនៃបណ្ឌិតនោះឯង ។

ហេតុនេះ គួរអស់លោក-អ្នកចាំឯង្ឃាយនាំគ្នាគប់រកបណ្ឌិតទំរាំស្តាប់ពាក្យប្រៀនប្រដៅរបស់លោក តាមការណាឱ្យឃើញច្បាស់ហើយប្រតិបត្តិតាម ខ្លឹងថ្មានសេចក្តីសុខចំរើនដល់ខ្លួន ដូចខ្ញុំយដែលខ្ញុំថ្មានសំដែងមកនេះ ។

និគមវិបត្តកថា

ពាលទំនឹងបណ្ឌិត មានគំនិតមានយោនិផ្ទុយ ។ ពីគ្នា ពាលប្រព្រឹត្តខ្លួរអំពើខុសត្រូវតែគ្រប់បែបយ៉ាង ជាទីសំអប់នៃមនុស្សទំនឹងទេព្តា ធ្វើខ្លួនឯង ទំនឹងអ្នកដទៃដែលថ្មានគប់ប្រសព្វជាមួយ ឱ្យតែតក្កកោសក្តីលោកនេះទំនឹងលោកខាងមុខ ។ បណ្ឌិតប្រព្រឹត្តខ្លួរអំពើសុចរិតគ្រប់យ៉ាង ជាទីគោរពបំអាននៃមនុស្សទំនឹងទេព្តា ធ្វើខ្លួនឯងទំនឹងអ្នកដទៃដែលចូលមកស្និទ្ធស្នាលជាមួយ ឱ្យថ្មានខ្លួរសុខចំរើន តក្កលោកនេះទំនឹងលោកខាងមុខ ។

ពាលទាំធ្វើអំពើអាក្រក់ លួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃជាដើម ។ បណ្តិតទាំឲ្យធ្វើអំពើល្អ មានធ្វើបុណ្យទានរក្សាសីលជាដើម ។ ការសេពគប់ពាលនឹងបណ្តិតនេះ តែងតែទទួលទទូលខុសផ្សេង ។ គ្នា ដូចជាកូនសេក កាលខើបនឹងញាស់ឡើង ចិត្តស្អាតឥតសៅហ្មង លុះត្រូវឡប់ព្រុះបក់ធក់ធ្លាក់សោតខ្ចាត់ខ្ចាយព្រាត់ប្រាសគ្នាទៅ ។ កូនសេក ១ ជ្រុះធ្លាក់ទៅលើអាស្រមព្រះមហាឫស្សី ។ ក៏រើសយកទៅចិញ្ចឹមថែរក្សា ។ ឯកូនសេក ១ ទៀតធ្លាក់ទៅដល់មណ្ឌលពួកចោរ ។ រើសយកទៅថែរក្សា ។ សេកដែលទៅជាមួយមហាឥសីមានចិត្តសប្បុរសគិតតែខ្វល់ខ្វាយសន្សំកុសលផលបុណ្យ ឆ្ពោះមុខតាមផ្លូវបៃតង់បណ្តិត សេកដែលទៅជាមួយពួកចោរ មានសន្ដានចិត្តអាក្រក់ រៀនតែលួចឆក់ឱបឫស្សាដូចជាចោរកំណាច ឥតខ្វាចស្ងប់ឡើយ ។

មើលចុះលោក-អ្នក ! គួរឲ្យស្ញើចពេកណាស់ សូម្បីសត្វតិរច្ឆានកំតង់ប្រៃក្លាយ ទៅជាល្អអាក្រក់បានដែរ ដោយសារអាទុកភាពនៃការសេពគប់ពាលបណ្តិត ។

ហេតុនេះ គួរតែយើងខំាគ្នាចៀសវាង កុំឲ្យជួបប្រទះក្បែរស្មើខ្ពស់ទាល ។ គួរតែស្វះស្វែងគប់តែបណ្តិត ដើម្បីត្រេបយកសេចក្តីដែលលោកប្រៀនប្រដៅ ទើបសុខចំរើនវុឌ្ឍិរឿងនឹងកើតមានគ្រប់កាលវេលា ។

គប់ពាលភាលថ្មាបង្អាបដល់ខ្លួន គប់ប្រាជ្ញអាចផ្ចង់ជួនកុសល
គប់ពាលនាំទុក្ខពោសមកដល់ គប់ប្រាជ្ញអាចផ្តល់ផលសុខសាន្ត ។
គប់ពាលនាំខន្ធនួនដេកព្រៃ គប់ប្រាជ្ញប្រពៃដេកគ្រឹះស្ថាន
គប់ពាលនាំក្តៅក្រហាយប្រាណ គប់ប្រាជ្ញនាំប្រាណបានត្រជាក់ ។
គប់ពាលនាំឲ្យគេស្អប់ខ្ពើម គប់ប្រាជ្ញដណ្តើមគ្នារួមក្បែ
គប់ពាលនាំឲ្យខ្វែងឆៃកចាក់ គប់ប្រាជ្ញរួមក្បែជាសាមគ្គី ។
គប់ពាលនាំឲ្យធឹកសុក គប់ប្រាជ្ញរក្សាសីលប្រក្រតី
គប់ពាលនាំឲ្យភ្លាក់អវិជ្ជ គប់ប្រាជ្ញសិរីនាំទៅសួគ៌ ។

ព្រៃវែងថ្ងៃ ១០ វិច្ឆិកា ឆ្នាំ ១៩៦១

ហេង - សមអាន

អាថ៌កំបាំងរបស់ពុទ្ធសាសនា

លោក ប៊ូ - ប៊ូ រៀបរៀង (តចប់)

រឿងអាថ៌កំបាំងមួយចំនួនទៀត

ដែលអស់លោកអ្នកអានគួរតែជ្រាប

ហេតុនេះ ព្រះពុទ្ធសាសនា តង់ទ្រង់នៅតែក្នុងប្រទេសណា ដែលពួកអ៊ីស្លាមផ្សាយទៅមិនដល់ គឺប្រទេសបែកខាងលើផណ្តៀ ប្រទេសនេប៉ាល់ ប្រទេសទីបេ ទឹងបណ្តាស្រុកដែលនៅកណ្តាលទ្វីបអាស៊ី មានស្រុកខ្លះទៀត នៅបែកខាងត្បូង គឺប្រទេសលង្កា នៅបែកខាងកើត គឺប្រទេសកូមា មន សៀម ខ្មែរ យួន ចិន កៅលី ទឹងជច្រើន ។ ប្រទេសទាំងនេះ នៅគោរពកាន់តាមព្រះពុទ្ធសាសនាជាប់រៀងរហូតមកដល់សព្វថ្ងៃនេះ ប៉ុន្តែ កាន់លទ្ធិផ្សេងគ្នា គឺពួកនេប៉ាល់ ទីបេ ទឹងស្រុកកណ្តាលទ្វីបអាស៊ី ព្រមទាំងចិន យួន ជប៉ុន ទឹង កៅលី កាន់ព្រះពុទ្ធសាសនាខាងលទ្ធិមហាយាន ។ ពួកលង្កា កូមា មន សៀម ខ្មែរ កាន់ព្រះពុទ្ធសាសនា ខាងលទ្ធិហីនយាន(១) ។

២ – តើមកពីហេតុអ្វី បានជាព្រះពុទ្ធសាសនាចំរើនរុងរឿង ?

ចម្លើយ : បានជាព្រះពុទ្ធសាសនា ចំរើនរុងរឿង មកពីហេតុដែលព្រះមហាកស្សបត្រាំងឆ្លាយ មានព្រះពុទ្ធសង្ឃាជ្រះថ្លា ទ្រង់ចំទុក

១– សៀមនឹងខ្មែរ មុនដំបូងកាន់លទ្ធិមហាយាន ដល់មកខាងក្រោយ ទើបត្រឡប់កាន់លទ្ធិហីនយាន ដូចសព្វថ្ងៃនេះវិញ ក្នុងរវាង ព. ស. ១.៨០០ ព. ស ១.២៥៧ ។

បំរុងលើកដំកើង ដូចជាការធ្វើសង្គាយនាធម្មវិន័យកាលគ្រាមុនហើយ នោះ មានព្រះបាទអជាតសត្រូវជាដើម ដែលព្រះអង្គទ្រង់ចំទុកបំរុងក្នុងគ្រាបឋមសង្គាយនា ។

សូមស្រង់យកព្រះរាជប្រវត្តិនៃព្រះបាទធម្មាសោកមហារាជ មកបញ្ជាក់ដោយសង្ខេបក្នុងខ្លឹមនេះ ដើម្បីជាឧទាហរណ៍ដូចតទៅ៖

ព្រះបាទធម្មាសោកមហារាជ បានឡើងសោយរាជសម្បត្តិតពីព្រះបាទ ពិន្ទុសារ ជាព្រះវររាជបិតា ក្នុង ព.ស. ៦១៨ មុន គ.ស. ៣៦៩ ឆ្នាំ ក្នុងព្រះរាជធានី ប៉ាតលិបុត្ត នៃមគធរដ្ឋ (ប្រទេសឥណ្ឌា) ។ កាលព្រះអង្គទើបសោយរាជ្យ ជាដំបូង ទ្រង់សព្វព្រះហឫទ័យ ក្នុងការពង្រីកអាណាខេត្តឲ្យធំទូលាយចេញទៅទៀត តាមលំអានចម្បាំងព្រះអយ្យកាធិរាជនីងព្រះវររាជបិតា ។ ទ្រង់លើកកងទ័ពទៅវាយប្រទេសកលិង្គរដ្ឋ ឲ្យធ្លាក់ទៅក្នុងព្រះរាជអំណាចបាន ។ លុះស្រេចការព្រះរាជសង្គ្រាមហើយ ទ្រង់ជ្រាបថាពួកអ្នកស្រុកកលិង្គរដ្ឋ ត្រូវចាប់ជាឈ្លើយចំនួន ១៥០.០០០ នាក់ (មួយសែនប្រាំម៉ឺន)

សម្លាប់ចោល អស់ចំនួន ១០០.០០០ នាក់ (មួយសែន) ស្លាប់ក្នុងសមរភូមិច្រើនជាអនេកទៅទៀត ។ ព្រះអង្គបានជ្រាបយ៉ាងនេះហើយ កំរើតព្រះរាជហឫទ័យសង្វេគតក់ស្លុតក្រៃលែង ទើបទ្រង់ព្រះរាជតម្រិះថា «ការដែលព្រះមហាក្សត្រ ស្វែងរកកិត្តិយស ខំឯពង្រីកអាណាខេត្ត

ដោយអាការធ្វើសឹកសង្គ្រាម បៀតបៀនគេឲ្យក្តៅក្រហាយ ឲ្យអន្តរាយ ជីវិតជាច្រើនយ៉ាងនេះ មិនសមគួរឡើយ ។ តាំងពីទ្រង់ឈ្នះឯយល់ យ៉ាងនេះមក ព្រះអង្គកំឈប់ធ្វើសង្គ្រាម ទ្រង់បែរទៅសិក្សាខាងលទ្ធិសាសនាវិញ ទើបកើតសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ខាងលទ្ធិហីនយាន ជាយ៉ាងខ្លាំង រហូតដល់ទទួលថ្វាយ ព្រះអង្គជាឧបាសក ហើយបានទ្រង់ព្រះផ្នួសជាភិក្ខុ ក្នុងព្រះពុទ្ធសាសនាមួយគ្រា ។ តមក ព្រះអង្គព្យាយាម គ្រប់គ្រងប្រជារាស្ត្រ ដោយធម្មានុភាព (តាមអំណាចធម៌) គឺថា ទ្រង់ដឹកនាំប្រៀនប្រដៅអ្នកស្រុកឲ្យប្រព្រឹត្តធម៌ ឲ្យតាំងខ្លួនជាមនុស្សសុចរិតល្អ ឲ្យមានកល្យាណធម៌ (សីលប្រាំ) ។

មានសេចក្តីក្នុងសិលាចារឹកថា សម័យព្រះបាទធម្មាសោកមហារាជ នោះ តតិធម៌ ដែលអ្នកប្រទេសមគធៈគោរព ប្រតិបត្តិ មាន ៤ ផ្នែកគឺ ៖

១- តតិធម៌ តាមព្រះពុទ្ធសាសនា

២- តតិធម៌ តាមសាសនាព្រាហ្មណ៍

៣- តតិធម៌ តាមសាសនាជេន របស់និគ្រន្ថអឡាតរ៉ាយ

៤- តតិធម៌ តាមសាសនា របស់អាជីវក ។

ព្រះបាទធម្មាសោក មហារាជ ទ្រង់ចំណុកបំរុង ព្រះពុទ្ធសាសនា ដោយលក្ខណៈ ៣ យ៉ាង គឺ ៖

១- ការសង្គាយនាធម៌វិន័យ

២- ការឱ្យប្រកាសផ្សាយព្រះពុទ្ធសាសនា ទៅក្នុងប្រទេសនានា

៣- ការកសាងតុទ្ធចេតីយ ដូចមានបុរាណវត្ថុនៅដាប់រហូតមក ដល់សព្វថ្ងៃ ជាកស្តុតាងស្រាប់ ។

ចំណែកគតិធម៌ តាមសាសនាព្រាហ្មណ៍ សាសនាជៃន ទើង សាសនារបស់អាជីវក ព្រះចាទធម្មាសោកមហារាជ មិនទ្រង់បៀតបៀន បង្ខិចបង្ខាំញេ គ្រាន់តែមិនទ្រង់ទំនុកបំរុង ស្មើនឹងព្រះពុទ្ធសាសនា ប៉ុណ្ណោះ ។

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៊ុ រៀបរៀង

ភាគ

ចំណែកកាលក្រោយមក បច្ចុប្បន្នជនបទកើតមានចោរបះបោរជាច្រើនលើក ព្រះបាទតាពណាស៊ីនឹងស្តេចយាងចេញទៅបង្ក្រាបការចលាចលនៅបច្ចុប្បន្នជនបទនោះ ទើបទ្រង់ត្រាស់ផ្តាំព្រះកដទៅថា មា បមជ្ជសិ ម្នាលទៅអ្នកមានសុទ្ធរកក្តីដំបូន្មាន នាងចូរកុំប្រមាទធ្វេសប្រហែសក្នុងការកុសលឡើយ រយៈនឹងទៅបង្ក្រាបបច្ចុប្បន្នជនបទ នាងចូរចំរើព្រះតបៈសទ្ធាមែនទែន ទម្រាំតែយើងត្រឡប់មកវិញ ទ្រង់ត្រាស់ផ្តាំព្រះអគ្គមហេសីប៉ុណ្ណោះរហើយ ស្តេចយាងចេញទៅជាមួយព្រះកដបរិពារត្រមាំងតុរង្គយោធា។

សម្មា បដិបជ្ជិត្វា ព្រះកដទៅធ្វើសច្ចាប្រតិបត្តិចំរើព្រះតបៈតាមព្រះពុទ្ធដីការនៃព្រះពុទ្ធស្វាមីពុំហានបំណែតបំណោយឡើយ ។ ចំណែកព្រះមហាក្សត្រលើកបតុរង្គយោធាទៅដល់បច្ចុប្បន្នជនបទហើយ ក៏តតាំងបង្ក្រាងដើម្បីនឹងចាប់ចោរក្បត់ប្រទូសកយ ។ ចោរតាំងឡាយចាញ់ព្រះតេជៈជាមិ នាំគ្នារត់ចូលព្រៃពួនជាត់អស់ទៅ ។ ព្រះមហាក្សត្រក៏ទ្រង់តង់រោងនៅបង្គន់ចាំចាប់ចោរឱ្យបានខ្លះ ។

ថ្ងៃមួយ ព្រះកដទៅមកវង់ចាំតាបសដែលនឹងនិមន្តទៅកាន់ព្រះកដ

និវេសន៍ គង់ចាំប្រគេនអាហារបិណ្ឌបាត តាំងពីព្រឹករហូតដល់ល្ងាចមិនឃើញតាបសសោះ ក៏យាងទៅផ្ទំក្បែរសិរីហាចញ្ជារ ។ ឯព្រះតាបសនោះ ចេញពីព្រះរាជនិវេសន៍ ហោះមកតាមអាកាសប្រទេស មកដល់ព្រះរាជនិវេសន៍ហើយហោះចុះមក ។ ព្រះរាជទេវីបានឮសូរស្បង់ចីវរកំសុតព្រះទ័យ ស្ទុះក្រោកឡើងប្រញាប់ប្រញាល់ គិតមិនខាន់ របូតព្រះកូសាជណ្តាប់ចេញពីព្រះអង្គ ថែមទាំងរបូតព្រះកូសាស្ទៀតផងទៀត ។ ព្រះតាបសក្រឡេកឃើញព្រះរាជទេវី ជាវិសភាគារម្មណ៍ គឺអារម្មណ៍ជាសត្រូវនឹងព្រហ្មចរិយធម៌ដូច្នោះ កំកើតកាមៈសេចក្តីត្រេកត្រអាល មិនអាចបង្ការកាមគោជនាហារបាន ទើបនិយាយប្រាប់ហេតុក្នុងសន្ដានចិត្តនៃខ្លួនដែលប្រតិព័ទ្ធ ស្រឡាញ់ព្រះរាជទេវីយ៉ាងខ្លាំង ។ ព្រះរាជទេវីឮតែកមិនត្រមត្រិះតាមពាក្យតាបស ចេះតែហាមប្រាមជារឿនជង្រើនត្រាដោយប្រការផ្សេង ។ ។ ប៉ុន្តែ ព្រះតាបសមិនស្តាប់តាក្យព្រះនាងហាមឃាត់សោះ បង្ខំសម្រេចមេថុនកិច្ចជាមួយព្រះនាងតាល់តែបានដូចបំណងក្នុងប្រាង្គប្រាសាទនោះ លុះរួចកិច្ចនេះហើយ ហោះវិលទៅទន្សាយវិញវែងកើត ក៏ដើរទៅឯព្រះរាជនិវេសន៍ដើង ។ ព្រះតាបសតែងទៅសេពមេថុនធម៌ព្រះរាជទេវីជាយូរថ្ងៃ ។

ចំណែកអាមាត្យទាំងឡាយបានសង្កេត ដឹងហេតុនេះច្បាស់លាស់ហើយ ក៏បញ្ជូនសាសន៍ជាសេចក្តីស្វាគមន៍ទៅថ្វាយព្រះមហាក្សត្រ-

សូមទ្រង់ជ្រាប ។ ឯព្រះតាបសនោះ តែដល់ទៅលត្រឹក តែងចូលទៅកាន់ព្រះរាជនិវេសន៍ សេពបញ្ចាកាមរស ជាមួយព្រះរាជទេវីជានិច្ចរៀងរាល់ថ្ងៃមក ។

រួមសម្ដេច្ចា ព្រះចុះពាក្យណាស៊ី ទ្រង់បង្គ្រាបបច្ចន្តជនបទតាប់ ពួកចោរបានហើយធ្វើអ្នកជនបទឲ្យនៅជាសុខសាន្ត រួចស្តេចយាងត្រឡប់មកព្រះនគរវិញ ដល់ព្រះនគរហើយ ព្រះអង្គពុំបានស្តេចចូលទៅកាន់ព្រះរាជនិវេសន៍ទេ ទ្រង់ស្តេចទៅឯព្រះរាជឧទ្យាន ជួបនឹងព្រះបរមពោធិសត្វសិន ទ្រង់ត្រាស់សួរនូវសេចក្ដីស្វាត់កំចាំងតាមសាសន៍ដែលអាមាត្យផ្ទៀទៅថ្វាយថា លោកជាម្ចាស់ប្រព្រឹត្តកន្ទួលប្រពៃណីជាមួយព្រះរាជទេវីមែនឬទេ ?

ព្រះតាបសថ្វាយព្រះពរថា មហារាជ សូមថ្វាយព្រះពរបពិត្រព្រះរាជសម្ភារ អាត្មាភាពមានសេចក្ដីប្រមាទ មិនអាចទប់ទល់ដំកល់ស្មារតីបានឡើយ ធ្វើការខុសឆ្គងដូចព្រះរាជតម្រាស់ពិតមែនហើយ សូមព្រះរាជសម្ភារអត់ទោសដល់អាត្មាភាព កុំឲ្យមានទោសតទៅទៀតទាំងមុខទៀត។

ព្រះមហាសត្វទ្រង់ត្រាស់ថា អាម ភន្តេ បពិត្រលោកម្ចាស់ ខ្ញុំទទួលវាចារបស់លោកម្ចាស់ ខ្ញុំអត់ទោសដល់លោកម្ចាស់ លោកម្ចាស់កុំប្រមាទ ចូរពិចារណាខ្លួនដែលលោកម្ចាស់ធ្លាប់ធ្វើរឿងនេះតាំងពីមុនមក ។

កសិណាំ សមាបជ្ជិត្វា ព្រះបរមពោធិសត្វក៏ចូលកាន់កសិណសមាបត្តិ ជាន់ដូចដើមហើយញ៉ាំងឈានទី៥អភិញ្ញាឲ្យកើតឡើងវិញ កំណើតអភិញ្ញាឲ្យដាក់តាំងនៃឫទ្ធិហើយហោះឡើងទៅកាន់អាកាសវេហាស៍ដែនជមិទេសនាជល់ព្រះឃោតាភរណសី ចប់ហើយ ថ្វាយព្រះពារណ ។ ព្រះមហាក្សត្រទ្រង់ត្រាស់អាកាសនាយាត់ព្រះតាបសឲ្យតង់ទៅតទៅទៀត ។ ព្រះតាបសថ្វាយព្រះពរថា ខ្ញុំនេះប្រកបដោយភ័យអាត្មាភាពសូមថ្វាយព្រះពរលាទៅឯព្រៃហិមពាន្តហើយ ថាហើចកំហោះទៅតាមអាកាស ចំរើនកសិណសមាបត្តិតាមគេចនៃព្រះតាបស លុះអស់ជន្មាយុហើយ មានឈានមិនសាបសូន្យក៏បានទៅកើតក្នុងព្រហ្មលោក ។ ចំណែកព្រះមហាក្សត្រក៏ស្តេចយាងត្រឡប់ចូលទៅក្នុងព្រះនគរវិញ ។

ការដែលព្រះបរមពោធិសត្វ ចំរើនទូវឈានសមាបត្តិនោះឯង ចាត់ជាតរុណកម្ម ជាមហគ្គតកុសល លុះអស់ព្រះជន្មបានទៅកើតក្នុងព្រហ្មលោក នាំបដិសន្ធិក្នុងជាន់ព្រហ្ម កម្មដទៃទៀតដែលជាលោកិយកុសលមានផលតិច មិនធ្វើទុំស្មើនឹងចំរើនឈានសមាបត្តិទេ ព្រោះហេតុថាឈានសមាបត្តិអាចកំចាត់បង់ នូវទុបកិលេសបានជាជាន់ ។ ។ ឯបុគ្គលដ្បូងនោះប្រកបដោយចិត្តជាឯកគ្គតាសមាធិ ។

អកុសលកម្មណានាំបដិសន្ធិក្នុងទុគ្គតិភព អកុសលកម្មនោះឈ្មោះថា

តវុកកម្ម គឺអកុសលកម្មរបស់បុគ្គល អ្នកប្រទូសរកយកដល់ព្រះរតនត្រ័យជាដើម ដូចសមណៈអាក្រាតប្រទូសរកយកចំពោះអង្គ សម្តេចព្រះបរមទេសល ដោយក្តែងពោលពាក្យបង្កាច់ទម្លាក់ទោសលើព្រះពុទ្ធអង្គមានសេចក្តីសង្ខេបតទៅនេះ ៖

រឿងនាងសុន្ទរីបរិព្វាជិ

សមណៈអាក្រាតតាំងឡាយ (ពួកតរេល) ប្រឹក្សាគ្នាថា តាំងពីព្រះសមណគោតមបានត្រាស់ដឹងមក ហាតលាភសក្ការៈពួកយើងមានលាភសក្ការៈសាបសូន្យអស់ គ្មានអ្នកណានាំយកលាភសក្ការៈមកឲ្យយើងសោះ បើដូច្នេះពួកយើងនឹងបង្កើតអ្នកណាម្នាក់ដែលចេះធ្វើឲ្យកើតទោសដល់ព្រះសមណគោតម កាលបើទោសកើតមានដល់ព្រះសមណគោតមហើយ ជនតាំងឡាយមុខជាត្រឡប់មកជ្រះថ្លាទឹងពួកយើងវិញ ទឹងនាំយកលាភសក្ការៈមកឲ្យពួកយើងជាមិនខានឡើយ ។

ឯកោ ទមន្ត ត្រង់នោះ មានសមណៈអាក្រាតម្នាក់ជាអ្នកមានគំនិតភ្លាំងភ្លាំនិយាយថា បពិត្រលោកតាំងឡាយ ខ្ញុំគិតឃើញឧបាយមួយ ទឹងអាចញុះញង់ទោសឲ្យកើតឡើងដល់ព្រះសមណគោតមបានត្រូវយើងទៅតឹងនាងសុន្ទរីបរិព្វាជិ បង្គាប់ឲ្យនាងនេះធ្វើអំពើខុសច្បាប់តែចេះតែចេញចូលទៅមកក្នុងវត្តជេតពនជាញឹកញាប់ លុះយូរបន្តិចប្រាប់ឲ្យនាងសុន្ទរីធ្វើអាការដូចជាស្ត្រីមានផ្ទៃពោះធំ រួចយើងដួលពួកចោរឲ្យ

សម្លាប់នាងសុន្ទរី ហើយឲ្យយកទៅកប់លាក់ទុកក្នុងគន្លងសម្រាមក្បែរវត្តជេតពន យើងធ្វើទុច្ចរិតលើយ៉ាងនេះ មុខជាភ្លក់ទោសទៅលើព្រះសមណគោតមពុទ្ធានឡើយ ។

សមណៈអាក្រាតពាំងនោះឆ្លើយថា អត្ថេសោ ឧបាសោ អើ ! ទុច្ចរិតនេះមានប្រយោជន៍មែន ឃើញត្រមគ្នាដូច្នេះហើយក៏នៅស្ងៀមមិនឱ្យយកប្រាប់ អ្នកដទៃឲ្យលេចឮរឿងនេះឡើយ ។ មានកាលមួយថ្ងៃ នាងសុន្ទរីបរិព្វាជិកាចូលទៅក្នុងទីប្រជុំនៃសមណៈអាក្រាតពាំងនោះ ។ សមណៈអាក្រាតពាំងអស់គ្នាមិនឱ្យយស្តីគេនាងសុន្ទរីមួយម៉ាត់សោះ ។ នាងសុន្ទរីនឹកឆ្ងល់ណាស់ក្នុងចិត្តថា ចុះមានហេតុអ្វីបានជាលោកពាំងពួងមិនឱ្យយស្តីនឹងខ្ញុំមួយម៉ាត់សោះ តើខ្ញុំមានទោសអ្វី ? សមណៈអាក្រាតពាំងនោះឆ្លើយថា នាងមិនយើញថាព្រះសមណគោតមបៀតបៀនពួកយើងខ្លះ ។ នាងសុន្ទរីសួរថា កើតកកើរ ចុះលោកម្ចាស់នាងអស់ទាំងឱ្យខ្ញុំធ្វើដូចម្តេច ? ពួកសមណៈអាក្រាតប្រាប់ថា នាងចូរបង្កើតទោសណាមួយឱ្យកើតមានដល់ព្រះសមណគោតម ឱ្យនាងតែបានតាមគំនិតប្រាថ្នាស្មើរបស់ខ្លួន ។ នាងសុន្ទរីបរិព្វាជិកាឮពាក្យថា សាធុ ល្អហើយ ។ លុះចេញទៅផ្ទះវិញ ។

ចាប់ដើមពីនោះមក កាលជនពាំងឡាយទៅស្តាប់ព្រះសទ្ធម្មទេសនាចប់ហើយចេញពីវត្តជេតពនវិលមកផ្ទះវិញ នាងសុន្ទរីក៏ដើរចូលទៅកន្លែ

វត្តជេតពនតាមផ្លូវដែលមហាជនចេញមកនោះ ។ លុះដល់ពេលត្រឹកខ្ជើង ការមហាជនចូលទៅកាន់វត្តជេតពន នាងសុន្ទរីចូលទៅសម្ងំនៅកាន់វត្តជេតពនដែរ ។

ពួកសមណៈ អាក្រាតនាំគ្នាយកដំណើរសេចក្តីនេះទៅផ្សាយដំណឹងប្រកាសប្រាប់បណ្តាជនថា នាងសុន្ទរីបរិព្វាជិចូលទៅសម្ងំនៅក្នុងវត្តជេតពនជាមួយព្រះសមណគោតម ឯព្រះសមណគោតមក៏ត្រេកត្រអាលដោយអំណាចមេថុនសមាចារ (ការសេពមេថុន) ជាមួយនាងសុន្ទរីនោះ ។ ពួកមនុស្សដែលមានសទ្ធាជាតិលក់ជឿសំដីនៃសមណៈអាក្រាតស្មុគ ឥតសង្ស័យឡើយ ។

លុះកន្លងយូរបន្តិចមក សមណៈអាក្រាតទាំងនោះជួលពួកចោរឲ្យទៅសម្លាប់នាងសុន្ទរីហើយឲ្យនាំយកទៅកប់លាក់ទុកក្នុងគំនរសម្រាម រួចធ្វើកលជាផ្តើលនោះឡោកោលាហល ថានាងសុន្ទរីបរិព្វាជិចូលមកជេតពនទៅកាន់វត្តជេតពនហើយស្រាប់តែបាត់ខ្លួនទៅ ថាដូច្នេះហើយក៏នាំគ្នាដើរស្វះស្វែងរកសព្វច្រកល្ហក កំពេញប្រទេះឃើញខ្មោចនាងសុន្ទរីនៅគំនរសម្រាម ទើបនាំយករឿងនេះទៅក្រាបទូលព្រះមហាក្សត្រ សូមទ្រង់ប្រឹក្សាឲ្យឃើញថាសម្តេចព្រះបរមសាស្តា ធ្វើខ្លួនអស់ទម្ង (មេថុន) ជាមួយនាងសុន្ទរីហើយខ្ជាចអ្នកផងជំនឿឮ រឿងនេះនឹងកើតពោសគេតិះដៀលទើបប្រើសារពីកឲ្យសម្លាប់នាងសុន្ទរីចោលទៅដើម្បីនឹងបំបាត់ជាន ។

ព្រះមហាក្សត្រចាន់ទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ព្រះតម្រិះថា សម្តេចព្រះបរមសាស្តាមិនចាន់ធ្វើអំពើណាមកដូច្នោះទេ ពួកសមណៈអាក្រាតកែងធ្វើអំពើទ្រគ្រឹងនេះ ដើម្បីនឹងទម្លាក់ទោសលើព្រះអង្គ ចាំអញឲ្យគេចូនអ្នកសម្លាប់នាងសុន្ទរីបរិព្វាជិកាឲ្យចានហើយ ធ្វើយ៉ាងណាទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបទ្រង់មានព្រះរាជបញ្ជាឲ្យរាជបុរសចាំងឡាយគ្រាច់ចរៅស៊ើបសួរដំណឹងឲ្យដឹងហេតុនោះ ។

ចំណែករាជបុរសចាំងឡាយក៏ធ្វើតាមព្រះរាជបញ្ជា ។ ឯពួកចោរដែលសម្លាប់នាងសុន្ទរីបរិព្វាជិនោះ ចាំគ្នាចៅស៊ីផឹកនៅក្នុងកន្លែងសុក ។ សុកមនមន្តោ ហុត្វា ចោរម្នាក់ស្រវឹងសុកវាយចោរម្នាក់ ។ ចោរដែលវាយត្រូវនោះ វាយតបវិញហើយនិយាយថា ហេតុអ្វីបានជាឯងវាយអញ ។ ចោរនោះឆ្លើយថា នាងសុន្ទរីបរិព្វាជិកាអញសម្លាប់មែនឬទេ ។ ចោរម្នាក់ឆ្លើយថា ឯងមិនដឹងទេឬ អញសម្លាប់នាងសុន្ទរីបរិព្វាជិ ។

ពួករាជបុរសលឮស្តាប់ឮសំដីចោរ ប្រកែកគ្នាដូច្នេះហើយក៏ចាប់ចោរចាំងនោះនាំយកមកថ្វាយព្រះរាជា ព្រះអង្គបង្គាប់ឲ្យសាកសួរយកចម្លើយ ។ ពួកចោរឆ្លើយប្រាប់តាមត្រង់ថា សមណៈអាក្រាតចាំងឡាយជួលខ្លួនឲ្យសម្លាប់នាងសុន្ទរីបរិព្វាជិនោះ ទើបទ្រង់ត្រាស់ឲ្យសមណៈអាក្រាតចាំងនោះមកសាកសួរចម្លើយទៀត ។ ពួកសមណៈអាក្រាត

ទ្វើយទុលសាកោតដូចតាក្យចោរ ទើបព្រះអង្គត្រាស់ឲ្យចុះព្រះពុទ្ធ
ភាជ្ញាហើយឲ្យនាំបណ្តើរទៅស្រែកអាក្រោះ ប្រកាសទោសខ្លួនឲ្យអ្នក
ខេត្តដើងឮត្រប់គ្នា រួចហើយទ្រង់ឲ្យនាំយក សមណៈអាក្រក្រតាំងនោះ
ព្រមទាំងពួកចោរទៅប្រហារជីវិតតាមទោសរបស់ខ្លួន ។ ពួកសមណៈ
អាក្រក្រតនឹងពួកចោរតាំងនោះ លុះស្លាប់ហើយ ទៅកើតក្នុងមហានរកអវិចី
ព្រោះហេតុអកុសលទុច្ចរិតដែលខ្លួន ធ្វើគរុកម្មនោះ ។ ឯនាងសុន្ទរី
បរិព្វាជិ កាលដែលពួកចោរសម្លាប់ស្លាប់ហើយ ក៏ទៅកើតក្នុងមហាអវិចី
នរកដូចគ្នាដែរ ។ គរុកម្មនេះ ក៏ពាប់បញ្ចូលក្នុងអកម្មបច្ច័យ ២៤ ប្រការ ។

គរុកម្ម សង្ខេបប៉ុណ្ណេះ ។

(តមក)

ឡើងទៅគាល់ហ្លួងស្តេចជាប្រក្រតីដូច្នោះកូវ ខាងពុំគាប់ចិត្តនឹងពោធិ-សត្វនោះឡើយ ហើយខាងគិតថាអើ! មហោសធនេះឯងធ្វើឲ្យយើងប្រាសនឹងកូនសំឡាញ់ ហើយឲ្យអញព្រួយលំបាកក្តាត់ ដ្បិតតែគំនិតមហោសធនេះឯងអេះ បើដូច្នោះអញខុកចូរឡើយ អញនឹងរកកលឲ្យគេសម្លាប់ឆាប់ៗកូវ បានអេះ ម្ល៉ោះហើយខាងប្រុមប្រុងបង្គាប់អស់ស្រីវល្លភាទាំង ៥០០ តែងនឹងបម្រើគាត្មាថា ម្នាលស្រីវល្លភាទាំងឡាយអើយ ចូរមេទាំងឡាយតាមមើលបំណាំមហោសធ ឲ្យឃល់ពេលអ្វីមួយហើយយើងនឹងចំបែកមហោសធនោះ ឲ្យជាហេតុគេខនឹងគ្នាបន្តិចហើយ អញនឹងទូលស្តេចឲ្យសម្លាប់ឆាប់កុំឲ្យដំនាវហ៊ាះ ម្ល៉ោះហើយអស់ស្រីវល្លភាទាំងអម្បាលនោះ សឹងតែដើរតយគន់ចាំឃ្លាំមើលជាយន្តវហេតុដំណើរនៃពោធិសត្វនោះជាប្រក្រតីសព្វថ្ងៃទៅហោង ។ មានកាលសម័យថ្ងៃមួយខាងដីកេរីបរិញ្ជកាឡើងទៅគាន់ចង្ហាន់លើព្រះរាជមន្ទីរស្តេច ស្រេចហើយចុះទៅហោង ។ ព្រះពោធិសត្វសោត អ្នកលីលាចូលមកប្រយោជន៍ដើម្បីនឹងឡើងទៅគាល់មហាសត្ត្រ កំប្រុះគ្នាកណ្តាលព្រះលានស្តេច ខើបពោធិសត្វអ្នកចូលទៅ លុតជង្គង់សំពះខាងកេរីបរិញ្ជកា ហើយឈរទៅហោង ។ ឯខាងកេរីបរិញ្ជកា ខាងគិតជញ្ជឹងរំពឹងថា

ខ្ញុំមហាសច់នេះ ដោយអញឮគេថាមានប្រាជ្ញានោះ សភាពជាអ្នកប្រាជ្ញមែនពិតក្តី តុំសភាពជាអ្នកមានប្រាជ្ញាក្តី អញចង់ដឹងឲ្យជាក់ច្បាស់តាលនេះម៉ាលហ្ន៎ មៀរហើយនាងក្តាប់ដៃស្តាំនាំដណ្តើងប្រាថ្នាទៅតាន់តោងដំសត្វ ទើបតោងដំសត្វមើលឃើញល់ហើយ អ្នកលាដៃស្តាំនាំចង្ក្រាញទៅតាន់នាងវិញ នាងគើបវិញ្ញដីតានាងថា មែនពិតដូចអញឮហើយ ដៃហៅទៅអ្នកប្រាជ្ញអើយ ស្តេចបុត្តីឲ្យទៅនាំចៅមកពីប្រទេសឆ្ងាយ ឥឡូវនេះចៅបំរើតើយល់ជាប្រការម្តេចទៅ នាងដណ្តើងអាថ៌ប្រាស្នាថាតែក្នុងចិត្តនាងឯងទេ រីតោងដំសត្វអ្នកដឹងក្នុងអាថ៌ប្រាស្នា នាងក្តាប់ដៃឲ្យព្រះអង្គនោះហោង ។ ទើបអ្នកតិតថា ម្នាលនាងដ៏អើយ តាំតអញបានប្តេជ្ញាខ្លឹងស្តេចហើយ លោកឲ្យយកអញមក ឥឡូវនេះ ស្តេចមិនទាន់ឲ្យទ្រព្យតិចតួចបានបរិច្ចូរទៅឡើយ ព្រះមហាសច្ចអ្នកស្រាយអាថ៌ប្រាស្នាតែក្នុងចិត្តឯងទេ ។ នាងគើបវិញ្ញដីតា នាងដឹងក្នុងអាថ៌ប្រស្នានៃព្រះមហាសច្ចហើយ នាងលើកដៃឡើងចាប់ក្បាលតាតា ហើយនាងឆ្លេចត្រែកឲ្យចៅមហាសច់នោះ ហើយនាងថា ដៃចៅមហាសច្ចនោះបើដូច្នោះ ចៅនឹងព្រួយល់ជាកម្លាំងណាយ ហេតុអ្វីកំចៅមិនបួសដូចអញនេះហ៊ុំ ។ ព្រះមហាសច្ចដឹងអាថ៌ប្រស្នាហើយ អ្នកយកដៃស្តាំបង្ហុនឯង ហើយអ្នកឆ្លេចត្រែកឲ្យទៅនាងគើបវិញ្ញដីតាវិញ ដោយអាថ៌ប្រាស្នាអ្នកតិតថា ដៃនាងអើយ អញនេះតប៉ុន្តែចិញ្ចឹមកូនប្រពន្ធច្រើន

ហេតុនេះហោង អញមិនបួសដូចនាងនេះ ។ ឯនាងកើរបរិព្វាជិកា
នាងក្តាប់ដៃ ដណ្តើងព្រះមហាសថជាគាថប្រស្នាស្រេចហើយ នាងទៅ
កាន់ថានលំនៅនាងវិញហោង ។ រីព្រះមហាសថអ្នកសំតែះលានាង
កើរបរិព្វាជិកាហើយ អ្នកទៅតាល់ស្តេចហោង ។ ឯនាងនន្ទាទេពីប្រកប
ន្ទូរស្រីវិលូកាតែងនឹងបម្រើនាង គង់នៅបង្អួចសីហបញ្ជរ នាងឃល់ន្ទូរអំ-
ពើអ្នកតាំងពីរដូច្នោះកូវ នាងចូលទៅកាន់សំណាក់នៃស្តេចហើយនាង
ទូលថាដូច្នេះ ឆេវ បពិត្រអម្ចាស់អើយ រីថៅមហាសថអ្នកប្រាជ្ញនេះ
ខឹងនាងកើរបរិព្វាជិកាមិនទេឡើយ ឥឡូវនេះសមគំនិតជាមួយនឹងគ្នាហើយ
បង្កើតជាសត្រូវនឹងអម្ចាស់ មានចំណង់ចង់ឃាតជាសម្លាប់អម្ចាស់នោះ
មិនទេឡើយ ។ រីព្រះបាទបុឡឹនីស្តេចមានបន្ទូលថា នាងអើយ ចើ
ដូច្នោះតើ នាងបានឃល់ឯងឯង ឬនរណាប្រាប់នាងហ៊ុ ។

មហាភ ឥរិព្វាជិកា បរិភុញ្ជិត្វា ថាសាធ
ទិតរន្តិ មហោសធំ ទិស្វា ហត្ថតលំ វិយ ទ្រលមណ្ឌលំ
វិយ ច សមំ កត្វា រញ្ជិ អត្តនោ ហត្ថកតំ
សង្កោសិតំ ហាត្តិ បសារេតិ . . . . .

នាងនន្ទាទេពីទូលថាដូច្នេះ មហាភ បពិត្រមហាភជអើយ
ឯនាងកើរបរិព្វាជិកានាងនាន់ចង្ហាន់ស្រេចហើយ នាងបុះអំពីប្រាសាទ
ទៅឃល់ថៅមហាសថ ហើយនាងថាអំពៅនៃស្តេចឯង ហាក់ដូចលុះ

កណ្តាប់ដៃនៃគាត់ហើយ ហាក់ដូចមួលអំណោះអំហាកគាត់នាចនឹងកូឲ្យ
លុះកណ្តាប់ដៃនៃអាត្មា នាងនឹងសោយរាជសម្បត្តិនោះឯងហោង ។
រីឯមហោសថសោត សំដែងអាការកាន់ជាវិលើយថា អំណើះបាន
ពីរបីថ្ងៃហើយ អញនឹងកាត់កយកក្បាលនៃស្តេចចុឡនីព្រហ្មទត្តរាជ ឲ្យ
លុះកណ្តាប់ដៃនៃអាត្មាអញហើយនឹងយករាជសម្បត្តិ ហេតុនោះនាង
គេរមែរញ្ជូជិតា នាងក្តាប់ដៃឲ្យមហោសថដោយអាចប្រស្នា នាងដឹ
តិតថា ហៃមហោសថអើយ ក្តីតែមិនកាន់ជាវិលុកស្តេចយករាជ
សម្បត្តិហ៊ុនៃ ទើបមហោសថ លាដៃនោះដោយគំនិតថា យក
សម្បត្តិនេះទាំងឆាយឲ្យបាននោះហោង ។ ទើបនាងដឹយកដៃស្ទាបក្បាល
នាងដោយគិតថា បើដូច្នោះនឹងកាត់ក្បាលហ៊ុនៃ ទើបមហោសថយកដៃ
ស្ទាបតបវិញថា នឹងកាន់ជាវិនៃតោះ យករាជសម្បត្តិប្រាកដមិនខ
ឡើយអម្ចាស់ ព្រះអង្គប្រហែសនឹងមហោសថឯណាបាន តួរអម្ចាស់
ឲ្យសម្លាប់មហោសថនោះឆាប់ ។ ទៅអេះ ស្តេចស្តាប់តាក្យនាងនូវខេ
ខួលដូច្នោះហើយ ទ្រង់ត្រេកអរថា នាមហោសថនេះ ពុំអាច
ដើម្បីនឹងខ្ចីស្តួតអញដូច្នោះឡើយ ថាបើដូច្នោះ អញលួងលោមដណ្តឹងនាង
គេរមែរញ្ជូជិតាលងមើលហ៊ុនៃ ។ លុះព្រឹកឡើងវិញ នាងគេរមែរញ្ជូជិតា
នោះ នាងទៅនាន់ស្រេចហើយ ស្តេចបួលទៅខៀបនាងគេរមែរញ្ជូជិតា
ទើបស្តេចបន្ទូលដណ្តឹងថា ហៃនាងគេរមែរញ្ជូជិតាអើយ នាងបានយល់

ចៅមហាសថហ៊ុះ នាងខូលវិញថា បពិត្រមហាកដអើយ នាថ្ងៃអម្បាលមិញ អញទាន់ស្រែចហើយ អញចេញអំពីខេះទៅដល់ក្រៅព្រះកដថាន អញបានយល់គាត់ហើយមហាកដ ។ ស្តេចបន្ទូលដណ្តឹងវិញទៀតថា បើអញបានយល់ដូច្នោះហើយ តើបានស្រដីនិយាយផងគ្នាថាអ្វីខ្លះ ។ ចៅហ៊ុះ ។ នាងគេរៀបរៀបាដំណាខូលថា បពិត្រមហាកដអើយ រីអញនឹងចៅអ្នកប្រាជ្ញ នឹងបានស្រដីនិយាយទៅមកកាន់គ្នានោះគ្មានឡើយមហាកដអើយ ចៅមហាសថនោះ ដោយអញឮគេថា គាត់ជាអ្នកប្រាជ្ញ ថាបើធម្មជាតិជាអ្នកប្រាជ្ញមែនពិតហើយ គាត់ដឹងអាចប្រស្នានៃអញនេះឯងអេះ ម្ល៉ោះហើយអញក្តាប់ដៃស្តាំនាំចេញទៅឲ្យចៅមហាសថនោះកន្ទងអាចប្រាស្នាថា ហៃចៅមហាសថអ្នកប្រាជ្ញ ព្រះចុតុប្បន្ន ស្តេចមានព្រះកដហឫទ័យស្រណុកត្រេកអរនឹងចៅ ឬមួយស្តេចមានព្រះហឫទ័យតុំស្រណុកត្រេកអរនឹងចៅ មួយទីសោត ញ៉ាំងស្តេចសង្រ្គោះអាស្រមរុណាចំញឹមរក្សានៃចៅ ឬមួយស្តេចតុំសង្រ្គោះអាស្រមរុណាចំញឹមរក្សានៃចៅហ៊ុះ ។ ចៅមហាសថលាដៃបង្ហាញមកអញវិញហើយគាត់ឆ្លើយវិញថា តាំតអញបានប្តេជ្ញានឹងស្តេចហើយ លោកឲ្យចៅអញមកវិញវិនេះ ហេតុលោកមិនទាន់ឲ្យទ្រព្យអ្វីមួយតិចតួចនោះហោងហើយអញយកដៃស្ទាបក្បាល ដោយកន្ទងអាចប្រាស្នាថាដូច្នេះ មួយទីសោតបើដូច្នោះ ចៅកុំព្រួយលំបាកធ្វើអ្វី ហេតុអ្វីចៅមិនបួសដូចអញ

នេះហ៎ះ ។ ចៅមហោសថគាត់ស្តាប់ផ្លែនោះក្នុងចិត្តគិតថា ដ្បិតនឹងចំភ្លឹមកូនប្រពន្ធអញច្រើន តប្បីដំណាក់នឹងបុត្រកំយោ គាត់ថាមិនបួសហេតុបន្តុះនោះហោង ។ ព្រះបាទបុប្ផនីមានព្រះបន្ទូលថា ម្នៃនាងកើបរត្នាដ៏ការអើយ ចៅមហោសថឃើលមានប្រាជ្ញាមែនពិតប្រមែចអេះ ។ អាម មហារាជ បថវីតលេ អញ្ញោ តាទិសោ បណ្ឌិតោ នាម នត្ថីតិ អាហ ។ នាងកើបរត្នាដ៏ការ្ចូលទៅមហាក្សត្រវិញថា មហារាជ បពិត្រមហារាជអើយ អើគាត់មានប្រាជ្ញាមែនពិត ដូចមហារាជថានោះហោង មហារាជនឹងស្រាវជ្រៀសរសៃអ្នកឯង អស់ពាំនឹងផ្ទៃក្រោមនេះក្តី នឹងមានអ្នកដទៃណាមួយ តប្បីហៅអ្នកប្រាជ្ញមានសតិបញ្ញាដូចចៅមហោសថនេះគ្មានឡើយ ។ ព្រះបាទបុប្ផនីព្រហ្មទត្តរាជ ស្តេចស្តាប់ពាក្យនាងកើបរត្នាដ៏ការហើយ ស្តេចលើកដៃសំពះហើយឲ្យដំណើរទៅគាន់ឋានលំទៅហោង ។ ឯនាងកើបរត្នាដ៏ការ កាលណានាងលាទៅហើយ រីចៅមហោសថអ្នកប្រាជ្ញអ្នកលាឡើងទៅគាល់ព្រះបាទបុប្ផនី ។ លំដាប់នោះ ស្តេចជណ្តឹងចៅមហោសថថា ម្នៃចៅអ្នកប្រាជ្ញ ញ៉ាំងចៅឲ្យបានយល់នាងកើបរត្នាដ៏ការហើយ ។ ចៅមហោសថទូលថា មហារាជ បពិត្រមហារាជអើយ អើអញខ្ញុំបានយល់គាត់ នាថ្ងៃអម្បាលម៉ានោះនានឹងតប្បីចេញអំពីព្រះរាជមន្ទីរអង្វាស់នេះឯង អញខ្ញុំបានយល់នាងកើបរត្នាដ៏ការ

នាងក្តាប់ដៃដណ្តើងជាអាចម៍ស្លាប ម្តេចក៏អញនឹងថាដូច្នេះ ទើបអញ
ស្រាយអាចម៍ស្លាបថាដូច្នេះ ។ ព្រះមហាសត្វត្រេ ស្តេចស្តាប់ពាក្យតោធ-
សត្វហើយ ស្តេចមានព្រះហឫទ័យនោះស្មោះសរត្រេកអរ ពុំមានសន្ទុះ
កង្វារនឹងតោធសត្វនោះដល់តិចឡើយ ចាប់ដើមអំពីថ្ងៃនេះទៅ ស្តេច
មកដំកល់ដំកើងនៃចៅមហាសថ ជាថានេះសេនាបតីធំទុតម ប្រសើរក្រៃ
លែងជាងសេនាបតីផង ហើយស្តេចបង្វែរអស់ក្រិត្យក្រមជាក្សត្រនោះ
ឲ្យទៅមហាសថឯងគ្រងហោង រីឯសស្តាធិការនៃព្រះមហាសថនោះ
រឹងរូងរុងរឿងឡើងប្រាកដមែនហោង រីព្រះមហាសថទ្រង់ព្រះតម្រិ-
ណាថា អ្នកស្តេចនេះអ្នកឲ្យយសស័ក្តិអញតេញចរំបូរពុំដែលដាច់ឡើយ
នាព្រះមហាក្សត្រនេះអ្នកឲ្យតំណែងសម្បត្តិអញច្រើនម្ល៉ះនេះ តែស្តេចផ្ញើ
ដោយជាតិត ឬស្តេចនេះមានបំណងនឹងចង់សម្លាប់អញអេះ ទើបស្តេច
នេះធ្វើអំណោយឲ្យដូច្នេះ នេះអញក្រមើនឹងដឹងជម្រិះស្តេចនេះ បើដូច្នេះ
ហើយគួរអញគិតឲ្យក្តៅខើបជាន់អេះ បើស្តេចនេះមានព្រះហឫទ័យ
ស្មោះសរត្រេកអរនឹងអញក្តី នោះមានព្រះហឫទ័យពុំស្មោះសរត្រេកអរ
នឹងអញក្តី ថាបើអញទឹងឲ្យដឹងព្រះហឫទ័យនៃស្តេចនោះហើយ លុះ
តែអញអាស្រ័យនឹងអ្នកដទៃនោះហោង ។ តេរីបរិញ្ញាតិកា
ញ្ញាណសម្បន្នា សា ឃតេកទុទាយេន ជាតិសន្តតិតិ
ចិន្តេត្វា ពហូនិ កន្ទុមាលានិ តហេត្វា បរិញ្ញ-

ដំណាយ អាត់សំ តង្វា តំ ប្ងវនេត្តា វង្ខិត្តា . . .

ព្រះមហាសត្វនោះ ទ្រង់ព្រះចិន្តាពិចារណាថា នាងតេរីបវិញ្ញ-ដំណនេះ ប្រកបទ្វៃក្រាដ្ឋានោះច្រើន អញក្រែងតាត់ដឹង។ ចាំយកលម្អិច តួរអញទៅដណ្តឹងតាត់ហោង ម្ល៉ោះហើយព្រះមហាសត្វអ្នកក្រាជ្ញ អ្នក ឃកនីទៅនូវខ្នែងជួបគន្ធមាលាក្តីផ្ការស្រេចហើយ ទើបលើលាទៅកាន់ ឋានលំនៅនៃនាងដីតេរីបវិញ្ញដំណោះ ទើបនាងដីបវិញ្ញដំណតង់ស្ងួនទៅ ហើយ ទើបអ្នកបូជាខ្នែងជួប ក្តី ផ្កា ស្វាមូ អ្នកក្រាបសំពះនាង តេរីបវិញ្ញដំណស្រេចហើយ អ្នកពិតពុទ្ធដីកាថា អយ្យេ បពិត្រអ្នក ដីតេរីបវិញ្ញដំណប្រសើរអើយ ព្រះបាទបុប្ផនីព្រហ្មទត្តពាជ ស្តេចតត រលឹកគុណអញខ្ញុំនេះ ចាប់ដើមអំពីថ្ងៃខ្ញុំបានស្រដីនឹងអម្ចាស់នោះមក អញ ស្តេចឲ្យយសសក្តិនៃអញខ្ញុំនេះច្រើនក្រៃពេក ឯខ្ញុំក្រែងបីដូចគេជ្រមុជ ប៉ុះក្នងទឹកជ្រៅ មួយសោត ខ្ញុំក្រែងស្តេចឲ្យយសអញដោយនូវសភាព ត្តិ ពុំដោយនូវសភាពត្តិ នោះខ្ញុំពុំដឹងឡើយ នាងដីតេរីបវិញ្ញដំណថា ចៅអើយ ចៅស្រដីពិកេះ។ គាប់ពេក បើដូច្នោះ អញនឹងតតនូវអាថិ ប្រស្នាមួយឈ្មោះ ខក្ខកេស្សនោះ នាត្រីកនេះឯង អញនឹងទៅព្រះ រាជមន្ទីរស្តេចនោះហោង ។ កិរ ដូចយើងភ្ជុំរៀង។ មក រដែម្រះ ចិត្តនៃនាងតេរីបវិញ្ញដំណ ត្រិះរិះតតនូវប្រតាដូច្នេះ មួយសោត គប្បី អញនូវធ្វើ។ ចាំយកលនឹងស្តេចថា ។ បមាដូចបុរសមួយជាឈ្មួញ តែង

ដើរជួញសំពៅផង អញនឹងលងដណ្តើងជាច្រើនស្មាទៅនឹងស្តេចនេះចន្តិចលងមើល ពោះស្តេចនេះមានព្រះហឫទ័យត្រេកអរស្មោះសរសោះនឹងចៅមហាសឋអ្នកច្រើនដូនេះក្តី ពោះយោចម៏ពុំមានព្រះទ័យត្រេកអរសោះនឹងចៅមហាសឋនេះក្តី អញនឹងឲ្យដឹងហោង ។ លុះព្រឹកឡើងនោះនាងដីតេរីបរិព្វាជិកាទៅឆាន់លើព្រះពាជមន្ទីរស្តេច កាលណារណ្តាប់ឆាន់តត្តិក្រឹត្យស្រេចហើយ នាងអង្គុយស្ងៀមនៅហោង ។ ភជាបិ តំ វន្ទិត្វា ឯកមន្តំ និសីទិ ។ ព្រះបាទបុព្វនីព្រហ្មទត្តពាជ ស្តេចបបួលទៅសំពះនាងដីតេរីបរិព្វាជិកា នាងក៏លួមមហាក្សត្រថា បពិត្រមហាពាជក្សត្រថ្លៃប្រសើរអើយ ពោះយោចម៏មហាពាជអ្នកមានព្រះហឫទ័យនោះស្មោះសរស្រណុកត្រេកអរសោះ នឹងចៅមហាសឋអ្នកច្រើនដូនេះមែនពិតហើយ អញនឹងដណ្តើងច្រើស្មាមួយនេះ តែងនឹងសំដែងកណ្តាលដំនុំអស់មហាជនទាំងឡាយ រីអំពើនោះមិនគួរស្រដីឡើយថា មហាពាជអើយ អញនឹងដណ្តើងមហាពាជ នាថានស្មាត់កំចាំងហើយ អញនឹងមហាពាជឲ្យដឹងច្រើតដូហោង ។ ឯព្រះបាទបុព្វនីព្រហ្មទត្តពាជ ស្តេចច្រើអស់មនុស្សម្នាមហាជនធំធាំងឡាយឲ្យចេញទៅក្រៅស្ងាត់ហើយ ទើបនាងដីតេរីបរិព្វាជិកាក្រាបទូលថា បពិត្រមហាពាជ បពិត្រសម្តេចមហាពាជអើយ អញនឹងដណ្តើងតាមច្រើស្មាអ្នកបន្តិចហ៎ ។ លំដាប់ នោះ ព្រះបាទបុព្វនី ស្តេចបន្ទូលថា

ហៃនាងកែវបរិព្វាជិកាអើយ បើនាងដណ្តើងអញ ។ ឧន្តែយច្រាបនាង ដោយទូដំណឹងដែលអញដើងនោះហោង ។ លំដាប់នោះ នាងកែវបរិព្វាជិកា សូត្រទូរបទគាថាជាបឋមទូច្រាស្នាមួយឈ្មោះ ខត្តវក្ខុស្ស នោះថាដូច្នេះ :

សាធេ ភោ ឧយ្យោមាជានំ សត្តដ្ឋំ ខុនកញ្ញាវោ
មនុស្សត្តលិមេសានោ ជានំ កណ្ហោយ្យ វក្ខុសោ
អនុបុព្ពំ កថំ ឧត្វា មុញ្ចេសិ ឧកវក្កតោតិ ។

មហោភាជ បពិត្រមហាភជអើយ អញនឹងទុបមាដូចព្រះអង្គ ស្តេចនេះឯងមួយ ហើយមានអ្នកចាំង ៦ គឺនាងខេរីព្រះកន្ធោង្គមហាភជ មួយ នាងនន្ទាខេមីព្រះអគ្គមហេសីមហាភជមួយ ៗលៗ ណាមន្ត្រីកុមារ សម្តេចព្រះអណុជមួយ ជនុសេកកុមារអាមាត្យសម្ងាញ់មហាភជមួយ អាចារ្យកែវវត្តព្រាហ្មបុរោហិតមួយ បើអ្នកចាំង ៦ នេះ ជិះសំពៅសោត ទៅកណ្តាលបក្រាំងមហាសមុទ្រខាយ ខត្តវក្ខុស្សអាកែវខ្ញីតតន្ទឹក មហិមានោះសោត ក៏តែងការកម្ចីការអំពីមនុស្សចាំងឡាយ ថាបើពុំឲ្យកម្ចីការវាឡើយ ក៏វាទឹងជាខ់តន្ទូចឲ្យលិចសំពៅនោះ តើនឹមហាភជ នឹងឲ្យនរណាមួយនោះជាអណ្តាប់វាហើយ អ្នកនឹងជោះចេញឲ្យរួចអំពីអាកែវខ្ញីតវាធ៌នោះហ៎ ។

តំ សុត្វា ភជា អត្តជោ យថា អជ្ឈាសយំ

កាថេន្តោ ឥមំ គាថមាហ ។ មហាសុត្រធំរាជ ស្តេចស្តាប់ពាក្យទាំងដីកេរបំភ្លឺដីកានោះហើយ ទើបស្តេចសំដែងដោយទូវអធ្យាស្រ័យនៃអាត្មា សូត្រជាបទគាថាដូច្នេះថា :

មាតរំ បឋមំ ទដ្ឋំ ភរិយំ ទត្វាន កាតរំ
តតោ សហាយំ ទត្វាន បញ្ចមំ ទដ្ឋំ ព្រាហ្មណំ
ឆដ្ឋាហំ ទដ្ឋមត្តានំ នេវ ទដ្ឋំ មហោសធ ។

ទាំងដីកេរបំភ្លឺដីកាអើយ បើដូច្នោះ អញនឹងឲ្យគ្គាយអញជាដើមហើយ ថាបើអាស័ក្សទើកវាអញខ្លៅនោះ លំដាប់អំពីនោះ អញនឹងឲ្យប្រពន្ធ ឲ្យប្អូន ឲ្យមិត្រសម្លាញ់ នឹងឲ្យព្រាហ្មណ៍ជាគំរប់ ៥ អំពីនោះទៅខ្លៅ អញឲ្យខ្លួនអញជាគំរប់ ៦ ឯចាមហោសថអ្នកប្រាជ្ញនេះ អញមិនឲ្យឡើយ ។

ឯត្តកេន អយំ បញ្ហោ និដ្ឋិតោ

បញ្ហានេះចប់តែប៉ុណ្ណេះ

ឯវំ ញាតំ បរិញ្ញដីកាយ រញ្ញោ មហាសត្តេ សុហទយត្តំ ។ ន បន ឯត្តកេនេវ បណ្ឌិតស្ស កុណោ ទាកោ អហោសិ ។ តេនស្ស ឯតទហោសិ ។

រំនាងដីកេរបំភ្លឺដីកាថា : ស្តេចនេះមានព្រះហឫទ័យទាំងនោះស្រណុកត្រកអរសាទរស្មោះសរនឹងចាមហោសថអ្នកប្រាជ្ញនេះ ដូចនឹងគ

អញ្ចឹងតែអម្បាលនេះឯង ហេតុស្តេចលើកគុណនៃមហាសេដ្ឋអ្នកប្រាជ្ញ
នេះប្រកដហោង ហើយឃើញគេស្តេចស្រែងថា អស់អ្នកទាំងអម្បាល
នេះបានគុណជាទោស ហេតុនោះហោង អញទើបស្រដីអំពីអ្នកទាំង
អម្បាលនោះ ដោយខ្លួនតើចាត់តគុណក្តី មានគុណក្តី ឲ្យប្បាស
កណ្តាលជំនុំនៃអស់មហាជនឆន្ទរាគឯណាយនោះហោង ។ នាងគេរ
បរិព្វាជិកាតតថា មហាក្សត្រនេះអ្នកសំដែងតែគុណខ្មៅមហាសេដ្ឋអ្នក
ប្រាជ្ញ ឯគុណខ្មៅដូចហាសេដ្ឋអ្នកស្នាដូនោះ ប្រកដដូចព្រះចន្ទ្រពេញ
បូណ៌មីនាកណ្តាលអាកាសមែនពិតដោយប្រការដូច្នេះឬម្តេចអេះ ហើយ
អញទើបដណ្តើងអាចប្រាស្នានេះនឹងស្តេចវិញទៀតមើលហ៎ះ ហើយនាង
គេរបរិព្វាជិកាថា មហារាជ បពិត្រព្រះសម្មតិទេពមហារាជអើយ
មហារាជបន្ទូលថា ទីឆ្ងល់ម្តាយជាមុនទោះ មហារាជ នាម៉ែហៅលោកជា
ម្តាយនោះជាអ្នកមានគុណច្រើន ឯមហារាជសោត បើនឹងយកអ្នកជវៃ
មកជាម្តាយនោះ មិនដូចម្តាយមហារាជឡើយ នាងគេរបរិព្វាជិកាថា
មហារាជអើយ ម្តាយអ្នកនោះសោត មានឧបការគុណធ្ងន់ច្រើនណាមហា
រាជ អញទើបសំដែងរៀបរៀងគុណព្រះមាតានេះ ហើយសូត្រជាបទ
គាថាតម្រង់ពីថា :

ទោសេ-តា ឥតេ ជ:ឧដ្ឋំ ច ធីយរត្តាឧុកម្ប៊ីតា
ជត្តិ តយិ បទុដ្ឋាសិ បឝ្ចិតា អត្ថឧសម្ប៊ិតំ

อญฺญำ ๓ยนิสำ กตฺวา ๓ฆา ตำ ปริโมจยิ
ตำ ตาทิสึ ตาฬาธนึ ขิปิสำ กณฺฐฆาฏึ
มาตรำ เตน โฆเสน ธฆฺฆาสิ ธกาสกฺขิ โฆตำ ๆ

ยมกาภาย ปติ๎ตรสมฺเย ยมกาภาเยน มฺยาย อนฺโต-
เคหสฺมึ ปติ๎ตรสมฺเย ปติ๎ตรา สทฺธึ ปาปกมฺมำ กโรนฺตี
ทิสฺวา ปุตฺตสฺส ปาปกมฺมโต นิวาเรตุกาเมน ปิตรา
ปุตฺโต ปาปกมฺมโต นิวาเรตพฺโพติ ๆ

(เอวมาทิ)

អ្នកជាតិនិយម

[វិចារណាកថា]

លោក ជេង ទ្រីវ តែងរៀបរៀង

ពាក្យថា « អ្នកជាតិនិយម » បើមិនបានពិចារណានឹងរំពឹងត្រិះរិះឲ្យដិតដល់ យើញដូចជាងាយប្រតិបត្តិសោះ មនុស្សមានសញ្ជាតិជាខ្មែរ ត្រូវនៅជាខ្មែរ មនុស្សមានសញ្ជាតិជាយួន ត្រូវនៅជាយួន មនុស្សមានសញ្ជាតិជាចិន ត្រូវនៅជាចិន ។ល។ មិនចាំបាច់តតែអ្វីតទៅទៀតឡើយ តតែតែរកស៊ីប្រមូលទ្រព្យធនឲ្យបរិបូណ៌ ខុតជាការស្រេច ។ តែផ្ទុយទៅវិញ អ្នកជាតិនិយម មិនត្រូវស្ថិតទៅជាអសកម្មឡើយ ឬមានសកម្មភាពដែរ តែកន្លែកងាកចេញពីវត្ថុបំណងដើម ។

សួរថាប្រតិបត្តិដូចម្តេច ទើបហៅថា « អ្នកជាតិនិយម » ពិតមិនមែន « អ្នកជាតិនិយម » ក្លែងក្លាយ ? ចំពោះរឿងនេះ អ្នកជាតិនិយមពិត ត្រូវមានភាតព្វកិច្ច ត្រូវមានការចាំបាច់ គឺថាត្រូវប្រឹងត្រូវតស៊ូ ត្រូវព្យាយាមអត់ធ្មត់ លុះត្រាតែជាតិរបស់ខ្លួនមានសេ្ថរ ។

ជាបឋម អ្នកជាតិនិយម ពេញចិត្តនឹងសប្បាយចិត្ត កន្លែការងារដោយស្តីនូវភាសាជាតិខ្លួន ទោះជាផ្លូវការក្តី ក្រៅផ្លូវការក្តី ។ ដែលពោលយ៉ាងនេះមិនមែនមានន័យថា ហាមផ្តាច់មិនឲ្យនិយាយភាសាបរទេសឡើយ ជាពិសេស កន្លែទូតសម្ព័ន្ធមិត្តនៃអង្គការសហប្រជាជាតិដែលភាសាត្រូវលើកយកមកថ្លែងទៅ ទីនោះមានកម្រិតចំនួន ។ អ្នកដែលមិនពេញចិត្ត

ខ្លះនិយាយភាសាខ្លួន ហើយនិយមតែភាសាបរទេស តាមការណ៍ពិត
មិនមែនជាអ្នកជាតិនិយមឡើយ ព្រោះសុភាសិតថា: សំវិសជាតិ « មារ
យាទសួត » ។

អ្នកជាតិនិយម តែញ៉ាំងគ្នាឲ្យសប្បាយចិត្ត ក្នុងការសិក្សាអក្សរ
សាស្ត្រជាតិរបស់ខ្លួន ក្នុងការអានសៀវភៅ សារពត៌មាន ទស្សនាវដ្តី
ក្បួនតម្រាផ្សេងៗ សរសេរជាអក្សរជាតិ ទោះបីអក្សរខ្មែរពិបាកគូស
ពិបាកសរសេរ ពិបាកកាច់ជ្រុង ពិបាកអានដូចម្តេចក៏ដោយ មានជាអាទិ
ដូចអក្សរកូមា អក្សរសំស្ក្រឹត អក្សរចិន ។ ចំពោះរឿងនេះ មិនមែនបដិ-
សេធជាច់ខ្សោះ នូវការសិក្សាទំនឹងការអានអក្សរបរទេសទេ តែគួរតែឲ្យអ្នក
ជាតិនិយម ទុកការសិក្សាទំនឹងការអានអក្សរបរទេស ជាជាន់ចុងក្រោយ ព្រោះ
ការរស់នៅក្នុងលោកមិនមែនមានតែជាតិមួយទេសទេ គឺមានច្រើនហើយ
ជាតិទាំងនេះ ត្រូវតែមានការប្រស្រ័យទាក់ទងគ្នា ដើម្បីញ៉ាំងសហប្រតិ-
បត្តិការឲ្យមានដណើរលឿនទៅមុខ តែអ្នកជាតិនិយមមិនដែលភ្លេចស្មារតី
បណ្តែតអារម្មណ៍ បណ្តោយខ្លួនឲ្យចំណាញ់ក្នុងអក្សរសាស្ត្របរទេសលើស
ខ្លួនឡើយ ដូចជាពស់លើសពីរដង្កៀបឬថ្នាន់លើសមាន់ឡើយ ។ អ្នកដែល
និយមតែអក្សរបរទេស អ្នកដែលនិយមតែអានសៀវភៅ ទំនឹងសារពត៌មាន
បរទេសថាពិភេរថាត្រឹមត្រូវ ថាប្រសើរ ព្រោះការនេះគឺតមកតែពីធ្វើ
ពីស្នេហា មិនមែនជាអ្នកជាតិនិយមដ៏ពិតប្រាកដឡើយ ។ ពាក្យ

ចំនៀមរោលថា : « ឃ្លានខ្លាញ់ ស្រេឡាញ់ល្ហុង » ។ ពាក្យចំនៀមមួយទៀតថា : « ដេកផ្ងួរល្ហុង រមួលផ្ងួរគ្រែច » ។

អ្នកជាតិនិយមស្រេឡាញ់ចូលចិត្តសំលៀកបំពាក់ដែលជាតិបានឆ្លាក់ប្រកាន់ខុសមកជាយូរយារណាស់មកហើយ ។ ដែលបរទេស គាល់ណាក្រឡេកឃើញ អាចសំគាល់បានថាជាតិនេះជាតិនោះ ។ ចំពោះជាតិខ្មែរ សំលៀកបំពាក់អាចចែកជាពីរបែបតាមភេទខ្លួន : ទី ១ ស្លៀកសំពត់ ពាក់អាវកុតកត្រង់ (ប្រុស) ស្លៀកសំពត់បង់ក្បាច ឬ សំឡុយ ពាក់អាវខ្លី (ស្រី) ទី ២) ស្លៀកខោដើងវែង (ខោចិន) ពាក់អាវដៃវែង (អាវចិន) (ប្រុស) ស្លៀកខោដើងវែង (ខោចិន) ឬ សំពត់ ពាក់អាវបំពង់វែង (ស្រី) ។

សួរថា ប្រសិនបើគេប្រើសំលៀកបំពាក់បែបអឺរុប តែចិត្តគំនិតនឹងការប្រព្រឹត្តរបស់គេដើម្បីជាតិពិត នឹងសន្និដ្ឋានថាគេមិនមែនអ្នកជាតិនិយមឬ ? អាចនឹងសន្និដ្ឋានថាជាអ្នកជាតិនិយមដែរ តែជាអ្នកជាតិនិយមមិនសូវសុទ្ធសាធ ។ អ្នកចិត្តសាស្ត្រតែងពោលថា ចិត្តជាម្ចាស់លើរូបកាយ ចិត្តតែងបញ្ជាកាយឲ្យធ្វើយ៉ាងនេះយ៉ាងនោះ ដូចព្រះចៅផែនដីទ្រង់ព្រះបញ្ជាមន្ត្រីសេនាបតីឲ្យធ្វើអ្វីមួយដូច្នោះដែរ គឺព្រះអង្គទ្រង់សព្វព្រះហឫទ័យហើយ ទើបទ្រង់ព្រះបញ្ជា : បានន័យថាចិត្តស្រេឡាញ់ហើយទើបឲ្យកាយធ្វើ ។ តួយ៉ាងដូចនៅប្រទេសកម្ពុជា ក្នុងព្រះពុទ្ធព្រះ

ម្ភូង ។ ជាគាត់ នៅព្រះបរមកដំង ព្រះករុណាជាអម្ចាស់ដីតែលើត្បូង ទ្រង់ព្រះបញ្ជាឲ្យនាម៉ឺនសព្វមុខមន្ត្រីប្រើសំលៀកបំពាក់ជាតិ ចូលក្រាបបង្គំគាល់ព្រះអង្គ នេះសឲ្យឃើញច្បាស់ថាព្រះអង្គជាអ្នកជាតិនិយមដ៏ពិតប្រាកដ ។

អ្នកជាតិនិយមស្រឡាញ់ទឹងពេញចិត្តបរិភោគទឹងប្រើប្រាស់វត្ថុណាជារបស់ជាតិ វត្ថុណាដែលជាតិបានបង្កើតឲ្យមានហើយ ពេញចិត្តទឹងវត្ថុនោះ ទោះជាមានគុណភាពទន់ខ្សោយជាងវត្ថុបរទេសក្តី ឯការនិយមបែបនេះនឹងផ្តល់ជល់ជាតិ នូវអត្ថប្រយោជន៍ដ៏ធំជាអនេកបា្រការទៅអនាគត ។ គួរឲ្យខ្មាសបា្រទេជូចនៅភ្នំពេញ ទឹងទីប្រជុំខាងជនបទ តាមការសង្កេត ខ្មែរភាគច្រើន និយមប្រើតែម្ហូបចំណីបរទេស(១) ។ អ្នកអានចាំងឮយអាចនឹងឆ្លើយថា : ទី ១ ព្រោះម្ហូបចំណីរបស់គេឆ្ងាញ់ពិសា ទី ២ ព្រោះគ្មានឃើញជាតិធ្វើអ្វីយកទៅដាក់លក់ដូចគេ ។ មែនពិតម្ហូបចំណីរបស់គេឆ្ងាញ់ប្រាកដ តែការឆ្ងាញ់ ការធ្វើឲ្យមានឧជារសនេះមកពីអ្វី ? ជាមកតែពីការធ្វើញឹកញយហើយមានការត្រឹមត្រូវផង ។ ភៅអីអត្តិយ គាលដែលអ្នកចាប់ផ្តើមធ្វើជាដំបូង មានតែដើងបួនទឹងក្តារមួយបន្ទះសម្រាប់អត្តិយប៉ុណ្ណោះ ចូរមើលឥឡូវ ភៅអីមានសណ្ឋានរូបរាងយ៉ាងណា ។ ដែលថាគ្មានគេយកមកលក់គឺត្រូវពិត តែបានជាគ្មានអ្នកណាជាលក់ តើមកពីហេតុអ្វី ? មកតែពីជាតិមិននិយម ។ តាម

---

១. មិនមែនជាចំអកហង្ការឡើយបរិភោគតែម្ហូបជាតិទេ តែគួរនិយមម្ហូបជាតិឲ្យច្រើន ។

ការសង្កេត ហើយគួរឲ្យទំកអៀនម៉្លាងខ្លៃតតីនៅពេលដែលមានទេសចរ
ពីបរទេស ចូលមកធ្វើកិច្ចទស្សនាម្តង ។ : តេចេញពីប្រទេសគេទៅ
ក្នុងប្រទេសដទៃ តើដើម្បីប្រយោជន៍អ្វី ? ដើម្បីចង់ដឹងវត្តដ៏ប្លែក ។ នៅ
ប្រទេសនោះ ។ ដូចជាទេសភាព ទំនៀមទំលាប់ម្ហូបចំណី ។ ល ។
បើអ្នកលក់ យកតែម្ហូបចំណីរបស់គេ លក់ឲ្យគេទិញតាន តើអ្នកទេស
ចរក៏ទិនីទឹកថាជូបម្តេចទៅវិញ ?

អ្នកជាតិនិយម ស្រឡាញ់ពេញចិត្តមនុស្សដែលមានសញ្ជាតិដូចគ្នា
អ្នកជាតិនិយម មានគោលគំនិតតែមួយគឺ ធ្វើយ៉ាងណាឲ្យជនរួមជាតិមាន
រសចក្តីចំរើន មានការថ្កុំថ្កើ មានកិត្តិយយខ្ពង់ខ្ពស់ អ្នកជាតិនិយមស៊ូ
ប្តូនឹងជនរួមជាតិរបស់ខ្លួន គឺថាបើមានកន្ទែងមួយប្រកបដោយប្រយោជន៍
ហើយមានបងប្អូនរួមជាតិម្នាក់ទិនិងជនបរទេសម្នាក់ត្រូវការ អ្នកជាតិនិយម
ស៊ូលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដោយប្រគល់កន្ទែងនោះទៅឲ្យបងប្អូន
រួមជាតិ ។ អ្នកជាតិនិយម ឃល់ឮស់ថា បើនិយមបរទេសជាងជាតិខ្លួន
ព្រោះតែអ្វីមួយនោះ ផលអាក្រក់នឹងធ្លាក់មកលើជាតិដ៏ពិតប្រាកដនៅអនា-
គត ។ គួរអៀនខ្មាស់ប្លែ ហើយគួរឲ្យអ្នកស្រុកអាចខុកចិត្តលើយើងទៅមុខបានប្លែ
បើបានចំណីអ្វីទ្វាញ់ យើងមិនរវ៉ែទៅបងប្អូនយើងបរិភោគ យើងត្រូវប្រាប់ជាឲ្យទៅអ្នកដទៃវិញ ? អ្នកជាតិនិយម បើ
យើញជាតិខ្លួនមានអាសន្ន រមែងជួយសង្គ្រោះឥតប្រកាន់ថាខ្លះ ។

អ្នកជាតិនិយមក្លែងក្លាយអើយ! កុំមានតណ្ហាចោលបន្ទុំក្តែង ។ ថាអញ «អ្នកជាតិនិយម» ខ្លាំងគេក ត្រូវរិះគិតឲ្យមែនទែន ហើយឲ្យចេះអៀនផង គ្មានន័យណាដឹងជាធំយើងដឹងខ្លួនយើងទេ ។

អ្នកជាតិនិយម គេញុចិត្តនឹងគោរពប្រតិបត្តិសាសនាជាតិរបស់ខ្លួន យកចិត្តទុកដាក់យ៉ាងមធ្យត្តចំពោះកម្មវិធីខាងសាសនាជាតិ បង្ហាញអាការយ៉ាងច្បាស់លាស់ ឲ្យដូចបរទេសឃើញនឹងក្អែក ថាខ្លួនជាអ្នកប្រកាន់សាសនាជាតិមែន អ្នកជាតិនិយមរមែងអនុលោមតាមទំនៀមទម្លាប់ខាងសាសនាជាតិ មិនយកទំនៀមបរទេសមកលាយឡំក្នុងតំណែសាសនាជាតិ រមែងមិនពោលក្នាស់តិះដៀល មិនពោលរិះគន់ចាក់រុកពេចឲ្យខ្ទេចខ្ទីសាសនាជាតិ អ្នកជាតិនិយមរមែងការពារយ៉ាងពេញទំហឹងនូវសាសនាជាតិ បើមានហេតុដទៃដ៏មិនសមរម្យចូលមកលុកលុយដោយមានវត្ថុបំណងដើម្បីលិបអត់ពណ៌ ។

តាមការសង្កេតយ៉ាងយូរខែដ៏ហ្មត់ចត់ សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ព្រះអង្គជាគំរូលខាងអ្នកជាតិនិយម សូមពិនិត្យមើលចុះ គ្រប់វិស័យជាតិទាំងអស់ព្រះអង្គទ្រង់ប្រកាន់យកគ្មានសល់ចន្លោះត្រង់តែខ្លួនឯណា : ព្រះអង្គចេះពោលការសាជាតិយ៉ាងពូលំពូលាយ តក្សរសាស្ត្រជាតិនឹងវប្បធម៌ជាតិគ្រប់ផ្នែក ព្រះអង្គចេះធើតធុតការរិះគន់ ព្រះអង្គទ្រង់ព្រះភ្នែស ព្រះអង្គ

ចេះទេសនាស្អាតជាងធម្មកថិកជាច្រើនដែលធ្លាប់មានមកល្បី ព្រះអង្គទ្រង់ស្ថិតនៅក្នុងអនាគតភាព ចំពោះសាសនាជាតិ ។ គួរឲ្យអៀនខ្មាស់ប្លែកបើមានតិចជាងសាសនាជាតិម្ជុល ។ ខ្លួនដែលប្រកាសខ្លួនថាជាអ្នកជាតិនិយម ហើយប្រកាសថាខ្លួនមិនចេះខំនៀមទាំងសាសនារបស់ខ្លួនទៅវិញ ។

អ្នកជាតិនិយម រមែងគោរពព្រះពុទ្ធបល្ល័ង្កជាតិ ពុកព្រះពុទ្ធបល្ល័ង្កជាទីសក្ការៈបូជាខ្ពស់ជ្រុតចាកការរិះគន់ អ្នកជាតិនិយមប្រកាន់ពុកព្រះពុទ្ធបល្ល័ង្កជានិមិត្តរូបរបស់ជាតិ លើកតំកើងពុកព្រះពុទ្ធបល្ល័ង្កជារូបរបស់ជាតិដែលគ្រប់តែមនុស្សត្រូវគោរពមិនបាន អ្នកជាតិនិយមរមែងការពារព្រះពុទ្ធបល្ល័ង្កជាតិពុកដូចជាប្រស្រីក្អែករបស់ខ្លួន ពុកព្រះពុទ្ធបល្ល័ង្កជាដំបែជាមេស្អា ជាស៊ុមឆ័ត្រជាតិ ។

អ្នកជាតិនិយមក្លែងក្លាយ ត្រូវពុកជាខេវខ្ពត់ជាតិ ពុកជាឆៃជាតិ ពុកជាសង្កើចជាតិ ពុកជាមួសជាតិ ពុកជារុយជាតិ ពុកជាដង្កូវដួងជាតិ ពុកជាក្រាជាតិ រួមសេចក្តីពុកជាអ្នកបំផ្លាញជាតិ ដូចជានាលិកាលើ ហើយនៅតែដើរចង្អុលជ្រុលប៉ោងជល់បណ្តាជន ។

តើឲ្យអ្នកជាតិខ្មែរគោរពនឹកម្ចាយខ្លួនដូចម្តេចកើត បើខ្លួនដែលជាកូនមិនចាំងរលៀគោរពផង ? ជាតិ សាសនា ព្រះពុទ្ធបល្ល័ង្ក ពុកជានឹកម្ចាយនៃអ្នកជាតិនិយម ។ ដូច្នេះ ចំពោះរឿងនេះ អ្នកជាតិនិយម គួរតប្បីតែស៊ូដោយសុខន្ធនៈទើងដោយការអត់ធ្មត់ ។

ប្រវត្តិ ខែត្ត កំពង់ ចាម

ស្រាវជ្រាវដោយ ឧ - ឆាម

ខ្ញុំសូមជូនប្រវត្តិខែត្រកំពង់ចាមនេះ តាមសេចក្តីស្រាវជ្រាវរបស់ខ្ញុំ ខ្ញុំមិនមែនចង់សរសេរតទល់លោកអ្នកអាន ឲ្យសព្វគ្រប់គាំងពីកិច្ចការគាត់ខងនឹងរាជការទេ ខ្ញុំសូមបញ្ជាក់ត្រង់តែឈ្មោះថាកំពង់ចាមប៉ុណ្ណោះ។

តាមពាក្យបរម្បាថា កំពង់ចាមជាកំពង់របស់ចាម តែយើងមិនដឹងថាតើកំពង់របស់ចាមសំកប់មុនខ្មែរ ឬក៏កំពង់របស់ចាមសំកប់ខេសាទ ។ រឿងនេះ គួរឲ្យយើងចង់ដឹងដែរ ដើម្បីឲ្យដឹងពីតន្ទរឈ្មោះខែត្រនៃប្រទេសកម្ពុជាដូចយ៉ាងកំពង់ចាមជាដើមនេះ ។ តើខែត្រកំពង់ចាមជាកំពង់របស់ចាមមែនឬក៏មានឈ្មោះដូចម្តេចទៅវិញ ។

ចំពោះរឿងខែត្រកំពង់ចាមនេះ ខ្ញុំសូមជូនយោបល់ដូចតទៅនេះ៖

១ – តាមផែនទីដែលលោក ម៉ាក់សេលនេរ (Marcel Ner) និយាយអំពីចាមនៅកន្លែងប្រទេសឥណ្ឌូចិន លោកបានបង្ហាញតាមផែនទីថា នៅប្រទេសកម្ពុជា ចាមច្រើនទៅក្នុងភូមិគ្រា ស្រុកក្រូចឆ្មា ខែត្រកំពង់ចាមសព្វថ្ងៃ ទីណាគ្រាយចង្វា ។ ក្នុងនឹងពីរនេះហើយដែលមានមជ្ឈមណ្ឌលសាសនាមូយស៊ុលម៉ង់ (អស្លាម) ច្រើន Centre spirituel musulman ត្រង់ខែត្រកំពង់ចាមសព្វថ្ងៃនេះក៏មានចាមដែរ តែមិនសូវច្រើនទេសម័យនោះ ។ ដូច្នេះពាក្យបរម្បានេះ គឺអាចសន្និ-

ដ្ឋានបានដែរ ព្រោះថាមានភូមិខ្លះគេហៅថាភូមិចាមដែរ ព្រោះចាមនៅច្រើន ប៉ុន្តែថាតាក្យបរម្បាកដូចជាកលាយលក្ខណអក្សរគ្មាន ។ មុនទីដែលសន្និដ្ឋានយកឈ្មោះនេះថាជាត្រឹមត្រូវ យើងសូមសង្កេតនូវន័យខាងក្រោមនេះសិន ។

២ - តាមយោបល់បូដ្វាំង (Baudoin) ក្នុងសៀវភៅ Monographie de Kampong-Cham ថាខេត្តកំពង់ចាមនេះ គឺ កំពង់រងចាំ « rive où veille la garde » (១) ។

៣ - លោកម៉ាដ្រូល (Madrolle) ថា លោកបានធ្វើដំណើរមកប្រទេសកម្ពុជា ហើយគាត់បានសរសេរសៀវភៅមួយថា « មគ្គុទ្ទេសរបស់ម៉ាដ្រូល » (Guides Madrolle) លោកបានសរសេរថា ខេត្តកំពង់ចាម ពីដើមឈ្មោះថា កំពង់ចាំ ។ ចេះឈ្មោះនេះ លោកម៉ាដ្រូលថាកំពង់ចាំ តើគេចាំអ្វី ? ត្រង់នេះ លោកថាគេ ចាំសាឡាងឆ្លងទៅទន្លេបិទ ធឹងកំពង់ចាម (Kompong-cham, le quai d'attendre du bac (២) ។ កន្លែងដែលគេចាំឆ្លងសាឡាងគឺទៅត្រង់ថ្ម ។ រឿងនេះ ដូចជាសមព្រោះថាសព្វថ្ងៃនេះក្តី ពីអតីតកាលក្តី មនុស្សជាច្រើនទៅរង់ចាំឆ្លងដសាឡាងរាល់ក្រឹងទន្លេបិទ ធឹងកំពង់ចាម ។

---

១ - Circonscription de Kompong cham ទំព័រ ១

២ - Guides Madrolle ទំព័រ ១៦៧ ។

៤ - តាមឯកសារបស់លោក កែវ-ហង្ស ចាងហ្វាងវិស្រែតយ៉ុំសួង ស្រុកតួងយ៉ុំ ដែលមានតំកល់នៅក្រុមទំនៀមទំលាប់ថា កំពង់ចាម ពីដើមគេហៅថា « កំពង់ប៉ាំ » ។ តាមសេចក្តីដំណាលនៃឯកសារនេះថា កំពង់នេះ គេមកចាំដង្អែស្តេចបស្ចិមក្រុងធ្វើត្រើយខាងកើត ។

បើយើងយកឯកសារបស់លោក កែវ-ហង្ស មកប្រៀបធៀបនឹងលោកម៉ាជ្រូល យើញថាស្របគ្នា មានខ្លះគ្នាបន្តិចបន្តួចតែត្រង់:

ក) លោក កែវ-ហង្ស ថា ចាំដង្អែស្តេចបស្ចិមក្រុងធ្វើត្រើយខាងកើត ។

ខ) សៀវភៅ circonscription de Kompong cham ថាកំពង់រនាំចាំ

គ) លោកម៉ាជ្រូលថា. ចាំធ្វើសាឡាងទៅវិញទៅមក ។

ពាក្យថាចាំធ្វើនេះ យើញថាស្របគ្នា ។ លោកចាំងប៊ីរូបនេះមិនបានន័យយល់សាសន៍ចាមសោះ យើញន័យយកតែសាឡាង បស្ចិមក្រុងធំងាំ ។

៥ - នេះជាយោបល់របស់ខ្ញុំ ។ រឿងខែត្រកំពង់ចាមនេះយើងបានពិនិត្យទៅតាមផែនទីភូមិសាស្ត្រ ដូចទៅហើយយើងបែរមកពិនិត្យតាមអក្ខរាវិទ្យាម្តង ។ ខ្មែរយើងពីដើមសរសេរច្រើនតែខ្ជិលបន្តិច ដូចយ៉ាងទៅសិលាចារឹកនគរវត្ត ខ្ញុំសូមជូនពាក្យខ្លះ « កុំប៊ីមាង » សរសេរថា « កុំម្បីមាណ » ។ ខ្ញុំ » គេសរសេរថា « ខ្ញុំម » យើញថាគេ

ចូលចិត្តមានទិគ្គហិតហើយនៅតែធ្វើតម្រកបទនឹង «ម» ទៀត ។ ពាក្យថា កំពង់ចាម នេះក៏មានតម្បាន:ម ដែរ ហើយនៅសិលាចារឹកនគរវត្ត មានពាក្យមួយ «បាំ» សរសេរថា បាំម្ម ។ ភាហរណ៍ (១) ខ្ញុំសូមកុំល្មាំង អនុភាព្យបែកខ្លាំង លើសសាសឆុតបាំម្ម ដូចព្រះវេនុមាន . . . ។ ដូច្នេះពាក្យថា បាំ គេអាចសរសេរបានថា បាំម, បាំម្ម, បាំម្ម បាម់ ។ ភាហរណ៍ថា បាម់ មានបន្ទុក់នេះដែលអានថាបាំ បានដែរ ជាហេតុមួយដែលនាំឲ្យច្រឡំនឹងពាក្យថា សាសន៍បាម ប៉ែសិនណាជាគេសរសេរគ្មានបន្ទុក់ ។ តែពាក្យថាបាំ គេសរសេរមិនឲ្យប្រកបនឹង ម ទេ តែថាសម័យមុនសរសេរមានៅហើយ ដូច្នេះបានជាពាក្យថាកំពង់បាំ ទៅជាកំពង់បាមទៅវិញ ។

តារាត្រែះរ៉ែះពីខាងអក្ខរាវិរុទ្ធ យើញថាលោកម៉ាជ្រូលក្តី សៀវភៅ circonscription de kg-cham នឹងឯកសាររបស់លោក កៃ-ហង្ស ក្តីយើញមានន័យស្របគ្នា ដូច្នេះខែត្រកំពង់ចាម យើងអាចសន្និដ្ឋានបានថាកំពង់បាំ ។

មតិខ្ញុំ មិនចង់ឲ្យកែឈ្មោះខែត្រកំពង់ចាមមកជាកំពង់បាំទេ ហេតុដែលឲ្យខ្ញុំយកឈ្មោះខែត្រនេះមកជូន ព្រោះខ្ញុំចង់ឲ្យលោកអ្នកអានជ្រាបខ្លួឈ្មោះខែត្រនេះឲ្យច្បាស់លាស់ខ្លួប្រវត្តិដើម ។ ប៉ែលោកអ្នកអានមានយើញប្រវត្តិឈ្មោះខែត្រនេះច្បាស់ ហើយមានជាលាយលក្ខអក្សរផង សូមសរសេរជូនតាមានៅក្រុមចំខៀមទម្ងាប់ខ្មែរនៅក្រសួងធម្មការ ។

១- សិលាចារឹកនគរវត្ត ទំព័រ ១០៩ ។

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហាទ័ន-ខាត់ រៀបរៀន

(តមក)

អធម៌មយ គុ. ដែលសម្រេចហើយដោយអធម៌ ។

អធម្យ គុ. ដែលមិនប្រកបដោយធម៌ ដែលវិសភាគ ។

អធម៌ណ នបុ. កិរិយាមិនចូលទៅជិត កិរិយាមិនចូលទៅប្រយុទ្ធ ។ គុ. ដែលមិនចូលទៅជិត ដែលមិនចូលទៅប្រយុទ្ធ ។ អធម៌ណិយ គុ. ដែលមិនគប្បីចូលទៅជិត ដែលមិនគប្បីចូលទៅប្រយុទ្ធ ដែលមិនគប្បីចូលទៅជាន ។

អធស អវ្យ ក្រោម ខាងក្រោម នៅដី ។ អធះ ក្ប ក្នុង ។ – ករណ នបុ. កិរិយាធ្វើឲ្យនៅខាងក្រោម កិរិយាចាញ់ ។ – កាយ បុ. កាយឯជិខាងក្រោម ។ – ក្រិយា ស្ត្រី. កិរិយាធ្វើឲ្យដាខាងក្រោម កិរិយាមើលងាយ។ – ទេន នបុ. កិរិយាដឹកឯជិខាងក្រោម កិរិយាកប់ក្នុងដី ។ – ភន គុ. ដែលដាខាងក្រោម ។ – តល នបុ. ផ្នែកឯជិខាងក្រោម ភាគខាងក្រោម ។ – តាត ឯជិខាងក្រោម ។ – តាទ្ទិត ស្រី ទឹកខាងក្រោម ។ – តាល្បណ៌ គុ ដែលមានលក្ខណៈខាងក្រោម ។ – ជាត បុ. កិរិយាធ្លាក់ចុះឯជិខាងក្រោម កិរិយាទល់ឯក ។ – អយ្យ គុ. ដែលដេកឯជិខាងក្រោម ដែលដេកលើផែនដី ។ - ឯយ្យ ស្រី កិរិយាដេកឯជិខាងក្រោម កិរិយាដេកលើផែនដី ។ – ឧទ គុ. ដែលមានមែកទោរទៅខាងក្រោម ។ – តាយិន គុ. ដែលដេកឯជិខាងក្រោម ដែលដេកលើផែនដី ។ តិរស៊ី តីមិ គុ. ដែលមានក្បាលឯជិខាងក្រោម

ដែលមានក្បាលសំយុង ។ – ស្ត គុ. ដែលឋិតនៅឆ្នងខាងក្រោម ។ អធគ្ឃ គុ. ដែលប្រព្រឹត្តទៅឆ្នងខាងក្រោម ដែលប្រព្រឹត្តទន្ទលំទោន ។ អធគ្ឃណាវិបាត ប៉ុ. កិរិយាធ្លាក់ចុះដោយកិរិយាប្រព្រឹត្តទៅឆ្នងខាងក្រោម កិរិយាចូលទៅត្រែកក្រោមម្ខាងនៃដងនាំមួយ ។ ។ អធោ ល្បង ប៉ុ ដែលកើតខាងក្រោមនៃដុំរទេះ ឬ ? តាមព្រះក្រឹម្ត តាមព្រះវិន្ត ។ អធោង្គ នប៉ុ ទ្វារធំ – គត គុ. ដែលទៅឆ្នងខាងក្រោម ដែលចុះ ដែលទន្ទលំទោន ដែលស្ងាប់ ។ – គតិ ដំណើរទៅឆ្នងខាងក្រោម កិរិយាចុះ កិរិយាធ្លាក់ កិរិយាទៅកាន់នរក ។ ដ៏ហ្វឹក ស្ត្រី អណ្តាតឆ្នងខាងក្រោម កន្ទើត ។ – ទ្ធ ស្ត្រី កិរិយាយល់ឃើញឆ្នងខាងក្រោម សេចក្តីយល់ច្រេង ? ។ - ទ្វារ នប៉ុ. ទ្វារឆ្នងខាងក្រោម ទ្វារធំ ។ – ភាគិ គុ. ដែលមានឆ្នងខាងក្រោម ? ។ - ឥលយ ប៉ុ. ទីលំនៅឆ្នងខាងក្រោម នរក ។ – បវ នប៉ុ ទ្វារធំ ។ ភាគ ប៉ុ. ភាគឆ្នងខាងក្រោម ។

អធិគមនីយ គុ. ដែលគប្បីដល់ ដែលគប្បីបាន ដែលគប្បីសម្រេច ដែលគប្បីរៀន។

អធិគា ក្រ. នៅក្រៃលែង ចូលដៃ ដោះ សង្ស័យ សិក្សា អាន ។

អធិគុណ គុ. ដែលមានគុណក្រៃលែង ដែលមានគុណច្រើន ។

អធិគូហាមិ ក្រ. វិ នៅក្នុងផ្ទះ ។

អធិគ្រីវមិ ក្រ. វិ ឆ្នងក ។

អធជដិន ក្រ. កើតក្រៃលែង មកពីនំលោក ។

រឿងសាមកុក

ទកញ្ចាំបុលពជសេនា ន្ធ-ភក ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទំនៃបេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាផង ។

ឃ្លោ-អ៊ុន

តាហានទាំងពួនដំកបថា កាលលោកបែកទ័ពត្រឡប់មកពីក្នុងស្នាមចម្បាំងនោះ ខ្ញុំបាទឃើញនឹអ៊ីនឹងឡៅកុយលើកទ័ពដំនូនដូនចេញពីស្រុកឡុកសៀ រាយត្រឡប់ខ្លួបពីក្រោយ អ៊ុយអៀនហាន់តុងនៅក្នុងចំណោមបានប្រយុទ្ធគ្នាជាចលាចល ហានតុងអ៊ុយអៀនលើសកម្លាំងធន់ពុំបានក៏នាំគ្នារត់ទៅទិសខាងកើត ខៀវហ៊ុយឮដូច្នោះក៏និយាយទឹងឡៅពីថា នឹងស្មៀមនៅពុំបានទេ ត្រូវតែលើកទៅជួយ សូមឲ្យលោកលើកទៅខាងស្តាំ ខ្ញុំបាទលើកទៅខាងឆ្វេង រាយខ្លួបប្រសព្វគ្នា ឡៅពីយល់ត្រូវដែង ក៏លើកតាហានចេញចាកបន្ទាយ ព្រែកគ្នាទៅជាមួយទឹងខៀវហ៊ុយម្នាក់ ១ ផ្លូវ ឯងឹអ៊ីឡៅកុយដែលលើកតាហានត្រឡប់ខ្លួបហាន់តុងនឹងអ៊ុយអៀននោះ បានឮសម្លេងតាហានឡៅពីទឹងខៀវហ៊ុយស្រែកហៅ

គឺកងរំតង ដួលទៅក៏ស័យណាស់ ដំឆងថាកងទ័ពខ្មៅតាំលើកទៅខ្លួចំ
ស្លាក់ផ្លូវទីឆងទៅក៏ពុំបាន ទើបនាំគាហានវះតាមផ្លូវត្រឡប់តេចូលទៅកងស្រុកវិញ ខ្មៅតីទីឆងខ្មៅហ៊ុយក៏បង្ខំដេញគាហានឲ្យស្រុតតាមផ្លូវទៅ ។

ឯដំឡាន់ លុយតង មិនគាន់ដឹងខ្លួនថា ខ្មៅតី ខ្មៅហ៊ុយលើកមកពីក្រោយ ក៏លើកគាហានស្រុតទៅដើម្បីទីឆងខ្លួចាប់យកខ្លួនហាងតុងទីឆងអ៊ុយអៀនឲ្យបាន បាងតុងទីឆងអ៊ុយអៀន ដួនជាគាល់ខ្លួនណាស់ កំត្រឡប់សេះដេញគាហានចូលតយុទ្ធទីឆងដំឡាន់ លុយតងទទួលខ្មៅតីខ្មៅហ៊ុយលើកទៅភាន់តីក្រោយក៏ឆយខ្លួចប្រសព្វគ្នា ដំឡាន់ លុយតងក៏ទៅកងចំណោមទ័ពដែលខ្លួចនោះ ឃើញលើសកម្លាំងទីឆងតពុំឈ្នះ កំចុះតីលើសេះនាំគាហានតាំងតស់ចូលទៅតំនាច់ខ្មៅតីស៊ុចំណុះចុះចូល ខ្មៅតីកំទទួលយកទុកធ្វើការជាមួយ ទើបចាត់គាឲ្យគាហានរៀបតាំងកធ្វើបន្ទាយជាប់គ្នាទីឆងស្រុកឡុកសៀតីទិសខាងកើត ។

ខ្មៅយីមដឹងថា ដំឡាន់ លុយតងចុះចូលទៅនៅខាងខ្មៅតីហើយ កំកើតខ្លុកក្តៅកងចិត្ត ទើបប្រឹក្សាគ្នាទីឆងងឺអ៊ុ ខ្មៅកុយ ខ្មៅឈុនថា ឥឡូវដំឡាន់ទីឆងលុយតង ចូលទៅនៅខាងខ្មៅតីហើយ សត្រូវកំចូលមកតាំងប្រកិតគ្នាខល់ទីឆងដើងកំផែងដូច្នេះ យើងទីឆងស្មៀមនៅម្តេចបាន ត្រូវតែមានសំបុត្រប្តឹងទៅដល់ខ្មៅដៀងសុំកងទ័ពមកជួយ ហើយយើងទីឆងចំ-បែកគាហានលើកចេញទៅវាយកុំឲ្យសត្រូវតាំងខ្លួនបាន ដំអ៊ុខ្មៅកុយ

ខ្លៅឈ្មុនតិយល់តាម ។

ខ្លែវយឹមទើបតែងសំបុត្រឲ្យចំរើតាន់ទៅដល់ខ្លៅដែរ ហើយនិយាយទឹងខ្លៅឈ្មុនថា វេលាព្រឹកនេះ យើងលើកតាហានចេញទៅច្បាំងនឹងខ្លៅពី រួចធ្វើជាចាញ់ប្រៀបរត់ថយក្រោយតាមដើងកំផែងទៅទិសខាងដើង ឲ្យងំអ៊ូលើកតាហានចេញទៅពួនបង្កប់ស្ពាត់ផ្លូវខាងទិសនោះ ថើយើញតាហានខ្លៅពីដេញតាមទៅ ឲ្យនាគ្នាចេញមកស្ទាក់ផ្លូវវាយប្រសព្វគ្នា តាហានខ្លៅពីមិនខាន់ដឹងខ្លួនក៏ងឹងបែកចាក់ទៅឯងយើងនឹងបានជ័យជំនះដោយងាយ ឯខ្លួនខ្លៅកុយនោះ ត្រូវឲ្យទៅរក្សាស្រុកជាមួយនឹងខ្លួនអ្នក ជួយគ្នាត្រួតត្រារក្សាតាហានវេលាយាមល្ងាតកុំប្រមាទឡើយ លុះចាត់ការស្រេចហើយ ដល់ពេលព្រឹក ខ្លែវយឹមក៏លើកតាហានស្រែកហៅចេញពីក្នុងស្រុកទៅ ។

ខ្លែវហ៊ុយឃើញខ្លែវយឹមចេញមក ក៏លើកតាហានចេញពីបន្ទាយឲ្យចូលច្បាំងប្រយុទ្ធគ្នានឹងតាហានខ្លែវយឹមជាច្រូលច្របល់ ខ្លែវហ៊ុយបរាសេះចូលតនឹងខ្លែវយឹមបាន ១២ ក្បែង ខ្លែវយឹមធ្វើជាថយរត់ខ្ជិនដើងកំផែងទៅខាងដើង ខ្លែវហ៊ុយតំបន់ជាយសេះស្ទុះតាមដោយកម្លាំងរហ័សដ៏អ៊ូនឹងតាហានដែលបង្កប់ទៅនោះ លុះឃើញខ្លែវហ៊ុយហួសទៅឯលំក៏ចេញស្រមកស្ទាក់ពីក្រោយ ខ្លែវយឹមក៏ពាត្រឡប់ពីមុខមកត ចោមព័ទ្ធខ្លែវហ៊ុយទៅកណ្តាលចំណាម ចោមចាញ់នឹងធ្លាប់ពីមុខពីក្រោយទ្វេនស្ទាំ

ខៀវហ៊ុយនៅកន្លែងចំណាមទ័ព មិនដឹងនឹងធ្វើប្រការម្តេច ទេះតែយកលំ
តែងត្រាស់ហៅព្រួញដុំវិញខ្លួន ខ្លួលជូឡុងលើកទ័ពចូកមកដល់ ក៏លើក
ទាហានខ្លីងគោក ស្រូតៗដួយខៀវហ៊ុយក្នុងមួយរំពេចនោះ រាយ
ឈ្លាយទ័ពងឺអ៊ូតិក្រោយ ចូលទៅកាប់សម្លាប់ទាហានជាច្រើនណាស់
ដែលសល់តិស្ងាប់នោះក៏បែកខ្ចាត់ខ្ចាយអស់ទៅ ជូឡុងក៏ចាប់ខ្លួនងឺអ៊ូបាន
ខៀវហ៊ុយ បានការកំបាំងចូលជាច្រើនប្រមល់កាប់សម្លាប់ទាហានខៀវ-
យីមបែកត់ចូលស្រុក ។

ខៀវហ៊ុយឃើញជូឡុងក៏សួរថា ឥឡូវខុងបេងទៅឯណា ជូឡុង
ប្រាប់ថា ខុងបេងមកដល់ហើយ កំពុងអង្គុយនិយាយនឹងខ្លៅតិ តែខ្លួន
ខ្ញុំលើកតលមកជួយអ្នក ខៀវហ៊ុយនឹងជូឡុងក៏មានសេចក្តីរីករាយនឹងគ្នា
បបួលគ្នានាំយកខ្លួនងឺអ៊ូមកបន្ទាយ ឃើញខុងបេងអង្គុយសន្ទនានឹងខ្លៅតិ
ខៀវហ៊ុយក៏ចូលទៅគំនាប់ ខុងបេងសួរថា អ្នកឯងធ្វើម្តេចបានជាមក
ដល់មុនយើង ខៀវហ៊ុយក៏ពណ៌នាឲ្យខុងបេងស្តាប់តាមរឿងដែលបាន
ធ្វើការច្បាំងរៀងមកគ្រាមផ្លូវគ្រប់ប្រការ ខុងបេងក៏និយាយនឹងខ្លៅតិថា
ខៀវហ៊ុយនេះតិដើមមកមានចិត្តភាចសាហាវណាស់ ឥឡូវហេតុម្តេចក៏
ចេះមកម្ងាប់ចិត្តបាន ស៊ីយកពាជការជាប្រមាណ ដែលចេះអត់ចិត្តបាន
យ៉ាងនេះតិព្រោះបុណ្យសោភជាប្រធាន ។

ខណៈនោះជូឡុងក៏នាំយកខ្លួនងឺអ៊ូចូលទៅជួនខ្លៅតិ ។ ក៏សួរថា

ខ្ញុំអ្នកនៅក្នុងឃុំកណ្តាប់ដៃយើងដូច្នេះហើយ ខឹងចំណុះចុះចូលឬទឹងតតាប្រកាន់ម្តេច ងឹមុឺឆ្លើយថា ខ្ញុំខ្ញុំជាខ្ញុំលោកជាប់យកមកនៅក្នុងអំណាចលោក ខ្ញុំជាខ្ញុំសុំនៅជាខ្ញុំលោក ថាហើយក៏ខុនតំនាប់តាមប្រពៃណីល្បើតីជានយើញដូច្នោះ ក៏ចុះទៅស្រាយចំណងចេញពីខ្លួនងឹមុ ខុងបេងក៏សួរទៅទៀតថា នរណាដែលនៅក្បាស្រុកខ្លួកសៀនោះ ងឹមុឺឆ្លើយថា ល្បើឈ្មោនជាបុត្រល្បើដៀងមកនៅឈរក្បាស្រុក ឯជាហានមានតែល្បើកុយនឹងខ្លៃយើម ។ ជាជាហានឯកក្នុងស្រុកសែឈ្មួនមានច្បាំដែរខ្លាំងតូចណាស់ ។

ខុងបេងដឹងដូច្នោះទើបគិតថា ឧបាយកលម្តេចឲ្យជាន់ខ្លួនខ្លៃយើមជាមុនសិន ទើបនឹងយកស្រុកសែឈ្មួនបានដោយស្រួល ទើបខុងបេងល្បើងសេះទាំងជាហានទៅមើលទីកន្លែងនឹងចូលធ្វើការនោះ លុះទៅដល់ត្រង់ភ្នាគយទិសឯកើត ឃើញព្រៃឫស្សីមួយអន្ទឹង ឆ្ងាយពីស្ពានគំមាំនាំកៀវប៉ាប្រមាណ ៦០ សិន (២៤០០ម.) ទើបឲ្យហានគុងនឹងអ៊ុយអៀនឃុំជាហានម្នាក់មួយភាន់ ចូលទៅពួនបង្កប់នៅក្នុងព្រៃនោះ ចាំងសងខាងផ្លូវឆ្ងេងស្ពាំហើយបង្គាប់ថា បើខ្លៃយើមលើកចេញមក ឲ្យកាយខ្លួចាំងសងខាង ឲ្យខ្លៃហ៊ុយឃុំជាហាន ១ កងទៅស្កាត់នៅចុងក្រោយ ឲ្យដួលឃុំជាហាន ១ កងទៅបង្កប់នៅខាងទិសឯឆៀង ហើយឆ្លាំថា បើយើងបញ្ជោតខ្លៃយើមឲ្យលើកជាហានដេញកន្ទុងចូលធុតស្ពានហួសមក ក៏ឲ្យ

លើកចេញស្លាក់ផ្ទះពុក ហើយរើស្ពានចេញឲ្យអស់ កុំឲ្យខ្មៀវយើមចូលត្រួ-
ឡប់ចូលស្រុកវិញបាន ដើម្បីឲ្យខ្មៀវពីទីធ្លាំងនឿមគាំទ្រយុំតាហានអែបនៅ
សងខាងត្រើយដើមស្ពាន ចេញទៅចម្ងាយប្រហែល ២០ សិន (៨០០ម.)
លុះពុងចេងចាត់ចែងរៀបចំរួចហើយ កំរៀងរេះតូចមួយ តែងខ្លួនយ៉ាង
រមែរម នាំតាហានប្រហែល ៣០ នាក់ ចូលទៅបញ្ឆោតខ្មៀវយើមឲ្យ
ចេញមក ។

ខ្មៀវយើមឃើញពុងចេងយុំតាហានចូលទៅឡកចំអកឲ្យ ក៏ខឹងណាស់
ចាត់ចែងតាហានលើកទៅច្បាំងមួយរំពេច ខណៈកាលខ្មៀវយើមបកសំ-
បុត្រទៅដល់ខ្មៅដឿង សុំកងទ័ពឲ្យលើកមកជួយនោះ ខ្មៅដឿងក៏
ចាត់ប្រើគោអេង យុំតាហានលើកមកឯស្រុកខ្មុកសៀ ខ្មៀវយើមក៏ឲ្យ
ខ្មៀវអែកនៅរក្សាស្រុក ឲ្យគោអេងយុំតាហានជាកងក្រោយលើកចេញ
ពាក់ស្រុក លុះឃើញពុងចេងដឹះរេះតូច យុំតាហានប្រហែល ៣០ នាក់
ដើរតាមមក ក៏ចង្អុលប្រាប់តាហានថា ពុងចេងនេះ យើងបានឮល្បីថា
មានប្រាជ្ញា សេចក្តីគិតដឹង តែងកលសឹកបញ្ឆោតជាច្រើនប្រការណាស់
តែឥឡូវយើងឃើញធ្វើការចូលមកដូចជាមនុស្សគ្មានប្រាជ្ញាអ្វីសោះ ដូចជា
មិនសមនឹងពាក្យដែលឮល្បីនោះឡើយ នឹងខ្លាចអ្វីបែបពុងចេងប៉ុណ្ណោះ
ថាហើយក៏យកដងលំតែងចោះឲ្យតាហានស្ទុះចូលទៅនឹងចាប់យកពុង
ពុងចេង ។

ខុនបេងឃើញខៀវយឹមដេញតាមមកគំលោតចោលរនេះឡើងសេះបកត្រឡប់មកក្រោយ ធ្វើហាក់បីដូចជាខ្លាច នាំតាហានតាំងអស់រត់ខ្ចឹងស្ពានទៅត្រើយម្ខាង ខៀវយឹមបានការគំដេញតាហានលើតតាមទៅដូច្នឹងគំលើកតាហានចេញស្ពាត់ខ្ចឹងពីក្រោយស្ពាន ហើយឲ្យតាហានរុះរើស្ពានចេញអស់ ខ្លៅពីនឹងដើមងាំនឃើញបានការគំលើកតាហានចេញស្ពាត់តាំងសងខាងផ្លូវ ខៀវយឹមឃើញដូច្នោះក៏យល់ថា ខុនបេងតែងតលុចាយឋភ្លោត ក៏នាំតាហានលោតរត់ត្រឡប់ទឹងចូលទៅក្នុងស្រុកវិញ លុះដល់ចុងស្ពាន ឃើញរុះរើអស់ ទឹងខ្ចឹងទៅពុំរួចក៏ទៅស្ទាំងកាំងតាំងអស់គ្នា ដូច្នឹងគំឲ្យតាហានកាយប្រសព្វចូលទៅ ខៀវយឹមក៏ចាក់ទ័ពរត់ត្រឡប់ទៅតាមផ្លូវទិសខាងត្បូង ដល់ទីហឹងគុង ទឹងអ៊ុយអៀនៗគំចេញមកស្កាត់ទ័ពពីមុខទឹងសងខាង កាប់សម្លាប់តាហានខៀវយឹមស្លាប់ជាច្រើនណាស់ ខៀវយឹមឃើញលើសកម្លាំងទឹងតស៊ូពុំបាននាំតាហានប្រមាណ ៣០ នាក់ចរសេះស្រួតរត់ទៅប្រទះទឹងខៀវហ៊ុយស្ទាក់ឆ្ងាចុងផ្លូវទៅខាងមុខ សុទ្ធតែគ្រឿងអាវុធចេញមកតតុកតគាក់ហើយខៀវហ៊ុយស្រែកពញាក់ដោយសម្លេងខ្លាំង តាហានខៀវយឹមក៏ភ័យស្លុតស្មារតីបែកខ្ចាត់ខ្ចាយទៅអស់ ខៀវហ៊ុយក៏ដេញតាហានចូលចោមព័ទ្ធចាប់យកខ្លួនខៀវយឹមបាន គោរនេងឃើញខៀវហ៊ុយចាប់បានខ្លួនខៀវយឹមហើយយល់ថាទឹងខំច្បាំងតទៅពុំឈ្នះទ័ពខ្លៅពិ កំនាំគ្នាចូល

ទៅគំនាប់ចុះចូលដូច្នឹង ខ្ញៀវហ៊ុយ ខ្លួវអស់នាយចំពនាយកឆ័ត្តឆ័ត្តលុះបានដំយដំនេះហើយ កំនាំគ្នាលើកត្រឡប់ខ្លួតមកបន្ទាយ ដូច្នឹងទើបយកខ្លួនគោអេងចូលទៅដូនខ្លៅតាំ កំមិនបានយកគោសគោអេង ត្រឡប់ឲ្យបំណាច់ផ្ទាន់ទៅវិញ ។ ណៈនោះ ខ្ញៀវហ៊ុយកំនាំយកខ្លួនខ្ញៀវយឺមចូលទៅដូនខ្លៅតាំ សួរថា បណ្តានាយតាហានដែលមានក្តីនឹងស្រុកសែលួនេះកំរៀមឆ្ងាចអំណាចយើងចូលមកគំនាប់អស់ហើយ ទៅតែខ្លួនអ្នកឯងមួយនេះ ហេតុម្តេចទើបមកវិនិចនិនិងយើងខ្ញុំដូច្នេះ ? ដែលខ្លួនមិនត្រាមចុះចូលយើងដូច្នេះ ព្រោះតែឃើញប្រការម្តេច ។

ខ្ញៀវយឺមឮខ្លៅតាំនិយាយដូច្នេះកំវិនិចណាស់ មិនបានខ្វាចដល់សេចក្តីស្វាប់ស្រែកតំហកថា ខ្លួនយើងជាជាតិតាហានមិនមានខ្វាចអន្តរាយស្តាយជីវិតគិតត្រឡប់ទៅចំណុះចុះចូលដល់អ្នកដទៃប្រាថ្នានឹងរក្សាជីវិតវិញ មិនស្រឡាញ់ស្រុកនោះកំមិនគួរជាមនុស្សខ្ញៀតត្រង់ទឹងនាយទៅហ្នាយ ធម្មតាជាតិតាហានហើយ មកមានឈ្មោះទៅហ្នាយតាំរនោះកំមិនត្រូវតាមប្រពៃណី ធម្មតាស្រីដែលល្អកំមិនត្រូវប្រាថ្នាស្វាមីដល់ ២ បើលោកទឹងបង្ខំឲ្យយើងចំណុះចុះចូលនោះ បើទឹងពុំឈ្នះកំត្រូវតែតំនាប់ទៅ តែយើងទៅមិនមានចិត្តនឹងតិតកក្តីមេត្រីដល់លោកទេ ហើយកំដេរខ្លៅតាំជាភាសាក្សត្រគោះ

(ទៅមានត)

រឿងល្បែកឡាហ្វុងតែន

លោក ដេង - ទ្រីវ ប្រែរៀបរៀង

(តមក)

ពាក្យ) ត្រចៀកកាំនឹងចាប

ក្នុងការធ្វើដំណើរទាំងឡាយរបស់ខ្លួន ត្រចៀកកាំតែងបានចេះដឹងច្រើន ។ អ្នកណាដែលបានឃើញច្រើន អាចចាំបានគំរើន ។

ត្រចៀកកាំដឹងមុនរហូតដល់ឱ្យលំព្រុះបន្តិចបន្តួច ហើយបានឱ្យដំណឹងនេះដល់អ្នកដើនទឹកទាំងឡាយ មុនពេលឱ្យលំព្រុះនោះ លេចចេញមក ។

នៅពេលនៃការសាចគ្រោះថ្នាក់ ត្រចៀកកាំបានឃើញអ្នកស្រែម្នាក់យកគ្រាប់ឆ្អឹងទៅចាចសាចលើអាចម៍ចំណេះជាច្រើន ។

ត្រចៀកកាំនិយាយប្រាប់ចាបថា តាមយោបល់ខ្ញុំ របស់នេះ មិនស្រួលទេ ខ្ញុំអាណិតអ្នកទាំងឡាយណាស់ ឯរូបខ្ញុំមិនជាអ្វីទេ ក្នុងការមានគ្រោះថ្នាក់ធំបំផុត ខ្ញុំចេះជកបយខ្លួន ទៅឆ្ងាយបាន ឬក៏ទៅនៅក្នុងកៀនកោះណាមួយបាន អ្នកឃើញឬទេ ដៃនោះដែលចេះតែរើកក្នុងអាកាស មានថ្ងៃណាមួយ ហើយថ្ងៃនោះក៏មិនមែនជាឆ្ងាយឡើយ ។ របស់ដែលដៃនុ៎ះបាចសាច នឹងទៅជាសេចក្តីវិនាសដល់អ្នក ។ គ្រឿងប្រដាប់សម្រាប់ក្តោបយកអ្នក សំណាញ់សំពាប់បង់ក្រួបយកអ្នក ចាំយ

មិនតែប៉ុណ្ណោះ ត្រឿងដទៃផ្សេង ។ ជាច្រើនដែលគាល់ណាវាដូរមកដល់ បណ្តាលឲ្យអ្នកស្លាប់ ឬអ្នកជាប់គ្រុង តើតមកតែពីរបស់នោះឯង។ ហេតុដូច្នេះ បងអ្នកជឿខ្ញុំចុះ ចូរចាំស៊ីគ្រាប់នុះឲ្យអស់ទៅ ។

ចាបនាំគ្នាគោលចំអកឲ្យត្រចៀកគាំ ព្រោះខ្មៅកន្ធរចំការខាំឆ្កាយ វាមានអាហារច់ណីជាច្រើន ។

លុះឆ្មៃដុះពាសពេញចំការប្រកបដោយពណ៌បៃតងខ្ចី ត្រចៀកគាំនិយាយប្រាប់ចាបខៀតថា បងអ្នកចឹកដកមួយខន់ម្តង ។ ចោលឲ្យអស់ចេញទៅ ខ្លាដើមឆ្មៃដែលគ្រាប់ចម្រៃនេះបង្កើតនោះ បើមិនដូច្នោះទេ អ្នកខៀនតែដល់ខ្លួនសោះក្តីវិនាសដ៏ពិតប្រាកដ ។

ចាបធ្វើយតបថា : ហោរអកុសល ចូលចិត្តតែពោលប៉ាំប៉ាច់ប៉ាំប៉ាច ឥតប្រយោជន៍ ហ្នឹងឬមុខការល្អដែលអ្នកបង្គាប់ឲ្យយើងធ្វើ ត្រូវយើង ១ ពាន់នាក់ ទើបអាចដកឆ្មៃមួយវាលនេះបាន ។

ត្រចៀកគាំពោលប្រាប់ខៀតថា ឥឡូវឆ្មៃដុះទ្រុបទ្រុលអស់ហើយ ការណ៍នេះពិតជាមិនល្អទេ រឿងអកុសលនឹងមកដល់យ៉ាងឆាប់មិនខាន។ ប៉ុន្តែ ដោយហេតុរហូតមកដល់ពេលនេះ គ្មានឧណាជឿពាក្យខ្ញុំសោះ ដូច្នេះ បើការណាអ្នកឃើញវាលស្រែពាសពេញដោយសន្ធឹង ហើយបើមនុស្សគាំងខ្លាយ ខ្មៅមិនខាន់យកចិត្តទុកដាក់ចំពោះស្រូវប្លែរបស់គេ រួចមកគិតប្រយុទ្ធតែនឹងចាបគាំងខ្លាយ ការណាគេដាក់អន្ទាក់នឹងសំ-

ណាញ់ដើម្បីប្រុងចាប់ចាប អ្នកខាងឡាយចូរឈប់ហើរតោងខ្នងមួយ
ទៅកាន់ខ្នងមួយ ត្រូវរត់ទៅជ្រកនឹងលំនៅផ្ទះមនុស្ស ឬក៏ត្រូវផ្ទាស់ឆ្ងាយ
អាកាស គឺត្រូវគ្រាប់តាមខាងក្រៃ សត្វត្រូវដក់ហើយនឹងសត្វខ្លែក ។
តែអ្នកខាងឡាយមិនមានចំណាប់ហើរឆ្ងាយពីភូមិភាគន្លាន់នឹងមហាសាគរ
នឹងមិនមានទម្លាប់ហើរទៅកាន់ប្រទេសដទៃដូចយើងឡើយ ។ ដូច្នេះ អ្នក
មានតែផ្លូវមួយ ដែលអាចផ្តល់នូវសេចក្តីសុខដ៏ក្សេមក្សាន្តបាន គឺត្រូវទៅទៅ
សម្ងំក្នុងរន្ធនៃជញ្ជាំងផ្ទះណាមួយ ។

ចាប់ដោយធុញព្រាន នឹងស្តាប់ត្រចៀកកាំដែលនិយាយដដែល ។
កំនាំគ្នាស្រែកចេកចាប ។ យ៉ាងអ្នកអាប់រកស្តាប់អ្វីមិនឮ ។

មៅចិប់ផុត ចាំបាច់ច្រើន ត្រូវជាប់អន្ទាក់មនុស្សពាំងឡាយ ។
យើងតេញចិត្តស្តាប់តែសការជាតិណាដែលជារបស់យើង ហើយ
ដឿហេតុអាក្រក់ លុះណាតែហេតុនោះមកដល់ ។

៣៤) ចោរនឹងសត្វលា

ចោរពីរនាក់ឯគ្នា ព្រោះតែសត្វលាមួយដែលលួចបានមក អា-
មួយចង់រក្សាទុក អាមួយទៀតត្រូវការចង់លក់ ។

ក្នុងពេលដែលអាចោរទាំងពីរកំពុងប្រកាយប្រតប់គ្នាទៅវិញទៅមក
ស្រាប់តែមានអាចោរទី ៣ មក ហើយចាប់យកលានោះ ។

សត្វលាខុកដូចជាទ្រនកឆ្កែណាមួយដ៏ខ្លាំងខ្លាយ ឯ
ចោរវិញខុកដូចជាត្រមាមហាសត្វគ្រអង្គុំណាមួយ ដូចជាស្តេច ។ ត្រង់ស៊ីល
ភ័ន ខ្លួនគឺ ទឹងហ៊ុងគ្រី ។ ។ ខ្ញុំមិនយក១ភាហារណ៍ពីរ ខ្ញុំលើកយក
១ភាហារណ៍ចឹង ដើម្បីឲ្យបានជួនល្មមក្នុងរឿងនេះ ។ ឯប្រទេសដែល
វាយយកបាន ច្រើនតែមិនបានភ្ជាក់ទៅក្នុងកណ្តាប់ដៃនៃអ្នកណាមួយ
ឡើយ ។ មានសេចក្តីជួនមកដល់ ហើយសម្រុះសម្រួលអ្នកទាំង ៣
រួចយកលាជាប្រយោជន៍ខ្លួន ។

៣៥) ក្មេងតឹងគ្រូបង្រៀន

ក្នុងរឿងនេះ ខ្ញុំមានបំណងចង់ឲ្យឃើញទូវ៉ាសេ្តីបន្ទោសឥត
ប្រយោជន៍នៃមនុស្សឆ្កួតខ្លះ ។

ក្មេងដំចង្រឹមម្នាក់លេងនៅតាមមាត់ប្រាំងខ្នេ «សែន(១)» ហើយអិល
ដើងភ្ជាក់ទៅក្នុងទឹក ។ ដោយគ្រោះល្អ ខ្លួលមានដើមស្វាយ(២)
មានមែកសាខាសំយុងចុះដល់ទឹក ជាន់ជួយក្មេងនោះមិនឲ្យលិចលង់ ។
កំពុងដែតតោងមែកស្វាយ ជួនជាមានគ្រូបង្រៀនម្នាក់ដើរមកត្រង់កន្លែង
នោះ ក្មេងក៏ស្រែកថា : ជួយផង! ខ្ញុំស្លាប់ហើយ! ។

១- ទន្លេមួយនៅប្រទេសថាំង ហូរកាត់ស្បែរក្រុងប៉ារីស ។

២- ឈើក្នុងប្រទេសត្រជាក់ ច្រើនដុះនៅមាត់ទឹក មានមែកសាខា ស្រដៀងដើមត្រែនៅប្រទេសកម្ពុជា ។

គ្រូបង្រៀនស្ទុះទៅ តាមស្មារស្រែក ហើយគិតតែពីស្តីបន្ទោសក្មេង ដោយសំដីគម្រោះគម្រើយខុសពេលវេលាថា : អ៊ាំ! អាស្អាចាស់ម្យ៉ាត លោកអើយមើលចុះ ជាមកធ្វើលីលាអ៊ីចឹង រួចលោកទំលែងក្បាអាចោរបែបនេះចុះ! ទំយកចិត្តទុកដាក់ចំពោះអាជម្រើងនេះចុះ ។! ឥតុកម្តាយនៅឯណា សមជាមានទុក្ខវេទនា! មានសេចក្តីទុក្ខព្រួយខ្លាំង! ខ្ញុំអាណិតគាត់អ្វីម្ល៉េះទេ! លុះពោលស្តីបន្ទោសយ៉ាងនេះហើយ ទើបលោកគ្រូនោះស្រែងក្មេងចេញពីទីក ។

ក្នុងទីនេះ ខ្ញុំបន្ទោសមនុស្សជាច្រើនដែលគេមិនបានជាគិតដល់ ។ អ្នកប៉ាច់ប៉ាច់ប៉ាច់ប៉ាច អ្នករិះគន់គេ អ្នកត្រាប់គេ ពាំងអស់នេះ អាចដឹងខ្លួនបានចំពោះសំដីដែលខ្ញុំនិយាយនេះ ។ មនុស្សពាំង ៣ ក្រុមនេះ តើគេច្រើនអ្វីម្ល៉េះទេ គឺព្រះអាទិទេពស្រឡាញ់ពួកនេះណាស់ បានជាព្រះអង្គបង្កើតឲ្យមានច្រើនយ៉ាងនេះ ។

ក្នុងកិច្ចការអ្វីពាំងអស់ ក្រុមនេះគិតតែរកមធ្យោបាយដើម្បីភ្ញាំងពាក្យសំដីរបស់ខ្លួនឲ្យប្រពឹត្តទៅតែប៉ុណ្ណោះ ។

នែសំឡាញ់! សូមជួយខ្ញុំឲ្យរួចពីគ្រោះភ័យសិន ចាំឯងស្តីបន្ទោសខាងក្រោយចុះ ។

៨- រឿង បែងចំណែក

8— Le partage

រឿងព្រេងភូតកុងតុង

conte de la nationalité Tong

១ កាលបែកមរតកកើត ខ្ញុំបានសុខទេព្រួយឥតទុក
សុខទាញនង្គ័លភ្ជួរបក កស់ភូនដីលកក្នុងចម្ការ ។
អ្នកណាឈ្លើយចិត្តពាលសាមាន្យ ពិយោជក្សាហានសុខទា
ឲ្យខ្ញុំព្រួយប្រាណរឹងភ្នែកផ្សា ទុកប្រុះទាច្រូងគ្មានសល់ ។
ខៅលើថូបដ្ឋានទៃឆ្កែ ខ្ញុំបានថូនថែជារឿយ ។
មានដុះឫស្សីល្អត្រាណាត្រើយ ឲ្យប្រាក់កែវវើយ មាសធងណា ។
តើអ្នកណាចិត្តឫស្យាកាច ប្រើអំណាចឃោរឃៅតាមចិត្តា
កាប់ឫស្សីដួលលើពសុធា ធ្វើឲ្យាងប្រុះធាទុកំណែន ។
តើតទុក្ខឥតស្បើយចិត្តថ្នាំងថ្នាក់ ឲ្យាងមានចិត្តស្ងួតក្រៀមយាមសែន
ឫស្សីធ្វើច្រូងបងច្រណែន មានញឹកធងមែនមានគេញី ។
តើអ្នកណាកាចដុតច្រូងខ្ញុំ ដើមច្រូងតិសងំព្រួយឥតបី
ធ្វើឲ្យាងតូចទុក្ខមិនចេញស្តី ឥតត្រាប្រណីអសប្បុរស ។

ឥឡូវនេះ ឲ្យាងតូចគ្មានសល់អ្វីឡើយ ក្នែស្ងាប់ ឫស្សីរលំ ច្រូងរលាយទៅជាផេះ ។ ពេលអាណេះ ឲ្យាងតូចលើចបចូក ដើម្បីទំងទៅកាន់កន្លែងព្រៃដីថ្មី ដែលស្ថិតទៅខាងកើត ។ ឲ្យាងតូចកំយកគ្រាប់ត្រឲ្យាចមួយទៅបណ្តុះកន្លែងដីនោះ ហើយយកផេះទៅដាក់ ។

គ្រាប់ត្រឡាចក៏មានតន្ទុកដុះចេញមកភ្លាម ។ ថ្ងៃទី ១ តន្ទុកនោះ ចេញពីដី ។ ថ្ងៃទី ២ មានទ្រុយចេញ ថ្ងៃទី ៣ មានសន្ទឹកខៀវស្រងាត់ ថ្ងៃទី ៤ មានដើមទង់ដុះពាសពេញចង្កើរភ្លុំ ថ្ងៃទី ៥ មានបុប្ផាមានពណ៌លឿងដូចមាស ថ្ងៃទី ៦ មានផ្លែពាសពេញច្រើនជាអនេកប្បការ ។ បណ្តាផ្លែត្រឡាចតាំងឡាយមានផ្លែមួយធំប្រវែង ៩ តឹដេ (pied)(១) ហើយមនុស្ស ២ នាក់ទើបសែងរួច ។ ឡាងតូចបានឲ្យដាក់នាមផ្លែត្រឡាចធំនោះថាជា «ស្តេចផ្លែត្រឡាច) (le Roi des potirons) ។

មានស្វាមួយបានគ្រាច់ភៅកាន់ខ្លែនោះ បានលួចចេះផ្លែត្រឡាចមួយយកភៅទុកក្នុងគុហាដែលជាលំនៅបង់ប្អូនវា ។ ស្វានោះ បានភៅបបួលស្វាឯទៀតភៅចេះផ្លែត្រឡាចយកទុកពាសពេញគុហានោះ ។

ថ្ងៃស្អែក ក្រោយដែលមានចោរមកលួច ផ្លែត្រឡាចអស់ជាងពាក់កណ្តាលដូច្នេះ ឡាងតូចក៏ឃ្លាំចាំមើល ។ ឡាងតូចបានចោរផ្លែត្រឡាចធំនោះ ហើយក៏ចូលភៅសម្លុតបួនលាក់ខ្លួន អាត្មាចាំឃ្លាំមើលចោរដែលលួចផ្លែត្រឡាច ។ ដល់ពេលតាត់កណ្តាលគ្រាត្រស្ងាត់ ឡាងតូចឃើញស្វាជាច្រើនមកលួចចេះត្រឡាចនាំយកភៅអស់ភៅសល់តែស្តេចត្រឡាច ដែលធ្ងន់ពន់ពេកណាស់មិនអាចយកភៅរួច ។

---

១ — តឹដេ (pied) ជាវង្វាស់ជាន់ដើមរបស់ជាតំរមាប្រវែង ៣៣ សន្ទឹមែត្រ ៩ ដើង គឺប្រវែងជា ៣៣ × ៩=២៩៧ សន្ទឹមែត្រ គឺ ២ម៩៧ ។

ទាយនៃស្វាចាំងឡាយ ដោយឃើញថាស្វាចាំងនោះមិនអាចយកស្ពៃចត្រឡាចទៅបាន ក៏គិតថា បើដូច្នេះមានតែអញបន់ស្រន់ដល់ខៅតាវក្បាះទាំងនោះឲ្យមកជួយ ។ ដល់គិតហើយសុំឲ្យស្វាចាំងឡាយទៅដញ្ជូនពីគុហានោះមក ខ្លួនដើរតាមទាស ដើរតាមច្រាក់ហើយយកមកដាក់ពីមុខស្ពៃចត្រឡាច ។ ស្វានោះកំអុដខ្នែងក្រហមកំញាន ហើយយកដៃពាយថ្វាសខ្លួនសុំឲ្យខៅតាស្ពៃចយាងមកកាន់ទីនេះ ដោយសេចក្តីអនុគ្រោះ ។

ឡាងតូចបានក្រឡេកឃើញស្ពៃចត្រឡាចមើលមកក្រៅឃើញសព្វគ្រប់ ក៏គិតថាពេលនេះសមហុចឲ្យហើយ រួចក៏ស្រែកយ៉ាងខ្លាំង ។ ស្វាស្មានថាស្ពៃចត្រឡាច មានព្រះពជ្ឈង្គាខ្លួនព្រះពជ្ឈខ្លួលសូរសើហានាគកំភ័យតក់ស្លុតឥតឧបមា តេ្រាសចេញពីទីនោះទៅ ទុកចោលខ្លួនដើរតាមទាស ដើរតាមច្រាក់ ។

ដល់ពេលស្វាត់ ស្វាវត់អស់ ឡាងតូច ចេញពីស្ពៃចត្រឡាចរើសយកដើរតាមទាស ដើរតាមច្រាក់ទៅតេហាដ្ឋានខ្លួនវិញ ។

ឡាងធំ លុះបានឥតមានទាងលើឫកអស្ចារ្យ ក៏សួរឡាងតូចថា : តើឯងទៅលួចតេនវត្តនេះពីណាមក ?

ឡាងតូច ក៏រៀបរាប់រឿងពីសេចក្តីគ្រប់ចំពូក ។

ពេលសាយណ្ហសម័យ ឡាងធំក៏ធ្វើតាមពាក្យឡាងតូច ។ ឡាងធំទៅស្ថិតនៅក្នុងស្ពៃចត្រឡាចអស់កាលយ៉ាងយូរ ។ ដល់ពាក់កណ្តាល

អង្គ្រត្រស្ងាត់ ឡាងធំយើញស្វាជាច្រើនមក តែគតមានយកដើងពាន មាសដើងពានច្រាក់សោះឡើយ ។ ស្វាទាំងឡាយនោះក៏ស្ទុះទៅកាន់ស្ពេចត្រឡាចហើយលើយកទៅ ។ ឡាងធំដែលស្ថិតនៅក្នុងស្ពេចត្រឡាចក៏និទ្រាលក់ទៅ ។

ស្វាទាំងឡាយធ្វើដំណើរអស់កាលជ័យូរ ឃានឡើងកំពង់មួយ ឆ្នូងទន្លេរួចទើបទៅដល់ថ្នាំមួយធំអស្ចារ្យ ហើយចុះទៅមិនរួចព្រោះថ្នាំនោះស្ថិតទៅទាំងធ្លុងដូចជញ្ជាំងដូច្នោះ ។ ក្នុងពេលនោះ ឡាងធំ ដែលស្ថិតនៅក្នុងស្ពេចត្រឡាចក៏ភ្ញាក់ពីដេកឡើងរួច ដោយស្មានថាស្វាទាំងឡាយគេរៀបចំពិធីបួងសួង ក៏ស្រែកយ៉ាងខ្លាំង ។ ស្វានោះក៏ភ្ញាក់ខ្លាចស្ពេចត្រឡាចចោលទៅទីនោះ រួចរត់ទៅឃាត់ ។ ស្ពេចត្រឡាចនោះ ក៏រមៀលធ្លាក់ពីលើរហូតដល់ដើងតុំខាងក្រោមឃាក់បែកខ្លួចខ្ទីតស់ ។ ចំណែកឯឡាងធំដែលស្ថិតនៅក្នុងស្ពេចត្រឡាចនោះ ក៏ខ្លួលរបួសយ៉ាងធ្ងន់ ឆ្អឹងឃាក់បែកខ្លួចខ្ទីខ្លួលមរណភាពជាអវិសាន ។

ពួជអសប្បុរស កុំសេពគប់សោះ
ឃានខ្លួចខ្លោសក័យ ដូចឯឡាងធំ
យើងខ្លួកជាទ័យ ចិត្តកាចចង្រៃ
ប្រាណវិនាសបង់ ។

ចប់រឿងបែងបែក នៅមានរឿងទី ៩ នាមថា «អ្នកលក់ត្រីនឹងយក្ខ ខ្លាក់» តទៅទៀត ។

សំបុត្រទី ៥

លោក ឆេង ផ្ទៀវ ជាបុត្រលោក

លោក ឈ ឆ - អៀម ប្រែតាមសាអង់គ្លេស

សត្វទាំងឡាយកើតឡើង

យើងបានឃើញថា បឋមសញ្ញានៃជីវិតនៅលើផែនដីយើងនេះ ប្រហែលជាពួកសត្វសមុទ្រយ៉ាងសាមញ្ញតូចតាច ហើយនឹងជាលក្ខណៈតាមទាំងឡាយនោះ (Water plants) ។ សត្វទាំងនេះអាចរស់នៅបានតែក្នុងទឹកប៉ុណ្ណោះ ហើយប្រសិនបើស្រង់ចេញផុតពីទឹកទុកឲ្យស្ងួតទឹកកាលណា វាមុខជាត្រូវស្លាប់ ដូចជាត្រីមានពាងដូចធ្លាក់ស្លាប់សត្វថ្ងៃនេះ ដូច្នោះ ប្រសិនជាគេស្រង់វាដាក់នៅមាត់សមុទ្រទុកឲ្យស្ងួត ។ ប៉ុន្តែក្នុងសម័យនោះ មានភូមិភាគលិចទឹក ឧទាហរណ៍ដែលសម្បូណ៌ដោយផុកល្បប់ច្រើនណាស់ច្រើនជាងយើងមានសត្វថ្ងៃនេះឆ្ងាយណាស់។ ឥឡូវនេះ ត្រីមានពាងដូចធ្លាក់ទាំងនោះ ឧទាហរណ៍ពួកសត្វសមុទ្រដទៃទៀតណាដែលមានស្បែកធំគ្រាន់បើបន្តិច អាចរស់នៅលើគោកបានយូរជាងសត្វសមុទ្រខ្លះទៀត ព្រោះវាពុំងាយស្ងួតទឹកឆាប់ ។ ដូច្នេះពួកត្រីមានពាងដូចធ្លាក់ណាមានស្បែកខ្ចាត់ ឧទាហរណ៍សត្វឯទៀតដូចត្រីពួកនេះ ចេះតែមានចំនួនតិចទៅ ៗ ជាលំដាប់ ដោយពុំអាចឈរមុខរស់នៅលើគោក

ជានស្រួល ឯសត្វសមុទ្រដែលមានស្រកាតឹងជាង កំកាន់តែមានច្រើនឡើង ។ ។ នេះជាការណ៍មួយយ៉ាងជាប់ចិត្ត គួរកត់សំគាល់ពេកណាស់ ។ គឺមានន័យថា សត្វតាំងឡាយតែងធ្វើខ្លួនក ឬក៏ អនុវត្តខ្លួនវាឲ្យស្របបន្តិចម្តងៗ ទៅទឹងវត្ថុតាំងឡាយដែលរស់នៅជុំវិញខ្លួនក ។ កូនបានឃើញនៅក្នុងសារមន្ទីរកេនស៊ិនតុនខាងត្បូង (the sauth Kensington Museum)នៅក្រុងឡុងដ្រ ថាតើបក្សីទឹងសត្វតាំងឡាយនៅក្នុងហេមន្តរដូវ ទឹងក្នុងប្រទេសត្រជាក់ដែលមានទឹកកក ច្រើនក្លាយទៅជាមានពណ៌សដូចទឹកកកយ៉ាងដូចម្តេច តើនៅក្នុងប្រទេសក្តៅដែលសម្បូណ៌ដោយ ពេហណា (Végétation) ទឹងដើមឈើមានពណ៌ខៀវខ្ចី សត្វតាំងនោះក្លាយទៅជាមានពណ៌ខៀវ ឬក៏មានពណ៌ក្តីណាមួយយ៉ាងដូចម្តេច ។ នេះគឺជាអនុលោមខ្លួនកឲ្យស្របទៅទឹងវត្ថុតាំង. ឡាយដែលមាននៅជុំវិញក ។ វាផ្ទាស់តណិក ដើម្បីការពារខ្លួនកាទឹងសត្រូវរបស់ក ព្រោះសត្រូវពុំអាចមើលរកឃើញដោយឡើយ បើប្រសិនជាវាមានពណ៌ដូចជាវត្ថុតាំងឡាយនៅជុំវិញខ្លួនក ។ ពន្លុះពេលក្រាសនៅក្នុងប្រទេសត្រជាក់ ដើម្បីធ្វើខ្លួនកឲ្យកក់ក្តៅក្នុងពេលត្រជាក់។ ឯសត្វខ្លា មានសម្បុរលឿងហើយមានធ្នូត។ កំដូចខ្លែង ។ ពណ៌នេះដូចជាពន្លឺព្រះអាទិត្យដែលចាំងតាមចន្ទោរមែកឈើនៅក្នុងព្រៃធំ ។ គឺពិបាកទឹងមើលឃើញខ្លានៅក្នុងព្រៃធំក្រាសពេកណាស់ ។

ព្រឹត្តហេតុយ៉ាងដូច្នេះ ដែលសត្វតាំងឡាយទាំងឡាយធ្វើខ្លួនឲ្យស្របនឹងសភាពដែលនៅដុំវិញខ្លួននេះ គឺជារឿងមួយមានសារសំខាន់ណាស់។ តាមពិត សត្វតាំងឡាយតុំបានទាំងផ្ទាស់ប្តូរដោយខ្លួនឯងទេ ។ ប៉ុន្តែសត្វដែលផ្ទាស់ប្តូរ ហើយអនុលោមទៅតាមសភាពដែលនៅដុំវិញខ្លួនវាមិនមានសំណាងប្រសើរជាងសត្វឯទៀតក្នុងការរស់នៅ ។ ដូច្នេះសត្វដំពូកនេះ វាមិនមានចំនួនកើនឡើង ឯសត្វដទៃទៀតនេះ តុំកើតឡើងឡើយ ។ នេះគឺឲ្យឃើញបានរឿងច្រើនណាស់ ។ គឺឲ្យឃើញថា សត្វមានកាយសាមញ្ញ តាំងឡាយ រមែងវិវឌ្ឍសន្សឹម ។ ទៅតាមបែបភាពខ្ពង់ខ្ពស់បែបសត្វ ហើយប្រហែលជាអស់ពេលកាប់លានឆ្នាំមកក៏វិវឌ្ឍទៅតាមបែបភាពជាមនុស្ស ។ យើងតុំអាចមើលឃើញការផ្ទាស់ប្តូរ ប្រព្រឹត្តទៅនៅដុំវិញយើងទេ ពីព្រោះការផ្ទាស់ប្តូរជាសភាពសន្សឹម ។ ហើយដំណើរបស់យើងជាសភាវៈខ្លី ។ ចំណែកឯធម្មជាតិចេះតែធ្វើការផ្ទាស់ប្តូរ នឹងធ្វើឲ្យបានប្រសើរឡើងជានិរន្តរ៍ ។ ធម្មជាតិតុំចេះឈប់ឋិតឋេរឡើយ ។

ឥឡូវនេះ កូនទៅចាំបានទៅទៀតឬយ ថាពិភពលោកបានទៅជាត្រជាក់ហើយ ហើយកាន់តែមានដំណើរគោកថន្ទិចម្តងៗ ។ នៅពេលដែលពិភពលោកបានត្រជាក់ហើយ អាកាសធាតុក៏បានផ្ទាស់ប្តូរ ហើយវត្ថុឯទៀតក៏បានផ្ទាស់ប្តូរដែរ ។ ក្នុងពេលដែលផែនដីប្រែប្រួល សត្វតាំងឡាយ

កំបានផ្ទាស់កេរបន្តិចម្តង ។ ដែរ ហើយប្រកេរថ្មី ។ នៃសត្វតាំងឡាយ
កំបានកើតឡើង ។ ដំបូង យើងមានតែសត្វសមុទ្រមានរាងកាយសាមញ្ញ
តមក ទើបមានសត្វសមុទ្រមានរាងកាយសាំញាំ ។ ក្រោយមកទៀត
ទៅពេលដែលដីគោកបានកើនឡើងហើយ ទើបកើតមានសត្វដែលរស់
នៅក្នុងទឹកផង លើគោកផង ខ្លះងដូចជាក្រពើ ឬ កង្កែបសត្វថ្លែនេះ ។
តមកទៀត ទើបកើតមានសត្វដែលរស់នៅតែលើគោក រួចទើបមាន
បក្សីដែលអាចហើរទៅក្នុងអាកាសបាន ។

ឥតុកបានរាប់ឈ្មោះកង្កែប ។ នេះ គឺជាការសិក្សាដ៏មានប្រ-
យោជន៍មួយ ព្រោះក្នុងដីវិតផ្ទាល់របស់វា វាបង្ហាញយើងថាតើសត្វ
តាំងឡាយផ្ទាស់ការបន្តិច ។ ពីសត្វទៅក្នុងទឹកមកជាសត្វទៅលើគោក
យ៉ាងណា ដូចម្តេចខ្លះ?។ កង្កែបពីដំបូងវាជាត្រី ប៉ុន្តែក្រោយមកវាក្លាយទៅ
ជាសត្វទៅលើគោក ហើយដកដង្ហើមតាមសួតដូចសត្វលើគោកដូច្នោះ ។

ក្នុងសម័យដ៏យូរលង់នោះ មានព្រៃធំ ។ ជាច្រើនកាលដែលចាប់ផ្តើម
មានទៅលើគោក ។ ដីគោកជាដីសើមដក់ទឹកតាំងអស់ ព្រមតាំងមាន
ព្រៃតាំងនោះ ត្រូវបានស្រុតលិចទៅ ដោយសារកម្លាំងសង្កត់នៃថ្មទឹងធ
ផែនដី ព្រៃនោះកំបានក្លាយបន្តិចម្តង ។ ទៅជាធ្យូងថ្ម ។ កូនដឹងថា
រយើងបានត្បូងថ្មអំពីអណ្តូងរ៉ែ ដំមានជម្រៅជ្រៅទៅក្នុងដី ។ អណ្តូង
រ៉ែធ្យូងថ្ម គឺពិតជាព្រៃជាន់ដើម នៃសម័យដ៏យូរលង់នោះ ។

ក្នុងចំណោមសត្វទៅលើគោកមុនគេ គឺមានពស់ ថ្លែន ក្រពើ យ៉ាងធំៗ ។ ក្នុងបណ្តាសត្វទាំងនោះ មានខ្លះមានប្រវែងដល់ទៅជាង ៣០ម៉ែត្រ ។ ចូរកូនស្មានបង្កើតពស់ឬថ្លែន ដែលមានប្រវែងជាង៣០ ម៉ែត្រល្បឹងមើល! តើកូនទៅនឹកឃើញ ជាសាណាកូត (Fossils) នៃសត្វទាំងនោះ នៅក្នុងសារមន្ទីរក្រុងឡុងដ៏ឬទេ ?

តមកទៀ ទើបមានសត្វទាំងឡាយដែលកាន់តែដូចសត្វដែលយើញ មានសត្វថ្ងៃនេះ ។ សត្វទាំងនោះហៅថាថនិកសត្វ ពីព្រោះវាចិញ្ចឹមកូនវា ថនិកសត្វដែលដូចមនុស្សជាងគេ គឺស្វា ។ អ្នកខ្លះបានស្មានថាមនុស្ស បានក្លាយមកពីស្វា ។ នេះបានន័យថា នៅពេលដែលសត្វនិមួយ ។ បាន អន្តុវត្តខ្លួនវាឲ្យស្របបន្តិចម្តង ។ នៅនឹងសភាពទាំងឡាយដែលនៅដុំវិញ ខ្លួនវា ហើយបានក្លាយទៅជាប្រសើរឡើង ។ ដូច្នេះ ដំបូងឡើយមនុស្ស ក៏មិនគឺអ្វីក្រៅពីស្វាដែលមានភាពកាយប្រសើរហើយនោះដែរ ។ មែន រហើយ មនុស្សចេះតែបន្ត ឬក៏ធម្មជាតិចេះតែបន្ត ធ្វើឲ្យចំរើនឡើង ។ ហើយឥឡូវនេះ មនុស្សចេះតែគិតពិចារណាអំពីខ្លួនគេគ្មានឈប់ ។ គេស្មានថាខ្លួនគេមានសភាពឆ្ងាយពីសត្វយ៉ាងដាច់ខាត ។ តែជាការមួយ ល្អគួរលើកថា យើងដាបងប្អូនជីដូនមួយនឹងស្វា ហើយសូម្បីតែឥឡូវនេះ ក៏គង់មានគ្នាយើងជាច្រើន កាន់តែរីយោមរយោទហាក់ដូចជាស្វាឯចឹង!

ភ្នំព្រះរាជទ្រព្យ និង ប្រាសាទអង្គរស

របស់ក្រុមជំនុំទៀមចំលាប់

កាលណាយើងធ្វើដំណើរចេញពីភ្នំពេញ តាមផ្លូវជាតិលេខ ៥ (ផ្លូវពីភ្នំពេញទៅបាត់ដំបង) ចម្ងាយ ៣៧គីឡូម៉ែត្រ យើងនឹងប្រទះឃើញផ្លូវចូលមួយខាងឆ្វេងដៃខ្ពោះទៅទិសខាងលិច ដែលមានចាក់ដីរកៀរស្ងួយ៉ាងស្អាតស្អំ ។ បើយើងចូលតាមផ្លូវនេះតទៅទៀត ចម្ងាយតែ ៣ គីឡូម៉ែត្រប៉ុណ្ណោះ នឹងទៅដល់ជើងភ្នំមួយដ៏មានទេសភាពស្រស់ប្រឹមប្រិយ គ្របដណ្តប់ទៅដោយព្រៃព្រឹក្សាលតាវល្លិពណ្តៀបតន់ស្រងាត់ នឹងមានកំពូលចេតិយ កំពូលព្រះវិហារ លេចចេញផុតព័ទ្ធព្រឹក្សាចាំងនោះផង ។ ភ្នំវែងសណ្តូកទទឹងថ្ងៃនេះហើយដែលហៅថា «ភ្នំព្រះពរាជទ្រព្យ» ។ សព្វថ្ងៃទីតាំងភ្នំនេះចាំងមូលស្ថិតនៅក្នុងឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ដ៏មានអ្នកស្រុកអ្នកភូមិសំនៅជាហូរហែតាមដងផ្លូវ ចូលតាមផ្លូវជាតិទៅ ទឹងតាមផ្លូវលំព័ទ្ធជុំវិញជើងភ្នំនេះផង ។ នៅជាប់ទឹងជើងភ្នំខាងកើតលើផ្ទៃដីរាបជង់ជេងស្រឡះស្រឡំ មានវត្តមួយស្អាតជាតឈ្មោះ «វត្តគុក» ។ ខន្ធឹមទឹងវត្តនេះមានផ្លូវជាងណ្តើរឡើងទៅលើភ្នំដែលរថនាគីនៃទ្ធជ្ញាយក្រៀមធ្វើដាក់យ៉ាងខ្លាយ ហើយវែងលាលែ ចត់បែនតេនតង់ទៅតាមសណ្ឋានដីចំណោតភ្នំ តាំងពីផ្ទៃដីរាបហូតទៅដល់ទីភ្នំ ។ ហួសពីវត្តនេះទៅជិតមួយគីឡូម៉ែត្រទៀត ទើបធុនថ្នល់ចាក់

កៅស៊ូ ។ ត្រង់ផុតថ្នល់កៅស៊ូនោះ មានជណ្តើរមួយទៀតធ្វើពីឥដ្ឋឡើង
ទៅលើខ្នង់កំភ្នំដែរ ។ ប្រហែនជាមានជណ្តើរ មានកូនអាចមកគូចមួយដងមាន
គុជស្អាតស្អំ ឥឡូវមានតែព្រះសង្ឃមួយអង្គតង់ទៅថែទាំរក្សាព្រះវិហារ
ចេតិយដែលមានទៅលើខ្នង់កំភ្នំនេះតាំងអស្សាលម៉ាន ។

កំភ្នំព្រះពន្លឺ! ដែលហៅថាកំភ្នំព្រះពន្លឺនេះ គឺសំដៅដល់
តួកំភ្នំតាំងមូលមានតាំងវិហារ-ចេតិយ-ព្រៃព្រឹក្សារួមជាមួយផង ។ ហេតុ
ដូចម្តេចបានគេហៅថាកំភ្នំនេះតាំងមូលថាជា «កំភ្នំព្រះពន្លឺ» ដូច្នេះ?
ត្រង់នេះ យើងក៏យើញចំឡើយដើម្បីជម្រះការសង្ស័យនេះបានថា ៖
ដោយគ្រង់យល់ថា កំភ្នំនេះមិនខ្ពស់ពេក ហើយស្ថិតទៅក្បែរទន្លេធំជាពន្លកំង
ស្រាប់ ព្រះពន្លាសម័យនោះ ក៏គ្រង់តាត់ឲ្យសាងព្រះចេតិយដ៏ ។ ឥឡូវមាន
ចំឡាក់លំអតែតនាយសំពប់បញ្ចុះព្រះបរមអដ្ឋិ ឥឡូវ ព្រះអដ្ឋិនៃព្រះពន្លឺ
វត្តក្នុងវត្ត ដោយចាត់សាងបូជនីយដ្ឋានតាំងនោះដោយកម្លាំងព្រះពន្លឺ
គ្រប់ផ្លាល់ព្រះអង្គ ។ ហេតុនេះហើយទើបមានសម្មតិនាមថា «កំភ្នំ
ព្រះពន្លឺ» ។ រហូតមកដល់គ្រាសព្វថ្ងៃនេះទៀត ក៏នៅតែមាន
ការស្តាបមាបន្ទែម ឥឡូវ ការថែទាំរក្សាទីតម្កល់ខ្នង់នេះយ៉ាងខ្ជាប់ខ្ជួនដោយ
សារកម្លាំងព្រះពន្លឺដែរ ។

រីឯសណ្ឋានកំភ្នំ ឥឡូវទីតាំងនៃបូជនីយដ្ឋានតាំងឡាយនៅលើកំភ្នំនេះ
មានរបៀបរៀបចំដូចតទៅ ៖ គ្រង់គ្រាយកំភ្នំតាំងមូលតីវែងសណ្ឋានតាដើង

ទៅត្បូងជាជួរភ្នំមួយ ដ៏មានកំពូលខ្ពស់ត្រដែតជាងគេបំផុតនៃខ្នង ដែលយើងសន្មតកន្លែងនេះជាចំណុចសំគាល់បំពីគ. ១. ត កប់ពីខាងជើងទៅ ។ ត្រង់ចំណុច «ក» ខ្ពស់ជាងគេ មានជណ្តើរធ្វើពីថ្មបាយក្រៀមពេនតាំងដែលនិយាយរួចមកហើយ ឡើងទៅដល់លើដែលមានចេតិយធំ ។ បីគេហៅថា «ចេតិយត្រៃត្រឹង្ស» ។ កាលណាយើងឡើងតាមនេះទៅដល់ភ្នំ នឹងប្រទះចេតិយធំមួយមុខគេនៅខាងខ្នងវិញ ដែលជាចេតិយរបស់ព្រះករុណាព្រះខត្តិយកោដ្ឋ «ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស» ដ៏មានក្បាច់ក្បូរស្រស់បំព្រងនៅស្អាតបាតនៅឡើយ ។ យើងឡើងតាមជណ្តើរថ្មដដែល សរសៀរតាមចំហៀងចេតិយនេះបន្តិចទៅទៀត ទើបដល់ទៅចេតិយពីរទៀតមានទំហំប៉ុនគ្នា គឺបាតក្រោមមួយជ្រុង ។ មានប្រវែង ១៥ ម៉ែត្រ នឹងមានរបងដែកព័ទ្ធជុំវិញនៃចេតិយទាំងពីរនេះ បណ្តាចេតិយទាំងពីរ មួយខាងត្បូង ព្រះបាទសម្តេចព្រះនរោត្តមព្រះអង្គទ្រង់សាងឡើងនៅគ.ស. ១៨៩១ ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃព្រះបាទសម្តេចព្រះអង្គឌួងជាព្រះវរាជបិតា ។ ចេតិយនេះមានក្បាច់ក្បូរតាមបែបចេតិយធម្មតា គ្រាន់តែមានចម្លាក់ថ្មកត្រង់កំពូលនឹងសង្ឃារនៃព្រហ្មមុខបួន[1]តាមបែបចេនាខ្មែរតែប៉ុណ្ណោះ ។ ចេតិយទាំងនេះដែរ ក៏មានទំហំប៉ុនគ្នាដែរ ប៉ុន្តែមានធ្លាក់ជារូបដំរីលេចក្បាលភ្លោ ។ ឡើងប៉ុន ។ ដំរីមែនទែន គេហៅថាចេតិយ «សាមតាន់» ។ ចេតិយនេះ ព្រះបាទជយវរ្ម្មាកសាង

១- តាមក្បាច់រចនាទៅអង្គរគឺជាមុខរលោងកេសរៈតែខ្មែរនិយមហៅថាមុខព្រហ្ម ។ ។

ឡើងតាំងពី គ.ស. ១៦២៣ ដើម្បីបណ្តុះព្រះបរមអដ្ឋិនៃព្រះបាទស្រីសុរិយោតណាជាព្រះវរោជបិតា ។ ចំណែកខាងទៅលើខ្នងកំពូលនេះ គួរជាទីទស្សនាពន់ពេកណាស់ ព្រោះមើលទៅក្រោមឃើញផ្ទះនៃផ្ទះអ្នកស្រុកតូចតាចតិចតួច មើលទៅខាងលិចឆ្ងាយទៅឃើញភ្នំសូរ ។ ទៅឆ្ងាយសន្ធឹមខាងកើតឃើញទឹកដៃទន្លេសាប ទីឆ្ងាយភូមិអ្នកស្រុកកំពង់ហួរ ខាងជើងឃើញភូមិភ្នំចាស់ទីឆ្ងាយៗគ្មានត្រឹម ទីឆ្ងាយ ខាងត្បូងឃើញថ្នល់ជាតិលេខ ៥ ទៅពីភ្នំពេញវែងលៃលួចជាលាតសន្ធឹងពួរមួយចង្វាយ ។ ទៅជុតពីខ្នងកំពូលនេះ មានជណ្តើរមួយចុះទៅបន្ថែកខាងជើងទៀត ប្រសិនជាយើងចុះទៅតាមនេះ យើងនឹងប្រទះឃើញចេតិយតូចដំណើតពីរទៀតទៅទន្ទឹមគ្នា មួយខាងកើតមួយខាងលិច គេហៅថា «ចេតិយទន្ទឹម» ។ ចេតិយទន្ទឹមខាងកើត ព្រះបាទសម្តេចព្រះអង្គចន្ទទ្រង់សាងឡើងកាលពី គ.ស. ១៧៤៨ ដើម្បីបណ្តុះព្រះអដ្ឋិនៃព្រះបាទសម្តេចអង្គអេងជាព្រះវរោជបិតា ។ សព្វថ្ងៃកំពូលបាក់ជ្រុះខ្លះទៅហើយ មួយទៀតខាងលិច គឺព្រះបាទជ័យជេដ្ឋាទ្រង់សាងពីគ.ស.១៦២៣ ដើម្បីបញ្ចុះព្រះអដ្ឋិនៃព្រះសង្ឃរាជព្រះបិតុលា ។ សព្វថ្ងៃទៅប្រុបចេតិយនេះ មានព្រះសង្ឃគង់នៅដោយសង់ជាកុដិសាលាតូចៗជានិវេសន៍ស្ថាន ។

យើងឡើងត្រឡប់ទៅកាន់ចេតិយត្រៃត្រឹង្សត្រង់ចំណុច «ក» វិញ រួចយើងចុះទៅតាមជណ្តើរដែលទៅខាងត្បូង ឯបតាមចេតិយនៃព្រះ

ភ្នំណាត្រង់ទិត្តិយកោដ្ឋ ហើយយើងមិនចុះដណ្តើរវែងមកកាន់ដីកបរិញ្ញ
នៅឡើយទេ យើងដើរឆ្ពោះទៅត្បូងត្រង់ ។ យើងចុះដណ្តើរស៊ុមដ៏ត
ជន្តិច យើងដើរលើដីទេ តែដីត្រង់នេះមិនកបស្មើទេ បេះតែសំយុងចុះ
បន្តិចម្តង ។ ហាក់ដូចជាឡាំដំណើរយើងឲ្យចុះទៅកាន់ជ្រោះជ្រលងភ្នំ លើ
ថ្មតែបរកុបពុំកបស្មើ ដំបូងយើងប្រទះគុហាតម្រៀបជញ្ជាំងថ្មបាយក្រៀម
តួបមួយ មានដំកល់ព្រះពុទ្ធរូបមួយអង្គ គេហៅថា «ព្រះពុទ្ធជ្រកត
ដំបងដែក» ។ យើងសសៀរគាមចំហៀងខាងកើតនៃគុហានេះយ៉ាង
តិចបាក ព្រោះផ្លូវបង្អៀតធ្វង់កាត់ក្បាលថ្មដ៏ខ្ពស់ ។ ហើយធំ ។ ធង
ទៅមុខបន្តិចទៀត ដីកាន់តែចោតជ្រៅទៅ ។ ធ្វង់កាត់ជ្រលងនេះរួច
ប្រទះឃើញមានគុហាតូច ។ បីទៀតនៅជង្រុងជង្រែងពីដើងទៅត្បូង ។ ដំបូង
ជាគុហាចាស់ធ្វើពីឥដ្ឋសឹងតែរបេះចេញពីគ្នាទៅហើយ គុហានេះគេហៅ
ថា «ព្រះនាគ» គឺដំកល់ព្រះពុទ្ធរូបនាគប្រាក់ ។ តទៅទៀតគុហាព្រះ
កែវ មានចំហាតូចជាងមុន គឺដំកល់ព្រះពុទ្ធរូបតូចល្មមមួយព្រះអង្គទៀត ។
ទៅខាងត្បូងគេ គឺ «គុហាព្រះគោ» ដ៏ជាគុហាតូចតាប រង្វាស់បស៊ីងតែ
ត្រឹមក្បាលមនុស្ស ត្រូបតាលើរូបគោមួយដេកទៅលើអាសនៈបៃមុខទៅ
អគ្នេយ៍ ។ ផុតពីនេះផ្លូវដ៏ខ្ពង់ជ្រៅថែមទៅទៀត ។ ត្រង់ចំនាបនោះ
មានដណ្តើរមួយចុះទៅផ្លូវដ៏កបឯង្គវិស្តល់ ខ្ទង់មានដណ្តើរមួយទៀតវិញ
ទៅកាន់ដ៏ខ្ពង់កំពូលខ្ពស់មួយកន្លែងទៀតជាចំណុច «១» ។ ត្រង់

ចំណុច ..ខ.. នេះ មានព្រះវិហារមួយធំដាច់ជាងគេក្នុងបណ្តាបួនទិស-ដ្ឋានទាំងឡាយទៅកុំព្រះកដទ្រព្យ គឺមានទំហំបណ្តាយ ៤០ ម៉ែត្រ ទទឹងទទឹង ២៣ ម ៤០ បែរមុខឆ្ពោះមកទិសខាងជើង គឺចំផ្លូវដើរមកពីជើងដែលយើងកប់រៀបហូរហែមកហើយនោះ ។ ចេះយើងឈរមើលឥដ្ឋចំនាបមានជណ្តើរខាងមុខមុនទឹងឡើងទៅកាន់ព្រះវិហារនេះ យើងទឹងយើញទិដ្ឋភាពវិហារខ្ពស់ត្រដែតសេចចេញពីចុងឈើខ្ពាន់ខ្ពាប់ ។

ព្រះវិហារនេះមានភាពចំឡែកណាស់ បើយើងធៀបធ្មឹមទឹងវិហារនានាទាំងអស់ក្នុងប្រទេសកម្ពុជា គឺទីមួយត្រង់បែរមុខឆ្ពោះទៅទិសខាងជើង ខ្ចែកពីព្រះវិហារទាំងឡាយដែលតែងតែបែរទៅខាងកើត ទីពីរត្រង់ជំបូលព្រះវិហារនេះ ពុំមានសណ្ឋានខ្ពស់ស្រួចដងខ្លាំងប្រកបដោយជហ្វាជនក្តារដូចវិហារនានាទេ គឺបែរជាកងជាបទាមានសណ្ឋានប្រហែលជំបូលផ្ទះបុរីតទៅវិញ ។ ជញ្ជាំងព្រះវិហារធ្វើពីឥដ្ឋ បូកបាយអារយ៉ាងក្រាស់ខាងក្នុងមានសសរចំនួន ២៦ បែកជា ៤ ជួរបណ្តាយព្រះវិហារ ។ ពីរជួរជើងរៀងចំហៀងម្ខាង ៧ ទឹងជើងរៀងមុខពីរ មានទំហំ ០ម៦០ ឯពីរជួរកណ្តាលជាកន្ទោង សសរទាំមួយ ។ មានទំហំ ២ម០០ បើមនុស្សឈរគាងដៃបន្តគ្នា ៥ នាក់ទើបនឹងសសរនេះជុំ ។ នៅក្នុងព្រះវិហារនេះទៀតមានព្រះពុទ្ធរូបមានវិជ័យមួយព្រះអង្គធំសំបើម គ្រាន់តែទទឹងក្បែនពីបុងម្ខាងទៅបុងម្ខាង ១០ ម ០០ កំពស់ពីបល្ល័ង្កទៅដល់បុងមួលិ ១១ ម ៤០

ហេតុនេះហើយបានជាបុរាណមូលត្រូវខ្ពស់ទុលទៅដល់ដំបូលព្រះវិហារ បើតាតកំពស់នេះទៅនឹងខ្នាតបូកណាដែលទំយកមកថ្វាយព្រះសុគតសំរាប់វិន័យក្នុងព្រះពុទ្ធសាសនានោះ ឃើញថាមានកំពស់ ១៨ ហត្ថព្រះសុគតនេះឯង ។ អាស្រ័យដោយព្រះពុទ្ធរូបដ៏ធំអស្ចារ្យមានកំពស់ដល់ ១៨ ហត្ថយ៉ាងនេះហើយ ទើបអ្នកស្រុកសន្មតតាមព្រះវិហារនេះថា „វិហារអង្គារស„ មានន័យថា ដប់ប្រាំបី គឺសំដៅដល់ព្រះពុទ្ធរូបតន់កំពស់១៨ហត្ថ។ រីឯការប្លែកគួរឲ្យឆ្ងល់ត្រង់បែរមុខទៅដើរនឹងមានដំបូលទាំងនោះ បើតាមឯកសារនៅក្រមដ៏ខ្ទុំខ្ទេមលំបាក់ស្តីអំពីប្រវត្តិព្រះវិហារនេះថា កាលពីរាជ្យសតវត្សទី ១៣ ឯនោះ ចិនបានមកស្ថាបនាព្រះពុទ្ធរូបនេះឡើងហើយធ្វើជាដំបូលប្រកបុំគ្រងរក្សាព្រះពុទ្ធរូបនេះផង ។ ដូច្នេះ ចិនក៏បានដំបូលទាបទាំងតាមរបៀបចិន ហើយដំកល់ព្រះពុទ្ធរូបឲ្យបែរព្រះភក្ត្រទៅខាងដើមឆ្ពោះទៅកាន់ប្រទេសចិន តាំងពីកាលដំបូងនោះមក(១)។ អាស្រ័យលើតំនិតថែទាំទុកដាំណែលដើម ព្រះពន្ធាខ្មែរយើងកំព្រះអង្គតុំតែប្រែឲ្យបាត់ឯនឡើយ ទោះបីជាព្រះអង្គបានជួសជុល ឬ សាងបន្ថែមនូវតួព្រះវិហារនេះមួយលើកពីរលើកមកហើយក៏ដោយ ។

ផុតអំពីព្រះវិហារនេះទៅ យើងតុំអាចដើរលើខ្នងភ្នំនេះបន្តបន្ទាយទៅមុខទៀតក៏បានទេ ដ្បិតវាព្រៃផ្សៃស្មុកស្មាញពេក ដូច្នេះ យើងត្រូវចុះថយមកដល់ដីរាបធម្មតាសិន រួចទើបឡើងទៅខ្នងភ្នំខាងកើតដែលជា

---

๑ - សូមអានឿងនេះនៅក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ ៨ របស់ពុទ្ធសាសនបណ្ឌិត្យ។

ជួរកំពូលតែមួយជាដែល ប៉ុន្តែតែនបត់មកខាងកើតវិញ មានសណ្ឋានដូចមកាឬក្រពើត្រកងកំពុយ ឬក៏ត់កន្ទុយពីក្រោយមកមុខវិញ ។ ខ្លងកំពូលនេះជាចំណុច « ត » ដែលមានដណ្តើរដើមម្ខាងតិ ខ្លងមានតម្រៀបដុំថ្មគ្រាន់តែកុំឲ្យអិលទៅគេលមានក្រៀនប៉ុណ្ណោះ ។ យើងដើរឡើងតាមដណ្តើរនេះ មិនខ្ពស់ជាងត្រង់ចំណុច « ១ » ទេ យើងនឹងប្រទះឃើញផ្លូវបែកជាពីរត្រង់មានស្រះជាតាងទឹកមួយនៅកណ្តាល គឺខាងស្តាំដៃបែកឡើងទៅកាន់វិហារមួយគួចល្មមរៀបជាបែបខ្នែរសស្អាត គេហៅថាវិហារតាសាន់ សង់ពីជាយតម្រែកក្រៀន ។ ឯខាងទ្វេនបែកទៅកាន់ « ព្រះវិហារព្រះនិភ្នាទ » ដ៏មានដំបូលប៉ុតប្រក់ក្បឿងយ៉ាងចាស់ ជញ្ជាំងធ្វើពីជាយ-អរយ៉ាងក្រាស់ តែចាស់ជ្រោបខ្លិបទៅហើយ ។ ព្រះវិហារនេះបែរមុខទៅជើងវែង មានខ្លងទទឹង ៨ម ០០ បណ្តោយ ១១ ម ២០ ហើយនៅក្នុងនោះមានព្រះពុទ្ធរូបចាំនិភ្នាទមួយព្រះអង្គ ព្រះគេសទៅកើត ព្រះបាទទៅខាងលិច បែរព្រះភក្ត្រទៅខាងត្បូង បណ្តោយព្រះអង្គពីព្រះគេសទៅជល់ប្លុងព្រះបាទប្រវែង ១០ ម៉ែត្រ ។ ទៅពីមុខជាច់ខ្លងព្រះវិហារនេះមានរបតិយចាស់ដកមួយដែលកសាងឡើងតាំងពីគ.ស. ១៨៦៧ គឺព្រះបាទបរមិន្ទរកជា ព្រះនាងសុគន្ធមាលាជាព្រះមហេសីនៃព្រះបាទបន្ទុកជា ជា ព្រះវរពេជមិតា ។

កាលណាយើងចុះភ្លឺខ្លងកបនេះមកកាន់ដីទាបជម្ពុតវិញ យើង

ខ្ញុំនឹងប្រទះឃើញចេតិយតូច-ធំជាស់ ។ ជាច្រើននៅជុំវិញជាស ខ្លះរុះធ្លាក់ ចុះយកអាចនឹងឥដ្ឋជាច់រោយចនឹងមានដើមឈើដុះគ្រប់ពីលើ តែមានខ្លះ ទៀតនៅគង់វង្សល្អនៅឡើយ ។ ចេតិយទាំងនេះ ជារបស់ព្រះពុទ្ធ ចនឹងព្រះពុទ្ធវង្សាទុវង្សពីមុន ។ មក ។

ដូច្នេះ សរុបសេចក្តីបានដូចតទៅ គឺឈ្មោះភ្នំដែលហៅថា « ភ្នំ ព្រះពុទ្ធគ្រឹត្យ » នោះ ដោយសារជាទីដែលព្រះពុទ្ធតាំងពីដើមមកគ្រង់ ខុកជាបូជនីយដ្ឋានផ្តាល់ព្រះអង្គនឹងព្រះពុទ្ធវង្សាទុវង្សព្រះអង្គផង ដូចមាន ការកប់រៀបពីចេតិយនិមួយ ។ ដែលជាសំខាន់ ។ ជាងគេនៅលើភ្នំនេះរួច មកហើយស្រាប់ ។ ឯឈ្មោះព្រះវិហារថា « វិហារអង្គារស » នោះ គឺ សំដៅដល់ព្រះវិហារដែលមានដំកល់ព្រះពុទ្ធរូបកំពស់ ១៨ ហត្ថនោះឯង ។

N
1
2
3
4
5
6
7
8
9
10

សញ្ញាសំគាល់

លេខ ១= ចេតិយសាមភាន់ (ព្រះចុងជយវេជ្ជាសាងពីគ.ស.១៦៦៣)

– ២= ចេតិយព្រះចុងនរោត្តមសាងពីគ.ស. ១៨៨១ ។

– ៣= ចេតិយព្រះករុណាទត្តិយ (ព្រះមុនីវង្ស)សាងពីគ.ស. . . ។

– ៤= ព្រះវិហារវេជ្ជាវស

– ៥= ព្រះវិហារ ព្រះនិញ្ញាន

– ៦= ចេតិយព្រះចុងបរមិន្ទរាជា (សាងពីគ.ស.១៩៦៧)

– ៧= វិហារភ្លុកតាសាន់ (ខែរវស្សាមភាន់ស៊ីសង្ខប់)

– ៨= ចេតិយខ្ទីម (ខាងកើតព្រះចុងអង្គីចន្ទសាង១៧៨៨)

– ៨= –»– (ខាងលិច ព្រះជយវេជ្ជាសាងពី ១៦៦៣)

– ១០= គុហាអ្នកតាដំបងរំដក

– ១១= គុហាព្រះខោត (ក្នុងភ្នំបូងាតប្រកំ)

– ១២= គុហាព្រះកែវ (ព្រះភ្នំខ្ចប)

– ១៣= គុហាព្រះរតា (ភ្នំបរតាដែក)

ឯសញ្ញាមួល (o) ដូច្នេះ ជាចេតិយចាស់ព្រះពុទ្ធសាសនា ឯសាសនា
នៅលើភ្នំនេះដែរ ។ ឯចេតិយដែលនៅខាងក្រោមជាថ្មីប៉ុន្មាន តតែចេង
តែងនេះទេ ។

បាតុកម្មខាងព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

ទាត់ុកម្មនៃព្រះសង្ឃ

គណៈធម្មយុត្តិ

នៅថ្ងៃទី ៨ មិថុនា ១៩៦៣ វេលាម៉ោង ៩,១៥ នាទី ព្រះសង្ឃ គណៈធម្មយុត្តិ បានមកប្រមូលគ្នានៅមុខវត្តបទុមវតីកជវកាម ក្រោមអធិបតីភាពនៃសម្តេចព្រះសុជម្មាធិបតីសង្ឃនាយក គណៈធម្មយុត្តិកនិកាយ ដើម្បីថ្វែងនូវញត្តិសោកស្តាយ ខឹងចង្អុលបង្ហាញចំពោះវិញ្ញាណក្ខន្ធនៃពុទ្ធសាសនិក ដែលត្រូវរដ្ឋការក្រុងព្រៃនគរបានធ្វើទារុណកម្ម មានការបាញ់សម្លាប់ជាដើម ។

ព្រះសង្ឃបានតុកបានចារនឹងចងថា « ជយោ ព្រះពុទ្ធសាសនា ! សូមព្រះពុទ្ធសាសនានៅជាស្ថាពរក្នុងពិភពលោក ! » បងនៅមុខយ៉ាងមុខនៃព្រះវិហារវត្តបទុមវត្តីកជវកាម ហើយរៀបតំកល់ក្តារមួយសម្លឹងយ៉ាងវិចិត្រ ដោយមានគ្រប់ចំនាសនាពីលើ ដែលជានិមិត្តរូបនៃវិញ្ញាណក្ខន្ធ នៃពុទ្ធសាសនិកដែលបែកស្ថានទៅកាន់បរលោកដោយស្នាដៃរដ្ឋការវៀតណាមខាងត្បូង ។

ព្រះសង្ឃជួបជុំហើយ ព្រះតេជព្រះគុណ ភូច-សៀង (ថៃយ័ណ) ជាតំណាងព្រះសង្ឃ បានថ្វែងញត្តិមួយមានសេចក្តីដូចតទៅ :

សូមក្រាបបង្គំទូល សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណ
ធម្មយុត្តិ វត្តបទុមវតី សូមគាន់ជ្រាប ។

ខ្ញុំព្រះករុណាខ្ញុំអស់អគ្គ ស្ថិតនៅក្នុងព្រះពុទ្ធចក្រ និងខែត្រក្រៅ
នៃព្រះពុទ្ធអាណាចក្រកម្ពុជា ដែលនឹមន្តមកប្រជុំ នៅចំពោះព្រះភក្ត្រ
សម្តេចជាអម្ចាស់ នាវត្តបទុមវតីកន្លងមកនេះ ដោយព្រះករុណាខ្ញុំអស់
អគ្គ ឃុនទទួលដំណឹងយ៉ាងក្រៀមក្រំគួរឲ្យតក់ស្លុត តាមវិស្សជាតិ
និងសារពតិមានផ្សេង ។ ថាព្រះពុទ្ធសាសនានឹងពុទ្ធសាសនិក នៅប្រ-
ទេសយៀកណាមខាងត្បូង ត្រូវរង្គានុវត្តក្រូងក្រៃនានា សង្កត់សង្កិនធ្វើ
ការុណកម្មផ្សេង ។ ដោយដុតបំផ្លាញវត្តអារាមនៃព្រះសង្ឃខាងព្រះពុទ្ធ
សាសនាខ្លះ ដោយចាប់ឃុំឃាំងធ្វើឃាតកម្មដល់ព្រះពុទ្ធសាសនិកអ្នក
កាន់ព្រះពុទ្ធសាសនាខ្លះ ដែលជាអំពើផ្ទុយនឹងសេចក្តីថ្លែងការជាសាកល
ស្តីអំពីសិទ្ធិនៃមនុស្សត្រង់មាត្រា ១៨ នៃច្បាប់អន្តរជាតិ ។

ចំពោះការដឹះជាន់រំលស់រង្គានុវត្ត ឆ្លុះ-និនយៀម មកលើព្រះពុទ្ធ
សាសនា ទឹងពុទ្ធសាសនិកនៅប្រទេសយៀកណាមខាងត្បូងទាំងប៉ុន្មាន
ដូចឃុនក្រាបបង្គំទូលហើយខាងលើនេះ ខ្ញុំព្រះករុណាខ្ញុំអស់អគ្គដែល
ជាពុទ្ធសាសនិកដែរនោះ មានសេចក្តីខ្វាយខ្វល់យ៉ាងអាណាចអាធ័ម
រកទីបំផុតគ្មាន ដើមចូលមកក្រាបបង្គំទូលសម្តេចជាអម្ចាស់ជាទីគោរព

សូមសម្តេចជាអម្ចាស់មេត្តាទាំយកសេចក្តីក្រៀមក្រំ ទំនឹងការសោកស្តាយ
នៃខ្ញុំព្រះករុណាទាំងអស់អង្គ ថ្វាយចំពោះសម្តេចព្រះ ខេមិន្ទ-សុីហនុ
នរោត្តម-សុីសុវត្ថិ ព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ដែលព្រះអង្គជាព្រះអគ្គពុទ្ធសាស-
ន្តូបត្ថម្ភក៍ដ៏ខ្ពង់ខ្ពស់ ហើយទ្រង់ប្រកបដោយព្រះប្រាជ្ញាញាណយ៉ាងជ្រាលជ្រៅបំផុតនោះ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសជួយសង្គ្រោះដោយព្រះ
ភាវមធ្យោបាយប្រកបដោយសន្តិវិធីយ៉ាងណា ដើម្បីធ្វើឲ្យព្រះពុទ្ធសាសនា
នឹងពុទ្ធសាសនិកកងប្រទេសយើកណាមខាងត្បូង ឋានប្រកបដោយ
សេចក្តីសុខសន្តិភាពជាស្ថាពរ រួចចាកផុតការសង្កត់សង្កិន នៃរដ្ឋការ
ក្រុងវៀតនាម ។

ខ្ញុំព្រះករុណាទាំងអស់អង្គ មានសេចក្តីសង្វឹមលើសម្តេចជាអម្ចាស់
ជាព្រះសង្ឃនាយក ព្រមទាំងសម្តេចព្រះបិតាសន្តិភាពជាតិ ថាព្រះអង្គ
នឹងទ្រង់ជួយស្រោចស្រង់ ព្រះពុទ្ធសាសនា នឹងពុទ្ធសាសនិក នៅ
យើកណាមខាងត្បូង ឲ្យបានរួចផុតស្រឡះអំពីមហន្តរាយ ដែលកើត
អំពីការរើបជាន់ របស់រដ្ឋការ ង្ហ័ុ-ឌិនយៀម ក្រុងវៀតនាម ដោយ
ស្នាព្រះហស្តដ៏ពន់ពេកនៃព្រះអង្គពុំខាន ។

ក្រាបបង្គំទូល នៅវត្តបទុមវតីពាវភាម ក្រុងភ្នំពេញ ថ្ងៃទី ៨
ខែមិថុនា ឆ្នាំ ១៩៦៣

ហត្ថលេខា ពុទ្ធបរិស័ទ បព្វជិតគណធម្មយុត្តិ

លុះចប់ញត្តិហើយ សម្តេចព្រះសុធម្មាធិបតី ព្រះអង្គមានៈថេរដីកាតបទៅកាន់ព្រះសង្ឃវិញថា: ខ្ញុំព្រះករុណា មានសេចក្តីត្រេកអរណាស់ ដោយបានមកឃើញព្រះថេរៈពុន្តេរ មានសេចក្តីឈឺចាប់ចំពោះការធ្វើគត់ពុទ្ធសាសនិកនៅវៀតណាមខាងត្បូង ។ ខ្ញុំព្រះករុណាជឿជាក់ថា ព្រះករុណាគ្រប់ព្រះអង្គមានព្រះទ័យអាណិចអាណិមសោកសៅចំពោះពុទ្ធសាសនិកដែលបានធ្វើមរណៈកាល ហើយបានមកបង្ហូរកូលទុក្ខសៅដល់វិញ្ញាណក្ខន្ធនៃពុទ្ធសាសនិក នៅវៀតណាមខាងត្បូងដែលកាន់ព្រះពុទ្ធសាសនាដូចយើង ។ ខ្ញុំព្រះករុណាសន្យាថា នឹងនាំយកញត្តិរបស់ព្រះករុណាគ្រប់ព្រះអង្គ យកទៅថ្វាយសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋព្រះចិតាឯកភាជ្យជាតិ សូមឲ្យទ្រង់ជ្រាបផង ។ នៅពេលនេះ សូមព្រះករុណាគ្រប់ព្រះអង្គចូលកាន់មរណៈសញ្ញាជាមួយពុទ្ធសាសនិកនៅវៀតណាមខាងត្បូង ហើយសូមបង្ហូរកូលបញ្ចូនបុញ្ញភាគីជូនទៅវិញ្ញាណក្ខន្ធនៃពុទ្ធសាសនិកដែលបែកស្ថានទៅហើយ ។

លុះចប់កិច្ចតាមច្បាប់ព្រះពុទ្ធសាសនាហើយ សម្តេចមានៈថេរដីកាថ្លែងអំណរគុណចំពោះព្រះសង្ឃទាំងអស់ដែលបានមកសំដែងញត្តិនៅវត្តបទុមវតីពេលវេលាក ។

បាតុកម្មនៃព្រះសង្ឃ

គណៈមហានិកាយ

នៅថ្ងៃទី ១១ ខែតុលា ឆ្នាំ ១៩៦៣ វេលាម៉ោង ៩ និង ៣០ នាទី ព្រះសង្ឃគណៈមហានិកាយនៅក្នុងកុដិនីមួយៗ នៃវត្តកាល់ប្រែន ជាច្រើនអង្គ បានមកប្រមូលជុំនៅមុខវិហារវត្តឧណ្ណាលោម ក្រោមអធិបតីភាពនៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ដើម្បីសំដែងនូវសេចក្តីសោកស្តាយចំពោះពុទ្ធសាសនិកនៅវៀតណាមខាងត្បូង ដែលត្រូវរដ្ឋការយៀតណាមខាងត្បូងបានចាប់ចងនិងធ្វើការបង្ខំដោយអំពើព្រៃផ្សៃ ។

ព្រះសង្ឃបានរៀបចំតាល់ក្លាមេឈូសដ៏ចំក្រែ ដែលមានខ្ទង់សាសនាត្រួតនៅពីលើផង ជានិមិត្តរូបនៃពុទ្ធសាសនិកដែលខ្លួលយោគយកម្ចាស់ន យោរយៅដោយស្មារតីដ៏ខ្ជិន-យៀម ។


ព្រះសង្ឃមកជួបជុំហើយ ព្រះតេជព្រះគុណសាសនមុខី តឹម-ភួ ជាតំណាងនៃព្រះសង្ឃ បានថ្លែងញត្តិមួយយ៉ាងក្រៀមក្រំចំពោះអគ្គលេខាណៈនៃពុទ្ធសាសនិកនៅវៀតណាមខាងត្បូង ។ សេចក្តីនៃញត្តិនោះមានដូចតទៅ :

ខ្ញុំព្រះករុណាជាតំណាងព្រះសង្ឃ គណៈមហានិកាយ
មានចំនួនប្រើនយេអង្គ ដែលបានតាំងភ្នែកធ្វើបាតុកម្មនៅវត្តឧណ្ណាលោមនេះ

សូមក្រាបបង្គំទូល សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក
គណៈមហានិកាយ តង់នៅវត្តទុណ្ណាសោម ក្នុងកជនីក្តីពេញ
សូមទានមេត្តាប្រោសជ្រាប ។

ខ្ញុំព្រះករុណាតាំងអស់គ្នា មានចំនួនជាច្រើនរយរូប នៅវត្តខែត្រ
ក្រៅខ្លះ នៅក្នុងវត្តកជនីក្តីពេញនេះខ្លះ មានព្រះពាគណៈហានុក្រម
ជាដើម ឋានទាំងគ្នាចូលប្រជុំត្រៀបត្រានៅខាងមុខធំងខាងក្នុងវិហារវត្ត
ទុណ្ណាសោមនេះ ចំពោះព្រះភក្ត្រសម្តេចជាអម្ចាស់ ដើម្បីក្រាបទូលអំ-
ពីព្រឹត្តិការណ៍មួយដ៏ចំឡែក ដែលទើបនឹងកើតមានឡើងនៅប្រទេស
យៀកណាមខាងត្បូង ដោយសេចក្តីសង្ខេបដូចតទៅនេះ :

ខ្ញុំព្រះករុណាតាំងអស់គ្នា ឋានទទួលដំណឹងតាមវិទ្យុជាតិ នឹង
តាមសារពត៌មានផ្សេង ។ ថា កាលពីក្នុងខែពិសាខ ព.ស.២៥០៦ នេះ
ពុទ្ធសាសនិកជាតិយៀកណាមខាងត្បូង សុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាស
នា តាំងបព្វជិតតាំងគ្រហស្ថ តាំងស្ត្រីតាំងបុរស តាំងក្មេងតាំងចាស់ពុំងន
នាំគ្នាធ្វើបុណ្យវិសាខបូជា សម្តែងសេចក្តីគោរពចំពោះព្រះសម្មាសម្ពុទ្ធ
បរមគ្រូ តាមប្រពៃណីនៃអ្នកកាន់ព្រះពុទ្ធសាសនានៅទីក្រុងហ្វេ យៀក
ណាមខាងត្បូង ។ ពួកពុទ្ធសាសនិកជនតាំងអស់នោះ ឋានត្រូវពួក
រដ្ឋការធ្វើ-ខិន-យៀម ក្រុងវៃព្រនតរធ្វើការុណាកម្មផ្សេង ។ ដោយគ្រឿង
អាវុធ មានការចាញ់សម្លាប់ពួកបព្វជិតនឹងគ្រហស្ថ ស្រី-ប្រុស-ក្មេង-ចាស់
អស់ជាច្រើនរូប ចាប់ឃុំឃាំងអស់ជាច្រើនរូប ព្រមទាំងដុតបំផ្លាញវត្តអា-



សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណមហានិកាយ ព្រមទាំងភិក្ខុសង្ឃជាច្រើនរូបអង្គុយ ប្រជុំគ្នានៅវត្តឧណ្ណាលោម កាលពីថ្ងៃទី ១១-៦-៦៣ ដើម្បីស្តាប់ព្រះធម៌ទេសនាបុណ្យលក់ព្រះត្រៃបិដកនៃព្រះសាសនាពីភាសាជាតិជឿតណាមទាំងស្លាង អនុវត្តដោយអំពើ ឃោរឃៅនៃរដ្ឋការយួន ។

ពាមនៃពុទ្ធសាសនាចាំនឹងនោះទៀតផង ឃើញថា ផ្នែកការងើប-ដួល-ឃើម
នេះ ធ្វើអំពើថោកទាប បៀតបៀនសង្កត់សង្កិនលើប្អូនអ្នកកាន់ព្រះពុទ្ធ
សាសនាចាំងឡាយ ដោយហេតុមកអំពីជនចាំងនោះ មិនបានកាន់
សាសនាតាមគួលិកជួចខ្លួន អំពើនេះ ឃើញថាជួយស្រឡះពីសេចក្តីថ្លែង
ការណ៍ជាសាកលវៃលស្តីអំពីសិទ្ធិនិងសេរីភាពនៃមនុស្ស ក្រុងប្រការ១៨
នៃច្បាប់អន្តរជាតិ ។

ចំពោះការធ្វើអំពើក្រៃដ្ឋណាមកថោកទាប របស់ផ្នែកងើប-ដួល-
ឃើម មកលើព្រះពុទ្ធសាសនានិងអ្នកកាន់ព្រះពុទ្ធសាសនាទៅវិញណាមុ
ខាងក្រៅនិងចាំនឹងនោះ នាឲ្យខ្ញុំព្រះករុណាចាំងឡាយ ដែលជាអ្នកកាន់
ព្រះពុទ្ធសាសនាជាមួយគ្នាដែរនោះ មានសេចក្តីឈឺចាប់ខ្លាចផ្សា ព្រម
ចាំងមានសេចក្តីសោកស្តាយអាណិតអាសូរយ៉ាងក្រៃលែង ចំពោះពុទ្ធ-
សាសនិកជនដែលខ្វះលាងនិងគ្រោះចាំងនោះ ពិតមែនតែពួកពុទ្ធសាស-
និកចាំងនោះ មានជាតិផ្សេងគ្នាក៏ដោយ ប៉ុន្តែជាអ្នកកាន់ព្រះ
ពុទ្ធសាសនាជួចគ្នា រមែងតែមានសេចក្តីស្រឡាញ់រាប់អានគ្នា ជួចជាបង
ប្អូននឹងគ្នាដែរ ។

សេស្រ័យហេតុដូចបានក្រាបបង្គំទូលខាងលើនេះ ទើបខ្ញុំព្រះករុណា
ចាំងអស់គ្នាខាំងយកញត្តិមួយរួបរួមយោបល់គ្នាសម្តែងសេចក្តីទុក្ខ និងសេច
ក្តីសោកស្តាយដែលផុះចេញពីសន្ធានចិត្តរឿង ។ ខ្ញុំទូលមកក្រាបទូល

សម្តេចជាអម្ចាស់ជាព្រះបិតាសង្ឃក្នុងប្រទេសកម្ពុជា សូមសម្តេចមេត្តា
ប្រោសនាំយកញត្តិដ៏ក្រៀមក្រំរបស់ខ្ញុំព្រះករុណាខ៉ាំងឡាយនេះ ថ្វាយ
ចំពោះសម្តេចព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ព្រះអង្គជាព្រះអគ្គពុទ្ធសាសនូបត
ម្ភក៍ដ៏ខ្ពង់ខ្ពស់ សមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ជួយសង្គ្រោះដោយ
ព្រះពរជមធ្យោបាយយ៉ាងណា ដើម្បីធ្វើព្រះពុទ្ធសាសនា ទឹងពួកពុទ្ធបរិ
ស័ទ អ្នកកាន់ព្រះពុទ្ធសាសនាប្រកបដោយសុខសន្តិភាព តាំងនៅជា
ស្ថាពរអស់កាលជានិច្ចនិរន្តរ៍តទៅ ដូចជាព្រះពុទ្ធសាសនាដែលបានតាំង
ក្នុងប្រទេសកម្ពុជានិងក្នុងប្រទេសដទៃផង ។

ខ្ញុំព្រះករុណាខ៉ាំងអស់គ្នា មានសេចក្តីទុក្ខចិត្តយ៉ាងមាំចំពោះសម្តេចជា
អម្ចាស់ជាព្រះសង្ឃនាយកគណៈមហានិកាយ ទឹងសម្តេចព្រះប្រមុខរដ្ឋជា
ព្រះបិតាសន្តិភាពជាតិ ថាព្រះអង្គទ្រង់មានព្រះប្រាជ្ញាញាណដ៏ជ្រាលជ្រៅ
ទឹងទ្រង់ព្រះមេត្តាប្រោសជួយសង្គ្រោះស្រោចស្រង់ព្រះពុទ្ធសាសនា ព្រម
ទាំងជនអ្នកកាន់ព្រះពុទ្ធសាសនានៅវៀតណាម ខាងត្បូងឲ្យមានសិទ្ធិសេរី
ភាពក្នុងផុតអំពីភយន្តរាយ ដែលកើតអំពីការបៀតបៀនដោយអយុត្តិធម៌
របស់រដ្ឋការ៉ើ-ជិន យៀម ដោយព្រះពរជមធ្យោបាយដ៏ឥតវិរៈបរិ
ព្រះអង្គជាប្រាកដ ។

ថ្ងៃទ្រាបបង្គំទូលនៅថ្ងៃទី ១១ មិថុនា ១៩៦៣

នៅមុខ ខឹងខាងក្នុងវិហារវត្តឧណ្ណាលោម



ជាគុកម្ម នៃពុទ្ធសាសនិកជាតិខ្មែរ នឹងបរទេស នៅខាងមុខព្រះបរមរាជវាំងចតុមុខ កាលពីថ្ងៃទី ១៥-៦-៦៣ ដើម្បីប្រដាំងនឹងអំពើដុះ
ជាន់ព្រះពុទ្ធសាសនា នៅវៀតណាមខាងត្បូងនៃរដ្ឋាភិបាល ង៉ូ ឌិន យឹម នឹងសូមសង្ឃេបឲ្យប្រទេសមេត្តាធ្វើអន្តរាគមន៍ជួយរំដោះទុក្ខ ។

បន្ទាប់ពីការថ្វាយភ្លើងរួចមក សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ព្រះអគ្គសង្ឃព្រះទើយថ្វាយអំណរគុណដោយសោមនស្សទៅកាន់ព្រះសង្ឃ ហើយទើបសម្តេចបានចាប់ផ្តើមសួរសុខទុក្ខយ៉ាងមមិចង្អៀកចង្អូល ទៅកាន់សុខសប្បាយនៅវិញណាក្នុងចំណោមអ្នកកាន់ព្រះពុទ្ធសាសនា ដែលខ្លួនមានឱកាសដោយការសង្កត់សង្កិន នៃផ្លូវការ ដើរ-ឱន-យឿម ។

ក្នុងឱកាសនៅព្រឹក ថ្ងៃទី ១៣ ខែមិថុនា ១៩៦៣ វេលាម៉ោង ៧ នាទី ៤០ នាទីព្រឹក ទៅវត្តទុលគោ មានការសម្ពោធជាគុកមួយដងទៀត ដោយក្រុមទាយក-ទាយិកា នៃសមាគមមាន់ធ្លាយ គឺសមាគមសង្គ្រោះសាលាសង្ឃសុខ (ខ្លួនតាពួន) សាលាចំណេញកុសល ចិនត្រកែក វេស្ម័សាមគ្គីសុខ (ឃ្លាំងវីរសេរ) សាលាគោងព្រឹក្ស (ខ្លួសម្លាយព្រៃ) សាលាបុណ្យធម្មទាន (ខ្លួសតក) សាលាសមាគមកុមារសង្គ្រោះបណ្តុះវិជ្ជា (ចិកល្អក់) ក្រុមសាមគ្គីសាលធម្មទាន (ចិកល្អក់) សមាគមប្រជុំមិត្រសន្តិភាព (ផ្សារដើមគរ) ដែលបានហែក្បួនដោយក្រុម ។ គាន់បដាចារឹកពាក្យស្លោកជាច្រើន មានដូចដើមថា :

ពុទ្ធសាសនានៅរៀកណាមខាងត្បូង សូមឱ្យចំរើនរុងរឿង ជូចប្រទេសកម្ពុជា ការពារសិទ្ធិមនុស្សនៅរៀកណាមខាងត្បូងត្រូវតែបរាជ័យ សូមឱ្យអង្គការសហប្រជាជាតិ

បង្ក្រៀបអំពើជិះជាន់ពុទ្ធសាសនានៅយួនខាងត្បូង យើងសូមកាន់មរណាសញ្ញាយ៉ាងក្រៀមក្រំ រួមជាមួយនឹងពុទ្ធជនទៅក្រុងហ្វ៊ូ ព្រះពុទ្ធសាសនាប្រជៅខ្សែសុខស្មៀមស្ងាត់រៀបរយល្អអហិំសា ជាដើម សំដែងថ្លែងញត្តិថ្វាយសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ។

ក្រុមចាតុករាំងនោះ ចានតុបតែងក្តារមឈូសនឹងត្រចង់សាសនាតិលើដូចតែចាតុកម្មមុនៗដែរ ។ ត្រង់ក្រុមចាតុករាំងអស់ ចានហែជាក្បួនមានទឹកមុខក្រៀមក្រំស្រងូតស្រងាត់ ហើយបញ្ចេញមនោសញ្ចេតនារម្មណ៍ចូលកាន់មរណសញ្ញា ចំពោះពុទ្ធបរិស័ទនៅវៀតណាមខាងត្បូង ដែលចាត់បង់ជីវិតទៅដោយសារស្ថានភៃយមកជាយៀម ។

មរណៈទុក្ខនៃពួកពុទ្ធសាសនិកដែលកើតឡើងដោយអំពើឃោរឃៅនៃរដ្ឋាភិបាលវៀតណាមខាងត្បូងនេះ គេមិននឹងរំលាយចោលពីខ្លួនសន្តានៃពុទ្ធបរិស័ទដោយកំឡាំងអ្វីណាមួយឡើយ សូម្បីតែកម្លាំងបរមាណូក៏មិនអាចបំបាត់បង់ដែរ ។

តាមការពិចារណារបស់ពួកពុទ្ធបរិស័ទ សកលលោកទាំងមូលថាបើសិនជារដ្ឋាភិបាលនៅវៀតណាមបំបិទសិទ្ធិសេរីភាពដល់អ្នកកាន់ព្រះពុទ្ធសាសនាដូចសព្វថ្ងៃនេះ ស្ថានការនៅវៀតខាងត្បូង នឹងប្រែក្លាយទៅជាស្ថានការមួយរឹងរឹតតែដុនជាបទៅជាងកាលពីថ្ងៃ ។ ការបំបែកខ្លួនដាច់ខ្សែសា-



សម្តេចសហនីនៃព្រះប្រមុខរដ្ឋកម្ពុជា ទ្រង់កំពុងថ្លែងភាបចំពោះការទទួលអង្ករសុំនៃក្មួនចៅ
ពុទ្ធសាសនិកជាតិខ្មែរនិងបរទេស ស្តីអំពីការដឹងជាន់ព្រះពុទ្ធសាសនា នៅឃ្លាក
ណាមខាងក្បែង កាលពីថ្ងៃ ទី ១៥-៦-៦៣ ពីលើព្រះវិមានឧត្តុង្គយ ។

សមា ជាសញ្ញាដែលសាកសមក្រួយជាមួ ហើយគេមិនសូវហ៊ានលួកដៃឆន ។

ក្លួនដែរ ជាទម្រង់ជួបដុំហើយ សហជីវិន ទុត-ជី ជាតំណាងសមាគមទាំងអស់ សហជីវិនម៉ុច-ស៊ុយ តំណាងពុទ្ធបរិស័ទតួមហាមន្ត្រី ជាតិចិនឲ្យក្លួន-ឈរមានរបៀបហើយ ទើបលោក ញ-ជួ ជាតំណាងពុទ្ធបរិស័ទថ្ងៃញត្តិយាំនក្រៀមក្រំ ចំពោះការបាត់បង់ជីវិតនៃពុទ្ធសាសនិកនៅវៀតណាមខាងត្បូង ដែលមេដឹកនាំ ង៉ោ-ឌិន-យៀម បានសម្លាប់ចោល ។ ដោយសេចក្តីសោកសៅនៃទេមពុទ្ធសាសនិក ចំពោះវៀតណាមខាងត្បូងអ្នកកាន់ពុទ្ធសាសនាតិចជាងគេ ទើបលោក ឃួ ក្បៀ ទីឯលោកសែម សាត ថ្ងៃឯញត្តិចនៃមន្ទីរសេចក្តីសោកស្តាយនូវរឿងរ៉ាវក្លួននៃពុទ្ធសាសនិកដែលត្រូវគេសម្លាប់ចោលនោះ ។

លុះចប់ញត្តិនៃក្រុមបាត់ហើយ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណមហានិកាយ បានថ្លែងបញ្ជាក់នូវសេចក្តីសោកយ៉ាងក្រៀមក្រំ ហើយបន្តបន្ទាប់មកទៀត ព្រះសង្ឃជារច្រើនយកអង្គិបានស្វាធ្យាយធម៌បង្សុកូលបញ្ចុះតុលស ជូលវិញ្ញាណក្ខន្ធនៃពុទ្ធសាសនិក ដែលបាត់បង់ជីវិត ព្រោះការគេប្ចឹ ទីឯពុទ្ធសាសនា ។

(នៅមានត)

ភាសាសន្ទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៥ លេខ ១០ ខែ តុលា

ព. ស. ២៥០៥ គ. ស. ១៩៦៣

– ក្នុង ១៣ –

ព្រះរាជក្រឹត្យ

តែងតាំងសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាសម្តេចព្រះសង្ឃរាជ

ព្រះរាជក្រឹត្យ

ជានទ្រង់យល់រដ្ឋធម្មនុញ្ញ ព្រះរាជអាណាចក្រ ។

ជានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៦០១ ប.រ. ចុះថ្ងៃទី ៦ តុលា គ.ស. ១៩៦២ កែប្រែ នីតិបន្ថែម តាមអត្ថបទក្រោយ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី ។

ជានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៣០ រ.ស. ចុះថ្ងៃទី ៣១ ធ្នូ ១៩៦០ ស្តីពីការរៀបចំក្រសួងនានានៃព្រះបរមរាជាណាចក្រ ។

ជានទ្រង់យល់ព្រះរាជក្រឹត្យលេខ ២ រ.ស. ចុះថ្ងៃទី ២៣ មករា ១៩៥៨ ស្តីពីការតែងតាំងអគ្គនាយក ក្រសួងនានានៃព្រះបរមរាជាណាចក្រ ។

ជានទ្រង់យល់ព្រះរាជក្រឹត្យលេខ ១២៣ ន.ស. ចុះថ្ងៃទី ៣ មេសា ១៩៥២ ស្តីពីការរៀបចំក្រសួងធម្មការ សាសនសិក្សាធិការ ។

ជានទ្រង់យល់ព្រះរាជក្រមលេខ ១២ ន.ស. ចុះថ្ងៃទី ៩ កុម្ភៈ ១៩៤៣ ស្តីពីការរៀបចំក្រុមពាជការ ក្រសួងពុទ្ធចក្រ ក្នុងព្រះរាជអាណាចក្រកម្ពុជា ដោយមានកែប្រែតាមព្រះរាជក្រមលេខ ៦៨ ន.ស. ចុះថ្ងៃទី ១៨ កញ្ញា ១៩៤៣ នីតិលេខ ១ រ.ស. ចុះថ្ងៃទី ២៦ វិសាខ ១៩៤៨ ។

ជាន់ទ្រនំយល់ព្រះកដក្រសួរលេខ ៦៩ ន. ស. ចុះថ្ងៃទី ៤ មិថុនា ១៩៤៩ ដែលតែងតាំងព្រះរតនវង្ស ជួន-ណាត ជាទីព្រះសង្ឃនាយក គណៈមហានិកាយ ។

ជាន់ទ្រនំយល់ព្រះកដក្រសួរលេខ ៤៣ រ.ជ. ចុះថ្ងៃទី ១៨ មេសា ១៩៥០ ដែលតាំងព្រះមហាសុមេធាធិបតី សង្ឃនាយក ជួន-ណាត ជាទីសម្តេច ។

ជាន់ទ្រនំយល់ព្រះកដក្រសួរលេខ ៧ រ.ជ. ចុះថ្ងៃទី ៣១ មករា ១៩៥៦ តែងតាំងព្រះពុទ្ធាចារ្យ កុល-ទេស កងគណៈថ្នាក់ទី ១ គង់វត្តបទុមវតី ជាសង្ឃនាយកស្តីទី ។

ជាន់ទ្រនំយល់ព្រះកដក្រសួរលេខ ១៤ រ.ជ. ចុះថ្ងៃទី ២៨ កុម្ភៈ ១៩៥៨ តែងតាំងព្រះមហាវរៈ កុល-ទេស ជាសង្ឃនាយកគណៈធម្មយុត្តិកនិកាយទីរហើយទំនឹងដំណែង ជាខន្ធកៈតំណែងជាទីសម្តេចព្រះសុជន្ធាធិបតី ។

តាមព្រះកដប់ណាន់យើង ។

ព្រាស់បង្គាប់

ប្រការ ១ — ទ្រនំសព្វព្រះកដហប្ញទ័យលើក ព្រះថាខន្ធៈ-សក្តិជាៈ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១

ដល់សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយក

គណៈ មហានិកាយ ។

សម្តេចព្រះសង្ឃរាជថ្នាក់ទី ៦

ដល់សម្តេចព្រះសុធម្មាធិបតី តុល-ទេស សង្ឃនាយកគណៈធម្ម-យុត្តិកនិកាយ ។

ប្រកាស ២ – សព្វថ្ងៃសត្រូវប្រើពាក្យ សម្តេចព្រះសង្ឃរាជ ជំនួសព្រះអង្គនេះ គឺជាសព្វថ្ងៃសប្រើសម្រាប់ពាក្យសព្វ ។

ប្រកាស ៣ – សម្តេចព្រះសង្ឃរាជជំនួសព្រះអង្គ មានសិទ្ធិត្រូវបានចុតូសិទ្ធិដូចខាងក្រោម៖

ព្រះសុវណ្ណកាជ ពីរសេស

ឆ្នូតស្រេច ពីរសេស

ឆត្រព្រះសិរ ពីរសេស

ខន់សម្រាប់ព្រះទីនាំងរថយន្ត

បុព្វសិទ្ធិទាំងនេះ មានមួយណាលើសឬនឹងរបស់ព្រះសង្ឃ នៅលើព្រះទីនាំងរថយន្តខាងស្តាំ មានខន់សាសនា ខាងឆ្វេង មានខន់សម្រាប់សម្តេចព្រះសង្ឃនាយក ។

ប្រកាស ៤ – អ្នកទទួលការងារវរៈវៀងជ័យ អគ្គនាយក ក្រសួងនាទាំងនៃព្រះបរមរាជវាំង ទីឯអ្នកអគ្គលេខាស្តី ដែលមានតំណែងក្រសួងធម្មការនិងសាសនាសិក្សាធិការ ត្រូវទទួលការងារតំណែងរៀងខ្លួនឲ្យបានសម្រេច

តាមព្រះរាជក្រឹត្យនេះ ។

ធ្វើនៅព្រះបរមរាជវាំងក្រុងភ្នំពេញ នៅថ្ងៃទី ២៨ វិច្ឆិកា ១៩៦៣

ព្រះហស្តលេខា : ន. សីហនុ

បានឃតសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខា សម្តេចព្រះប្រមុខរដ្ឋ

អ្នកឧកញ៉ាវ៉ែវ:វៀងដ៏ឃ អគ្គ

នាយកក្រសួងនានា នៃព្រះបរមរាជវាំង


ហត្ថលេខា: សាន យុន



សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយថានឡើងព្រះហឫទ័យជាសម្តេច
ព្រះសង្ឃរាជទី ១ នៃគណៈមហានិកាយ នៅថ្ងៃទី ២៨ វិច្ឆិកា ១៩៦៣



សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ជានឧត្តុងព្រះហានៈជាសម្តេច
សង្ឃរាជទី ២ នៃគណៈធម្មយុត្តិនៅថ្ងៃទី ២៨ វិច្ឆិកា ១៩៦៣



អង្គសន្និបាត

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
បេញ្ញារាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

ផ្នែកសាសនា	ទំព័រ
- មិនគួរភ្លេចសំនឹងដើម (វិចារណកថា) លោក ផេង-ត្រីវ៉ែ តែងរៀបរៀង . . .	៩៩១
- ប្រវត្តិ និងកិត្តិគុណរបស់ធម្មិ ព្រះមុនីកោសល ស្សរ - ហាយ តែងរៀបរៀង . . .	៩៩៦
- ព្រះអភិធម្មបិដក (តម្ពីព្រះមហាបដ្ឋាន) លោក ប៊ូ - ប៊ី តែងរៀបរៀង (ត) . .	១០០៧
- មហោសថជាតក (ត)	១០១៦
- ផ្ញើនជាសំណាក់ឈ្មោះ កច្ចានី សែនឧទ្ទិសផលទៅឲ្យខ្មោចធម៌សុចរិត ព្រះសាសនមុនី កឹម - ឆ្ង តែងរៀបរៀង	១០២៧
ផ្នែកអក្សរសាស្ត្រ	
- អំពីចោរកម្ម (វិចារណកថា) រៀបរៀង ដោយលោក ផេង - ត្រីវ៉ែ . . .	១០៣៦
ដើមកំណើត និងការវិវត្តន៍ នៃអារ្យធម៌ខ្មែរ ដោយ លី - ជាមតេង . . .	១០៤១
វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហាយ៉ាង - ខាត់ រៀបរៀង (ត) . . .	១០៤៧
- រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា ង្ហួ - ពាន ប្រែរៀបរៀង (ត) . . .	១០៤៩
ល្បើកហ្គាហ្វុងតែន លោកផេង - ត្រីវ៉ែ ប្រែពីភាសាជាវ៉ាំង (ត)	១០៦៦
- រឿងព្រោងព្វាកគុង (ការបែងចែក) លោក វ៉ាយ - ប៊ុក ប្រែពីភាសាជាវ៉ាំង (តចប់) .	១០៧២
- សំបុត្រ ទី ៦ របស់លោកខេរ៉ុ លោក ឈន-អៀម ប្រែពីភាសាអង់គ្លេស . . .	១០៧៧
- ឆាំប៉ុកអង្រែ (ទំនៀមទម្លាប់ខ្មែរ)	១០៨៣
ផ្នែកកំណាត់នៃប្រវត្តិការណ៍	
- ជាតុកម្មខាងព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា	១០៩០
- សារាចរ ស្តីអំពីការ ពាំពារ ថែរក្សាបូរាណវត្ថុជាតិ	១០៩៥

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
ប៊ីនេះលោកហៅ ពុទ្ធសាសនា

វិចារណាកថា

មិនគួរភ្លេចសំដីដើម

លោក ដេង - ទ្រីវរៀបរៀង

ខ្ញុំព្រះករុណាលើកឿងនេះមកពិរោណាដោះស្រាយ ដើម្បីជាវិភាគទានមួយគួច ផ្នែកខាងការសិក្ខា ដល់ព្រះតេជព្រះគុណជាសមណៈតំាងច្បាយខ្លះ ក្នុងដំណើរដើវិភាគនៃព្រះអង្គក្នុងពុទ្ធសាសនា ។

តាមការបានឮ បានឃើញនឹងការសង្កេត មានកុលបុត្រកាគខ្លះ បានបេញចាកគេទ្រហស្ថ ហើយចូលកាន់គេទ្ធកបួសក្នុងព្រះពុទ្ធសាសនា ជាសាសនាដែលមានគោលដៅគឺការស្ងប់ ច្រើនតែភ្លេចសំដីដើមរបស់ខ្លួនគឺថា លុះបានចូលស៊ុបក្នុងសាសនាកាលណា ចៃដាមិនសូវមានការខាក់ខន់នឹងការស្ងប់ ។ ព្រះតេជព្រះគុណបានសិក្សាច្បាប់ព្រះពុទ្ធសាសនាសព្វគ្រប់ហើយ បើខ្ញុំព្រះករុណាយកច្បាប់នេះមកលាតត្រដាងអធិប្បាយពន្យល់

នោះ ទើបព្រាត់ចុះក្នុងបុកណាសិតថា : « ប្រដៅត្រូវហើយ » ។

ពិតមែនហើយ មនុស្សប្រុសជួន នោះបើជាគ្រហស្ថក្តី ជាបព្វជិតក្តី មិនមានជនណាម្នាក់អាចហ៊ានប្រកាសថាខ្លួនគាន់ប្បាប់ដំរៀនពាត់ប្រសើរជាងជនដទៃបានឡើយ តែនោះយ៉ាងនេះក៏ដោយ គង់មានជនខ្លះឬក្រុមជនខ្លះ មានស្មារតីល្អ រលឹកញ៉ាយ ។ ដល់ប្បាប់ឬ ពាក្យសំដីដែលខ្លួនបានសិក្សា ដែលខ្លួនបានសន្សានោះដែរ ការលឹកញ៉ាយ ។ នេះហើយ ជាកត្តាដ៏យ៉ាងសំខាន់មួយ សម្រាប់ញាក់ពាញចិត្តភ្ញាក់ភ្ញាំងរបស់យើង ឲ្យវិលមករកគន្លងត្រូវបានខ្លះដែរ ។

ព្រះតេជព្រះគុណជាគួឬ ជាតំរូ នៃសេចក្តីស្ងប់ នៃសេចក្តីសន្តោស នៃសេចក្តីករុណា នៃសេចក្តីខន្តី នៃការច្រាំងាត់ចិត នៃសេចក្តីមិនត្រូវការវែកមុខវែកមាត់ នៃសេចក្តីសប្បុរស របស់គ្រហស្ថពាំងឡាយ ។ ការកង្វល់ឥតមានស្រាក ព្រោះតែសេចក្តីត្រូវការ ជាការៈជាច់ណាត់របស់អ្នកគ្រប់គ្រងផ្ទះ ។ ព្រះតេជព្រះគុណ នៅពេលដែលចូលសុំបជាពុទ្ធបុត្រហើយ មានការស្រាល ឬ មានព្រះហឫទ័យជាច់ស្រឡះពីកង្វល់ក្នុងសម្ភារៈហើយ ។ តែងផ្ញើជីវិតាពជាយស្ថង នេះគឺការណ៍ពិតជាបឋម ។ គួរតឬព្រះតេជព្រះគុណសមណៈនោះនោះ សើរើត្រិះរិះនឹងពិចារណាក្នុងពេលណាមួយជាច្ឋម្ដងល្ឋងមើល ។

ចំពោះការខ្ពស់មុខ ចំពោះសក្តិយស (សមណសក្តិ) ចំពោះការ

ចានលាភនឹងមិនចានលាភ រឿងអស់នេះ ចើតាមការណ៍ដែលខ្ញុំព្រះពុណ្ណ
ចានដឹងខ្លះ មិនជាការចាំចាច់របស់តុក្ខបុត្រឡើយ ។ តែ ប្រសិន
បើជាត្រូវចានវិញ កំតប្បីខ្លួលយកដែរ ក្នុងសភាគសមរម្យ ។ គួរ
តែយកប្រវត្តិនៃព្រះតុក្ខអគ្គ មកលាតត្រដាងជាឧទ្ធរនៅខាងមុខ ។ ពុកជា
អាម្មណ៍ ដើម្បីកាត់ងឹចិត្ត ដើម្បីធ្វើជាបងចិត្ត ។ ព្រះតេជព្រះគុណ
ចាំងឡាយជ្រាបស្រាប់ហើយ ជាចិត្តជាវត្តុរញ៉ាក់រញ៉ៃណាស់ ជាវត្តុ
រហ័សណាស់ ជាវត្តុឃ្លេងឃ្លាងណាស់ ប្រៀបចានឧឡឹកស្វាប្តូគោ
ក្រាសចាកខ្សែ តែបើមានការយាមល្បាតឃ្លាំជាទំនួ តាមខ្ញុំព្រះពុណ្ណ
យល់ វាគ្រាន់ចើណាស់ដែរ ដូចជាសត្វសិង្ហឬសត្វខ្លារបស់អ្នកសិល្ប:
សៀក (cirque) សត្វចាំងតាវបែបនេះ ជាសត្រូវនឹងមនុស្ស ជាសត្រូវ
ឧឡឹងសត្វដទៃ ព្រោះវាមានមហិទ្ធិរិទ្ធិ ហើយនិយមយកសាច់ជាអាហារផង
តែអ្នកសិល្ប:សៀក អាចយកសត្វតាប្រភេទនេះមកឲ្យនៅកណ្តាលជំទុំ
ចំណោមមហាជនដែលជាអ្នកភ្ញាចស្ងាប់ឲ្យរាំ ឲ្យដើរ ឲ្យរត់ចុះឡើងដើម្បី
ទស្សនាចាន ។ សួរថាសត្វសាហាវចាំងតាវបែបនេះ ហេតុដូចម្តេច
ក៏មិនស៊ុះទៅចាំទស្សជន? ឆ្លើយថាមកតាតេជាក់ទ្រង់វា គេមានវិជ្ជាចាំង
វា គេតាមថែរក្សាវ៉ា កុំឲ្យវាអាចទៅធ្វើអំពើព្រៃផ្សៃចាន ។

ចុះចំណែកចិត្តរបស់មនុស្ស ជាតិសេស របស់ព្រះតេជព្រះគុណសមណ:
ចាំងឡាយនោះ ឧឡឹងមានអ្វីជាវត្ថុ ជាបងសម្រាប់កាត់ងឹ សម្រាប់ស្ងាត់ដែរ?

មិនមានអ្វីស្រាប់ពីស្មារតីឡើយ ។ ដូច្នេះ ទើបខ្ញុំព្រះករុណា ចូលចិត្តទុកស្មារតី ជាកត្តាដ៏ចម្បងបំផុត ក្នុងការស្វាគ៌ចិត្តដែលប្រួលប្រែបល់ងាកទៅរកផ្លូវទុស្ស ។ ព្រះតេជព្រះគុណសមណៈ ចាំងឡាយនោះ គួរទស្សាហ៍នឹកទៅរកពេលខាងដើម គឺពេលដែលព្រះតេជព្រះគុណស្ថិតនៅក្នុងព្រះវិហារកណ្តាលដំទុំសង្ឃ ២១ អង្គ ហើយមានព្រះតេជព្រះគុណមួយអង្គចាស់គង់ពីខាងមុខ ដែលហៅថាព្រះឧបជ្ឈាយ៍នោះ ។ ពេលនោះ ព្រះតេជព្រះគុណនៅជានាគនៅឡើយ ហើយព្រះតេជព្រះគុណគោលចំពោះដំទុំសង្ឃថាដូចម្តេច? ព្រះតេជព្រះគុណសន្យាខ្លួនឯងថាដូចម្តេច? ឯវិធីកែទង្វើដែលព្រះតេជព្រះគុណបានបញ្ចេញកណ្តាលដំទុំសង្ឃ បើតាមខ្ញុំព្រះករុណានៅចាំគឺជាបឋម ការប្រគល់សំពត់កាសាវៈដល់ព្រះឧបជ្ឈាយ៍ សូមឱ្យលោកបំបួសព្រះតេជព្រះគុណ ដើម្បីប្រព្រឹត្តសមណធម៌ ធ្វើរលាស់ចោលនូវទុក្ខចាំងពួង ។ កាលណាព្រះឧបជ្ឈាយ៍បានទទួលយកសំពត់កាសាវៈហើយ នាគទូលព្រះឧបជ្ឈាយ៍ទៀតថា: សូមព្រះឧបជ្ឈាយ៍យកសំពត់កាសាវៈនេះបំបួសខ្លួន ដើម្បីបានប្រព្រឹត្តសមណធម៌ ធ្វើរលាស់ចោលនូវទុក្ខចាំងពួង។ ពេលដែលនាគបានស្លៀកដណ្តប់សំពត់កាសាវៈហើយ ខ្លួនត្រូវមកអង្គុយចំពោះព្រះកម្ពុឧបជ្ឈាយ៍ម្តងទៀត ឧបជ្ឈាយ៍ប្រទានតបបញ្ចកកម្មដ្ឋានគឺ កេសា លោមា នខា ទន្តា តចោ ជាផ្លូវតិចារណាថាសក់ រោម ក្រចក ធ្មេញ ស្បែកជាដើមនេះ សុទ្ធសឹងតាំងនៅក្នុងព្រះត្រៃលក្ខណ ។

សេចក្តីប៉ុន្មានខនេះហើយ ជាសំដីដើមដំបូងបង្អស់ ហើយសំខាន់អស្ចារ្យ ដែលហូរចេញយ៉ាងស្មោះត្រង់ ពីដួងចិត្តដ៏បរិសុទ្ធនៃព្រះតេជព្រះគុណ សមណៈគាំងឡាយនោះ នៅខណៈនៃការធ្វេងកាត់ពីភេទមួយទៅភេទមួយ ដែលគេនិយមថុកជាឧត្តមភេទ ។

តាមការយល់ ហើយប្រហែលជាមិនឃ្លៀងឃ្លាតប៉ុន្មាន ជាគួរគប្បីព្រះតេជព្រះគុណសមណៈគាំងឡាយនោះ ឧស្សាហ៍រំលឹកសំដីនៃព្រះអង្គនេះឲ្យបានញយ ។ នោះលោកធម៌នឹងមិនសូវគ្រប សង្កត់ មិនសូវញាំញី មិនសូវធ្វើទុក្ខបុកម្នេញខ្លួនព្រះអង្គតេក ។ បើកាលណាធម៌នេះមានកំឡាំងខ្លាយ សមណៈអធិតវណ៌នឹងចិត្តកង្វល់ កំនំងខ្លាយដែរជាស្ងប់រម្ងាប់ហើយសេចក្តីសុខ ការស្ងប់ ត្រូវតែកើតមានដល់ព្រះអង្គ ។

ជាអវសាន ខ្ញុំព្រះករុណា សូមបញ្ជាក់ថា អត្ថបទនេះ មិនមែនជាការរិះគន់ មិនមែនជាការប្រមាថ គឺជាការរំលឹកដោយសុទ្ធចិត្ត ដើម្បីចៀសវាង ទុបសគ្គអធម៌ពីខាងក្រៅ ដើម្បីការពារព្រះតេជព្រះគុណសមណៈគាំងឡាយនោះនឹងអំពើមិនគប្បីរបស់អសប្បុរស ដែលនឹងធ្លាក់មកលើព្រះពុទ្ធសាសនាដ៏ប្រសើរតែប៉ុណ្ណោះ ។

ប្រវត្តិនិងកិត្តិគុណរបស់ធម៌

រៀបរៀងដោយ

ព្រះមុនីកោសល សុវ-មាយ អធិបតីវត្តនៃក្រុមដំនុំព្រះត្រៃបិដក

ធម៌គឺសេចក្តីពិត ជាន់ចាប់តំណើតខៅក្នុងលោកវស់ជាធម្មតា បិតខៅជាច្រើនៃសេចក្តីវិនាស ជាច្រើននៃពាក្យថា „ចាស់គ្រាំគ្រា„ ។ ធម្មតាវត្ថុអ្វី ។ ជាន់អស់ក្នុងលោក មានប្រាក់មាស រវេះ ផ្ទះជាដើម ដែលគេសន្ធឹងសូន្យតាក់តែងកសាងខ្លើងហើយ រមែងមានរូបប្រែប្រួលខៅផ្សេង ។ តាមកាលសម័យដែលនិយមកន់អាន ដូនកាលវត្តដែលមិនមែនជាមាសប្រាក់សុទ្ធទេ ប៉ុន្តែគេអាចតាំឡៃ ធ្វើដោយភ្នែកភ្លាយឲ្យមានភាពដូចប្រាក់ មាសសុទ្ធក៏ថាន ។ មាសប្រាក់តាំឡៃនោះក្តី រវេះ ឋ្ងផ្ទះជាដើមក្តី រមែងចាស់គ្រាំគ្រាទ្រុឌទ្រោម ដែលថ្លាប់មានតម្លៃក៏ត្រឡប់ខៅជារបស់ឥតតម្លៃវិញ ។ មួយទៀត វត្ថុមានមាសប្រាក់ជាដើមដែលជារបស់ភ្នែកភ្លាយ កាលបើគេដឹងច្បាស់ថា ជារបស់ភ្នែកភ្លាយហើយ គេក៏លែងត្រូវការរបស់ទាំងនោះ សេចក្តីនេះ យ៉ាងណាមិញ ច្បាប់ទំលាប់កន្លងខ្លួណាមួយ ដែលគេថ្លាប់គោរពជឿ ដោយឥតពិចារណារកហេតុផល ជាច្បាប់ដែលគេតាក់តែងខ្លើង ដោយខុចាយមិនសម

ហេតុផល គឺជាដំណើរមិនស្របទៅតាមសេចក្តីពិត ច្បាប់ខ្មាប់ចាំងនោះ តង់ត្រូវអ្នកផង ដែលមានប្រាជ្ញា ឆ្លាប់ចាន់ស្ទាបស្ទង់តិចារណា អាចយល់ថាស់កំហុសបាន ថាជាច្បាប់មិនពិត ព្រោះមិនសមហេតុផល បើទុកជាគេមិនចាប់ថ្នាក់ កិតង់គេដឹងបាន ហើយគេកងចាលលែងគោរពតទៅទៀត ។ ច្បាប់នោះក៏ទៅជារបស់រៀវកេយ សាបរលាប លែងមានអ្នកណាមួយគោរពជឿចុះចូលកំយ៉ាងនោះដែរ ។

ទើបឯព្រះធម៌ មានសភាពពិតមែនគឺច្បាប់ ដែលស្របតាមហេតុផលតែងមានអាយុដ៏វែងស់ទៅប្រចាំលោកជាស្ថាពរ មិនចេះចាស់គ្រាំគ្រា មិនចេះរៀវកេយ សាបសូន្យ ថយចុះដូច្នោះឡើយ ។

ស្វាក្ខាតធម៌ : ដែលព្រះសម្មាសម្ពុទ្ធបស់យើង ទ្រង់បានត្រាស់ដឹងឡើងហើយ ទ្រង់ប្រកាសប្រដៅមនុស្សក្នុងលោក តាលដើមដំបូង មិនសូវមានមនុស្សជ្រះថ្លាជឿកាន់ច្រើនប៉ុន្មានទេលុះតាលខាងក្រោយមក ទើបពួកទៅតា នឹងមនុស្សបានដឹងឮសុសសាយច្រើនគ្នាស្ងើចសរសើរថា ឧហ្ម៎ ! នេះជាធម៌ពិតប្រព្រឹត្តទៅដើម្បីសេចក្តីសុខក្សេមក្សាន្ត រួបនាំគ្នាប្រព្រឹត្តប្រតិបត្តិកាន់តាម ដើម្បីលែងកើងកំលេស កើងទុក្ខ រហូតបានមគ្គផលនិព្វាន តាមនិស្ស័យវាសនា យ៉ាងស័ក្តិសិទ្ធិ ដូចទឹកសម្រាប់លត់ភ្លើង ។ ធម៌គឺសេចក្តីពិត មានអាយុដ៏វែងដ៏ឆាំមួន ជារបស់មិនចេះចាស់ថ្មី មិនចេះស្ងាប់ អាចរស់នៅបិតថេរតាំងមានតម្លៃអង្វែងត

រៀមិនរចេះចុះថ្លៃឡើយ សេចក្តីនេះ តប្បីសន្និដ្ឋានបានដោយងាយ ដូចយ៉ាងធម៌របស់ព្រះសម្មុទ្ធនៃយើងតាំងពាន់ឆ្នាំ ដែលព្រះអង្គសំដែងឡើងតាមពិត មិនវិបរិតខុសចាកសេចក្តីពិត បើយើងគិតគាំងអំពីឆ្នាំដែលព្រះអង្គបរិនិព្វាន មកដល់ឥឡូវនេះបាន ២៥០៦ ឆ្នាំ ហើយ ពោះបីយូរអង្វែងមកប៉ុណ្ណោះ ព្រះធម៌នោះ ក៏នៅថ្មីឥតខ្ចីតាត់ដដែល ដូចប្រក្រតីឥតមានចាស់គ្រាំគ្រា ប្រែប្រួល ខូចតម្លៃយ៉ាងណា ។ឡើយ ។

ពុទ្ធភាសិត ដែលមានមកក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ បញ្ជាក់ចំពោះពាក្យថា «ធម៌» របស់លោកអ្នកសប្បុរស មានព្រះសម្មុទ្ធជាដើម ជាធម៌មិនរចេះចាស់គ្រាំគ្រា ឬមិនរចេះសោះសូន្យ កាលបើមិនមានសេចក្តីចាស់គ្រាំគ្រាទេ សេចក្តីឈឺចាប់ក៏មិនមាន កាលបើសេចក្តីឈឺចាប់មិនមានទេ សេចក្តីស្លាប់ក៏ពុំមានឡើយ ។ សេចក្តីចាស់គ្រាំគ្រាមានចំពោះតែរូបដែលមានរូបដូចយ៉ាងរនេះ ផ្ទុះសម្បែង ឧដ្ឋរូបកាយ របស់មនុស្សសត្វប៉ុណ្ណោះ ។

ពាក្យថា ធម៌ ដែលអធិប្បាយមកនេះ សំដៅយកសេចក្តីពិតជាតាមធម៌ គឺសេចក្តីល្អ អាក្រក់ ជាធម្មជាតិឥតមានរូបកាយ គឺមានតែតាមដែលចាប់កំណើតនៅក្នុងលោកសម្រាប់ដឹងបាន ដោយបញ្ញាចក្ខុប៉ុណ្ណោះ ឥតមាននរណាមួយស្រាវជ្រាវរកប្រតិទ្ធឃើញថាធម៌នេះ ចាប់កំណើតពីកាលណា ។ បានឡើយ ដូចភ្នែងនឹងឮសំដែលគេមិនអាចដឹងដើម

កំណើតបានដូច្នោះដែរ គឺជាធម្មជាតិ តែងកើតមានទៅប្រចាំលោកជាធម្មតា ។

សេចក្តីអធិប្បាយខាងលើនេះ អាចយល់បានថា កុសលកម្មនឹងអកុសលកម្ម តែងរស់នៅជាស្ថាពរប្រចាំលោកជានិច្ច ចាំងមគ្គផលនិព្វានក៏មានទៅក្រោកដ មិនត្រូវនាសបាត់បង់ចាកលោក ដោយអន្តរាយណាមួយឡើយ សូម្បីលោកជាតុចាំងមូលត្រូវក្តីងរេះ កុសលាកុសលកម្មនឹង មគ្គផលនិព្វាន អាចតាំងនៅដដែល មិនចេះរលត់រលាយបានទេ ចំណែកខាងភាសាវែកតរបស់ពួកជនខ្លះដែលនិយាយឡើងថា ធម៌ថ្មី ធម៌ចាស់ សាបសូន្យរៀរកេយនោះ កប់ថាជាមោយៈ (ជាភាសាឥតប្រយោជន៍) ។ សូមលោកអ្នកចាំងឡាយ ប្រើវិចារណញ្ញាណឲ្យហ្មត់ចត់ ឲ្យឃើញច្បាស់ថា ធម៌របស់លោកអ្នកសព្វៗសមានព្រះសម្ពុទ្ធជាដើមនោះ មិនមានថ្មី មិនចាស់ទេ មិនចេះសាបសូន្យឡើយ ព្រោះធម៌ជាសភាវៈឥតរូប មានតែនាម សម្រាប់សិក្សាប្រតិបត្តិប៉ុណ្ណោះ មានភាសាថា ថ្មីចាស់ សាបសូន្យ ចំពោះតែរបស់មានរូប ដូចយ៉ាងរូបសាស្ត្រស្ងឹកតែ ឬសៀវភៅជាដើម ។ សូមលោកអ្នកបែរទៅពិចារណាតាមពុទ្ធភាសិតថា (ពជវថាំងឡាយ ដែលជាងរចនាល្អហើយ រមែងដល់នូវសេចក្តីចាស់គ្រាំគ្រា សាបសូន្យ សូម្បីសរីរកាយរបស់សត្វចាំងឡាយ ក៏ដល់នូវសេចក្តីចាស់គ្រាំគ្រា សាបសូន្យដូចគ្នាដែរ ទើប

ធម៌របស់លោកអ្នកសប្បុរសមានព្រះសម្ពុទ្ធជាដើម មិនដល់នូវសេចក្តីគ្រាំគ្រាដូច្នោះឡើយ ។

ពាក្យថា « ធម៌ » របស់លោកអ្នកសប្បុរស ជានដល់ធម៌ ៣ យ៉ាងគឺ :

๑ - បរិយត្តិធម៌ ជានដល់ច្បាប់សម្រាប់សិក្សា ,

๒ - បដិបត្តិធម៌ ជានដល់ច្បាប់សម្រាប់ប្រតិបត្តិ ,

๓ - បដិវេធធម៌ ជានដល់ការត្រាស់ដឹង ។

ពុទ្ធវចនៈ គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ជានដល់ព្រះត្រៃបិដក គឺព្រះវិន័យ ព្រះសូត្រ នឹងព្រះអភិធម្ម ដែលព្រះសម្ពុទ្ធទ្រង់សំដែងទុកមកជាពុទ្ធប្បញ្ញត្តិកំមាន ជាពុទ្ធានុញ្ញាតកំមាន ដើម្បីឲ្យពុទ្ធបរិស័ទរៀនសូត្រឈ្មោះថា បរិយត្តិធម៌ ។

កុសលធម៌ទាំង៣យ៉ាង មានទាន សីល ភាវនា ជាដើម ដែលជាធម៌គួរពុទ្ធបរិស័ទគោរពប្រតិបត្តិតាន់តាម ឈ្មោះថា បដិបត្តិធម៌ ។

កាលបុគ្គលជាបព្វជិត ជាត្រហស្ថ មានសទ្ធាជ្រះថ្លា ជានប្រតិបត្តិតាមដោយគោរព ចំពោះកុសលធម៌ទាំង៣យ៉ាងនោះហើយ រមែងជានដល់គុណវិសេសដ៏ខ្ពង់ខ្ពស់បំផុតគឺ ការត្រាស់ដឹងមគ្គផលនិព្វានដែលជាគោលដៅរបស់ព្រះពុទ្ធសាសនា នេះឈ្មោះថា បដិវេធធម៌ ។

ធម៌ទាំង ៣ យ៉ាង ដូចរៀបរាប់មកខាងលើនេះ មិនមានឈ្មោះថាធម៌

ចេះចាស់ឈឺចាប់ស្លាប់ឡើយ ដោយហេតុថា ជាសភាវៈឥតរូបកាយ គឺគ្រាន់តែជាឋានសម្រាប់សិក្សា សម្រាប់ប្រតិបត្តិប៉ុណ្ណោះ ។ រីឯដែលមានរូបកាយអស់ដូចយ៉ាងនេះ ផ្ទុះសម្បែង ឱនរូបមនុស្សសត្វជាដើម ទើបមានថ្មី មានចាស់ មានជម្ងឺមានមរណៈ ។

សេចក្តីពិត មិនសាបសូន្យ

បុណ្យ គឺអំពើល្អ បាប គឺអំពើអាក្រក់ គុណ គឺសេចក្តីចំរើន ទោស គឺសេចក្តីវិនាស ទាំង ៤ យ៉ាងនេះជាដើមឈ្មោះថាជាប្រវត្តិគឺជាដើមកំណើតរបស់ពាក្យថាធម៌ ដែលថាសេចក្តីពិតរស់នៅប្រចាំលោកជាដរាប សូម្បីក្នុងកាលលង្វែត គឺកាលដែលមិនមានព្រះពុទ្ធត្រាស់ដឹង ឬមិនមានអ្នកប្រាជ្ញ ក៏តែងមានបុណ្យ មានបាប មានគុណ មានទោស តាំងនៅជាប្រក្រតី ឥតមានសាបសូន្យ ចាកលោកធាតុឡើយ ។ បើបុគ្គលណាមួយក្នុងលោកមាន កាយ វាចា ចិត្ត ប្រព្រឹត្តល្អ ត្រូវតាមសីលធម៌ មានព្រហ្មវិហារ ផ្សាយទៅក្នុងពពួកសត្វគ្រប់ទិស មានកតញ្ញូកតវេទីតាជម៌ ចំពោះលោកអ្នកមានគុណ មានមាតាបិតាជាដើម បុគ្គលនោះរមែងបានទទួលផលបុណ្យ ដោយការជួបប្រទះនឹងសេចក្តីសុខជម្រើនដោយពិត បើបុគ្គលប្រព្រឹត្តអាក្រក់ ដោយមិនមានគុណធម៌ មិនមានព្រហ្មវិហារ មិនមានកតញ្ញូកតវេទីតាជម៌ ចំពោះលោកអ្នកមានគុណក៏រមែងទទួលផល បាប ទទួលទោសដោយខ្លួនឯង មិនចាំបាច់

នរណាមួយប្រគល់ផលបុណ្យជូនឲ្យខ្លួនឯង នេះជាសេចក្តីបញ្ជាក់ឲ្យ
ឃើញថា បុណ្យ ជូន គុណ ទោស ជារបស់មាននៅក្នុងលោក
ជាធម្មតាមិនមែនកប់ថាប្តូរសាបសូន្យទេ ។ ពាក្យថា បុណ្យ
ជូន គុណ ទោស ទាំងនេះឈ្មោះថាធម៌ ព្រោះជាសភាវៈទ្រទ្រង់
ខុកន្ទរលក្ខណៈរបស់ខ្លួន ។

បុណ្យជូនជាដើមនេះ ឈ្មោះថាជា ប្រវត្តិរបស់ធម៌ ដែល
ចាប់កំណើតកើតឯង ហើយជាក់ឮសជាប់នៅក្នុងលោកដោយខ្លឹងខាត់
មិនចេះចាស់គ្រាំគ្រា ប្តូរនាសសាបសូន្យដោយពិត ប៉ុន្តែជារបស់ស្ងាត់
កំបាំងអំពីប្រជា របស់មនុស្សប្រជុំជន ដូចគ្នឹងជារបស់មាននៅខ្លឹង
ខាត់ ចាប់កំណើតនៅជាប់នឹងអាកាស ឬនៅក្នុងដើមឈើ កាលបើគេចេះ
រិដ្ឋាភាគ្រឿងផ្សំជាគុត្រូវតាមហេតុផល ក្លឹងកំអាចនេះលះជាអណ្តាត
ខ្លឹងបាន បើមិនចេះគ្រឿងផ្សំទេ ក្លឹងកំមិនអាចនេះខ្លឹងបានឡើយ ។
មួយទៀត ព្រះធម៌ដូច ឧសថ គឺថ្នាំសម្រាប់រម្ងាប់រោគ ដែលកើតអំពី
ជាតិឈើ ឬអំពីជាតុផ្សេង ។ ជារបស់កើតមាននៅជាធម្មតា មិនចេះវិ
នាសទេ គ្រូពេទ្យអ្នកចេះចាំក្សួនតម្រាអាចផ្សំជាតុតាមរូបមន្តឲ្យទៅជា ឧ
សថបានដោយងាយ ។ ពាក្យដែលយើងនិយាយថា ក្លឹងលេត់នេះជា
សេចក្តីសន្មត គឺក្លឹងគ្រាន់តែរលត់អំពីចន្លឿងប៉ុណ្ណោះ ឥតជាក្លឹងរលត់
ចាត់ទៅចាកលោកមែនទែនក៏ទេ សេចក្តីនេះយ៉ាងណាមិញ ប្រវត្តិ

ខ្ញុំកត្តិគុណរបស់ធម៌តែងមានខ្លាំងលោកដោយពិតប្រាកដ មិនចេះ
វិនាសសាបសូន្យ មិនចេះស្ងាប់ធុតតូចតិយ៉ាំងនោះដែរ ។

ពាក្យដែលគេនិយាយថា ព្រះធម៌សាបសូន្យ ឬសាសនារៀវកេយ
នោះ គ្រាន់តែសំដៅយកព្រះធម៌ដែលសាបសូន្យ ចាកខន្ធសន្តានរបស់
បុគ្គលអ្នកសិក្សាអ្នកប្រព្រឹត្តប៉ុណ្ណោះ ពុំមែនសាបសូន្យឬរៀវកេយចាក
លោកឡើយ ។

មគ្គផលនិព្វាន ឈ្មោះជាកិត្តិគុណរបស់ធម៌ តែងតាំងខ្ពស់
ខ្ពាយនៅក្នុងលោកដោយហូរហែរជាជាងមកមិនដាច់ ព្រោះហេតុនោះបុ-
គ្គលអ្នកស្មើបដំណើងកេងមក្នុងលោកនេះតែងមានតែពាល់ ។ ការ តាម
សេចក្តីប្រតិបត្តិក្នុងសាសនារបស់គេ ប៉ុន្តែច្រើនតែប្រទះទៅលើផ្លូវពង
ដោយអំណាចអវិជ្ជានាំសត្វឲ្យវង្វេង ឬដោយគំនិតយល់ខុសតាមលិទ្ធិរបស់
គ្រូដោយខ្លួន ។ ។ ក្នុងកាលជាបន្ទោះព្រះពុទ្ធត្រាស់ឡើង តាំងប្រាកដ
ថាមានបុគ្គលខ្លះក្នុងលោកមានចិត្តឆ្ងៃយណាយចាកកាមគុណ ខ្ពស់ក្តក
បង់ស្រុះស្រួងរកប្រតិបត្តិពង្រាវតារ ដែលជាក្រសែនៃមោក្ខធម៌ គឺព្រះនិព្វាន
ហើយលះកេទគ្រហស្ថ ចេញចាកកាមារម្មណ៍ កាន់កេទជាតាបសឥសី
ប្រព្រឹត្តតបវត្ត ដើម្បីស្រូតទៅរកព្រះនិព្វានជាធម្មតា ។ តាបសខ្លះប្រ
ទះបានតែត្រឹមឈានសមាបត្តិ ឬអភិញ្ញាជាលោកីយប៉ុណ្ណោះ តាបស
ខ្លះហ្មាងរហូតដោយខ្លះគ្រឿងផ្សំ ឬមានគ្រឿងផ្សំធាតុវិជ្ជាច្រើនជាស្មារតី

មិនខាន់គ្រប់គ្រាន់ ព្រះសម្ពុទ្ធរបស់យើង កាលនៅជាពោធិសត្វកំនៅក្នុងពួកតាបសដូច្នោះដែរ ព្រះអង្គតែងជាប់ព្រះហឫទ័យក្នុងការស្វែងរកព្រះធម៌ ទោះបីព្រះអង្គបានជាក្សត្រិយ៍សោយរាជ្យ ដែលគួរស្រឡាំងកាំងក្នុងសម្បត្តិ ឥតឃើញសបរិភោគ ទ្រង់ក៏មិនភ្លេចអំពីដំណឹងបុណ្យឡើយ តែងតេញព្រះហឫទ័យក្នុងកេរតាបសជារឿយ ។ ទំប្រព្រឹត្តយ៉ាងខ្ពស់ក្រៃដ្ឋជាងតាបសឯទៀត ។ ជាដរាបអស់ច្រើនជាតិណាស់ ។ ព្រះមហាបុរសមានព្យាយាមយ៉ាងក្លៀវក្លាអង់អាចអង់អាល មិនតក់មិនលែងចោលអំពីការស្វែងរកមោក្ខធម៌ ព្រោះអាស្រ័យការដឹងថាមុខជានឹងបានឃើញមោក្ខធម៌ដូចប្រាថ្នា ។ ព្រះអង្គទំប្រឹងសន្សំសេចក្តីល្អ លះសេចក្តីអាក្រក់ ចំណាំប្រតិបត្តិរបស់ព្រះអង្គនឹងព្រះធម៌របស់ព្រះអង្គ ឆ្លាប់ប្រតិបត្តិរៀងតបដរាបដល់បច្ឆិមជាតិ ទើបបានត្រឿងឆ្ងាតុសព្វគ្រប់ ហៅថា បារមីធម៌ ១០ ប្រការនោះឯង ។

លុះព្រះបរមពោធិសត្វមានបារមីធម៌ ចូលមកគ្រប់គ្រាន់ក៏បានរំពឹងស្រាវជ្រាវរកពន្លឺញាណព្រះធម៌ជាអនុលោមប្បដិលោម រាល់តែបានឃើញងាក់ឡាស់ដោយសព្វញ្ញុតញ្ញាណហើយទ្រង់សំដែង បើកបង្ហើបបង្ហាញធម៌នោះ ។ ដល់ពួកសត្តនិករឲ្យភ្ញឹកឡាស់ហាក់ដូចជាព្រះចន្ទរះឡើងដូចថ្ងៃ ១៥ កើត ។ ព្រះធម៌ដែលចាប់តំណើតនៅកន្លងថ្ងៃរលោកធាតុជាយូរលង់មកហើយនោះក៏ស្រាប់តែរះបើកអណ្តែតឡើង ហាក់ដូចជាប្រ

សូតចាកលោកជាគុមកប្រតិស្ថានច្ចុ ។ ចំពោះព្រះតក្កៃនៃព្រះមានព្រះ
ភាគ នេះឯងហៅថាព្រះអគ្គត្រាស់ដឹង ។ មួលហេតុដែលនាំឲ្យភ្លូកតា
បសឯទៀត ។ ក្តី តាបសគឺព្រះពោធិសត្វក្តី ទំនង្វាតបំពេញបារមីធម៌
ពាំងនោះ ក៏ព្រោះអស្រ័យការដឹងក្នុងក្រអូប ការចាំប្រតិទិនកិត្តិគុណ
របស់ធម៌ជាប់ហែរ ។ មក ដូចជាដំណឹងថាមាសតេជ្រជាបច្ច័យ នាំឲ្យ
គេស្វែងរកមាសតេជ្រ គឺអស្រ័យការដឹងជាដើមហេតុ ទើបមាន
ការស្វែងរកជាខាងក្រោយគេ ។ មក រហូតទាល់តែបានសម្រេចផលដូច
ប្រាថ្នា ។ ដំណឹងថាមគ្គផល ជាន់ព្រាន រមែងមានក្នុងក្រអូបនៅក្នុង
លោក សូម្បីមគ្គផលជាធម៌ទាំងសូន្យឲ្យធ្លុងឡើងចាកលោកព្រះនិព្វានជា
គុណជាតិដ៏ត្រឡប់ចាកលោកហើយក៏ពិតមែន តែកិត្តិស័ព្ទរមែងសល់
នៅក្នុងលោកមិនចេះសាបសូន្យឡើយ ។ លុះព្រះអគ្គបរិបូណ៌ដោយ
ប្រាជ្ញាស្មារតីគ្រប់គ្រាន់ ដោយសេចក្តីត្រិះរិះជ្រាបច្បាស់ចំពោះព្រះអង្គ
ហើយ ទើបទ្រង់លើកស្រាវជ្រាវប្រមូលយកធម៌ដែលមាននៅក្នុងលោក
ស្រាប់នោះ មកលាតត្រដាងសំដែងសើរើចែករំលែកឲ្យមានមាតិការដោត
ក្រងតម្រៀប ឲ្យមានតម្រង មានរបៀប ជាគោលចាក់ពក់ជ្រៅ
សង្កេបពិស្តារច្បាស់លាស់ជាក់ស្តែងឡើងដើម្បីឲ្យពួកបរិស័ទនិកាយរបស់
ព្រះអង្គ ងាយស្តាប់ងាយពិចារណាកេងវៀរប្រតិបត្តិ ។ ពួកមនុស្សអ្នក
មានសេចក្តីជ្រះថ្លាក្នុងធម៌ គោរពចំពោះព្រះអង្គនាំគ្នាហៅថា ព្រះអង្គ

ជាន់ត្រាស់ដឹកមកមក ។ ធម៌ដែលព្រះអង្គជាន់ត្រាស់ដឹងពាំងនោះ គឺតិ
ធម៌ដែលភ្ជាប់មាននៅស្រាប់ក្នុងលោកនោះឯង ។

សរុបសេចក្តីពាំងអស់ ដែលជាន់អធិប្បាយមកនេះ ឃើញថាព្រះ
ធម៌ជាក់ឮសនៅក្នុងលោកមិនចេះសាបសូន្យ មិនចេះចាស់មិនចេះថ្មីទេ
មនុស្សពួកខ្លះ ដែលប្រកាន់ដោយសេចក្តីកំន្តប្រឡំថា ធម៌មានចាស់
ថ្មីនោះ គួរដូរលេខគំនិតពិចារណាខ្មែរ ប៉ើឃើញថា ការប្រកាន់នោះ
នៅក្នុងលេខកំន្តប្រឡំ គួរលះលុបចោលចេញឲ្យជ្រះស្រឡះ ។

+

+ +

ព្រះអភិធម្មបិដក

(កម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៊ុំ រៀបរៀង

ភាគ

---

៥ – ពហុលកម្ម

កុសលាកុសលេសុ បន យំ ពហុលំ កំ ពហុលកម្មំ ជាម តំ ធីយរត្តំ លទ្ធាសេវនំ វេឯតព្ពំ យំ ក ពលវំ កុសលេសុ សោមនស្ស-ការំ អកុសលេសុ សន្តាបការំ ឯតំ ទ្វយំ ពហុលំ ជាម ហោតិ ។

លំដាប់នេះ សូមវិសជ្ជនាកថ៌កម្មបច្ច័យ អធិប្បាយនូវពហុលកម្មតទៅ សេចក្តីថា ទុវិធំ ពហុលកម្មនោះមាន ២ ប្រការគឺ ពហុលកម្មជាកុសល ១ ពហុលកម្មជាអកុសល ១ ។ បើកម្មជាកុសលមានកម្លាំងឈ្មោះថា ពហុកម្មជាកុសល ។

ម្យ៉ាងទៀត បើសំដែងតាមបទត្ថ គឺប្រែតាមអត្ថនៃបទនោះថា កម្មដែលបុគ្គលធ្វើច្រើន ឬធ្វើរឿយៗ នោះឯងឈ្មោះថា ពហុលកម្ម ។ ធីយរត្តំ អ្នកប្រាជ្ញគប្បីដឹងថាពហុលកម្មនោះ ដោយអំណាចនៃអាសេវនៈ គឺការសេពគប់រឿយៗ ឬធ្វើរឿយៗ នោះឯងឈ្មោះថា

ពុហុលកម្ម ។

សោមធស្ស ... ពហុលកម្មខាងកុសល ធ្វើមនុស្ស
ឲ្យត្រេកអរ ។ ពហុលកម្មខាងអកុសល ធ្វើឲ្យក្តៅក្រហាយក្នុងសន្តាន-
ប៉ុន្តែ ខ្លីនំណត់ការឲ្យផលមិនបានទេ ។ បើអកុសលកម្មមានកម្លាំង
ច្រើនជាងកុសលកម្ម អកុសលកម្មក៏ឲ្យផលដឹកនាំទៅ ។ បើកុសល
កម្មមានកម្លាំងច្រើនជាងអកុសលកម្ម កុសលកម្មក៏ឲ្យផលដឹកនាំទៅ ។
កម្មពាំងពីរនេះ បើខាងណាមានកម្លាំងច្រើនជាង ខាងនោះឲ្យផលដឹក
នាំទៅ ប្រៀបដូចអ្នកចម្បាប់ពីរនាក់ចូលលេងចម្បាប់ជាមួយគ្នា សោ
តសេចក្តី ធម្មតាអ្នកចម្បាប់ពាំងពីរនាក់នោះ បើអ្នកចម្បាប់ណាមាន
កម្លាំងខ្លាំងជាង អ្នកចម្បាប់នោះក៏ចាប់ចោកដួលអ្នកចម្បាប់ម្ខាងដែល
ខ្សោយជាងខ្លួនឲ្យដួលចុះ ក្នុងខណៈស្មាមយុទ្ធបាន សេចក្តីនេះមានឧបមា
ដូចម្តេច ។ យំ ភន្តេ កម្មណាជាកម្មច្រើន មានកម្លាំងច្រើន
ជាង ដោយអំណាចនៃអាសេវនៈគឺការសេពគប់ប្តូរធ្វើញឹកញាយ កម្មនោះ
ក៏ត្រូវសន្តឹត្តន្ទូកម្មមានកម្លាំងតិច ហាមឃាត់ឬពាំងកកម្មដទៃទៀតមិនឲ្យ
ផលបាន មានឧបមេយ្យដូចអ្នកចម្បាប់ ដែលមានកម្លាំងខ្លាំង ចាប់
ចោកអ្នកខ្សោយឲ្យដួលចុះដូច្នោះ ។

រឿងនាយប៉ុន្តូស្លូករឹកប្រុស

អ្នកប្រាជ្ញតម្រិះនិដ្ឋានថា ពហុលកម្មខាងអកុសលឲ្យផលដូចជា-

នាយចុន្ទសូភកែបុរស មានដំណាលថា ចុន្ទសូភកវិតោ នាយចុន្ទសូភកែបុរសនោះ តែងសម្លាប់ជ្រូកលក់ចិញ្ចឹមជីវិតខ្លួនទើបបុត្រកវិយោ ទៅកាន់ជនបទជួរភ្នំទជ្រូក ដោយអាហារ យកមកចិញ្ចឹមទុកខាងក្រោយផ្ទះបស់ខ្លួន បំប៉ននដោយអាហារឱ្យភ្នំទជ្រូកធាត់ធំឡើង ហើយទើបសម្លាប់យកទៅលក់ ។ ឯផ្ទះបស់នាយចុន្ទសូភកែនោះ នៅក្បែរព្រះវិហារ ប៉ុន្តែនាយចុន្ទសូភកែមិនដែលទៅថ្វាយបង្គំ សម្តេចព្រះបរមគ្រូជល់ម្តងសោះឡើយ ។

ថ្ងៃមួយ នាយចុន្ទសូភកែនោះមានជម្ងឺបច្ចុប្បន្ន (គ្រុនក្តៅខ្លាំង) អន្ទះអន្ទែងបម្រះខេទៀលទៅមកក្នុងផ្ទះ ស្រែកថ្ងូរសូរដូចជាសម្លេងជ្រូក ។ ឮរាំ បិទហាត្ថា ជនខាងក្រៅយល់ច្បាស់ក្រែងនាយចុន្ទសូភកែរមៀលធ្លាក់ពីលើផ្ទះមកដី ទើបនាំគ្នាបំបែកជ្រាផ្ទះចេញឱ្យជាប់ ។

តែស្មើ ខណៈ ក្នុងខណៈនោះ កិត្តិសព្ទយសបានឮសម្លេងនៃនាយចុន្ទសូភកែស្រែកដូចជាសូរសម្លេងជ្រូកដូច្នោះ ក៏សំគាល់ថាគេសម្លាប់ជ្រូកធ្វើការជាមង្គល ។ ចំណែកនាយចុន្ទសូភកែនោះបានសោយផលអកុសលកម្មជាពហុលកម្ម ដូចគាល់ខ្លួនសម្លាប់ជ្រូកនោះដែរ ព្រោះហេតុតែផលនៃបាណាតិបាតនោះឱ្យផលរៀបរាប់ជាក់ស្តែងនឹងភ្នែក ។ លុះនាយចុន្ទសូភកែជាច់ខ្យល់ស្លាប់ហើយ ទៅកើតក្នុងអវិចីមហានរក ព្រោះខ្លួនប្រព្រឹត្តទុច្ចរិតលាមកសម្លាប់ជ្រូកជានិច្ច ។

បេតិ បដិក្កន្តា ចំណែកភិក្ខុទាំង៥នោះ ត្រឡប់ពីទីគោចរបិណ្ឌបាត មកវិញ ចូលគាល់សម្តេចព្រះសព្វញ្ញ ក្រាបទូលថា កន្តេ ភគវា ឧបតិត្រព្រះទ្រង់ព្រះភាគ ថ្ងៃនេះក្នុងផ្ទះនាយចុន្ទសូករិកបុរស គេសម្លាប់ជ្រូកធ្វើការមង្គល សម្ងោនជ្រូកស្រែកលាន់ឮចេញពីផ្ទះមកដល់ថ្លង់ជាទីគោចរភិក្ខាចារ ។

តំ សុត្វា សម្តេចព្រះបរមសាស្តាទ្រង់ព្រះសណ្តាប់ពាក្យភិក្ខុក្រាបទូលនោះហើយ ទើបទ្រង់ត្រាស់ថា សម្ងោនដែលអ្នកកល់គ្នាឮនោះ មិនមែនសម្ងោនជ្រូកស្រែកទេ គឺជាសម្ងោននៃចុន្ទសូករិកបុរសស្រែកដោយហេតុសោយផលនៃអកុសលកម្មដែលខ្លួនបានធ្វើ លុះក្ស័យជីវិតហើយ អកុសលកម្មនោះឲ្យផលនាំចុន្ទសូករិកបុរសទៅកើតក្នុងអវចីមហានរក ។

ភិក្ខុទាំង៥ឮក្រាបទូលថា បុគ្គលធ្វើនូវអកុសលកម្មដ៏លាមកក្នុងជាតិនេះហើយ ក៏ទទឹងបានសោយផលនៃអកុសលកម្មនោះក្នុងជាតិខាងមុខ ។

លំដាប់នោះ សម្តេចព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា អាម ភិក្ខវេ តេភិក្ខុទាំង៥ឮ ចាបគាវី បុគ្គលធ្វើនូវអំពើបាបអកុសលជាប្រក្រតី កាលរស់នៅក្នុងលោកនេះក៏រមែងក្តៅក្រហាយ ស្លាប់ទៅកើតក្នុងលោកខាងមុខ ក៏រមែងក្តៅក្រហាយដែរ តែតែង-

ក្តៅក្រហាយក្នុងលោកខាងមុខ ដោយអំណាចសេចក្តីក្តៅក្រហាយ ព្រោះហេតុនៃកម្មនិងផលរបស់កម្ម ដូចនាយចុន្ទសូករកនេះឯង ។

អ្នកប្រាជ្ញគប្បីដឹងថា នាយចុន្ទសូករកបុរស កាលសង់នៅក្នុងមនុស្សលោកនេះ កំបានសោយផលនៃអកុសលកម្មដ៏សហស្ស លុះអស់ដំរីតាមសម្បុលោកនេះទៅហើយ ទៅកើតក្នុងអវិចីមហានរកនោះ ដោយអំណាចនៃអកុសលកម្មដែលកាប់បញ្ចូលក្នុងពហុលកម្ម ។ ឯពហុលកម្មខាងអកុសលកម្មនេះ រមែងសម្រេចផលឲ្យបានសេចក្តីទុក្ខ ។

រឿងនាងកុមារីទុគតិ

ចំណែកពហុលកម្មខាងកុសល រមែងឲ្យបានសោយទូរសេចក្តីសុខក្នុងជាតិនេះនឹងជាតិមុខ ដូចនាង១ជាសិកាម្ចាក់ក្នុងវង្សនៃអនាថបិណ្ឌិកមហាសេដ្ឋី ។ កាលកន្លងយូរមក វង្សត្រកូលនៃអនាថបិណ្ឌិកមហាសេដ្ឋីដាច់អស់ហើយ នៅសល់តែនាង១ជាសិកាម្ចាក់នោះ ជានាងកុមារីមានចិត្តត្រេកអរក្នុងកិរិយាកុសល ជាស្រីកំសត់ទុគតិអនាថា ប៉ុន្តែនាងមានសេចក្តី១ស្រាប់ ប្រគេនសលាកភត្តទានដល់ព្រះសង្ឃមួយថ្ងៃមួយអង្គ ជាកល់ថ្ងៃ ។ នាងទៅសូមសង្ឃអំពីសំណាក់នៃសង្ឃជាមេបញ្ជី ។ នាងកុមារីនោះប្រគេនសលាកភត្តជាប់ជានិច្ចកល់ថ្ងៃ ។ ចំណែរបេកាលមក នាងកុមារីគ្មានវត្ថុអ្វីនឹងប្រគេនសលាកភត្តនឹងធ្វើបិណ្ឌបាតទាន ទើបទៅគាន់ពោះវ៉ែនតាស៊ីឈ្នួលគេធ្វើថ្នាលព្រោះសំណាច

លុះបានទ្រព្យមកហើយក៏ធ្វើសលាកកត្តិទានមួយថ្ងៃមួយអង្គ មិនលះបង់
ការកុសល់ទេះឡើយ ។

ដំណឹងនាងកុមារីធ្វើទានជាប់ជានិច្ចដូច្នេះ កិលេសខ្លួនឯងលេចឡើង
ដល់ព្រះមហាក្សត្រ ព្រះអង្គទ្រង់ព្រះសោមនស្សណាស់ ត្រាស់ប្រើឲ្យ
រាជបុរសទាំងឡាយនាំយកវេវៀចខ្លួនាងមកកាន់ព្រះរាជវាំង ដល់
ហើយទ្រង់ត្រាស់សួរពីនិធ្វើទានទោះចំពោះនាងកុមារី តើមែនដូចពាក្យ
គេថាឬមិនមែន ។ នាងកុមារីក្រាបទូលរៀបរាប់សេចក្តីតាំងពីដើមដំ-
បូងមកដូចជាតាក្សអ្នកផងថាមែន ។ ព្រះមហាក្សត្រទ្រង់ព្រះ
សណ្តាប់ហើយ មានព្រះរាជហឫទ័យជ្រះថ្លាក្រៃលែង តំឡើងតាំងនាង
កុមារីខ្លួនក្នុងនិជាព្រះអគ្គមហេសី ព្រះរាជទានទ្រព្យក្នុងព្រះឃ្លាំង មាន
ព្រះរាជឱង្ការត្រាស់ថា ម្នាលនាងខៅ នាងចូរធ្វើកុងការកុសលតាមចិត្ត
ប្រាថ្នាចុះ ទ្រព្យក្នុងឃ្លាំងតាំងអស់នោះ យើងប្រគល់ឲ្យនាងហើយ។

តតោ បដ្ឋាយ ចាប់ដើមពីនោះមក នាងកុមារីកំសត់ខ្លួនក៏
បានឡើងជាទេវីរបស់ព្រះរាជវរៈខៅ ជាមហាឧបាសិកា បានប្រគេន
សលាកកត្តិទានដល់តិក្ខតាំងឡាយកាន់តែច្រើន ។ ឡើងជាលំដាប់ ទើប
ប្រគេនខ្លួនកត្តិដល់តិក្ខដែលសូត្របានដំរាមកូ ប្រគេនខ្លួនកត្តិដល់តិក្ខុ
ដែលរៀននឹងបង្រៀនព្រះបរិយត្តិធម៌ ។ ព្រះរាជទេវីនេះ លុះរលត់
សង្ខារហើយក៏បានទៅកើតកន្លែងឋានឆកាមាវចរសួគ៌ ។

ការកុសលដែលត្រេះកផវើធ្វើនោះឈ្មោះថាពហុលកម្ម ព្រោះ-
ហេតុធ្វើឲ្យច្រើន ។ ឡើងជាលំដាប់ ។ ការកុសលណាដែលបុគ្គលធ្វើឲ្យ
ច្រើន ។ ឡើងជាលំដាប់ដូច្នោះ ការកុសលនោះកប់បញ្ចូលក្នុងពហុល-
កម្មទាំងអស់ ដូចសាធុជនបំពេញការកុសលកាលថ្ងៃទៃ គឺទស្សាហ៍
ស្តាប់ធម្មទេសនាមិនដាច់ កំចាត់ខាងពហុលកម្មខាងកុសលកម្ម ។
ប៉ុន្តែ ពហុលកម្មជាកុសលនោះ បុគ្គលមិនជាយនឹងធ្វើឃ្លានគ្រប់គ្នាទេ
ព្រោះអ្នកខ្លះមានសន្ដានចិត្តជាពាលឥតសទ្ធាជ្រះថ្លា គឺមិនដឿកម្មមិន
ដឿផលរបស់កម្ម បើឃើញអ្នកសប្បុរសធ្វើកុសលអ្វី ។ ក៏ចូលធ្វើជា
មួយគេដែរ ធ្វើគ្រាន់តែឲ្យគេសរសើរខ្លួនប៉ុណ្ណោះកុំឲ្យគេតិះដៀល
និន្ទាខ្លួន ។ អ្នកខ្លះមានសទ្ធាដឿកម្មផលមុតមាំ ទស្សាហ៍ធ្វើបុណ្យ
កុសលកាលថ្ងៃទៃច្រើន ។ ពេកទៅ អ្នកសទ្ធាដូចគ្នាតែឆ្ងល់និយាយសរសើរ
ថាគេរំធ្វើបុណ្យកុសលជាប់ជានិច្ច គេនឹងបានសោយផលបុណ្យច្រើន
ណាស់ ។ ចំណែកអ្នកឥតសទ្ធាវិញ បែរជានិយាយតិះដៀលថា
គេរំធ្វើបុណ្យច្រើនពេកខាលតែហួសកម្លាំងខ្លួន ធ្វើបុណ្យមិនដឹង
ប្រមាណខ្លួនសោះ ។ ពាក្យសរសើរនឹងពាក្យនិន្ទាទាំងពីរចំពួកនេះ
តែងកើតមានឡើង ដល់សាធុជនជាសប្បុរសអ្នករំបំពេញបុណ្យកុសល
ជាពហុលកម្មជាប់ជានិច្ចឥតខានឡើយ ។ ហេតុនេះ សាធុជនអ្នកស្រ-
ឡាញ់ពហុលកម្មជាកុសលត្រូវដំកល់ចិត្តសទ្ធាឲ្យនឹងធឹង កុំឲ្យឡើងជារ

តាមពាក្យសរសើរ កុំឲ្យភោមនស្សអាក់អន់ចិត្តតាមពាក្យទន្ទិ្ធ គួរតប្បី-
ទំអត់សង្កត់ដោយអធិវាសនាខន្តីពិចារណាឲ្យឃើញច្បាស់ថា «មនុស្ស
កើតមកក្នុងលោកនេះមិនផុតពីពាក្យទន្ទិ្ធគ្រប់គ្នា» ។ សមតាមព្រះ
ពុទ្ធដម្រាស់ដែលអង្គសម្តេចព្រះពិជិតមារ ត្រាស់ទីឆ្ងព្រះអានន្ទថ្លែថា
អានន្ទ នែអានន្ទ ឯតំ និន្ទនិកា បសំសនិកា ពាក្យទន្ទិ្ធ
នេះក្តី ពាក្យសរសើរនេះក្តី រមែងមានទៅក្នុងលោកនេះគ្រប់រូបមនុស្ស ។
អ្នកខ្លះទន្ទិ្ធឬសរសើរព្រះចន្ទ ព្រះអាទិត្យ ផែនដី មហាសមុទ្រ
ឬល់ កំដៅថ្ងៃទំងរក្ងៀង ។ សូម្បីអង្គសម្តេចព្រះបរមគុរុសពលា
ដែលជាអគ្គបុគ្គលកំទៅតែមិនផុត អំពីពាក្យទន្ទិ្ធទំងពាក្យសរសើរដែរ ។
អន្តមសោ ដោយហោចទៅ គ្រាន់តែរូបព្រះបដិមាករ ឬរូបព្រះ-
ពេតយ៍ កំតងំមានមនុស្សទន្ទិ្ធ ឬសរសើរមិនខាន ។ ម៉ៅលោក
ទៅប្រព្រឹត្តទៅជាបាបណា ទន្ទិ្ធទំងសរសើរកំទៅតែមានជាបាបនោះ ។
ឯការដែលទំងរួចផុតពីទន្ទិ្ធឬសរសើរនោះ មានតែសេចក្តីអត់សង្កត់
ខប់ចិត្តដោយអធិវាសនាខន្តីម្យ៉ាងប៉ុណ្ណោះ ។

ការដែលធ្វើចិត្តឲ្យទៅជាកណ្តាល ។ មិនសោមនស្សទំងពាក្យ
សរសើរ មិនភោមស្សទំងពាក្យទន្ទិ្ធនោះជាការក្រណាស់ ពីព្រោះសា-
មញ្ញសត្វបុថុជ្ជនមិនងាយនឹងខប់ចិត្តឃាត់ចិត្តឲ្យទៅជាកណ្តាលៗបានទេ ។
ប៉ុន្តែ មានបុថុជ្ជនខ្លះខំធ្វើឲ្យចិត្តជាកណ្តាល ។ បាន មួយខណៈដែរ

ដោយការគាំងស្មារតីនឹករឭកពីពារណា កិច្ចការដែលជាកុសលជាប្រ
យោជន៍ដល់ខ្លួន ចំរក្សាកុសលនោះមិនឲ្យវិនាសសាបសូន្យទៅវិញ សម
តាមព្រះពុទ្ធភាសិត ដែលទ្រង់ត្រាស់នឹងព្រះអត្តទត្តត្ថេរថា៖

អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថំ បសុតោ សិយា ។

សេចក្តីថា បុគ្គលមិនញាំងប្រយោជន៍របស់ខ្លួនឲ្យវិនាសទៅ ព្រោះ
តែប្រយោជន៍របស់អ្នកដទៃសូម្បីច្រើនទេ នឹងប្រយោជន៍របស់ខ្លួនហើយ
គួរតែជាអ្នកខ្វល់ខ្វាយនូវប្រយោជន៍របស់ខ្លួន ។

បើបុគ្គលនឹករឭកដល់ព្រះពុទ្ធអង្គ ដែលទ្រង់ប្រោសប្រទានសទ្ធម្ម
ទេសនា ដូចសំដែងមកខាងដើមនេះហើយ កំអាចអត់សង្កត់នូវចិត្តសោ-
មនស្សប្រកោមនស្សដែលកើតពីពាក្យ សរសើរឬពីពាក្យនិន្ទានោះបាន
មុខជានឹងស្វែងរកធ្វើអំពើកុសលជាក់ខ្លួនជាប់ជាប្រចាំ មិនអាក់ខាន ។
កុសលដែលបុគ្គលបានធ្វើញឹកញាយច្រើន ។ ឡើងយ៉ាងនេះ ចាត់ជាពហុ
លកម្មទាងកុសល ជាបច្ច័យឲ្យកើតកុងសុគតិភពបាន ។

ពហុលកម្ម សង្ខេបប៉ុណ្ណេះ ។

មហោសធជាតក

(តចប់)

មហារាជ បពិត្រមហារាជអើយ រីប្រពន្ធអ្នកសោតមានសំដីនោះផ្អែមល្ហែមពីពេះ មុខតួឱ្យអាសូរកំណាស្រឡាញ់ពេញចិត្ត ជាអ្នកខៀនត្រង់ផ្ចង់មានយោគគំនិតជាប្រក្រតី មានពពួកស្រីប្រសើរពាំនឡាយ សឹងមកសម្រាប់ជាបរិវារ ហើយជាអ្នកមានសីលអំពីកន្លងគាត់នៅនឹងខ្លួនស្រមោលនឹងរូបពុំដែលចេះឯង ក្រោកដមានប្រុងជាយល់អាថជាប្រក្រតី ប្រកបទូវគុណនោះច្រើន ដោយទូវទោសនោះម្តេចអ្នកឱ្យខក្តួរកសត្យវាធីហ៎ៈ ។

រីព្រះបាទបុប្ផនិមិត្តសំដែងទោសនៃតរិយាថាជាឥតគុណនោះស្តេចបន្ទូលជាបទគាថាដូច្នេះ ៖

ទិដ្ឋារតិសមាបន្នំ អនត្ថវសមាគតំ
សា មំ សតានំ បុត្តានំ អយាចំ យាចតេ ធនំ
សោហំ ធនាមិ សារតោ ឥហ៊ុ ឧដ្ឋាវចំ ធនំ
សុទុច្ចជំ ចជិត្វា បជ្ជា សោចាមិ ទុម្មតោ
ឧព្ភរី តេន នោសេន ធជ្ជាមិ ឧតរក្តិនោតិ។

ម្នៃនាងកេរីបរិព្វាជិកាអើយ នាងនេះជាអ្នកល្ងង់ក្រសាលស្តុះអំណាចតិលេសផង ហើយធ្វើប្រយោជន៍តែក្នុងមិនគប្បី

សូមយកទៅប្រដាប់អាត្មា នាកូនទីដ៏ខ្ជួនោះ ឲ្យមកកាន់អញ ។ ក្រ
មិនបានឲ្យ ។ ហើយអញស្រណោះជនឯវិញ អញប៉ងឲ្យទៅដោយចិត្ត
ស្រឡាញ់ ដូច្នោះហើយមានពាក្យសំដីនោះថា តូច ។ ធំ ។ នោះ
ច្រើន ឯក្រោយអញមានចិត្តនោះពុំស្រណុក ក៏កើតជាសោកស្តាយ
ទ្រព្យនោះវិញ ហេតុនោះ ទើបអញឲ្យទៅកកូស្សអោរក្សទឹកឥន្ទ ។

លំដាប់នោះ នាងតេរីបវិញ្ញាដិកាខូលវិញថា អម្ចាស
បពិត្រមហាកដអើយ ឯប្រពន្ធអ្នកដោយខ្លួរពោសដូច្នោះហើយ រីឯ
តិក្ខណាកុមារមន្ត្រីកុមារប្អូនអ្នកនោះ តើគាត់មានគុណនោះច្រើនប្រការ
ក្រៃពេក ដោយខ្លួរពោសនោះ ម្តេចអ្នកឲ្យអោរក្សទឹកឥន្ទហ្នឹង ? ហើយ
នាងតេរីបវិញ្ញាដិកាខូលវិញថា អម្ចាស បពិត្រមហាកដអើយ !
ស្រុកឯណាមិនចំណុះយើងក្តី ទៅតិក្ខណមន្ត្រីកុមារនោះ គាត់ប្រ
មូលទាំមកបំពេញការដសម្បត្តិនៃអ្នក ហើយគាត់ប្រដាប់តម្កល់ទុកទ្រព្យ
នោះច្រើនប្រពៃ ឮដំណាន់ឆ្ងល់ឆ្ងល់សោត សឹងដំហានក្លាប្រសើរ ប្លែន
អ្នកនោះ តើដោយខ្លួរពោសនោះដូចម្តេច ក៏បានជាអ្នកឲ្យអោរក្សទឹក
ឥន្ទ នាងដោយខ្លួរយើងបានឮរៀងមកថា ទៅតិក្ខណមន្ត្រីកុមារ កាល
ទើបកើតទៅនាព្រះពជមន្ទីរនោះ កាលនោះទៅតិក្ខណមន្ត្រីចំរើនវ័យ
ធំឡើង ឯឆត្តិត្រាហ្មណ៍នោះសោត គាត់ឲ្យជាអ្នកតំណាន់តែងកាន់
ដាវ ហើយឆត្តិត្រាហ្មណ៍ថាដូច្នេះ ម៉ែហាតិក្ខណាកុមារអើយ ចូរ

ថាកាន់ដាវនេះ ធ្វើការបរើអញហោង, ឯចៅតិក្ខណមន្ត្រីកុមារ
សោត តែងសំគាល់ថា ឯព្រាហ្មណ៍នេះ គាត់ជាឪពុក ហើយ
អញនឹងចំរើគាត់អំពីថ្ងៃនេះទៅហោង ។

លំដាប់នោះ, មានអាមាត្យមួយមកស្រដីប្រាប់តិក្ខណមន្ត្រីកុមារ
ថា ម្នាលចៅតិក្ខណមន្ត្រីកុមារអើយ! អ្នកឯងសោត មិនមែនជា
ជាកូនឆ្កែព្រាហ្មណ៍នេះឡើយ, អ្នកអើយ! កាលប្រសូតអ្នកចេញ
មកអំពីផ្ទៃម្តាយអ្នកហើយ សណាគខេវឯងគាត់បំពុលសម្លាប់នៃស្តេចម-
ហាពុទ្ធនីរាជ ជាព្រះជនកអ្នកហើយទាំងបង្អែរពាជសម្បត្តិស្នូតច្រត្រឡប់
ព្រាហ្មណ៍សោយពាជសម្បត្តិវិញហោង, រីស្តេចមហាពុទ្ធនីរាជ មែន
ពិតប្រាកដជាព្រះបិតាអ្នកហោង ។ រីចៅតិក្ខណមន្ត្រីកុមារសោត
កាលណាបើបានស្តាប់ពាក្យអាមាត្យនោះ ដឹងជាក់ច្បាស់ប្រាកដដូច្នោះ
ហើយ ខឹងខឹងព្រាហ្មណ៍នោះមហិមាក្រៃពេក ហើយគិតពិចារណាថា
បើដូច្នោះអញអត់អង្គាល់ឡើយ អញនឹងសម្លាប់ព្រាហ្មណ៍នេះចោលឥឡូវ
ម្យ៉ាត ដោយខ្លួនឯងបាយកលអ្វីមួយ ដោយខ្លួនឯងចំណេះប្រាជ្ញាអញ
ហោង ។ លុះនោះ ចៅតិក្ខណមន្ត្រីកុមារ កាលនឹងចូលទៅ
កាន់ត្រកូលស្តេចហើយ ឲ្យដាវមួយទៅអាមាត្យតែងបំរើ ហើយទៅ
ស្រដីនឹងអាមាត្យដទៃថា ម្នាលព្រះស្តេងអើយ! ចូរព្រះស្តេងទៅនា
ព្វារស្តេច ហើយដណ្តើមដាវនេះមួយថា ដាវអញ ហើយព្រះស្តេងធ្វើ

ជាដំណោះប្រកែកផង់គ្នា តែវិតតែជាវិនេះអ្នកផ្តាំដូច្នោះហើយ អ្នកចូលទៅ ឯបុរសទាំង ២ នាក់ធ្វើជាឈ្លោះគ្នា ឯចៅតិក្ខណមន្ត្រីកុមារ គាល់ណាបើឮអ្នកទាំង ២ នោះ ឈ្លោះគ្នាដូច្នោះហើយថា : អស់អ្នកទាំង ២ ឈ្លោះគ្នាប្រកែកអ្វី ? បុរសទាំង ២ ឮហើយឆ្លើយថា អ្នកអើយ! យើងជាណ្តើមជាវគ្នា ! ទើបអាមាត្យក្រឡាប់មកវិញប្រាប់ថា អម្ចាស់តែឈ្លោះប្រយោជន៍ជាណ្តើមជាវផង់គ្នាអម្ចាស់ ទើបចៅតិក្ខណមន្ត្រីនោះប្រើខ្លួវអាមាត្យនោះទៅហៅ ឯឥត្ថិព្រាហ្មណ៍នោះសោត ឮហើយជណ្តើងថា វៃចាតិក្ខណមន្ត្រីកុមារៈអើយ ! ពាក្យនោះថាអ្វី ? ចៅតិក្ខណមន្ត្រីទូលថា ឆេះ បពិត្រអម្ចាស់អើយ ! ដោយខ្ញុំអញខ្ញុំឮតែប្រាប់ថា ជាវដែលអម្ចាស់ឲ្យខ្ញុំកាន់នោះ មានបុរសមួយក៏មកជណ្តើមថាជាជាវ ព្រាហ្មណ៍ថា ម្នាលតិក្ខណមន្ត្រីកុមារអើយ ! បើដូច្នោះចូរបាឲ្យទៅយកជាវនោះមកអញនឹងមើលផង ថាបើជាវនោះហើយអញស្គាល់ឯងអេះ ចៅតិក្ខណកុមារ ក៏ឲ្យទៅយកជាវនោះមកដល់ហើយ ហូតចេញអំពីស្រោមស្រែចហើយ ទើបចៅតិក្ខណមន្ត្រីកុមារទូលថា ឆេះ បពិត្រអម្ចាស់អើយ ! ចូរអម្ចាស់ឯងមើលមើលហោង ហើយធ្វើហាក់ដូចនឹងបង្ហាញឲ្យឯងទៅខៀបហៀបដល់ ហើយលើកឡើងសំពង់វិធ៍ទៅតែម្តង ជាច់ក្រាហ្មណ៍ធ្លាក់ក្បាលតូងចុះខាងដើងអាត្មានោះហោង ។

តតោ រាជកុមារោ ឱហីរិត្វា រាជវេសំ បដិបជ្ជិត្វា ឧភោ អលង្ការិត្វា តស្ស អភិសេកេ ឧបដ្ឋិតេ មាតា ចូឡនិកុមារស្ស មត្ថកេ វិសេ-ឆការំ អាចិក្ខិ ។ លំដាប់នោះ រីឈាតិក្ខណមន្ត្រីកុមារ អ្នកឲ្យដំរះព្រះរាជមន្ទីរស្តេចស្រេចហើយ អ្នកឲ្យប្រជាប់ព្រះនគរប្រពៃ រហើយនៃ ទើបឲ្យទៅយកអ្នកមកអភិសេកឲ្យសោយរាជសម្បត្តិជាស្តេច រីព្រះមាតាអ្នកនោះសោត ប្រាប់ទៅចុឡនីកុមារនោះនូវសភាព នៃការឲ្យទៅនៅស្រុកមនុវដ្ឋនាយ ។ ឯរីឈាតិក្ខណមន្ត្រីកុមារ បានឮតាមនោះហើយ អ្នកទៅកាន់ស្រុកមនុវដ្ឋ ទើបអស់សេនាយោធាផង ពាំងឡាយចោមរោមជាបរិវារ ហើយទៅយកអ្នកជាបងនាំមក បង្អែរស្វែតច្ឆត្រយករាជសម្បត្តិឲ្យបងសោយរាជវិញ ។ ចាប់ដើមអំពីនោះទៅ រីឈាតិក្ខណមន្ត្រីនោះសោត សន្មតឲ្យហៅជារាជក្ខណមន្ត្រីវិញហោង។ ឯនាង តើរឹបវិញ្ញាដឹងនូវដណ្តឹងថា មហាកដអើយ ! រីឈាតិក្ខ-ណមន្ត្រីកុមារ ប្អូនអ្នកមានគុណសភាពបង្ហើរអម្បាលនេះ ដោយនូវពោសនោះម្តេច? អ្នកនឹងឲ្យគារក្សទឹកវាំងនោះហឺន ?

ព្រះបាទចុឡនីពដ្ឋ ស្តេចនឹងសំដែងពោសរាជក្ខណមន្ត្រីកុមារនោះហើយ ស្តេចបន្ទូលសូត្រជាបទគាថាដូច្នេះ :

មយោ ចិតា ជានបទា អានិតា ច បដិក្កហំ

អាគតំ បរវេជ្ជកិ អតិដ្ឋាយ ពហុធនំ ។
ធនុក្ក-ហានំ បវរោ ស្វាវេ តិក្ខណាមន្តិ ច
មយាយំ សុទិតោ ភជា ឥតិ បញ្ចតិ ធារតោ ។
ឧបដ្ឋានំបិ មេ អយ្យេ ន សោ ឯតិយថាបុរេ
ភាតរំ តេន ឧសេន ឧដ្ឋាហំ ទុការកិ្ខជោតិ ។

ម្នាងកែវមែរិញ្ជាជិកាអើយ ! អញប្រមូលនាំមកនូវភជសម្បត្តិជាន អំពីនគរដែមកណ្តាប់ដំណល់ទុកនូវទ្រព្យច្រើនឯណា ខ្ញុំធ្វើជាន សឹងជាំក្នុងហាន អញទុកជាទាហានប្រសើរ ហើយសោយភជសម្បត្តិឲ្យស្រណុកចិត្ត តិក្ខណកុមារនេះ បបួលគ្នានាំចេញទៅនៅស្រុកជនបទក្រៅវិញ ហើយគាត់មើលងាយអញនូវប្រការដូច្នេះឯង ម្នាងអើយ សូម្បីអ្នកជាំនឿឡាយតែងបំរើអញក្តី ចៅតិក្ខណមន្ត្រីកុមារនេះ មិនឲ្យមកកាន់អញដូចអំពីមុនទាយឡើយ ម្នាងអើយ ! ព្រោះហេតុអញនេះ ដោយនូវទោសដូច្នេះហោង ទើបអញឲ្យគាក្សេតវាធីនេះ ។

ម្នាងកែវមែរិញ្ជាជិកានូលវិញថា មហាភជ បពិត្រមហាភជអើយ ! ព្រោះហេតុអ្នកនាំងអម្បាលនោះ យើងទុកស្នេះនៅនេះហោង មហាភជអើយ ! ព្រោះចៅធនុសេខកុមារ តើគាត់ជាសំឡាញ់ទឹងអ្នក ប្រកបនូវគុណមានប្រការច្រើនក្រៃពេក ទោះអ្នកឯងក្តី ចៅធនុសេខកុមារក្តី ឯអ្នកនាំងពីរនេះ សឹងកើតទ្រាំ ១ ខែ ១ ថ្ងៃមួយផងគ្នា អ្នក

ចាំងពីរនេះកើតនៅបញ្ចាលនគរហើយសឹងជាសំឡាញ់ផងគ្នា សឹងមានច្បាប់ មានមារយាទប្រពៃ អាល័យតែងដើរតាមរួមទុក្ខរួមសុខនឹងគ្នាតុំដៃលខ្ចិលឡើយ ហើយអ្នកខ្វល់ខ្វាយពីព្យាយាមចំរើនគុណប្រព្រឹត្តនឹងអស់ក្រឹត្យផងគ្នា ពោះថ្ងៃពោះយប់ក្តី ហេតុជាសំឡាញ់នឹងគ្នាពោសនោះម្តេចក៏អ្នកឲ្យខកក្តេស្សរៈភតីហ្នឹង ?

លំដាប់នោះ ព្រះចុន្ទកុឡ្ឍនីព្រហ្មទត្តភជ ស្តេចសំដែងពោសនៃធនុសេទកុមារហើយបន្ទូលសួរជាបទគាថាដូច្នេះ :

ចវិយា មំ អយំ អយ្យេ សញ្ជាតស្នេហោ មយា សមា
អជ្ជាបិ តេន វណ្ណេន អតិវេលំ បជគ្ឃតិ ។
ឧព្ភវិយាបិ មេ អយ្យេ មន្តយាមិ រហោគតោ
អជាមន្តា បវិសតិ បុត្តេ អប្បដិវេទិតោ ។
លទ្ធង្វាកេ កតោ តាសោ អហិវិកំ អជានរំ
សហាយំ តេន ឆោសេន ឧជ្ឈាហិំ ឧកវត្តិនោតិ ។

ប្រែថា ម្នាលនាងកែវបវរភាដិកាអើយ ! ធនុសេទកុមារនេះកតែងធ្វើអំពើជាល្បែង មិនដឹងអធ្យាស្រ័យនៃអញជាកូនស្តេចឡើយ ហើយជាអ្នកលេងតិះដៀលទៅមកជាមួយនឹងអញ ជាអ្នកមើលងាយពុំកោតក្រែងអញ ការនេះធ្វើខុសគន្លងពេលាពេក នាងអើយ ! អញនឹងស្រដីនាមិនគួរបើស្រដីនោះ លុះអញទៅនៅនាឋានសួគ៌ នឹងបួល

ផ្តាល់ផ្តាប់ស្តេចដឹងចិត្តមុនទោះហើយ ក៏ធ្វើឧបការឲ្យបានជានាគរបើបើក
មិនគួរបើបើក ជាអ្នកឥតខ្មាសហើយឥតពិចារណាផង ក៏ជាសំឡាញ់
នឹងអញទេះ យល់ស្តេចដំណេក ហេតុដោយខ្លួនពេកដូច្នោះហោង អញ
ឲ្យទេកក្តស្រែកឥតហោង ។

លំដាប់នោះ នាងកេរិណីក្រាបដំណាលទូលវិញថា បពិត្រមហាកដ-
អើយ! ទោសនៃចៅធនុសេខកុមារនេះ យើងស្នេះខុសនៅនេះសិន
ដូច្នោះ ព្រាហ្មណ៍បុរោហិត តើគាត់មានគុណប្រការច្រើនទឹងអ្នកពេក
ក្លាត់ ហើយនាងនឹងសំដែងគុណព្រាហ្មណ៍បុរោហិត សូត្រជាបទព្រះ
គាថា ដូច្នេះ :

កាសលោ សព្ភិមន្តានំ វុឌ្ឍានំ អាគតាគមោ
ឧប្បាតេ សុបិនេ យុត្តោ និយ្យានេ ច បវេសនេ។
បហៅ កុម្មគ្គលិក្ខស្មឹ ឧក្កត្តបនកោវិទោ
ព្រាហ្មណាំ តេន នោសេន ឧជ្ឈាសិ ឧកវក្កិនោតិ ។

មហាកដ បពិត្រមហាកដអើយ! រីព្រាហ្មណ៍បុរោហិតនេះ
ជាអ្នកឈ្លាសដឹងខ្លួនហើយពីនិមិត្តផង មានហេតុគេចំនើបជាដើម គឺ
បន្ទូត្រាស សូរ្យត្រាស អ្នកមានតំនិតវិសេសនេះ ចបទេសចបព្រួត
ពុទ្ធព័យចង្រៃផង ចូរកន្ធឹងជួះ ជាអ្នកចេះប្រកបកំចាត់បំបាត់ចបព្រួត
ផង ហើយជាអ្នកដឹងឫក្សយោមនានឹងបញ្ចូលព្រួញជនពុកកន្ធឹងឃ្លាំង ជា

អ្នកឈ្មោះដឹងហោរាយ ដឹងកិច្ចកលផ្លែត្រែក្រាម ហើយដឹងដល់នាគាសនាយនោះ មហាភដអើយ! ព្រាហ្មណ៍បុរោហិតនោះ គាត់មានគុណច្រើនប្រការម៉្លេះនោះ តើដោយខ្លួវគោសនោះម្តេច អ្នកនឹងឲ្យខគរក្ខសវធ៌ហឺ? ។

ទើបព្រះចាតុប្បន្ន ស្តេចសំដែងនូវគោសនៃព្រាហ្មណ៍បុរោហិត ជាបន្លាសូត្រជាបទព្រះគាថាដូច្នេះ ៖

បរិសាយំបិ មេ អយ្យេ ខុម្មិលិត្វា ខនិក្ខតំ
តស្មា អច្ចកមំ លុទ្ធំ ធជ្ជាហំ ខគរក្ខិនោតិ ។

ប្រែថា ម្នាងដ៏ចេរីបរិព្វាជិកាអើយ! សូមអ្នកអង្គុយនៅទាកណ្តាលដំខ្ទុះបរិស័ទអាមាត្យទាំងឡាយក្តី នាងអើយ! ព្រាហ្មណ៍បុរោហិតនោះ គាត់ភ្លៀកភ្នែក ធ្វើភ្នែកក្រឡៀវទៅដូចតេឡឹង ហើយរមិលមើលហាក់ដូចតេរមមកអញគាំងតិតភ័យ ហើយអញចុះទៅដោយហេតុគោសនោះហោង អញឲ្យខគរក្ខសវធ៌ ។

លំដាប់នោះ នាងចេរីបរិព្វាជិកាខូលវិញ្ញាថា មហាភដ បពិត្រមហាភដអើយ! អ្នកទាំង ៥ នេះ ហេតុគោសដូច្នោះហើយ ហើយអ្នកសូមឲ្យខគរក្ខសវធ៌ខ្លួនអ្នកឯង បើដូច្នោះ អញនឹងដណ្តឹងអ្នកវិញទៀត អ្នកយល់គុណចៅមហោសថមានប្រការនោះតើដូចម្តេច? នាងចេរីបរិព្វាជិកាខូលដណ្តឹងសូត្រជាបទព្រះគាថាដូច្នេះ ៖

សសមុទ្ទបរិសាសំ មហាសាគរគុណ្ណាលំ
ឥសុទ្ធរំ អារាសសំ អមច្ចុនរិភរិតោ ។
ចាតុរន្តោ មហារជ្ជោ រិជិតារី មហាព្យសោ
បថព្យា ឯកាធជាសិ យសោ តេ រិបុលំ គតោ ។
សោឧប្បសិត្តីសហស្សានិ អាមុត្តមណិកុណ្ណលា
ជាជាជនបទា ជារី នេវកញ្ញាបមា សុភា ។
ឯវំ សព្វង្គសម្បន្នំ សព្វកាមសមិទ្ធិនំ
សុខិតានំ បិយំ ឥឃំ ជីវិតំ អាហុ ខត្តិយ ។
អថ តុំ កេន វណ្ណេន កា បន ហេតុជា
បញ្ញិតំ អនុរក្ខន្តោ ចាបំ ចជ្ជសិ ខុទ្ទជន្តុ ។

ប្រែថា មហាក្សត្រអើយ! ឥឡូវនេះ អ្នកជាស្តេចប្រសើរតែម្នាក់ឯង នៅទាំងផែនក្រោមនេះជាឥស្សរកំពូលអស់ទ្វីបទាំង ៤ ដ៏មានទីទៅទូវអាមាត្យមុខមន្ត្រីសេនាបតីជនទាំងឡាយជាបរិវារ ឯអស់អ្នកជនទៅសព្វថ្ងៃដ៏ផែនក្រោមនេះ មានអ្នកដ៏ជាតិសូរអស់នាឋានលំនៅបុរសជនទាំងឡាយ ទៅដល់ឆ្នេរមហាសមុទ្ទជាបរិក្ខេបៈ រីសមុទ្ទសាគរនោះសោត តែងជាគ្រឿងប្រដាប់ផែនក្រោមនេះ ហើយមានកំលាំងនោះច្រើនអ្នកមានជ័យឈ្នះសង្គ្រាមចម្បាំងនោះផង រីក្តីក្តើយសូអ្នកសោត ដ៏ជ លាយ មានទីទៅទូវស្រីស្តុកជនទាំងឡាយ មួយម៉ឺនច្រាំមួយពាន់

សឹងពាក់ខ្លីទៅទូវែងឯកុណ្ឌលផង សឹងតែវិមណីរតែនព័ចិត្រប្រៃ ស្រីជនបទផងផ្សេង ។ សឹងល្អប្រៃ ដូចស្រីសួគ៌ទេពកញ្ញា ហើយអ្នកប្រកបទូវែសូរសេម្បត្តិតាំងអម្បាលនេះ ទើបលោកហៅមហាក្សត្រសេដ្ឋីតែហើយតែងនឹងប្រកបទូវសុខសួស្តីសំរិទ្ធិ លុះដោយទូវចំណង់តាំងពួងខោះអ្នកផងតាំងពួងនឹងស្រឡាញ់អស់កាលដ៏លង់ទៅហោង ហើយម្តេចកំអ្នកមកវក្សាឯចៅមហោសថអ្នកប្រាជ្ញខេះ ហើយថាស្ងួចង់ដឹងតែគាត្មាឯងវិញដូច្នេះ តែមួយទីសោត ហេតុដោយវណ្ណៈអ្វី ដោយហេតុប្រយោជន៍នោះតើឈ្មោះអ្វី កំអ្នកថាស្ងួចង់ដឹងតែអ្នកឯងវិញនោះហឹង ។

ឯព្រះបាទបុប្ផនីព្រហ្មទត្តនោះមិញ អ្នកស្តាប់នាងតែមែរឮជាគរហើយ ស្តេចខឹងសម្តែងគុណនៃចៅមហោសថអ្នកប្រាជ្ញ ទើបសូត្រជាបទគាថាដូច្នេះ ៖

ជួនចាស់ម្នាក់ឈ្មោះ កញ្ចាំ សែនខុទ្ទិសធិល ជួនទៅឱ្យខ្មោចធម៌សុបរិត

រៀបរៀងដោយព្រះសាសនមុនី កឹម-ភ្ជុ

រឿងនេះជាប្រវត្តិមួយដែលកើតឡើងកន្លងទៅជាយូរអង្វែងហើយ: មានបុរសកម្លោះម្នាក់នៅក្នុងក្រុងភាពណាសី កាលដែលឪពុកខ្លួនអនិច្ចកម្មទៅហើយ គាត់លើកតម្កល់តម្កើងម្ចាយខុកកង់ថានៈដ៏ខ្ពង់ខ្ពស់ដូចជាទេវតា ទំប្រតិបត្តិថែទាំបំរើម្ចាយដោយកិច្ចវត្តគ្រប់យ៉ាង មានដូនទឹកក្តៅទឹកត្រជាក់សម្រាប់ងូត លុបមុខនឹងឈើស្ទន់ជាដើម ជូនចំណីអាហារមានបបរនឹងចុាយជាដើមគ្រប់វេលា ។ យាយកញ្ចាំជាម្ចាយ ដោយហេតុមានកូនប្រុសតែមួយជាទីស្រឡាញ់ ឃើញកូននោះធ្វើការនៅព្រៃផងនៅផ្ទះផង ដែលមានសេចក្តីខ្វល់ខ្វាយច្រើនពេក ទឹកភ្នែកកូនយ៉ាងក្រៃលែងហើយនិយាយនឹងកូននោះថា នែកូន! សព្វថ្ងៃ ម្ចាយឃើញកូនឯងខ្លាំងណាស់ ណាធ្វើការព្រៃផង ណាជាតមកធ្វើការផ្ទះផង។ ម្ចាយគិតថា នឹងរកប្រពន្ធឱ្យកូនឯងកុងតេលទាប់។ នេះ ដើម្បីឱ្យវាធ្វើការនៅផ្ទះ ជំនួសកម្លាំងកូនឯងខ្លះ តើកូនឯងយល់ថាម៉េច? កូនប្រុសឆ្លើយថា ខ្ញុំមិនសូវជាចង់ចុាននុ៎ងទេ ព្រោះគិតឃើញថា យកគេមកនៅក្នុងផ្ទះ ឱ្យគេបំរើម្ចាយខ្លួនក្រែងមិនដូចខ្លួនខ្ញុំ ខ្ញុំគាំងចិត្តថា យកខ្លួនបំរើមើអស់មួយជីវិត កុំឱ្យមែព្រួយ ។ យាយកញ្ចាំ ពោះឮពាក្យកូន

និយាយប្រកែកដោះសាយ៉ាងណា កំនៅតែមិនអស់មិនហើយឥតក្នុងចិត្ត
សោះ ចេះតែខ្ជូចនិយាយហើយ និយាយទៀត អស់ពាក្យជាច្រើនដង ។
ឯបុរសជាកូននោះ ពាល់គំនិតកំនៅស្ទឹមឥតមានប្រកែកថាអ្វីទៀតឡើយ
ដោយគាំងចិត្តគោរពចំពោះម្តាយរបស់ខ្លួន ។ យាយកុច្ចានី ពាលបើដឹង
ថាកូនលែងប្រកែកហើយ កំនៅគាន់ត្រកូលមួយ និយាយជណ្តើងកូនស្រី
គេដែលមានជាតិត្រកូលប្រហែលគ្នានឹងខ្លួន ត្រកូលនោះកំព្រមព្រៀង
ប្រគល់ឲ្យ ហើយកំនាំគ្នាធ្វើអាពាហមង្គលតាមប្រពៃណីរួចសព្វគ្រប់ហើយ
យាយកុច្ចានី កំនាំកូនប្រសាស្រីនោះមកឲ្យនៅក្នុងផ្ទះរបស់ខ្លួន ។ នាង
កូនប្រសានោះ តាំងតែចូលមកនៅក្នុងផ្ទះម្តាយក្មេក នៅរួមសុខទុក្ខជា
មួយនឹងក្តីរបស់ខ្លួន មុនដំបូងកំយកចិត្តទុកដាក់ធ្វើកិច្ចការក្នុងផ្ទះបំរើគោរព
ម្តាយក្មេងឥតមានការមោះហ្មងអ្វីឡើយ ។ លុះកាលជានាងក្រោយមក
នាងនោះកំមានគំនិតអាក្រក់កើតឡើង ចង់បណ្តេញចំបងចង់ម្តាយក្មេក
ចាស់នោះឲ្យចេញពីផ្ទះ ព្រោះថាបើទុកឲ្យយាយចាស់នៅក្នុងផ្ទះនេះតទៅ
នាំឲ្យអញលំបាកបំរើផ្គាប់ផ្គុំណាគាត់ណាស់ បើកេរុបាយធ្វើឲ្យគាត់នេះ
ឃ្លានចេញពីផ្ទះទៅ អញនឹងបានសុខស្រួល មិនសូវលំបាកប៉ុន្មានផង ។

ថ្ងៃមួយ នាងនោះនិយាយនឹងប្តីរបស់ខ្លួន ដោយប្រើកេរុបាយទុច្ចរិត
ញុះញង់មួលបង្កាច់បំផ្លើសពីសេចក្តីពិត ខ្មាក់ខោសកំហុសទៅលើ
យាយ កុច្ចានីជាម្តាយក្មេក ដើម្បីឲ្យប្តីជឿថា បង ! បងឯងចេញពីផ្ទះ

ទៅធ្វើការខាងក្រៅជាតិទៅ ម្តាយបងឯង មិនដឹងជាហេតុអីទេ ស្រាប់តែដេរបញ្ឆោវុឹតែម្តង ។ បុរសជាប្តីនោះ ឮពាក្យប្រពន្ធនិយាយច្រើនដូច្នោះ មុនដំបូងនៅស្ងៀម ។ ក្រោយមក ប្រពន្ធក៏និយាយទៀត ។ ចាប់ដើមពីថ្ងៃនោះ នាងប្រពន្ធចេះតែបង្កហេតុផ្សេង ។ ជួនកាលដួសយកបបរដែលកំពុងក្តៅឡាំងទៅបង្ខំម្តាយក្មេកឲ្យបរិភោគ កាលបើម្តាយច្រើនថា បបរនេះនៅក្តៅណាស់កុំគាលសិន ក៏ទៅយកទឹកត្រជាក់មកចាក់ប៉ះពេញក៏មាន ជួនកាលយកបបរត្រជាក់ស្រេងទៅបង្ខំឲ្យបរិភោគ បើម្តាយក្មេកច្រើនថា បបរនេះត្រជាក់ណាស់ ទៅយកទឹកក្តៅកំពុងពុះមកចាក់ប៉ះពេញក៏មាន ជួនកាលយកបបរប្រៃពេក ស្ងាបពេក ទៅបង្ខំឲ្យបរិភោគក៏មាន កាលបើម្តាយក្មេកច្រើនថា បបរប្រៃពេកឬស្ងាបពេក ក៏ស្រែកគំហកគម្រាមដោយសំដីគ្រោះថ្នាក់ថា គ្មានអាណាផ្តាច់ចិត្តកញ្ឆាស់ឯងត្រូវទេ ម្តងអីចេះ ម្តងអីចុះ គេយកបបរក្តៅមកឲ្យថាក្តៅពេក បបរត្រជាក់ថាត្រជាក់ពេក យកបបរប្រៃមកឲ្យថាប្រៃពេក បបរស្ងាបថាស្ងាបពេក បើចេះតែយ៉ាងហ្នឹង អាណាផ្តាច់ត្រូវ ។ នាងនោះចេះតែរអ៊ូរទាំ ធ្វើអាការបញ្ឆោះបន្ទោសបង្កហេតុឈ្លោះប្រកែកជាមួយនឹងម្តាយក្មេកដូច្នេះតែរាល់ថ្ងៃ ដោយគំនិតមិនចង់ឲ្យម្តាយក្មេកនៅក្នុងផ្ទះជាមួយ ។

កាលណាបើប្តីត្រឡប់មកពីធ្វើការវិញម្តង ។ នាងប្រពន្ធតែងនិយាយតួញតែរៀបរាប់ប្រាប់ប្តីដូច្នេះៗ ដូច្នោះៗ តាមដែលខ្លួនឯក

ឃើញ ហើយក៏និយាយថែមទៀតថា ខ្ញុំម៉ែលទៅប្រហែលជាគ្រាំនៅក្នុងផ្ទះនេះជាមួយនឹងយាយកញ្ចាស់ចង្រៃការឡកណ្តៀបបនេះទៀត តុំបានទេ បើបងឯងមិនដឿ មិនស្តាប់ខ្ញុំទេ ខ្ញុំមុខជានឹងចុះចេញទៅនៅខាងផ្ទះម្តាយឪពុកខ្ញុំវិញ នៅថ្ងៃណាមួយជាមិនខាន ។ បុរសជាប្តី កាលបើប្រពន្ធនិយាយច្រាបអំពីទោសម្តាយរបស់ខ្លួនញាយ ។ ហើយ ក៏ដឿតាមពាក្យប្រពន្ធ ហើយទៅនិយាយរករឿងបណ្តោញម្តាយខ្លួនថា ម៉ែឯងចុះចេញពីផ្ទះនេះទៅ ចូរទៅនៅទីណាដែលតេញចិត្តចុះ ។ យាយកញ្ចានី ជាម្តាយ លុះឮសំដីកូននិយាយបណ្តោញខ្លួនដូច្នោះ ក៏កើតទុក្ខ ទ្រហោយំ ចុះចេញពីផ្ទះ ហើយទៅធ្វើការស៊ីឈ្នួលអាស្រ័យ នឹងត្រកូលដ៏ស្តុកស្តម្ភមួយរកស៊ីចិញ្ចឹមដ៏តែដោយលំបាក ។ កាលដែលម្តាយក្មេកនោះចេញពីផ្ទះទៅហើយ ខាងក្រោយមក កូនប្រសាស្រីនោះមានគភ៌ បានកើតកូនប្រុសមួយក៏និយាយនឹងប្តីថា នែបង! បងឯងឃើញទេ ម្តាយបងឯងតេញជាស្រីចង្រៃមែន កាលដែលម្តាយបងឯងនៅក្នុងផ្ទះជាមួយខ្ញុំ មិនចេះមានកូនសោះ ឥឡូវស្រាប់តែខ្ញុំមានកូន បងឯងចូរដឹងថាម្តាយបងឯងនោះពិតជាស្រីការឡកណ្តៀប្រាកដមែនហើយ ។

ចំណែកខាងយាយកញ្ចានីបានដំណឹងថា កូនប្រសាមានកូន ខាងក្រោយដែលខ្លួនថយចេញពីផ្ទះហើយបានតាំងគ្រៃទៀតថា ចង្រៃមកពីខ្លួន ទើបបានជាគេគ្មានកូន ។ យាយកញ្ចានីនឹកថា : តុព្វោអើយ! បើរឿងនេះពិត

ដូច្នោះមែន គួរឲ្យអស់សំណើចណាស់ ដេរដ្ឋាបថាយនធម្មិ (ធម្មិសម្រាប់ធ្វើសេចក្តីគោរពកោតក្រែងរាងគ្នានឹងគ្នា ក្នុងត្រកូលត្រួសារ) ឱនឯធម្មិសុបរិតតាំងបីយ៉ាងក្នុងលោកនេះ ប្រហែលជាស្ងាប់ផុតទៅហើយទេដឹង? បើធម្មិសុបរិតតាំងនេះមិនទាន់ស្ងាប់នៅឡើយទេ កូនដែលកដេរ ប-ណ្តេញម្តាយឲ្យចេញពីផ្ទះ មុខជាមិនបានកូនទេ មុខជាមិនបានសុខទេ ដូច្នេះយើញថា ដេរដ្ឋាបថាយនធម្មិឱនសុបរិតធម្មិ ស្ងាប់ផុតជាប្រាកដហើយ ។ ម៉េយ៉ាងហ្នឹងមែន អញគួរតែធ្វើបុណ្យទុទ្ទិសផលបញ្ជូនទៅឲ្យភ្លោចធម្មិតាំងនោះ ។ លុះគិតដូច្នោះហើយ យាយកញ្ចាន៏ ក៏រៀបចំយកឆ្នាំងឱនអង្គរ ព្រមតាំងម្ហូបខ្ទះបន្តិចបន្តួច ដើរចូលទៅកន្លែងព្រៃភ្លោច ដល់ហើយក៏រើសប្រមូលក្បាលភ្លោចមនុស្ស៣ មកដាក់តែលើធ្លីជាមុំដើងក្រានតាំងដណ្តើ ជាយ ចំអិនម្ហូប រួចហើយក៏បេះស្លឹកឈើយកមកដាក់ជាយខ្ទះម្ហូបខ្ទះរៀបចំសែនទុទ្ទិសទៅឲ្យភ្លោចធម្មិថា ។ ដេរដ្ឋាបថាយនធម្មិ ឱនសុបរិតធម្មិអើយ! អ្នកប្រាកដជាស្ងាប់ផុតទៅហើយ ជានាងខ្ញុំត្រូវកូនធ្វើទុក្ខបុកម្នេញ ដេរបណ្តេញឲ្យចេញពីផ្ទះ ហើយមកនៅឯទុក្ខលំបាកតែម្នាក់ឯងយ៉ាងនេះ បើអ្នកនៅស៊ីមិនស្ងាប់ទេ ប្រហែលជានាងខ្ញុំបានសុខ នៅរួមជាមួយនឹងកូន មិនមែនមកទទួលទុក្ខវេទនាដូច្នេះឡើយ ខ្ញុំជឿជាក់ថា សុបរិតធម្មិប្រាកដជាស្ងាប់មែនហើយ ឥឡូវខ្ញុំសូមទុទ្ទិសកុសលនេះ ជូនទៅឲ្យភ្លោចធម្មិសុបរិតឯង សូមឲ្យអ្នកទទួលយកចុះ ។ ខណៈនោះ មានខ្ពាមួយ

អង្គ យើញយាយកញ្ចាន ដែលដល់ខ្លួវសេចក្តីក្តៅសំបាក កំពុងតែធ្វើកិច្ច
សែនទេវតាសុសលជូនទៅឲ្យរំលែកណាខ្លួនខ្មោចធម៌សុចរិត ដោយសំ
គាល់ថា ធម៌ស្ងាប់ហើយ តំដណែនគេទេជាព្រាហ្មណ៍ចាស់ម្នាក់ដើរចូល
ទៅសួរថា នែយាយ! យាយឯងរៀបចំធ្វើអីហ្នឹង?-ចាសគា! ខ្ញុំសែន
ជូនបុណ្យទៅឲ្យខ្មោចធម៌សុចរិត ។ គាព្រាហ្មណ៍សួរថា យ៉ា! សែន
ជូនបុណ្យទៅឲ្យខ្មោចធម៌សុចរិតយ៉ាងម៉េចអីចេះ ចំឡែកណាស់តើ ខ្ញុំ
តាំងពីកើតមកដល់ចំណាស់នេះ មិនដែលឮ មិនដែលឃើញបែបនេះ
សោះទេ ឮតែឃើញតែគេសែនជូនទៅឲ្យខ្មោចមនុស្ស ចុះរឿងនេះ
វាមានហេតុគេទេដូចម្តេចខ្លះទៅ ចូរយាយប្រាប់ឲ្យហូរវែមកមើល?-ទ
គាអើយ! រឿងនេះ គឺវាកើតលេចចេញមកពីសាច់ឈាមឯងតែម្តង មិន
មែនអ្នកដទៃគ្រោមកឲ្យទេ ដំបូងខ្ញុំ មានកូនប្រុសតែមួយជាទីស្រឡាញ់
របស់ខ្ញុំ លុះវាតអំពីប្តីរបស់ខ្ញុំទៅ កូនប្រុសខ្ញុំនោះ មានជេដ្ឋបចាយន
ធម៌ ទើសសុចរិតធម៌ រស់រើតមកលើរូបខ្ញុំ គឺចេះតែរាតប្រតិបត្តិខុក
ចំរុងគ្រប់បែបយ៉ាង មានដូនខឹកក្តៅខឹកត្រជាក់ ទើងចំណីអាហារជាដើម
ដល់ខ្ញុំគ្រប់វេលា គ្មានដែលមានហ្នឹងអ្វីឡើយ ខ្ញុំគិតឃើញថាសព្វថ្ងៃ
កូនមានសេចក្តីខឿយហត់លំបាកណាស់ ធ្វើការនៅក្រៅផ្ទះឯង ងាកមក
ធ្វើការក្នុងផ្ទះឯង លុះគិតឃើញយ៉ាងនេះហើយ ក៏និយាយនឹងកូនថា នែ
កូន! ម្តាយគិតរកប្រពន្ធឲ្យកូនឯងគ្រាន់តែនឹងមានឲ្យគេជំទួសកម្លាំងកូន

ឯងវិញ ។ មុនដំបូង កូនខ្ញុំប្រកែកមិនត្រមយកដែរ ប៉ុន្តែដល់និយាយ
បង្ខំញុយ។ ទៅ ក៏ត្រមតាមខ្ញុំ ខ្ញុំទៅនិយាយដណ្តឹងកូនស្រីគេបានហើយ
ធ្វើមង្គលការរួចសព្វគ្រប់ ក៏នាំយកមកឲ្យនៅក្នុងផ្ទះជាមួយ ។ នាងកូន
ប្រសារនោះ មុនដំបូងមានអី ស្រួលបួលល្អណាស់ ចេះមានដង្ហើបចាយ
ធម៌ នឹង សុចរិតធម៌ គួរសម រស់រៀកមកលើរូបខ្ញុំជាម្តាយក្មេកដូចជាកូន
ប្រុសបង្កើតដែរ ។ ទាំងក្រោយមក មិនដឹងជាខុសតាលក្តី មេកូនប្រសា
នោះ វាក្តៅក្រហាយដូច្នឹងក្តុបក្តួមភ្លា បញ្ឆោះបន្ទុកដល់ខ្ញុំតែពាលថ្ងៃ
លែងមានដង្ហើបចាយនធម៌ នឹងសុចរិតធម៌ មកលើរូបខ្ញុំទាល់តែសោះ
មិនតែប៉ុណ្ណោះ ក៏និយាយញុះញង់ដឹកនាំកូនប្រុសខ្ញុំដែលត្រូវជាប្តីក៏ ឲ្យ
ជួយរឹងប្រឌឹងខ្ញុំថែមទៀត ឯកូនប្រុសខ្ញុំនោះសោត ដែលជាកូន
ធ្លាប់តែមានដង្ហើបចាយនធម៌នឹងសុចរិតធម៌ គួរសមមកលើរូបខ្ញុំជាម្តាយ
ជាន់ចុងក្រោយតុំដែលមានឧុសថានអ្វីម្ល៉ងសោះ ក៏ត្រឡប់ទៅសម្លាប់ដង្ហើ
បចាយនធម៌ នឹងសុចរិតធម៌ឲ្យស្ងាប់អស់រលីង ដោយការញុះញង់ពីមេ
កូនប្រសារនោះ ម្ល៉ោះហើយក៏ត្រួតជៀតគ្នា ដេរបណ្តេញបំបរបង់ខ្ញុំជាម្តាយ
ឲ្យចុះចេញពីផ្ទះ ខ្ញុំតុំអាចត្រាំនៅតទៅទៀតបាន ក៏ចុះចេញពីផ្ទះដើរ
ទៅរកសុំទានគេទ្វេរ ស៊ីឈ្នួលគេទ្វេរ ដោយសេចក្តីទុក្ខលំបាកយ៉ាងខ្លាំង
ត្រាន់តែឲ្យរស់នៅទាំងត្រដរ ដរាបមកដល់សព្វថ្ងៃនេះ ។

ពីដើមខ្ញុំធ្លាប់បានឧបត្ថម្ភដង្ហើបចាយនធម៌ នឹងសុចរិតធម៌អំពីកូនឱ

របស់ខ្ញុំ ឥឡូវ ដេរដ្ឋាបថាយនធម៌ ទឹងសុចរិតធម៌នោះស្លាប់ទៅហើយ ទើបបានជាខ្ញុំរៀបចំធ្វើកិច្ចសែនបញ្ចុនបុណ្យនេះ ទៅឲ្យខ្មោចធម៌ដែលស្លាប់ទៅហើយនោះ សូមតាជ្រាបចុះ ។

-ទុអីចឹងទេឬ! បើតាមខ្ញុំយល់ថា ដេរដ្ឋាបថាយនធម៌ទឹងសុចរិតធម៌មិនទេះស្លាប់ទេ គឺរស់រើតតាំងទៅជាប្រក្រតី ប៉ុន្តែមកពីកូនយាយឯងទេតើ ដែលលះបង់ចោលមិនតាន់ ។ អើមិនអីទេយាយ យាយឯងកុំព្រួយ ចាំខ្ញុំទឹងជួយប្រុងប្រៀង ធ្វើឲ្យដេរដ្ឋាបថាយនធម៌ ទឹងសុចរិតធម៌ក្លឹងត្រួសារបស់យាយឯងរស់ឡើងវិញ ហើយទឹងជួយឲ្យយាយឯងបានទៅទៅផ្ទះវិញឆាប់ ដោយទុក្ខយរបស់ខ្ញុំជាមិនខាន ។

- សូមអរគុណទឹងប្រសាសន៍របស់តាណាស់ ប៉ុន្តែខ្ញុំមើលទៅប្រហែលជាគ្មានទិស្សីយសង្ឃឹមថា ទឹងបានទៅទៅផ្ទះនោះវិញទេតា! ។

ទេព្តាដែលតំណែងគេទជាព្រាហ្មណ៍នោះ បានទៅតាន់ផ្ទះកូនរបស់យាយកច្ចានីនោះ ហើយក៏និយាយពន្យល់អំពីគុណទឹងទោសរបស់កូនដែលគោរពទឹងមិនគោរពចំពោះមាតាទឹងបិតារបស់ខ្លួន ឲ្យកូនប្រុសព្រមតាំងកូនប្រសាស្រីនោះស្តាប់សព្វគ្រប់ហើយ ក៏ត្រឡប់ទៅតាន់វិមានរបស់ខ្លួនវិញ ។

ក្រោយដែលបានស្តាប់ទុកទេរបស់ទេព្តានោះមក ដនតាំងពីនាក់តីប្តីទឹងប្រពន្ធ មានសេចក្តីកិតក័យតក់ស្លុតទឹងកំហុសរបស់ខ្លួន ក៏បានញ៉ាំង

ដើម្បីបពាយនធម៌ ទីដ៏សុចរិតធម៌ ឲ្យកើតពោរពេញរស់រវើកក្នុងសន្តានចិត្តឡើងវិញ ហើយនាំគ្នាទៅអញ្ជើញយាយកច្ចានជាម្តាយអំពីព្រៃភ្នំចោះមកឲ្យនៅផ្ទះ ហើយនាំគ្នាគោរពប្រតិបត្តិ ទំនុកបំរុងតាមថាខៈនៃខ្លួនជាកូនដូចដើមឡើងវិញ ។

អំពីចោរកម្ម

(វិចារណកថា)

រៀបរៀងដោយលោក ជេង-ជ្រឹះ

អំពីរឿងចោរកម្មនេះ ប្រទេសណាក៏មាន គ្រាន់តែផ្ទែកគ្នាត្រង់ច្រើនទំងន់តិចប៉ុណ្ណោះ ។ គួរគិតគួរត្រិះរិះដែរ ចំពោះរឿងនេះ ព្រោះជាឧបសគ្គដ៏ធ្ងន់ដល់ប្រទេសជាតិ ។ ច្បាប់សម្រាប់ផ្ដន័មួយ ។ មានបញ្ញត្តិបទចោរកម្ម ទៀតទំងមាត្រាស្ដីពីការហាមឃាត់ ទំងស្ដីពីការផ្ដន្ទាទោស ។ ច្បាប់សាសនាក៏មានលើកយកបទចោរកម្ម មកដោះស្រាយមានតាំងច្រាប់អាទិសង្ឃដំលោមក តាំងខាងបច្ចុប្បន្ន តាំងខាងបរលោក តែចោរកម្មទៅតែមានជាដរាប ។

មានបញ្ហាចោទឡើងថា: ចោរកម្មមកអំពីអ្វី ? ទំងអាចបៀសវាងបានឬមិនបាន ?

តាមការត្រិះរិះ ទំងការសង្កេត យើញថាចោរកម្មកើតមកពីសេចក្ដីត្រូវការ ន័ងសេចក្ដីត្រូវការហួសប្រមាណ ។

ចំពោះន័យនេះ គេជ្រែតចូលមកពន្យល់ថា មានជនខ្លះ មានសេចក្ដីត្រូវការដែរ តែគេមិនអាចធ្វើចោរកម្មបាន ។ បើដូច្នេះ យើញថាសំនួរទី ២ ត្រូវដោះស្រាយទៅឯង ព្រោះមនុស្សអាចបៀសវាងចោរកម្មបាន ។ ពាក្យដែលថា « សេចក្ដីត្រូវការ ទំងសេចក្ដីត្រូវការហួសប្រមាណ » ជាការណ៍ពិត តែការណ៍ពិតនេះ រមែងពឹងផ្អែក

រមែងសិតផ្តេក តែទៅលើចរិយារបស់ដទៃម្នាក់ ៗ ប៉ុណ្ណោះ មិនមែនជាការណ៍ ដូចទៅឡើយ ព្រោះកោតៈអាចនឹងរកតាមផ្លូវសុចរិតបាន ។

តទៅនេះ នឹងល្បងមើលវែកញែកនូវប្រភេទនៃចោរកម្ម តើដូចម្តេចខ្លះ?

ចោរកម្មចែកជាមេចម្បងមានតិ៍ ដែលខ្ញុំសន្មតឈ្មោះថា: ចោរកម្មព្រោះភ្លើង ឧទ្ធចោរកម្មស៊ីស្តរ ។

ឯចោរកម្មព្រោះភ្លើងចែកជាមែកជាងច្រើនប្រការ: ការគាន់យកដោយស្វាត់កំបាំងក្នុងចិត្តនឹត ការឆក់យក ការប្លន់យក ការប្រវាញ់ ចោតបញ្ឆោត ការប្លន់ ។ល។ ពាក្យនេះហៅថាចោរកម្មព្រោះភ្លើង ។

ចុះចោរកម្មស៊ីស្តរដូចម្តេច? ចោរកម្មនេះឃ្លួមយក: ការលក់ដូរបស់ដោយការបន្ទំ ការលក់ដូរតែក្លែងក្លាយ ការលក់ដូរដោយវិធីបំបាត់ក្លែកដញ្ឆើង ឬ ដោយដញ្ឆើងក្លែង ការបំពេញមុខជាមិនយកចិត្តទុកដាក់ ការបំពេញមុខជារដោយប្រឈុបប្រឈែងឆ្បោបឆ្បប ខ្ជោមខ្ជឹម ការគាន់មុខជាមិនស្មោះត្រង់ ការប្រព្រឹត្តធម៌មិនតាមតន្ត្រង ពាក្យនេះហៅថា « ចោរកម្មស៊ីស្តរ » ។

សូមមិត្តអ្នកអានពាក្យឡាយដួយពិចារណាមើល តើចោរកម្មព្រោះភ្លើងនឹងចោរកម្មស៊ីស្តរពាក្យនេះ មួយណាមានអានុភាពនឹងឲ្យដល់អាក្រក់ដ៏ខ្លាំងខ្លាយជាងមួយណា? តើគួរខ្លាច គួរខ្ពើមរអើមមួយណាជាងមួយណា?

បើតាមការសង្កេត នឹងការភ្ជាប់ដឹងឮ ព្រោះភ្លើងនឹងស៊ីស្ពារ មានសភាពស្ទើរប្រហាក់ប្រហែលគ្នា តំប៉ុន្តែ បើជញ្ជឹងគ្រិះរិះឲ្យជ្រៅបន្តិចទៅទៀត ឃើញថាស៊ីស្ពារខ្លាំងជាង សមដូចពាក្យថា: «ភ្លុងភ្លាំងស៊ុំទឹកភក់ ហឹម ។ ស៊ុំទឹកជ្រៅ » ។ បើពោលជាឧបាល គួរតែខ្លែមរអែមចាំងពីរ កុំថាឡើយអ្នកសុចរិតដែលមិនចង់ឃើញចង់ឃល់ ទ្លុះចោរកម្ម សូម្បីចោរខ្លួនឯងហ្នឹង ក៏មិនត្រូវការចោរកម្មដែរ ដូចមនុស្សម្នាក់ធ្វើចោរកម្ម ហើយមានម្នាក់ទៀតមកបន្តធ្វើចោរកម្មពីលើអ្នកខាងដើម អ្នកនេះក៏មិនសប្បាយចិត្តឡើយ ។

ដូច្នេះ តាមតែព្រោះភ្លើងក្តី ស៊ីស្ពារក្តី ត្រូវតែចៀសវាង ត្រូវតែស្អប់ខ្ពើម ។

តទៅនេះ គឺវែកញែក រកសេចក្តីអន្តរាយ សេចក្តីទុក្ខវេទនា សេចក្តីស្លិតស្លៃ ដែលបណ្តាលមកពីចោរកម្មទាំងពីរ តើមួយណាស៊ុកលន់ជាងមួយណា ? មួយណាជាភ្លើងនេះវិញ មួយណាជាភ្លើងនេះទៅ ។

បើពិចារណាឲ្យសព្វគ្រប់ បើសង្កេតឲ្យដិតដល់ ឃើញថាព្រោះភ្លើងខ្លាយជាងស៊ីស្ពារ ។ ព្រោះភ្លើងធ្វើឲ្យអន្តរាយ ធ្វើឲ្យខូចប្រយោជន៍ចំពោះបុគ្គល ដោយឆាប់ឆេះឆាបឆួលត្រឹមតែគណៈ: ចំណែកស៊ីស្ពារធ្វើឲ្យវេទនាដល់សង្ឃ ប្រៀបជាឧទឹងភ្លើងនេះវិញ ដូចអស់លោកអ្នកអានជ្រាបស្រាប់ មិនធ្វើឲ្យវិនាសត្រឹមតែដើមឈើដែលជាសម្បត្តិជាតិ

ប៉ុណ្ណោះទេ គឺស្ទាប់តាំងពីស្រមោចសង្ឃាឡើងទៅ គឺថាជីវិតសត្វកប់មិន
អស់ដែលត្រូវឆ្លាក់ក្នុងមហាម៉ាត់ ប្រកបដោយចង្កឹមដ៏មុតសាហាវនៃក្តឹង
ព្រៃ ។ ត្រូវប្រគល់ដល់មនុស្សនឹងសត្វនានា នូវផលមួយទៀត
ដ៏សែនអាក្រក់គួរឲ្យសង្វេត គួរឲ្យអាណាចអាធ័ម គឺការខ្វះក្តឿង
ខ្ចីចិតហូរព្រោះ ដែលជាបច្ច័យដល់អាយុជីវិតនៃមនុស្សក្នុងប្រទេសតំាង
មួល ។ ចោរកម្មស៊ីស្ករ ពិតជាធ្វើឲ្យវិនាសប្រយោជន៍ដល់សង្ឃតែម្តង
ដូចជាក្តឹងនេះព្រៃនេះឯង ។ តាមលទ្ធិពុទ្ធសាសនា ត្រង់នេះគឺលើក
យកអានិសង្សជាកុសលមកបរិយាយប្រៀបធៀប : ធ្វើទានចំពោះបុគ្គល
ជានអានិសង្សមិនស្មើនឹងគណៈ ធ្វើទានចំពោះគណៈ ជានអានិសង្ស
មិនស្មើចំពោះសង្ឃ ។ ពាក្យថា « បុគ្គល » សំដៅយកតែមនុស្ស-
ម្នាក់ ពាក្យថា « គណៈ » សំដៅយកចំនួនរូបមនុស្សពីរនាក់ទៅត្រឹម
បីនាក់ ឯ « សង្ឃ » វិញ សំដៅយកចំនួនរូបមនុស្សពីបួននាក់ឡើង-
ទៅ អ្នកណាធ្វើទានចំពោះសង្ឃនឹងជានផលានិសង្សប្រើនអនេកអនន្ត ។
នេះចំពោះផ្លូវជាកុសល ឯផ្លូវជាអកុសលវិញគឺយ៉ាងនោះដែរ ដូចចោរ-
កម្មស៊ីស្ករ គឺពិតជាធ្វើចំពោះសង្ឃហើយ ។ អំពើណាដែលបណ្តាល
ឲ្យមានសេចក្តីទុក្ខធំទូលំទូលាយ ការផ្តន្ទាទោសក៏គួរតែឲ្យធំស្មើគ្នា ដើម-
បីសម ។ ក៏ប៉ុន្តែ ត្រូវចាត់វិធានការណ៍ដូចម្តេច ដើម្បីអាចផ្តន្ទាទោសដល់
ចោរកម្មស៊ីស្ករបាន? ព្រោះស៊ីស្ករ ភាគច្រើនស្ថិតតែនៅតាំងអស់ មិនស្ថិ-

ដែលឮថាជាខន្ធសួនខណ្ឌកម្មសោះ ។ គឺចំណុចត្រង់នេះហើយដែលមានសេចក្តីលំបាកយ៉ាងខ្លាំងមិនដាយដោះស្រាយរួច ព្រោះស៊ីស្តរនឹងស៊ីស្តរជួបគ្នា ឧបមាដូចជាសាច់ញាតិ នឹងសាច់ញាតិជួបគ្នា ត្រូវតែស្រឡាញ់គ្នា រាប់រកគ្នា តិចណាស់ដែលឋដ្ឋនធ្វើបាបឋដ្ឋនឯង ។ បើដូច្នេះត្រូវចាត់ការយ៉ាងណា ដើម្បីបំបាត់ចោរកម្មស៊ីស្តរបាន ? តាមយោបល់ខ្ញុំមានមធ្យោបាយបី គឺ ទី ១ យកសតិសម្បជញ្ញៈជាប្រមាណ ទី ២ បង្ក្រាបដោយកំណត់កង់ការចំណាយ ទី ៣ ត្រូវបញ្ជូនទៅបរលោក ។

ជើមកំណើត និង ការរីកចំរើនៃអារ្យធម៌ខ្មែរ

ដោយ លី-ដាមតេង

នៅពុទ្ធសាសនបណ្ឌិត្យ

យើងដឹងហើយថាដែលគេហៅពេញលេញជា «អារ្យធម៌» មួយ ចានលុះណាតែអារ្យធម៌នោះ មានលក្ខណៈគ្រប់គ្រាន់ បញ្ជាក់ឲ្យយើញ នូវការចេះដឹងពុះពេញបរិបូរណ៍ពីភាគនោះ ព្រោះសុំត្រាកដប្រជាសំរាប់ជាគ្រឿង សំគាល់នូវចំណេះវិជ្ជាប្រាជ្ញាលក្ខណៈនៃសេចក្តីចំរើនរបស់ជាតិ ។ រីឯអារ្យធម៌ ខ្មែរយើងមានរូបភាពខ្សោយបន្តិចបន្តួច ។ មកជាអង្វែងហើយ, បើគិតតាមប្រ-វត្តិសាស្ត្រយើងយើញថា ចាប់ផ្តើមមានមកតាំងពីមុន គ្រិស្តសតវត្ស ទៅទៀត ។ អារ្យធម៌ដំបូងនោះគឺកម្រងការចេះដឹងផ្សេង ។ មានភាសា-ក្លេង-ចំរៀង-ទំនៀមទំលាប់របស់ជនជាតិដើម គឺកុលសម្ពន្ធផ្សេង ។ ជា ពួក ផ្លាស៊ី (Autochtones) ដែលរស់នៅលើផែនដីខ្មែរយើង ដូច ជាគួយ-សំរែ-ពរ-ព្នង ហើយដែលមកពីថៃពិតមែនតែពួកនេះទៅជា អ្នកនៅដោយព្រៃ ហាក់ដូចគ្មានវប្បធម៌សោះ តែជនជាតិទាំងនេះបាន ចុះកេ្តីអារ្យធម៌ឲ្យយើងច្រើនណាស់ ដូចជាទំនៀមទំលាប់, សិល្បៈ, ភាសា ។ ល ។ ក្រោយពេលដែលកសាងបានជារូបរោមហើយ អារ្យធម៌យើងកំព្រាវែងលួសឥទ្ធិពលខ្លះ ។ អំពីអារ្យធម៌ជនជាតិផ្សេង ។ ដែលចូលមកអាស្រ័យនៅក្នុងស្រុកយើង ព្រោះជាធម្មតា តាមមតិមនុស្ស

ប៉ុណ្ណោះ ឬសព្វថ្ងៃស្ទួរតែត្រូវការបញ្ចូលបន្ថែមយ៉ាងនេះ ដូចមានសេចក្តីបញ្ជាក់តទៅ ខ្ញុំរៀបរាប់ណែនាំតាមលំដាប់ដែលផ្សាយចូលមកគឺ ៖

ក - អាវ្យធមិឥណ្ឌា

អាវ្យធមិឥណ្ឌាជាអាវ្យធមិខ្លាំងក្លា ព្រោះមានមកពីឥណាចក្រឥណ្ឌាជាច្រើនតាន់ឆ្នាំមុនគ្រិស្តសករាជ ចាន់ធ្វើចូលមកក្នុងប្រទេសយើង តាមរយៈ ព្រាហ្មណ៍កៅណ្ឌិន្យ កាលពីសតវត្សទី ១ នៃគ្រិស្តសករាជ ហើយចាន់ផ្សាយពាសពេញលើប្រទេសយើងតាំងពីកាលនោះមក ដូចជាភាសាសំស្ក្រឹត, លក្ខិ, សាសនានិង ទំនៀមជាច្រើនដែលគ្រាយៅជាទំនៀមទំលាប់សមញ្ញរបស់អ្នកស្រុកយើងរហូតដល់សព្វថ្ងៃ ។ ដោយហេតុពួកព្រាហ្មណ៍ទាំងនោះ ចាន់ឡើងជាក្សត្រត្រង់ពផ្សារលើទឹកដី កំចាត់វប្បធម៌ផ្សាយអាវ្យធមិបន្ថែមនេះ ឲ្យចាន់រកជាមួយអាវ្យធមិដើមនៃយើង ។

ខ - អាវ្យធមិចិន

តាមការសង្កេតអាវ្យធមិចិនចាន់ចូលមកកាន់ស្រុកយើង ក្នុងរវាងសតវត្សទី ៣ តាមរយៈពួកអន្តោប្រវេសន៍ជាតិចិន ដែលនាំទំនិញចេញចូល ហើយខ្លះក៏មកតាំងទីលៅជាប់លាប់នឹងស្រុកយើងត្រមាំងមានប្រពន្ធកូនពង្រីកត្រួសារ ហើយបង្ហាត់ហ្វឹកហ្វឺនអាវ្យធមិចិនតាមរយៈក្រុមញាតិ ព្រោះចិនចាន់មកពង្រីកត្រួសារបន្តិចម្តង ។ ជាពិសេសគឺទំនៀមទំលាប់, ការប្រតិបត្តិកងការរស់នៅប្រចាំថ្ងៃ ទឹងដំខ្មៀវផ្សេង ។

ច្រើនទៀត ។ ដូច្នេះឥណ្ឌាលអារ្យធម៌ចំនួន ក៏លោយចូលក្នុងអារ្យធម៌ដើមរបស់យើង ហើយកែសាយព្រមគ្នាជាលំដាប់មក ។

ក - អារ្យធម៌បស្ចិមប្រទេស

អារ្យធម៌នេះ បានហូរចូលមកស្រុកយើងនៅចុងសតវត្សទី ១៩ តែមានកំឡាំងខ្លាំងក្លាណាស់ ព្រោះដាប់មកជាមួយពួកអ្នកមានអំណាចធ្វើជាអាណាព្យាបាលប្រទេសយើង ។ ហេតុនេះទើបមានសន្ទុះយ៉ាងហ៊ាន់ឲ្យយើងរើសយកសុទ្ធតែធម៌, សំលៀកបំពាក់ទំនើបបបរសិល្បៈខ្លះមកបញ្ចូលថែមក្នុងអារ្យធម៌ដើម ហើយគាន់តែរីកចំរើនឡើងរហូតសព្វថ្ងៃនេះ ។

ដូច្នេះ យើងបញ្ជាក់បានថា ទោះបីជាអារ្យធម៌កំណើតដើមរបស់យើង ត្រូវទទួលឥទ្ធិពលអារ្យធម៌ពីទីនានាខ្លះមកបន្ថែមក៏ដោយ ក៏យើងនៅតែមានលក្ខណៈមួយ ជាលក្ខណៈជាតិយើង ឥតឲ្យបាត់បង់ឡើយ ហើយអារ្យធម៌នានានោះ គ្រាន់តែជាវណ្ណបច្ចជាវត្ថុធាតុសំរាប់ធ្វើឲ្យអារ្យធម៌ដើម របស់ខ្លួនយើង តែតែមានទ្រង់ទ្រាយល្អឡើងប៉ុណ្ណោះ ។ ហេតុនេះ ទើបយើងទទួលស្គាល់បានថាខ្មែរមានអារ្យធម៌មួយប្លែកដរបស់ខ្លួនពុំមែនទើបតែយកតាមគេទេ ហើយក្តីស័ណល់អារ្យធម៌ដើមនោះ អ្នកប្រាជ្ញសព្វថ្ងៃទទួលស្គាល់គ្រប់គ្នា គេឲ្យឈ្មោះថាអារ្យធម៌អូស្ត្រូ-អាស៊ី (Austro-Asiatiques) ដែលមានកំណើតដើមនៅលើដែនដីនានា ជាគោះជាជ្រោយ នៅតាមសមុទ្រប៉ាស៊ីហ្វិក គឺភូមិភាគ

ស្រុកយើង; ទូយតាមអារ្យធម៌ឥណ្ឌូ-អឺរុប (Indo-Européenes) ដែលមានតំណើតនៅឥណ្ឌានិងនៅអឺរុប ។

បើរកយើញនូវតំណើត និងរូបភាពប្លាស់នៃអារ្យធម៌ខ្មែរយើងដែលប្រតិស្ឋានឡើងជាក់ច្បាស់ដល់ដើយើងដូច្នោះហើយ យើងគេនឹងតែតាមដានសង្កេតមើលថាតើ តាំងពីមានរូបភាពមករហូតសព្វថ្ងៃនេះ អស់រយៈពេលជាងពីរពាន់ឆ្នាំមកហើយ មានការវិវត្តន៍យ៉ាងណាខ្លះ ។ យើងដឹងមកហើយថា ពិតមែនតែមានឥទ្ធិពលនៃអារ្យធម៌នានាជាតិជាពិសេសគឺជាតិដែលជាប់ទងនឹងខ្មែរយើងមែន, ប៉ុន្តែឥទ្ធិពលទាំងនោះរឹងតែតែធ្វើជាមធ្យោបាយ ជួយរុញច្រានឲ្យអារ្យធម៌មានកំឡាំងនឹងមានរូបភាពបែកសាច់ឈាមពេញលេញបន្ថែមឡើងទៀត ។ ដូច្នោះយើងអាចបែករំលែកនូវអារ្យធម៌យើងតាមបែបប្រវត្តិសាស្ត្រ ជាបី សម័យកាលធំៗ គឺ៖

១ - អារ្យធម៌ខ្មែរសម័យអង្គរ

សម័យកាលដ៏ធំនេះ យើងកប់តាំងពីចាប់ផ្តើម មកទល់គ្នានឹងពេលខ្មែរលះបង់ពួជានីអង្គរ ក្នុងសតវត្សទី ១៥ នៃគ្រិស្តសកពជ ។ រៀលនេះជាពេលកសាងឥតឈប់ឈរ ធៀបទុបមាដូចជាឈើដែលខ្ចីបំផុតដុះហើយលូតលាស់ជាលំដាប់រហូតចាស់ចាន់ជាទ្រនំទ្រុយរុក្ខជាតិមួយ ធួនល្មម ។ ចាប់ពីមុនគ្រិស្តសកពជមកគាល់គ្នានឹងសតវត្សទី ៧ អារ្យធម៌ខ្មែរពុំទាន់លេចឈ្មោះពេញខ្នាតនៅឡើយមែន ប៉ុន្តែបើមើលពីគ្រឹះដំណែល

ជាសក្ខីភាពកំតង់យើញនៅសេសសល់ច្រើនណាស់ ដូចជាប្រាសាទថ្ម
តូចតាចនៅភូមិភាគអគ្នេរបុរី ។ ល្បែងប្រពៃណីផ្សេង ។ ទំនៀមភាសាទំនៀមយ
ស្តីជាដើម ។ លុះចាប់ពីសតវត្សទី ៨ មកស្ថាបត្យកម្មធំ ។ រចស់យើង
កំលេចធ្លោ ។ ឡើង របៀបរៀបចំស្រុកខេត្តក៏ចេះតែកើតជាលំដាប់ ។
របបជីវភាព (Mode de vie) របស់ខ្មែរកំផ្លាស់ប្តូរទៅតាមវិត្តភោគសម័យ
ដូចមានរូបចំឡាក់នៅជាប់នឹងជញ្ជាំងប្រាសាទអង្គរធំទុកជាជាន់ស្រាប់ ។
មែកធាងគ្រប់វិស័យ ប្រាថ្នាតែឥតឧបមាស្មើ ។ គ្មានហួតប្រាថ្នាទៅជាអារ្យ-
ធម៌ជាតិខ្លាំងពូកែមួយនៅបុរីបូព៌ាប្រទេសនេះ ។ អាស្រ័យហេតុនេះ
ហើយ ប្រាថ្នាជាទៅសម័យនេះ ជាតិថ្មីៗទៅដែតខាងយើងប្រាថ្នាចំឡងប្រវែត
យកបែបអារ្យធម៌យើងទៅធ្វើជាអារ្យធម៌ជាតិខ្លួនផង ។

២ – អារ្យធម៌ខ្មែរសម័យកណ្តាល

សម័យកាលនេះ យើងកំណត់ពីសតវត្សទី ១៥ រហូតមកដល់ទី ១៩
នៃគ្រិស្តសករាជ ។ គ្រានេះប្រវត្តិសាស្ត្រប្រាប់យើងថា ស្រុកខេត្តកើត
រឹតវែរដោយសង្គ្រាមខ្លាំនស្រុកមកពីបច្ចាមិត្រឯក្រៅ ។ ផង ទំនៀមទាន
សង្គ្រាមកង់ស្រុកវុកគួនខ្លះទៀតផង ទាំងថ្ងៃផ្លាអារ្យធម៌ជាក់ចុះត្រឡប់
ទៅវិញ ។ កាលណាមានអាសន្នឬកោលាហលយ៉ាងនេះ ធ្លាប់ប្រព្រឹត្ត
ក្តី ធ្លាប់សង្គមធម៌ក្តី ដែលជាមែកធាងធំ ។ នៃអារ្យធម៌យើងនោះ ក៏លែ
ត្រឡប់ជាសូន្យសូម្បី គឺពុំបានលុតលាស់ឡើងថ្មីមទៀតទេ ទំនៀមថ្ម

តាំងចង់ថយក្រោយទៅវិញខ្មែរផង ដ្បិតអ្នកស្រុកអ្នកខេសគ្មានទុកាសនឹងកសាង ហើយបើសាងបានហើយ ក៏គ្មានលទ្ធភាពនឹងរក្សាត្រង់ទុកឲ្យគង់វង់បាន ដោយសារតែការខលាចលបុកអុកជារឿយ ។ ។ រីឯអ្នកខ្មែរនេះទឹកដីមកពីក្រៅសោត ក៏ព្យាយាមដឹកជញ្ជូនប្រមូលយកអារ្យធម៌យើងទៅ ហើយលួចបញ្ចូលអារ្យធម៌គេឲ្យស្រោចចូលមកផែនដីយើងខ្មែរផង ។ ហេតុនេះ យើងមិនត្រឹមតែលំបាកដោយរក្សាទ្រព្យមត៌កអារ្យធម៌ខ្លួនប៉ុណ្ណោះទេ ថែមទាំងតិចបាកខប់លន់នឹងតំឡាំងអារ្យធម៌ក្លាយរបស់គេ ចូលមកប្រឹតប្រែតថែមទៀត ។ សង្ឃឹមទៅយើញថាកន្លងសម័យកាលនេះ ជាពេលគ្រោះជាគគ្រោះជាំធ្លាក់មកលើអារ្យធម៌យើងក្នុងប្រវត្តិសាស្ត្រ ។

៣ - អារ្យធម៌ខ្មែរសម័យបច្ចុប្បន្ន

សម័យនេះយើងពុំបាច់ពន្យល់រៀបរាប់ច្រើនទេ ព្រោះជាពេលដែលយើងគេបានយើញបានឃើលនឹងភ្នែកសព្វ ។ ខ្លួនហើយ ។

ប៉ុន្តែគួរសង្កេតតែមួយចំណុច គឺត្រង់សម័យកាលនេះ មានចែកជាពីរភាគ គឺ សម័យអាណាព្យាបាលជាក់ផ្ទាល់ និង សម័យឯករាជ្យ ។

សេចក្តីបរិយាយមកនេះ គ្រាន់តែឲ្យយើងរកឃើញថា ខ្មែរយើងពិតជាមានអារ្យធម៌មួយរបស់ខ្លួន ទើបមានទាំងប្រវត្តិប្លាស់លាស់ផង ពុំមែនដូចពាក្យស្មានខ្លះថា ខ្មែរចំឡែង ឬ យកឫសគល់ពីអារ្យធម៌ណាមួយទាំងស្រុងនោះឡើយ ។

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំង-ខាត់ រៀបរៀង

(តមក)

អធិជិឥន្ធ នបុ. កិរិយាកើត កំណើត ។

អធិជ្ញាតុ ក្រ.វិ. ឮដឹងស្គាល់ដឹងដំណឹង ។

អធិជ្យ គុ. (ធ្នូ) ដែលមានខ្សែបងហើយ ។ – ធា ស្រី. ការនៃធ្នូដែលមានខ្សែបងហើយ ។

អធិជ្យោតីមមិ ក្រ.វិ. មានពន្លឺក្រៃលែង ។

អធិតត គុ ដែលត្រួប ដែលប្រក ។

អធិតល្យម៑ ក្រ. វិ. ឮដឹងកំពែង ឮដឹងប្រាការ ។

អធិត្យកា ខ្ពង់បឮ ។

អធិទណ្ឌនេតិ បុ. អ្នកកាន់ឬអាជ្ញាដ៏ក្រៃលែង យម: ។

អធិទីធិតិ គុ. ដែលផ្សាយពន្លឺក្រៃលែង ។

អធិទេវតា ស្រី. ទេវតាក្រៃលែង ទៃ នបុ. ទេវតាក្រៃលែង, ទេវតាមិ តាមបង្គាប់អធិទេព ។

អធិទ្វៃវិត នបុ. ទេវតាក្រៃលែង ទេវនិការ ។

អធិនាគមិ ក្រ. វិ. លើឬឮដំរី ឬ នាគដំរៃលែង

អធិនិវាស ក្រ ស្ងែរកាល់នៅ ។

អធិនិគមិ ក្រ. វិ. រាល់យប់ ។

អធិប នុ. អ្នកគ្រប់គ្រងរៃលែង ត្រូ នាយ ម្ចាស់ផែនដី ។ អធិបតិ បុ អធិបតី អធិបតិវតី នុ. ដែលមានត្រួ ដែលមានចៅហ្វាយ ។

អធិបាណិ ក្រ. វិ. ឮនដៃ ។

អធិបុរន្ត្រី ក្រ. វិ. ចំពោះស្ត្រី ។

អធិបៀរុម្ន សុ. សេចក្តីភ្ញាហានរៃលែង ។

អធិប្រជិមិ ក្រ. វិ ជាមកំណើត ។

អធិប្រាជ្ញិមិ ក្រ វិ ដោយអធិប្រាជ្ញា ។

អធិផាណិត នុ. ដែលមានផាណិតរៃលែង ដែលមានកើតអំពៅច្រើន ។

អធិពាធិ ក្រ. បៀតបៀនរៃលែង ញាំញីរៃលែង ។

អធិភុជិ ក្រ. បរិភោគរៃលែង ស៊ីច្រើន ។

អធិភ្ជ បុ. នាយ អ្នកគ្រប់គ្រង ។

អធិភ្ជត សុ. សត្វរៃលែង ព្រះព្រហ្ម ។ ភ្ជតម ក្រ. វិ. ទាក់ទង ដោយសត្វ ឬ ដោយវត្ថុ ។

រឿងសាមកុក

ពីកញ្ចាំរបុលពាដសេនា ខ្ញុំ-ភាន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាឃ្លាសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ ។
>
> ———— ឃ្លោ-អ៊ុន ————

ខ្ញុំយើងមព្វខ្លៅពីនិយាយដូច្នោះក៏ខឹងណាស់ មិនបានខ្វាចដល់សេចក្តីស្លាប់ ស្រែកគំហកថា ខ្ញុំនយើងជាជាតិពាហានមិនមានខ្លាចអន្តរាយស្តាយជីវិត គិតត្រឡប់ទៅចំណុះចុះចូលដល់អ្នកដទៃ ប្រាថ្នានឹងរក្សាជីវិតវិញ មិនស្រឡាញ់ស្រុកនោះក៏មិនគួរជាមនុស្សខ្មែរត្រង់ឧឡារយទៅហ្មាយ ធម្មតាជាតិពាហាន ហើយមកមានឧឡារយទៅហ្មាយពីរនោះក៏មិនត្រូវតាមប្រពៃណី ធម្មតាស្រីដែលល្អក៏មិនត្រូវប្រាថ្នាស្វាមីដល់ ២ បើលោកនឹងបង្ខំឲ្យយើងចំណុះចុះចូលនោះ បើទុំនឹងពុំឈ្នះក៏ត្រូវតែគំនាប់ទៅ តែយើងទៅមិនមានចិត្តនឹងគិតកក្តីមេត្រីដល់លោកទេ ហើយក៏ដេរខ្លៅពីជាពាក្យទ្រគោះអស់ពេះខ្លាំងណាស់ ខ្ញុំនបេងព្វដូច្នោះក៏ខឹងណាស់ បង្គាប់ឲ្យពាហានចាំខ្ញុំនខ្មែរយើមទៅប្រហារជីវិតបង់ ។

ខ្លៅពីយើញថាខៀវយ៉ង ជាមនុស្សត្រង់សុចរិតនឹងនាយខៅហ្នាយ កំឲ្យមានចិត្តគិតសង្ឃឹម ទើបឲ្យនាំយកសពខៀវយ៉ង ទៅបញ្ចុះទុកនៅទីដើមស្ពានតឹមជាំមកៀក ហើយនាំឲ្យចារឹកអក្សរជាក់នៅថ្មឆ្នាក់ទុកថា «ខៀវយ៉ងជាមនុស្សត្រង់ » ក្រោយៗនឹងឲ្យមនុស្សចាំងពួងយកគួហើងតទៅមុខ ។

លុះព្រឹកឡើង ខ្លៅពីប្រ[illegible]ជាន់នឹងនឹអ៊ុ នៅបណ្តានាយខាហានកូនខាហានក្នុងស្រុកសែឈួន ដែលចូលមកនៅនឹងខ្លៅពីនោះ លើកខាហានជាកងមុខ ចូលទៅក្នុងស្រុកឡុកសៀ លុះខាហានលើកទៅដល់ដើងកំផែងហើយ កំស្រែកហៅខ្លៅឈុមនឹងខ្លៅកុយថា ការប្រខាល់គួដល់ប៉ុណ្ណោះហើយ កុំបីធឹងខឹងតទៅខៀតឡើយ ចូរប្រញាប់បើកទ្វារចេញមកគំនាប់ខ្លៅពីដោយល្អទៅចុះ ខោះនឹងខំមានៈនៅកំយើញថានឹងរក្សាការពារស្រុកនេះពុំបានទេ កុំឲ្យបានសេចក្តីក្តៅក្រហាយដល់អាណាប្រជាខុកស្តុកតាំងពួងឡើយ ។

ខ្លៅកុយឈរទៅលើកំពែង បានឮសម្លេងស្រែកឡើងទៅដូច្នោះកំឡើងណាស់ ស្រែកតបមកវិញជាពាក្យគ្រោះអសុរកេះមិនមានគួរសមនឹងចំណុះចុះចាញ់ ដើម្បីនាំទ័ពយើញខ្លៅកុយមានចិត្តព្រហើនគាងកាចដូច្នោះកំឡើងណាស់ ចាប់លំពែងនឹងពួយឡើងទៅ ខណៈខៀវអេកកាត់ក្បាលខ្លៅកុយខម្លាក់ចុះមកឲ្យ ហើយក៏បើកទ្វារស្រុកចេញមក

ខ្ញុំលេងឆ្មាំងដាំនំ ។ មានចិត្តត្រេកអរណាស់ ទើបនាំគាហានតាំងតួនចូលទៅក្នុងស្រុក ។

ខ្លៅឈ្មួនឃើញគាហានខ្លៅតីចូលស្រុកទៅ ក៏ឲ្យបើកទ្វារទៀសខាងកើតនាំគាហានស្រួតរត់ចេញទៅស្រុកសៃឈ្មួន លុះខ្លៅតីចូលទៅក្នុងស្រុកហើយក៏សួរថា នរណាមានសេចក្តីស្វាមីភក្តិនឹងយើង ចាន់តាត់ក្បាលខ្លៅកុយខ្ញាក់មកឲ្យនោះ ឆ្មាំងដាំនំធ្វើយថា ខ្ញុំវៃអេកនោះដែលមកតំនាប់លោក ចាន់តាត់ក្បាលខ្លៅកុយខ្ញាក់ចុះមកឲ្យ ខ្លៅតីក៏ឲ្យចំណាប់ភ្ញាន់ដល់ខ្ញុំវៃអេកជាច្រើន ហើយក៏ចាត់ចែងអ្នកស្រុកឲ្យទៅជាសុខមិនឲ្យគាហានណាទៅបៀតបៀនឲ្យកើតអន្តរាយ ។

ខុងបេងថា ឥឡូវស្រុកឡុកសៅចានមកយើងហើយ ឯស្រុកសៃឈ្មួនក៏ដូចជាទៅក្នុងកណ្តាប់ដៃយើងដែរ បើយើងនឹងលើកទៅវាយយកវេលាណាក៏បាន តែការណាខ្ញុំត្រូវដែលត្រូវចំណុះស្រុកសៃឈ្មួននោះមិនទាន់ពាបពាប សុំឲ្យលោកចាត់ខ្ញុំវៃអេកនឹងធីអ៊ីឲ្យនាំជូនឡងលើកគាហានទៅច្បាបច្រាមស្រុកតេងតាំង ឲ្យឆ្មាំងដាំនំនឹងគោអេងនាំខ្ញុំវៃហ៊ុយលើកគាហានទៅសង្កត់ស្រុកតេកយ៉ុង ដែលទៅនឹងខុងបេងនោះឲ្យចុះចូលជាប្រក្រតី ចាត់ចែងមុខមន្ត្រីឲ្យទៅរក្សាស្រុកតាមកូមិលំទៅស្រេចហើយទើបឲ្យលើកកងទ័ពទៅវាយយកស្រុកសៃឈ្មួនឲ្យព្រមគ្នា នាយទ័ពនាយកងតាំងតួន លុះបានខ្ញុំលការដែលខុងបេងចាត់ចែងដូច្នេះហើយ តាំង

អស់គ្នាក៏លើកទាហានចេញទៅ ។

ខុនចេងក៏សួរអ្នកស្រុកសែឈួនថា យើងនឹងលើកទ័ពទៅវាយយកស្រុកសែឈួនក្នុងគ្រានេះ តើតាមផ្លូវដែលនឹងលើកទៅនោះ មានតួយបន្ទាយដាច់ឆ្ងាយនៅប៉ុន្មានអន្លើ ពួកអ្នកស្រុកឆ្លើយដំកបថា មានតួយកឹមកុកជាបន្ទាយធំមាំមួនណាស់នៅដំបន់នោះ មួយទៀត តួយកឹមកុកនោះទាហានក៏ស្រុះស្រួល ទាំងខ្លាំងពូកែមានច្បាំដែលណាស់ បើវាយបានបន្ទាយនោះហើយ ក៏មិនមានទីដែនឱនឹងទឹងទៀតបាន នឹងលើកទៅវាយយកស្រុកសែឈួនបានដោយងាយណាស់ ។

ខុនចេងដឹងដូច្នោះ ក៏ឱ្យប្រុងប្រៀបរៀបចាទាហាន នឹងលើកទៅ ហួតចេងថា ដែលលោកនឹងលើកទៅវាយយកស្រុកសែឈួននោះ ខ្ញុំបាទយល់ឃើញថា អាណាប្រជាខ្មែរស្រុកនឹងបានសេចក្តីក្តៅក្រហាយណាស់ សុំឱ្យលោកបង្អង់កងទ័ពខ្មែរសិន ព្រោះស្រុកឡុកសៀក៏បានជារបស់លោកហើយ ស្រុកសែឈួនដូចនៅក្នុងកណ្តាប់ដៃលោកដែរ ខ្ញុំបាទនឹងមានសំបុត្រទៅដល់ឡៅដៀងមួយច្បាប់ឱ្យចេញមកចំណុះចុះចូលលោកតាមប្រពៃណី ឡៅដៀងដឹងថាស្រុកឡុកសៀនេះបានមកលោកហើយ ក៏ទន់ព្រមចំណុះមិនខាន បើជារឹងទឹងប្រការម្តេច សឹមយើងលើកទ័ពទៅវាយដាក្រោយ ខុនចេងយល់ត្រូវផង ទើបឱ្យបង្អង់កងទ័ពឈប់ ហើយឱ្យហួតចេងមានសំបុត្រទៅដល់ឡៅដៀង ។

ឯខ្មៅឈុន លុះតែទៅដល់ស្រុកសៃឈួនហើយ គិតណានាំគ្នាចាប់
ហេតុដំណើរឲ្យចិតាស្តាប់ត្រង់ប្រការ ខ្មៅជៀងក៏ឲ្យប្រមូលមន្ត្រីខ្វិកជ
ការចូលមកប្រឹក្សាថា អឡូវស្រុកឡុកសៀទូចហើយ មុខជាខ្មៅពីនឹង
លើកទ័ពចូលមកកាប់ដល់ស្រុកយើងឯណោះទៀតជាប្រាកដណាស់ យើង
នឹងតតាវោរយ៉ាងណាឲ្យបានគង់ល្អតទៅ ។

តែក៏ប្រឹក្សាឆ្ងើយថា ខ្មៅពីបានស្រុកឡុកសៀក៏មែន តែពួកគ
ហានសុទ្ធតែជាមនុស្សផ្តេសផ្តាស ព្រោះច្រើនតែពួកឈ្លើយ មិនបានជា
ចិត្តមួយនឹងជួយធ្វើការឲ្យអស់ពីចិត្តទេ នឹងធ្វើការកំពុំសូវត្រមត្រៀងគ្នា
ហើយតិចតួចផង មិនជួននឹងធ្វើសង្គ្រាមនឹងយើងបាន សុំឲ្យលោក
ចាត់មនុស្សចេញទៅបណ្តេញកៀរយកអាណាប្រជានុកស្តុក ក្នុងស្រុកចាំ
សេ ចំសាងឯលិច ឲ្យទ្វងស្ទឹងចោសុីយចូលមក ទៅខាងត្រើយស្រុក
យើងឲ្យអស់ ហើយឲ្យដុតបំផ្លាញស្បៀងអាហារដែលនាំយកមិនបានទៅ
សល់ប៉ុន្មានគោះឲ្យអស់កុំឲ្យខុក បើខ្មៅពីនឹងលើកទ័ពមកព័ទ្ធស្រុកយើង
ស្បៀងអាហារក្នុងស្រុកយើងក៏មានច្រើនបរិបូណ៌ ត្រូវតែទំរក្សាស្រុក
ខុកឲ្យមាំ កុំឲ្យធ្វើនៅសបាន ឯខ្មៅពីមកពីស្រុកឆ្ងាយ គង់នឹងអស់
ស្បៀងអាហារ បើគ្រាំទៅយូរតេទៅយកស្រុកយើងមិនបាន អស់ផុត
ស្បៀងអាហារវិលាណា សេនាគហានមានតែថយកម្ងាំងចុះ គោះ
នឹងធ្វើការកើមិនពេញដៃ មុខជានឹងលើកទ័ពត្រឡប់ទៅឯង គហាន

យើងមានកម្ងាន់ស្រុះស្រួលគ្នា កំនត់លើកពាមកយយកស្រុកវិញខាងបុនវែង មុខជានឹងចាប់ឡៅពីបានដោយងាយ ។

ឡៅជឿងថា ធម្មតាសត្រូវមកធ្វើអន្តរាយ គួរនឹងរកឧបាយការពាររក្សាស្រុក ខុកកុំឲ្យអាណាប្រជានុកស្ត្រីបានសេចក្តីក្តៅក្រហាយ នេះសត្រូវលើកមកមិនខាន់នឹងបានប្លាំងតកម្ងាន់គ្នាឲ្យយើញយ៉ាងណាស្រាប់តែទៅកៀរយកគ្រួសារអ្នកស្រុកឲ្យកើតទុក្ខព្រាត់ទំលាំនៅ បានសេចក្តីក្តៅក្រហាយខ្លះ ។ យើងគ្មានមិនយល់យើញផងសោះ កាលឡៅជឿងកុំពុងប្រឹក្សាការខោះ ខ្លួលអ៊ុយគួនយកសំបុត្រហួតចេងចូលទៅឲ្យឡៅជឿង ។ ហែកស្រាមមើលយើញសេចក្តីថា ខ្ញុំបាទហួតចេង សូមគំនាប់មកជល់លោកជ្រាប ព្រោះពីដើមលោកមានចិត្តស្រឡាញ់ឡៅតាំងយ៉ាងសុចរិតមិនមានគិតរង្គើសព័ន្ធសោះ បានជាប្រើខ្ញុំបាទឲ្យនាំពាហនទៅខ្លួលឡៅតាមកជល់ស្រុកសែឈួន ក្រាថ្នាំនឹងឲ្យដួយធ្លុបផ្លួនការពាររក្សាស្រុកឲ្យមានសេចក្តីសុខតទៅ ឥឡូវលោកមកជឿកាន់យកពាក្យសំដីមនុស្សក្បាះក្បាង់ លោកក៏មិនបានសួងំតិគ្រោះឲ្យហ្មត់ចត់ ទើបបានសេចក្តីព្រាត់ឃ្លាតមេគ្រីឡៅពីទៅវិញ ត្រឡប់បានសេចក្តីគាមនស្ស ជាទុក្ខម្នេញទៅជាសត្រូវនឹងគ្នា ឯឡៅតាក៏បានធ្វើការធំលើសលប់មិនឈប់បង្អង់មកជល់ប៉ុណ្ណេះហើយ មួយទៀតអាណាខេត្តឯទៀតក៏ចំណុះចុះចូលទៅខាងឡៅតាអស់ហើយ នៅឡើយតែត្រឹមស្រុកសែឈួនប៉ុណ្ណេះ

សូមឲ្យលោកត្រិះរិះគិតប្រៃប្រួលសម្រួលតាមកាលៈទេសៈគួរនឹងចំណុះចុះ
ចូលឡៅតាមប្រពៃណីទៅវិញស្រួលជាជាង ព្រោះឡៅតាមទុស្សប្រកបដោយស័ត្យតិតត្រង់ល្អណាស់ ហើយមានចិត្តនោះស្មោះសរស្រឡាញ់អ្នកចាំងពួង គ្មានអាឃាតឮឡាចាខនណា បើលោកពិគ្រោះពិចារណាឃើញគួរនឹងការហើយ ក៏ឲ្យចេញមកតំនាប់តាមស្រួលទៅចុះ ដើម្បីនឹងបានសេចក្តីសុខតទៅ ឡៅតាមនមានចង់សត្រូវនឹងលោកជាក្រុងក ។

ឡៅដៀងមើលចចាំសេចក្តីក៏ខឹងណាស់ ឈ្លើសំបុត្រនោះចាលមួយរំពេច ហើយដេរថាអាចោរលក់ម្ចាស់ ក៏ពោលមកយ៉ាងនេះ ក្រាថ្នាំនឹងយកប្រយោជន៍ចំពោះខ្លួនវា បង់កំឡាំង ដែលបានខំទុកចំរុងឲ្យក៏មានយសសក្តិរៀងមក វាមិនយកចិត្តស្រឡាញ់ឯងដោយស្មោះត្រង់បង់សេចក្តីតញ្ញាសោះ ហើយក៏បណ្តេញអ្នកកាន់សំបុត្រនោះឲ្យថយចេញមួយរំពេច ទើបប្រើអ៊ុយហ៊ួនជាប្អូនកំយោនឹងលីយៀមឲ្យលើកទាហាន ៣ ម៉ឺនទៅកៀរគយកឹមកុកខុកឲ្យមាំមួន តាំងហោ ទីប្រឹក្សាក៏ចូលទៅនិយាយនឹងឡៅដៀងថា សុំឲ្យលោកមានសំបុត្រទៅដល់ខៀវឡៅហ្វាយស្រុកហ៊ានតុង សូមឲ្យលើកកងទ័ពមកជួយចុះ មុខជាតស៊ូនឹងឡៅពីបាន ឡៅដៀងថា ដែលអ្នកនឹងឲ្យទៅសុំកងទ័ពស្រុកហ៊ានតុងមកជួយនោះ ខៀវឡូនឹងយើងក៏ជាសត្រូវនឹងគ្នា កាលណាគេនឹងមកជួយ ។

តាំងហោថា ខោះបើខៀវឡាស់អធ្យាស្រ័យខឹងយើងយ៉ាងណា តែវេលានេះ ខ្លោតីធ្វើការធំលើសលុបខ្លាំងណាស់ បើបានស្រុកសៃឈួនវេលាណា កំតង់ខឹងខន្ធោនទៅយកស្រុកហ៊ុនតុងវិតជាប្រាកដ ព្រោះស្រុកសៃឈួនដូចនៅត្រង់រឹមបបូរមាត់ ស្រុកហ៊ុនតុង។ បមាដូចធ្មេញ បើបបូរមាត់ក្លាត់ប្រហាទៅហើយ មិនលែងឡើយខឹងឃើញធ្មេញនោះ ព្រោះនៅជិតគ្នាណាស់ សូមឲ្យលោកមានសំបុត្រទៅនិយាយចុះថា ខ្លោតីវេលានេះធ្វើការមានកម្លាំងជិតពេញផែនដីទៅហើយ សុំឲ្យខៀវឡរិះគិតជួយទៅវិញទៅមកកុំឲ្យអន្តរាយស្រុកចាំងសងខាង ខៀវឡកំតង់ខឹងគិតខ្លាចមិនអាចបង្ក្រាំឈប់ទេ ឃូរនាប់កំតង់ខឹងលើកតលរហ័មកជួយលោកទេ ខ្លោដៀងយល់ឃើញត្រូវផង កំតែងសំបុត្រចាត់ចំរើឲ្យកាន់ទៅដល់ខៀវឡ ។

សាមគ្គីកខ្វៃ ៥៤

តាំងតីមាំឈៀវបែកទ័ពរត់តីបូធូទៅ។ នៅស្រុកដៀងក្រៅស្រុកចិនហើយវិលមកវាយស្រុកតីជីវ រហូតដល់គួនអ៊ូ មានចំរើទៅសុំឡៅតីសូនឹងមាំឈៀវ ខុងបេងមានសំបុត្រទៅឃាត់គួនអ៊ូ។ ក៏ឈប់មានមិនបានបួលទៅដល់ឡៅតី ។

ឯម៉ាឈៀវកាលបែកចំពារតំពីចូនូ ទៅតាមខ្នែអ៊ូយហោ គ្រានោះ កំ
ទៅនៅស្រុកធ្យៀវក្រៅដែនស្រុកចិនបានប្រហែល ៣ ខែ កំបញ្ចុះបញ្ចាល
ការបានជាច្រើន កំទោកយយកអាណាខែត្រដំបន់ដែលចំណុះចូនូ
បានជាច្រើនអង្វែ ហើយកំលើកទៅកយយកស្រុកគីដីវ អ៊ុយ ១ ឆ ទៅ
ហ្វាយស្រុកគីដីវឲ្យសំបុត្រទៅដល់ហៃហ៊ូអៀនឲ្យលើកទៅជួយ ហៃហ៊ូ
អៀនក៏ព្រងើយកន្តើយមិនសូវយកចិត្តទុកដាក់ មិនបានឲ្យដំណឹងទៅដល់
ចូនូ។ មិនបានលើកចំពាទៅជួយអ៊ុយ ១ ឆ សោះ អ៊ុយ ១ ឆ ចេះតែរង់ចាំកងចំព
ហៃហ៊ូអៀនជាយូរខែឯណាស់ មិនឃើញលើកទៅសោះ កងចំពម៉ាឈៀវ
ក៏លើកពីខ្នែស្រុក អ៊ុយ ១ ឆ គិតទំនឹងលើកចំពចេញទៅចំណុះចុះចូលម៉ា-
ឈៀវ ។

ពេលនោះអៀវហ៊ូទាយ ភាហានក៏ចូលទៅស្រែកឃាត់ ហាមថា
ដែលទំនឹងលើកចេញទៅចំណុះចុះចូលម៉ាឈៀវតែម្តងនោះ ខ្ញុំមិនពេញ
ចិត្តសោះ ព្រោះម៉ាឈៀវនោះជាមនុស្សអកតញ្ញូ ទំនឹងទៅហ្វាយទាយ
មិនមានសុចរិតពិតត្រង់សោះ ត្រូវការអ្វីទំនឹងចេញទៅចំណុះ បើខ្ញុំសក់
ស្កូតែស្លាប់ក្នុងស្រុកតែម្តងទៅជាជាង អ៊ុយ ១ ឆ ថា តឡូវបើការបុថ្-
ជ្ជនគាល់តួមកដល់ប៉ុណ្ណេះហើយ អ្នកឯងនឹងមកឃាត់ហាមយើងមិន
ឲ្យចេញទៅចំណុះចុះចូលគេធ្វើម្តេចបាន អ៊ុយ ១ ឆ មិនស្តាប់ក៏បើកទ្វារ
ស្រុកចេញទៅខួលម៉ាឈៀវ ឲ្យចូលទៅក្នុងស្រុកហើយគំនាប់តាម

ប្រពៃណី មាំឈៀវៅដល់ស្រុកតគីដីវហើយថា អ្នកឯងចេកគ្មានទួលគំនាប់យើងគ្រានេះ ខ្លឹងបានចំណុះចុះចូលតមសុភាពសុចរិតត្រង់កំរេ ហេតុពីព្រោះមាល់ច្រកខ្លឹងរកទីចៀសកងពុំបាន ហើយបានជារឿងដូច្នេះ បើអ្នកឯងស្មោះស្ម័គ្រភក្តីខ្លឹងយើងកំគួរធ្វើតាមដំបូង តាមស្រួលទៅចុះ នេះពុំមែនធ្វើតាមអំពើសុចរិតពិតត្រង់ យូរទៅកំគង់ខ្លឹងគិតប្រទូសរ៉ាយយើងវិញ យើងខ្លឹងជឿទុកចិត្តកំមិនបាន ថាហើយកំបង្គាប់ទាហាន ឲ្យនាំយកខ្លួនអ៊ុយវង់ខ្លឹងត្រប់ត្រួតៅប្រហារជីវិតចាំងអស់ ទាហានចាំងពួកកំដំកបថា អៀវហ៊ូនេះគឺជាទាហានអ៊ុយវង់ កាលដើម អ៊ុយវង់ ខ្លឹងបង់ចេញមកគំនាប់លោកនោះ អៀវហ៊ូរឃាត់ហាមខ្លឹងខ្លឹងចិត្តលោក គឺគ្មានចិត្តកក្តីខ្លឹងលោកសោះ សុំឲ្យលោកយកអៀវហ៊ូទៅសម្លាប់ចេញ មាំឈៀវថា អៀវហ៊ូខ្លឹងចាស់ដូច្នោះជាប្រពៃណី ព្រោះជាមនុស្សខ្មៀងត្រង់ខ្លឹងសម្លាប់ចេញពុំគួរ គួរតាំងអៀវហ៊ូឲ្យជាទាហ៊ានដ៏ឧត្តមរក្សាស្រុកតគីដីវ អៀវហ៊ូគំនាប់ហើយថា ឥឡូវកេរយោខ្ញុំបានស្លាប់ឯស្រុកលាមអៀ ខ្លឹងសុំលាលោកទៅតែងការសពមួយខែពីរខែសិន បើស្រេចការហើយ ខ្ញុំបានខ្លឹងត្រឡប់វិលមករកលោកវិញ មាំឈៀវក៏ព្រមអនុញ្ញាតឲ្យអៀហ៊ូទៅ អៀវហ៊ូលាមាំឈៀវទៅដល់ស្រុកឡូកសេវដែលកៀវយឹមជាកូនរបស់មាក្សាខែត្រនោះ ក៏ត្រង់ចូលទៅគេមាកាកៀវយឹម គំនាប់ហើយក៏យំសោកថា ខ្លួនខ្ញុំបានទៅនៅធ្វើកជការជា

មួយទឹងអ៊ុយ១ឆងឯស្រុកតីដាវ មិនបានការពារក្សាទាយចៅហ្វាយរបស់ខ្លួនឲ្យផុតសេចក្តីអន្តរាយ ខ្លួលម៉ាឈៀរអាសត្រូវផែនដីមកសម្លាប់អ៊ុយ១ឆងចៅ ខ្ញុំបាទមិនដឹងបើទឹងគិតម្តេច ព្រោះខ្មាសមុខមិនដឹងទឹងយកចៅទុកឯណាបានឡើយ បានសេចក្តីអប្បយសដល់បណ្តាជនអ្នកស្រុកតាំងតួងខ្លាំងណាស់ ព្រោះធ្វើមនុស្សរក្សាទាយចៅហ្វាយមិនបានឥឡូវអាណាប្រជាកស្តូកក្នុងស្រុកតីដាវក៏ក្តៅក្រហាយឈឺចិត្តតែគ្រប់គ្នាគិតទឹងប្រឆូសព័យម៉ាឈៀរវិញឲ្យបាន ហេតុអ្វីបងខ្ញុំបានធ្វើដល់ចៅហ្វាយស្រុកឡូកសេ មិនបានចាត់ចែងតាហានលើកចៅដួយកំចាត់ សត្រូវចេញទំនៅស្ងៀមចៅបាន មិនមានឈឺចិត្តសោះឡើយ ។

មាតាក្មេវយឺមជាចាស់មានអាយុ ៨២ ឮដូច្នេះក៏ឲ្យហៅខ្លួនក្មេវយឺមមកប្រាប់ថា ឥឡូវស្រុកតីដាវ មានទ័ពម៉ាឈៀរលើកចៅប្រឆូសព័យអ៊ុយ១ឆងកំរើយដីតែចៅហើយ ចៅក៏នៅត្រងើយមិនលើកតាហានចៅដួយតាល់តែអន្តរាយស្រុកបានចៅតែអស់ ទោសកំហុសកំទឹងមានមកចំពោះខ្លួនចៅជាខ្មួនមិនខាន បើដឹងការនេះចៅដល់ចូនូវណា កំទឹងយកទោសវិលនោះ ហើយនិយាយទឹងក្មេវហ្នឹងថា ខ្លួនចៅខាងនេះបានខ្លួលតំទាប់ដាប់ប្តេជ្ញាទឹងម៉ាឈៀរ ។ ក៏ជឿចិត្តឥតពាក់ល់លើកដំកើងខ្លួនឲ្យធ្វើនាម៉ឺនបានស៊ីបៀវត្សរ៍តែហើយ ហេតុម្តេចក៏តេចមកគិតមិត្រទ្រុស្តទឹងតែវិញ ចៅជាមនុស្សអកតញ្ញូនគុណតែចៅខ្លួន ។

ក្មេវហ្នឹងឆ្លើយថា ដែលខ្ញុំបាទចំណុះចុះចូលម៉ាឈៀរនោះមិនមែន

ជាការសុចរិតច្រោកដល់ខ្លួន ច្រើនជាងគ្រាន់តែដោះដៃតែខ្លួនប៉ុណ្ណោះ ដើម្បីមិនឲ្យ
អន្តរាយដល់អ្នកស្រុក ចានជាប្រមុខមកដល់នេះ ព្រោះមិនគិតធ្វើ
ការសងសឹកវិញឲ្យចាន គេរៀបរឹមថា ម៉ាឈៀវនោះមានថ្វីដៃខ្លាំង
ពូកែណាស់ ដែលមិនគិតកំចាត់ចេញក៏កម្រ អៀវហ៊ូថា ទោះបីថ្វីដៃក
ខ្លាំងពូកែក៏មែន តែមិនចានជាមនុស្សមានសតិបញ្ញាដែលមិនយល់ការកត់
ប្រៀកក្នុងថ្ងៃសង្គ្រាមប៉ុន្មានទេ ប្រសិនបើលោកមិនគិតកំចាត់ចេញក៏គង់
ចាន តាលខ្ញុំចាទមិនមកនោះ កំចានណាត់ការពុកមិនឡើងខ្លាន់ ទៀ
ហេង បើបងមិនលើកតាហានទៅកំចាត់ម៉ាឈៀវវិលណា អ្នកចាំងពីរ
ក៏មិនខ្លួលជាកលសឹក ចាត់ការក្នុងស្រុកស្រាប់ហើយ ។

មាតាគៀវយឹមថា បើដូច្នោះចូរទៅគិតកំចាត់ចេញឲ្យឆាប់ចុះ
បើលុះពុកឲ្យយូរទៅ គេក៏មានគំនិតគិតឃើញការម៉្យាង ។ យើងក៏ធ្វើគេ
ពុំចាន មានសេចក្តីលំបាក ធម្មតាកើតមកជាមនុស្សក្រលំគ្នា នរណា ។
ក៏ត្រូវតែស្វាប់ម្តងម្នាក់ដូចគ្នា បើចៅទីធ្វើសង្គ្រាមហើយ មិនត្រូវគិត
ខ្លាចសេចក្តីស្លាប់នោះឡើយ ។ មួយទៀតក៏មិនត្រូវគិតអាល័យពក្យ
ក្រាយដល់ម្តាយនេះឡើយ បើថាព្រួយវិតក្កដល់ម៉ែហើយ ម៉ែក៏ទីធ្វើស្លាប់
ឲ្យហើយរួចសឹមទៅចុះ ម្តាយគិតនេះតីកុំឲ្យព្រួយវេលដល់ទៅ គៀវយឹម។
ឮមាតាថា ក៏ចាត់ឲ្យទៀតាំងចាត់ចែងតាហានត្រៀមពុកព្រម រួចលើក
ទៅជាមួយទីធ្វើអៀវហ៊ូ ។

ម៉ាឈៀវលុះដឹងថា អៀវហួតៅប្រាប់កៀវយ៉ឹមឲ្យលើកទ័ពមកទីធ្វើអន្តរាយដល់ខ្លួនដូច្នោះគឺទីនឹងវ៉ាំងណាស់ គាំងតែលើកទាហានចេញពីស្រុកតីជីវៅជាមួយជាំងគេកទីងម៉ាតាយ ប្រាថ្នាទីងចាំរង់ទ័ពកៀវយ៉ឹម លុះកៀវយ៉ឹមលើកទាហានតៅដល់កណ្តាលផ្លូវ ក៏ប្រទះគ្នាទីងទ័ពម៉ាឈៀវ ទើបបរសេះចេញតៅបញ្ជ្រៅទៅមុខទាហានតាំងភ្លងហើយស្រែកថា អាសត្រូវផែនដី ឯងចើចង់តស៊ូនឹងអញក៏ចូលមកចុះ ម៉ាឈៀវទីនលើសកម្លាំង គាំងតែបតុលចូលវាយប្រកាប់ជាប់ដៃគ្នា សម្លាប់ទាហានកៀវយ៉ឹមស្លាប់ច្រើនណាស់ កៀវយ៉ឹម អៀវហ៊ីតស៊ូមិនបាន ក៏បំផាយសេះតៅ ម៉ាឈៀវបានដំនងក៏ចេញតាមតៅ ទៀតាំងទាហានកៀវយ៉ឹមឃើញដូច្នោះ កំលើកទាហានស្ទុះតាមក្រោយ កៀវយ៉ឹមក្រឡេកមកឃើញក៏ត្រឡប់មុខមកតវិញ ម៉ាឈៀវគំនៅក្នងចំណាមទ័ព ចេះតែកប់ឆីតារាខ្លួនតៅវិញតៅមក ។

ខណួលហៅហ៊ូអៀន លើកកងទ័ពស្រួចចូលមកប្រសព្វគ្នា ក៏ដេញទាហានឲ្យចូលប្រកាប់ប្រចាត់ជួយកៀវយ៉ឹម ទាហានតាំង ៣ កងក៏ចូលប្រយុទ្ធតតូ៉ជុំវិញខ្លួនម៉ាឈៀវ ។ លើសក់ឡាំងនឹងតស៊ូពុំឈ្នះ ក៏ស៊ុះបំតារង់ណាយតៅតៅ ដល់ភ្នំស្រាង ស្មុមដល់តៅស្រុកតីជីវក៏ហៅឲ្យបើកទ្វារខណួល ទៀហោង ឡេងខ្វាន ដែលនៅក្នងស្រុកនោះ មិនឲ្យបើកទ្វារខណួល តាំងតែឡើងលើកំផែង ហើយឲ្យទាហានបាញ់ធ្នូចម្រុះចុះមក

ហើយស្រែកដេរមាំឈៀវមិនដាច់ពាក្យសោះ រួចគិយកបុត្រតរយាន៥ដង ស្ទុះត្របក្បូតកាត់ក្បាលខ្មាក់ចុះមក ចំពោះមុខមាំឈៀវ។ ឃើញដូច្នោះគំលឺឆួលនេះក្នុងចិត្ត ហាក់ដូចភ្លើងឆេលើដើមទ្រូង ធ្លាក់ពុះពារលើសេះដល់ ៣ ដង ៤ ដង មិនដឹងដែលទឹងធ្វើប្រការម្តេច ។

ខណៈនោះហៃហ៊ូអឿន ឃុំតាហានលើកទ័ពតាមមកតាន់មាំឈៀវ។ តាហានតិចណាស់ ក៏វាយខ្ចាយស្ទុះរត់ទៅ ខ្លួលប្រុះទឹងកងទ័ពកៀវយឹមទឹងអៀវហ៊ូស្ងាត់នៅតែមុខ មាំឈៀវបេរសេះពុះពារចំលាយតាហានតាំងខ្ចាយចេញទៅផុតអស់ ខ្លៀវតាំងក៏លើកជួនថែមទៅជាក្រោយ ក៏ចោមព័ទ្ធមាំឈៀវជុំវិញ តាប់សម្លាប់តាហានស្ងាប់ដេរដាសមាំឈៀវម៉ាកាយទឹង ចាំងតេក ឃើញតាហានសល់ទៅប្រហែល ៥០ នាក់ ក៏បេរសេះគេចនាំតាហានតាំងខ្លោះស្ទុះរត់ចេញរួចទៅ តាំងពីថ្ងៃលុះយប់ទៅដល់ស្រុកឡុកសេ ដើរទៅដល់តែរកែងឆ្អឹង តាហានក្នុងស្រុកឡុកសេមិនចាន់សង្កេតព្រោះយប់ងងឹតណាស់ សំគាល់ថា កៀវយឹមចេញហ្វាយស្រុក លើកត្រឡប់ទៅវិញក៏បើកទ្វារខ្លួល មាំឈៀវក៏នាំតាហានកន្ទុងចូលទៅក្នុងស្រុកបាន ហើយដេញតាប់សម្លាប់អ្នកស្រុកស្លាប់ជាច្រើនណាស់ រួចចូលទៅចាប់យកម្ចាយកៀវយឹមមកគ្រៀវផ្ទះ មាតាកៀវយឹមមិនខ្លាចសេចក្តីស្លាប់ ចង្អុលមុខដេរមាំឈៀវថា អាសត្រូវផែនដី អាឯងសម្លាប់អញជាស្រីតំតាមចិត្តចុះ មាំឈៀវខឹងណាស់ គិយកត្របី

ការប់មាតាកៀវយើមស្លាប់ លុះព្រឹកឡើងវៃហាហ្លួអៀនដឹងដំណឹងក៏លើកការហានដឹតតាមមកខ្មែត មាំឈៀវតន់ចេញពីស្រុកឡុកសេវៅ ក៏ជួបប្រទះនឹងអៀវហ្លួលើកការហានតាមមកក្រោយខ្មែត មាំឈៀវក៏បរសេះចូលប្រយុទ្ធនឹងអៀវហ្លួ ការប់សម្លាប់ការហានអៀវហ្លួស្លាប់ច្រើនណាស់ អៀវហ្លួត្រូវលំពែងជាការធ្ងន់ពន់ប្រមាណក៏មិនបានតន់ចូលតស៊ូនឹងមាំឈៀវជាសាហ៊ាស ខ្លួលវៃហាហ្លួអៀនលើកត្រឡប់តាមមកពីក្រោយជួយអៀវហ្លួ មាំឈៀវក្រឡេកឃើញការហានខ្លួនសល់តែ៧ នាក់ក៏ខាំចុំឆឹតេត មាតាយមួការហានតាំងនោះគេចវៅ ។

វៃហាហ្លួអៀន បានតំចាត់មាំឈៀវ បែកតន់វៅហើយ ក៏លើកការហានវៅច្បាបច្បាមអាណាខេត្ត ឡុកសេបានកចការជាប្រក្រតីគ្រប់ដំបន់តាំងឲ្យកៀវយើម នៅរក្សាស្រុកនោះដូចដើម ទើបនាំយកអៀវហ្លួដែលត្រូវបួស ឡើងវេះត្រឡប់វៅក្រុងហ៊ូតោ ប្តឹងការឲ្យចូនូជ្រាបគ្រប់ប្រការ ។ ចូនូក៏មានសេចក្តីត្រេកអរណាស់ ទើបតាំងឲ្យអៀវហ្លួជាឥស្សរជំ ។

ខណៈកាលមាំឈៀវបែកវៅនោះ ក៏ប្រឹក្សាគ្នានឹងចុំឆឹតេត មាតាយថា ឥឡូវនេះ យើងនឹងរកទីអាស្រ័យមិនបានឡើយ នឹងវៅតឹងការលើស្រុកខិសឯកើតនឹងឯលិច ក៏សឹងជាដែនដំបន់របស់ចូនូចាំងអស់ យើងនឹងនាំគ្នាវៅប្រស្រ័យនៅនឹងខៀវឡងស្រុកហ៊ានតុងចុះ លុះប្រឹក្សាគ្នា

ហើយ មាំឈៀវចាំងតេត ឧឆ មាំតាយ កំនាំពាហាន ៥ នាក់ចូលទៅ
នៅកងស្រុកហ៊ានតុងជាមួយនឹងខ្មៀវឡ ។ កំខួលរាប់អានស្រឡាញ់ពេញ
ចិត្តណាស់ ទើបនិយាយនឹងឪប្រឹក្សាចាំងពួងថា ឥឡូវ មាំឈៀវមក
នៅនឹងយើងហើយ ដែលយើងនឹងគិតធ្វើការទៅខាងមុខនោះយើញថា
ស្រួលណាស់ ខាងឯសងកើតកំនឹងបានតស៊ូប្លន់ ខាងឯសងលិច
កំនឹងគិតយកស្រុកសែឈួន គ្រានោះសត្រូវដែលមានខ្លួនកំនឹងកោត
ក្រែងវែងខ្លាច ព្រោះមាំឈៀវមានអំណាចខ្លាំងពូកែមកជាកម្លាំងយើង
ហើយគួរតែយើងនឹងលើកកូនក្រមុំយើងឲ្យយកគ្នាជាស្វាមីភរិយា នៅនឹង
គ្នាតាមប្រវៃណី ។

អៀវប៉ែកហាមឃាត់ថា ដែលលោកនឹងលើកបុត្រីឲ្យជាភរិយាមា
ឈៀវនោះ ខ្ញុំបាទមិនពេញចិត្តសោះ ព្រោះមាំឈៀវនោះអកតូនឹង
រក្សាតែបុត្រកំរិយារបស់ខ្លួន កំមិនគង់មួងទៅហើយ វេលានេះ បើលោក
លើកបុត្រីឲ្យទៀត តទៅមុខកំគង់នឹងរក្សាបុត្រលោកពុំបានដូចគ្នា គង់
នឹងលះបង់ឲ្យអន្តរាយជាក្រាកជាពុំខាន សូមឲ្យលោកនិះគិតអានសិន ។
ខ្មៀវឡយល់ឃើញត្រូវ កំមិនបានលើកកូនក្រមុំឲ្យមាំឈៀវវិញ មាំ-
ឈៀវដឹងថា អៀវប៉ែកឃាត់ខាំងកំពង់ពួជ្មោះកំខាស់តួចចិត្តខ្លាំងណាស់
គិតទឹងនឹងអៀវប៉ែកមិនរសាយ គិតនឹងប្រឌួសពាយឲ្យបានវិញ ។ អៀវ
ប៉ែកដឹងខ្លួន កំប្រឹក្សានឹងអៀវសុនជាបងថានឹងជួយកំចាត់មាំឈៀវចេញ ។

ឯអ៊ុយគួនដែលកាន់សំបុត្រមកពីស្រុកសែឈួននោះ លុះទៅដល់ហើយក៏យកសំបុត្រនោះទៅជូនខៀវឡ ។ បានខ្លួលមើលឃើញសេចក្តីថា ខ្លៅដឿងដំណមកខៀវឡបានជ្រាប ដ្បិតឥឡូវនេះខ្លៅតែលើកទ័ពមកធ្វើអន្តរាយដល់ស្រុកសែឈួនហើយ គឺតប្រឆំនឹងធ្វើការឲ្យខ្លួលំខ្លួលាយតទៅទៀត ឯស្រុកសែឈួននឹងស្រុកហ័នតុងនោះ កំទបមាបីជួបបបួរមាត់ទឹងឆ្នេញគ្នាជិតណាស់ បើខ្លៅតែវាយបានស្រុកសែឈួនហើយក៏គង់នឹងកលជាលមកវាយយកស្រុកហ័នតុងមិនបង្អីតខាន គាណាប្រទុកស្តាំជួងក៏នឹងបានសេចក្តីក្តៅក្រហាយ ការនេះសូមឲ្យអ្នកជួយលើកគាហានចាំងឡាយទៅជួយកំចាត់ខ្លៅតែចេញ បើសម្រេចបានការហើយ ខ្ញុំនឹងលើកអាណាខេត្តឲ្យអ្នក ២០ ដំបន់ ។ ខៀវឡឃើញសំបុត្រដូច្នោះក៏មានអំណរណាស់ ព្រោះចង់បានអាណាខេត្តសែឈួនក៏ខ្លួលពាក្យនឹងអ៊ុយគួនថានឹងលើកកងទ័ពទៅជួយ ។

រឿងល្បែកឡាហ្វុងតែន

លោក ដេង - ទ្រីវ ប្រែរៀបរៀង

(តមក)

ពិ៦ កិច្ចប្រឹក្សាដៃសត្វកណ្តុរ

មានគ្នាមួយឈ្មោះ « រូឌីឡាវខ្លុះ » តែងតែចាប់កណ្តុរចាំងឡាយជាចំណីស៊ើរទើងពាយអស់ ។ កណ្តុរខ្លះដែលនៅសល់ ខ្លាចមិនហ៊ានចេញពីរន្ធ ម្ល៉ោះហើយរកចំណីចំអែតកាយបានតិចតួចពន់ពេក ហើយ « រូឌីឡាវ » កាលណានៅរកកណ្តុរមិនមែនដូចឆ្នាះ ហាក់ដូចជាក្រាយច័ាចតែម្តង ។

ថ្ងៃមួយ អាដើងទើលទៅរកញ៉ាងលើដំបូលផ្ទះ ហើយក្នុងពេលដែលវាកំពុងប្រតិបត្តិជាមួយញ៉ាវប្រកបដោយសម្រែកដ៏ភ្ញាំង ពួកកណ្តុរដែលនៅសល់ នាំគ្នាធ្វើសន្និបាតត្រង់កៀនមួយ ស្តីពីការចាំបាច់បច្ចុប្បន្ន។

ដំបូងព្រឹទ្ធបុរស (កណ្តុរចាស់) ជាអ្នកមានការប្រុងប្រយ័ត្នជាងគេបង្ហោញយោបល់ថា ត្រូវតែយកចង្រ្កង់ទៅចងកវូឌីឡាកុំបង្អង់យូរ ធ្វើដូច្នេះ កាលណាគ្នារូឌីឡាមករកស៊ីកណ្តុរ ។ គាចរត់ពួនទៅក្នុងអ្វី ។ ខាន់ ព្រោះវាដើរមកឮសូរចង្រ្កង់ជាដំណឹង គឺមានតែមធ្យោបាយមួយនេះឯង ។

កណ្តុរចាំងអស់ក័យល់ស្របតាមលោកព្រឹទ្ធបុរសកណ្តុរ គឺថាគ្មាន

មធ្យោបាយអ្វីដទៃដែលស្រោចស្រង់កណ្តាឲ្យប្រសើរជាងនេះទេ ។ ការលំបាកនៅត្រង់យកចង្ក្រានទៅចងកន្ទា ។ អាមួយនិយាយថា ខ្ញុំមិនហ៊ានទៅសោះទេ ខ្ញុំមិនឆ្លួតទេ អាមួយទៀតពោលថា ខ្ញុំមិនមានសមត្ថភាពសោះ ។ អាមួយថាដូច្នេះ អាមួយថាដូច្នោះ រកធ្វើអ្វីមិនកើតពាល់តែនាំគ្នាបំបែកជួរទៅ ។

គេតិតតែពិការក្បា មហាសន្ធំបាតមានទីប្រឹក្សាច្រើនលើសលុប តែលុះត្រូវការអនុវត្ត គ្មានអ្នកណាម្នាក់ចេញមុខ ។

៣៣- សត្វប្រចៀវនឹងកង្កែបពីរ

ប្រចៀវមួយហ៊ោរទៅជ្រកនឹងសំបុកសត្វកង្កែប លុះអស្រ័យនៅយ៉ាងនេះហើយ កង្កែបដែលជាសត្រូវនឹងកណ្តុរមកយូរនោះ កាលបើឃើញដូច្នោះ ក៏ស្ទុះមកប្រជែងនឹងសម្លាប់ ។

កង្កែបពោលថា ម្តេចក៏អ្នកឯងហ៊ានមកនៅនឹងមុខខ្ញុំ ព្រោះពូជអ្នកឯងនេះ ជាខរកទុកាសតែនឹងបំផ្លាញខ្ញុំទេតើ ! ក្រែងអ្នកឯងជាកណ្តុរឬ ? ចូរប្រាប់មកឲ្យត្រង់ កុំកុហក ។ ប្រាកដមែន អ្នកឯងជាកណ្តុរពិតឬមួយខ្ញុំមិនមែនជាកង្កែប ! ។

ប្រចៀវអង្វរថា : សូមអ្នកអភ័យទោសដល់ខ្ញុំផង សំដីនេះ ខ្ញុំពុំត្រមះពិចារណាមុនទេ ខ្ញុំពុំមែនជាកណ្តុរសោះ ! មនុស្សចិត្តអាក្រក់បោះតែយកដំណឹងខុសនេះមកប្រាប់អ្នក ដោយសារអ្នកនិពន្ធកន្ទឹកលោក ។

ខ្ញុំជាបក្សីទេតើ អ្នកមិនមើលស្លាបខ្ញុំ! ជាយោគជនសត្វហើរ!

យោបល់ប្រចៀវគួរជាទីគាប់ចិត្ត ហើយហាក់ដូចជាត្រូវផង។ ប្រចៀវចេះតែសំខួន ពាល់តែកង្កែនបើកឲ្យមានសេរីភាពអាចដកខ្លួនចេញបាន។

ពីរថ្ងៃក្រោយមក សត្វប្រចៀវល្ងីល្ងើនេះ ដោយស្រវាំងតែកង្កែក ក៏ហើរទៅជ្រកទឹងសំបុកសត្វកង្កែនមួយដទៃទៀត ដែលជាសត្រូវទឹងសត្វបក្សីវាត្រូវខួលគ្រោះភ័យដល់អស់ជីវិត ជាប្តីម្ចងទៀត។

សត្វកង្កែនម្ចាស់សំបុក ក្តោងច្រមុះវែង ស្ទុះទៅបំរុងទឹងទាំប្រចៀវកូនហាន:ជាសត្វស្លាប ពេលនោះប្រចៀវតែភ័ថា កង្កែនប្រមាថមើលងាយវា: អ៊ីខ្ញុំជាសត្វស្លាប! ចូរអ្នកសំឡឹងមើលខ្ញុំឲ្យច្បាស់ តើខ្ញុំពិតជាសត្វស្លាបមែនឬ? សត្វបក្សីគេសំគាល់ត្រង់ស្លាប ខ្ញុំជាកណ្តុរទេតើ! ជាយោ កណ្តុរចាំងឡាយ! ឃើញឬទេ ព្រះបង្កើតសត្វឆ្នាំឲ្យច្រឡំគ្នាវែង។

ប្រចៀវរួចរស់ជីវិតពីរលើក ព្រោះតែការឆ្លើយដោះដឹកនាំវៃនេះ។

៣៨- កង្កែបសុំស្តេចមួយព្រះអង្គ

ដោយទៀយហាត់ទឹងសភាពប្រជាធិបតេយ្យ កង្កែបចាំងឡាយស្រែកសុំចំពោះព្រះ ឲ្យព្រះអង្គធ្វើខ្លួន ឲ្យតាំងនៅក្រោមអំណាចជាធិបតេយ្យវិញ។ ព្រះកំពុងម្ចាក់ស្តេចមួយព្រះអង្គយ៉ាងស្ងួតបូតពីលើមេឃ

ប្រទានដល់កង្កែប : តែស្តេចព្រះអង្គនេះ ក្នុងពេលដែលភ្ញាក់មក លាន់ឮសូរអស្ចារ្យ ពាល់តែពួកកង្កែបជាសត្វល្ងីល្ងើហើយខ្វាចច្រើន ខ្លះមុជពួនក្នុងទឹក ខ្លះពួនក្នុងគុម្ពកក់ ខ្លះក្នុងប្រហុស ខ្លះក្នុងន្លក្រតាំង មិនហ៊ានអើតចេញ មើលចំ ជាយូរពេល នូវព្រះកន្ត្រៃស្តេចដែលវាស្មានថាជាយក្ស ថ្មី ។

តើជាស្តេចយ៉ាងសូតដូចជាឈើមួយដុំ តែអាការៈធ្វើឲ្យកង្កែបកិតភ័យតក់ស្លុត ។ លុះយើញស្តេចយាងទៅមកបង្ហាញព្រះអង្គ កង្កែបអន់ភ័យ កំហ៊ានចេញពីរូងវៀងខ្លួន ។ កង្កែបខ្លះហ៊ានចូលជិត តែទៅបុកពោះ ។ អាមួយយើញកំធ្វើតាម អាមួយទៀតចូលមកដែរ មិនយូរប៉ុន្មាន វាមកអ៊ូដូចស្រមោច ទៅទល់ជុំតុត កង្កែបទៅជាស្ទះស្ទាលនឹងស្តេច រហូតដល់ទៅហ៊ានលោតពំលើព្រះអង្សា ។ ស្តេចស្ងួតនេះ មិនប្រកាន់ទោស ហើយគង់ទៅតែស្ងៀម ។

មិនយូរប៉ុន្មាន ព្រោះអង្គុតនឹងកង្កែបដែលស្រែកសុំឲ្យប្រទានស្តេចណាដែលចេះតំរើតទៅវិញ (មិនយកទេស្តេចធ្មឹងដូច្នេះ) ។ ស្តេចទេពតិបញ្ជូនត្រដក់មកឲ្យ ត្រដក់ចឹកបបប់ចុះបបប់ឡើង លេបកង្កែបតាំងមួលដោយសេចក្តីក្រែកយនៃអាត្មា ។

ចំណែកកង្កែបឮត្រដក់គ្នា ហើយព្រះមានបន្ទូលទៅនឹងកង្កែបតាំងទោះថា : ចុះវាអ្វីទៀតហើយ ! បំណងអ្នកពាល់គ្នាទេតើដែលបង្ខំយើងឲ្យ

រកស្តេចដែលប្រកាន់ថែបនេះ ។

ដំបូង អ្នកត្រូវតែរក្សាខុសឡែតម៉ត់ខ្លួរដ្ឋភិបាលរបស់អ្នក តែបើមិនបានធ្វើយ៉ាងនេះ តបវិញធ្វើយ៉ាងណា សុំឲ្យស្តេចតែមួយរបស់អ្នក មានចិត្តល្អជាទីបំផុត ហើយស្មូតបូតផង ហើយអ្នកត្រូវតែត្រេកអរនឹងស្តេចថែបនេះទៅ ខ្លាចត្រែងលោជាជួបណាមួយវិញ ដែលគាត្រក់លើសសុបនោះ ។

៣៩- អ្នកប្រមឹកនឹងប្រពន្ធ

មនុស្សម្នាក់ ។ រមែងមានគុណវិបត្តិរបស់ខ្លួន ហើយតែងវិលមករកគុណវិបត្តិនេះជាធម្មតា : ការអៀនខ្មាស ការខ្លាច មិនអាចធ្វើជាថ្នាំពូកែបានឡើយ ។

ចំពោះការណ៍នេះ ខ្ញុំនឹករឃើញរឿងមួយ ព្រោះខ្ញុំមិនដែលនិយាយអ្វីដែលគ្មានយកទៅបារម្ភមកជាទីអាងឡើយ ។

អ្នកប្រមឹកតែងធ្វើឲ្យខូចខ្លួសុខភាព ខូចគំនិតនឹងប្រាក់កាសរបស់ខ្លួន ។

មនុស្សថែបនេះ ចូលក្នុងឆាកជីវិតមិនទាន់បានពាក់កណ្តាលផង ក៏ស្រាប់តែអស់ប្រាក់លើង ។

ថ្ងៃមួយ អ្នកប្រមឹកនេះ ស្រវឹងជោក សន្ធប់ចាត់ស្មារតី ឃើញដូច្នោះ ប្រពន្ធលើកជាក់ក្នុងមឈូស ។ ដោយអំណាចស្រា គាត់នៅ

លក់ឥក្ខនីនោះ ។ កាលបើបានដឹងស្មានតែ គាត់យើញអណ្តាប់ភ្នែច
នៅដុំវិញខ្លួន គឺខ្មៀនគោលនឹងសំពត់សរុំសព ។

គាត់គោលថា : យី! ចុះអ្វីហ្នឹង? ប្រពន្ធអញមេម៉ាយទេតើ! ។

ឧកាសនោះ ដោយយកសំពត់គាន់ខ្លួនមកទៅវិ ហើយធ្វើសម្ងួនឲ្យ
ប្លែក នាងប្រពន្ធ មករកភ្នែចនោះ ចូលទៅដិតមឈូស ជាក់ដូនដល់
គាត់ ទូវិបាយសម្ងួរជាសំណៅនសម្រាប់ភ្នែច ។

ខណៈនោះ ប្តីដឿជាក់ថា អាអ្នាជាពលរដ្ឋនៃប្រទេសនរកពិតប្រាក
កដ គាត់សួរចំនោះប្រពន្ធដែលទៅសំពត់ថា ឯងជាអ្វី? ។

នាងប្រពន្ធធ្វើយប្រាប់ថា ខ្ញុំជាយាយដីនាងស្បៀងអាហារនៅឋាន
ព្រះយមរាជ ហើយខ្ញុំយកអាហារមកឲ្យអ្នក ដែលជាប់ទោសក្នុងទីដី
ឯងឹតនេះបរិគោត ។

ប្តីធ្វើយថាំងឥតគិតថា នាងឯងមានបានយកស្រាមកឲ្យវាផឹកផង
ទេ? ។

រឿងព្រេងបិនទី ៩

អ្នកលក់ត្រីនឹងយក្សខ្វាក់

Le vendeur de poisson et Yack borgne (conte tibétain)

ប្រែពីភាសាជ្វាំង ដោយលោក ក៉ុយ-ប៊ុក

តាំងពីអតីតកាល នៅក្នុងទេវៈ មានព្រះមហាក្សត្រិយ៍មួយអង្គ ទ្រង់មិនដែលសោយព្រះក្រយ៉ាំគ្មានត្រីទេ ។ តែក្នុងពេលមួយ ប្រទេសរបស់ព្រះអង្គមានវិបត្តិដោយគ្មានភ្លៀង ដីប្រែក្រហែងរកទឹកគ្មាន ។ នៅជាតស្ទឹង មានទឹកបន្តិចបន្តួច ត្រីក៏មានចំនួនថយចុះតាមលំដាប់ ។

ព្រះមហាក្សត្រិយ៍ទ្រង់មិនអាចសោយព្រះស្ងោយបានដោយគ្មានត្រី ទ្រង់មានព្រះរាជឫទ័យព្រួយបារម្ភជាខ្លាំង ក៏មានព្រះរាជបញ្ជាឲ្យចំពះព្រះរាជប្រកាសត្រប់ក្នុងឋានថា : « បើអ្នកណាមានត្រីស្រស់ឬត្រីងៀតយកមកថ្វាយទ្រង់ ។ នឹងជូនរង្វាន់ដល់អ្នកនោះតាមសេចក្តីសុំ » ។ ដំណឹងនេះក៏ឮសព្ទ័សូរខ្ទរខ្ទាសពេញប្រទេស ។ មានមួយថ្ងៃ មានបុរសម្នាក់មកដល់មុខព្រះបរមរាជវាំង បានយកពីបរទេស ខ្លួវត្រីមួយហើយមានចំណងចង់យកត្រីនោះទៅថ្វាយព្រះមហាក្សត្រ ។ នាយឆ្មាំព្រះបរមរាជវាំងឃាត់ហើយសួរថា :

« នែ បុរស ! អ្នកឯងមកណាមកណា ?

បុរសនោះតបទៅនាយឆ្មាំថា : « ខ្ញុំចង់សូមគាល់ព្រះរាជា តើបាន

ឬទេ? » ។

នាយឆ្មាំតបថា : « តើអ្នកមានការណ៍អ្វី? » ។

បុរសឆ្លើយថា : « ខ្ញុំមានត្រីមួយដែលខ្ញុំយកមកពីបរទេស សូមថ្វាយចំពោះព្រះពជា » ។

នាយឆ្មាំគិតក្នុងចិត្តថា : « ត្រីមួយ! អ្នកណាយកទៅថ្វាយព្រះបរមកត អ្នកនោះមុខជាបានក្តីគាប់ប្រសើរ! ព្រោះហេតុដូច្នេះ បានជានាយឆ្មាំពោលទៅកាន់បុរសថា : មិនអីទេ អ្នកចុកត្រីនៅទីនេះហើយ ខ្ញុំនឹងយកទៅថ្វាយព្រះអង្គជួសអ្នក » ។

បុរសតបថា : « ទេលោក ខ្ញុំសូមយកត្រីនេះទៅថ្វាយព្រះពជាខ្លួនឯង » ។

នាយឆ្មាំឆ្លើយថា : « បើអ្នកលក់ត្រីនោះមកឲ្យខ្ញុំ ។ ទើបឲ្យតម្លៃអ្នកតាមត្រូវការ » ។

ដោយបុរសនោះមិនព្រមលក់ត្រីឲ្យសោះ នាយឆ្មាំក៏សន្ទនាព្រមព្រៀងនឹងបុរសថា : ។

« ខ្ញុំអនុញ្ញាតឲ្យអ្នកចូលគាល់ព្រះពជាបាន តែបើអ្នកបានអ្វីៗ ត្រូវយកអ្វីៗនោះមកចែកខ្ញុំផង » ។

បុរសឆ្លើយថា :

« បើព្រមព្រៀងបែបនេះ ខ្ញុំក៏ពេញចិត្តណាស់ លោកនឹងបាន

វង្វាន់ពាក់កណ្តាល ។

នាយឆ្នាំតបថា: « តើអ្នកឯងនិយាយដោយសច្ចាពិតឬ! អ្នកឯងត្រូវស្បថឲ្យខ្ញុំជឿផង! » ។

ក្នុងពេលនោះ នាយឆ្នាំក៏អនុញ្ញាតឲ្យបុរសនោះ ចូលទៅក្នុងព្រះបរមរាជវាំង ។ លុះបុរសដើរតាមដំហានចូលទៅ បុរសនោះក៏ងាកក្បាលមកវាយនាយឆ្នាំហើយសួរថា: » ខ្ញុំមិនស្គាល់ឈ្មោះលោក បន្តិចទៀត ខ្ញុំនឹងមកវាលោក ដើម្បីនឹងចែកវង្វាន់ពាក់កណ្តាលនោះ » ។

នាយឆ្នាំឆ្លើយថា: « ខ្ញុំឈ្មោះយក្ខខ្លាក់ អ្នកណាក៏ស្គាល់ខ្ញុំដែរ » ។

បុរសក៏ចូលទៅក្នុងព្រះបរមរាជវាំង ហើយបង្គំគាល់ព្រះរាជា រួចទើបថ្វាយគ្រឿងនោះទៅព្រះអង្គ ។ ក៏មានព្រះរាជហឫទ័យសោមនស្សឥតឧបមា មានបន្ទូលសួរបុរសថា: « តើអ្នកប្រាថ្នាបានអ្វី? » ។

បុរសនោះក្រាបបង្គំទូលថា:

« ទូលព្រះបង្គំជាខ្ញុំមិនចង់បានវង្វាន់អ្វីទេ សូមតែព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យអាមាត្យរាយមួយតាន់បន្ទុះក្តារ » ។

ព្រះករុណាជាអម្ចាស់ដ៏វិសេស ទ្រង់ព្រះសណ្តាប់ទូវសេចក្តីក្រាបបង្គំទូលតបនៃបុរសនោះ ទ្រង់ព្រះសម្រួលជាយ៉ាងខ្លាំងហើយទ្រង់មានព្រះរាជឫទ្ធាថា: » បុរសនេះជាមនុស្សល្ងីល្ងើដែរ! បានជាមិនចង់បានវង្វាន់ ចង់ឲ្យគេវាយតាត់ទៅវិញ » ។

ព្រះរាជាទ្រង់មានព្រះរាជឫទ័យសួរហើយសួរទៀត បុរសនោះនៅតែធ្វើយតបនូវពាក្យដដែល ។ ។ ព្រោះហេតុដូច្នេះ ព្រះអង្គទ្រង់មិនដឹងជាទ្រង់ព្រះតម្រិះយ៉ាងណា ក៏ទ្រង់ត្រាស់បង្គាប់ឲ្យគេវាយ ១០០ បន្ទុះក្តារ តែទ្រង់ឲ្យវាយតិច ។ ។

អាមាត្យក៏ចាប់ផ្តើមបុរសនោះលើផែនប្រថពី ហើយក៏វាយតិច ។ ។ លុះវាយដល់គ្រប់ប្រាំរយដងបុរសនោះក៏ក្រោកឈរឡើងហើយពោលថា:

« ប៉ុណ្ណឹងហើយ ខ្ញុំបានឧទ្ទិសចំណែកខ្ញុំហើយ ឈប់ ។ » ។

អាមាត្យនឹកក្នុងចិត្តថា · ចំណែកមួយទៀតគឺអ្វីទៅ ! អ្នកណានឹងត្រូវឲ្យគេវាយប្រាំរយ ! » ។

ក្នុងពេលនោះ បុរសក៏ក្រាបបង្គំទូលព្រះរាជានូវគតិមានសព្វគ្រប់ប្រការហើយបន្តែមថា :

« ទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គហៅអ្នកយាមម្ខាក់នោះមក ហើយទ្រង់ត្រាស់បង្គាប់ឲ្យឧទ្ទិសវគ្គាន់ពាក់កណ្តាលទៀត » ។

ព្រះរាជាទ្រង់ព្រះក្រោធយ៉ាងខ្លាំង ហើយទ្រង់ត្រាស់បង្គាប់ឲ្យហៅ « យក្ខខ្លាក់ » នោះមកប្រញាប់ ។

« យក្ខខ្លាក់ » កំពុងតែគិតក្នុងចិត្តថា បើបានវគ្គាន់ពាក់កណ្តាលនោះមក តើអញនឹងគិតធ្វើអ្វី ? ។ កំពុងតែគិតសប្បាយក្នុងចិត្ត ស្រាប់តែនាយសន្ទិជាលខៅដល់ ។ « យក្ខខ្លាក់ » កំលោតត្រេកត្រអាល

សប្បាយជាខ្លាំង ។ លុះទៅដល់មុខព្រះភក្ត្រព្រះអង្គ ឃើញទ្រង់ក្រោធដូច្នោះ « យក្ខខ្លាក់ » មានចិត្តព្រួយជាមួយជាខ្លាំង ។ ព្រះរាជាទ្រង់ជ្រាបនូវតែឃើញ « យក្ខខ្លាក់ » ទ្រង់មានព្រះរាជបញ្ជាឲ្យចាប់នាយឆ្មាំនោះមកឲ្យដេកលើដែនប្រថពី ហើយកំតាំងរាយប្រាំរយដំបងថ្ងូសរីយ៉ាងខ្លាំង រួចនាយសន្តិបាលប្រាប់ « យក្ខខ្លាក់ » ថា:

« នេះគឺវង្វាន់ពាក់ព័ន្ធលំពោះរឿងអម្បាលម៉ិញនេះ ដែលឫសបានថ្វាយចំពោះព្រះរាជា ។ « យក្ខខ្លាក់ » ឈឺកំពឹងតូចជាខ្លាំង តែបានហាមាត់ញញឹមទៅឫសនោះថា :

« នេះចំណាវង្វាន់ប្រសើរថ្លៃថ្លា មែនទេមិត្ត ! » ។

« លោកណាស់លោកខ្ចប លោកនេះជាពូជ ហាយនភាព ចង់បានខុសបទ ប្រាំរយនាប កូនចៅគួរជ្រាប « យក្ខខ្លាក់ជាន័យ ។

ចប់រឿងអ្នកលក់ត្រីនឹង « យក្ខខ្លាក់ » នៅមានរឿងបក្សាចាចាតាខ្លួនឯងហង្សមាសតទៅទៀត ។

សំបុត្រទី ៦

របស់ លោក នេរុ ផ្ញើទៅបុត្រីលោក

ឈ្មោះ នាង លក្ស្មី

លោក ឈ ន - អៀម ប្រែព័ត៌សាអង់គ្លេស

កំណើតនៃមនុស្ស

យើងបានឃើញនៅក្នុងសំបុត្រយើងមុនថា យ៉ាងដូចម្តេចដីតបាន កើតឡើងនៅលើផែនដីក្នុងទ្រង់ទ្រាយយ៉ាងសាមញ្ញបំផុត ហើយវិវឌ្ឍនាបន្តិចម្តងៗ រាប់លានឆ្នាំ ទើបបានមកជាសណ្ឋានទ្រង់ទ្រាយសត្វថ្ងៃនេះ។ ក្នុងដំណើរវិវឌ្ឍនានៃដីតនេះ យើងក៏បានកត់សំគាល់ឮវិក្ខ្លនមួយដ៏មានសារៈសំខាន់យ៉ាងជាប់ចិត្ត គឺថា សត្វតាំងឡាយតែងចិតទំអនុលោមធ្វើខ្លួនឲ្យស្របទៅនឹងសភាពតាំងឡាយ ដែលនៅជុំវិញខ្លួនវាជាជាងបាប។ ក្នុងការចិតទំនេះ វាបានបង្កើនពន្លឺកម្ចីនូវគុណសម្បត្តិថ្មីៗ ទៀតជាច្រើន ហើយបានប្រែទៅជាសត្វមានគុណសម្បត្តិខ្ពង់ខ្ពស់នឹងមានពន្លឺកាយកាន់តែសាំញ៉ាំឡើង។ យើងអាចឃើញនូវការផ្លាស់ប្តូរនេះ ឬក៏វិវឌ្ឍនភាពនេះ ដោយមធ្យោបាយជាច្រើន។ តួយ៉ាង ដំបូងបង្អស់ មានសត្វគ្មានឆ្អឹងកើតឡើង ប៉ុន្តែដោយសត្វបែបនេះពុំអាចរស់នៅបានយូរ វាក៏បានបង្កើនឲ្យមានឆ្អឹងឡើង។ ឆ្អឹងដំបូងដែលវាបានបង្កើនឡើង គឺឆ្អឹងខ្នង។ ដូច្នេះ យើងអាចមែងចែកសត្វជាពួក: គឺ និយាដ្ឋដឹកសត្វ

(សត្វគ្មានឆ្អឹងខ្នង) និងបង្កាដូកសត្វ (សត្វមានឆ្អឹងខ្នង) ។ មនុស្ស និង
សត្វដែលកូនឃើញទៅជុំវិញកូន សុទ្ធតែមានឆ្អឹង ។

តមកទៀត កូនប្រទះឃើញសត្វសាមញ្ញតាំងឡាយដូចជាពួកត្រី
ដែលពងហើយចោះបង់ពងនោះចោល ។ វាពងម្តងៗកប់ពាន់ ប៉ុន្តែវា
មិនថែរក្សាពងតាំងនោះទេ ។ មេមិនចេះការពារកូនតូចៗទេ វាគ្រាន់
តែពងហើយចាកចេញទៅ ពុំរំលែកត្រឡប់មករកពងវាវិញឡើយ ។ ដោយ
ហេតុតែគ្មានអ្នករក្សាថែរ ភាគច្រើននៃពងតាំងនោះត្រូវស្លាប់ ហើយភាគ
តិចក៏បានញាស់ទៅជាពួកត្រី ។ នេះមិនគឺជាការខ្ជះខ្ជាយមួយយ៉ាងសំ
បើមទេឬ ? បើយើងថយមកពិនិត្យសត្វដែលមានគុណសម្បត្តិខ្ពស់
វិញ យើងឃើញថាពងឬកូនតូចៗ នៃសត្វប្រភេទនេះ មានចំនួនតិច
ទេ ប៉ុន្តែវាចេះថែរក្សាពងឬកូនតូចៗ យ៉ាងមត់ចត់ ។

មេមាន់គឺពងដែរ ប៉ុន្តែវាចេះក្រាបហើយគ្រាស់ពងរបស់វា ហើយ
លុះដល់កូនមាន់តូចៗ ញាស់ហើយ វាចិញ្ចឹមកូនតាំងនោះអស់ពេលបន្តិច
ទៀតផង ។ តែដល់កូនមាន់ធំឡើង មេមាន់មិនសូវរវល់ថែរក្សាប៉ុន្មាន
ឡើយ ។

តមក មានការប្រែប្រួលយ៉ាងធំ ក្នុងចំណោមសត្វឆ្អឹងខ្ពស់តាំងឡាយ
គឺថនិកសត្វ ដែលខ្ញុំពុកបាននិយាយខ្លះហើយក្នុងសំបុត្រមុន ។ សត្វ
ពួកនេះពុំពងទេ តែរក្សាពងទុកនៅក្នុងពោះ ហើយបង្កើតជាកូនពេញ

លក្ខណៈតែម្តង ដូចជាខ្លែ ឆ្មា ខន្ធាយ ។ ហើយបន្ទាប់មក មេបំបៅកូន ។ ដូច្នេះ មេរក្សាការពារកូនរបស់វាយ៉ាងម៉ឺងម៉ាត់ចត់ ។ ពេះជាដូច្នោះក៏ដោយ កូនតង់ឃើញថាមានការខ្លះឆ្ងាយយ៉ាងខ្លាំងណាស់ដែរ។ ខន្ធាយបង្កើតកូនមានចំនួនច្រើន តិចបីខែម្តង ហើយកូនភាគច្រើនត្រូវស្លាប់ទៅវិញ ។ ប៉ុន្តែសត្វខ្ពង់ខ្ពស់ដូចជាដំរី បង្កើតកូនម្តងតែមួយប៉ុណ្ណោះ តែចេះថែកូនយ៉ាងប្រពៃ ។

ដូច្នេះ កូនត្រូវយល់ថា ទៅពេលដែលសត្វចំរើនធំឡើង វាពុំពងទេ គឺតែពោះកូនតូចដែលធំជាត់ឡើង ដូចជាមេវាសុទ្ធសាធឯចឹង គ្រាន់តែតូចជាងប៉ុណ្ណោះ ហើយតាមធម្មតា សត្វខ្ពង់ខ្ពស់បង្កើតកូនម្តងតែមួយ ។ កូនគួរកត់សំគាល់ទៀត សត្វខ្ពង់ខ្ពស់រមែងមានសេចក្តីស្រឡាញ់ខ្លះ ។ ចំពោះកូនរបស់វា ។ មនុស្សគឺជាសត្វខ្ពង់ខ្ពស់បំផុត ហេតុដូច្នោះហើយ កូនរមែងឃើញម្តាយឪពុកតែងស្នេហាអាសូរនឹងថែទាំកូនយ៉ាងផ្ចិតផ្ចង់ ។

តាមគន្លងនេះ មនុស្សក្រោកដជាបានចំរើនឡើងជាជំបូងអំពីសត្វតាបមក ។ តាមស្មាន បឋមមនុស្សមានភាពប្រហាក់ប្រហែលនឹងមនុស្សដែលយើងឃើញសត្វថ្ងៃនេះដែរ ។ មនុស្សនោះ ពាក់កណ្តាលជាស្វាត្រាម ពាក់កណ្តាលជាមនុស្សសៅនៅ ហាក់ដូចជាមនុស្សសុទ្ធសាធ ។ តើកូននៅចាំបានទេ កាលយើងទៅជួបលោកសាស្ត្រាចារ្យម្នាក់នៅក្រុងហៃដែលបឺគ្ស៊ី (Heidelberg) ក្នុងប្រទេសអាល្លឺម៉ង់ ? លោក

ចាន់ចង្អាញយើងនូវសាមន្តរតួចមួយដែលគោរពភក្តីដោយចាស្ថាណ៍ភូត ហើយជាពិសេស នូវឆ្អឹងរាងក្បាលចាស់មួយ ដែលលោកបានរក្សាទាក់ សោតុយាំងម៉ត់ចត់ ។ គេសន្និដ្ឋានថាឆ្អឹងរាងក្បាលនោះ ជារបស់មនុស្សជាន់ដើមណាមួយ ។ ឥឡូវនេះ យើងហៅមនុស្សជាន់ដើមនោះ ថាមនុស្សហៃដែលបឺក្ស (The Heidelberg man) ដោយហេតុថាឆ្អឹងរាងក្បាលរកឃើញកប់នៅជិតក្រុងហៃដែលបឺក្ស ។ មែនហើយ កាលពីសម័យត្រង់នាយនោះ ពុំមានក្រុងហៃដែលបឺក្សឬងានីណាមួយផងទេ ។

ក្នុងសម័យជាន់ដើមនោះ កាលដែលបឋមមនុស្សនៅគ្រាច់ឆ្ពិតវិលវល់ចុះឡើង: អាកាសធាតុត្រជាក់ពេកណាស់ ។ សម័យនោះ គេហៅថា យុគទឹកកក ពីព្រោះមានទឹកកកច្រើនណាស់ ។ តំនទឹកកកចាំងឡាយ ដូចជាតំនទឹកកកដែលឋិតនៅជិតអាកាសានខាងជើង (The Nord Pole) សព្វថ្ងៃនេះ ចានអិលចុះមកកាន់ប្រទេសអង់គ្លេសនឹងប្រទេសអល្លឺម៉ង់ ។ មនុស្សចានប្រទះនឹងការពិបាកក្នុងការរស់នៅណាស់ ហើយមានពេលកង្វល់យ៉ាងច្រើន ។ គេច្បាស់ថារស់នៅតែពីណាដែលគ្មានតំនទឹកកកប៉ុណ្ណោះ ។ អ្នកវិទ្យាសាស្ត្រចានច្បាប់យើងថា នៅសម័យនោះ សមុទ្រមេឌីតាក៏ណេមិនមែនជាសមុទ្រទេ គឺគ្រាន់តែជាបឹងមួយឬពីរប៉ុណ្ណោះ ។ ឯសមុទ្រក្រហមក៏ពុំមានដែរ ។ គឺជាដីគោកចាំងអស់ ។ តាមស្មាន តាតង់នៃប្រទេសស៊ីបេរី គឺជាកោះមួយ ហើយ

មានសមុទ្រនៅត្រង់ពុន្ធាប (PunJab) ទឹងត្រង់ផ្នែកនៃទ្វេត្រង់ឯណ្ឌាយ
របស់យើង ។ ចូរកូនស្មានខុកភូមិភាគឥណ្ឌៀ ភាគខាងត្បូង ទឹងឥណ្ឌៀ
ភាគកណ្តាលខុកដូចជាកោះមួយយ៉ាងធំ ដែលជាប់ផុតពីដួរក្តៅហិមល័យ
ដោយសមុទ្រល្បឹងមើល ! កូនមុខជាត្រូវទៅកាន់ស្រុកមូស្សួរ Mussoorie
ដោយកថាំល់មួយដំណាក់មិនខាន ។

នៅពេលដែលមនុស្សកើតឡើងជាដំបូង គឺត្រូវសត្វធំ ។ ជាច្រើន
ចោមរោមជុំវិញ ហើយត្រូវរស់នៅក្នុងសេចក្តីភ័យខ្លាចនៃសត្វទាំងនោះ ។
សត្វថ្ងៃនេះ មនុស្សជាម្ចាស់នៃពិភពលោកហើយ គេប្រើសត្វទាំងឯណ្ឌាយ
ឲ្យធ្វើអ្វី ។ តាមគេប្រាថ្នា ។ គេបានផ្សាំងសត្វខ្លះដូចជាសេះ មេគោ
ដំរី ក្តែ ឆ្នា ទឹងសត្វដទៃទៀតជាច្រើន ។ គេបរិភោគសត្វខ្លះ ហើយ
សត្វខ្លះដូចជា សិង្ហ ខ្លាធំ ខ្លាឃ្មុំ គេចាញ់សម្រាប់សេចក្តីសប្បាយ ។ ប៉ុន្តែក្នុង
សម័យនោះ មនុស្សមិនបានជាម្ចាស់ទេ គឺគ្រាន់តែជាសត្វលោកវង់វេទនា
ដែលត្រូវគេបណ្តេញដែរ ទិតខំគេចវេះប្រាសអំពីពាឡម្រឹគធំ ។ ។ តែ
បន្តិចម្តង ។ មនុស្សបានលើកសួយខ្លួនឯងហើយបានទៅជាមានឥទ្ធិឫទ្ធិ
ខ្លាំងឡើង ។ ទាល់តែក្លាយទៅជាមានកម្លាំងជាងសត្វទាំងអស់ ។ តើ
មនុស្សខ្លាំងត្បូតែយ៉ាងដូចម្តេច ? មិនមែនដោយសារអត្តពលទេ ព្រោះ
ថាដំរីខ្លាំងលើសជាងមនុស្សទៅទៀត ។ គឺដោយសារតែប្រាជ្ញាទឹង
កំណើនៃខួរក្បាល ។

យើងអាចតាមរាណាមើលដើមកំណើត នៃការដុះដាលនៃប្រាជ្ញា

តាំងពីសម័យត្រង់នាយនៃមនុស្សរហូតដល់មកសម័យបច្ចុប្បន្ននេះ ។ ពិតមែនហើយ គឺប្រាជ្ញានេះឯង ដែលវិញកមនុស្សចេញអំពីសត្វឯទៀតៗ តាមធម្មតា គ្មានការប្លែកអ្វីទេ រវាងមនុស្សនឹងសត្វ ។

តាមស្មាន ការរកឃើញដំបូងមុនគេ ដែលមនុស្សរកឃើញ គឺការរកឃើញភ្លើង ។ យើងបង្កាត់ភ្លើងសព្វថ្ងៃដោយសារឈើគូស ។ តែតាមពិត ឈើគូសគឺជាវត្ថុធ្លាក់ចុងក្រោយ ។ នេះទេ ។ កុងសម័យដាន់ដើម គេបានភ្លើងដោយគូសថ្មព័ត្តដុំទៅវិញទៅមកពាល់បែកផ្កាជាភ្លើង ហើយផ្កាភ្លើងនេះបំរះជាប់ទៅលើដុំចំបើងស្ងួតឬវត្ថុស្ងួតអ្វីមួយដទៃទៀត ។ ជួនកាលភ្លើងបណ្តាលមានឡើងដោយឯង ។ នៅកុងព្រៃ ប្រហែលជាដោយសារបុះខ្ជិចគ្នាឬកំភ្លឺអ្វីដទៃទៀត ។ សត្វពុំធ្លាតកងវៃដើម្បីល្មមយល់បានអំពីការនេះឡើយ ។ ប៉ុន្តែមនុស្សធ្លាតកងវៃជាង ។ គេឃើញនូវសារៈប្រយោជន៍របស់ភ្លើង។ភ្លើងធ្វើឲ្យគេកក់ក្តៅកុងរហូតដូចនឹងបង្កើលសត្រូវរបស់គេគឺសត្វធំៗ ឲ្យចៀសចេញទៅឆ្ងាយ ។ ដូច្នេះនៅពេលដែលភ្លើងចាប់មានឡើង មនុស្សប្រុសស្រីបានវិតវំរក្សាភ្លើងខុតដោយបោះស្វឹកឈើស្ងួតទៅកុងភ្លើង ។ គេពុំចង់ឲ្យរលត់ទៅវិញទេ ។ បន្តិចម្តង ។ គេបានយល់ឃើញថា គេអាចបង្កើតកំទេចផ្កាភ្លើងនឹងភ្លើងដោយខ្លួនគេបានដោយប្រកួតថ្មជាមួយគ្នា ។ នេះគឺជាការរកឃើញមួយយ៉ាងធំសម្រាប់គេ ហើយការរកឃើញនេះប្រគល់ដល់គេនូវអំណាចខ្លះទៅលើសត្វដទៃឯង ។ តាំងអំពីនោះមក មនុស្សក៏បានបុះកុងគន្ធនជាម្ចាស់នៃពិភពលោក។

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរថ្មីឃ្នាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

រថាំបុកអង្រែ

ស្រង់ពីសៀវភៅ រថាំប្រជាប្រិយខ្មែរ

រថាំបុកអង្រែ ជារថាំថ្មីមួយផ្សេងពីរថាំគោះអង្រែ ។ សព្វថ្ងៃ រថាំនេះយើញមាននៅស្រុកភូមិធ្លាយតាំងជាន់ ព្រោះគាត់នៅជារថាំប្រជាប្រិយ ដែលអ្នកស្រុកនិយមលេងនៅពេលបុណ្យចូលឆ្នាំ ដើម្បីលើកដំកើនតិចតួចពីបុណ្យនេះឲ្យកាន់តែទទ្បាកកក្បើង ។ អាស្រ័យដោយការខ្វះខ្លាយពុំសូវមាននៅសល់ច្រើនកន្លែង រថាំនេះក៏ស្ទើរតែគេលែងស្គាល់ឈ្មោះទៅហើយ ។ ប្រសិនជានៅចាំឈ្មោះខ្លះ ។ ក៏គេពុំសូវដែលយើញរូបភាពល្បាស់លាស់នៃរថាំបុកអង្រែនេះដែរ ។

យើងសង្កេតត្រង់ឈ្មោះថា « បុកអង្រែ ។ » អាចហុចន័យមក

ភ្លាមវិញថា ចង្កាកនៃរចាំនេះ ច្បាស់ជាអាស្រ័យជាមួយការបុកអង្រែ ឬ
ក្នងស្នាល់ឬបុកលើឈើកណាត់ណាមួយ ដើម្បីបញ្ចេញសូរជាមិន
ខាន ប៉ុន្តែតាមពិតពុំដូច្នោះទេ ។ អង្រែនេះជាដងឱបឆ្អែមចង្រ្កានដែល
អ្នកពាក់កាន់ទៅដៃដើម្បីបុកទៅទីដី បញ្ចេញសូរតាមចង្កាក់ស្បាច់ពាក់របស់-
ខ្លួន ។ តាមការពិនិត្យសង្កេតឲ្យច្បាស់លាស់ពីបច្ចេកទេសរចាំនេះ
យើញមានរបៀបដូចតទៅ ៖

១ - អំពីប្រដាប់ប្រដា

ក គ្រឿងភ្លេង -

គ្រឿងភ្លេងសំរាប់ប្រកបរចាំនេះ គ្មានអ្វីច្រើនទេ មានតែអង្រែ ៤
គឺអង្រែដែលត្បាចង្រ្កានំ ជាធ្វើពីឫស្សីឬធ្វើពីឈើ ។ បើធ្វើពីឫស្សី
គេយកឫស្សីមានទំហំប៉ុនកំភួនដៃ មានប្រវែងប្រមាណជា ១ ម៉ែត្រកន្លះ
ឬ ២ ម៉ែត្រ ហើយពុះខាងបុង ច្រៀកជាបន្លះ ។ បិតឲ្យស្តើងស្អាត
រួចតត់បន្លះទាំងនោះឲ្យកែបុងកំជាងដូចជាមាត់ដុប ដោយយកបន្លះឫស្សី
ផ្សេងទៀត ដែលចិតស្តើង មកស្បាញក្រងជាបន្លះលំនៅឲ្យទៅជាប់ មាន
សណ្ឋានដូចមាត់ត្រែ ។ តាមបណ្តោយបន្លះឫស្សីដែលស្បាញនោះ
មានចងបន្ថែងត្បាក្នុងចង្រ្កានំប៉ុន ។ ម្រាមដៃដង្ហែគ្នាគ្រប់ ។ ជម្រៀក ។
នៅចុងបំផុតនៃជម្រៀកឫស្សីដែលត្បាចង្រ្កានំ មានចងក្រណាត់ជាតិដែល
ច្រៀកតូច ។ ធ្វើជាបុងរំយោល ។ ឯខាងតាល់ដងឫស្សីនេះ ពុំមានចង

ជាអ្វីខ្លះ ព្រោះសំភាប់ចុកទៅនឹងដីឲ្យឮសូរតាមបទឬតាមចង្វាក់កំ ។ ជួនកាលគេធ្វើដងខ្លះពីឈើមានសណ្ឋានដូចអង្រែ(១) តែបើដងធ្វើជាឈើគំរូវតែយកមន្ទះឫស្សីមកបន្ថែមខាងចុង ធ្វើជារបៀងសំភាប់ព្យួរចង្រ្កែងដូចរោលមកហើយនេះដែរ ។

អស្រ័យដោយលំអងចុងដោយចង្អាមចង្រ្កែងយ៉ាងនេះហើយ បានជាកាលណាគេចុកទៅ អង្រែខោះកំបោរញ្ជាសូរច្រាវ ។ យ៉ាងគឹកគង ។

ទី- ប្រជាប់តុបតែងកាយ-. អ្នកត់ចាំងនេះ មានប្រុសមានស្រី ហើយប្រុសស្រីចាំងនេះ មានសំលៀកបំពាក់ផ្សេងគ្នាដូចតទៅ ៖

ប្រុស ។ ពាក់អាវវៀលកដៃខ្លី មានពណ៌តាមគេចូលចិត្ត ស្លៀកខោខ្លីពាក់កណ្តាលក្បៅ ចុងដើងចំក្រណាត់ជាតិក្រហម ហើយក្រមួចគឺងជាប់ខ្លឹងសាច់ ។ កចងកន្សែងប្រមុច ជំលាក់ចុងសំតាកទៅក្រោយខ្នង ។ សក់កាត់ដើងកញ្ជើ ។

ស្រី ។ ពាក់អាវបំពង់វែងទៅចលើជង្គង់ជំនួនិច ពណ៌លឿងត្រួយចេកឬចុងល័ក្ខ ដៃអាវស្ពួចរៀតគឺងចុងដៃ ។ សំពត់ចងក្បិនកំពណ៌ដែរ តាមការចូលចិត្តពណ៌អ្វីក៏បាន ។ ដៃពាក់កងប្រាក់ចាំងសងខាង ត្រចៀកពាក់ការំពក់ បង់កកន្សែងសូត្រសំយុងចុះមកមុខចាំងសងខាង ។ សក់កាត់ផ្តាច្ចូ ។

---

១ - តាមឯកសារនៅក្នុងក្រុមដំនុំ មានតែឯកសាររបស់លោកកែវ . ពុល នៅភូមិជ្រៃរយោង ឃុំអង្គតាសោម ស្រុកក្រាំងក់ ខេត្តតាកែវ ដែលឲ្យពត៌មានហ្មត់ចត់ជាងនេះ ។

២ - អំពីវិធីលេង

វិធីលេងរបាំនេះ ត្រូវមានមនុស្ស ៤ នាក់ ប្រុស ២ នាក់ ស្រី ២ នាក់ស្មើគ្នា ។ ម្នាក់ ។ សុទ្ធតែកាន់ដង់អង្រែមួយ ។ រៀងខ្លួន ។ ដល់ពេលរាំ គេឈរសង្គមាងមុខគ្នា គឺស្រី ។ ពីរនាក់ឈរម្ខាង ប្រុស ពីរនាក់ឈរម្ខាង ហើយចាប់ផ្តើមច្រៀងម្តងម្នាក់ធ្វើយគ្នាខំនងដូចជាច្រៀងប្រជែង តែមានកំណាយជាមួយផង ។ បើនរណាមួយជាអ្នកច្រៀង អ្នកនោះឈានចេញមកមុខឃ្លាតពីជួរបន្តិច ហើយចាប់ច្រៀងយោលខ្លួនតាមក្បាច់រាំ ដើងគោះចង្វាក់ ដៃម្ខាងកាន់អង្រែបុកបញ្ចេញសូរដៃម្ខាងរាំយ៉ាងខ្មាន់ក្តួន ។ ម្នាក់ទៀតដែលត្រូវច្រៀងតទៅវិញ ក៏ធ្វើដូចគ្នានេះដែរ ។ រីឯអ្នកដែលមិនច្រៀងតាំងប៉ុន្មាន សុទ្ធតែជួយបុកអង្រែឲ្យចង្វាក់ស្មើ ។ គ្នាត្រមតាំងយោលខ្លួនរាំរើតរំពើងជាមួយផង ។

ក្រៅពីអ្នករាំតាំង ៤ នាក់នេះ តែងមានអ្នកឈរមើលហើយជួយខះដៃឲ្យចង្វាក់រាំជាច្រើននាក់ទៀត ។

ដោយសារវិធីរាំនេះ គេលេងតែនៅពេលចូលឆ្នាំ ស្របជាមួយវិធីរាំប្រជប្រឡែង ច្រើនបែបច្រើនយ៉ាងទៀតនោះ អ្នកស្រុកតំយកវិធីរាំបុកអង្រែទៅបញ្ចូលជាមួយល្បែងចោលឈូងឬ ចម្រៀងប្រជែង ធ្វើយឆ្លងគ្នារវាងស្រីប្រុសទៅតំមាន ។ ហេតុនេះបានជាលោក កែវ-កុល នៅអង្គតាសោមបានឲ្យការណ៍ថា ៖ ពីដើមលោកប្រុះគេលេងវិធីរាំនេះនៅ

ភូមិត្រុយឆ្ន ឃុំជម្រះពេន ស្រុកសំរោង ខេត្តតាកែវ គេប្រឿងបទប្រុបកែ ឬបទចោលឈូង ដោយប្រឿងធ្វើយធ្វង់គ្នាអស់មួយវគ្គ ចោះឈូងម្តង ។ ហើយអ្នកស្រុកនោះក៏ហៅចាំនេះថា « កំបុកអង្រែចោលឈូង ។ » ស្ទាប់គ្នាដូច្នេះ ។

ឯគោលបំណងនៃការកំបុកអង្រែនេះ ពុំមានត្រូវការសុំលុយកាក់អ្វីទេ គ្រាន់តែជាការសប្បាយក្នុងពេលបុណ្យភាគច្រើន ប៉ុណ្ណោះ ។

៣ - អំពីឧទ្ទុកប្រឿង

ដោយអ្នកស្រុកនិយម យកចាំនេះទៅការលេងភ្ជាប់ជាមួយល្បែងចោលឈូង ឬបទប្រុបកែ ស៊ីងចាត់ជានដើម ដូចអធិប្បាយមកខាងលើបានជាបទប្រឿងក្នុងពេលកំសុទ្ធស៊ីងជាបទចោលឈូងឬប្រុបកែតាំងអស់ទៅដែរ មានបទតែកែកិអាន ទឹងបទកំសាវ ជាដើម ។ ដូច្នេះសេចក្តីជាចំនុកប្រឿងក៏អាស្រ័យតាមចំនុក ដែលមានស្រាប់ក្នុងល្បែងចោលឈូងនឹងចំរៀងប្រុបកែនោះដែរ មានតែសេចក្តីផ្តើមបទប៉ុណ្ណោះ ដែលរក្សាខុនន្ធវិលក្តណៈ ស្របជាមួយចាំនេះដូចឃ្លាដើមមានសេចក្តីថា៖

ពួកយើងប្រុស ។ (ឬថា ពួកយើងស្រី ។)
កំបុកអង្រែ
តាំងអស់គ្រប់គ្នា
មានប្រុសមានស្រី ។

ដូរវៃរចេត្រ
ខែចូលឆ្នាំថ្មី
លេងតាំងប្រុសស្រី
សប្បាយគ្រប់គ្នា(១) ។

អ្នករច្រៀងតាំងប្រុសតាំងស្រី តែចាប់ផ្តើមច្រៀងសុទ្ធតែយកឃ្លាខាងលើនេះមកធ្វើជាលំនាំដើម រួចបន្តទៅមុខ ទើបបញ្ចេញបញ្ចាសថែមថយតាមសំនួនរៀហារ ដែលគេឮក៏ឱ្យចាន់ស៊ើចសប្បាយក្នុងសិល្បៈនេះឡើង ។

៤- អំពីទ្រនំបត្រូ

តាមទំនៀមរៀងមក រចាំបុកអង្រែ មុនឆ្នំលេង សមាជិកវង់រចាំចាន់គ្នារៀបទ្រនំបត្រូជាមុនសិន ។ ទ្រនំបនោះមានរណ្តាប់ដូចតទៅ :

- ស្វាធម៌ ១ គូ
- អង្ករមួយត្រខ្យាក
- ខៀន ៥ ផ្លូប ៥
- សំពត់សមួយផ្ទត់
- ស្វាជម ៤
- ប្រាក់មួយរៀលនឹងកាស ៤

ប្រជាប់ប្រជារៀបចំនៅផ្ទះអ្នកណាជាមេរចាំ គឺជាត្រូវកំនៃវង់រចាំនេះហើយកូនភំតាំងអស់គ្នា ត្រូវទៅដួបជុំអុជធូបថ្វាយបង្គំគ្រប់ ។ គ្នាមុនឆ្នំចេញទៅលេង ។

១- យកតាមឯកសារនៅក្នុងក្រុមដំនុំរបស់លោក កែវ កុល នៅភូមិត្រែរយោង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។

៩- អំពីដើមកំណើតខ្មែរ


តាមឯកសារតែមួយដែលយើងមាន ពុំបានបញ្ជាក់ថាជាប់ពុកអង្គ្រែមានដើមកំណើតមកពីប្រទេសណា ឬកើតមកពីពួកកុលសម្ព័ន្ធណាទេ ។ ប៉ុន្តែ បើយើងពិនិត្យលើដានតាមការសង្កេតអំពីរបៀបរាំ ប្រដាប់គ្រឿងបន្ទះនិងសំលៀកបំពាក់ដូចមានចែងក៏ប្រមាណបានដែរ យើងឃើញថាជាសិល្បៈចាស់ពួកណាឆ្ងាយគាំងពីការរួមដើមរបស់ខ្មែរ មុនគ្រិស្តសករាជពេលខ្លះ ឯណោះដូចមានប្រដាប់ពុកឲ្យឮស្តាប់ ដូចជាបណ្តារបស់ជាំគ្រដាំដែរ ។ ប៉ុន្តែប្រភពគ្រដាំនៃទេពនាដាវនិងតូចបែបខេះខ្លាំង ឃើញថាតំនងជាទើបតែតាក់តែងខ្លាំង ទៅសម័យកណ្តាលរវាងសតវត្សទី ១៥ ដល់ ១៦ ប៉ុណ្ណោះ ដោយយើងនិយាយទៅតាមសំលៀកបំពាក់ ដូចជាប្រុសស្លៀកខោខ្លី ស្រីពាក់អាវបំពង់រៃ ជាដើម ។

ប៉ុន្តែ ទោះបីជារបាំច្រើនជាង់ថ្នាក់ច្រើនលើក ច្រើនគ្រាយ៉ាងណាក៏ដោយ លក្ខណៈដើមគឺប្រដាប់បន្ទះ ទន្ទឹងស្លាប់ក់ កំទៅតែក្បាច់ក្តីដំណែលសិល្បៈបុកណានៃជនជាតិដើមដែលជាមូលដ្ឋាននៃការរួមដើមរបស់យើង គឺជារបស់ពួកអង្គកស៊ី (Autochtones) ដែលសង់ទៅតូមិភាគអាស៊ីខាងត្បូង ដែលអ្នកប្រាជ្ញសព្វថ្ងៃសន្មតឈ្មោះថា «អាវ្រួមអូស្ត្រូ-អាស៊ី» (Austro-Asiatiques) មានការរួមបុកណារបស់ខ្មែរយើងជាគំរូ ។

បាតុកម្មនៃពុទ្ធសាសនិកនៅមុខព្រះបរមរាជវាំងបតុម្ភ ។

ពត៌មានយ៉ាងអាណោចអាធម៌ ស្តីពីការគេសង្កេបស់ពុទ្ធសាសនិក ប្រធាំងនឹងរដ្ឋការវៀតណាមខាងត្បូង រហូតដល់មានបាត់បង់ជីវិត សុំឲ្យ រដ្ឋការង៉ោ - ឌិន - យៀម បើកឲ្យមានសិទ្ធិខាងសាសនា ធ្វើឲ្យពុទ្ធសាស និកជនចាំងសាកលលោក មានប្រទេសសេរីលង្កា កូមាជាដើម មាន សេចក្តីរំភើបយ៉ាងខ្លាំង ហើយបានចាំងធ្វើបាតុកម្មយ៉ាងធ្ងន់ធ្ងរ នៅក្នុង ប្រទេសវៀនាខ្លួន ដើម្បីសុំឲ្យមគ្គីអន្តរជាតិជួយព្រមានរដ្ឋាភិបាល ង៉ោ - ឌិន - យៀម ឲ្យបញ្ឈប់នូវអំពើដ៏ឃោរឃៅនេះយ៉ាងរួសរាន់ ហើយសូមកុំឲ្យ រំលោភលើធម្មនុញ្ញនៃសហប្រជាជាតិ ស្តីអំពីសិទ្ធិ សេរីភាពខាងជំនឿ ។

រដ្ឋការង៉ោ - ឌិន - យៀម បានរំលោភលើសិទ្ធិនៃពុទ្ធសាសនិកនៅ វៀតណាមខាងត្បូង ធ្វើឲ្យរំជួលដល់សាកលលោក សូម្បីតែអ្នកកាន់ សាសនាដទៃទៀត គេបានចូលកាន់មរណសញ្ញាជាមួយនឹងពុទ្ធសាស - និកដែរ ។ សាកលលោកចាំងអស់ គេព្រួយណាស់តែសង្គ្រាមខាងសា - សនា ដោយមានការរំលោភសិទ្ធិសេរីភាពខាងសាសនា នៅវៀត ណាមខាងត្បូង ទើបសាកលលោកដៃលកាន់សាសនាក្រៅពីពុទ្ធសាសនា



ព្រះភិក្ខុសង្ឃនៅវត្តឧណ្ណាលោម ពង់សង្រ្គែមចូលកាន់មរណទុក្ខ ព័ទ្ធជុំវិញក្តារមឈូសអាទ្រ បទពង់សាសនាពីលើជាឧទ្ទិសនៃសាពុទ្ធសាសនិកជាតិយៀកណាមខាងត្បូងទាំងបព្វជិតទាំងគហស្ថ ថៃលទ្ធលអត្ថកថាអោយអំពើបៃតងនៃការងឺ ទិ:-ហើយ ការពីថៃទី ១១-៦-៦៣ ។

ទេដួយព្រួយ ជួយកើតទុក្ខជួសជនពុទ្ធសាសនិក ដែលត្រូវផ្លូវការរៀក
ណាមមានតួនឆ្លើទុក្ខបុកម្ញាងោះ ។

ចំណែកទេមជនវិញ ៩៩ : ជាអ្នកកាន់ព្រះពុទ្ធសាសនា មិនត្រម
ព្រងើយកន្តើយឡើយ ក្រោកឡើងប្រជាំងជាជាប់ខាត មិនឲ្យនណា
មួយរំលោភលំទ្ធិខាងពុទ្ធសាសនាឡើយ ។ ក្រោយពីព្រះសង្ឃគាំង
ឥរគណៈ : ចានឆ្លើចាតុកម្មយ៉ាងមហោឡារកៅក្នុងវត្តទេណ្ណាលមនីង
បពុមតែកដាកមក ទៅវេលាត្រឹកថ្ងៃទី ១៩ មិថុនា ឆ្នាំ ១៩៦៣ ប្រជា
ពលដ្ឋខ្មែរ ចានមួតាមកមុខព្រះបរមកជាំង ចូលគាន់មណោទុក្ខជាមួយ
ពុទ្ធសាសនិកទៅរៀកណាមខាងតួន ដែលចានស្ទាប់ចាត់បនំជីវិត ក្នុង
ក្តីចតារព្រះពុទ្ធសាសនា តទល់នឹងផ្លូវការធ្វើ - ឌិន - យៀម ។

ចាតុកវាំងអស់ដែលទៅថ្លែងទុក្ខទៅមុខព្រះបរមកជាំង មិនមែន
សុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាសនាចាំងអស់ បើតាមយើងសង្កេតឃើញ
សួមត្រឹតែអ្នកកាន់សាសនាតូច្រើម ក៏តេទៅជួយមួមធ្វើចាតុកម្មប្រជាំងនឹង
ផ្លូវការធ្វើ - ឌិន - យៀម (កាតូលិក) ដែលចំបងសំខ្លៃសើតាតខាង
ព្រះពុទ្ធសាសនា រហូតដល់ទៅសម្លាប់ពុទ្ធសាសនិកេះទៀតផង ។ ចាតុ
ការប្រមាណ ៦ ម៉ូននាក់ កាន់បដាទៅឈរថ្ងៃញត្តិ ថ្វាយសម្តេចព្រះជិត
សន្តិភាពជាតិ សួមអន្តុទ្ធឲ្យព្រះអង្គទ្រង់ជួយធ្វើអន្តរាគមន៍ ចំពោះសោកល
លោកក្នុងរឿងឃាតកម្មនៃពុទ្ធសាសនិក ទៅរៀកណាមខាងតួន ។

ចាតុការ៉ាំង៉ានោះ មានព្រះសង្ឃជាសមណានិសង្សនៃពុទ្ធិកវិទ្យាល័យព្រះសុភម្រិត ទីដ៏មហាវិទ្យាល័យព្រះស៊ីហនុកជ ព្រះសង្ឃយួនផ្នែកមហាយាន ឧបាសក-សិកា ទីដ៏ក្រុមឥស្សាម ចានឈរយ៉ាងស្រង្គឹតស្រង៉ាត់ ។

នៅវេលាម៉ោង ៩ គត់ សម្តេចព្រះប្រមុខរដ្ឋជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលមានសម្តេចក្រុមព្រះស៊ីសុវត្ថិមុនីវេត ប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ទីដ៏ព្រះរាជបរិពារជាច្រើនតជាច្រើន ហែហមព្រះអង្គផង ព្រះអង្គទ្រង់ស្តេចយាងចេញពីព្រះរាជដំណាក់ មកឧបត្ថម្ភក្រុមចាតុការ ក្រោមស្បែរខែដែលគ្រហស្ថយ៉ាងកងរំពង ។

ក្រោយដែលព្រះអង្គថ្វាយបង្គំព្រះសង្ឃ ទីដ៏ឧបត្ថម្ភក៍ក្រោយថ្វាយបង្គំពីភ្លូនចៅពុទ្ធសាសនិកហើយ សម្តេចពុទ្ធសាសនូបត្ថម្ភក៍ ព្រះអង្គទ្រង់ស្តេចយាងទៅប្រថាប់ នៅលើព្រះទីនាំងចន្លុះយ៉ា ទើបសហជាតិន ភ័ក្ត្រសូតជាដំណាងនៃពុទ្ធិកសមាគម ចានថ្លែងថ្វាយខ្លួនវិញក្តី ហើយជាបន្ទាប់មកទើបពុទ្ធសាសនិកជនជាច្រើន ចានអានញត្តិជាបន្តបន្ទាប់គ្នា ។ គួរឲ្យចាប់អារម្មណ៍ចំពោះជនឥស្សាមដែលចានថ្វាយញត្តិ ប្រធានមិនពេញចិត្តចំពោះយ៉ាមកជាតូលិក ង៉ោ-ឌិន-យៀម ដែលរំលោភមកលើពុទ្ធសាសនិករហូតដល់ស្លាប់ចាត់បង់ជីវិត ។ ជាទីបំផុត ក្រុមចាតុការ ចានសុំឲ្យសម្តេចព្រះប្រមុខរដ្ឋ ជួយធ្វើអន្តរាគមន៍ជាមួយនឹងសាកលលោក ចំចាត់ខ្លួអំពើព្រៃផ្សៃ កាប់សម្លាប់ពុទ្ធសាសនិក នៅវៀតណាមខាងត្បូង កុំឲ្យ-



លោកសង្ឃរាជតំយៀកណាម ១ អង្គថ្វែងញត្តិថ្វាយចំពោះសម្តេចព្រះប្រមុខរដ្ឋាភិបាលដោយ ក្នុងឱកាស
ជាតុកម្មនៃពុទ្ធសាសនិកវិស្សប្រជាំងនឹងការដឹះជាន់ព្រះពុទ្ធសាសនានៃរដ្ឋការ ង្គុំ ឆឺង យៀម នៅថ្ងៃ
ទី ១៩ មិថុនា ១៩៦៣ នៅមុខព្រះបរមរាជវាំងបតុម្ម ភ្នំពេញ

មានទៀត ហើយសុំឲ្យត្រមានដោ - ឌិន - យៀម ឲ្យបើកសិទ្ធិសេរីភាព ដល់ពុទ្ធសាសនិក ឲ្យបានចូលាយផង ។

លុះចប់ញត្តិនៃក្រុមឋាតុករហើយ សម្តេចព្រះបិតាសន្តិភាពជាតិ ទ្រង់មានព្រះបន្ទូលទៅកាន់កូនចៅយ៉ាងកងវែង ។

សម្តេចទ្រង់បញ្ជាក់ថា បន្ទាប់ពីព្រះអង្គឋានចូលញត្តិនៃព្រះសង្ឃ តាំងពីតណៈ ហើយ ព្រះអង្គទ្រង់ធ្វើសារលិខិតទៅកាន់មហាអំណាច ជាច្រើន មានអាមេរិកាំង អង់គ្លេស ឋាកាំងជាដើម ឲ្យគេជួយជាសំខឿន ប្រធានាធិបតីដោ - ឌិន - យៀម ឲ្យលះបង់ចោលនូវអំពើព្រៃផ្សៃកាច សម្ងាប់ពួកពុទ្ធសាសនិក ហើយព្រះអង្គនឹងទំនៅទៀតចំពេញតាម ព្រះសមត្ថភាពដើម្បីធ្វើអន្តរាគមន៍ក្នុងរឿងនេះ ។

នៅពេលចប់ព្រះសង្ឃថា គួរជាទីពុកចិត្តនៃក្រុមឋាតុករហើយ ព្រះសង្ឃជាសមណនិស្សិតឋានស្វាធ្យាយធម៌បង្ក្រូល ទទួលសុសល ចំពោះវិញ្ញាណក្ខន្ធ នៃពុទ្ធសាសនិកជាតិរៀកណាមខាងត្បូង ដែលឋាតំ ជីវិតកងកាតេស៊ូដើម្បីការពារព្រះពុទ្ធសាសនា នៅរៀកណាមខាងត្បូង។

ក្រោយការស្វាធ្យាយធម៌បង្ក្រូល សម្តេចសហជីវនៃព្រះប្រមុខរដ្ឋ ទ្រង់ឋានថ្វាយបង្គំព្រះសង្ឃនឹងលាកូនចៅឋាតុកាតាំងអស់យ៉ាងនិវត្តន៍ចូល គាន់ព្រះបរមកជាំងវិញ ។

ចំណែកក្រុមឋាតុកវដ្ឋកព្រះសង្ឃជាតិយួនមហាយាន ឧងពុទ្ធ -

សាសនិកខ្មែរ-យួន ឥស្លាមជាតិប្រុសស្រី ចូលកាន់បដាសរសេរពាក្យ
ស្លោកប្រធាងទីតាំងការរំលោកសិទ្ធិសេរីភាព លើពុទ្ធសាសនិកនៃរដ្ឋកិ-
ច្ចសហគ្រាសនេះ ដើរជាជួរយ៉ាងរៀបរយកាត់មុខវាំង ឆ្ពោះទៅតាមវិថី
ទូកញ៉ាំឈូន មហាវិថីព្រះចាខនកេត្តម ហើយបត់ចូលទៅតាមទូកញ៉ាំ
ពេជ ។ ចាតុតរាំងនោះយកបដាទៅនរចាលទុកនៅមុខស្ថានលោក
ដំណាងនៃសាធារណរដ្ឋវៀតណាមខាងត្បូង ហើយក្រុមចាតុតរបន្ទឹសព្ទ
សញ្ញាថា « ដំយោព្រះពុទ្ធសាសនា » តង់រំពងរហូតដល់ម៉ោង ១៦
ចាតុតរបែកខ្ញែកគ្នាទៅកាន់គេហដ្ឋានរៀងខ្លួន ប្រកបដោយវិន័យយ៉ាង
ស្ងៀមស្ងាត់ ។

សម្តេចព្រះប្រមុខរដ្ឋធម្មនុញ្ញ ព្រះនរោត្តមសីហនុ ប្រកាសដឹងពីការកាន់កាប់ទីដែនដីរបស់ខ្មែរ ដែលយកពីកម្ពុជាដោយសន្ធិសញ្ញាព្រះបរមរាជវាំង ក្នុងឆ្នាំ ១៨៥៣ ដើម្បីប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ ក្នុង ឆ្នាំ ១៩៦២ នៅក្នុងព្រះបរមរាជវាំង។

សារាចរស្តីអំពីការគាំពារ ថែរក្សា ប្រពាណវត្ថុជាតិ

ភ្នំពេញ ថ្ងៃទី ៧ កញ្ញា ឆ្នាំ ១៩៦៣

សារាចរ

រដ្ឋលេខាធិការដ្ឋានក្រសួងអប់រំជាតិ ទទឹងចិត្រសិល្បៈ ដំណាងមកសហជីវនៅហ្វាយខេត្តគ្រប់ខេត្ត កុងត្រាក់ព្រះពន្ធអាណាចក្រ ។

កម្មវត្ថុ – ការបំពារបំពានលើប្រាសាទនិងការបំផ្លិចបំផ្លាញវត្ថុប្រពាណរបស់ជាតិ ។

ខ្ញុំតែងទទួលពត៌មានជាញឹកញាប់ ពីឆ្នាំប្រាសាទទាំងឡាយ នៅតាមខេត្តថា : ថ្វីបើមានសេចក្តីអំពាវនាវដែលក្រសួងខ្ញុំបានធ្វើ មកទល់ទឹងសព្វថ្ងៃនេះយ៉ាងណា ក៏ដោយ តាមរយៈក្តីរាយការណ៍ តាមប្រកាសបិទផ្សាយក្តី តាមសម្លេងវិទ្យុជាតិក្តី ឃើញថា សេចក្តីអំពាវនាវទាំងនេះ ដូចជាពុំបានទទួលលទ្ធផលដ៏ជាក់ស្តែងសោះនៅឡើយ ព្រោះថាការបំពារបំពានទឹងការបំផ្លិចបំផ្លាញប្រាសាទនិងវត្ថុប្រពាណជាតិ ដោយជនជាតិយើងភាគខ្លះ នៅតែមានប្រព្រឹត្តជារឿយៗ ដែលជាហេតុនាំឲ្យមានគ្រោះថ្នាក់មួយយ៉ាងធំដល់អនាគតនៃដំណែលសិល្បៈរបស់បុព្វបុរសជាតិយើង ។ គេតែងសង្កេតឃើញមានជនខ្លះ ជញ្ជូនយកដុំថ្មសិលាប្រពាណទៅប្រើការតាមទំនើងចិត្តខ្លួន គឺយកទៅធ្វើជាថ្មសំលៀងកំបិត តូចៗ យកទៅកាយ

ចំបែកធ្វើជាកំណល់ស្ពានដើរចូលទៅកាន់គេហដ្ឋាន នៅរដូវលិចទឹក ឬធ្វើជាកំណល់សសរផ្ទះក៏សឹងមាន លុបលួចកាប់ព្រៃឈើដែលរាជការរក្សាទុកជាគ្រឿងលំអក្រុងសាខបុកណា ការសង់លំនៅស្ថាន ឬ ជាំដំណាក់ឯបរិវេណក្រុងសាខជាដើមៗលៗអំពើទាំងនេះ ជាហេតុបំផ្លាញគ្រឹះស្ថានបុកណារបស់ជាតិបន្តិចម្តងៗ លុះត្រាវិនាសសូន្យ តែម្តង ទៅអនាគតដ៏ខ្លីនេះជាមិនខាន ។

ក្រសួងអប់រំជាតិ ទំនើបវិចិត្រសិល្បៈ ដែលមានការៈកិច្ចខ្វល់ខ្វាយត្រួយាំងធ្ងន់លើក្រុងសាខទំនើបវត្តបុកណាទាំងឡាយ ក្នុងព្រះពុទ្ធសាសនាចក្រត្រៀមអំពីវិធានការណ៍ដែលបានចាត់រួចមកហើយ កំពុងពិនិត្យទំនើងធ្វើសេចក្តីព្រាងច្បាប់ថ្មីមួយ ដើម្បីកំណត់ព្រំប្រទល់ក្រុងសាខបុកណាឲ្យបានជាក់លាក់ ទំនើងត្រូវជាបទបញ្ជាផ្សេងៗទៀត សម្រាប់ទប់ទល់ទំនើងអំពើឈ្លានពានត្រូវបែបយ៉ាង ដូចបានពណ៌នាខាងលើស្រាប់ ។

តែដោយហេតុថា ច្បាប់ថ្មីនេះ ពុំទាន់បានដាក់ឲ្យអនុវត្តនៅឡើយក្នុងរយៈពេលជាបណ្តោះអាសន្ននេះ ខ្ញុំសូមសហជីវិន មេត្តាជួយហាមប្រាមយ៉ាងណាជាប់ប្រជាពលរដ្ឋយើង កុំឲ្យមានការប្រព្រឹត្តល្មើសបែបនេះទៀត ។ ម៉្យាងវិញទៀត បើត្រូវការស្ថាបនាគេហដ្ឋាននៅទីណាមួយដែលមានក្រុងសាខបុកណានៅជិត សូមឲ្យសង់យ៉ាងតិចចម្ងាយ ១០០ម៉ែត្រពីក្រុងសាខបុកណានោះជាកំហិត គឺគិតចាប់តាំងពីកំពែងខាងក្រៅទៅ ទោះ

ជាគ្រឹះស្ថានដោះសម្រាប់សាធារណៈប្រយោជន៍ក្តី សម្រាប់ប្រយោជន៍ឯកជនក្តី ។

រីឯនការនេះចឿសក់ធំដើម្បីកុំឲ្យមានការលំបាកគ្រប់យ៉ាងនៅថ្ងៃក្រោយ ក្នុងកិច្ចការការនឹងជួសជុលក្រុងសាខជាតិ ។

ខ្ញុំសង្ឃឹមថា សហជីវិនខ្ញុំជាជួយធ្វើសហប្រតិបត្តិការក្នុងរឿងនេះ ក្រែងតែបានសម្រេចលទ្ធផលល្អជាក់ពុំខាន ។

ហត្ថលេខាៈភ្លូ-ស៊ី-គុយ

ភក្តីជសុទ្ធិយា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៥ លេខ ១១ ខែ វិច្ឆិកា

ព. ស. ២៥០៥ គ. ស. ១៩៦៣

- ក្នុង ១៣៦ -



ភ្នំពេញសន្ទេស

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
បេញ្ញារាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

ផ្នែកសាសនា — ទំព័រ

- តួរអនុវត្តតួវការយ៉ាំចីវរនៃសាមណេរឬ? (វិចារណកថា) ព្រះមុនីកោសល សូ-ហាយ អធិបតីរង នៃក្រុមដំនុំព្រះត្រៃបិដក តែងរៀបរៀង ១០៩៨
- អធិបតេយ្យកថា ការសំដែងអំពីអធិបតេយ្យ ៣ យ៉ាង (តបប់) ព្រះសាសនមុនី កឹម-តូ ក្រុមដំនុំព្រះត្រៃបិដក តែងរៀបរៀង ១១០៤
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ូ តែងរៀបរៀង (ត). . . ១១២០
- ព្រះពុទ្ធសាសនានៅប្រទេសឥណ្ឌា តែងរៀបរៀង ដោយ ឧ-គាម . . . ១១២៩
- ព្រះមហោសថជាតក (តបប់) ១១៣៦

ផ្នែកអក្សរសាស្ត្រ

- កន្ទុយខ្វៀនឆ្នា និងអាចរណៈត្រង់វិញ្ញាបនៈ ឬទេ? (វិចារណកថា) ដោយ លោក ផេង-ដ្រើវ ១១៤៥
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត) . . . ១១៤៩
- រឿងសាមក្កុក អ្នកឧកញ៉ាវិបុលរាជសេនា គួ-កន ប្រែរៀបរៀង (ត) . . . ១១៥១
- ល្បើកហ្គាហ្វុងតែន លោកផេង-ដ្រើវ ប្រែពីភាសាចាវ៉ាំង (ត) ១១៦២
- រឿងព្រេង ជ័ន (ត) (ការ្យាថាតាគូទូនិងពំពួលបក្សា) លោក ភ័យ-ប៊ុក ប្រែពីភាសាចាវ៉ាំង ១១៦៨
- សំបុត្រ ទី ៣ របស់លោកនេរុ លោក ឈន-អៀម ប្រែពីភាសាអង់គ្លេស . . ១១៧៣
- ទំនៀមទម្លាប់ខ្មែរ ប្រកាសប្រឡងទំនៀមទម្លាប់ខ្មែរ ១១៨១

ផ្នែកកំណត់ទីធ្លប្រវត្តិការណ៍

- ពិធីបុណ្យចំណែនព្រះជន្មវស្សាសម្តេចព្រះសុធម្មាធិបតី សង្ឃនាយក គណៈធម្មយុត្តិកនិកាយ ព្រះនាមជាន្ញាណោ ភុល-ទេស ១១៨៦

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ
ឲ្យដុំបាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

វិចារណាកថា

តួរអនុវត្តន៍តួរការឃ្លុំបីពារនៃសាមណេរឬ?

ព្រះមុនីកោសល ស្វរ-ហាយ អធិបតីរង នៃក្រុមជំនុំព្រះត្រៃបិដក

តែងរៀបរៀង

ពាក្យថា « ឃ្លុំ » នេះជាវប្បធម៌របស់ខ្មែរ បានដល់ការបិទបាំងកាយដោយការគ្រងបុព័ន្ធកាយ តាំងមូលដោយចីពរ រៀវលែងតែក្បាល តាមវិនយប្បញ្ញត្តិ ដែលមានមកក្នុងសេក្ខិយវត្ត ត្រង់សារុប្បសិក្ខាបទទី៣ បាលីថា « សុសប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា » ប្រែថា បព្វជិត គប្បីសិក្សាថាអាត្មាអញបិទបាំងកាយដោយល្អនឹងទៅក្នុងចន្លោះផ្ទះ ។ បាលីថា សុបដិច្ឆន្នៈ ប្រែថា បិទបាំងកាយដោយល្អ ប៉ុន្តែអដ្ឋកថាចេញសេចក្តីប្រាប់ថា បព្វជិតកាលបើត្រូវការចេញទៅកាន់ទីខាងក្រៅវត្ត ត្រូវយកចីពរតម្រឹមជាយតាំងពីឲ្យស្មើគ្នា ហើយមូរចីពរបិទបាំងកាយដោយអនុវាត ដោយតាក់កណ្តាប់បិទបាំងជាបដល់កំភួនដៃ ហើយសឹមដើរចេញទៅ ក្នុងទី

ចន្លោះផ្នែ ។ ប្រមូលសេចក្តីខាងលើនេះ តាក្យខ្មែរបស់យើងហៅថាឃ្លុំ ។ មួយទៀត មានអធិប្បាយថា ការឃ្លុំនេះ បព្វជិតត្រូវចាប់ចីពរតម្រឹមជាយទាំងពីរ គឺ ដៃឆ្វេងកាន់ជាយទាំងពីរឲ្យជាប់ ដៃស្តាំមួរចីពរក្តោបកាយឲ្យខៅចូរ ល្មមកុំឲ្យតឹងពេក រួចត្រង់តំមួរចីពរដាក់លើ ស្មាឆ្វេងឲ្យចំទំងឯក រហូតដល់កកួនដៃ ប៉ុន្តែកុំឲ្យចំទំងទាំងក្បាលរួចដៃស្តាំទាញត្រសាច់ចីពរចុះក្រោម ឲ្យខៅលើស្បែរ វាង ៤ ង្គាប់ លុះដើរចេញទៅ ដៃឆ្វេងត្រូវកាន់រមួរចីពរឲ្យជាប់ ហើយមិនត្រូវស៊ើយចីពរឬលាត់កងើ្ញឲ្យឃើញជង្គង់ឬភ្លោះខោះឡើយ ចើកុំស៊ើយចីពរកំពុងដើរ ត្រូវអាបត្តិទុក្កដ បើសាមណេរ គួរដល់ខណ្ឌកម្ម ។

សេក្ខិយវត្តត្រង់សិក្ខាបទទី ៣ នេះ ជាសិក្ខាបទសម្រាប់ប្រើប្រាស់ទាំងភិក្ខុទាំងសាមណេរ ។ សិក្ខាបទដែលសាធារណៈដល់សាមណេរនោះ មិនមែនតែសិក្ខាបទមួយត្រង់ការឃុំចីពរនេះទេ គឺសិក្ខាបទក្នុងសេក្ខិយវត្ត ៧៥ ត្រូវភិក្ខុនឹងសាមណេរប្រតិបត្តិទាំងអស់គ្នា មិនមែនសេក្ខិយវត្ត ៧៥ របស់ភិក្ខុ ដោយឡែក របស់សាមណេរ ដោយឡែកនោះឡើយ ។

សុប្បដិបត្តិសិក្ខាបទទី ៣ ជាតុប្បញ្ញត្តិ ចំពោះភិក្ខុនឹងសាមណេរ ដោយមានសេចក្តីបង្គាប់បញ្ជាទៅលើភិក្ខុសាមណេរ ត្រូវឲ្យតែឃុំចីពរទាំងអស់គ្នា មិនចំពោះតែភិក្ខុទេ ។ សិក្ខាបទទាំងអស់ក្នុងព្រះ

វិន័យពុកថាជា ព្រះពុទ្ធក្រែម តើជាច្បាប់សម្រាប់កិច្ចការដែលត្រូវប្រ-
ព្រឹត្តតាម ក្នុងព្រះវិន័យរបស់ព្រះសម្មាសម្ពុទ្ធដោយពិត ។

ប្រទេសកម្ពុជាយើង មានអង្គការអាជ្ញារបៀបរៀបចំព្រះពុទ្ធសាន
ដោយមាន ក្រសួងព្រះសង្ឃនាយក ទំនង ក្រសួងធម្មការ
ជាប្រធាន ក្រោមព្រះរាជូបត្ថម្ភនៃព្រះមហាក្សត្រ ។ កាលពីឆ្នាំ
១៩៤៤ សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ កាលនៅជា
ព្រះមហាក្សត្រសោយរាជ្យ បានទ្រង់ចាត់ការ ឲ្យប្រជុំតាំងគណៈ
កម្មការមួយក្រុម យកគម្ពីព្រះវិន័យមកប្រៃ រួចដែកដេញដោល វែក
ញែកប្តូរយោបល់ អំពីការយ៉ុំត្រង់របស់កិក្ខុសាមណេរ លុះមកដល់ចំណុត
គណៈកម្មការ បានសម្រេចចិត្តជាឯកច្ឆន្ទថា កិក្ខុទំនឹងសាមណេរ ត្រូវយ៉ុំចីវរ
ដូចគ្នា ។ ព្រះករុណាជាម្ចាស់ជីវិត ទ្រង់បានចេញ ព្រះរាជ
ក្រមមួយ លេខ ១៦៩ ចុះថ្ងៃទី ១៣ ខែកញ្ញាឆ្នាំ ១៩៤៤ ជាព្រះរាជ
ក្រមរៀបចំព្រះពុទ្ធសាសនា ឲ្យសាមណេរយ៉ុំចីវរជាដើម ឲ្យមាន-
របៀបរៀបរយ មានតុល្យភាពប្រសើរវិសេសឡើង ។

អំពីការយ៉ុំចីវរនៃសាមណេរនេះ គួរតែអនុវត្តជាប្រចាំផងណាស់
ដោយឃើញថាសេក្ខិយវត្តត្រង់សិក្ខាបទទី ៣ ពុកថាជា ព្រះពុទ្ធក្រែម
ដែលត្រូវតែអនុវត្តនោះ ក៏ច្បាស់លាស់ណាស់ហើយ គួរជាទីគោរពដ៏ខ្ពង់
ខ្ពស់របស់ពុទ្ធបរិស័ទដោយពិត ចាំងព្រះពន្លាក្រមរបស់ព្រះករុណាជា-

ម្ចាស់ដីវត្តក៏ជាន់ចេញច្បាស់ហើយ ដែលត្រូវតែប្រតិបត្តិតាម ដោយគោរពព្រះសង្ឃដីការបស់សម្តេចព្រះសង្ឃនាយក ក៏ជាន់ចេញផ្សាយ ព្រមានចំពោះព្រះសង្ឃគ្រប់វត្ត អំពីការយុំចីពរនៃសាមណេរនេះ ក៏ច្រើនដងហើយ ប៉ុន្តែ នៅតែមានបព្វជិតនឹងគ្រហស្ថខ្លះ មិនព្រមចូលនូវការអនុវត្តន៍ប្រតិបត្តិតាមព្រះពជក្រម នឹងព្រះសង្ឃដីកានោះសោះ ចេះតែនៅមានការភៀចក្រាញ ពីនឹងផ្អែកទៅលើសេចក្តីយល់ខុស រហូតដល់មកសព្វថ្ងៃនេះ ។

បព្វជិតនឹងគ្រហស្ថខ្លះ ដំទុំគ្នាបញ្ឆោតញោចយល់ថា ទំនៀមទម្លាប់របស់យើងពីដើម មានតែកិក្ខុទេដែលយុំចីពរ ឯសាមណេរសុទ្ធតែត្រូវចីពរទាំងអស់ ឥឡូវនេះ ស្រាប់តែមានព្រះពជក្រម ឲ្យសាមណេរយុំចីពរដូចកិក្ខុដែរ បើដូច្នោះ មានតែនាំឲ្យច្របូកច្របល់គ្នាអស់ហើយ មិនដឹងលោកណាជាកិក្ខុ លោកណាជាសាមណេរទេ ល្អើយវត្តយើង កុំឲ្យសាមណេរយុំចីពរធ្វើអ្វី យើងចេះសម្លុំស្ងៀម ។ នៅតាមបុរាណរបស់យើងទៅចុះ ។

ការពោលពាក្យដោយភៀចក្រាញ ជ្រុងធ្វេងទើងថា បើឲ្យសាមណេរយុំចីពរ ខ្លាចច្របូកច្របល់កិក្ខុនេះ មិនមែនជាបញ្ហាជ្រាលជ្រៅតាមគតិបណ្ឌិតទេ គឺជាបញ្ហាកក់កំតែល ។ ត្រង់ពាក្យថា ខ្លាចច្របូកច្របល់គ្នាព្រោះយុំចីពរដូចគ្នានេះ មិនគួរឲ្យតើតមានសោះ ។ រឿងនេះគួរតែចារណាឲ្យរឿយៗចុះ ដូចសេចក្តីតទៅខាងមុខ ។

ឧទាហរណ៍ ដូចយ៉ាងកូនសិស្សក្នុងសាលាមួយ ។ មានចំនួនសិស្សច្រើនយេនាក់ ផ្នែកកូនសិស្សប្រុស ស្មើគ្នាពាក់ដូច ។ គ្នា ជាឯកសណ្ឋាន ផ្នែកកូនសិស្សស្រី ក៏ស្មើគ្នាពាក់ជាឯកសណ្ឋានដែរ ប៉ុន្តែគ្រូបង្រៀន ម្តេចក៏មិនប្រឡំកូនសិស្សរបស់គេ ?

ភាហានក្នុងបន្ទាយមួយ ។ មានចំនួនច្រើនយេនាក់ដែរ ភាហានទាំងនោះស្មើគ្នាពាក់ដូច ។ គ្នា ជាឯកសណ្ឋានទាំងមួក ស្បែកជើង ក៏ដូចគ្នាដែរ ម្តេចក៏មេភាហាន អ្នកត្រួតត្រា មិនខ្វាចប្រឡំគ្នា ?

កូនចៅស្រីប្រុសរបស់អ្នកស្រុក កាលដែលទៅប្រជុំគ្នាក្នុងពិណាមួយដែលមានបុណ្យម្តង ។ មានទុកសក់ដូចគ្នា មានសម្លៀកបំពាក់ដូចគ្នា មានតណិដូច ។ គ្នាជាច្រើនទាក់ណាស់ដែរ ប៉ុន្តែម្ចាយឪពុករបស់ក្មេងទាំងនោះ ម្តេចក៏មិនដែលឮគួញផ្អែរអំពីការប្រឡំកូនគ្នា ?

ប្រៀបមកសេចក្តី អំពីការយ៉ុំចីពរនៃសាមណេរ ជាការចាំបាច់ណាស់គឺត្រូវតែអនុវត្តតាមតាំងជាប្រក្រតី ។ បព្វជិតនីមួយគ្រហស្ថខ្លះដែលតុំព្រមយល់ស្រប តាមពុទ្ធប្រមនីមួយព្រះពុទ្ធប្រមនោះ ដោយហេតុតែខ្លះវិចារណញ្ញាណ នីមួយខ្លះការសិក្សាអប់រំ ក្នុងសំណាក់លោកអ្នកចេះដឹង ។ ណាស់តេក រកឮប់មកអាងជាកស្តុតាងមិនកើត យកសព្វបើតាក្យថាបើឲ្យសាមណេរយ៉ុំ ខ្វាចប្រឡំគ្នានឹងតិកុ ឃ្លានជាវត្តខ្លះ មិនត្រមឲ្យសាមណេរយ៉ុំចីពរសោះ ។

សូមពុទ្ធបរិស័ទចាំដ៏បព្វជិតចាំដ៏គ្រហស្ថ ពិចារណាតាមអត្ថបទនេះឲ្យរឿយៗ ដើម្បីជាជំនួយនៃប្រាជ្ញាស្មារតី ក្នុងការដោះស្រាយបញ្ហាដែលភ្ជាប់ឃល់ខុស ប្រកាន់ខុស ក្នុងការប្រព្រឹត្តិធ្វើតាមព្រះធម្មវិន័យរបស់យើង ហើយត្រូវអនុវត្តចំពោះបច្ចាប់សេក្ខិយវត្តទី ៣ នោះជាដរាបទៅ!

ត្រង់ការខ្ចាចប្រឡំកិក្ខុសាមណេរ ព្រោះឃ្លាំពីពាក្យដូចគ្នានោះ គួរលើកយកមកពិចារណាឲ្យរឿយ ៗ កុំខាន បើឃើញពិតហើយ គួរលើកឡាត់ចង់សេធចោលនូវការប្រកាន់ក្រៅបច្ចាប់នោះចេញទៅ ព្រោះប្រយោគដែលភ្ជាប់ប្រកាន់ខុសនេះ ពុំគាចដោះពុទ្ធឲ្យរួចទេ គួរតែជូរផ្ចាស់សេចក្តីប្រកាន់នេះចោលចេញ!

រៀបរៀងដោយព្រះមុនីកោសល សូរ-ហាយ

អធិបតីវត្តនៃក្រុមជំនុំព្រះត្រៃបិដក

អធិបតេយ្យកថា

ការសំដែងអំពីអធិបតេយ្យ ៣ យ៉ាង

ព្រះសាសនមុនី តាម.ក្ស រៀបរៀង

អធិបតេយ្យ គឺអ្វី?

ភាពនៃបុគ្គលជាអធិបតី ឬភាពនៃបុគ្គលយកអ្វីមួយជាអធិបតីឬជាធំ ហៅថាអធិបតេយ្យ ។ បានសេចក្តីថា បើបុគ្គលប្រព្រឹត្តធ្វើកិច្ចការណាមួយ ទោះខាងតតិជមិ ដូចការបំពេញកុសលផ្សេងៗ មានការឲ្យទាន នឹងការក្សាសីលជាដើមក្តី ទោះខាងតតិលោក មានការសិក្សាចំណេះវិជ្ជាផ្សេង ។ នឹងការប្រកបមុខរបរចិញ្ចឹមជីវិតជាដើមក្តី ហើយយកខ្លួនជាអធិបតីឬជាធំក្នុងមុខការដែលខ្លួនប្រព្រឹត្តធ្វើនោះ ។ ហៅថា អត្តាធិបតេយ្យ ។ បើយកលោកជាធំ ហៅថា លោកាធិបតេយ្យ បើយកធម៌ជាធំ ហៅថា ធម្មាធិបតេយ្យ ។ អធិបតេយ្យ មានន័យច្រើនផ្សេងពីនេះទៀតក៏មាន ដូចជា រាជាធិបតេយ្យ យកព្រះរាជាជាអធិបតីឬជាប្រមុខ បជាធិបតេយ្យ យកប្រជារាស្ត្រជាអធិបតី យ៉ាងនេះជាដើម ប៉ុន្តែក្នុងទីនេះ ខ្ញុំបានដកស្រង់តែអធិបតេយ្យ ៣ យ៉ាងពីក្នុងគម្ពីរអង្គុត្តរនិកាយ តិកនិបាត ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងចំពោះតិត្ថិយ៍ឲ្យ ដូចមានសេចក្តីតទៅនេះ –

អធិបតេយ្យ ៣ យ៉ាងនោះគឺ

๑ – អត្តាធិបតេយ្យ ភាពនៃបុគ្គលយកខ្លួនជាធំ ។

๒ – លោកាធិបតេយ្យ ភាពនៃបុគ្គលយកលោកជាធំ។

๓ – ធម្មាធិបតេយ្យ ភាពនៃបុគ្គលយកធម៌ជាធំ ។

អធិបតេយ្យទាំង ๓ យ៉ាងនេះ ជាធម៌មានប្រយោជន៍ដ៏សំខាន់ដល់ពុទ្ធបរិស័ទទាំងឡាយ ដែលជាអ្នកប្រារព្ធធ្វើកិច្ចការអ្វីមួយខាងផ្លូវលោក ឬខាងផ្លូវធម៌ ។ ធម៌នេះ ពិតមែនតែព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងចំពោះបព្វជិតអ្នកបួសក្នុងព្រះពុទ្ធសាសនា ប៉ុន្តែបុគ្គលជាគ្រហស្ថ អ្នកនៅគ្រប់គ្រងផ្ទះសម្បែង ក៏គួរផ្ទេរសេចក្តីនោះ មកជាវត្ត សម្រាប់ប្រព្រឹត្តប្រតិបត្តិជាប្រយោជន៍ចំពោះខ្លួនដែរ ដូចសេចក្តីអធិប្បាយដែលខ្ញុំកំពុងលាបាំងតទៅនេះ –

អធិបតេយ្យខាងគតិធម៌

អត្តាធិបតេយ្យ

ដូចម្តេចហៅថា អត្តាធិបតេយ្យ ? ភាពនៃបុគ្គលយកខ្លួនជាធំ ពាក្យថាខ្លួនក្នុងទីនេះ បានដល់អត្តភាពគឺរូបកាយទាំងមូល ព្រមទាំងចិត្តរួមបញ្ចូលផង ទើបហៅថា អត្តាធិបតេយ្យ ។ តិក្ខុត្តំ សាសនានេះ ទោះទៅនៅក្នុងព្រៃក្តី នៅឈើក្តី នៅក្នុងអគារដ៏ស្ងាត់មានតូប កុដិ សាលា វិហារ ជាដើមក្តី គួរពិចារណាឲ្យឃើញច្បាស់យ៉ាងនេះថា អាត្មាអញ កាលដែលចេញចាកផ្ទះមកបួសនេះ មិនមែន-

ប្លួស ព្រោះហេតុចង់បានលាភសក្ការៈប្លូចាវ៉ា គឺត្រឿងស្បៀកដណ្តប់ដែលតាយក-តាយិកាឲ្យដោយសទ្ធាទេ មិនមែនប្លួសព្រោះហេតុតែចង់បានបិណ្ឌបាតគឺអាហារគោជនផ្សេងៗដែលតាយក-តាយិកាឲ្យដោយសទ្ធាទេ មិនមែនប្លួសព្រោះហេតុចង់បានសេនាសនៈ គឺទីដេកនិងទីអង្គុយ មានកុដិ សាលា វិហារ ជាដើម ដែលតាយក-តាយិកា ធ្វើឲ្យដោយសទ្ធាទេ មិនមែនប្លួសព្រោះហេតុចង់បានសម្បត្តិ កុងកតភូចនិងកតជំ គឺសម្បត្តិមនុស្សប្លុសសម្បត្តិទេវតា កុងកតណាមួយទេ មិនមែនប្លួសព្រោះហេតុតែចង់បានឋានៈ គឺយសស័ក្តិជាឧនៈជានោះទេ ។ អាត្មាអញដែលចេញចាកផ្ទះ មកប្លួសកុងព្រះពុទ្ធសាសនាដោយសទ្ធានេះ ព្រោះតែឃើញសេចក្តីទុក្ខច្រើនប្រការណាស់ គឺ ជាតិទុក្ខ ទុក្ខព្រោះមានជាតិ គឺការកើតឡើងនៃខន្ធ ៥ ជរាទុក្ខ ទុក្ខព្រោះមានជរា គឺការចាស់គ្រាំគ្រាទ្រុឌទ្រោមនៃខន្ធ ៥ មរណទុក្ខ ទុក្ខព្រោះការបែកធ្លាយចាត់ចង់ផៅនៃខន្ធ ៥ សោកទុក្ខ ទុក្ខព្រោះសេចក្តីសោកស្តាយ សង្រេងសង្រៃ ប្លុសេចក្តីក្រៀមចិត្ត ដែលប្រកបដោយសេចក្តីវិនាសណាមួយ មានសេចក្តីវិនាសព្រាត់ប្រាសចាកទ្រព្យ ឬ ញាតិជាទីស្រឡាញ់ជាដើម ហ៊ានទៅទុក្ខ ទុក្ខព្រោះការយំទួញ រៀបរាប់ប្លូរប្លែជាពីនេះពីនោះ ដែលប្រកបដោយសេចក្តីវិនាសណាមួយ មានសេចក្តីវិនាសព្រាត់ប្រាសចាកទ្រព្យឬញាតិជាទីស្រឡាញ់ជាដើម ទុក្ខទុក្ខ ទុក្ខព្រោះសេចក្តីលំបាកប្រព្រឹត្តទៅកុងកាយ

ខ្ញុំឯចិត្ត ដោយហេតុបានខ្លួលខ្លួវអារម្មណ៍ណាមួយខ្ញុំឯជាទីត្រេកអរ
ដែលកើតអំពីកាយសម្ផស្សនោះ ។ ទោមនស្សទុក្ខ ទុក្ខព្រោះសេចក្តី
អាក់អន់ដែលកើតកន្លឯចិត្ត ដោយហេតុបានខ្លួលខ្លួវអារម្មណ៍ណាមួយ
មិនជាទីត្រេកអរដែលកើតអំពីចិត្តសម្ផស្សនោះ ។ ឧបាយាសទុក្ខ ទុក្ខ
ព្រោះសេចក្តីចង្អៀតចង្អល់ណែនក្នុងចិត្ត ឬសេចក្តីលំបាកតានតឹងក្នុងចិត្ត
ដោយហេតុដែលប្រកបដោយសេចក្តីវិនាសណាមួយ មានសេចក្តីវិនាស
ត្រាត់ប្រាសញាតិជាដើម ឬប្រកបដោយហេតុនៃសេចក្តីទុក្ខណាមួយ
មានការសម្លាប់ឯការចាប់ចងឃុំខាំឯជាដើម ដែលកើតឡើងប៉ះពាល់
ត្រូវសន្តតិ អប្បិយេហិ សម្បយោគទុក្ខ ទុក្ខព្រោះការជួបប្រសប់ជា
មួយនឹងសត្វ នឹងសង្ខារគាំងឡាយ ដែលមិនជាទីស្រឡាញ់ពេញចិត្ត
បិយេហិ វិប្បយោគទុក្ខ ទុក្ខព្រោះការត្រាត់ប្រាសចាកសត្វនឹងសង្ខារ
គាំងឡាយដែលជាទីស្រឡាញ់ពេញចិត្ត យម្បិច្ឆំ នលភតិ តម្បិទុក្ខ
ទុក្ខព្រោះប្រាថ្នាខ្លួវហេតុណាឬវេរសំណាមួយ ហើយមិនបានដូចសេចក្តី
ប្រាថ្នាសង្ខិត្តេន បញ្ចាបាទានក្ខន្ធទុក្ខ ទុក្ខគាំងអស់ បើចំប្រជុំឲ្យខ្លីតិចចុះមក
នៅត្រង់ឧបាទានក្ខន្ធគាំង ៥ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ
ហ្នឹងឯង ។ បើឧបាទានក្ខន្ធគាំង ៥ ផុតរលត់អស់ទៅត្រឹមណា សេចក្តី
ទុក្ខគាំងឡាយ មានជាតិទុក្ខជាដើម ក៏ផុតរលត់អស់ទៅត្រឹមនោះដែរ
ព្រោះហេតុនោះ តើអាត្មាអញនឹងប្រតិបត្តិដោយឧបាយយ៉ាងណា ដើម្បី

ខ្លួនឯងឲ្យរួចផុតពីគន្លងនៃទុក្ខទាំងអស់នេះ ឲ្យប្រាកដជាបាន ។

មួយយ៉ាងទៀត ខ្លួនអាត្មាអញ បានលះបង់នូវកាមទាំងពីរយ៉ាងគឺ វត្ថុកាម នឹងកិលេសកាម បែបណា ដែលមាន គឺកោតទ្រព្យ ទោះជីតិច-ច្រើន ទាំងមានវិញ្ញាណ នឹងឥតវិញ្ញាណ ព្រមទាំងពួកញាតិ ជ្រះស្រឡះអស់ហើយ ទើបចេញចាកផ្ទះ មកបួសក្នុងព្រះពុទ្ធសាសនានេះ កាលបើបានបួសយ៉ាងនេះហើយ មិនគួរបើកាត្មាអញ ជាមនុស្សវង្វេងស្វែងរកគ្រឿងកាមបែបនោះ ដូចកាលដែលខ្លួនទៅជាគ្រហស្ថនោះវិញសោះ ឬអាត្មាអញ មិនគួរបើប្រព្រឹត្តធ្វើនូវអំពើលាមក អាក្រក់ណាមួយ លើសពីការស្វែងរកកាមទាំងនោះទៅទៀតសោះ ។ កិក្ខុនោះ លុះពិចារណាយ៉ាងដូច្នេះហើយ ក៏តាំងចិត្តថា អាត្មាអញនឹងប្រារព្ធសេចក្តីព្យាយាមដ៏ម៉ឺងម៉ាត់មិនបន្ធូរមិនបន្ធយ ក្នុងការសិក្សានឹងសេចក្តីប្រតិបត្តិរបស់ខ្លួន ឆ្ពោះទៅរកការចេះដឹង នឹងមគ្គផលនិព្វាន ប្រឹងស្មារតីយ៉ាងរឹងប៉ឹង មិនឲ្យវង្វេងភ្លាត់ ធ្វើនាមកាយនឹងការដកាយឲ្យស្ងប់រម្ងាប់ មិនឲ្យរសាប់រសល់ ធ្វើចិត្តឲ្យតាំងមៅម៉ាំក្នុងកុសលធម៌ ឲ្យជាចិត្តមានអារម្មណ៍តែមួយ ។ កិក្ខុនោះ កាលបើបានធ្វើខ្លួនឯងឲ្យជាអធិចតេយ្យ (យកខ្លួនជាធំ) យ៉ាងនេះហើយ ក៏ព្យាយាមប្រុងប្រយ័ត្ន មិនឲ្យអកុសលធម៌ណាដែលមិនទាន់កើត មិនឲ្យកើតឡើងបាន អកុសលធម៌ណាដែលកើតឡើងហើយ ក៏ព្យាយាមពង្រេចពង្រឹល មិនឲ្យកើតតទៅទៀត កុសលណាដែលមិន-

ខាន់កើត ត្រូវធ្វើឲ្យកើតឡើង កុសលធម៌ណាដែលបានកើតឡើងហើយ ត្រូវធ្វើកុសលធម៌នោះ ឲ្យរឹងរឹតតែកើតចំរើនឡើងតទៅទៀត រក្សាខ្លួនឲ្យបានបរិសុទ្ធស្អាត នេះឯងហៅថា អត្តាធិបតេយ្យ ។

លោកាធិបតេយ្យ

ដូចម្តេចហៅថា លោកាធិបតេយ្យ ? ភាពនៃបុគ្គលយកលោកជាធំ ពាក្យថា លោក ក្នុងទីនេះ បានដល់មនុស្សពួកខាងក្នុងខាងចាស់ ដកបដល់ទេវតា មារ ព្រហ្ម ជាទីបំផុត ទើបហៅថា លោកាធិបតេយ្យ ។ តថាក្នុងសាសនានេះ ពោះតទៅក្នុងព្រៃក្តី តទៅទៀតល់នៃឈើក្តី តទៅកន្លែងអគារដ៏ស្ងាត់មានភូមិ កុដិ សាលា វិហារ ជាដើមក្តី គួរពិចារណាឲ្យឃើញច្បាស់យ៉ាងនេះថា អាត្មាអញ កាលដែលចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនានេះ មិនមែនបួសព្រោះហេតុតែចង់បានលាភសក្ការៈ ឬ ច័រវ៉ែ តឹត្រឹងស្មៀកដណ្តប់ដែលគាយកគាយិកាឲ្យដោយសទ្ធាទេ មិនមែនបួស ព្រោះហេតុតែចង់បានចំណូចបាតគឺអាហារគោជនផ្សេង ។ ដែលគាយក-គាយិកាឲ្យដោយសទ្ធាទេ មិនមែនបួសព្រោះហេតុតែចង់បានសេនាសន គឺទីដេក ឥដ្ឋទីអង្គុយ មានកុដិ សាលា វិហារ ជាដើម ដែលគាយក-គាយិកា ធ្វើឲ្យដោយសទ្ធាទេ មិនមែនបួស ព្រោះហេតុតែចង់បានសម្បត្តិក្នុងតភពខ្លួន ឥដ្ឋតភពជំ គឺថាចង់បានសម្បត្តិមនុស្ស ឬសម្បត្តិទេវតា ក្នុងតភពណាមួយ ដោយព្រហ្មចរិយៈ

ជម៌ តើសីលនឹងវត្តដែលអាត្មាអញប្រព្រឹត្តនេះវេ មិនមែនបួស ព្រោះហេតុ
ចង់បានហានៈតិយសស័ក្តិជានេះជានោះទេ ។ អាត្មាអញ ដែលចេញ
ចាកផ្ទះ មកបួសក្នុងព្រះពុទ្ធសាសនាដោយសទ្ធានេះ ព៌ាព្រោះតែឃើញ
សេចក្តីទុក្ខប្រើនប្រការ តែងរៀតបៀន គ្រប់សត្តិត តើជាតិទុក្ខ ជរាទុក្ខ
មរណៈទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ
ជាដើម បើដូច្នេះ តើអាត្មាអញនឹងធ្វើសេចក្តីប្រតិបត្តិដោយឧបាយយ៉ាងណា
ដើម្បីនឹងកន្ត្រាំនឲ្យរួចផុតពីគន្លងនៃទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។
អាត្មាអញ បានលះបង់តាមគុណជ្រះស្រឡះអស់ហើយ ក៏ចូលមកបួស
ក្នុងព្រះពុទ្ធសាសនាត្រង់ឆ្ងាំងយ៉ាងនេះ ហើយត្រូវប់ជាបណ្តោះយូគំនិត
ឲ្យទៅត្រិះរិះស្ទាបអង្អែលត្រឿងតាមថាល្អ ថាស្រួលដូច្នេះ ឬ ដូច្នោះក្តី
បណ្តោយគំនិតឲ្យទៅត្រិះរិះក្នុងផ្លូវអកុសល ប្រកបដោយឣភ្យាបាទក្តី
បណ្តោយគំនិតឲ្យទៅត្រិះរិះក្នុងផ្លូវអកុសល ប្រកបដោយវិហឹសាក្តី ការ
ប្រើគំនិតទៅត្រិះរិះក្នុងផ្លូវអកុសលដ៏លាមកដូច្នេះនេះ ឃើញថា អំពើពុំ
សមគួរដល់អាត្មាអញជាបព្វជិតសោះឡើយ ។

មួយយ៉ាងទៀត លោកសន្ទិដ្ឋសមានចំហាំធំណាស់ ក៏ក្នុងលោក
សន្ទិដ្ឋសដ៏ធំនេះ តង់មានសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញបណ្ឌិត មាន
ឫទ្ធិ មានចិត្តចក្ខុ ឣាចកំណត់ដឹងខ្លួចិត្តនៃបុគ្គលដទៃបាន មិនតែ
ប៉ុណ្ណោះសោត ពួកសមណព្រាហ្មណ៍ទាំងនោះ រមែងមើលឃើញបាន

ចាំងកង់ខ្ចីដែតចាំងកង់ខ្ចីឆ្វាយ លោកគង់ដឹងនូវគាត្មាអញយ៉ាំងនេះឬយ៉ាំងនោះតុំខាន កាលបើលោកបានដឹងហើយ លោកមុខជានឹងប្រកាសប្រាប់គ្នាលោកឲ្យដឹងថា ម្នាលអ្នកដ៏ចម្រើនចាំងឡាយអើយ ចូរអ្នកមើលកុលបុត្តនេះចុះ កុលបុត្តនេះចេញពីផ្ទះមកបួសក្នុងព្រះពុទ្ធសាសនាត្រឡំងយ៉ាំងនេះហើយ មិនសមបើបណ្តាយចិត្ត ឲ្យត្រិះរិះទៅច្របូកច្របល់ប្រឡាក់ប្រឡួសដោយធម៌ជាអកុសលដ៏លាមកដូច្នេះទៀតសោះឡើយ ។ មិនតែប៉ុណ្ណោះសោត គង់មានពួកទេវតាដែលមានឫទ្ធិ មានចិត្តបក្ខ ឈានដឹងនូវចិត្តនៃបុគ្គលដទៃបាន តែងមើលឃើញចាំងកង់ខ្ចីដែតចាំងកង់ខ្ចីឆ្វាយ ទេវតាចាំងឡាយគង់ដឹងនូវគាត្មាអញដែលធ្វើយ៉ាំងនេះឬយ៉ាំងនោះតុំខាន កាលបើទេវតាចាំងនោះបានដឹងហើយ មុខតែប្រកាសប្រាប់គ្នាថាម្នាលអ្នកដ៏ចម្រើនចាំងឡាយអើយ ចូរអ្នកមើលកុលបុត្តនេះចុះ កុលបុត្តនេះចេញពីផ្ទះមកបួសក្នុងព្រះពុទ្ធសាសនាត្រឡំងយ៉ាំងនេះហើយ នៅតែបណ្តាយចិត្តឲ្យទៅត្រិះរិះច្របូកច្របល់ ប្រឡាក់ប្រឡួសដោយធម៌ជាអកុសលដ៏លាមកដូច្នេះទៀត ។ កិកុនោះ លុះតិចាវណាឃើញយ៉ាំងនេះហើយ ក៏មានសេចក្តីអៀនខ្មាសចំពោះលោក គឺមនុស្សនឹងទេវតាទូទៅ ហើយផ្គងចិត្តដ៏ម៉ាំថាអាត្មាអញនឹងប្រារព្ធសេចក្តីព្យាយាមឲ្យម៉ឺងម៉ាត់ មិនបន្ទរបន្ទយកងមុខការសិក្សា នឹងសេចក្តីប្រតិបត្តិរបស់ខ្លួន ជាដំណើរគ្រោះទៅរកការចេះដឹងនឹងមគ្គផលនិញ្ញន ត្រូវតាំងស្មារតីឲ្យនឹងប៉ុនមិនឲ្យរវើរវាយក្លាត់ ត្រូវ-

ធ្វើតាមកាយនឹងវាចាយ៉ាងស្ងប់រម្ងាប់ មិនឲ្យសោះសៅសល់ ត្រូវតម្កល់ចិត្តឲ្យមាំក្នុងកុសលធម៌ ឲ្យដាច់ចិត្តមានអារម្មណ៍តែមួយ ។ កិរិយានោះ កាលបើបានធ្វើលោកឲ្យជា អធិបតេយ្យ (យកលោកជាធំ) យ៉ាងនេះហើយ កំព្យាយាមកំចាត់ប្រដាប្រដួសកុំ មិនឲ្យអកុសលធម៌ណាដែលមិនទាន់កើត មិនឲ្យកើតឡើងបាន អកុសលធម៌ណាដែលកើតឡើងហើយ កំព្យាយាមលះបង់ ពង្រាបពង្រឹលអកុសលធម៌នោះ មិនឲ្យកើតតទៅទៀត កុសលធម៌ណាដែលមិនទាន់កើត ត្រូវធ្វើឲ្យកើតឡើង កុសលធម៌ណាដែលបានកើតឡើងហើយ ត្រូវធ្វើកុសលធម៌នោះ ឲ្យរឹងរឹតតែកើតចម្រើនឡើងតទៅទៀត រក្សាខ្លួនឲ្យបានបរិសុទ្ធស្អាត នេះឯងហៅថា លោកាធិបតេយ្យ ។

ធម្មាធិបតេយ្យ

ដូចម្តេចហៅថា ធម្មាធិបតេយ្យ ភាពនៃបុគ្គលយកធម៌ជាធំ ពាក្យថា ធម៌ ក្នុងទីនេះ បានដល់ សីល សមាធិ បញ្ញា ឬបានដល់ លោកិយធម៌ និងលោកុត្តរធម៌ ទាំងអស់ ទើបហៅថា ធម្មាធិបតេយ្យ ។ កិរិយានោះ គេរៀនក្នុងវិន័យក្តី នៅទៀបគល់នៃឈើក្តី នៅក្នុងអគារដើរស្វែងមាន តូប កុដិ សាលា វិហារ ជាដើមក្តី គួរពិចារណាឲ្យឃើញច្បាស់យ៉ាងនេះថា អាត្មាអញ កាលចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនានេះ មិនមែនបួសព្រោះហេតុតែចង់បានលាភ-

សក្ការៈ ឬ ចីវរ គឺគ្រឿងស្លៀកដណ្តប់ដែលតាយក-តាយិកាឲ្យដោយសទ្ធាខេ មិនមែនបួសព្រោះហេតុតែចង់បានបិណ្ឌបាត គឺអាហារកោជនត្រប់យាំង ដែលតាយក-តាយិកាឲ្យដោយសទ្ធាខេ មិនមែនបួស ព្រោះហេតុតែបានសេនាសនៈ គឺទីដេក ឧដ្ឋីអង្គុយ មានកុដិ សាលា វិហារ ជាដើមដែលតាយក-តាយិការធ្វើឲ្យដោយសទ្ធាខេ មិនមែនបួសព្រោះហេតុតែចង់បានសម្បត្តិ ក្នុងភពតូច ឧដ្ឋភពធំ គឺថាចង់បានសម្បត្តិមនុស្ស-ឬសម្បត្តិខេវតា ក្នុងភពណាមួយ ដោយសារព្រហ្មចរិយធម៌ គឺសីលឧដ្ឋវត្តដែលអាត្មាអញប្រព្រឹត្តនេះខេ មិនមែនបួស ព្រោះហេតុតែចង់បានហានៈ គឺយសស័ក្តិជានេះជានោះខេ ។ អាត្មាអញដែលចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនាដោយសទ្ធានេះ ពីព្រោះឃើញសេចក្តីទុក្ខច្រើនប្រការមានជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ជាដើម ដែលតែងតែបៀតបៀនត្រូវសត្វលោកទាំងអស់ព្រមទាំងខ្លួនអាត្មាអញផង ហើយក្នុងនេះ តើអាត្មាអញ នឹងប្រតិបត្តិដោយទុបាយយ៉ាងណា ដើម្បីនឹងធ្វើឲ្យរួចផុតពីគំនរនៃទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។

ធម៌ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់ដឹងហើយក្នុងលោកហើយ ទ្រង់បានសំដែងទុកមក ដើម្បីឲ្យសត្វលោកប្រតិបត្តិតាមនោះ មានដើមថា ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ

អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ
វេទិតព្វោ វិញ្ញូហិ (ប្រែថា) ធម៌ដែលព្រះមានព្រះភាគ ទ្រង់
ត្រាស់សម្តែងទុកហើយដោយប្រពៃ ជាធម៌ដែលព្រះអរិយបុគ្គលគប្បី
យើញជាក់ច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យខ្លួវផលមិនរង់ចាំកាល ជាធម៌គួរ
នឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌គួរបង្អោនចូលមកកុំកុងក្នុង
ខ្លួន ជាធម៌ដែលវិញ្ញូជនគប្បីដឹងច្បាស់ចំពោះខ្លួន ។ ពាក្យថាធម៌កុង
ទីនេះ សំដៅយកធម៌ចំនឹតីរយ៉ាងគឺ បរិយត្តិធម៌ ១ នវលោកុត្តរធម៌ ១ ។

បរិយត្តិធម៌នោះ បានខាងការសិក្សាបិដកចាំង ៣ គឺ វិនយបិដក
សុត្តន្តបិដក អភិធម្មបិដក ដែលក្រុមព្រះសង្គីតិកាចារ្យ ជាន់ប្រមូល
រៀបចំទុកជាក់តាមពួក តាមក្រុម កំណត់ហៅថា វិន័យ ព្រះសូត្រ ព្រះ-
អភិធម្ម ប្រជាប់ដោយធម្មក្ខន្ធ ៨.៤០០០ ធម្មក្ខន្ធ មានចំនួនច្រើនយ៉ាង
នេះក៏ដោយ គឺសុទ្ធសឹងតែជាឧភតវល្ល ។ សម្រាប់បំភ្លឺផ្លូវប្រាប់ហេតុផល
អ្នកសិក្សានឹងអ្នកប្រតិបត្តិតាម ឲ្យបែរមុខឆ្ពោះទៅរកសុខសន្តិភាព កុង
លោក នឹងសុខព្រះនិព្វាន តែម្យ៉ាងប៉ុណ្ណោះ ។

នវលោកុត្តរធម៌នោះ បានខាងធម៌ថ្នាក់ខ្ពស់ចាំង ៩ យ៉ាង គឺមគ្គ ៤
ផល ៤ និព្វាន ១ ជាធម៌ធ្វើបុគ្គលអ្នកប្រតិបត្តិតាម បានសម្រេចនោះ
ឲ្យគួរងឺតចាកលោកចាំង ៣ មានតាមលោកជាដើម ។ នវលោកុត្តរធម៌
នេះ ពាក់ថាជាផលនៃបរិយត្តិ នឹងបដិបត្តិ ឬថា បរិយត្តិ នឹងបដិបត្តិ ជា-

មូលហេតុនាំឲ្យបានសម្រេចនូវខណៈតុល្លៈធម៌ក៏បាន ។ ពុទ្ធនុភាពនាំឲ្យ
អស់ បើប្រមូលដោយខ្លឹមក ហៅថា ធម្មវិន័យ ។ នេះឈ្មោះថាឱឡាទិកធម៌ ជាធម៌ស្រោចស្រង់យើងរយោងអ្នកប្រតិបត្តិតាម ឲ្យរួចផុតចាកភ្លើងទុក្ខនឹងភ្លើងកិលេសបានដោយពិត ។

អាត្មាអញ បានចូលមកកាន់ធម្មវិន័យដែលព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់សម្តែងនុ៎ះល្អឥតខ្ចោះយ៉ាងនេះហើយ ម្តេចឡើយក៏ត្រូវប៉ះពាល់ជាមនុស្សទម្រន់ខ្លួលច្រអូស ជាមនុស្សក្រូសប្រហែសទៅវិញ អំពើនេះជាការពុំសមគួរដល់អាត្មាអញសោះឡើយ ។ តទុកខោះ លុះពិចារណាឃើញដូច្នេះហើយ ក៏តាំងចិត្តថា អាត្មាអញនឹងប្រារព្ធសេចក្តីព្យាយាមឲ្យមុឺងម៉ាត់ ពុំបន្ធូរបន្ធយកន្លងការសិក្សានឹងសេចក្តីប្រតិបត្តិរបស់ខ្លួន ដែលជាដំណើរឆ្ពោះទៅរកការចេះដឹង ខឹងមគ្គផលនិព្វាន ត្រូវតាំងស្មារតីឲ្យរឹងប៉ឹងមិនឲ្យរង្គើងភ្លាត់ ត្រូវធ្វើទាមកាយនឹងការងារកាយឲ្យស្ងប់រម្ងាប់ មិនឲ្យរសាប់រសល់ ត្រូវតម្កល់ចិត្តឲ្យមានឯកគ្គតាធម៌ក្នុងកុសលធម៌ ឲ្យជាចិត្តមានអារម្មណ៍តែមួយ ។ តទុកខោះ កាលបើបានធ្វើធម៌ឲ្យជាអធិបតេយ្យ (យកធម៌ជាធំ) យ៉ាងនេះហើយ ក៏ព្យាយាមរាំងប្រុងប្រយ័ត្ន មិនឲ្យអកុសលធម៌ណាដែលមិនទាន់កើត មិនឲ្យកើតឡើងបាន អកុសលធម៌ណាដែលកើតឡើងហើយ ក៏ព្យាយាមលះបង់តម្រេចពង្រឹលអកុសលធម៌ខោះ មិនឲ្យកើតតទៅទៀត កុសលធម៌ណាដែលមិនទាន់កើត ត្រូវធ្វើឲ្យ-

កើតឡើង កុសលធម៌ណាដែលបានឡើងហើយ ត្រូវធ្វើកុសលធម៌
នោះឱ្យរឹងតែតែកើតចម្រើនឡើងតទៅទៀត រក្សាខ្លួនឱ្យបានបរិសុទ្ធស្អាត
នេះឯង ហៅថា ធម្មាធិបតេយ្យ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់សម្តែងបញ្ជាក់ថែមទៀតថា ធម្មតា
បុគ្គលអ្នកធ្វើអំពើអាក្រក់ណាមួយក្នុងលោក អំពើអាក្រក់នោះ មិនដែល
កំចាំងបាត់ទេ គឺខ្លួនអ្នកធ្វើរមែងដឹងថាពិត ឬ មិនពិតដោយខ្លួនឯង អ្នក
ធ្វើត្រូវជាសាក្សីផ្ទាល់ចំពោះខ្លួនឯង អ្នកធ្វើត្រូវផ្ទួញផ្ទាល់ខ្លួនដោយខ្លួនឯង
បើអ្នកធ្វើបិទបាំងអំពើអាក្រក់ ដែលមានក្នុងខ្លួនឯងហើយ អ្នកប្រាជ្ញគាំង
ល្អាយមានព្រះពុទ្ធជាដើម ទឹងទៅតាំងល្អាយ រមែងឃើញបុគ្គលតាល
ដែលប្រព្រឹត្តទុស្សកន្តលោក ព្រោះហេតុនោះ បុគ្គលយកខ្លួនជាធំ ឬត្រូវ
យកលោកជាធំ ក្នុងមុខការដែលខ្លួនត្រូវបំពេញ ត្រូវធ្វើ ហើយជាអ្នក
ប្រព្រឹត្តប្រតិបត្តិតាមធម៌នោះ ។ ផង ទើបទឹងទៅជាអ្នកប្រាជ្ញ មាន
ប្រាជ្ញាល្អ ជាអ្នកស្គាល់ច្បាស់នូវប្រយោជន៍ក្នុងលោកនេះទឹងលោកខាង
មុខដោយពិតប្រាកដ ។

អធិបតេយ្យគាំង ៣ យ៉ាងគឺ អត្តាធិបតេយ្យ លោកាធិបតេយ្យ
ទឹងធម្មាធិបតេយ្យ ដែលបានអធិប្បាយមកហើយនោះ យើញថាបាន
ការដូចគ្នា អាចឱ្យសម្រេចប្រយោជន៍ដូចគ្នា មិនមែនណាអន់ខ្លាយ
ជាងណាឡើយ ប៉ុន្តែមានបុគ្គលខ្លះយល់ថា បណ្តាអធិបតេយ្យគាំង ៣-

យ៉ាំង មានតែធម្មាធិបតេយ្យមួយទេ ដែលល្អប្រសើរជាងអត្តាធិបតេយ្យ នឹងលោកាធិបតេយ្យ ដែលពោលយ៉ាំងនេះ ព្រោះតេយល់ថា អត្តាធិបតេយ្យ ប្រែថា ភាពនៃបុគ្គលមានខ្លួនជាធំ ឬយកខ្លួនជាធំ ជាន សេចក្តីថា អ្នកណាមួយដែលផ្តើមធ្វើការកុសលអ្វីផ្សេង ។ មានការឲ្យ ទាន នឹងការរក្សាសីលជាដើម ហើយលើកយកខ្លួនជាធំ សម្រេចក្នុង ការឲ្យទាននឹងការរក្សាសីលនោះ មិនវល់តើពើអំពីការខុសត្រូវ មិន គោរពដល់ច្បាប់ ឬ មិនយកច្បាប់មកជាប្រមាណឡើយ ស្រេចហើយ តែនឹងខ្លួនយល់ឃើញយ៉ាំងណា ក៏ធ្វើយ៉ាំងនោះទៅ គឺធ្វើអនុលោមទៅ តាមគំនិតដែលយល់ឃើញ ទោះបីមានគេនិយាយណែនាំ ប្រាប់ពន្យល់ ពីការខុសត្រូវដូចម្តេច ក៏មិនវល់យកចិត្តទុកដាក់ ស្តាប់គោរពធ្វើតាមដែរ។

បើបុគ្គលជាអ្នកធ្វើកុសលណាមួយ ដោយតាំងចិត្តជាអត្តាធិបតេយ្យ ដូចបានពោលមកនេះ កុសលនោះ មិនសូវជាបានការប្រសើរប៉ុន្មានឡើយ ។

មួយទៀត គេយល់ថា លោកាធិបតេយ្យ ប្រែថា ភាពនៃ បុគ្គលមានលោកជាធំ ឬយកលោកជាធំ ជានសេចក្តីថា អ្នកណា មួយដែលផ្តើមធ្វើកុសលអ្វីផ្សេង ។ មានការឲ្យទាននឹងការរក្សាសីលជា ដើម ប្រែនធ្វើផ្គាប់ចិត្តមនុស្សខ្លួនឯង ដើម្បីឲ្យគេគោតសរសើរចំពោះ ខ្លួន ថាជាអ្នកមានទ្រព្យសម្បត្តិក្តី ថាជាអ្នកប៉ុនប្រសប់ក្តី ចង់ជានក្តី

ឈ្មោះក្តី យ៉ាងនេះជាដើម មិនស្ងួតគិតពីការខុសត្រូវ មិនគោរពច្បាប់ឬ មិនយកច្បាប់មកជាប្រមាណឡើយ គឺធ្វើជាយមានបំណង គ្រាន់តែឲ្យគេយើញស្ងើចសរសើរខ្លួនប៉ុណ្ណោះ បើបុគ្គលអ្នកធ្វើកិច្ចការជាកុសលណាមួយ ដោយតាំងចិត្តជាលោកាធិបតេយ្យ ដូចបានតណិនាមកនេះ កិច្ចការជាកុសលនោះ មិនស្ងួតជាបានការប្រសើរប៉ុន្មានឡើយ ។

អ្នកដែលមានសេចក្តីយល់ចំពោះអត្តាធិបតេយ្យ ទំាងលោកាធិបតេយ្យ បែបដូចបានតោលមកនេះ ក៏យើញថាជាការសមរម្យមួយយ៉ាងដែរ ព្រោះថាធម្មតាបុគ្គលអ្នកប្រាថ្នាធ្វើអ្វីមួយ ដោយអាងយកខ្លួនជាធំ ឬយកលោកជាធំហើយ រមែងតែតុំស្ងួរតែងប៉ុនប៉ងខ្ជាប់ខ្ជួនខឿងតាត់ក្នុងមុខការនោះៗ ប៉ុន្មានឡើយ ចួនកាលតឹង ចួនកាលធូរ ប្រៀបដូចជនអ្នកធ្វើការងារជាប្រយោជន៍ផ្ទាល់ខ្លួន ទំាងជនអ្នកធ្វើការងារ ក្រោមបង្គាប់អ្នកដទៃ ឯជនអ្នកធ្វើការងារជាប្រយោជន៍ផ្ទាល់ខ្លួននោះ ជួនកាលគិតយើញថា ការងារនេះជាប្រយោជន៍ផ្ទាល់ខ្លួនឯងអាត្មាអញ ។ ចង់ធ្វើក៏បាន ឈប់ធ្វើក៏បាន ចំណែកខាងជនអ្នកធ្វើការងារ ក្រោមបង្គាប់អ្នកដទៃនោះ ជួនកាលធ្វើដោយការចង់ផ្គាប់ចិត្តអ្នកម្ចាស់ការ ឬខ្លាចអ្នកម្ចាស់ការស្តីបន្ទោសម្ល៉ោះហើយក៏ខំប្រឹងប្រែងធ្វើទៅ បើអ្នកម្ចាស់ការធ្វើប្រើយកន្តើយមិនរិះគន់ទេ ខ្លួនក៏ធ្វើដោយសោះអន្តើយទៅដែរ សេចក្តីនេះយើញថាអត្តាធិបតេយ្យ ទំាងលោកាធិបតេយ្យ មិនប្រសើរវិសេសដូចជាធម្មាធិ-

បតេយ្យទេ ព្រោះហេតុអ្វី ? ព្រោះហេតុថា អត្តាធិបតេយ្យ ខ្ញុំឯ លោកាធិបតេយ្យ អាស្រ័យដោយមានទុច្ចរិតលេសចូលមកលាយឡំជាកម្លាំង ឯធម្មាធិបតេយ្យ យកធម៌តឹងច្បាប់ជាធំ ក្នុងមុខការដែលខ្លួនត្រូវធ្វើ មិនធ្វើអនុលោមឲ្យត្រូសខុសតឹងច្បាប់ឡើយ ។

សេចក្តីដែលបានបរិយាយវែកញែកដូចខាងលើនេះ ថា អត្តាធិបតេយ្យ ខ្ញុំឯលោកាធិបតេយ្យ មិនប្រសើរស្មើខ្ញុំឯធម្មាធិបតេយ្យទេនោះ កំណត់ជឿយកជាការបានដែរ ប៉ុន្តែខ្ញុំអ្នករៀបរៀងអត្ថបទនេះ ពុំទាន់ដែលបានឃើញខ្ញុំយ កុងតម្ពីរណា ដែលអធិប្បាយសេចក្តីដូច្នោះឡើយ បើតាមខ្ញុំឯងដំណើរសេចក្តីនោះ ប្រហែលជាគេយល់ដោយអត្តនោម័តទេដឹង ? ព្រោះហេតុនោះ អធិបតេយ្យទាំង ៣ យ៉ាង ដែលខ្ញុំបានដកស្រង់ចេញពីកុងតម្ពីរអង្គុត្តរនិកាយតិកនិបាត ត្រមាំងអដ្ឋកថា មករៀបរៀងក្នុងសៀវភៅនេះ បុគ្គលអ្នកមានប្រាជ្ញា ប្រថ្នាខ្លួនប្រយោជន៍គឺសេចក្តីសុខ ខ្ញុំឯសេចក្តីចម្រើន ឲ្យតើតឡើងដល់ខ្លួន ទាំងកុងផ្លូវលោក ទាំងកុងផ្លូវធម៌ គប្បីកាន់យកតាមន័យនោះចុះ ។

(នៅមានត)

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ូ រៀបរៀង

តមក

៦- យថាសន្នកម្ម

យំ បន អាសន្នមរណោ អនុស្សរិតុំ សក្កោតំ យថាសន្នំ នាម តនេវ យថា នាម តោក-ណាសទ្ធ បរិបុណ្ណាសទ្ធ វជិរទ្ធ ទ្វារេ វិវរិត្វេ យោ អាសន្នោ ហោតិ សោ ឯវ បឋមតរំ តច្ចតិ ។

លំដាប់នេះ សូមវិសជ្ជនាកថ័កម្មប្បច្ច័យ អធិប្បាយនូវយថាសន្នកម្ម តទៅ សេចក្តីថា កុសលាកុសលេសុ យថាសន្នកម្មនោះ មាន ៤ យ៉ាងគឺជាកុសល ១ ជាអកុសល ១ ។ យថាសន្នកម្មប្រែថា កម្មដ៏ជិតក្នុងកុសលទាំងឡាយនេះ ។ កម្មណាមានក្នុងជវនៈ បុគ្គលនឹក រឭកយើញនូវកម្មណាក្នុងវេលាជិតនឹងលះជវនៈ កម្មនោះឯងឈ្មោះថា យថាសន្នកម្ម ។

ឯយថាសន្នកម្មនោះ ទៀបដូចគោដែលឈរនៅក្បែរមាត់ទ្វារក្រាល វជិរទ្ធ ទ្វារេ វិវរិត្វេ កាលបើទ្វារក្រាលគេញៅដោយហ្វូងនៃគោ ដែលនាយគោចាលបើកចេញក្នុងពេលព្រឹក ដើម្បី

ទំនងបញ្ជូញគោចាំងឡាយឲ្យត្រាច់ទៅស្មៅនៅស្មៅ យោ អាសន្នេ
កុងវេលាគេបើកទ្វារក្រាលនោះ បើគោណាឈរទៅជិតមាត់ទ្វារក្រាល
ជាងគេដោយហោចទៅ សូម្បីគោចាស់ជាងគេក្តី កំតង់តែគោចាស់
ជាងនោះ ចេញទៅមុនគោឯទៀតវែរ ។ សេចក្តីខេះមានឧបមាដូចម្តេច
ឃើញថាសន្ទកម្មដែលទំនងឲ្យផលនោះ កំមានឧបមេយ្យដូច្នោះ ។

ឃើញថាសន្ទកម្មជាកុសលទំនងជាអកុសលចាំង ២ ប្រការនោះ បើ
កម្មណាដែលបុគ្គលទំពាត់ឃើញក្នុងមរណាសន្នសម័យ គឺទៅគេល
ជិតទំនងរលត់បញ្ចក្ខន្ធ កម្មនោះតែងឲ្យផល នាំបដិសន្ធិក្នុងលំដាប់នៃបច្ចុ-
ប្បន្នភព ។ បើបុគ្គលជិតស្លាប់ ទំពាត់ឃើញកុសលកម្ម ។ ក៏ឲ្យផលមុន។
បើបុគ្គលជិតស្លាប់ ទំពាត់ឃើញអកុសលកម្ម ។ ក៏ឲ្យផលមុន ។

រឿងព្រោនសង្ខបឈ្មោះទមិឡទោវារិក:

ឃើញថាសន្ទកម្ម ជាកុសលក្តី ជាអកុសលក្តី រមែងឲ្យផលមុនដូច
ជាគោឈរជិតមាត់ទ្វារក្រាល ត្រូវតែចេញមុនគោឯទៀតដូច្នោះ ហេតុ
នោះបានជាកម្មនេះឈ្មោះ ឃើញថាសន្ទកម្ម ។ ព្រះអដ្ឋកថាចារ្យទាំងអតីត
និពន្ធមកសំដែងទុកឲ្យយើញផលនៃឃើញថាសន្ទកម្ម ជាកុសលទំនងជាអកុ-
សលចាំងពីរប្រការ ប៉ុន្តែសូមពណ៌នាទូវផលនៃឃើញថាសន្ទកម្មខាងកុសល
ជាមុន មានសេចក្តីដំណាលថា ៖

មជ្ឈអង្គណាគាមេ ភ័រ ចានត្បរៀង ។ មកថា មាន
បុរសម្នាក់ឈ្មោះ ទមិឡពោរាកែ នៅភូមិស្រុកឈ្មោះ មជ្ឈអង្គណាគ្រាម
ទមិឡពោរាកែនោះ ជាព្រានសន្ធូចគ្រាច់រកមច្ឆា ពលិសំ អាជាយ
កញ្ចា ដល់វេលាព្រឹក កាន់ទូវិសន្ធូចចេញពីផ្ទះចូលទៅកន្លែងព្រៃ គ្រាច់
ស្ទះស្ទើរកស្ទូចត្រី ចានយកមកចិញ្ចឹមខ្លួនទីនឹងបុត្រភរិយា តៈយា
គោដ្ឋាសេ ភត្តា រកត្រីចានមក ហើយចែកជាបីចំណែក គឺ
យកទៅដូរអង្ករ ១ ចំណែក យកទៅដូរទេធ ១ ចំណែក ចំអិនបរិភោគ
ជាមួយអាហារ ១ ចំណែក បញ្ញាសវិសជ្ជនិ ភរិយាគ្មាន គ្រាន់
តែទមិឡពោរាកែបុរសធ្វើអំពើចាណាតិចានតែប៉ុណ្ណោះ កន្លងមកដល់ ៥០ ឆ្នាំ
មិនដែលមានទ្នាំណាមួយឡើយ ។ លុះកាលជាអម្ចឹងមក ទមិឡពោ-
រាកែបុរស ដល់ទូវាតជាមនុស្សចាស់ជរាហើយ មានរោគាព្យាធិជាអនុ-
ជ្ឈានវិស័យ តឹឈឺធ្ងន់ដើរមិនរួច ជិតដល់មរណកាល ។

គ្រានោះ ព្រះបុលូចិណ្ណចាតិយតិស្សត្ថេរ គង់នៅក្នុងគិរីវិហារ ចាន
ជ្រាបដំណឹងថា ទមិឡពោរាកែបុរសឈឺធ្ងន់ដូច្នោះ ក៏គិតថា មយិ
វសន្តេ កាលបើអាត្មានៅក្នុងទីជិត ទមិឡពោរាកែបុរស ចូរកុំបីនាស
ឡើយ ។ ព្រះមហាថេរគិតដូច្នោះហើយ ក៏និមន្តទៅឈរកែវទ្វារផ្ទះ
នៃទមិឡពោរាកែបុរសនោះ ស៊ំដែងកាយឲ្យដល់តរិយា ។ ឃើញហើយ
ក្រាប់ស្ងាមីថា សាមិ បពិត្រស្វាមី ព្រះសមណៈដែលគង់នៅគិរីវិហារ

ខ្ញុំមន្តចូលមក ។

ឯទមិឡទោភរិកបុរស ឮពាក្យតាំយោគ្រាប់ដូច្នោះ គិតគឺថា អញ នៅក្នុងទីនេះឮប្រមាណ ៥០ ឆ្នាំមកហើយ មិនដែលឮនៅកាន់សំណាក់ព្រះសមណៈអង្គណាមួយសោះ ព្រះសមណៈចូលមករកអញនេះ តើព្រោះលោកឃើញគុណអញដូចម្តេច អញនឹងសមណៈមិនជាប់ស្និទ្ធស្នាលគ្នា មិនដែលមានគុណអ្វីនឹងគ្នាទេ គិតរួចគ្រាប់តាំយោថា អញមិនដែលស្គាល់សមណៈអង្គណាមួយសោះ ឯងចូរទៅគ្រាប់សមណៈនោះឲ្យចេញពីផ្ទះយើងទៅចុះ ។ ឯតាំយោក៏ទៅទូលព្រះមហាថេរតាមពាក្យប្តីថា សូមលោកម្ចាស់និមន្តទៅផ្ទះខាងមុខទៀតចុះ ។

ព្រះមហាថេរសួរថា ម្នាលឧបាសិកា សរីរប្បវត្តិ អាការប្រព្រឹត្តទៅក្នុងកាយនៃឧបាសកជាស្វាមីនាងនោះ តើដូចម្តេចទៅ ដើម្បីបានស្រាកស្រាន្តខ្លះដែរឬទេ ឥើបក្រែកដើរចូលជួបមិនរួច ។ តាំយាទូលថា ស្វាមីរបស់ខ្ញុំ កើតរោគជក ជាជម្ងឺធ្ងន់គ្មានកម្លាំងទេ កម្លាំងថយចុះតិចទៅរាល់ថ្ងៃ ពេលនេះ គាត់កាន់តែជាបហើយ ។ ព្រះមហាថេរនិមន្តចូលទៅក្នុងផ្ទះ គង់ដឹតហើយ ជាស់តឿនស្មារតីទមិឡទោភរិកបុរស ឲ្យទទួលព្រះត្រៃសរណគមន៍នឹងសីល ។ កាលព្រះមហាថេរនឹងឲ្យសីល ត្រូវឲ្យព្រះត្រៃសរណគមន៍ជាមុន លុះចប់ព្រះត្រៃសរណគមន៍ហើយ លោកប្រាប់ឆ្នឹងឲ្យសីលតទៅទៀត ដ៏ឫទ្ធិ មតា ប៉ុន្តែ អណ្តាតរបស់ទមិឡ-

ពោលគឺកុបុរសនោះឆ្អែតគាំង មិនអាចនឹងទទួលស័លបាន ទទួលបានតែត្រឹមព្រះត្រៃសរណគមន៍ចប់ប៉ុណ្ណោះ គំនៅស្ងៀមឈឹងទៅ ។ ព្រះមហាថេរៈ យើញអាការនៃបុរសនោះដូច្នោះហើយ ក៏លាត្រឡប់ទៅគាន់វិហារវិញ ។

សោបិ ឯកូត្តិ ចំណែកទម្ងន់ឡពោពាកុបុរសនោះ លុះចំណាយបញ្ចកុន្នះហើយ ក៏ជាន់ទៅតឹត ក្នុងជាន់ចតុមហាភូតិក សោយទិព្វសម្បត្តិ មានទាំងទេពនារីចោមរោមជាបរិវារ ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា កុសលកម្មនៃទម្ងន់ឡពោពាកុបុរសនោះជាយថាសន្នកម្ម គឺធ្វើទៅពេលដែលជិតអស់ជីវិត ទាំបដិសន្ធិក្នុងកាមាវចរសួគ៌ ។

ហេតុដូច្នោះ បុគ្គលដែលមានបញ្ញា ប្រសិនបើ កាលទៅតីក្នុងជាក្រមុំកម្លោះ មានសេចក្តីប្រមាទ មិនអាចធ្វើអំពើកុសលបានទេ លុះដល់មជ្ឈឹមវ័យ ពាក់កណ្តាលនៃអាយុ ក៏គប្បីធ្វើកុងឹការកុសលជាបដល់មរណកាល កុសលនោះនឹងបានជាយថាសន្នកម្ម ទាំបដិសន្ធិក្នុងសុគតិមជ្ឈឹមវ័យ អសង្ការន្តោ កាលបើកុងឹមជ្ឈឹមវ័យមានសេចក្តីប្រមាទ មិនអាចធ្វើកុសលបានទេ លុះដល់បច្ចឹមវ័យតឹជិតដល់អាយុខ័យ ក៏គប្បីតែធ្វើកុងឹការកុសលឲ្យខាងតែបានកុំខាន ។

កុសលដែលបុគ្គលធ្វើកុងឹពេលជិតស្លាប់ក្តី កុសលដែលបុគ្គលធ្វើ

ក្នុងគ្រាណា ។ ព័ម្មុនមក ប៉ុន្តែ ឃានទឹកវត្តកយើញនៅពេលដែតស្លាប់ ក្តី កុសលចាំងពីរប្រការនេះឈ្មោះ យថាសន្នកម្ម ជាកម្មទាំងដែសន្ធឹកក្នុង សុតតិកពជាន ។

យថាសន្នកម្មទាំងអកុសល

រឿងមហារិបកទុបាសក

អន្តរកថាយំ បន ក្នុងចន្លោះស្នាំនគ្គា មានឧបាសកម្នាក់ ជាអ្នកមានសទ្ធាជ្រះថ្លានៅក្នុងស្រុកដែតស្នាំនគ្គានោះ ជាមនុស្សរក្សាស៊ីល បំពេញទាន ចំរើនកាយគតាសតិកម្មដ្ឋាន តឺពិចារណាអាការ ៣២ មាន កេសាជាដើម តឺសរសួរនិ សជ្ឈាយិត្វា ទំស្វាធ្យាយចំរើន កន្ធ៍មកបានប្រមាណ ៣០ ឆ្នាំហើយ មិនបានសម្រេចព្រះសោតាបត្តិ-មគ្គសោះ ។ មហារបកឧបាសកគិតថា កាលអញចំរើនព្រះកម្មដ្ឋាន ដូច្នោះដល់៧ ៣០ ឆ្នាំហើយ នៅតែគ្មានឧកាសឡើបានសម្រេចមគ្គ. ផលអ្វីសោះ ប្រសិនជាព្រះពុទ្ធសាសនា ពុំមែនដឹកនាំសត្វអ្នកប្រតិបត្តិ ឲ្យរួចផុតវដ្តសង្សារបានទេមើលទៅ បានជាអញមិនបានសម្រេចគុណ វិសេសណាមួយសោះ ប្រសិនបើព្រះពុទ្ធសាសនាដឹកនាំសត្វឲ្យរួចផុត ចាកសង្សារវដ្តបានពិតមែនទោះ អញក៏មុខជានឹងបានសម្រេចធម៌វិសេស ណាមួយមិនខានឡើយ ។

ឯដ្ឋវិបល្លាសំ បត្វា មហាវាចកៈជាសកនោះ លុះគិតយើញដូច្នោះហើយ ក៏ដល់នូវទិដ្ឋិវិបល្លាសគឺយល់ខុសថាជាត្រូវ ហ្វាងពីគន្ថធុរៈនិយ្យានិកធម៌ស្រឡះ លះបង់ព្រះកម្មដ្ឋាន លែងចំរើនតាំងពីគ្រាយល់ខុសនោះមក ។ ចំណែកាលខាងក្រោយ មហាវាចកៈជាសកនោះ ធ្វើកាលកិរិយាស្លាប់ហើយ ទៅកើតជាក្រពើ មានខ្លួនប្រវែង ៨ ទ្រសក(១)នៅមហាគង្គា ។

ឯកំ សមយំ សកាជានិ សម័យមួយ មានឈ្មួញរកេះផ្លុកសសរសិលាប្រមាណ ៦០ ដើម ចរមកដល់ជិតច្រាំងទៅនៃក្រពើនោះ។ ក៏ត្រូវបាក់លេបចាំងគោចាំងរកេះចាំងដុំថ្មអស់រលីងទៅ ។

មហាវាចកៈជាសកទៅកើតកន្លែងតែប្លែកនឹងកំណើត ជាសត្វក្រពើនោះ ព្រោះផល នៃអកុសលកម្មដែលខ្លួនយល់ឃើញ វិបរិតខុសពាកគន្ថធម៌ លុះដល់វេលាជិតរលត់សន្លាវ កំនឹកឮកឃើញនូវគំនិតខុសរបស់ខ្លួននោះ ចាត់ជាយថាសន្ថកម្ម ។

ឯយថាសន្ថកម្មនោះ សំដៅយកកម្មដែលបុគ្គលនឹកឮកឃើញកន្លែពេលជិតស្លាប់ជាប្រមាណ គឺថាបើនឹកឮកឃើញកុសលកម្ម។ ក៏ឲ្យផល បើនឹកឮកឃើញអកុសលកម្ម។ ក៏ឲ្យផល ។ បុគ្គលធ្វើអកុសល

---

១)អានថា អ៊ុំ សប់ ឈ្មោះដង្វាស់បុរាណមួយប្រវែង ១៤០ ហត្ថ ក្នុង ១ ទ្រសក។ ជាឈ្មោះវែងថា ទ្រសកកំបាន ។ ជាឈ្មោះពោងថា ទ្រសកភាគកំបាន ។

អស់វេលាជាយូរណាស់ តែធ្វើតាំងអំពីបឋមវ័យរហូតដល់បច្ចិមវ័យ លុះដល់ពេលជិតស្លាប់ទើបរឭកឃើញនូវកុសលកម្ម ។ ក៏ទើបឲ្យផលនាំបដិសន្ធិកន្ធជាតិជាលំដាប់ ។ ដើម្បីនឹងធ្វើកន្ធការកុសល អស់វេលាជាយូរ តាំងអំពីដើមក្តីរហូតដល់ជិតទើបអស់ជីវិត បែរជាទើបរឭកឃើញនូវអកុសលកម្មទៅវិញ អកុសលកម្មនោះក៏ទើបឲ្យផល នាំបដិសន្ធិកន្ធជាតិជាលំដាប់ ។

ការដែលទើបធ្វើកុសលកម្មឲ្យជាយថាសន្ធកម្ម ភាពកុសល នាំបដិសន្ធិកន្ធសុគតិភពបាននោះ ត្រូវអាស្រ័យនូវកល្យាណមិត្តជួយរឭកជាសព្វគ្រឿងឲ្យធ្វើការកុសល នៅវេលាជិតទើបអស់ជីវិត ឥតកាលរលត់សង្ខារចិត្តក៏ទើបរឭកឃើញនូវកុសលនោះ ប្រៀបដូចមនុស្សមានដំណើរទៅជាការប្រញាប់ ដើរឃើញរថស់ណានៅជិតដៃ ក៏ចាប់ឆក់យករថស់នោះទៅភ្លាម ក៏ទើបរឭកឃើញនូវការកុសលនោះភ្លាម កុសលនោះទើបឲ្យផលនាំទៅកាន់សុគតិភព ។ ហេតុនោះ បុគ្គលដែលបានធ្វើអកុសលកម្មជ្រុលហួសទៅហើយ ត្រូវរឹងប៉ងក្លែចចោលកុំទើបនា ដើម្បីកុំឲ្យផលនៃអកុសលកម្មនោះទៅជាយថាសន្ធកម្មបាន ត្រូវរឹងធ្វើកុសលកម្មឲ្យទៅជាយថាសន្ធកម្មវិញ ដើម្បីឲ្យបានផលទៅបដិសន្ធិកន្ធសុគតិភព បើពុំជាសោយផលនៃអកុសលកម្មដែលខ្លួនធ្វើពុកជាយូរមកហើយក៏ដោយ ទើបកំណត់ថាអកុសលកម្ម ឲ្យផលក្នុងភពណា ក៏កំណត់មិនបានដែរ ។ កុសលកម្មទើបអកុសលកម្មទាំងពីរប្រការនេះ បុគ្គលបានធ្វើរួចមកហើយមិនមែនគ្នាន

ផលទេ បើមានផលខ្ចាំងក្លា ក៏ឲ្យផលជាទិដ្ឋធម្មវេទនីយ៍ បើមិនបាន
ជាទិដ្ឋធម្មវេទនីយកម្មទេ នឹងទៅជាអបរាបរិយវេទនីយកម្មប្តូជាយថាសន្ត-
កម្ម ។ ប៉ុន្តែ បើបុគ្គលបានសោយផលនៃកុសលកម្មមុន ជួនកាលចួល
ព្រះនិព្វានផុតហួសទៅ អកុសលកម្មតាមទៅឲ្យផលមិនខាន់ក៏មាន ។
កាលបើបុគ្គលមិនទាន់ដល់ព្រះនិព្វានជាបណា កុសលកម្មនិងអកុសល
កម្មដែលខ្លួនបានធ្វើរួចហើយ ក៏ជាប់តាមទៅជាបនោះ ។

ហេតុដូច្នោះ សម្តេចព្រះបរមសាស្តាចារ្យ ទើបទ្រង់ចាត់យថា
សន្តកម្ម ចូលកងកម្មប្បច្ច័យ ក្នុង ៤៨ ប្រការដូច្នេះ ។

យថាសន្តកម្ម សង្ខេបប៉ុណ្ណោះ ។

ពុទ្ធស្តាជន្លះនៅប្រទេសឥណ្ឌា

រៀបរៀង ដោយ ឧ តាម

នៅដើមខែមេសា ឆ្នាំ ១៩៦៣ ក្រសួងធម្មការបានបញ្ជូនព្រះភិក្ខុ ប៉ាង-ខាត (រីរយមណ្ឌិតា) ហើយខំធំខ្ញុំ ឲ្យទៅសិក្សាស្រាវជ្រាវព្រះពុទ្ធ-សាសនា តាមព្រះរាជក្រឹត្យ លេខ ៩ បរ. ចុះថ្ងៃ ២៩-១-៦៣។ ក្នុងការធ្វើដំណើរនេះ មូលនិធិអាស៊ីនៅប្រទេសកម្ពុជា ដែលមានលោក ឡេអូណាសេអ៊ូវ័រតុន ជាដំណាង (Leonard C. Overton) បានចេញសោហ៊ុយឲ្យខាងអស់ ។

ការធ្វើដំណើរទៅប្រទេសឥណ្ឌា មិនមែនជាការចូលប៉ុន្មានទេដូច លោកអ្នកខ្លះធ្លាប់បានធ្វើដំណើរទៅកាន់បរទេសដែរ ។ ព្រះភិក្ខុប៉ាង-ខាត ខំធំខ្ញុំ បានទៅជល់កូមា ត្រូវឈប់ដំណើរចាំយន្តហោះផ្សេងទៀត ។ នៅកន្លែងនោះបុគ្គលិកស្ថានឯកអគ្គរាជទូតខ្មែរយើង (លោក ឡឹក-ធន) ទៅរង់ចាំទទួលដំណើរយើង ហើយនាំយើងមកសំណាក់អាស្រ័យនៅគេហស្ថានឯកអគ្គរាជទូតយើង ។ ឯកឧត្តមឯកអគ្គរាជទូត (ស៊ុំ-ហៀង-ខំធំលោកដំណាវ) ជាមហាឧបាសក-សិកា បានរៀបចំចង្ហាន់ប្រគេនលោកឆាន់ ហើយជល់ថ្ងៃចេញដំណើរពីកូមាទៅប្រទេសឥណ្ឌា ឯកឧត្តមខំធំលោកដំណាវ ហើយខំធំលោកឡឹក-ធន បានជូនដំណើរយើងទៅកាន់

ចំណតអាកាសយាន ហើយនៅសំណេះសំណាលលេង រហូតដល់យន្ត
ហោះចេញ ។

នៅដល់ប្រទេសឥណ្ឌា គំនាបុគ្គលិកស្ថានឯកអគ្គរាជទូត (លោក
ហាក់ ភេង) និងលោក (James Geene) បុគ្គលិកអាជ្ញាធរមូលនិធិអាស៊ី
ប្រចាំប្រទេសឥណ្ឌា មកទទួលដំណើរយើងដែរ ។ យើងទោះដល់ប្រទេស
ឥណ្ឌាបានប្រកបដោយសេចក្តីសុវត្ថិភាពយ៉ាងណា តែគ្រាន់តែបើកទ្វារចេញ
ពីកន្លែងអាកាស ។


ប្រទេសឥណ្ឌា ជាកន្លែងដែលយើងត្រូវសំណាក់ស្នាក់នៅ
តែយើងមិនទាន់បានចេញពីក្រុង ដែល្លីភ្លាមទេ យើងត្រូវរង់ចាំនៅក្រុង
ដែល្លីរហូតដល់ពេលបួលន្ទាំ ព្រោះឯកឧត្តមឯកអគ្គរាជទូតខ្មែរនិងបុគ្គលិក
នៃស្ថានឯកអគ្គរាជទូត បានទិមន្តព្រះភិក្ខុចាំន ខាត់ ឲ្យនៅរង់ចាំថ្វេបុណ្យ
បួលន្ទាំខ្មែរ ដើម្បីនិងថ្វាយព្រះពរដល់សម្តេចព្រះមហាក្សត្រីយានី
នីនិងសម្តេចព្រះប្រមុខរដ្ឋ ។ ក្នុងពេលដែលយើងនៅរង់ចាំពេលបួល
ន្ទាំនេះ យើងបានទៅទាក់ទងនិងលោកអ្នកប្រាជ្ញជាតិឥណ្ឌា ស្តាំនាំឲ្យ
យោបល់ខ្លះអំពីព្រះពុទ្ធសាសនា ហើយនិងពុទ្ធស្ថានខ្លះដែលយើងមិន
ដែលជឿនតួ នៅក្នុងប្រទេសឥណ្ឌា ។

លុះពេលបួលន្ទាំហើយ យើងក៏ចេញដំណើរពីក្រុងដែល្លីទៅ
ភ្នំពេញតាមរថភ្លើងនៅថ្ងៃទី ១៩ មេសា ឆ្នាំជវដែល ។


ពុទ្ធគយា ជាកន្លែងដែលព្រះពុទ្ធជាម្ចាស់បានត្រាស់ដឹងនូវ. សម្មាសម្ពោធិញ្ញាណ ។ ពួកពុទ្ធបរិស័ទក្នុងពិភពលោកជាច្រើន បានត្រូចមកនមស្ការកន្លែងនេះ មានអ្នកខ្លះចំណាយពេលពេញមួយជីវិតទៅបួសនៅក្រោមដើមពោធិឬស ។ អ្នកខ្លះទៀតទៅគ្រាន់តែថ្វាយសក្ការបូជាដើមពោធិព្រឹក្ស ។



ពុទ្ធគយា ឯកឡើញតួបេតិយគាំងអស់



វេនបល្ល័ង្ក ដែលព្រះសម្មាសម្ពុទ្ធគង់ក្នុងពេលបានត្រាស់




បល្ល័ង្គមន្ទីរនេះ គេធ្វើដំណាងកាលដែល ព្រះអង្គទ្រង់ឃាងបង្រៀម មានខ្លះជាក់បែក

ក៨ក្រឹះ នៅក្នុងរដ្ឋ ប៉ីហារ (Bihar) ជាកន្លែងដែលព្រះពុទ្ធទ្រង់ទ្រង់ខ្ពង់ខ្ពស់នោះឯង ហើយជាកន្លែងដែលព្រះមហាកស្សប ប្រជុំធ្វើបឋម-សង្គាយនា ។

នៅកន្លែងនេះ យើងបានទៅទស្សនាកន្លែងជាច្រើនដូចជា :


๑- ណាលន្ទា នៅនាលន្ទា យើងបានទៅជួបលោកសេន ជាអ្នកកាន់តាប់សាមន្តរនៅនាលន្ទា ។ លោកនេះ បានតាំយើងដើរទៅទស្សនាពុទ្ធស្ថាន ។ ខ្ញុំបានទៅទស្សនាមហាវិទ្យាល័យនាលន្ទាពីរដង ហើយ គឺកាលដែលខ្ញុំត្រឡប់មកពីសហរដ្ឋអាមេរិកឆ្នាំ ๑๙๖๑ តែពេលនោះ ខ្ញុំមើលមិនសូវឃើញ ខ្លាមហាវិទ្យាល័យ នាលន្ទាដែលបាក់បែក ។ តាមលោកសេនឲ្យដឹងមានថា « ព្រះពុទ្ធបានទៅក្នុងសាមន្តរនេះដែលបាក់បែកព្រះនាសាព្រះហស្ត ពីព្រោះពួកមហាមិត្តបួលមក កាប់ព្រះនាសាព្រះហស្តព្រះពុទ្ធឲ្យដាច់ពីគ្នា» ។ លោក មិនហាហ្សាដ (Minhazad) អ្នកជ្រាបខ្លួនដឹងថា (๑)« ពួកមហាមិត្តបានដុតព្រះសង្ឃាពុទ្ធសាសនិកចំនួនជាង ๑.๐๐๐ អង្គនាំគ្នាសៃ ហើយជាង ๑.๐๐๐ អង្គទៀតកាត់ព្រះសៀរហើយដុតចោលចំណាស់ឃើញទៀត» ។

1— Bhagawan Buddha by R. R. DIWAKAR



លោក សេន អភិរក្សប្លុកណាវត្ត នៅសារមន្ទីរ ជាន់ព្រះមហា ជ័យ - ទាត់, ភ័- ឃ្លាំ
ខ្ញុំងខ្ញុំមើលមហាវិទ្យាល័យតាលគ្នា

២- រឿង្ក្រាំង សព្វថ្ងៃនេះ នៅតាមផ្ទាកវេបសំប្លុកណាវត្តគេសរសេរ
ថា វេណុវនៈវៀត ។ វេឡុវន ជាអាស្រមរបស់ព្រះបាទពិម្ពិសារ ទ្រង់ទ
ថ្វាយព្រះសង្ឃសម្ពុទ្ធ ។ សព្វថ្ងៃនេះ នៅមានដើមឫស្សីកែវបន្តិចបន្តួច
មានស្រះមួយ នៅចំកណ្តាល ហើយមានព្រះពុទ្ធរូបមួយព្រះអង្គ ។



ព្រះសង្ឃខ្មែរ ឱនភ្នមា កំពុងនមស្ការព្រះពុទ្ធរូបនៅក្នុងវត្តវេឡុវន

មហោសធជាតក

(តតិយ)

សសមុទ្ធវិសាសំ មហាសាគរកុណ្ឌលំ
ពសុន្ធរំ អាវសសិ អមច្ចបរិវារិតោ ។
ចាតុរន្តោ មហារដ្ឋោ វិជិតាវី មហព្ពលោ
បឋព្យា ឯករាជាសិ យសោ តេ វិបុលំ តតោ
សោឡសិត្ថីសហស្សានិ អាមុត្តមណិកុណ្ឌលា
ឆាឆាដនបធា ជាវ៉ ទេវកញ្ញូបមា សុភា ។
ឯវំ សព្ពង្គសម្បន្នំ សព្ពកាមសមិទ្ធិនំ
សុខិតានំ បិយំ ឥឃំ ជីវិតំ អាហុ ខត្តិយ ។
អថ តុវំ កេន វណ្ណេន កេន វា បន ហេតុនា
បណ្ឌិតំ អនុក្កន្តោ ចាបំ ចដ្ឋសិ ទុច្ចដ្ឋិ ។

ប្រែថា : មហាក្សត្រអើយ! ឥឡូវនេះ អ្នកជាស្តេចប្រសើរតែម្នាក់ឯង នៅទាំងផែនក្រមេនេះ ជាឥស្សរកំពូលអស់ទ្វីបទាំង ៤ ដ៏មានទីនៅទូវាមាត្យមុខមន្ត្រីសេនាបតីផងទាំងឡាយជាបរិវារ ឯអស់អ្នកផងនៅសព្វថ្ងៃឮដំផែនក្រមេនេះ មានអ្នកបងជាបងបង្អស់នាឋានលំនៅបុរសអ្នកផងទាំងឡាយ ទៅដល់ផែនមេហាសមុទ្ធជាបរិក្ខេប រីសមុទ្ធសាគរនោះសោត តែងជាគ្រឿងប្រដាប់ផែនក្រមេនេះ ហើយមានកំឡាំងនោះច្រើន

អ្នកមានដ៏ឃ ឈ្មោះសង្ក្រាមចម្បាំងនោះផង រីក្តៅឃ្លាសអ្នកសោកដ៏ធំខ្លាំងឃ មានទីភៅនូវស្រីត្រះស្ងួនធំតាំងឡាយ មួយម៉ឺនប្រាំមួយតាន់ សឹងតាត់ទីភៅនូវតែងកុណ្ឌលផង សឹងកងតែមណីរ័តន៍ពិចិត្រប្រពៃ ស្រីជនបពផងផ្សេង ។ សឹងល្អប្រពៃ ដូចស្រីសួគ៌ទេពកញ្ញា ហើយអ្នកប្រកបនូវសូរសម្បត្តិតាំងអម្បាលនេះ ទើបលោកហៅមហាសូត្រស់ដឹង ហើយតែងធំប្រកបនូវសុខសួស្តីសំរិទ្ធិ លុះដោយនូវចំណង់តាំងពួងនោះ អ្នងផងតាំងពួងនឹងស្រឡាញ់អស់កាលដ៏លង់ភៅហាង ហើយរម្ពចក៏អ្នកមកវក្សាឯថៅមហោសថ អ្នកប្រាជ្ញនេះ ហើយសូមជន់ដ៏រឹតអាត្មាឯងវិញដូច្នេះ តែមួយទីសោត ហេតុដោយណ្ហោះអ្វី ដោយហេតុប្រយោជន៍នោះឈ្មោះអ្វី កំអ្នកថាសូមជន់ដ៏រឹតអ្នកឯងវិញនោះហ៏ន ។

ឯព្រះចុតចូលនិព្រហ្មទត្តនោះមិញ អ្នកស្តាប់ងាងតែរីបរីភ្លាជាកា ហើយ ស្តេចនឹងសំដែងគុណនៃថៅមហោសថអ្នកប្រាជ្ញ ទើបសូត្រជាបទគាថាដូច្នេះ ។

យោនោបិ អាគតោ អយ្យ មម អត្ថំ មហោសធោ
ជានាតិ ជាតិមា ធីរស្ស អនុមត្តំបិ ឧក្កដំ ។
សចេបិ តាតិម្ហិ តាលេ មរណំ មេ បុរេ សិយា
ឧប្តេ ច មេ បឧប្តេ ច សុខាបេយ្យ មហោសធោ
អជាតកំ បច្ចុប្បន្នំ សព្វមត្តំ វិមុត្តិ

អជ្ឈាបកជកម្មដ្ឋំ ឯ ឧដ្ឋិ ឧការក្តិជោតិ ។

អយ្យ ភៃខាងអើយ ! រីឯថៅមហោសថបណ្ឌិតអ្នកច្រាជនេះ សូមម្បីកាលណាមកនៅជាអ្នកច្រាជ តែងនឹងបង្ហាញអស់អាថិសេចក្តីលោភ័យ លោភាធម៌នោះ មិនដែលឲ្យអំពល់ដឹងដល់អញឡើយ ហើយសូម្បីមាត្រថា ពុំដែលធ្វើទុក្ខអញដល់តិចឡើយ ពោះបីមានអំពើកាចជាក្តី តីការកម្រមកដល់អញនេះ ក៏ថៅមហោសថអ្នកច្រាជអាចទូចទម្ងន់ពាំងភួង ពោះអំពីមុនក្តី សឹងមានដូច្នេះហោង ពោះកូនប្រពន្ធម្តាយអញ ខ្លួនឯងអញឯងក្តី ក៏ថៅមហោសថអ្នកច្រាជនេះ គាត់តម្កល់ទុកឲ្យបានល្អប្រសើរ គាត់មានយោបល់អស់អាថិពាំងសម្លាយ ពោះបីអាថិកន្ធងរម្ងងៅហើយក្តី ពោះបីអាថិនឹងមានមកឯក្បែកក្តី គាត់ពុំដែលធ្វើឲ្យជាទោសនឹងអញឡើយ ហេតុអស់ប្រការគុណនោះហោង អញមិនឲ្យទុកក្នុងស្បែកធ្វើគាត់ទេ ។

បពិត្រអើយ ! រីព្រះបាទបុប្ផទិត្រហ្មទត្តជាមិញ ស្តេចតែងសរសើរគុណនៃព្រះមហោសថអ្នកច្រាជក្រយោយើង លើកឡើងប៉ាដូចនឹងៅដល់មណ្ឌលព្រះអាទិត្យ ព្រះចន្ទ្រ ៧រំ ស្រេចខ្លួវប្រការពាំងអម្បាលនេះហោង ។ ឥតិ ឥមំ ជាតកំ យថា អនុសន្ធិ-ត្តំ ហោតិ នេះហោង តីយើងស្រដីកំណត់ទំយាយនេះ លុះដោយខ្លួវដំណាចខ្ញ ស្រេចដោយខ្លួវប្រការអម្បាលនេះហោង ។

អថ បរិព្វាជិកោ ចិន្តេសិ ឯត្តកេនាបិ បណ្ឌិតស្ស កុណា ទាកជា ន ហោន្តិ សកលនគរាសីនំ មជ្ឈេយេវ សាកវបិដ្ឋេ អាសិត្តតេលំ វិយ វិប្បតិវណ្ណំ បណ្ឌិតស្ស កុណោ ទាកដេ ករិស្សន្តីតិ ភជាំ គហេត្វា ទាសានា ឱរុយ្ហ ភជ្ជណោ អាសនំ បញ្ញាបេត្វា តត្ថ និសីទិត្វា ទាករេ សន្និទាតាបេត្វា បុន ភជាំ អាទិតោ បដ្ឋាយ ទការក្ខសរូបញ្ចំ បុច្ឆិត្វា តេន ហេដ្ឋា កថិតនយេនេវ កថិតការេ ទាករេ អាមន្តេត្វា អាហ ។

លំដាប់នោះ នាងកើរបរិព្វាជិកា គិតពិចារណាថាដូច្នេះ វ៉ែគុណចៅមហាសេដ្ឋអ្នកប្រាជ្ញនេះ ប្រាកដអស្ចារ្យនេះហាន៎ គុណចៅមហាសេដ្ឋនោះ ទំនងឮប្រាកដខ្ញុំចៅអស់អ្នកធំនៅក្នុងព្រះនគរនេះ ជ្រួតជ្រាបជាពហៅ ដូចអ្នកប្រុចនូវប្រេង ប្រាយកយលើទឹងនៃមហាសមុទ្រត្រជាក់ អញនេះ ទំនងធ្វើគុណជាលំដាប់ចៅមហាសេដ្ឋប្រាកដការនោះហាន៎ម្ល៉ះហើយ នាងឲ្យក្រាលនូវកំពាលអាសនាកណ្តាលមុខព្រះលានស្តេចស្រេចហើយ ទើបឲ្យអញ្ជើញព្រះមហាសត្វចុះមកអំពីលើប្រាសាទស្ថានល្អ ហើយមកគង់លើកំពាលអាសនា ដ៏ខ្ញុំអស់មហាជនផងពាំនាំឡាយ នៅក្នុងព្រះនគរនោះ លុះមកជុំគ្នាហើយ ទើបនាងដណ្តើង

ប្រស្នាខគកក្ខសូនីឯស្តេចចុឡនី ចាប់ដើមអំពីនាយវិញទៀត ដូចបានសំដែងអំពីដើមនោះមកហោង កាលនោះ ព្រះបាទព្រហ្មទត្តកាដស្តេចឡើយប្រស្នានឹងនាងកេរីបរិភ្លាដិកានោះ ដោយខ្លះដំណើរនិយាយឡើយដូចអំពីកាលមុនរៀងមកនោះហោង អស់អ្នកផងចាំងខ្លាយស្រដីផងគ្នាសូត្រជាបទគាថាដូច្នេះ :

ឥទំ សុណាថ បញ្ចាលា ចុឡ្លនេយ្យស្ស កាសិតំ
បណ្ឌិតំ អនុរក្ខន្តោ ចាណិំ ចជតិ ខុទ្ទជំ ។
មាតុ កវិយាយ កាតុ ច សទិសោ ព្រាហ្មណស្ស ច
អត្តនោ ភរិយ បញ្ចាលោ ឆន្នំ ចជតិ ដិវិតំ ។
ឃំ មហាតុយា បញ្ញា ជិបុណា សាធុចិន្តិនី
ទិដ្ឋធម្មហិតត្ថាយ សម្បរាយ សុខាយ ចាតិ

បញ្ចាលា ភៃគ្នាយើង អ្នកបញ្ចាលនគរចាំងខ្លាយអើយ ! ចូរស្តាប់ខ្លះអំពើនេះ រីស្តេចចុឡនីពាជអម្ចាស់យើង ស្តេចបន្ទូលថា រក្សាចៅមហោសថ ស៊ូចង់ជីវិតអាត្មាព្រះអង្គឯង ឲ្យគកក្ខសូរាធតាងចៅមហោសថអ្នកប្រាជ្ញនេះ ភៃអ្នកបញ្ចាលនគរអើយ ! ស៊ូចង់ជីវិតអ្នកចាំង ៦ឯង មួយតីម្ចាយស្តេច មួយតីព្រះអគ្គមហេសីស្តេច មួយតីបួនស្តេច មួយមិត្តសំឡាញ់ មួយព្រាហ្មណ៍បុរោហិត មួយអាត្មាស្តេចឯងនោះ ហេតុនឹងខ្ចីប្រាជ្ញាចៅមហោសថប្រាកដ តាត់ចានអាថ៌ប្រស្នាខ្លះលាក់លៀម

កំចាំងប្រពៃក្រៃពេក ឯវំ ខ្ញុំប្រការដូច្នេះ ហេតុនាត់ធ្វើប្រយោជន៍ឲ្យ
អស់លោកផងទាំងពួយ ដោយខ្ញុំយោចលាំអាត្មា យល់អាចនឹងមិប្រ
សើរ តែងនឹងជាសុខ ព្រោះខ្ញុំជាឥតប្រាជ្ញហោង ។

ឥតិ សា រតនឃរសុត្ត មណិកុណ្ឌលេន កុដិ
កណ្ឌិត្ត វិយ មហាសត្តស្ស កុណោហំ ធម្មទេសនា
កុដិ កណ្ឌាតិ រតនឃរវិញ្ញាដិកា កាន់ទំាងខ្ញុំតំណូលធម្មវិសេស
ទេសនា សំដែងអំពើគុណនៃព្រះមហាសត្វក្រយានៃយើង ហាក់ដូច
អ្នកនាំផ្ទះរតនប្រសើរមកមានតំណាត់កែវមណីរតនជាដំបូលហោង ។

ឧតរកុរុសុបប្បញ្ញោ ឯដ្ឋតោ ។ រនីងស្រដីអាចប្រស្នា
ឧតរកុរុស្ស នាងដីកេរិចវិញ្ញាដិកា ខ្ញុំលដណ្តឹងព្រះចុតុប្បន្នព្រហ្មឧត្តរជ
មិញ ស្រេចខ្ញុំប្រការអម្បាលនេះហោង ។

ឯដ្ឋតា ច សត្ថុសោ មហាឧម្មគ្គជាតកវណ្ណនា ។
រីយើងនឹងពណិនាសរសើរ ដោយខ្ញុំដំណើរអាចិចុចាយនិយាយអំពីមហា
ឧម្មគ្គជាតកនេះមិញ ស្រេចចរិបូណ៌ប្រុណ្ណះហោង ។

ឥតិ សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា សច្ចា
និ បកាសេត្វា ជាតកំ សមោធានេន្តោ . . .

សាធវោ ភៃសាធុសប្បុរសធនទាំងពួយអើយ ! កាលនោះ
ព្រះពុទ្ធក្រយាយើង ជាតិជាគ្រូទៅតាមនុស្សម្នាមហាជនទាំងពួយស្តេច

ទាំងពួងព្រះធម្មវិសេសទេសនា ជាសណ្តាប់អស់មហាជនចតុព្វិធបរិស័ទ ស្រេចហើយ ព្រះអង្គទ្រង់ក្រសោបព្រះហស្តទាំងពីរព្រះតំណើតជាតកនេះ ទ្រង់ព្រះបន្ទូលថា កិត្តកវៃ ម្នាលកិត្តកដ៏ចំឡែកឱ្យាយអើយ ! រីឯអញតថាគត កាលនៅជាតោធិសត្វនៅឡើយ មានប្រាជ្ញាពុំគាន់ពុំ ព្រះបារមីពុំគាន់ចាស់ អញតថាគតស្វែងរកប្រាជ្ញាសព្វគ្រប់ញាណ បានដង្ហាញប្រាជ្ញាអ្នកដទៃមិនតែឥឡូវនេះ សូម្បីកាលមុនឡើយ សឹងមានប្រាជ្ញាដូច្នេះហោង ព្រះអង្គបន្ទូលនូវប្រការនេះហើយ ទើបព្រះអង្គភ្ជុំជាតកនេះ ហើយទ្រង់បន្ទូលសូត្រនូវបទគាថានេះ :

កិត្តកវៃ ម្នាលកិត្តកដ៏ចំឡែកឱ្យាយអើយ ! រីឯអាចារ្យសេនកៈនោះសោត លុះវិលរឹងមក បានជាព្រះមហាកស្សបសម្ពោធិញាណហោង អាចារ្យបុក្កុសៈនោះ លុះវិលរឹងមក បានជាព្រះកោដ្ឋញ្ញតេជៈវិញហោង អាចារ្យតាមិន្ធនោះ លុះវិលរឹងមក បានជាអម្ពដ្ឋត្ថេរវិញហោង រីព្រះបាទបញ្ចាលបន្ទូនោះ លុះវិលរឹងមក បានជាព្រះអនុរុទ្ធត្ថេរវិញហោង រីអាចារ្យទេវិន្ទនោះ លុះវិលរឹងមក បានជាព្រះសោណទណ្ឌកត្ថេរវិញហោង អាចារ្យកេវដ្តព្រាហ្មណ៍នោះ លុះវិលរឹងមក បានជាព្រះទេវទត្តត្ថេរវិញហោង ឯសលាកាទេវីនោះ លុះវិលរឹងមក បានជានាងចូលនិន្នាថេរីកិត្តិវិញហោង អាចារ្យអនុកេវដ្តព្រាហ្មណ៍នោះ លុះវិលរឹងមក បានជាព្រះមោគ្គល្លានត្ថេរវិញហោង នាងបញ្ចាលចន្ទីនោះ លុះវិលរឹងមក បានជានាងយសសុន្ទរីកិត្តិវិញហោង នាងបក្ខី

សាវ័កានោះ ចេរវិលវិនមក ជានាងមល្ងំកាកំកុនវិញហោង ១ម្តង
ទេវីនោះ ចេរវិលវិនមក ជានាងគោតម៍កំកុនវិញហោង ព្រះជាទេវ-
ហាជនោះ ចេរវិលវិនមក ជាព្រះកាឡុទាយ៉ីត្តេរវិញហោង រីនាង
គេរីបរិព្វាជិកានោះ ចេរវិលវិនមក ជានាង១ប្បលុវណ្ណាថេរីកំកុនវិញ
ហោង រីសម្តេចព្រះវរជបិតាពោធិសត្វនោះ ចេរវិលវិនមក ជាព្រះ
ជាទស្រីសុទ្ធោទនមហារាជ ជាស្តេចធំប្រសើរហោង រីព្រះវរជមាតានៃ
ពោធិសត្វនោះ ចេរវិលវិនមក ជានាងសិរីមហាមាយាទេវី ដ៏ជាព្រះ
កន្ទុងវិថ្ងៃនៃព្រះដ៏មានបុណ្យឥឡូវនេះហោង រីនាងអមកទេវីនោះ ចេរវិល
វិនមក ជានាងតិម្ពាសុន្ទរីថេរីកំកុនវិញហោង ចៅតំកូណមន្ត្រីកុមារ
នោះ ចេរវិលវិនមក ជាព្រះឆន្នត្តេរឥឡូវនេះវិញហោង ចៅធនុសេ-
កុមារនោះ ចេរវិលវិនមក ជានាងហុលត្តេរវិញហោង រីសេតសោម
បណ្ឌិតនោះ ចេរវិលវិនមក ជានាងព្រះមហាគានន្ទត្តេរវិញឥឡូវនេះហោង
ព្រះជាតុឡ្ឍនីកជានោះ ចេរវិលវិនមក ជានាងព្រះមហាសារីបុត្តត្តេរ
វិញហោង រីចៅមហោសថអ្នកប្រាជ្ញបណ្ឌិតនោះសោត មិនគឺអ្នកដទៃបី
ត្រែនឹងព្រះតថាគត ជានាងព្រះសព្វញ្ញុតញ្ញាណ ជាតំនាក់នៃ
អស់ត្រៃត្រកតតាំង ៣ឥឡូវនេះហោង ។

កោ សាធកោ ភៃសាធុសប្បុរសផងតាំងឡាយអើយ! ចូរ
ស្តាប់ត្រាប់ត្រងរៀនយកព្រះជាតកនេះហោង ។

មហោសថបណ្ឌិតជាតកំ បញ្ចមំ និដ្ឋិតំ បតិត្រអើយ!
រីយើងនឹងស្រដីដំណើរដំណាលតាលព្រះពុទ្ធក្រយោយើង ស្តេចចាប់
យកនូវព្រះសម្ពតកំណើតជាពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមកេរបវ
ឈ្មោះព្រះមហោសថបណ្ឌិតជាតំរប់ ៥ ជាតិនោះមិញ ចប់ស្រេចនូវប្រការ
ពាំងអម្បាលនេះឯងហោង ។

ចប់

កន្ទុយខ្វៀនឆ្នាំងអាចរលាត្រង់វិញបានឬទេ?

វិចារណកថា

លោក ជេង-ជ្រើវ ខំពន្ធ

កន្ទុយឆ្នាំមានពីរបែប គឺកន្ទុយត្រង់ និងកន្ទុយខ្វៀន ។ ចំពោះកន្ទុយត្រង់ ខ្ញុំលើកទុក មិនយកមកដោះស្រាយក្នុងនេះ ខ្ញុំសូមលើកយកតែកន្ទុយខ្វៀន មកតវ៉ាណាដោះស្រាយ ។

សួរថា គេអាចធ្វើឲ្យរលៅជាត្រង់វិញបានឬទេ ឬវាកន្ទុយខ្វៀនឆ្នាំ?

ឆ្លើយថា បើតាមការពិសោធន៍ កន្ទុយឆ្នាំតែខ្វៀនហើយ មិនដែលឃើញប្រែទៅជាត្រង់វិញបានឡើយ ដ្បិតធម្មជាតិបានតាក់តែងមកដូច្នេះ ខឹងគាញឲ្យរលាត្រង់ស្អុតល្អដូចកន្ទុយឆ្នាជាទៃពុំបានទេ បើមិនពេញចិត្តអស់ត្រឹមក្របែលចោលប៉ុណ្ណោះ ។

សួរថា ឆ្នាចង់បានកន្ទុយខ្វៀនក្លែងក្លាំអីចឹងឬ ?

ឆ្លើយថា ចេតាមការយល់ ហើយបើឆ្នាជាមនុស្សវិញ ប្រហែលមិនពេញចិត្តនឹងកន្ទុយក្លែងក្លាំដូច្នេះទេ តែឥឡូវ មិនដឹងជាធ្វើដូចម្តេច បើធម្មជាតិបានតាក់តែង ធ្វើឲ្យគ្នាមកយ៉ាំងនេះហើយ មិនពេញចិត្ត តំ មិនដឹងតាត់ចោលទៅណា អ្ហ៎ះហើយឆ្នាកន្ទុយខ្វៀន ត្រូវតែអត់ទ្រាំរក្សាទុកនូវសភាពនេះរហូតទៅ ដូចជាមនុស្សដែរក្លែងដូច្នោះ ។

ចំណែកមនុស្សចិត្តខ្វៀនវិញ តើសភាពហ្នឹង ដុះចេញពីកំណើតមកដូចឆ្នាដែរឬយ៉ាំងណា ? ចំពោះរឿងនេះ ខ្ញុំយល់ថាចិត្តខ្វៀនពីកំណើត

ដូចគ្នាក៏មាន ចិត្តខ្វៀនដោយសារតែអារម្មណ៍ពីស្រាមកបំរះក៏មាន ។ យ៉ាងដូចម្តេច ចិត្តខ្វៀនពីកំណើត ? ត្រង់ចំនេះ គឺសំដៅយកគ្រួសារជាប្រមាណៈ មានគ្រួសារខ្លះ និយមប្រព្រឹត្តអំពើខ្វៀនជាហូរហែមក ម្ល៉ោះហើយ ឈាមខ្វៀននេះក៏ដោយមកកន្លងឈាមខាងក្នុងដែលជាហេតុធ្វើឲ្យខាងនោះ លុះធំឡើង ត្រូវតែពេញចិត្តនឹងអំពើខ្វៀននេះឯង ។ ម្យ៉ាងទៀត មេគ្រួសារខ្លះជាមនុស្សមិនយល់ការវែងឆ្ងាយ ចានប្រព្រឹត្តអំពើនេះនៅមុខកូនឬ ទម្លាប់កូនឲ្យធ្វើដូចខ្លួនឬក៏ត្រេកអរនឹងអំពើខ្វៀនកូន ម្ល៉ោះហើយ ក្មេងយកតម្រាប់តាមនឹងគេញចិត្តចំពោះអំពើនេះ ដោយយល់ថាល្អប្រសើរ ព្រោះក្មេងទុកដូចជាកញ្ចក់ តែងតែស្រូបយកបាតអ្វៅចំពោះមុខ បញ្ចូលមកទុកក្នុងខ្លួនជាធម្មតា លុះខ្លួនធំឡើង និស្ស័យខ្វៀននេះនៅដដែរជានិច្ច រកលះបង់មិនបាន ដោយហេតុបានធ្លាប់ប្រព្រឹត្តមកជាយូរយារណាស់ហើយ ។ មនុស្សខ្លះទៀត ចេញមកពីគ្រួសារស្មូតត្រង់ទេតែនិយមសេពគប់នឹងពួកតែមនុស្សចិត្តខ្វៀន អំពើខ្វៀននេះក៏ដិតជាមជាប់ក្នុងចិត្តហូតទៅ ។

សួរថា មនុស្សដៃទំពក់ ចិត្តខ្វៀននឹងគាចកែខ្លួនឲ្យបានល្អឡើងវិញបានឬទេ ?

ឆ្លើយថា បើតាមការយល់នឹងការពិតពិចារណា មនុស្សបែបនេះនឹងគាចកែបាន ក៏ដោយអាស្រ័យវិធានការដ៏លំបាកណាស់ ។ ហេតុដូច

ម្តេចក៏ពោលយ៉ាងនេះ ដ្បិតថា ចិត្តដែលបុគ្គលចាន់ហ៊ឹកហាត់ឲ្យបែរទៅរកអំពើខ្វៀនហើយ មិនងាយនឹងមកញ៉ ម៉ិនងាយនឹងបំពត់ បំបែរឲ្យវិលមករកបទល្អបានដោយងាយឡើយ ។ តួយ៉ាង ដូចអ្នកប្រព្រឹត្តដក់អាកៀនជនក្រមនេះ ទោះបីមានច្បាប់អនុញ្ញាតហាមក្រុមមិនឲ្យដក់ តំនៅតែឆ្នៀតលួចលាក់ដក់ ឬ លេបអាចន៍ជាដម្ងូតា ព្រោះមានមេដុះជាប់នៅខាងក្នុងខ្លួន ស្រេចនៅហើយ ។ ឯអ្នកចិត្តខ្វៀន តំមានសភាពដូច្នោះដែរ ។ តែទោះជាយ៉ាងនេះក៏ដោយ ខ្ញុំនៅតែមានសង្ឃឹមថាខ្វៀនចិត្ត មិនមែនដូចជាខ្វៀនឆ្អឹងឡើយ បើសាមីខ្លួនចង់ ហើយសាមីខ្លួនមានប្រាថ្នានឹងធ្វើខ្លួនឲ្យល្អ ដើម្បីនឹងជួយសង្គ្រោះនឹងស្រោចស្រង់ខាតុប្រទេស ក្នុងសម័យនៃការកែទម្រង់សេដ្ឋកិច្ច ដែលសម្តេចសហជីវិនទ្រង់ជាមេផ្តើមដឹកនាំនេះ មុខជានឹងអាចពត់ឲ្យរលត្រង់ទៅបាន មិនបាច់ចាំគាត់ចាស់ដូចគ្នាឡើយ ។

ចំពោះការពត់ចិត្តខ្វៀននេះ ត្រូវចាត់វិធានការដែរបណា ? តាមរយៈមល់ខ្ញុំ វិធានការមានបីបែប : ទី ១ ត្រូវបញ្ចូលកងឹតមូវិធីសិក្សាខ្លួវរបៀបបង្ហាត់ពត់ចិត្តយុវជន យុវតី ឲ្យយល់ខ្លួវអំពើថាតាមស្ថិតិការប្រព្រឹត្តអំពើខ្វៀន ទី ២ សូមឲ្យ ។ សារ៉ាប់ប្រជុំរវាងសហការីតាងមន្ទីរពាក់ព័ន្ធមួយ ។ ហើយចៅក្រសួងជាអ្នកពោលពន្យល់ពីការប្រព្រឹត្តអំពើខ្វៀនដែលនាំឲ្យសាមីជនចាត់តាមផង នាំឲ្យមាតុប្រទេសធ្លាក់ចុះក្នុងមហន្តរាយផង តែសូមឲ្យចៅក្រសួងមានអតីតភាពវិសុទ្ធ ទី ៣ បង្កើតច្បាប់ផ្តន្ទា

ទោសយ៉ាងធ្ងន់បំផុត ដែលសាមីខ្លួន ប្រព្រឹត្តអំពើទ្រឿនទោះ កាលបើដឹងហើយ ត្រូវតែញុះញង់ខ្លួនចាកអំពើទ្រឿន ដូចស្វាបមានត្រូវអណ្តាតក្តៅឆ្អន ។ បើអនុលោមតាមវិធានការដូចពោលខាងលើ ទោះខ្ញុំយល់ថាការកែទម្រង់សេដ្ឋកិច្ចនៃសម្តេចសហជីវិនជាអម្ចាស់ ប្រហែលជានឹងមានការកែចំរើនធាប់រហ័ស ដូចព្រះហរទ័យប៉ុនប៉ងជាតិតប្រាកដ ។ ចិត្តទ្រឿន បើតាមការពិចារណា មានច្រើនដំណាក់ : ដំណាក់បឋមវ័យ ដំណាក់មជ្ឈឹមវ័យ និងដំណាក់បច្ចិមវ័យ មិនខុសគ្នាពីទ្រឿនក្តៅតឡើយ មានឫស្សីជាដើម ។ ទ្រឿនទំពាំង អាចតត់ឲ្យត្រង់តែនឹងដៃបាន ទ្រឿនឫស្សីខ្ចី អាចតត់ឲ្យត្រង់បាន តែដោយវិធីពេលក្តៅឆ្អន ឯទ្រឿនឫស្សីចាស់ អាចតត់ឲ្យត្រង់បាន តែដោយវិធីពេលក្តៅឆ្អនបន្តែមទឹកស្ករ ហើយត្រូវយកចិត្តទុកដាក់ជាទំបំផុត បើមិនដូច្នោះទេ ត្រូវបាក់តែម្តង នេះបើយល់ថាឫស្សីចាស់នេះ មានប្រយោជន៍ណាស់នឹងរកដើមដទៃមកជំនួសមិនបាន ។ ខ្ញុំយល់ថា ឫស្សីមួយគុម្ព មិនមែនមានតែកញ្ចាស់ទ្រឿនក្មង់មួយដើមនោះឡើយ បើពិបាកតត់តេក គួរបណ្តាយទុកវាឲ្យទៅឈរដើងរហូតទៅ ទុះអ្វីដើមឯទៀត នោះបើទៅស្មើរបន្ទិច ក៏អាចផ្សំប្រើបណ្តើរទៅបាន កុំឲ្យតែកូនកូនតាំងទេសតេ ទេសឯង ជាតិសេស តាំងឲ្យចោកគាបជាតិ ។

(តមក)

អធិមទ្យមិ ក្រ.វិ. ក្នុងពាក្យខ្លះ ។

អធិមនិ ក្រ. ឱនទៅក្រៃលែង ពេញចិត្ត ចូលចិត្ត ។

អធិមន្តិ ក្រ. ត្បូងក្រៃលែង (ឈើភ្លើង) ។

អធិមាត្រមិ ក្រ.វិ. ដោយអធិមាត្រា ។

អធិយជ្ញ ឈ្មោះ. ការបូជាក្រៃលែង ។ គុ. ដែលមានការបូជាក្រៃលែង ។

អធិយជ្ញមិ ក្រ.វិ. ដោយអធិយញ្ញៈ ។

អធិយុជិ ក្រ ប្រកបក្រៃលែង ទទួលការៈ ។

អធិរយោធ ឈ្មោះ. ទាហានទ័ពស្រួច។

អធិរជនិ ក្រ.វិ ក្នុងពេលយប់ ។

អធិរថិ ទាហានរថ សារថី ។ ឈ្មោះនាយសារថី ជាសាហាយក្រៃជាទ ឬគរស្ត្រ ។

អធិរាជិ ឈ្មោះ. ស្តេចក្រៃលែង ចក្រពត្រ ។ ៣ ស្រី. ភារិនៃអធិរាជ ។

អធិរាជ្យ នបុ. អធិរាជ្យ ។

អធិរុក្ខមន្ទិរគភិក្យម ក្រិ.វិ. តាមបង្ហូចនៃព្រះមន្ទីរជាវិការៈនៃមាស ប្រៃលែង ។

អធិរុហ ឡើងប្រៃលែង នៅលើប្រៃលែង ជាប់ប្រៃលែង ជំឡើងជំប្រៃលែង (ធ្នូ) ។ រូប គុ. ដែលស្ថិតនៅ ។

អធិរុហិ ន.ន. អ្នកដឹះប្រៃលែង អ្នាដឹះសេះ អ្នកឡើង (ដើមឈើ) រុហ. គុ. ដែលឡើង ។

អធិរូឍិ ស្រ. ការឡើង ការឡើង ។

អធិរោឍវ្យ គុ. ដែលគប្បីឡើង ។ នបុ. វិ. . . ធ៌បុគ្គលគប្បីឡើង ។

រឿងសាមកុក

ទុកញ៉ាំវិបុលភជសេនា ឬ-កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃ្លុំសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទំនៃបេះទជាយកលប់ណាន
ទាំងមានសន្តានស្នេហាជាតិ ។
——— ឃ្យុះ-អ៊ុន ———

យើមផៅឮដូច្នោះក៏និយាយហាមឃាត់ថា ខ្លៅដៀនទំនងលោកកំ ជាសត្រូវនឹងគ្នា ដែលថាមក ព្រោះការៈខាលខ្លួនហើយ មួយទៀត ការ ត្រង់នឹងវៀចនោះ ក៏ពាក់កណ្តាលម្ខាក់ ក្រែងថា ធ្វើការនោះសម្រេច ហើយ ទឹងប្រែត្រឡប់មិនព្រមឲ្យអាណាខេត្តមកវិញ ទឹងមិនបង់កម្ងាន ខទេឬ សុំលោកកុំអាលដឿស្តាប់ពាក្យសំដីខ្លៅដៀងនោះសិន ។ ខណៈនោះមាំឈៀកក៏ជំរាបទៀវឡាថា ខ្ញុំបាទបានមកប្រស្រ័យពីងបុណ្យ លោក ក៏ទៅមិនទាន់បានធ្វើការអ្វីតបស្នងសងគុណសោះ ឥឡូវខ្លៅតី លើកកងទ័ពមកវាយបានដំបន់ហៃប៉ាំងគួន ដែលជាតួយសំខាន់របស់ស្រុក សៃឈួនហើយ វេលានេះខ្ញុំបាទនឹងសុំយកតាសាលើកទាហានទៅធ្វើ ការឡាំងចាប់យកខ្លួនខ្លៅតីសម្លាប់ចេញ នោះខ្លៅដៀងចៅហ្វាយស្រុក

សែឈួនខ្ញុំមានសេចក្តីត្រេកអរ គង់ខ្ញុំលើកអាណាខេត្តដែលឡើង ២០ ដំបន់ ជូនលោកជាកំណាន់មិនខាន ខៀវឡឹងដូច្នោះក៏ត្រេកអរណាស់ និយាយខ្ញុំអ៊ុយគួនថា ឲ្យស្រុកត្រឡប់ទៅច្រាប់ឡៅដៀងចុះ ថាយើងត្រូមជួយធុរៈទោ ត្រាតែអស់កម្លាំង អ៊ុយគួនកំលោះខៀវឲ្យត្រឡប់ទៅវិញ ។

ខណៈនោះ ខៀវឡឹងតាំងហាន ២ ម៉ឺនឲ្យអៀវប៉ែកកាន់តាប់ទៅជាមួយខ្ញុំមាំឈ្មោះ តែវេលានោះ ចាំងតែកមានធុរៈឈឺ មាំឈ្មោះក៏ចាត់ឲ្យមនុស្សទៅពិគក្តីក្បែក្នុងស្រុកហ៊ីនតុង លុះបានបួកជោគល្អ មាំឈ្មោះខ្ញុំមាំតាយជាប្អូនក៏លើកកងទ័ពចេញពីស្រុកតម្រង់ទៅគយហែជាំងគួន។

ឯឡៅពី កាលតាំងទៅក្នុងស្រុកឡុកសៀ ហួតចេងក៏ច្រាប់ឡៅពីថា ខ្ញុំបានឲ្យសំបុត្រសម្គាត់ទៅដល់តាហានស្រុកសែឈួន ដើម្បីខ្ញុំឲ្យធ្វើជាកលសឹកខាងក្នុង នោះអ្នកកាន់សំបុត្រត្រឡប់មកច្រាប់ខ្ញុំបានវិញថា តែតទីប្រឹក្សា ប្រើតាហានចេញទៅដុតស្បៀងអាហាររបស់អ្នកស្រុកក្រៅ ហើយកៀរគ្រួនាំធ្វើស្ទឹងប៉ុយស៊ុយមកឲ្យដុតសត្រូ ហើយបង្គាប់តាហានដែលទៅរក្សាគយឲ្យទៅត្រួតត្រារក្សាបន្ទាយកុំឲ្យចេញតច្បាំង ឡៅពីខ្ញុំចេងដឹងដូច្នោះក៏ភ័យណាស់ថា កាលតែតឲ្យឡៅដៀងធ្វើដូច្នោះ តើយើងខ្ញុំគិតប្រការម្តេចទៅវិញ ? ហួតចេងថា តែតនោះមានតម្រេះរិះគិតចំណានណាស់ ប៉ុនប្រសប់ខាងការល្បួងបញ្ឆោតត្រប់ប្រការ តែខ្ញុំបានយល់ឃើញថា ឡៅដៀងមិនត្រមធ្វើតាមទេ លុះតន្ទួងមកបានមួយថ្ងៃ

មានចំរើមកប្រាប់ឡៅតាថា ឡៅដៀងមិនបានធ្វើតាមតែតទេ ។

ឡៅតាឮដូច្នោះកំសោយសេចក្តីព្រួយ ទុំងបេងក៏ប្រឹក្សាទំងឡៅតាថា ចាំយើងតែលើកទ័ពទៅកាយស្រុកតំមកុក បើបានហើយក៏តង់ទីងបានស្រុកសែឈួនដោយងាយ ឡៅតាយល់ឃើញត្រូវ កំចាត់អ៊ុយអៀនទំងហាងតុងលើកទាហានចេញទៅ ជាកងមុខ ឡៅតាទំងទុងបេង ជាកងហ្លួងលើកទៅតាំងនៅដែនស្រុកតំមកុក ឯអ៊ុយហ៊ិនចៅហ្វាយស្រុកតំមកុកដំងកំចាត់ឲ្យលីយៀមលើកទាហាន ៣ ពាន់ ចេញទៅបានច្បាំងគ្នានឹងហាងតុងបាន ៩០ ភ្លេង មិនអានចាញ់ឈ្នះគ្នា ទុំងបេងឃើញដូច្នោះ កិរាយឃ្មោះប្រាប់ទំងឲ្យហាងតុងវិលមកវិញ ហាងតុងឮសម្តេងឃ្មោះក៏នាំទាហានត្រឡប់មកវិញ ហើយសួរទុំងបេងថា ខ្ញុំបាទបានការនឹងចាប់ខ្លួនលីយៀមបានហើយ ហេតុម្តេចក៏សោកកាយឃ្មោះហៅដូច្នោះ ។

ទុំងបេងថា ត្បិតលីយៀមនោះមានកម្លាំងខ្លាំងពូកែណាស់ ដែលអ្នកនឹងច្បាំងតយកដំយដំនះតាមកម្លាំងតែម្តងមិនបានទេ បានជាយើងឲ្យកាយឃ្មោះហៅត្រឡប់មក ប្រាប់ទំងធ្វើកលបាយយកដំយដំនះវិញ ក្នុងពេលយប់ថ្ងៃនោះ យើងត្រូវចាត់ទាហាន ២ កងឲ្យទៅពួនបង្កប់ទៅតែត្បូរផ្លូវច្រកភ្នំ ដល់ព្រឹកស្អែកអ្នកចេញទៅច្បាំង ឲ្យធ្វើជាចំយរត់មកក្រោយ ចូលទៅតាមច្រកភ្នំនោះ លីយៀមតង់ទំងដេញតាមទៅ កាលណាមើលលីយៀមដេញហួសទៅហើយ ត្រូវឲ្យទាហានដែលពួនបង្កប់នោះកាយចូច

ចេញមកប្រសព្វគ្នា មុខជានឹងបានជ័យជំនះដោយងាយ ។ ហង្សតុង
យល់ឃើញត្រូវ លុះពេលយប់ក្នុងវិថីនោះ ខ្ពង់ចេងក៏ឲ្យអ៊ុយអៀនលើក
ទាហានទៅស្នាក់នៅក្បែរមាត់ផ្លូវ ហើយចាំបែកទាហាន ២ កងទៅបង្កប់
នៅច្រកភ្នំ ។ លុះវេលាត្រឹកហង្សតុងដំរះសេះនាំទាហានចេញទៅ ។

ឯលីយៀមឃើញដូច្នោះ ក៏បរសេះចេញមកតប្បាំងនឹងហង្សតុងបាន ១០
ភ្លេង ហង្សតុងធ្វើជាចរយតេបណ្តែតឲ្យដេញទៅតាមច្រកភ្នំ លីយៀមមិន
ដឹងកល ក៏ចាំជាយសេះដេញតាមទៅដល់មាត់ផ្លូវច្រកភ្នំ ខ្ពួលនឹកឃើញ
ក្រែងសត្រូវបង្កប់ទាហានចាំនៅទីនោះ ក៏ញាក់សេះត្រឡប់ថយមកវិញ
ឃើញអ៊ុយអៀនលើកទាហានស្នាក់ពីមុខច្រើនណាស់ លុះនឹងរត់ទៅខាង
ណាក៏មិនរួច ។ ខណៈនោះខ្ពង់ចេងឡើងទៅលើកំពូលភ្នំ ស្រែកចុះមកថា
លីយៀម ចូរប្រញាប់មកចំណុះចុះចូលយើងដោយល្អទៅ បើមិនស្តាប់
យើង ។ នឹងទាហានដែលបង្កប់សងខាងផ្លូវ ជាញាំនឹងធ្វើឲ្យស្លាប់ឥឡូវនេះ ។
លីយៀមឮដូច្នោះក៏ភ័យ ណាស់តែថា ខ្ញុំនអញទៅក្នុងចំណោមដំបងដ្បឹត
ដូច្នេះ បើនឹងទំរាំនឹងគិតក៏មិនរួចជីវិត គួរតែនឹងចំណុះចុះចូលខ្ពង់ចេង
ទៅវិញជាជាង តែតហើយក៏លោតចុះពីលើសេះ ចោះអាវុធពីដៃដោះ
ក្រោះចេញ ហើយឡើងទៅតំនាប់ខ្ពង់ចេងទៅលើកំពូលភ្នំដោយល្អ ។

ខ្ពង់ចេងមានសេចក្តីត្រេកអរណាស់ ក៏នាំលីយៀមចូលទៅតំនាប់
ឡើងពីក្នុងបន្ទាយ ឡើងពីអង្គើញឲ្យលីយៀមបរិភោគអាហារហើយថា

យើងធ្វើការតាំងនេះ ប្រាថ្នាតែនឹងទំនុកបំរុងផែនដីឲ្យបានសេចក្តីសុខ អស់អាណាប្រជាជនប៉ុណ្ណោះ ។ លើយៀមក៏ធ្វើយថា អ៊ុយហ៊ូនោះជាបងប្អូនខ្ញុំដែរ ខ្ញុំបានឮនឹងលឺកការអ៊ូកំតែងដឿស្តាប់ជាយូរលាវនេះ ខ្ញុំបានបង្គំសុំលោកទៅនិយាយឲ្យអ៊ុយហ៊ូនមកចំណុះចុះចូលលោកឲ្យបាន ។ ឡៅពីឮដូច្នោះក៏ត្រេកអរណាស់ថា បើអ្នកតាំងចិត្តសុចរិតត្រង់នឹងយើងហើយ ក៏ត្រូវស្រួតត្រៃទៅនិយាយនឹងអ៊ុយហ៊ូនដោយល្អចុះ ។ លើយៀមតំនាងលាឡៅពី ទុនបេងនាំពាហនទៅដល់ស្រុកតិមកុក ជួបនឹងអ៊ុយហ៊ូនហើយក៏ប្រាប្រឌរឿងឲ្យអ៊ុយហ៊ូនស្តាប់ ហើយថាឡៅពីនោះមានចិត្តអស្សាស្រ័យមេត្រីស្រឡាញ់អស់អាណាប្រជានុកស្តួស្រួលណាស់ ដែលឡៅពីមកធ្វើការនេះ ប្រាថ្នាតែនឹងទំនុកបំរុងផែនដីឲ្យបានសេចក្តីសុះប៉ុណ្ណោះ ។ បើអ្នកមិនព្រមចំណុះទំនែងនឹងតាំងតស៊ូនឹងទៅ ស្រុកយើងក៏តន់តែអន្តរាយ យើងតាំងឡាយនឹងមិនរួចពីសេចក្តីស្លាប់ក្នុងកណ្តាប់ដៃគេឥតអំពើ ។

អ៊ុយហ៊ូនបានឮដូច្នោះ ក៏យល់ឃើញត្រូវផង ទើបនាំពាហនចូលទៅតំនាងឡៅពី ហើយសូមអញ្ជើញឡៅពី ទុនបេងចូលទៅក្នុងស្រុកឡៅពីទុនបេងអស់សម្ប៉ែកក៏នាំគ្នាចូលទៅក្នុងស្រុកតិមកុកអ៊ុយហ៊ូនក៏តែងតុរៀបអាហារលៀង អញ្ជើញឡៅពីនឹងទុនបេងនូវអស់សេនាពាហនតាំងប៉ុន្មានឲ្យបរិភោគអាហារ លុះលៀងរួចហើយ ឡៅពីក៏បានតែងតា

ហានទឹងលើកទៅស្រុកអេកដាវ ខ្លួលមានបំរើសេះមកប្រាប់ថា អង្គវៃ ខៀវឡេប្រើម៉ាឈៀវ ម៉ាតាយ អៀវប៉ែក លើកកងទ័ពមកច្បាំងនឹងលោក ឯបេងតាត់ទឹងហាក់ដុនដែលលោកឲ្យនៅរក្សាគយហៃចាំងគួននោះបានត តាំងច្បាំងគ្នាទៅហើយ វេលានោះ បើលោកមិនលើកពលទៅជួយឲ្យ ហើសទេ ខឹតយនោះទឹងខូចអស់ ខ្លៅពីព្រួដូច្នោះក៏ស្ងួតកងចិត្ត ទើប ប្រឹក្សាទឹងខុងបេងថា លោកទឹងរ៉ែតតប្រការម្តេច ? ខុងបេងថា ខ្ញុំបាន ឃើញតែខៀវហ៊ុយទឹងជួឡុង ២ នាក់នេះ ទើបទឹងតទល់កម្ងាំងបានទឹងម៉ា ឈៀវម៉ាតាយ អៀវប៉ែតនោះ ។

ខ្លៅពីថា ជួឡុងនោះប្រើឲ្យទៅបញ្ជុះបញ្ចូលមនុស្សតាមមាត់ទន្លេ ដែន ស្រុកតេងកាំង ក៏ទៅមិនទាន់ទឹងត្រឡប់មកវិញ នៅតែខៀវហ៊ុយ បើ ដូច្នោះ ត្រូវឲ្យលោកចាត់ចែងទាហាន ប្រើខៀវហ៊ុយឲ្យលើកទៅជួយឲ្យ ទាន់ការ ។ ខុងបេងថា លោកកុំអាលមានប្រសាសន៍ឲ្យខ្លួចខ្លាយសិន ទុកឲ្យខ្ញុំទឹងរ៉ែតតនិយាយទឹងខៀវហ៊ុយផង ។ ខណៈនោះ ខៀវហ៊ុយដឹង ដំណឹងថា ម៉ាឈៀវលើកទ័ពមកយកតយហៃចាំងគួន ក៏ស្រួតចូលទៅ ស្រុកប្រាប់ខុងបេងថា អង្គវៃម៉ាឈៀវលើកទ័ពមកច្បាំងនឹងបេងតាត់ ហាក់ដុនហើយ ខ្ញុំទឹងសុំគាសា ចេញទៅតស៊ូនឹងម៉ាឈៀវ ។ ខុងបេង ធ្វើជាមិនឮ ហើយក្លែងថាខឹងខ្លៅតិ ដើម្បីបញ្ជាចិត្តខៀវហ៊ុយថា ឯម៉ា ឈៀវមានកម្ងាំងទឹងច្បាំងភ្លៃកណាស់ ចាំសរសេរសំបុត្រឲ្យបំរើសេះ

យកទៅស្រុកកេងដ៏វែឡែគួនអ៊ូមក ទើបតកម្ចាំងនឹងមាំឈៀវបាន ។

ឈៀវហ៊ុយឮដូច្នោះទឹងណាស់ថា ខ្លួនខ្ញុំបានេះ កំមានប្រាជ្ញាស្មារតីនឹងថ្លៃដែរ គ្រាចូលលើកពល១០០ម៉ឺនតាមទៅប្រយុទ្ធគ្នាខ្លួនឯងឈឺងប៉ាន់ឥឡូវ ខ្ញុំបានកំបានច្បាំងតទល់បាន ហើយធ្វើឲបាយកលតាល់តែតាហានចូលធ្វើឋយវិលទៅវិញ ឯមាំឈៀវនេះនឹងមានប្រាជ្ញាស្មារតីខ្លួនថ្លៃដែប៉ុន្មាន បានជាលោកនឹកចំពោះទៅដល់លោកគួនអ៊ូតែម្ដង ។ ឱុងបេងក្លែងតបថា គ្រាចូលលើកពល ១០០ម៉ឺនតាមមក នោះអ្នកបានតទល់មែនតែលើសកម្ចាំងណាស់ ដែលអ្នកគិតកល ឲបាយឲ្យពលចូលធ្វើឋយទៅនោះហាក់តែសត្រូវមិនខាន់គិត បើចូលដឹងពីតកាលណាជីវិតអ្នកនឹងខ្លួច អ្នកកុំអាលប្រមាថមើលងាយឡើយ ព្រោះមាំឈៀវនេះមានថ្លៃដែខ្លាំងក្លៃកណាស់ កាលច្បាំងនឹងកងទ័ពចូលទៅដំបន់ស្ទឹងមាសុីយនោះ ចូលចាញ់ប្រៀបជាច្រើន ពាល់តែងោះក្រោះ កាត់ពុកមាត់ ចូលទៅពួនព័ទ្ធបង្ខំនឹងកូនពាហាន ទើបចូលរត់រួចពីមាំឈៀវទៅបាន ។

ឈៀវហ៊ុយថា បើលោកនូវមន្ទិលសង្ស័យ ខ្ញុំបានទឹងសុំធ្វើសញ្ញាពុក បើខ្ញុំបានលើកពលទៅមិនបានជ័យជំនះលើមាំឈៀវទេ សូមឲ្យគាត់ក្បាលខ្ញុំបានចេញចុះ ។ ឱុងបេងថា បើត្រមនខ្លួលដូច្នេះមែន យើងក៏ល្មមពុកចិត្តបាន ឈៀវហ៊ុយក៏សរសេរសេរសញ្ញាពុកឲ្យឱុងបេង ។ អ៊ុយអៀនថា ខ្ញុំបានទឹងសុំទៅនឹង ឱុងបេងក៏ឲ្យអ៊ុយអៀនលើកពាហាន

៥០០ ជាកន្លះ ឲ្យខៀវហ៊ុយជាកន្លះក្បាល ខ្លៅពីជាកន្លះក្រោយ ហើយ
ខ្លួនបែងចែកបខ្លៅពីថា ខ្ញុំនឹងនៅជួយក្សាស្រុកគឺមកុកសិន បើជួបឡួង
មកដល់វិលាណា នឹងនាំគ្នាលើកតាមក៏ ។ ខ្លៅពីខៀវហ៊ុយ អ៊ុយ
អៀន ក៏លើកកន្លះពីក៏ដល់តយហែជាំងគួន ហើយកំឲ្យគាំងបន្ទាយនៅ
ទីជិតតយនោះ ។

ម៉ាឈៀវក៏ឲ្យអៀវប៉ែក បរសេះចេញមកចំប្លាងនឹងអ៊ុយអៀនបាន ១០
ភ្លេង អៀវប៉ែកតកម្ងាំងនឹងអ៊ុយអៀនពុំបាន ក៏ញាក់សេះថយរត់ អ៊ុយ-
អៀនមានចិត្តកំរើបដោយបងំបានសេចក្តីគាប់ប្រសើរ ក៏បរសេះដេញតាម
ក៏ដួចនឹងម៉ាតាយស្លាក់ពីមុខ អ៊ុយអៀនសំគាល់ថាម៉ាឈៀវ ក៏បរ
សេះកំជាវៀចូលចំប្លាងម៉ាតាយបាន ១០ ភ្លេង ម៉ាតាយធ្វើជាញាក់សេះរត់
អ៊ុយអៀនបានចំនួនស្រួល ក៏បរសេះដេញតាមក៏ ម៉ាតាយបែរមុខមក
វិញ ជាញ់នឹងធ្នូត្រូវស្មាអ៊ុយអៀន ។ ក៏ញាក់សេះថយមកវិញ ម៉ាតាយ
ក៏ដំជាយសេះតាមក៏មុខបន្ទាយ ខៀវហ៊ុយឃើញក៏បរសេះពីបន្ទាយ
ក៏ស្លាក់ចំមុខហើយស្រែកគំហកឲ្យម៉ាតាយ អ៊ុយអៀនក៏រត់ចូលបន្ទាយ
បាន ។ ខៀវហ៊ុយសួរថា អ្នកនេះឈ្មោះអ្វី ? ទើបហ៊ានដេញអ៊ុយអៀន
មកដល់មុខបន្ទាយ ធ្វើយឲ្យទាប់នឹងបានតស៊ូគ្នាឲ្យឃើញថ្ងៃដៃ ។

ម៉ាតាយធ្វើយ យើងឈ្មោះម៉ាតាយប្អូនម៉ាឈៀវនៅស្រុកសែសឡែង
ខៀវហ៊ុយថា ខ្លួននេះមិនគួរមកចង់ប្លុងដៃនឹងយើងទេ បើនឹងតស៊ូចំប្លាង

គ្នាឥឡូវនេះ ខ្លួនក៏ត្រូវស្ងាប់ឥតអំពើ យើងខុកជីវិតឲ្យខ្លួនៗ ចូរត្រឡប់ទៅប្រាប់ម៉ាឈៀវឲ្យចេញមកច្បាំងនឹងយើងទើបគួរ ម៉ាតាយបានស្តាប់ដូច្នោះ ក៏ខឹងខ្លាំងណាស់ ទើបបរសេះចូលទៅច្បាំងនឹងខ្មៀវហ៊ុយបាន ១០ ក្នុង ម៉ាតាយលះកម្លាំងនឹងខ្មៀវហ៊ុយពុំបាន កំញាក់សេះរត ខ្មៀវហ៊ុយឃើញបានការដេញតាមទៅ ។ ខ្មៅតាឃើញដូច្នោះក៏ហៅឃ្លោះខ្មៀវខ្មៀវហ៊ុយបានឮកំញាក់សេះត្រឡប់មក ខ្មៅតាថា បងដឹងចិត្តថៅមើរីរណាស់ ខ្លាចដេញសត្រូវទៅឆ្ងាយមានអន្តរាយ ឲ្យបងហៅឃ្លោះឲ្យត្រឡប់មកវិញ មួយទៀតថៅក៏មានជ័យជំនះម៉ាតាយហើយ គួរនឹងយកឫក្សខុកម្តងទៅចុះ ចូរឈប់ឲ្យមានកម្លាំងសប្បាយ ព្រឹកស្អែកសឹមចេញច្បាំង ។

លុះព្រឹកឡើង ខ្មៅតាបានឮសម្លេងតាហានស្រែកហោគគឹកកងមកដល់មុខបន្ទាយច្រើនណាស់ ខ្មៅតាក៏ឡើងលើសែនបន្ទាយតាហានចង្អុលបង្ហាញឲ្យឃើញម៉ាឈៀវ ។ ខ្មៅតាឃើញរូបម៉ាឈៀវម៉ាមួនសមជាតាហាន មុខដូចពណ៌ជាតិហិង្គុ ពាក់គ្រោះក្រាត់ ដិះសេះកាន់លំពែងទៅកណ្តាលពល ហើយសំឡឹងមើលថាបណ្តាមនុស្សទាំងពួងនិយាយល្បីឮថាម៉ាឈៀវមានរូបល្អ ក្លាហានក៏សមដូចពាក្យគេថា ខ្មៀវហ៊ុយឃើញ ម៉ាឈៀវលើកពលមក ក៏និយាយនឹងខ្មៅតាថា ខ្ញុំបាទនឹងសុំអាសាចេញច្បាំងនឹងម៉ាឈៀវ ខ្មៅតាថា ប្អូនឯងកំអាលសិន ត្រូវបង្អង់ទៅក្នុងបន្ទាយចាំមើលកលការ បើឃើញតាហានអត់អាហារហួសវេលា សឹមចេញទៅ

ជ្រាងចុះ ។

ឯម៉ាឈៀវ មិនបានយើញឡៅពីលើកខាហានចេញមកជ្រាង ក៏ឲ្យខាហានទៅស្រែកដៀមជាមជាពាក្យគ្រេគោះ ខ្មៀវហ៊ុយឮដូច្នោះខឹងណាស់ ដូចនឹងអណ្តែតខ្លួនចេញទៅស៊ីសាច់ម៉ាឈៀវឲ្យអស់តែម្តង តែនៅខ្លាចឡៅតីណាស់ ទើបទំអត់សង្កត់ចិត្តទុក ម៉ាឈៀវមិនបានយើញអ្នកឯណាធ្វើយតបចេញមក ក៏ឲ្យទ្វាស់គ្នាចូលទៅស្រែកឡកចំអកដេរគ្រេគោះជាពាក្យអសុរោះផ្សេង ។ គាល់តែថ្ងៃរសៀល ឡៅពីយើញម៉ាឈៀវអត់អាហារអស់កម្លាំងចុះហើយ ក៏ចាត់ខាហាន ៥០០ ឲ្យខ្មៀវហ៊ុយចេញតាក្នុងបន្ទាយទៅ ម៉ាឈៀវយើញខ្មៀវហ៊ុយចេញមកក៏មានអំណរណាស់ ទើបបក់ខន់ឲ្យខាហានថយមក ខ្មៀវហ៊ុយយើញដូច្នោះ ក៏បរសេះចេញទៅមុខខាហានហើយស្រែកថា ខ្លួនអញ្ជើះឈ្មោះខ្មៀវហ៊ុយ ម៉ាឈៀវឯងមិនស្គាល់ដៃអញខេឬ ? ។ ម៉ាឈៀវស្រែកតបថា ខ្លួនអញជាតូជនាម៉ឺនមកជាច្រើនតមកហើយ ធ្វើម្តេចអញនឹងស្គាល់ឯង ដែលជាជាតិស្រុកស្រែក្រៅខុរយសខោះ មិនសមគួរ ។

ខ្មៀវហ៊ុយឮដូច្នោះក៏ខឹងណាស់ បរសេះចូលប្រយុទ្ធគ្នានឹងម៉ាឈៀវបាន ១០០ ក្បួង ក៏នៅមិនទាន់ចាញ់ឈ្នះគ្នា ។ ឡៅពីយើញដូច្នោះ ក៏គន់សំឡឹងមើលថ្ងៃដៃខ្មៀវហ៊ុយនឹងម៉ាឈៀវហើយថា អ្នកចម្បាំង ៤ នាក់នេះ រួសរហ័សណាស់សមជាខាហានខ្លា តែគិតក្រែងថា ខ្មៀវហ៊ុយនឹង

ភ្លាត់ភ្លាំង កំភយឃ្មោះសញ្ញាឲ្យថយត្រឡប់ចូលបន្ទុយខៀវហ៊ុយឮសម្លេង
ឃ្មោះ កំដោះថយវិលមកហើយ ដោះគ្រោះចេញ ឈប់សម្រាកមួយ
ស្របក់ ក្រោះគ្មានពាក់ ឡើងសេះត្រឡប់ចេញទៅខៀត ស្រែកដៀម
ជាមឲ្យម៉ាឈៀវជាពាក្យអសុរោះគ្រោះ ។ ម៉ាឈៀវទើណាស់ គឺបរ
សេះចេញទៅប្រយុទ្ធគ្នាខ្លីនខៀវហ៊ុយម្ខាងខៀត ស្មៀតអាវុធគឺប្រតិតជាប់
គ្នាជាសន្ធឹកសន្ធាប់ណាស់ ។

ឡៅតិតវិតក្រែងខៀវហ៊ុយថ្ងូសការ គឺពាក់ក្រោះឡើងសេះទៅឈរ
ខៅមុខទាហាន ឃើញខៀវហ៊ុយខ្លីនម៉ាឈៀវក្បាំងគ្នាប្រហែល ១០០
ក្បែង កំភយឃ្មោះហៅខៀវហ៊ុយឲ្យត្រឡប់វិលវិញ ឡៅតិខិយាយថា ចង
ក្រែងចៅខឿយណាស់ ចានជាភយឃ្មោះឲ្យវិលមកឈប់សម្រាកសិន
ខៀវហ៊ុយថា ខ្ញុំចាខចានចេញមាត់ខលួសអាសាធ្វើការផ្លូនលោក ដើម្បី
ខឹងយកជ័យដំនះលើម៉ាឈៀវ ឥឡូវខៅមិនទាន់ពញ្ជាឈ្នះសោះ លុះខឹង
ឈប់ខខេកិនាំឲ្យខាតវេលា ហើយខៀវហ៊ុយកិនាំធ្មេញញញមុខខឹងចង់
ចេញទៅប្រយុទ្ធគ្នាម្ខាងខៀត ឡៅតិកិខិយាយហាមឃាត់ខៀវហ៊ុយថា
តេលាថ្ងៃខេះក៏ល្ងាចណាស់ហើយ ត្រូវឲ្យចូលទៅឈប់សិនចុះ ព្រឹកស្អែក
សឹមចេញទៅតស៊ូគ្នាម្ខាងខៀត ខៀវហ៊ុយថា ខ្ញុំចាខមិនចូលទៅខេ បើ
លោកឃើញថា យប់ងងឹតហើយ កំត្រូវអុជនប់ភ្លើងឡើង ខ្ញុំចាខខឹង
ចេញទៅក្បាំងខឹងម៉ាឈៀវត្រាតែចានជ័យដំនះ ។

(ខៅមានត)

រឿងល្បែកឡាហ្គុងតែន

លោក ដេង - ដ្រីវ ប្រែរៀបរៀង

៩០ បបរកន្ធឹងចៀម

ប្រហែលមួយពាន់ឆ្នាំកន្លងទៅ បបរកបានធ្វើសន្ធិភាពជាមួយនឹងចៀម ហើយកំឈប់ប្រកាសសង្គ្រាមរវាងគ្នានឹងគ្នា ។

រឿងនេះ ជាសុភមង្គលតែអាការខាងស្រុក នៃបក្សទាំងពីរប៉ុណ្ណោះ គឺតថា បើបបរកស៊ីចៀមអស់ច្រើន អ្នកគង្វាលក៏បានយកសែ្បកបបរជាច្រើន មកធ្វើជាអាវពាក់ដែរ ។

ពួកចៀមក៏គ្មានសេរីភាព ពួកបបរក៏ដូចគ្នាដែរ គឺថាបក្សទាំងពីរប្រើសុភមង្គលនៃខ្លួន ដោយមានការព្រួយបារម្ភជានិច្ច ។ ដូច្នេះ ដើម្បីសម្រេចឲ្យមានសន្ធិភាពឡើង គេត្រូវប្តូរល្បិចយុទ្ធសង្គ្រាម រវាងគ្នានឹងគ្នា ។ ឯល្បិចយុទ្ធសង្គ្រាមគឺបបរកនឹងកូនបបរក ចៀមនឹងកែ្ច ។ ការប្តូរនេះ អនុវត្តទៅតាមទំនៀមទម្លាប ដោយមានអ្នកស្ម័គ្រការជាអ្នករៀបចំសម្រួល ។

តាំពីនោះមក មិនឃើញប៉ុន្មាន កាលដែលកូនបបរកមានវ័យពេញវ័យក៏ដឹង ជាបបរកមែនទែន បរិបូណ៌ដោយកម្លាំង ហើយស្រែកហ្វាន់តែសាច់ឈាម រាត្រីតនៃកាលដែលពួកអ្នកគង្វាលមិនទៅ ក៏ចូលទៅក្នុងតណ្ឌាលហ្វូងចៀម ទាំកូនចៀមយ៉ាងឆាត់ ។ ឧស្ម័ចំនួនពាក់តណ្ឌាល

រហ័យតាំងនាំយកទៅកន្លែងត្រៃធ្វើជាអាហារ វាបានឲ្យដំណឹងសម្ងាត់នេះដល់គ្នាវា ។ ចំណែកឯឆ្កែដែលឈប់សម្រាកឥតត្រែងអ្វី ដោយឆ្អែតទៅលើដំណើរសន្ទិសញ្ញាសន្ធិភាព ក៏ត្រូវពួកចចកទាំងអស់ហូបកំពុងដេក អស់គ្នាទាល់ ។ រឿងនេះ ពួកចចកធ្លាប់ហ៊ានតែឆ្កែដ៏ធំមិនខាន់ ម្ល៉ោះហើយទាំងអស់ត្រូវស្លាប់ខ្លួចខ្លី គ្មានឆ្កែណាមួយរួចខ្លួនឡើយ ។

អំពីដំណើរនេះ យើងអាចសំរេចបានថា ត្រូវតែប្រយុទ្ធជាមួយនឹងប្រធាន៏ធំអ្នកតំណាង ។ សន្ធិភាព ជាការប្រពៃណាស់ ចំពោះខ្លួនខ្ញុំយល់ស្របតាម តែយកសន្ធិភាព មកប្រើជាមួយសត្រូវគ្មានដំណឿតើមានប្រយោជន៏អ្វី ? ។

៨១ - អ្នកគង្វាលបៀមនឹងសមុទ្រ

អ្នកអាស្រ័យនៅក្បែរសមុទ្រម្នាក់ជាយូរមកហើយ តែងពេញចិត្តនឹងការចិញ្ចឹមដំរីតស៊ូរបស់គាត់ ហើយគាត់រស់នៅ ដោយគ្មានសេចក្តីទុក្ខព្រួយឡើយ ។ បើកោគទ្រព្យរបស់គាត់តិចតួច ក៏គង់ជាទ្រព្យមានសភាពឯងខាត់ ។

ទៅថ្ងៃចុងក្រោយ ទ្រព្យសម្បត្តិចាំងឡាយ ដែលគេរកបានតាមផ្លូវសមុទ្រ បានញាំងចិត្តគាត់ឲ្យក្តួចកាន់ចង់បាន ទាល់តែគាត់លក់ហូងចៀម យករ៉ូកមកធ្វើដំនួញតាមសមុទ្រ ។ ឯរ៉ូកនេះក៏ដល់នូវសេចក្តីវិនាសដោយការលិចលង់ ។ គាត់ត្រូវវិលមកជាអ្នកគង្វាលវិញ ហើយ-

មិនមែនជាអ្នកតង្វាលនាយកដូចលើកមុនទេ គឺជាអ្នកតង្វាលស៊ីឈ្នួល ។ មិនយូរប៉ុន្មាន ដោយការខំសន្សំប្រាក់ខ្លះ គាត់ត្រឡប់ទិញបានចៀមឡើងវិញ ។

ថ្ងៃមួយ មានខ្សល់បក់មក ធ្វើឲ្យចៀមស្រួលខ្លួន ចៀមក៏នាំគ្នាដើរចុះទៅមាត់សមុទ្រ តែស្រាប់តែទៅជាំងឡាយ ។ ឃើញដូច្នោះ បុរសយើងមានវាចាថា ឧត្រះគង្គាអើយ ! លោកត្រូវការប្រាក់ឬ ? ខ្ញុំសូមលោកមេត្តា ទៅរកឯអ្នកដទៃផ្សេងទៅ ចំណែកខ្ញុំ ម្តងនេះ លោកឈប់យកពីខ្ញុំបានទៀតហើយ ។

ការណ៍នេះ មិនមែនជារឿងត្រេង បង្កើតឡើងដើម្បីការកែកាយទេ។ ខ្ញុំយកការពិតមកបង្ហាញ ដោយសេចក្តីពិសោធន៍ថា មួយរសេន បើពិតជាមានប្រាកដ គ្រាន់បើជាងប្រាំរសេនដែលមានទៅក្នុងសេចក្តីសង្ឃឹមត្រូវតែពេញចិត្តចំពោះសភាពនៃខ្លួន ហើយយើងត្រូវបិទត្រចៀកកុំស្តាប់ដំបូន្មានសមុទ្រទន្ធឹងអកដ្ឋ (១) ។ មួយ ធ្វើឲ្យសប្បាយចិត្ត ប្រសើរជាងមួយពាន់ ធ្វើឲ្យគួញភ្នែក ។

សមុទ្រតែងសន្យាថា ទន្ធឹងប្រគល់ឲ្យទូកវិតដំថ្មថ្ងា តែអ្នកត្រូវតែចេញឲ្យឆ្ងាយ ព្រោះខ្សល់ហើយទន្ធឹងពួកចោរប្លន់ មកដល់ឥឡូវហើយ ។

---

១ – សេចក្តីរំពឹងចង់បានវិតុ ដែលខ្លួនមិនអាច ឬដែលហួសសមត្ថភាពនៃខ្លួន

៨២ - អ្នកសួនប្បារនឹងស្តេចត្រាញ់

អ្នកជាំសួនប្បារម្នាក់ ជាអ្នកមានសម្បត្តិធនកណ្តាល មានសួនមួយល្អគួរសម ជាទីដើមានបងប្អូនពុំជុំវិញ ជាប់នឹងភូមិមួយ ។ គាត់យកកូនឈើជាំធ្វើជាបងរនាំជុំជិត ។ នៅទីនោះ មានបន្លែគ្រប់មុខ ជាអាទិ៍: ស្ពៃ សាឡាត ហើយនឹងផ្កាសព្វយ៉ាង មានផ្កាម៉ុះប្រទេសអេស្បាញជាដើម សម្រាប់ធ្វើជាតួនផ្កា នៅឧទ្យានបុណ្យរបស់ខ្លួន ។

សុភមង្គលនេះ តែងបានទទួលការអន្តរាយជាញឹកញាប់ ពីសត្វខ្យាយមួយ ទើបបុរសនោះ ទៅប្តឹងរឿងនេះ ចំពោះស្តេចត្រាញ់ក្នុងដំបន់ ។

បុរសក្រាបទូលស្តេចត្រាញ់ថា សត្វចង្រៃមកស៊ីបំផ្លាញតាំងល្ងាចតាំងព្រឹក ហើយអស់កាលជាការឥតប្រយោជន៍ដល់ខ្លួនក៏ តែថា ក៏សើចចំអកឲ្យគេលាលែងតែ ចំណែកដុំថ្ម ដំបង ព្រួនដ៏មិនបានការសោះ ទូលបង្គំនឹកស្មានថាជាខន្ធាយព្រាយមិនខាន ។

ស្តេចត្រាញ់មានបន្ទូលទ្រើយថា: ព្រាយមិនខានអ្វីក៏ដោយ ខ្ញុំត្រូវតែកំនាញ់ឲ្យខូច ពោះបើជាមិនខាន ពោះបើមានស្មៀត តែលល្ងាចយ៉ាងណា ក៏ហាក់មិនរួចពីអា « មីរ៉ូ » ផ្តែខ្ញុំទៅរួយ ។ នែតូ! ខ្ញុំសន្យានឹងបំផ្លាញសត្វចង្រៃហ្នឹង ជូនតូឯង តាលែតបានក្តីដំរែតខ្ញុំ ។

បុរសយើងក្រាបទូលសួរថា បើអ៊ីចឹង ព្រះអង្គនឹងចាត់ការនេះនៅពេលណា ?

-នៅពេលស្អែក មិនត្រូវខុសឲ្យយូរពេលវេលាទេ ។

រៀបចំស្រេចហើយ ស្តេចត្រាញ់ក៏យាងមកជាមួយ នឹងមនុស្សជាបរិវារបស់ទ្រង់ ។

ស្តេចត្រាញ់មានបន្ទូលថា : ដូច្នេះត្រូវយើងស៊ីផឹកសិន មេមាន់របស់ពូ សាច់ផុយល្អប្លែទេ ? ចុះនាងក្រមុំនុះ ហៅឲ្យចូលដឹតមក ! ពេលណាយើងនឹងរៀបការនាង ពេលណាយើងនឹងកេកូនប្រសា ? នែពូ ! ចូរស្តាប់ខ្ញុំ គឺរឿងនេះដែលត្រូវគិត ដែលត្រូវចំណាយប្រាក់ ។

ពេលដូច្នោះហើយ ស្តេចត្រាញ់ក៏ធ្វើការទាក់ទងនឹងនាងក្រមុំ ហៅមកឲ្យអង្គុយជិតទ្រង់ ស្មាបពុងដៃ ស្មាបដៃ កាន់ជាយកូនកន្ទែងគឺថាទ្រង់ប្រព្រឹត្តអំពើផ្តេសផ្តាស ដែលនាងក្រមុំ ត្រូវការពារ ប្រតែកតែដោយសេចក្តីគោរពដ៏ជ្រាលជ្រៅ ទាល់តែនៅចំពីមុខ ឥពុកកើតមានសេចក្តីសង្ស័យ ។

ពេលនោះ គេគិតតែស៊ី គេគិតតែផឹកបំផ្លាញ ឥតមានកោតញ៉ញ៉ែតនឹងត្រាប្រណី ។ ស្តេចត្រាញ់សួរថា ដើងជ្រូកដៀតរបស់ពូ ធ្វើពីកាលណា កំស្រស់អ្វីម្ល៉េះ ?

-ចុះសេះយើងក្រាបទូលថា ដើងជ្រូកដៀតនេះ ខុកថ្លាយទ្រង់ ។

-មែនពិតហើយ ខ្ញុំទទួលដោយចិត្តត្រេកអរជាទីបំផុត ។

ស្តេចត្រាញ់សោយក្រយ៉ាសម្បាយក្រៃលែង ចំណែកឯសេះនឹង-

ពួកបរិវារចាំងប៉ុន្មានក៏ស៊ុយាំងឮញាំ ចោំងគោះ តតក្រែងរមែងដូចជាខៅ
ក្នុងគ្រួសារជាមួយ ស្តេចគ្រាញ់បង្គាប់បញ្ជាអ្នកម្ចាស់ផ្ទះតាមអំពើចិត្ត ធ្វើអ្វី
ដោយសេរី សោយស្រាគ្នាហើយ ប្រព្រឹងនឹងកូនស្រីគ្នាទៀត ។

រឿងបរបាញ់មានសភាពធ្ងន់ខ្លាំងជាងការស៊ីផឹតទៅទៀត ។

គ្រប់គ្នា រីករាយជ្រួលច្របល់ ហើយតាំងប្រឹងប្រៀបខ្លួន : គេផ្ទុំគ្រែ
ផ្ទុំស្នែង លាន់ឮសូរគ្រហឹងអឺងកង ពាល់តែបុរសយើងស្រឡាំងកាំង
ពាល់គំនិត មិនដឹងតិតយ៉ាងណា ។

ឯការគោក្រក់បំផុតទៅទៀត គឺទៅក្រនំ គេដើរដេះជាន់សួនច្បារខ្លួច
ខ្លីអស់គ្មានសល់ : លាហើយដំរេងបន្ទៃ ! លាហើយស្តែ សាច្បាត !
លាហើយ មិនដឹងរកអ្វីបបរបាន់ទៀតទេ ! ។

ខន្ធាយដេកពួននៅក្រោមដើមស្តៅធ្វើត្រើយ លុះគេដើរតក
លុះគេរកយព្រៃបង្អើលក ។ រត់ផ្លូចចេញតាមប្រក់របងយ៉ាងធំ ដែលស្តេច
គ្រាញ់បញ្ជាឲ្យព្រែក ឲ្យគេគាត់គោះ ដោយហេតុគេពិបាក មិនអាច
ជិះសេះបរចេញពីសួនច្បារបាន ។

ពួយើងពោលថា : នេះហើយជាល្បែងរបស់ស្តេចគ្រាញ់ ។ ប៉ុន្តែ
ទ្រង់ធ្វើជាមិនឮនឹងសំដីពួយើង ហើយឆ្កែនឹងមនុស្ស បានធ្វើឲ្យអន្តរាយក្នុង
រយៈពេលតែមួយមោង ច្រើនជាងខន្ធាយទាំងឡាយក្នុងខែត្រទាំងមូល
ធ្វើក្នុងរយៈពេលមួយរយគ្រាំទៀត ។

រឿងព្រេងបិន (តមក)

Conte de la Chine (Suite)

10— La chacha Tatutu et le phénix (1) Conte tibétain

បក្សាចាចាតាខ្ទូខ្ទូ ជាបក្សាគូច ហើយមានសភាពរូបកាន់អាក្រក់ជាងបក្សាតាំងពាយ ។ បក្សាដែលមានរូបកាន់ច្រើនគ្រាយប្រកបដោយសោភ័នភាពគឺ « កំពូលបក្សា » ។

មានកាលមួយថ្ងៃ បក្សាចាចាតាខ្ទូខ្ទូមួយ ពាន់ទៅក្នុងតុម្ពស្មៅមានស៊ុតប៊ ។ តែក្នុងមួយថ្ងៃ ។ កាលណាបក្សាចាចាតាខ្ទូខ្ទូ ក្រោយដែលពាន់រួចហើយ បានចេញពីតុម្ពស្មៅនេះហ៊ោរហោត់ៗ មានសត្វកណ្តុរប្រែងមួយ ចូលទៅបរិភោគស៊ុតនោះអស់គ្មានសល់ ។ បណ្តាស៊ុតពាន់ប៊ីនោះ ស៊ុតពីរ សត្វកណ្តុរចង្រៃចូលមកអាស្រ័យអស់ នៅសល់ស៊ុតមួយ ។ បក្សាចាចាតាខ្ទូខ្ទូ មានសេចក្តីខ្ពុកខ្ពស់ឥតឧបមា ក៏ហ៊ោរទៅកេ « កំពូលបក្សា » ដើម្បីឲ្យកេយុត្តិធម៌ចំពោះរឿងនេះ ។ បក្សាចាចាតាខ្ទូខ្ទូ ដោយទឹកមុខក្រៀមក្រមតន់តេក ក៏ជំរាបកំពូលបក្សាថា:

បពិត្រលោកកំពូលបក្សាអើយ លោកជាស្តេចបក្សា លោកបានឥតឃើញខ្ញុំលំបាកវេទនាយ៉ាងណា ! មានសត្វកណ្តុរប្រែងមួយ គាចសាហាវយង់ឃ្នង មកអាស្រ័យស៊ុតខ្ញុំម្ចាស់អស់ទៅហើយ ! ខ្ញុំម្ចាស់អស់

---

(1) phénix បើតាមរចនានុក្រមថាកំងុលួស បានសេចក្តីថា, បក្សាក្នុងរឿងព្រេងប្លែកណែនដែលមានសភាពប្លែកអស្ចារ្យ គឺថាបើបក្សានោះស្លាប់ គេយកទៅបូជាភ្លើង បក្សានោះអាចកើតឡើងវិញ ពីធាតុខ្លួន ឬបក្សាមានរូបភាពដដែល ។ យើងសន្មតថា « កំពូលបក្សា »។

សង្ឃឹម សូមលោកមេត្តាជួយរកខុសត្រូវឱ្យបាន » ។

កំពូលបក្សាគិតកង់ចិត្តថា អញមិនទៅវែលំនឹងរឿងគួចតាចបែបនេះ ក៏តបទៅបក្សាជាចាតាខ្លួនថា :

« ខាងឯងឃើញទេ ខ្ញុំវែលតន់តេតណាស់ថ្ងៃនេះ ។ ម្តេចរឿងបន្តិចបន្តួចប៉ុណ្ណឹង នាំមកឱ្យខ្ញុំវែល! តាមតិត ត្រូវតែខាងឯងការពារដោយខ្លួនឯង ។ បើខាងឯងការពារមិនកើត តើខាងឯងឱ្យអ្នកណាការពារជួស ? ករណីយកិច្ចម្នាក់ ។ គឺត្រូវតែការពារកូនជួរចុះ! ។

បក្សាចាចាតាខ្លួន មានចិត្តក្តៅក្រហាយពន់ពេកចំពោះវាចាកំពូលបក្សា ក៏តបទៅថា ;

ដែលខ្ញុំម្ចាស់មកនេះ ព្រោះខ្ញុំម្ចាស់យល់ថាលោកជា «កំពូលបក្សា» ជាស្តេចនៃបក្សាទាំងឡាយ(១) ។ តែលោកប្រែទៅជាប្រមាថមើលងាយខ្ញុំវិញ ។ លោកមានប្រសាសន៍ថា ខុសខ្ញុំម្ចាស់ជាខុសបន្តិចបន្តួច ។ សំដីដែលលោកពោលនេះ គឺជាពាក្យខុសស្រឡះ ។ សូមលោកជ្រាបថា រឿងគួចតាចមែនពិត តែបើសម្រេចមិនបានស្រួល ប្រែទៅជារឿងធ្ងន់ទៅវិសឹងមាន ! សូមលោកកុំបន្ទោសខ្ញុំម្ចាស់ » ។

កំពូលបក្សាមិនវែលំនឹងស្តាប់វាចាបក្សាចាចាតាខ្លួន ធ្វើព្រងើយកន្តើយ។ បក្សាចាចាតាខ្លួន ក៏វែលត្រឡប់ទៅសំបុកវិញ ។ ដោយបក្សានេះទើង

១- បើកំពូលបក្សាជាស្តេចនៃបក្សាទាំងឡាយ តើពាក្យនិយាយត្រូវពោលដាក់សត្វឬ ?

គេកណាស់ កំលោតទៅខំលើមែកឈើមួយ ហើយកំយកស្មៅវែញធ្វើជាព្រួញ រង់ចាំមើលសត្វកណ្តុរប្រែង ។ ក្នុងមួយរំពេច កណ្តុរប្រែងក៏មកដល់ដើម្បីនឹងអាស្រ័យស៊ុតមួយដែលទៅសល់ ។ បក្សាបាតាគូខ្លួយើញកណ្តុរប្រែងមក កំយកព្រួញស្មៅបាញ់ទៅចំគ្រាប់ក្បែកកណ្តុរប្រែង ។ ឈឺក្បែកខ្លាំងក៏ស្រែក រត់ទៅមិនបានដាមើល រត់ទៅចូលប្រមុះសិង្ហដែលកំពុងដេកលក់នៅមាត់សមុទ្រ ។

ក្នុងពេលនោះ មានខាតមួយហែលទឹកមក ខ្លួលសិង្ហលោតទៅក្នុងទឹកសមុទ្រចំខ្លាតន្ទែងខ្លួន កំស្ទុះហោះហើរទៅលើនភាល័យ ជួនទៅបំះលើសំបុកកំពូលបក្សា ធ្វើឲ្យបែកស៊ុតអស់ ។ កំពូលបក្សា មានចិត្តក្តៅក្រហាយខឹងឥតឧបមា កំស្រែកទៅកាន់ខាតថា: ឯងជាខាត អញជាកំពូលបក្សា ។ ឯងសង់នៅក្នុងទឹក អញសង់នៅលើគោក ។ ឯងមិនដឹងខ្មែរថា អញកំពូលបក្សាធ្លាប់តែពង៦ចាខស៊ុតតែមួយក្នុងមួយឆ្នាំ ! ហេតុម្តេចឯងហោះលើអាកាសដូចសត្វគ្មួតក្រៅពីប្រទេសឯង ហើយមកប៉ះសំបុកអញ ធ្វើឲ្យបែកស៊ុតអញ ?

ខាតឆ្លើយតបទៅកំពូលបក្សាថា : « លោកមិនត្រូវបន្ទោសខ្ញុំទេ ។ រឿងពិតគឺខ្ញុំ កំពុងដួតទឹកហែលលេងសប្បាយ ស្រាប់តែមានសិង្ហមួយលោតទៅក្នុងទឹក ចំណងនឹងខាំត្រចាក់ខ្ញុំ ម្នាះហើយខ្ញុំក៏ត្រូវហោះទៅលើអាកាសឲ្យផុតពីគ្រោះថ្នាក់ បើខ្ញុំចង់ផ្លាញសំបុកលោក ហើយធ្វើឲ្យបែកស៊ុត

លោកតើដោយអាចេតនា បើលោកមិនជឿខ្ញុំ សូមហៅសង្ឃមកសួរចុះ»។

សង្ឃតបទៅកំពូលបក្សាថា: «បពិតកំពូលបក្សា» កុំឲ្យលោកយកទោសយកតែខ្ញុំ! ការណ៍ពិតគឺខ្ញុំកំពុងដេកលក់នៅមាត់សមុទ្រ ស្រាប់តែសត្វកណ្តុរប្រែងស្ទុះចូលមកក្នុងប្រហោងច្រមុះខ្ញុំ ដោយខ្ញុំឈឺខ្លាំងពេក ទើបស្ទុះលោតទៅកន្លែងសមុទ្រនោះទៅ លោកមើលចុះ កំហុសពិតជាធ្លាក់ទៅលើសត្វកណ្តុរប្រែងឯណោះ មិនមែនខ្ញុំទេ សូមលោកជ្រាប!»

ក្នុងពេលនោះ កំពូលបក្សាក៏ហៅរទៅកាន់សំបុកកណ្តុរប្រែង។ ដាក់បកំពូលបក្សាថា: « កំហុសនោះមិនមែនខ្ញុំប្រព្រឹត្តទេ កំហុសនោះត្រូវធ្លាក់ទៅលើបក្សាចាចាតាខ្លួនទេតើ! ព្រោះថាខ្ញុំកំពុងលេងសប្បាយនៅលើស្មៅ ស្រាប់តែបក្សាចាចាតាខ្លួននេះ យកត្រចៀមមកជាប់ត្រចៀកខ្ញុំ ដោយខ្ញុំឈឺចាប់ខ្លាំង កំស្ទុះចំក៏សនទៀលទៅលើប្រហោងច្រមុះសង្ឃកំពុងដេកលក់ ដោយហេតុនេះហើយ ទានជាកំហុសនោះត្រូវធ្លាក់ទៅលើបក្សាចាចាតាខ្លួនទើបសម »។

កំពូលបក្សាហៅរទៅកបក្សាចាចាតាខ្លួនតទៀត។ កំពូលបក្សាទើបនឹងទៅដល់ភ្លាម បក្សាចាចាតាខ្លួនពោលទៅកាន់កំពូលបក្សាថា:

១- លោកកំពូលបក្សា ខ្ញុំបាទពោលដាក់បលោកហើយ លោកមើលងាយខ្ញុំ លោកធ្វើជាត ជាថ្នង់ មិនចង់ស្តាប់វាចាខ្ញុំ ព្រោះខ្ញុំជាសត្វស្តមថោកទាប មានស្មាបតិ ខ្វិគ្មានកំឡាំងហើរ មានរូបកាយមិនស្រស់ស្អាត

ស្តួមផង ។ លោកខុកសេចក្តីខុកខ្វិចថាជារបស់បន្តិចបន្តួច បើប្រៀប
ធៀបទៅមិនមានតំហាស្មើនឹងគ្រាប់ល្ងផង ។ លោកបានប្រាប់ខ្ញុំថា
ការណីយកដំបូនៃមាតាត្រូវថែទាំបុត្រធីតា ហើយមិនត្រូវយករឿងបន្តិច
បន្តួចមកនាំឲ្យលោកវេល ។ បើដូច្នេះ តើខុកលោកកន្ត្រឹតេលនេះ
មានតំហាមិនស្មើនឹងគ្រាប់ល្ងទៅហើយ ! ម្តេចក៏លោកមិនបំពេញការណី
យកដំបូ ថែទាំសំបុកលោកឲ្យបានសុខស្រួល ម្តេចក៏លោកចេះតែដើរ
ឈ្លោះនឹងអ្នកដទៃគ្រប់គ្នាដូច្នេះ ។ កាលដែលសត្វកណ្តុរប្រែងចង្រៃ
ភស៊ីស៊ីតខ្ញុំ លោកថាមិនជាអ្វីទេ តែបើនាគចង់ផ្តាញសំបុកលោក
ហើយធ្វើឲ្យបែកស៊ីតលោក លោកថានេះជាខុកយ៉ាងធ្ងន់ចំផុត ។ នេះឬ-
សេចក្តីយុត្តិធម៌របស់លោក ! ខ្ញុំពន្លឺតែចិនៅតាមស្មៅ ហើយទៅរកចំណី
រាល់ថ្ងៃផង ចំណែកលោកពន្លឺតែមួយ តែនៅលើពុងឈើ ស្ថានការរបស់
លោកស្រួលនឹងការពារជាច្រើនផង ជាងយើងដែលជាបក្សាតូចតាច ។
បើដូច្នេះ ខ្ញុំត្រូវកត់ចំណាំថាបើការបន្តិចបន្តួចនាំឲ្យវិនាសអន្តរាយ រឿង
នេះត្រូវបន្ទោសតែលោកមួយទើបសម ។ ។

កំពូលបក្សាបានស្តាប់ពាក្យបក្សាចាចាតាខ្ចប់ មានចិត្តខ្មោមនស្ស-
ជាខ្លាំង គំហើរវិលទៅកេសំបុកវិញទៅ ។

ចប់រឿងកំពូលបក្សា នឹងបក្សាចាចាតាខ្ចប់ នៅមានរឿងទី ១១
តទៅទៀតគឺរឿងក្អែកមានទោស ។ ។

សំបុត្រទី ៣

មនុស្សជាន់ដើម

លោក ឈន-អៀម ប្រែពីភាសាអង់គ្លេស

យើងបានឃើញនៅក្នុងសំបុត្រយើងមុនថា ការផ្ទុកគ្នាយ៉ាងខ្លាំងរវាងមនុស្សហើយនឹងសត្វឯទៀត គឺប្រាជ្ញារបស់មនុស្ស ។ ប្រាជ្ញានេះធ្វើឲ្យមនុស្សឆ្ងាតវាងវៃនឹងខ្លាំងក្លៃជាងសត្វធំ ។ ដែលអាចកំណត់ចេញបំផ្លាញមនុស្សបាន បើសិនជាគ្មានប្រាជ្ញា ។ នៅពេលដែលប្រាជ្ញារបស់មនុស្សជុះដាលឡើង ឯអំណាចរបស់មនុស្សក៏ជុះដាលឡើងដែរ ។ ដើម្បីឆ្លើមពាក្យអំណាច មនុស្សពុំមានអាវុធពិសេសសម្រាប់ប្រយុទ្ធនឹងសត្រូវគាំងឡាយរបស់គេឡើយ ។ គេអាចត្រឹមតែចាលដុំថ្មគាំងឡាយទៅលើសត្វគាំងនោះប៉ុណ្ណោះ ។ ដូច្នេះ គេក៏ផ្តើមសាងគ្លួចៅ លំពែង ហើយនឹងវត្ថុជាច្រើនទៀតជាច្រើន ដែលធ្វើអំពីថ្ម ព្រមទាំងម្ជុល សម្រាប់អំពីថ្មយ៉ាងល្អ។ ធង ។ យើងបានឃើញអាវុធ ធ្វើអំពីថ្មជាច្រើននៅសារមន្ទីរ កេនស៊ិនតុនខាងត្បូង (The South Kensington Museum) ហើយនឹងនៅក្នុងសារមន្ទីរនាក្រុងហ្ស៊ីណែវ ។

ឃុតខឹកកក ដែលឥតុកបានឱ្យឃើញខ្លះហើយ នៅក្នុងសំបុត្រមុនបានចប់បន្តិចម្តង ។ ហើយគំនរខឹកកក ក៏បានវិនាសបាត់ទៅអំពីអឺរុបភាគច្រើនឆ្ងាយ នឹងអំពីទ្វីបអាស៊ី ។ នៅពេលដែលអាកាសធាតុ បានកក់ក្តៅទៅ ។ ទាំងឡើង មនុស្សក៏បានសាយភាយខ្លួនទៅ ។

កន្លែងសម័យនោះ គ្មានផ្ទះ គ្មានការគ្រប់គ្រងទេ ។

ប្រជាជនរស់នៅកន្លែងថ្ម ។ ពុំមានកសិកម្ម គឺការដាំនៅកន្លែងស្រែចំការទេ ។ មនុស្សប្រកបរកតែផ្លែឈើ គ្រាប់ឈើ ហើយនឹងសត្វដែលគេសំឡាប់បាន ។ គេពុំមានទំនាក់ទំនងស្រុកអន្លើទេ ពីព្រោះគេពុំបានដាំអ្វីនៅកន្លែងស្រែចំការសោះ ។ គេពុំចេះស្លៀកសង្ហា ប៉ុន្តែប្រហែលជាគេចេះចំអិនសាច់ នៅលើភ្លើងកំពុងឆេះ ដែលគេបំពាក់ទុក ។ គេពុំបានមានប្រដាប់ប្រើប្រាស សំរាប់ដាំស្រូវ ឬ ពាងក្រឡ ឧិន ខ្លះទេ ។

មានរឿងមួយដែលធ្វើឲ្យយើងចង់ដឹងចង់ស្គាល់ ។ មនុស្សព្រៃពាំងនោះ ចេះដឹងថាគួរគំនូរយ៉ាងដូចម្តេចហ៊ាន ។ តាមពិត គេពុំមានក្រដាស់ ឬ ស្មៅបបាក្តា ឬ ខ្មៅដៃ ឬ ជក់ទេ ។ គេមានត្រឹមតែម្ជុលធ្វើអំពីឆ្នឹងប្រដាប់ប្រដាស្រួច ។ ប៉ុណ្ណោះ ។ ជាមួយគ្រឿងប្រដាប់តាំងនេះ គេកេះ ឬ គួរបូសត្វ នៅលើជញ្ជាំងនៃរូងថ្ម ។ គំនូរខ្លះរបស់គេ ជារូបគំនូរល្អពិត ប៉ុន្តែគំនូរតាំងនោះ ស្ទើរតែតាំងអស់ ជាគំនូរចំហៀងមុខ (Profiles) ។ កូនដឹងថា ការគូរចំហៀងមុខ ងាយជាង ហើយតាមធម្មតាក្មេងតាំងឡាយតែងគូរបែបនេះដែរ ។ ដោយរូងថ្មមានការពន្លឺពិត នេះប្រហែលជាគេបានប្រើចង្កៀងយ៉ាងសាមញ្ញបែបណាមួយ ។

មនុស្សតាំងឡាយនោះ ដែលយើងបានពិភាក្សា ឈ្មោះថាមនុស្សនយុគថ្ម (The Palaeo lithie men) ឬ មនុស្សនៃយុគថ្មចាស់ ។ សម័យ

នោះគេឲ្យឈ្មោះថាយុគថ្ម ព្រោះថាមនុស្សធ្វើប្រដាប់ប្រើប្រាស់របស់គេ ពាំងអស់អំពីថ្ម ។ គេមិនទាន់ស្គាល់សារប្រយោជន៍ នៃលោហធាតុយ៉ាងណានៅឡើយទេ ។ សព្វថ្ងៃនេះ វត្ថុភាគច្រើនរបស់កូនឯង ក៏ធ្វើអំពីលោហធាតុដែរ ជាពិសេសអំពីដែក ។ តែគេពុំស្គាល់ដែកឬសំរិតទេ នៅពេលនោះ ហើយដូច្នេះ គេប្រើប្រាស់ថ្មវិញដែលពិបាកនឹងប្រើការជាងដែកទៅទៀត ។

មុនដែលយុគថ្មបានផុតរលត់ទៅ អាកាសធាតុនៃពិភពលោកក៏បានផ្លាស់ប្រែយ៉ាងខ្លាំង ហើយត្រឡប់ទៅជាក្តៅៗល្អ ។ ខ្លាំងឡើង ។ តំនរទឹកកកាំងធ្លាយ បានថយទៅឆ្ងាយ ទៅរកមហាសមុទ្រអាក់ទិកវិញ (The Artic Océan) ហើយត្រជាក់ ។ គំបានរលាយឡើងនៅលើទ្វីបអាស៊ីភាគតណ្ឌាល ហើយនឹងទ្វីបអឺរុប ។ ក្នុងត្រជាក់នោះ យើងឃើញមានកំណើតថ្មមួយនៃជីវភាពមនុស្ស ។ មនុស្សពាំងនោះ ជាអ្នកវៃឆ្លាតជាច្រើនជាងមនុស្សនៃយុគថ្ម ដែលយើងបានពិពណ៌នាអំបាញ់មិញ ។ ប៉ុន្តែ គេនៅតែធ្វើប្រដាប់ប្រើប្រាស់អំពីថ្មទៅឡើយ ។ មនុស្សពាំងនោះ ក៏បានទៅកាន់យុគថ្មដែរ ប៉ុន្តែជាយុគថ្មភាគខាងចុង ។ គេហៅមនុស្សពាំងនោះថា មនុស្សថ្មថ្ម (The Neolithic men) ឬ មនុស្សនៃយុគថ្មថ្ម ។

កាលបើពិនិត្យមនុស្សថ្មថ្មនេះ យើងនឹងឃើញថា គេមានវឌ្ឍនភាពយ៉ាងច្រើន ។ ប្រជារបស់មនុស្ស បានធ្វើឲ្យគេមានសន្ទុះទៅមុខយ៉ាង

លឿន បើប្រៀបធៀបទៅនឹងសត្វដទៃ ។ មនុស្សថ្មីទាំងនោះ បាន រកយើញនូវរបៀបកសិកម្ម ។ គេចាប់ផ្តើមភ្ជួរស្រែចំការ ហើយដាំ ដំណាំនៅក្នុងស្រែចំការនោះ ។ នេះគឺជារបមួយយ៉ាងប្រសើរ សម្រាប់ គេ ។ ឥឡូវនេះ គេអាចរកអាហារបានស្រួលជាង ជាងសការត្រូវទៅ ចាប់សត្វកាលពីលើលា ។ គេមានពេលទំនេរច្រើន មានពេល សម្រាកនឹង ពេលគិតពិចារណា ។ គេមានពេលទំនេរ ទាន់តែច្រើនឡើង គេក៏មានវឌ្ឍនភាពយ៉ាងច្រើនក្នុងការរកយើញនូវគ្រឿងឆ្ងាយ ៗ ដែរ ។ គេចាប់ផ្តើមធ្វើក្អមឆ្នាំងអំពីដី ហើយដោយបានក្អមឆ្នាំងនេះ ជាជំនួយ គេក៏ចាប់ផ្តើមស្វែងរកចំណីអាហារ ។ ប្រជាជនប្រើប្រាស ធ្វើពីថ្ម ក៏ទាន់តែប្រសើរឡើង ហើយដុះខាត់យ៉ាងរលើង ។ គេចេះ ផ្សាំងសត្វយ៉ាងដូចម្តេច ហើយដូចជា គោញី ក្តែ ចៀម ទឹង ពពែ ។ ហើយគេក៏ចេះត្បាញយ៉ាងដូចម្តេចដែរ ។

គេតស្រែយនៅក្នុងផ្ទះប្តូរ ។ ក្នុមទាំងនោះច្រើនសន់នៅតណ្តាលបឹង ដើម្បីកុំឲ្យសត្វសាហាវឬ ក៏មនុស្សដទៃ អាចរាយប្រហារគេបាន យ៉ាងងាយនៅទីនោះ ។ ដោយហេតុនេះ ប្រជាជនទាំងនោះ ឈ្មោះ ហៅថាអ្នកនៅតន់បឹង (Lake dwellers)

កូនមុខជាឆ្ងល់ថា ហេតុដូចម្តេច បានជាយើងដឹងអំពីប្រជាជនទាំង នេះ ច្រើនម្ល៉ះ ។ តាមពិត គេពុំបានសរសេរសៀវភៅទុកទេ ។ ប៉ុន្តែ

ឥឡូវកូនចាន់ធីយាយប្រាប់កូនៗថា សៀវភៅដែលយើងអានខ្លួវប្រវត្តិនៃមនុស្សទាំងនោះ គឺសៀវភៅពិនៃធម្មជាតិ ។ គឺមិនមែនជាការងាយអានសៀវភៅនេះទេ ។ ត្រូវមានអំណត់យ៉ាងមុតមាំ ។ មនុស្សជាច្រើនបានចំណាយជីវិតរបស់ខ្លួន ក្នុងការខិតខំអានសៀវភៅនេះ ហើយគេបានសន្សំខុក មានចំនួនយ៉ាងច្រើន ខ្លួវបាសាណីកូត ហើយនឹងសំណល់ឆ្អឹងកងអតីតសម័យ ។ បាសាណីកូតទាំងនោះ ត្រូវបានគេសន្សំខុកជាមួយគ្នា នៅក្នុងសារមន្ទីរ ។ ហើយយើងអាចយើញនៅទីនោះ ខ្លួវគួរឲ្យស្ញប់ស្ញែង ដែលខាត់យ៉ាងលើង ក្អមធំៗ ព្រួញ ទឹង ម្ជុលដែលធ្វើពីថ្ម ទឹងវែងៗជាច្រើន ដែលមនុស្សថ្មីបានធ្វើ ។ កូនបានយើញវត្ថុទាំងនោះជាច្រើន ដោយផ្ទាល់ខ្លួន ប៉ុន្តែប្រហែលជាកូនភ្លេចទៅហើយ បើសិនជាកូនយើញម្តងទៀត កូនមុខជាអាចយល់ខ្លួវត្ថុទាំងនោះ បានគ្រាន់បើ ។

ឥឡូវនៅចាំបានខ្លួវបែបផែនមួយយ៉ាងល្អ នៃលំនៅក្នុងបឹង នៅក្នុងសារមន្ទីរក្រុងហ្សឺណែវ ។ គេជាំបង្គោលឈើនៅក្នុងបឹង ហើយនៅលើបង្គោលទាំងនោះ គេសង់ជាកន្ទេះធ្វើអំពីឈើ ។ នៅលើកន្ទេះ គេសង់ខ្នមឈើហើយក្បាច់ខ្នមទាំងមូលដោយស្ពានតូចមួយ ទៅកាន់ដីគោក ។

មនុស្សថ្មីទាំងនោះ ស្លៀកពាក់បិទបាំងកាយដោយស្បែកសត្វឬដួនតាលដោយសម្បកឈើតគ្រាតគរគ្រើម ។ ដៃ គឺជាកូនឈើតូច ។

ដែលមានសរសៃយ៉ាងល្អ ប្រើសម្រាប់ធ្វើសំលៀកបំពាក់ ។ សព្វថ្ងៃនេះ នៅខេត្តស្ទឹងត្រែងក៏ធ្វើអំពីដៃ ។ ប៉ុន្តែក្នុងសម័យមុន សំពត់ដែលធ្វើអំពីដើមដៃ ជាសំពត់ត្រោត ។ ពេកណាស់ ។

មនុស្សចាស់ងាប់ នៅតែបន្តធ្វើឲ្យមានសេចក្តីចំរើន ។ គេចាប់ផ្តើមធ្វើប្រដាប់ប្រើប្រាស់ អំពីស្ពាន់នឹង សំរិត ។ ដូចកូនដងឹងស្រាប់ សំរិតគឺជាការលាយស្ពាន់ជាមួយសង្កសី ហើយវាធ្ងន់ជាងស្ពាន់ឬសង្កសីទៅទៀត ។ គេប្រើប្រាសមាសដែរ ប៉ុន្តែគេពុំអាចធ្វើគ្រឿងអលង្ការ អំពីមាសបានទេ ?

ប្រជាជនចាស់នេះ បានរស់នៅប្រហែលជា ១០.០០០ ឆ្នាំកន្លងទៅហើយ ។ តាមពិត យើងពុំអាចដឹងខ្លួវាលម្អិតឬសម័យពិតប្រាកដទេ ។ នេះគឺជាការស្មានចាស់អស់ ។ កូនគួរកត់សំគាល់ថា យើងបានជជែកគ្នាឆ្ងាយណាស់មកហើយ អំពីសម័យកាលច្រើនឆ្នាំ ។ ឥឡូវនេះ យើងកំពុងតែវិតចូលជិតឡើង ។ មកសម័យសព្វថ្ងៃ ។ តាំងពីមនុស្សថ្មចាស់ហួតមកដល់មនុស្សបច្ចុប្បន្ន ពុំមានការអាក់ខានឬការផ្ទាស់ប្តូរក្លាម ។ ទេ ។ ប៉ុន្តែ យើងនៅតែឆ្លងកាត់អំពីមនុស្សថ្មចាស់ ឆ្ងាយណាស់ ។ ការប្រែប្រួលបានធ្វើបន្តិចម្តងៗ ព្រោះជាច្បាប់នៃធម្មជាតិ ។ ជាតិផ្សេង ។ បានចំរើនកើនឡើងហើយ ជាតិខ្លះប្រកាន់តែតាមបែបបទរបស់គេ ខ្លះរស់នៅតាមជីវភាពរបស់គេផ្ទាល់ ។ ដោយអាកាសធាតុមិនដូចគ្នានៅកន្លែងកូមិភាគ

ទុសគ្នានៃពាក្យតាលោក មនុស្សកំត្រូវអនុលោមទៅតេឲ្យស្របទៅនឹងអាកាសធាតុនោះ ។ ហើយកំបានផ្ទាស់ប្តូរយ៉ាងខ្លាំង ។ តែយើងនឹងពិភាក្សារឿងនេះ នៅពេលក្រោយ ។ ។ មានរឿងមួយទៀត ដែលខ្ញុំចង់និយាយប្រាប់ក្មួនឥឡូវនេះ ។ ប្រមាណជាចុងឃុតនៃឆ្នាំ មានមហន្តរាយមួយបានកើតឡើងដល់មនុស្ស ។ ឪពុកបាននិយាយប្រាប់ក្មួនហើយថា នៅពេលនោះ សមុទ្រមេឌីតាណេ មិនមែនជាសមុទ្រទេ ។ មានតែបឹងពីរបីប៉ុណ្ណោះ នៅត្រង់នោះ ហើយនៅកន្លែងបឹងទាំងនេះមានមនុស្សជារាប់ចាន់បានរស់នៅ ។ ស្រាប់តែដីគោក ជិតច្រកសមុទ្រហ្សីប្រាល់តារ (Gibraltar) នៅចន្លោះទ្វីបអឺរុប និង ទ្វីបអាហ្វ្រិក ត្រូវស្រុតលិចបាត់ទៅ ហើយទឹកមហាសមុទ្រអាត្លង់ទិក ក៏ហូរស្រោចទៅកន្លែងជ្រលងតាម ។ នៃសមុទ្រមេឌីតាណេ ។ ទឹកក៏នៅតែបន្តហូរស្រោចទៅចំតេញសមុទ្រមេឌីតាណេ ហើយមនុស្សប្រុសស្រីជារាប់ចាន់ ដែលរស់នៅជិតខាងឆ្នេរកន្លែងបឹង ត្រូវបានលិចលង់អន្តរាយ ។ គេតាំងមិនអាចរត់ឲ្យរួចឡើយ ។ មានទឹកសាយភាយតាមតេញទីតាំងអស់ ប្រមាណ ៤ម៉ាល់ ។ មហាសាគរអាត្លង់ទិក បានបន្តហូរស្រោចទៅចំតេញតាល់តែជ្រោះជ្រលងតេញប្រៀប ហើយសមុទ្រមេឌីតាណេ ក៏មានអត្ថភាពឡើង ។

តាមពិត ក្មួនប្រហែលជាបានឮ ឬ បានអានអំពីមហាជំនន់ ។ តម្លៃ

(The Bille) តែដំនិតនៃអំពីមហាជនខ្មែរនេះ ហើយសៀវភៅជាភាសាសំស្ក្រឹតរបស់យើងខ្ញុំ ក៏និយាយដល់រឿងនេះដែរ ។ នេះប្រហែលជាជំនាន់ដំបូងឆ្ងាយ ដែលបំពេញសមុទ្រមេឌីទែរ៉ាណេ ។ នេះគឺជាមហន្តរាយដ៏អស្ចារ្យយ៉ាងនេះហើយ ដែលមានមនុស្សខ្លះបានតំណែ ហើយបាននិយាយប្រាប់រឿងក៏រាំងអស់ អំពីមហន្តរាយនេះ ដល់កូនចៅរបស់គេ កូនចៅរបស់គេរលឹកឃើញរឿងនោះ រួចនិយាយប្រាប់រឿងក៏រាំងទៅកូនចៅថ្មីរបស់គេតទៅទៀត ហើយរឿងក៏រាំងតែបន្តតទៅ ពីជំនាន់មួយទៅជំនាន់មួយ ។

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

ក្នុងធមាសទី ១ ឆ្នាំ ១៩៦៤

នៅធមាសទី ១ គឺតាំងពីខែមករា ដល់ខែមិថុនា ឆ្នាំ ១៩៦៤ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ១ មុខ គឺ :

អំពីភូមិខ្មែរ

ដូច្នេះ អស់លោកអ្នកចេះដឹងតាំងពីវ័យ ជាស្ត្រី ជាបុរស ឬជាបព្វជិត ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែនិញ្ញាសា តាមគោលបញ្ញាដូចរៀបរាប់ខាងមុខ ឱ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែមិថុនា ឆ្នាំ ១៩៦៤ ។

ការប្រឡងនេះមានរង្វាន់ដា ៤ ប្លាក់ ៖

ប្លាក់លេខ ១ . . . ១,១០០រៀល ប្លាក់លេខ ៣ . . . ៦០០រ

ប្លាក់លេខ ២ . . . ៨០០រៀល ប្លាក់លេខ ៤ . . . ៤០០រ

វិញ្ញាសាដែលដាក់ប្រឡងនោះ សូមសរសេរលើសៀវភៅសរ-
សេរ កុំសរសេរលើក្រដាសតែ ១ សន្លឹកស្តើងៗឡើយ ហើយសូមសរ-
សេរនាមនិងទីលំនៅរបស់ខ្លួនឲ្យច្បាស់លាស់លើក្រដាស ១ សន្លឹកដោយ
ឡែក ដាក់ស្រោមសំបុត្រ ១ ជាមួយនឹងវិញ្ញាសានោះ យកទៅឲ្យផ្ទាល់
ខ្លួនក៏បាន យកទៅឲ្យមេឃុំផ្ទៀងទាត់ចុះស្តម្ភឲ្យក៏បាន ដោយការខ្នងសំបុត្រ
ថា ៖ ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ (ផ្នែកក្រុមជំនុំ
ទំនៀមទម្លាប់ខ្មែរ)

ការប្រឡងលើកនេះ ក្រុមជំនុំដាក់ជូនតែរឿងកូមិខ្មែរ ១ មុខនេះទេ
ព្រោះយល់ថារឿងនេះមានសំខ្លួរច្រើនណាស់ ។ ឯកូមិនិងសង្គមខ្មែរក្រុម
ជំនុំបានដាក់ឲ្យប្រឡងម្តងហើយ តែលើកនេះដាក់ឲ្យប្រឡងទៀត ព្រោះ
លើកមុនយើងបានខ្វះឯកសារតិចណាស់ ពុំអាចបញ្ចេញជាសៀវភៅ

ភាសាបរទេសឲ្យពិស្តារបង្ហាញជនបរទេស ឲ្យស្គាល់ខ្លួនវប្បធម៌ខ្មែរពិត ប្រាកដល្អឥតល្អន់ចាន ។ តាមពិត ខ្មែរយើងសម័យបច្ចុប្បន្ន គួរតែខំរិះរកស្រាវជ្រាវឲ្យដឹងច្បាស់ខ្មែរសម័យបុរាណ និងសម័យថ្មរបស់ខ្លួន ហើយកត់ត្រាទុក ទើបកូនខ្មែរជាន់ក្រោយអាចស្គាល់ខ្លួនព្រឹត្តិការណ៍របស់ខ្លួនចាន ។ រឿងនេះគ្មានជាតិណាចេះដឹងស្គាល់ច្បាស់ខ្មែរមកម្ចាស់របៀបថៃបបរបស់ខ្មែរជាងខ្មែរទេ, តែដោយបណ្តាអ្នកចេះដឹងច្បាស់នោះអ្នកខ្លះពុំចានជាតិតកត់ត្រាទុកអំពីការរស់នៅរបស់ខ្មែរដែលចេះតែផ្លាស់ប្តូរតាមកាល ហើយនឹងមានថ្មីក ។ គ្មានៅតាមស្រុក តាមខែត្ររបស់គេ ទើបកន្លងការប្រឡងលើកនេះ ក្រុមដំទុំសូមឲ្យអស់លោកអ្នកស្ម័គ្រចិត្តប្រឡង អធិប្បាយអំពីភូមិ នឹងអំពីការចាក់ឌុងដោយការរស់នៅក្នុងភូមិ, ហើយដើម្បីជាជំនួយដល់គំនិតរបស់លោកអ្នក, ក្រុមដំទុំសូមជូនទិ-ហារណ៍នឹងសំនួរជាច្រើនដើម្បីបង្ហាញដល់លោកអ្នកថា ទោះជាការធម្មតាយ៉ាងណា ក៏ត្រូវតែមានច្បាប់-ម្ចាស់ដែរ ។ កាលបើចានឃើញសំនួរនេះហើយ លោកអ្នកនឹងកើតគំនិតចង់សួរគេឡើង, លុះសាកសួរទៅហើយ ទើបលោកអ្នកសរសេរចានល្អ ។

តោលបញ្ហានៃការប្រឡង

១- ទីកន្លែងនិងសម្ភារៈរបស់ភូមិ

ភូមិដែលលោកអ្នកនៅនោះឈ្មោះអ្វី នៅក្នុងឃុំណា ស្រុកណា ខេត្តណា ? ។ ល ។ ភូមិនោះមានផ្ទះ-ថ្ទល់-ផ្លូវដើន-ទន្លេ-ស្ទឹង-ព្រៃក ដែលគេអាចធ្វើដំណើរទៅមកត់ទន្លេបានដូចម្តេច? មានឆ្លាវឬទេ? ហើយផ្លូវទាំងនោះ, គេធ្វើដំណើរបានទាំងជ្រាំង ទាំងវស្សា ឬដូចម្តេច? ភូមិនោះជាភាគស្រែ ឬចម្ការ ឬតំបន់ព្រៃ ? ។ ល ។ អំពីផ្ទះសម្បែង, ដើម្បីងាយដល់ការសរសេរប្រស្នាឯទៀត ដែលលោកអ្នកនឹងត្រូវដោះស្រាយជាខាងក្រោយនោះ សូមលោកអ្នកជាស់លេខរៀងឲ្យផ្ទះនីមួយ ។ ក្នុងភូមិរបស់ខ្លួន ពីដើមភូមិដល់ចុងភូមិ, ដូច្នេះយើងអាចដឹងបានថា ភូមិរបស់លោកអ្នកមានផ្ទះប៉ុន្មាន ? សូមប្រាប់អំពីអគារដែលជាសម្បត្តិសាធារណៈ ដូចជាវត្ត សាលាសំណាក់ សាលារៀន ។ ល ។ ប៉ើលោកអ្នកអាចគូរផែនទីភូមិនោះបាន នោះជាការប្រសើរណាស់ទៅទៀត ព្រោះថានៅលើផែនទីរបស់លោកអ្នកត្រូវមានសរសេរថា នេះសាលា នេះព្រៃកឈ្មោះអ្វី នេះភូមិឈ្មោះអ្វី នេះផ្លូវពីភូមិណាទៅភូមិណា ? ។ ល ។ ទោះជាផែនទីនោះអាក្រក់យ៉ាងណា ក៏ជាដំនួយមួយដ៏សំខាន់ដល់សេច

ក្តីអធិប្បាយរបស់លោកអ្នកដែរ ។ ប៉ុន្តែបើលោកអ្នកគ្រាន់តែគួរខេ ពុំមានដាក់ថា ខេះសាលាឃុំឈ្មោះអ្វី វត្តនេះឈ្មោះអ្វី នេះត្រង់ឯកឈ្មោះអ្វីនេះស្រែខេ នោះ ផែនទីរបស់លោកអ្នកក៏យកជាការពុំបាន ។

២- អំពីគ្រួសារនៅក្នុងភូមិដែលលោកអ្នកតែងនោះ

ដើម្បីឲ្យសេចក្តីដែលលោកអ្នកតែងសរសេរនោះ បានច្បាស់លាស់ល្អ សូមលោកអ្នកប្រាប់ឈ្មោះម្ចាស់ផ្ទះនីមួយ ។ ដែលលោកអ្នកបានឲ្យលេខរួចទៅហើយខាងលើ រួចប្រាប់អាយុជនម្នាក់ក្នុងផ្ទះនោះថា អ្នកនោះត្រូវជាញាតិម្តេចនឹងលោកអ្នក ជាសាច់ថ្លៃ ឬជាសាច់បង្កើត ? ទីឯសូមប្រាប់ថា អ្នកនោះមានស្រែចម្ការប៉ុន្មាន របរកសិអ្វីខ្លះដែលជាមុខរបរបស់គាត់, របរអ្វីទៀតដែលជាការបន្ថែមចន្ទ្យរបស់គាត់ ។

ម្យ៉ាងទៀត បើលោកអ្នកប្រឡងមិនគួរផែនទីភូមិ ក៏គួរតែដាក់លេខផ្ទះនីមួយ ។ ដែរ ដើម្បីងាយចំណាំ ទីឯងាយអធិប្បាយឲ្យអ្នកអានយល់ ដូចជាថា ផ្ទះលេខ ១ គ្រួសារលេខ ១ ដែរ គ្រួសារនេះមានប្រពន្ធ ១ ប្តី ១ កូន ២ នាក់ ទីឯឪពុកខាងប្តី ជាមនុស្សចាស់ដែលមកនៅអាស្រ័យនឹងកូន ដោយគាត់ពិការភ្នែក ។ល។ ក្រោយដែលបានរៀបរាប់ដូច្នេះហើយ សូមលោកអ្នកប្រឡងប្រាប់ឈ្មោះម្នាក់ៗ ទីឯអាយុ. ស្រុកកំណើតរបស់គាត់ របស់ទ្រព្យដែលគាត់មាន ដូចជាផ្ទះសម្បែង

ស្រែក្តី គោក្របី ។ល។

ឧទាហរណ៍ ដូចនាងយ៉ីជាប្រពន្ធ កើតនៅក្នុងភូមិនោះដែរ ប៉ុន្តែប្តីគាត់ជាអ្នកជវៃ មកស្តីនាងនេះនៅភូមិណា ឬរស់ប្តីនោះជាអ្នកភូមិណា ស្រុកណា ខែត្រណា ឪពុកបង្កើតគាត់នៅឯណាពីមុនមក? ផ្ទះដែលគាត់នៅសព្វថ្ងៃជារបស់អ្នកណា ? ឧបមាថា : បើផ្ទះនោះជាផ្ទះខាងប្រពន្ធ គាត់ប៉ាន់ឧទ្ទិសជាកេរ្តិ៍មរតកអំពីម្តាយឪពុកគាត់ដែលស្លាប់ ឬយ៉ាងដូចម្តេចឬផ្ទះនោះជាផ្ទះដែលប្តីគាត់ធ្វើជូននៅពេលដណ្តឹង ។ល។

សេចក្តីពាក់ព័ន្ធនេះ ជាការយ៉ាងល្អិតដែលលោកអ្នកប្រឡងត្រូវអធិប្បាយក្នុងគ្រួសារទី១ ហើយដោយគ្រួសារទី១ នោះ មានលេខរៀងស្រាប់ហើយ លោកអ្នកប្រឡងនឹងមិនត្រូវពាក់ព្រំក្នុងការសរសេរឡើយ ។

សូមជួនតារាងជាគំរូ

ផ្ទះលេខ ១ :

គ្រួសារលេខ ១ :

ឪពុកឈ្មោះ . . . អាយុ . . . ស្រុកកំណើតនៅ . . . មានរបរកេសុីប្តូរពុំមាន

កូនប្រុស (បង្កើត ឬប្រសា) ឈ្មោះ . . . អាយុ . .

ស្រុកកំណើត របស់អ្នក ?

នាង . . . ជាប្រពន្ធឈ្មោះ . . . អាយុ . . . មាន
កូនប៉ុន្មាន ? . . . នាងនោះជាកូនចៅអ្នកណា នៅភូមិណា
ត្រូវជាញាតិនឹងប្តីដែរឬជាអ្នកដទៃ ?

កូនប្រុសឈ្មោះ . . . អាយុ . . . ធ្វើការអ្វី . . .
នៅរៀន . . . ឬនៅផ្ទះ ?

កូនស្រីឈ្មោះ . . . អាយុ . . . ធ្វើការអ្វី . . .
នៅរៀនឬនៅផ្ទះ ?

លោកអ្នកប្រឡងត្រូវធ្វើសេចក្តីពិយការណ៍ដូច្នេះ គ្រប់ផ្ទះកន្លះភូមិ
រៀបរាប់ ។

៣- ការទាក់ទងរវាងគ្រួសារទាំងឡាយក្នុងភូមិរបស់លោកអ្នក

ក្រោយដែលលោកអ្នកបានអធិប្បាយអំពីគ្រួសារមួយ ។ តាមលេខ
រៀង នឹងឈ្មោះដូចតាកន្លងមកនេះហើយ ការអធិប្បាយអំពីការទាក់-
ទងរវាងគ្រួសារទាំងនោះ ជាការងាយទៅវិញ ។

ឧបមាថា : នាងអ៊ុំ ជាម្ចាស់ផ្ទះលេខ ១ ត្រូវជាបងស្រីរបស់នាងនៅ
ដែលជាម្ចាស់ផ្ទះលេខ ៣ ប្តីនាងនៅនេះ ត្រូវជាប្អូនរៅរបស់នាងហើម

ទៅផ្ទះលេខ ១៤ ។ ប៉ុន្តែបើលោកអ្នកប្រឡងគ្រាន់តែអធិប្បាយពីការគាក់ខន្ធ
ខាងសាច់ញាតិ នោះមិនទាន់គ្រប់គ្រាន់ទៅឡើយទេ ត្រូវនិយាយពីការ
គាក់ខន្ធខាងការងារផង ដូចគ្រួសារលេខ ១ តែងតែទៅជួយធ្វើការស្មូន ដក
ប្រគាគាត់គ្រួសារលេខ ២ . ថាគ្រួសារលេខ ១ ទិនទិនគ្រួសារលេខ ៣ ឬមិនសូវចាប់
កេគ្នា ដោយហេតុអ្វី ? សូមប្រាប់ផង ថាឈ្មោះនោះកប់អាននឈ្មោះនោះ
ណាស់ ព្រោះធ្លាប់រៀនគ្រូជាមួយគ្នា ឬធ្លាប់មានការកំសត់តម្រើនអ្វី
មួយជាមួយគ្នា ឬថា អ្នកខាងពីរនាក់មិនស្និទិនគ្នាអំពីដំណើរស្រែ ។ល។

ម្យ៉ាងទៀត បើចង់និយាយពីគ្រួសារណាមួយ តើអ្នកស្រុកមាន
ទម្លាប់ហៅគ្រួសារនោះដូចម្តេចដែរ, តើគេដែលហៅថា «ពួកដើម
អង្គ្រង» ព្រោះទៅមុខផ្ទះនោះមានដើមអង្គ្រង់ឬទេ? បើមិនហៅដូច្នេះ
គេហៅដូចម្តេចវិញ ? ឬគេហៅថា «ផ្ទះម៉ឹងឯម» «ផ្ទះតាសម»
ដូច្នេះវិញទេ ?

ទៅក្នុងភូមិរបស់លោកអ្នកនោះ តើមានគ្រួសារណាមួយដែលគេ
កប់អាននៅឯណាគេឬទេ? បើមាន តើដោយហេតុអ្វីបានជាគេកប់អាននៅតាត់ ?
អ្វីដែលធ្វើឲ្យគេសំគាល់បានថា គេកប់អាននៅតាត់ ។

ទុយទៅវិញ បុះហេតុអ្វីបានជាមានគ្រួសារខ្លះ អ្នកស្រុកភូមិមិនសូវ
កប់អាន សូមអធិប្បាយពន្យល់ហេតុផលដូចខាងលើ ។

៤ - ជនដែលមិនមែនជាអ្នកបំណុះភូមិ

ក្នុងភូមិនីមួយ ។ មិនមែនមានសុទ្ធតែអ្នកភូមិអ្នកស្រុកនោះនៅទេ គឺតែងតែមានអ្នកចំណូលមកសំណាក់អាស្រ័យមួយរដូវ ឬមួយខ្ពាល ដើម្បីរកប្រាក់កាស ដូចជានៅរដូវស្លូង មានអ្នកចំណូលទៅស៊ីឈ្នួលស្លូងជក ភ្ជួរកសិ, រដូវត្នោត, ស៊ីឈ្នួលឡើងត្នោត; លុះផុតរដូវរក ទើបគេត្រឡប់ទៅកាន់ទីលំនៅខ្លួនវិញ ។ នៅភូមិខ្លះមានសាសន៍ដទៃដូចជា ចិន យួន ចាម រកស៊ីលក់ដូរ កាប់ជ្រូក កាប់គោលក់ ។ល។ តើជនចំនឹនេះមកនៅពីប៉ុន្មានឆ្នាំមកហើយ? បើអ្នកចំនឹនោះមិននៅជាប់នៅទីនោះ គឺមកដោយរដូវកាលទេ តើច្រើនមកនៅពេលណា? ពេលមកម្តងៗ ទៅអាស្រ័យនៅឯណា? មានការពាក់ព័ន្ធជាមួយអ្នកស្រុក អ្នកភូមិដូចម្តេចខ្លះ គេមករកស៊ីធ្វើការអ្វី? មកលក់ដូរឬរកទិញអ្វី? បើមកស៊ីឈ្នួលស្លូងជក តើគេគិតតម្លៃដូចម្តេច? គិតជាប្រាក់ ឬ ដូរវត្ថុអ្វី? ។ល។

៥- កិច្ចការដែលត្រូវធ្វើរួមគ្នា

កិច្ចការដែលត្រូវប្រជុំគ្នាធ្វើ ជួនកាលក្នុង ១ ភូមិត្រូវធ្វើ ៣ ឬ ៤ ដង ដូចជាឡើងភេន, កិច្ចការខ្លះទៀត ត្រូវធ្វើត្រប់ផ្ទះក្នុងភូមិតែម្តង ដូចជាបុណ្យនៅទីវត្ត បុណ្យកំចាត់ជម្ងឺ ឡើងអ្នកតា ។ល។ បើមាន

ការដូច្នេះកើតឡើង តើអ្នកស្រុកធ្វើដូចម្តេចខ្លះ ? សូមលោកអ្នកអធិប្បាយ
អំពីការរៀបចំធ្វើបុណ្យ នឹងការចាត់ចែងក្នុងរឿងបុណ្យនោះឲ្យបានហ្មត់
ចត់ល្អ ។

ម្យ៉ាងទៀត បើប្រសិនជាអ្នកភូមិនោះ នាំគ្នាដេញសត្វដូចជាជ្រូក
ព្រៃ ឈ្លូស ប្រើស ក្តាន់ ។ល។ តើអ្នកណាអ្នកកំណត់ថ្លៃ ? អ្នកណា
ជាអ្នកបញ្ជាឲ្យចេញដំណើរ ? អ្នកណាដែលគេត្រូវចាត់ការឲ្យដេញសត្វ
ទៅសំដៅអន្លាក់ ឬជង់ ឬក៏ប្រតឹង? អ្នកណាដែលត្រូវគេចាត់ឲ្យទៅចាំ
សំណាញ់ ឬប្រតឹង? អ្នកចាំងប៉ុន្មានដែលមានទាំងផ្សេង ។ ក្នុងរឿងដេញ
សត្វនោះ តើនៅពេលប្រដេញម្តង ។ ត្រូវមានទាំងដែល ។ កាលលើក
ឬដូចម្តេច ? ហេតុអ្វីបានជាអ្នកដេញចាំតែដេញ អ្នកចាំអន្លាក់នៅតែចាំ
អន្លាក់ដូច្នេះ? បើមានផ្លាស់ប្តូរគ្នាតាមកាល មិនទៀង តើអ្នកណាជាអ្នក
ចាត់ការប្រែប្រួលនោះ? ឬមួយគេមួលមាត់គ្នាលើសអ្នកណាមួយជាមេ ?
បើមានធ្វើដូច្នេះ តើគេលើសម្តងពុកសម្រាប់ប៉ុន្មានថ្នាំ ទើបលើសទៀត ?
ឬគេលើសសម្រាប់តែម្តងម្កាលប៉ុណ្ណោះទេ ? ការដែលលើសនោះ តើលើស
ព័ទ្ធពុកទៅកូន ព័ទ្ធមាទៅកូយ ឬក៏មានត្រួសារណាមួយដែលធ្លាប់តែធ្វើមេ
គេនៅពេលបបាញ់ ? លុះបាញ់ ឬចាក់សត្វនោះបានមក តើគេត្រូវ
ចែកគ្នាដូចម្តេច ដើម្បីសុខចិត្តចាំងអស់គ្នា ។

៦- កន្លែងសាធារណៈ:

នៅក្នុងភូមិនីមួយ ។ តែងតែមានកន្លែងសាធារណៈច្រើន សម្រាប់អ្នកភូមិនោះ ឬអ្នកដំណើរ ដូចជាសាលាទាន សាលាសំណាក់ព្រៃដែលគេនៅរកទុស ត្រពាំងដែលគេតែងនាំគោនៅឲ្យធឹកទឹក នៅជុំសាលឆ ឬនៅជង់មកអាស្រ័យ តើមានចំនៀមទម្លាប់ដូចម្តេចខ្លះទេចំពោះទីកន្លែងអស់ពាំងនោះ ?

ម្យ៉ាងទៀត ឧបមាថា : ដើមឈើដែលដុះនៅក្បែរសាលានោះចង់រលំសង្កត់សាលានោះ តើអ្នកណាត្រូវចាប់ផ្តើមគិតគូរកាប់ឈើនោះ ឬក៏មានចំនៀមថាត្រូវប្រជុំឲ្យមូលមាត់គ្នាទើបធ្វើបាន? ហើយការប្រជុំនោះធ្វើតែប្រុសៗទេ ឬស្រីមានសិទ្ធិឲ្យយោបល់ឆងបានដែរ? បើក្នុងចាប់ពីអាយុប៉ុន្មានៈទើបគេឲ្យចូលជជែកការបាន អ្នកណាខ្លះដែលជាអ្នកកាប់ឈើនោះ? ដល់កាប់បានមក ? អ្នកណាចាត់ចែងរឿងឈើនោះថាត្រូវយកទៅណា? ចែងចែកទៅអ្នកណា? ។ ល ។

៧- ការទាក់ទងរវាងភូមិជិតលោកអ្នកអធិប្បាយ និងភូមិជិតខ្លះ

ជួនកាលអ្នកភូមិដែលលោកអ្នកអធិប្បាយនោះ មានបងប្អូន ញាតិសន្តានទៅនឹងភូមិឆ្ងាយ ។ បើមានការទាក់ទងដោយញាតិសាច់ឈាម

នេះ សូមប្រាប់ថាគ្រួសារលេខប៉ុន្មាន ដែលមានការខាត់ខ្នងរបៀបនេះ (ព្រោះគ្រួសារមានលេខស្រាប់ទៅហើយ) ។

ឧបមាថា : មនុស្សឈ្មោះកៅ នៅក្នុងគ្រួសារលេខ ៣ តែងតែបុះខ្លឹងឆ្នុះណា ? . . . នៅភូមិណា ? . . . ព្រោះជាស្រុកកំណើតរបស់គាត់ ហើយគាត់តែងទៅលេងនឹងឪពុកម្តាយគាត់ដែលមានជីវិតរស់នៅឡើយ, ឬថាឈ្មោះ ម៉ក់ នៅក្នុងគ្រួសារលេខ ៤ ជារូបជួរចម្បងហើយកូនចៅនឹងសិស្សតណារបស់គាត់នៅភូមិណាមួយ តែងតែមកប្រជុំគ្នាធ្វើបុណ្យឡើងកេងនៅផ្ទះគាត់កល់ថ្ងាំ, ឬថាឈ្មោះនោះ ។ ក្នុងគ្រួសារលេខនោះមួយ ។ តែដល់ដូរគ្នោត តែងតែទៅរកស៊ីឡើងគ្នោតនៅភូមិណា ស្រុកណា ខែត្រណា ?

ចួនកាលភូមិនឹងភូមិ ត្រូវរួមកម្លាំងគ្នាធ្វើការ ឬបុណ្យទាន ដូចជាឡើងអ្នកតា ធ្វើកឋិន ពួនក្តុំស្រូវជាដើម សូមអធិប្បាយរៀបរាប់អំពីការចាត់ចែងរៀបចំបុណ្យនោះនឹងសូមប្រាប់ដើមកំណើតនៃបុណ្យនោះផង ។

៨- ការលក់-ទិញ-ដូរ នឹងទ្បើតផ្សេង ៗ តាមរបៀបខ្មែរ

គេនៅក្នុងភូមិតូចតាច ជិតក្តី ឆ្ងាយក្តី អ្នកស្រុកអ្នកភូមិតែងត្រូវការលក់ដូរផលដំណាំ ដែលបានមកអំពីចម្ការ ឬស្រែ គេត្រូវការលក់ដូរគោក្របី មាន់ទា កន្ទេល កន្ត្រែង អង្រឹង អំបោស បង្អែង ។ ល ។

ហើយត្រូវការទិញមកវិញនូវគ្រឿងប្រើប្រាស់ជាការចាំបាច់ ដូចជាប្រេង
កាត ជាដើម ចប ពូថៅ សំពត់អាវ បង្កៀន ។ល។ អ្នកខ្លះយកស្រូវ
ទៅដូរនឹងត្រី នឹងអំបិល នឹងប្រេងអុដ លោកអ្នកភ្ជាប់ឃានជ្រាបស្រាប់
ហើយថា ការលក់-ដូរ-ទិញនេះ អ្នកស្រុកខ្មែរយើងតាំមែនចេះតែធ្វើគាំង
ប្រថុយទេ គឺថាអ្នកស្រុកតែងដឹងថា ទៅដូរនេះគេត្រូវទៅលក់ ឬទៅ
ទិញអ្វីពីស្រុកនោះពីភូមិនោះ ហើយគេដឹងទៀតថា អ្នកស្រុកនេះមនុស្ស
ស្លូត អ្នកភូមិនេះមនុស្សមិនសូវសុចរិត ។ល។

ម្យ៉ាងទៀត មានជនមកពីភូមិក្រៅ ពីឆ្ងាយ . . . នាំរបស់មក
លក់ ដូចជាក្រាស កញ្ចក់ មេក្ប៉ ទឹកអប់ គ្រឿង ឆ្នាំង ចាំសង្ហរ ធូបទៀន
នំនែក កន្ត្រៃ កាំបិត សាច់ជ្រូក ម្ទុល ឬចូលមកកេទិញស្រូវ អង្ករ ស្ករ
ដែលអ្នកស្រុកធ្វើលក់, សូមអធិប្បាយអំពីការលក់ ឬដូរទិញផលិតផល
ទាំងនោះថា ច្រើនធ្វើនៅណា ដូរណា ទៅកន្លែងណា ?

ក្នុងគ្រួសារ ១ ប៉ើប្តីមានស្រែមួយ ប្រពន្ធមានស្រែមួយ ដែលជា
របស់ផ្ទាល់ខ្លួន មិនមែនជារបស់រួមសំចាច់ តើប្តីនឹងប្រពន្ធត្រូវស្រែនោះ
ទុកផលិតផលរួមគ្នា ឬដាច់ពីគ្នា ? តើមានរបស់អ្វីខ្លះដែលគេមិនត្រូវ
លក់ ត្រូវតែឲ្យទេ ឬឲ្យខ្លី ដល់អ្នកដឹកខាង ? មានរបស់អ្វីទៀតដែល
គេមិនឲ្យទេ ទោះជាគេឲ្យក៏ធ្វើកិច្ចជាលក់ដែរ (ដូចជាកាំបិត) គេថាកុំ
ឲ្យ ជាប់មិត្តភាព ។ ប៉ើមានរបស់អ្វីទៀត ដែលមានទំនៀមធ្វើដូច្នេះ

សូមអធិប្បាយនឹងពន្យល់ហេតុផលផង ។

ក្រុមដំនុំ សូមជំពាលោកអ្នកថា បើលោកអ្នកចង់សរសេរឿងនេះឲ្យបានល្អ លុះតែរកកូមិណាឲ្យតូចល្មម តែកូមិធំពេក មុខជាសរសេរពុំបានសព្វគ្រប់ល្អទេ ព្រោះផ្ទុះកំប្រែន គ្រួសារកំប្រែន ហើយលោកអ្នកមិនអាចស្គាល់គេអស់ទេ នឹងនាំឲ្យបាត់ខ្លួរភាពជាក់លាក់ នៅពេលដែលលោកអ្នកអធិប្បាយអំពីការពាក់ព័ន្ធរវាងគ្រួសារគ្រង់នេះ ពុំមែនបានសេចក្តីថា បើលោកអ្នកនៅកូមិធំ ឬនៅកូមិក្រង ហើយមិនអាចនឹងសរសេរការប្រឡងនេះបាននោះទេ គឺថាបើលោកអ្នកចង់ប្រឡងនៅតែប្រឡងបាន ដោយលោកអ្នកអធិប្បាយតែអំពីគ្រួសារបស់លោកអ្នក នឹងគ្រួសារណាដែលជាប់មានការពាក់ព័ន្ធជាមួយនឹងគ្រួសារលោកអ្នក ឬគ្រួសារណាដែលត្រូវជាសាច់ញាតិនឹងគ្រួសារលោកអ្នកប៉ុណ្ណោះ ។

សេចក្តីដែលលោកអ្នកបានមើលបានអាន តាំងពីលើមកទាំងប៉ុន្មាននេះ ជាលំនាំឲ្យអស់លោកអ្នកជ្រាបថា ការបែបនេះហើយ ដែលក្រុមដំនុំចង់ដឹង ប៉ុន្តែក្រុមដំនុំមិនប្តេជ្ញាថា អ្នកសរសេរត្រូវតែគោរពតាមលំនាំនេះជាដាច់ខាតនោះទេ គឺថាលោកអ្នកប្រឡងអាចអធិប្បាយយ៉ាងខ្លួចខ្លីអំការពាក់ព័ន្ធរវាងកូមិនឹងកូមិ ទំនៀមលក់ដូរ នឹងទំញាវគ្នាផ្សេង ។ ប្តូនិយាយអំពីរឿងអ្វីទៀតពាក់ព័ន្ធដោយកូមិ ដែលក្រុមដំនុំពុំបានជានឹកឃើញសួរ ដូចជាទំនៀមពាក់ព័ន្ធកូមិនឹងវត្ត ។ ល ។ ហើយបើមានការ

គួរកត់សំគាល់ កំសួមអធិប្បាយផង ។

សង្ខេបសេចក្តីថា គឺជាក្រុមដំនុំត្រូវការចង់ដឹងអំពីការគាត់ខឹងក្នុងការរស់នៅជាធម្មតារបស់ជនជាតិខ្មែរ ។

មុននឹងសរសេរតែង សូមអស់លោកអ្នកម៉ៅហើយម៉ៅទៀតនូវសេចក្តីខាងលើឲ្យយល់ល្អិតល្អន់សឹមសរសេរ, ទើបសរសេរបានល្អ ។

ជាពិសេស, កូមិណាដែលលោកអ្នកត្រូវការសរសេរតែង បើលោកអ្នកចេះចាំរឿងព្រេងនៃកូមិនោះ ដែលទាក់ទងដោយវត្ត ដោយអ្នកតា ។ល។ ដោយមនុស្ស - សត្វ ឬរុក្ខជាតិណាមួយ នោះជារឿងវែងក្តី ខ្លីក្តី សូមសរសេររឿងនោះមកផង ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ពិធីបុណ្យចំរើនព្រះជន្មវស្សា

សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ

ព្រះនាម ឥន្ទ្រញាណោ កុល-ទេស

ពិធីបុណ្យចំរើនព្រះជន្មវស្សានេះ បានកើតឡើងដោយកំលាំងសាមគ្គីនៃពួកបរិពុទ្ធសិទ្ធ-សិស្សានុសិស្សត្រង់ជាន់ថ្នាក់ ដែលបានយល់ឃើញថា: សម្តេចព្រះសុធម្មាធិបតីសង្ឃនាយក ព្រះនាម ឥន្ទ្រញាណោ កុល-ទេស មានព្រះជន្មគត់រប់ពី ៧៣ ព្រះវស្សាហើយ ។ នៅថ្ងៃ ១៣ កើត ខែស្រាពណ៌ឆ្នាំថោះនេះ គិត្រូវចំលើថ្ងៃ.ខែ.ឆ្នាំ ដែលសម្តេចបានសម្ភពនោះផង ។ ដូច្នេះ ទើបពួកពុទ្ធបរិសិទ្ធ-សិស្សានុសិស្សត្រង់ជាន់ថ្នាក់ តំណាត់ធ្វើដោយដាច់ខាត នូវពិធីបុណ្យចំរើនព្រះជន្មវស្សានេះឡើង ។

ពិធីបុណ្យនេះ បានទទួលនូវការគាំទ្រគ្រប់ជៃបយ៉ាងអំពីសំណាក់លោកសប្បុរស-ពុទ្ធបរិសិទ្ធ-សិស្សានុសិស្ស ព្រមទាំងអំពីក្រសួងធម្មការជាអាទិ៍ ដែលបានយកចិត្តទុកដាក់ចាត់ចែងតំច្ចបុណ្យ រហូតដល់បានសំរេចជាស្ថាពរ ហើយជាពិសេស គឺបានទទួលនូវព្រះបរមកជួបត្តម្ភ អំពីសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ជាអម្ចាស់ដ៏វិតលើត្បូង ទឹងអំពីសម្តេចព្រះទេបយុវរាជ នរោត្តម-សីហនុ ព្រះប្រមុខរដ្ឋនៃព្រះរាជអាណាចក្រកម្ពុជា នូវចតុបច្ច័យរួមចំនួន ៦៥.០០០រ៉ៀល (ប្រាំ-

ច្រាំពាន់រៀល) ។

សម្តេចព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះរាជហឫទ័យស្តេចយាងជាព្រះរាជាធិបតី ក្នុងពិធីស្រង់ទឹកភ្លៀ ប្រគេនសម្តេចព្រះសុធម្មាធិបតី សង្ឃនាយក នៅព្រឹកថ្ងៃទី ៤ ខែសីហា គ. ស. ១៩៦៣ ដើម្បីបញ្ចប់ពិធីបុណ្យចំរើនព្រះជន្មវស្សា ។

រាជពិធីបុណ្យដែលបានប្រព្រឹត្តធ្វើឡើង ដូចមានតោលតនៅនេះ :

- ថ្ងៃសៅរ៍ ១៣ កើត ខែស្រាពណ៍ ឆ្នាំថោះបញ្ចស័ក ព. ស. ២៥០៦ គឺថ្ងៃទី ៣ សីហា គ. ស. ១៩៦៣

ម៉ោង ១៩ . ០០ : ជួបជុំពុទ្ធបរិស័ទគ្រប់ហាន: គឺចៅអធិការគ្រប់វត្តនៃគណៈធម្មយុត្តិកនិកាយ ក្នុងព្រះពុទ្ធសាសនាចក្រកម្ពុជា ឧបាសក ឧបាសិកា នៅលើព្រះវិហារវត្តបទុមវតីពពជវរាភម មានការអុជប្រទីបជ្វាលា គ្រប់ទីតំខ្នែងបូជនីយស្ថានផ្សែង-ផ្សែង រហូតដល់គ្រប់កុដិក្នុងវត្តបទុមវតីពពជវរាភម ។

ម៉ោង ១៩ . ៣០ សម្តេចព្រះសុធម្មាធិបតីសង្ឃនាយក និមន្តឡើងគង់លើព្រះថេរាសនៈក្នុងព្រះវិហារ ។

ម៉ោង ១៩.០០ : លោកអ្នកឧកញ៉ាពិភក្តិសាសនៈ អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនសិក្សាធិការ « ម៉ែន - ឈុំ » ជាដំណាងតួតពុទ្ធបរិស័ទ-សិស្សានុសិស្សចាំងអស់ខ្ញុំងសុន្ទរកថាលើកទូរកង-

ការគុសល ប្រគេនសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក ដូចមានតទៅនេះ

សុភាសិតកថា

សូមក្រាបថ្វាយបង្គំ ក្រោមព្រះបាទសម្តេច ព្រះសង្ឃបិតា ជាទីគោរព សូមទានជ្រាប ។

ខ្ញុំព្រះករុណា តាងនាមនៃក្រុមពុទ្ធបរិស័ទ-សិស្សានុសិស្សត្រង់ប្រកេទ សូមសម្តេចជាទីគោរព ព្រះមេត្តាប្រោស ប្រទានឱ្យវេលាកាស ដើម្បីថ្វាយរៀបរាប់នូវបុព្វហេតុបុណ្យចំរើនព្រះជន្មវស្សានេះ ប្រគេនដោយសេចក្តីសង្ខេបដូចតទៅនេះ :

បពិត្រសម្តេចជាទីគោរព បុណ្យចំរើនព្រះជន្មវស្សានេះ បានផ្តួចផ្តើមកើតឡើងជារូបរាងពិតប្រាកដ ដោយទ្រព្យតតិរូបមួយនៃពុទ្ធបរិស័ទ សិស្សានុសិស្សត្រង់ប្រកេទ គឺព្រះសង្ឃធំធំគ្រប់ស្តេជាច្រើនរូប មានព្រះសុទ្ធម្មប្បីជា កេត-ធន អាចារ្យសំពាច់ត្តបទុមវតីជាអាទិ៍ បានគិតឃើញរៀង-រៀងខ្លួនថា :

សម្តេចជាអម្ចាស់ ជាព្រះបិតា បានទទួលនូវបន្ទុកការត្រង់ត្រួតគណៈសង្ឃពុទ្ធសាសនិក អស់រយៈកាលជាយូរផ្តាំមកហើយ តែពួកពុទ្ធបរិស័ទ-សិស្សានុសិស្សត្រង់ប្រប ដែលស្ថិតនៅក្រោមព្រះកិច្ចត្រង់ត្រួតរបស់សម្តេចជាអម្ចាស់ ពុំទាន់ដែលផ្តើមធ្វើតធីបុណ្យមួយ ប្រគេនជាកិច្ច-

តបស្នង ចំពោះព្រះករុណាចិត្តល្អ ឲ្យសមនឹងព្រះកិច្ចដឹកនាំ ដែលមានការៈដ៏ធ្ងន់នេះនៅឡើយ ។

មួយវិញទៀត មកដល់ថ្ងៃសៅរ៍ ១៣ កើត ខែស្រាពណ៌ ឆ្នាំថោះនេះ ក៏ត្រូវចំលើថ្ងៃ-ខែ-ឆ្នាំ ប្រសូតរបស់សម្តេចជាអម្ចាស់ផង ដែលជាព្រឹត្តិហេតុនាំឲ្យខ្ញុំព្រះករុណាខាំងឡាយ មានការប្រមូលរួបរួមគ្នាធ្វើពិធីបុណ្យចំរើនព្រះជន្មវស្សា ប្រគេនសម្តេចជាអម្ចាស់ ក្នុងឱកាសនេះបាន ។

សេចក្តីត្រមត្រៀងប្រកបដោយសុឆន្ទៈ រវាងព្រះសង្ឃនឹងគ្រស្ថក៏បានស្រេច ចុះសំរុងគ្នាជាឯកច្ឆន្ទ ថាត្រូវតែរួបរួមគ្នាធ្វើបុណ្យនេះ ឲ្យបានសំរេចកុំបីខាន ។

ទើបមហាសន្និបាត បានសំរេច សូមថ្វាយកិត្តិយសប្រធានគណៈកម្មការបុណ្យ ទៅអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-ឥស្សរៈ ទឹងជួនទៅលោកឧកញ៉ាមាស-សាអែម តំណាងខាងពួកឧបាសក ឲ្យជាអ្នកដឹកនាំពួកពុទ្ធបរិស័ទសិស្សានុសិស្សត្រប់ឋានៈ រៀបចំធ្វើពិធីបុណ្យឲ្យបានសំរេច ។

ថ្វាយកិត្តិយសអធិបតានី ទៅអ្នកអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ-សុមនមេធ ទឹងអ្នកអង្គម្ចាស់ក្សត្រី នរោត្តម-ឧត្តក តំណាងខាងឧបាសិកា ឲ្យជាអ្នកដឹកនាំពួកពុទ្ធសាសនិកាត្រប់ឋានៈ រៀបចំខាងយោគូទឹងភោជនាហារត្រប់យ៉ាង ។

ព្រមទាំងព្រះសង្ឃ ៧ជាគណៈ-ហានានុក្រម-កិក្ខុ-សាមណេរគ្រប់អង្គ ក្នុងវត្តបទុមវតីកដវែកកម មួយអន្ទោរដោយព្រះសង្ឃគ្រប់វត្ត ក្នុងខ័ណ្ឌ ឧត្តរ ព្រះសង្ឃជាចៅអធិការ ព័ត្រប់ខេត្ត ក្នុងព្រះរាជអាណាចក្រកម្ពុជា ចានឧទ្ទិសកុសលបុណ្យនេះផង ។ ម្យ៉ាងទៀត ក្រសួងធម្មការ ក្រោមការដឹកនាំ នៃលោកអ្នកឧកញ៉ាអនុរដ្ឋលេខាធិការ ម៉ែន-ឈុំ ចានជួយឧបត្ថម្ភយ៉ាងពេញទំហឹង ដោយចានផ្តល់នូវបុគ្គលិក ព្រមទាំងរថយន្ត នៃក្រសួង ឲ្យដួយចាត់ចែងកិច្ចការផ្សេង ។ រហូតដល់ចានសំរេចជាស្ថាពរ ។

ខាងសាលាក្រុង ក៏ចានរៀបចំធ្វើបាព័ត៌ មានលំអដោយផើង កូនឈើក្តៅជាតិផ្សេង ។ ទៀតផង ។

លោកអ្នកឧកញ៉ា តង់-ហេង នាយកឥន្ធនាគារ ចានផ្តល់ភ្នាក់ងារជាច្រើនរូប ឲ្យមកជួយធ្វើកិច្ចការក្នុងវត្ត ឲ្យរឹងតែតែប្រកបដោយសោភណភាព ព្រមទាំងចានផ្តល់អុសសំរាប់ដុត ចំអិនអាហារ ចំនួន ១០ ម៉ែត្រគីបមកទៀតផង ។

ខាងក្រុមហ៊ុនអគ្គីសនីកម្ពុជា ចានផ្តល់ភ្លើង ដើម្បីតុបតែងក្នុងពិធីបុណ្យនេះ ដោយឥតគិតតម្លៃ ព្រមទាំងពួកក្រុមជាងនៃកន្លែងយោធពលខេមរភូមិន្ទ ជួយធ្វើកិច្ចការរៀបចំភ្លើងយ៉ាងជិតដល់ ។

ក្រសួងឃោសនាការជាតិ ចានជួយបំពេញកិច្ចការ ខាងឃោសនាន័ងបោះពុម្ពកម្មវិធីបុណ្យ ដោយឥតគិតតម្លៃ ដើម្បីចូលជាកុសលក្នុងពិធី-

បុណ្យនេះផង ។

ខាងព្រះបរមកដរាំង ជាន់ជួយ១បត្តម្ភដោយគ្រឿងសម្ភារៈជាច្រើនមុខ មានតំកល ព្រំជាដើម ព្រមទាំងចាត់បុគ្គលិក ឲ្យមករៀបចំដោយសព្វគ្រប់ ។

លោកចាន់ហ្វាន់គ្រឹស្ដាន បុប្ផស៊ីកូឡា និងលោកចាន់ហ្វាន់គ្រឹស្ដានគ្រឹនស្ប៉ត ជាន់ជួយ១បត្តម្ភខាងកេសដ្ឋៈ ដើម្បីចូលជាកុសល ទៅកងពិធីបុណ្យនេះផងដែរ ។

បពិត្រសម្តេចជាអម្ចាស់ ការចាត់ចែងពិធីបុណ្យ ជាន់សំរេចដូចបំណងរបស់ខ្ញុំព្រះករុណាទាំងឡាយហើយ ។ ឥឡូវនេះ ខ្ញុំព្រះករុណាទាំងឡាយ សូមលើកនូវកងការកុសល ដែលកើតឡើងពីត្រង់ផ្នែកទាំងអស់ ប្រគេនសម្តេចជាទីគោរព ដើម្បីជាកិច្ចបូជា ចំពោះព្រះករុណាគុណដ៏ធ្ងន់របស់សម្តេចជាអម្ចាស់ ។

សូមសម្តេចជាអម្ចាស់ មេត្តាទទួលដោយព្រះទ័យអនុគ្រោះ ។

ទៅទីបំផុតនេះ ខ្ញុំព្រះករុណាទាំងឡាយជាពុទ្ធសាសនិក សិស្សានុសិស្សត្រង់ប្រកែក សូមបួងសួងដល់ព្រះមហាគេជាន្ទភាគនៃគុណបុណ្យព្រះរតនត្រ័យ ទើងគេជាន្ទភាគនៃទេព្តាកងវិសេនគោដ៏ចត្រកាលទាំងអស់ សូមអភិបាលរក្សា សម្តេចជាទីគោរព ជានប្រកបដោយព្រះបរមសុខ សព្វទិពកត្តីកាល កុំបីមានព្រះរោគាព្យាធិអ្វី មកបៀតបៀន-

ព្រះកាយពលព្រះឆ្នំបានឡើយ ។

សូមសម្តែចជាទីគោរព ប្រកបដោយព្រះជន្មាយុជាន៍រយព្រះវស្សា ទីឆ៍សូមប្រកបដោយព្រះពុទ្ធគុរ ៦ ប្រការគឺ ព្រះជន្មាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីទីឆ៍បានត្រង់ត្រង់ពួកពុទ្ធបរិស័ទ-សិស្សាទុសិស្សត្រង់ប្រកេទ ឲ្យបានចំរើនរុងរឿងតរៀងទៅ ។

មួយចំណែកទៀត សូមថ្វាយព្រះពរដល់ចំពោះ

- សម្តែចព្រះមហាក្សត្រីយានី ព្រះមាតាជាតិ ជាអម្ចាស់ដីវិតលើក្បាលឆ៍

- សម្តែចព្រះប្រមុខវង្ស ព្រះបិតាឯកជាតិ ជាព្រះអគ្គពុទ្ធសាស-នូបត្ថម្ភកដ៏ខ្ពង់ខ្ពស់

សូមព្រះអង្គគាំនឹងខ្ញុំ ខ្ញុំឆ៍បានប្រកបដោយព្រះបរមសុខសួស្តីសិរី-មង្គលត្រង់ប្រការ សូមគុណបុណ្យព្រះរតនត្រ័យ ទីឆ៍វត្ថុសក្តិសិទ្ធិនាគ្នាតិតណោកគាំឆ៍មួល ជួយអភិបាលរក្សាព្រះអង្គត្រង់ពេលវេលា ។

សូមខ្ញុំបានប្រកបដោយព្រះមហាជោគជ័យត្រង់ទិសទី សត្រូវគាំឆ៍ឡាយកុំបីមកយាយីព្រះកាយពលព្រះអង្គបានឡើយ ។

សូមខ្ញុំបានប្រកបដោយព្រះជន្មាយុជាន៍រយព្រះវស្សា ដើម្បីជាមួយបីត្រជាក់ដៃប្រជាពលរដ្ឋ ជាកូនចៅតរៀងទៅ ។

សូមគោរព ។

លុះលោកអ្នកទទួលញ៉ាំតនុវដ្ឋលេខាធិការក្រសួងធម្មការ « ម៉ែន-ឈុំ » ថ្វាយសុន្ទរកថានេះចប់ហើយ សម្តេចព្រះសុធម្មាធិបតីសង្ឃនាយក កំសត់ព្រះទ័យ ថ្វាយនូវសុន្ទរកថាមួយ ទទួលព្រះអំណរគុណវិញ មានសេចក្តីដំណឹងស្រួលដូចតទៅនេះ : ។

សូមតិតបថវដីកាព្រះបេកខុនុត្តរគ្រប់ព្រះអង្គ

សូមថ្វាយព្រះពរ ទ្រង់ ព្រះករុណាពិសេសគ្រប់ព្រះអង្គ

សូមចំរើនពរឯកទត្តម - អស់លោក - អ្នកសប្បុរសទាំងអស់

សូមបានជ្រោះ ។

សូមទ្រង់ជ្រោះ ។

សូមជ្រោះ ។

ខ្ញុំករុណា - អាត្មាភាព បន្ទាប់ពីបានស្តាប់នូវសេចក្តីថ្វាយរៀបរាប់ពីសកម្មភាពបុណ្យ ដោយតំណាងព្រះករុណាគ្រប់ព្រះអង្គ ទ្រង់ព្រះករុណាពិសេស និងឯកទត្តម - អស់លោក - អ្នក មកមានសេចក្តីរំភើបក្នុងហឫទ័យយ៉ាងក្រៃលែង ដែលរកវត្ថុអ្វីមកប្រៀបប្រដូចពុំបាន ហើយមានសេចក្តីគ្រេកអរសោមន្សជាអតិបរមា ក្នុងការដែលបានឃើញជាក់ស្តែងនឹងភ្នែក នូវសេចក្តីសាមគ្គីយ៉ាងជិតស្និទ្ធ រវាងព្រះសង្ឃនឹងពុទ្ធបរិស័ទខាងគ្រហស្តគ្រប់ជាន: ដែលបានយកព្រះទ័យ - យកព្រះហឫទ័យនឹងយកចិត្តទុកដាក់លើរូបខ្ញុំករុណា - អាត្មាភាព ដែលកាន់តែមានជំនាញ-



សម្តេចព្រះសុគន្ធាធិបតី សង្ឃនាយក ភូល-ទេស (គិន្នញ្ញវណ្ណោ) នៃគណធម្មយុត្តិកនិកាយ
ព្រះអង្គកំពុងនិមន្តអង្គទៀនបូជាព្រះភនវៃ ក្នុងឱកាសពិធីបើនព្រះដន្តវស្សាព្រះអង្គគំរប់ ៣៣
នៅថ្ងៃ ១៣ កើតខែស្រាពណ៌ ឆ្នាំខោះ ព.ស. ២៥០៦ នៅវត្តបទុមវតីពាក់ព័ន្ធ ។

ណាស់ទៅហើយ ព្រមទាំងបានឃើញនូវថាមពលស្រស់បែបយ៉ាងនេះចំពោះ
ព្រះករុណាស្រីព្រះអង្គ . ទ្រង់ - ឯកទត្តម - អស់លោក - អ្នក ក្នុងការរៀប
ចាត់ចែងព័ធមុណ្ឌចំរើនព្រះជន្មវស្សា ដើម្បីប្រទូន្មករុណា - អាត្មាភាព
ដែលប្រកបដោយសេចក្តីរុងរឿងយ៉ាងក្រៃលែង ហួសពីសេចក្តីស្មានទុក
របស់ខ្ញុំករុណា - អាត្មាភាពទៅទៀត ។

ខ្ញុំករុណា - អាត្មាភាព សូមគោរពសរសើរដោយហោឡាវិក នូវ
ភ្លុតតតិដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាស្រីព្រះអង្គ . ទ្រង់ - ឯកទត្តម - អស់
លោក-អ្នក សព្វប្រសេចំពោះអស់ ដែលបានឆ្លងខ្ញុំកន្លងមកដោយភាពយ៉ាងធំ
មកឲ្យខ្ញុំករុណា - អាត្មាភាព ក្នុងពេលនេះ ដោយបានរួមរួមគ្នាយ៉ាង
សប្បាយសប្បាស់ ប្រារព្ធធ្វើកតិការកុសលយ៉ាងគ្មានឆ្គង ដើម្បីលើក
ប្រគេនចំពោះស្រេចមកខ្ញុំករុណា - អាត្មាភាព ដែលពុំអាចឲ្យខ្ញុំករុណា -
អាត្មាភាព - មានការបំរែកក្ងេចបាន ទោះជាក្នុងអនាគតដ៏វែងឆ្ងាយដូចម្តេច
ក៏ដោយ ។

អំពើជាកុសលបែបនេះ នូវចាត់ទុកជាគំរូដ៏ត្រចះត្រចង់ដែលឲ្យដំ
ណាប់ដល់តញ្ញូកសមណ ឬព្រាហ្មណ៍ជាន់ក្រោយ ឃើញឮស្តាប់ថា យើង
គឺជាអ្នកប្រកាន់ខ្ជាប់តាមព្រះពុទ្ធឬណ្ណាំ ឥតខាន់ខ្ចោះត្រង់ណាឡើយ ។

ដ្បិតព្រះសក្យមុនីគោតមបរមសម្ពុទ្ធ បានត្រាស់ស្តីដែងថា សេចក្តី
ញញួ
ឥតញាក់តវេទី ជាប្រធានៃកុសលទាំងអស់ ។

អាស្រ័យហេតុនេះ ឯកុណា - អាត្មាភាព មានចិត្តត្រេកអរជាខ្លាំងបំផុត សូមសរសើរខ្លួនខ្ញុំទុត្តមគតិដ៏ទុត្តង្គទុត្តម របស់ព្រះករុណាគ្រប់ព្រះអង្គ - ទ្រង់ - ឯកទុត្តម - អស់លោក អ្នកសប្បុរសគ្រប់ប្រភេទជាថ្មីម្តងទៀត ដោយឃើញថា ព្រះករុណាគ្រប់ព្រះអង្គ-ទ្រង់-ឯកទុត្តម-អស់លោក-អ្នកសប្បុរសទាំងឡាយ បានទាំគ្នាកាន់ទីរក្សាយ៉ាងម៉ឺងម៉ាត់ហើយប្រតិបត្តិយ៉ាងដិតដល់ តាមដំណៀប្រកបដោយហេតុផលក្នុងពេលនេះ ។

ឥឡូវនេះ ខ្ញុំករុណា-អាត្មាភាព សូមទទួលដោយសេចក្តីត្រេកអរសាទរជាបំផុត នូវបួនទីយកម្មគ្រប់ថែបយ៉ាងទាំងអស់ ដែលបានកើតឡើងដោយសេចក្តីខ្នះខ្នែងយ៉ាងពេញទំហឹង របស់ព្រះករុណាគ្រប់ព្រះអង្គ-ទ្រង់-ឯកទុត្តម-អស់លោក-អ្នកសប្បុរសគ្រប់ប្រភេទ ។

ហើយជាអវសានេះ ខ្ញុំករុណា-អាត្មាភាព សូមទទួលថ្វាយនូវកតញ្ញូកតវេទិតាកុសលនេះ ចំពោះព្រះអតីតមហាក្សត្រគ្រប់ព្រះអង្គ មានព្រះបាទសម្តេចព្រះហរិរក្សភមាតិសក្សរាជាធិបតី ព្រះអង្គ ខ្លួន ជាដើម ទំនប្រគេនព្រះអតីតសង្ឃនាយកគ្រប់ព្រះអង្គ មានសម្តេចព្រះ សុតន្ធា សង្ឃរាជាធិបតីជាដើម សូមព្រះអង្គបានទទួលយកនូវតែដួមខ្ញុំញ្ញាវល តាមសព្វព្រះពុទ្ធហឫទ័យ ។

មួយវិញទៀត សូមថ្វាយព្រះកុសលនេះចំពោះ



សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋកម្ពុជា ទ្រង់ស្តេចមកជាព្រះអធិបតី នៅវត្តបុទុមវតី ក្នុងពិធីស្រង់ទឹកភ្ញី ប្រគេនសម្តេចព្រះសុធម្មាធិបតី សង្ឃនាយក នៅព្រឹកថ្ងៃទី ៤—៨—៦៣ ដើម្បីបញ្ចាប់ពិធីចំរើនព្រះជន្មវស្សាព្រះអង្គ ។

- សម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ជាម្ចាស់ជីវិត

- សម្តេចព្រះទេបយុវរាជ នរោត្តម-សីហនុ ព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ សូមព្រះអង្គគាំងខ្ញុ ទ្រង់ជាន់ប្រកបដោយព្រះបរមសុខសួស្តីសិរីមង្គលគ្រប់ពេលវេលា កុំបីមានព្រះរោគាពាធិសឹកសត្រូវអ្វីមកបៀតបៀនព្រះអង្គបាន ហើយសូមព្រះមហាតេជានុភាព នៃគុណបុណ្យព្រះរតនត្រ័យនឹងខេត្តាកងវែនកោដិចក្រវាឡ ជាជាប់ថែរក្សាព្រះអង្គ គ្រប់ទិវាកាលកុំបីខានឡើយ ។

ម្យ៉ាងទៀត ខ្ញុំករុណា-អាត្មាភាព សូមប្រគេន-សូមថ្វាយ នឹងសូមជូនសត្ថុសាធុការពារ ចំពោះព្រះករុណាគ្រប់ព្រះអង្គ-ទ្រង់-ឯកទត្តមអស់លោក-អ្នកស្បុរសគ្រប់ប្រភេទ សូមឲ្យបានប្រកបតែសេចក្តីសុខសួស្តីសិរីជ័យជោគគ្រប់បែបយ៉ាង កុំបីមានអន្តរាយអ្វីមកបៀតបៀនបាន ហើយសូមឲ្យបានសំរេចនូវពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

លុះថ្លែងសុទ្ធរេចាចប់ហើយ សម្តេច ក៏បានប្រទានទេសាសឲ្យពួកតុទ្ធបរិស័ទគ្រប់ប្រភេទ ធ្វើកិច្ចនមស្ការព្រះរតនត្រ័យ-សមាទានសីលចំរើនព្រះបរិត្ត លុះចប់ស្រេច ទើបធម្មកថិក ១អង្គសំដែងធម្មទេសនា ។

បន្ទាប់ពីពេលទេសនាចប់ មានចញ្ចាំងភាពយន្ត នឹងក្លែងតួរត្រីរេងជូនប្រជាជនទស្សនា រហូតដល់ពេលរំលងអធ្រាត្រ ។

លុះដល់ថ្ងៃអាទិត្យ ១៤ កើត ខែស្រាពណ៍ តិថ្ងៃទី ៤ ខែសីហា ព.ស. ២៥០៦ គ.ស. ១៩៦៣

- វេលាម៉ោង ៦.៣០ នាទី ពុទ្ធបរិស័ទ មានអ្នកអង្គម្ចាស់ ក្សត្រី ស៊ីសុវត្ថិ-សុមនមេធ ឧទ្ទិសអ្នកអង្គម្ចាស់ក្សត្រី នរោត្តម-ទត្តក ជាប្រធាន ចាប់រៀបយាគូប្រគេនព្រះសង្ឃចំនួន ១០០ អង្គតាមផ្លូវការ ហើយនិងមានបន្ថែមព្រះសង្ឃដទៃទៀតជាច្រើនអង្គ ។

- ម៉ោង ៨.០០ មានការជួបជុំពួកពុទ្ធបរិស័ទយ៉ាងច្រើនកុះករ នៅមុខព្រះវិហារ វត្តបទុមវតីរាជវរារាម ដើម្បីរង់ចាំទទួលព្រះរាជដំណើរ នៃសម្តេចព្រះប្រមុខរដ្ឋ នរោត្តម-សីហនុ ព្រះបិតាឯករាជ្យជាតិ ។

- ម៉ោង ៨.៣០ នាទី សម្តេចព្រះសុម្មាធិបតីសង្ឃនាយក ព្រះនាម ឥន្ទញ្ញាណោ អុល-ខេស ចាប់និមន្តពីកុដិរបស់ព្រះអង្គទៅ កាន់ព្រះវិហារ ដោយមានព្រះរាជាគណៈ ហានាទុក្រម - ទៅអធិការ និមន្តអមជាបច្ចាសមណៈផង ។

លុះដល់ម៉ោង ៩.០០ សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាសន្តិភាពជាតិ ដោយមានព្រះរាជបរិពារដង្ហែផង ស្តេចព្រះរាជដំណើរ ។

ពិធីការចាប់ផ្តើម ដោយអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-ឥស្សរៈ ប្រធានគណៈកម្មការបុណ្យ ជាដំណាងពួកពុទ្ធបរិស័ទ - សិស្សានុសិស្ស គ្រប់ប្រភេទ ថ្វាយព្រះសុន្ទរកថាស្វាគមន៍ មានសេចក្តីផ្តើមដូចតទៅនេះ :

សូមព្រះរតនៈដ៏កល់លើត្បូង

សូមគ្រាបបង្គំទូលព្រះករុណាថ្វៃតិសេស សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាឯកភាជ្យជាតិ

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ទូលព្រះបង្គំជាខ្ញុំ ក្នុងនាមនៃពួកពុទ្ធបរិស័ទ ទាំងបព្វជិត - គ្រហស្ថ គ្រប់ហាន: សូមថ្វែងនូវអំណរព្រះមហាករុណាគុណយ៉ាងស្មោះអស់ពីដួងចិត្ត ចំពោះព្រះករុណាថ្វៃតិសេស ដែលទ្រង់ព្រះមេត្តាប្រោសទ្វៀតនុកាសយាងមក ជាព្រះពាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងពិធីបុណ្យចំរើនព្រះជន្មវស្សា នៃសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ដែលញាំងពិធីបុណ្យ ឲ្យមានសភាពរុងរឿងជាអតិបរមា ។

សូមទ្រង់ព្រះមេត្តាប្រោស តទៅនេះ សូមព្រះពរជាន់វាកាសខ្ពស់ថ្វាយ ពីបុព្វហេតុនៃពិធីបុណ្យនេះ ដោយសង្ខេបដូចតទៅនេះ:

ចាប់តាំងពីបានទទួលព្រះរាជសព្រះពរជាន អំពីព្រះពរជបល្ង្គ នូវហាន:ជាសម្តេចព្រះសង្ឃនាយក គណៈធម្មយុត្តិកនិកាយ ចំនួន ៧ ឆ្នាំមកហើយ សម្តេចអង្គនេះ បានគ្រប់គ្រងបរិស័ទឲ្យមានសាមគ្គីភាព រឹងរឹតភាព នឹងសេចក្តីសុខសាន្ត ដោយព្រះទ័យត្រជាក់ត្រជុំ ប្រកបដោយខន្តីនឹងមេត្តា ហើយព្រះអង្គដឹកនាំការកិច្ច ញាំងព្រះពុទ្ធសាសនាឲ្យបតាវ: ចំរើនរុងរឿងត្រចះត្រចង់ គួរជាទីជ្រះថ្លាយ៉ាងក្រៃលែង ។

ឥឡូវនេះ សម្តេចកាន់តែមានព្រះជន្មវស្សាជរាណាស់ដែរហើយ ពុទ្ធបរិស័ទដែលធ្លាប់តែជ្រះថ្លាខ្ជិលស្រឡាញ់យ៉ាងជ្រាលជ្រៅ ចំពោះព្រះទ័យសម្តេច ពុំខាន់ចានធ្វើកុសលពិសេសអ្វីមួយប្រគេន ឲ្យសមគួរនឹងព្រះគុណនៅឡើយ ។

អាស្រ័យហេតុនេះហើយ ទើបពួកពុទ្ធបរិស័ទ ចាំងបពូជិត-គ្រហស្ថ ចានរួបរួមគ្នាជាឯកច្ឆន្ទ ចាត់ចែងធ្វើបុណ្យចំរើនព្រះជន្មវស្សា ថ្វាយតម្រង់នឹងថ្ងៃ-ខែ-ឆ្នាំសម្តែងនៃសម្តេច ដែលគាប់ជាព្រះជន្មាយុ ៧៣ ព្រះវស្សា ដើម្បីសំដែងកតញ្ញូ-កតវេទិតា តបស្នងនឹងព្រះគុណសម្តេចជាម្ចាស់ ។

សូមកុសលចាំងអម្បាលនេះ នឹងតេជានុភាពនៃព្រះរតនត្រ័យជួយអភិបាលរក្សាព្រះអង្គ ឲ្យចានប្រកបដោយសុខភាពបរិបូរ សព្វទិវាកត្រីកាល គង់នៅជាសង្ឃឋិតា ជាម្លប់ពុទ្ធបរិស័ទគណៈធម្មយុត្តិកនិកាយ ជាយូរអង្វែងតរៀងទៅ ។

ជាបញ្ចប់នេះ ទូលព្រះបង្គំ សូមថ្វាយព្រះពរជាកុសល ដែលកើតពីបុណ្យចំរើនព្រះជន្មវស្សានេះ ចំពោះសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ជាអម្ចាស់ដ៏ឥតលើសលុង ព្រមទាំងសម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាឯកជាតិ ជាទីគោរព សូមព្រះទ័យប្រកបដោយព្រះបរមសុខសួស្តី ក្នុងព្រះសិរីពលសម្បត្តិ ឈ្នះអស់ពួកសត្រូវគ្រប់ទិសទី កុំបីមក



អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ឥស្សរៈ ប្រធានគណៈកម្មការបណ្ណាថ្ងៃងព្រះសុន្ទរកថាស្វាគមន៍ ថ្វាយចំពោះសម្តេចព្រះបិតាឯករាជ្យជាតិ នៅទីលានវែលទ្រង់ស្តេចមកកាន់ពិធីស្រង់ទុក្ខភារី ប្រគេនសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ នៅថ្ងៃទី៤-៩-៦៣ នាវត្តបទុមវតីរាជវរាភម ។

បៀតបៀនព្រះអង្គបានឡើយ ។ ហើយសូមព្រះមហាវត្តជាទុកជាឧត្តមនៃគុណបុណ្យព្រះរតនត្រ័យ ទឹងវត្តសត្តិសិទ្ធិទាន ក្នុងពិភពលោកទាំងមូល ព្រមទាំងខេត្តមួយសែនកោដិចក្រវាឡ ជួយអភិបាលព្រះអង្គគ្រប់ទិវាកត្តិកាលជានិច្ច ។

សូមព្រះអង្គ មានព្រះជន្មាយុជាងរយព្រះវស្សា ដើម្បីទ្រង់ប្រថាប់នៅជាទិមិត្តរូបនៃសេចក្តីសុខសន្តិភាព-វឌ្ឍនភាព-ទឹងការសាមគ្គី ព្រមទាំងជាទីជម្រកដ៏ត្រជាក់ត្រជុំរបស់ប្រជាពលរដ្ឋជាកូនចៅ ដើម្បីជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភកតវៃរៀងទៅ ព្រមទាំងសូមប្រកបដោយព្រះជន្មាយុ វណ្ណៈ សុខៈ ពលៈ ទឹងបដិភាណៈកុំបីឃ្លាតឡើយ

សូមព្រះតេជៈដំកល់លើត្បូង ។

លុះចប់សុន្ទរកថានេះហើយ សម្តេចព្រះសុជម្មាធិបតីសង្ឃនាយកដោយមានព្រះពជាគណៈ ៤ អង្គអមព្រះអង្គផង ទិមន្តឡើងគង់លើបុស្សកសម្តេចព្រះប្រមុខរដ្ឋ ទ្រង់ប្រគេនទេសនាវារី ចំពោះសម្តេចព្រះសង្ឃនាយក ជាកិច្ចប្រសិទ្ធិពរ ចំពោះព្រះជន្មាយុ ឲ្យបានចំរើនតវៃរៀងទៅ ។

បន្ទាប់ពីពិធីខាងលើនេះ បានរួចសព្វគ្រប់ សម្តេចព្រះប្រមុខរដ្ឋទ្រង់សព្វព្រះរាជហឫទ័យថ្វាយព្រះសង្ឃថា ឥតព្រាងទុកមួយ រៀបចាប់ពីសកម្មភាពខាងសាសនាខ្លះ ទឹងអំពីប្រកេទរបស់ប្រទេស នាសម័យបច្ចុប្បន្ននេះខ្លះ ដែលបានប្រកបដោយវឌ្ឍនភាព ទឹងសន្តិភាព ព្រមទាំង

សាមគ្គីភាពជាអាទិ៍ ។

ព្រះសង្ឃកថាយ៉ាងពីរោះ « ដៃលពុំបានទាំមកចុះក្នុងទីនេះ » បានញាំងឲ្យពួកពុទ្ធបរិស័ទ មានសេចក្តីរីករាយយ៉ាងក្រៃលែង ។

លុះចប់ហើយ សម្តេចព្រះច្រមុះរដ្ឋ ព្រះពន្ធវត្តទៅកាន់ព្រះបរមកដ៏ាន់វិញ ។

ម៉ោង ១១-០០ រៀបភត្តាហារថ្វាយព្រះសង្ឃចំនួន ១០០ អង្គ ធាន់ ជាកិច្ចបញ្ចាប់ពិធីបុណ្យចំរើនព្រះជន្មវស្សាត្រឹមប៉ុណ្ណេះ ។


តន្ត្រីជាសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៥ លេខ ១២ ខែ ធ្នូ
ព. ស. ២៥០៥ គ. ស. ១៩៦៣

- ភ្នំពេញ -



ភ្នំពេញសារ៉ាយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញវន្តខ្មែរ ពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

	ទំព័រ
ផ្នែកសាសនា	
- ព្រះពុទ្ធសាសនា នៅសហរដ្ឋអាមេរិក (វិចារណកថា) តែងរៀបរៀង ដោយលោក ឧ. ជាន	១២១២
- អធិបតេយ្យៈ ការសំដែងអំពីអធិបតេយ្យ ៣ យ៉ាង (តបប) ព្រះសាសនមុនី កឹម - ឆ្ង	
ព្រមដំនុំព្រះធ្វើបិដក តែងរៀបរៀង	១២១៥
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ - ប៊ូ តែងរៀបរៀង (ត). . .	១២៣៥
- អំពីអ្នកបរិភោគកាម ១០ ពួក (ឧបាសកវគ្គទី ៥ ទំព័រទី ៤៩ អង្គុត្តរនិកាយ ទសកនិបាត)	១២៤៦
ផ្នែកអក្សរសាស្ត្រ	
- សេរីភាព (វិចារណកថា) ដោយលោក ផើង - ទ្រីវ	១២៥២
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហាបាំង - ខាត់ រៀបរៀង (ត) . . .	១២៥៧
- រឿងសាមកុក អ្នកនាងកញ្ចាំរិបុលរាជសេនា ឆូ - ពន ប្រែរៀបរៀង (ត) . . .	១២៥៩
- ល្បើកឡាហ្វុងតែន លោកផើង - ទ្រីវ ប្រែពីភាសាចាវ៉ាំង (ត)	១២៧០
- រឿងព្រេង ចិន (ត) (រឿងស្ពែក្រូរទោស) លោក ភ័យ - ប៊ុក ប្រែពីភាសាចាវ៉ាំង .	១២៧៣
- សំបុត្រ ទី ៨ របស់លោកខេរ៉ូ លោក ឈន - អៀម ប្រែពីភាសាអង់គ្លេស . .	១២៨២
- ទំនៀមទម្លាប់ខ្មែរ៖ ការស្នែងទន្សោង	១២៨៨
ផ្នែកកំណត់ទំនឹងប្រវត្តិសាស្ត្រ	
- ពិធីសម្ពោធធ្វើឆ្នាំងត្រែះស្ពាន ពុទ្ធិកសិក្សា សម្តេចព្រះនរោត្តម សីហនុ ក្រុងភ្នំពេញ . .	១២៩៣
- សុន្ទរកថា សហជីវិនអនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងព្រះវេជ្ជព្រះគុណព្រះពោធិវង្ស	១៣០៣

មួយឆ្នាំមាន ១២ លេខ តម្លៃដាក់ ៣០:០០

ការឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក ឲ្យធ្វើល្អទៅ
ឲ្យរុំសាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.ព.

វិចារណកថា

ដោយលោក ឧ គាម

ព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក(១)

នៅថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៩៤៩ មានព្រះសង្ឃចំនួន ៣០ អង្គបាន រួមប្រជុំគ្នានៅគេហដ្ឋានរបស់អ្នកគ្រូជប៉ុនម្នាក់ នៅទីក្រុងសានហ្វ្រាន់ស៊ីស្កូ ផ្នែកាលីហ្វ័រ្ញា (SAN FRANCISCO CALIFORNIA)។ ព្រះសង្ឃទាំងនោះ បានរួមជាសមាគមមួយឈ្មោះថា «សមាគមយុវជនពុទ្ធសាសនិក YOUNG MEN'S BUDDHIST ASSOCIATION »។ នេះជាសើកដំបូងបង្អស់ ដែលមានពុទ្ធសន្និបាតនៅសហរដ្ឋអាមេរិក ។

តាំងពីពេលនោះ មកដល់សព្វថ្ងៃនេះ អ្នកកាន់ព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក កប់ពាំងរដ្ឋហាវ៉ៃឯង មានចំនួនជាង ១៩០.០០០ នាក់ ហើយមានព្រះវិហារចំនួន ១២៩ សម្រាប់ធ្វើជាទីសក្ការបូជា ហើយមានមជ្ឈមណ្ឌលអប់រំព្រះពុទ្ធសាសនាដទៃទៀតជាច្រើន ដូចជាមាំងនៅរដ្ឋកាលី

---

១ - Vorld Buddhism, Vol. IX, n· 11, June 1961, page five.

ហ្វ័រញ៉ា (CALIFORNIA) នីវយ៉ក (NEW-YORK) ជាដើម ។

បឋមវិហារ

ការទូលថ្វាយ ព្រះវិហារជាបឋមចំពោះព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក គឺនៅក្រុងសានហ្វ្រានស៊ីស្កូ ឆ្នាំ ១៩០៥ ។ ព្រះវិហារនេះ ក៏បាននៅជាមណ្ឌលមួយសម្រាប់ក្រុមចេសកជនពុទ្ធសាសនិក នៅអាមេរិកខាងជើង ដែលបានចាត់តាំងឡើងកាលពីឆ្នាំ ១៩១៤ ។ មិនយូរប៉ុន្មាន សហគមន៍ពុទ្ធសាសនិកក៏ផ្សាយទៅរដ្ឋខាងលិច ដូចរដ្ឋអារីហ្សូណា (ARIZONA) យូថស (UTAH) វ៉ាស៊ីនតោន (WASHINGTON) អ៊ីរក្រឹន (OREGON) ។ កាលបើសកម្មភាពព្រះពុទ្ធសាសនា ចេះតែលូតលាស់ហើយ ព្រះវិហារ ក៏ចេះតែស្ថាបន័រៀងរាបមកដែរ ដូចយ៉ាងនៅទីក្រុង ដាន់វ័រ រដ្ឋកូឡូរ៉ាដូ (DENVER COLORADO) មីណាប៉ូលី (MINNEAPOLIS) ក្លីវឡិនដ៍ (CLEVELAND) ស៊ីកាហ្គូ (CHICAGO) ហ្វីឡាដេហ្វីយ៉ា (PHILADEPHIA) នីវយ៉ក (NEW-YORK) នីវហ្សឺស៊ី (NEW JERSEY) ។

ព្រះវិហារដែលសង់ក្រោយគេបង្អស់ នៅសហរដ្ឋអាមេរិក គឺនៅសានហ្វ្រាន់ស៊ីស្កូ ។ ទស្សនាវដ្តីផ្នែកខាងព្រះពុទ្ធសាសនា ផ្សាយចេញពីមណ្ឌលវប្បធម៌ពុទ្ធសាសនិកនៅកន្លែងប្រទេសជាច្រើន ចាត់ចែងដោយទៅសហរដ្ឋអាមេរិក ។

សហគមន៍ពុទ្ធសាសនិកនៅសានហ្វ្រានស៊ីស្កូ ជាសហគមន៍ធំជាងគេនៅសហរដ្ឋអាមេរិក នៅជាន់ ជាន់រំកូឡូរ៉ាដូ ជាមណ្ឌលសម្រាប់ពុទ្ធសាសនិក នៅរដ្ឋកូឡូរ៉ាដូ វ៉ាយ៉ូមីញ (WYOMING) នីវ៉ាដា (NEBRASKA) ហើយពុទ្ធមណ្ឌលនេះ មានគ្រួសារអាមេរិកាំងជាង ៤០០ គ្រួ ជាសមាជិកពុទ្ធសាសនិក ។

ព្រះវិហារពុទ្ធសាសនិកនៅនីវយ៉ក មានអាយុជាង ២២ ឆ្នាំ ។ តាលីវៃកញ្ញ ឆ្នាំ ១៩៧២ ប្រធានពុទ្ធសាសនិកជប៉ុន បានធ្វើអំណាយព្រះពុទ្ធរូបមួយព្រះអង្គ ធ្វើពីខ្ចីដែង ដល់សាពុទ្ធសាសនិកអាមេរិកាំងនៅនីវយ៉ក ។ ព្រះពុទ្ធរូបនេះទម្ងន់ពីរតោនកន្លះ ហើយជានិមិត្តរូបនៃសន្តិភាពនិងសន្តិសុខ ។

ប្រជាពលរដ្ឋអាមេរិកាំង

ការផ្សាយព្រះពុទ្ធវចនៈចូលទៅសហរដ្ឋអាមេរិក តាមរយៈសេចក្តីខ្នះខ្នែងរបស់លោករ៉ូប៊ាតក្លីតុន(ROBERT CLIFTON) ។ គាត់ជាបុត្រនៃលោកសង្ឃ យេស៊ូម្នាក់ ហើយសព្វថ្ងៃនេះ លោកបួសជាភិក្ខុមួយព្រះអង្គ មានឧត្តមបញ្ញាគុណថា ព្រះសុមង្គលោ (Preah Sumangalo) ។ ព្រះភិក្ខុសុមង្គលោ ជាក់ស្តែងថានីតិវិធីផ្សាយព្រះពុទ្ធសាសនានៅប្រទេសកាណាដា នីវរដ្ឋអាមេរិកខាងត្បូងខ្លាំង ។

អធិបតេយ្យកថា

ការសំដែងអំពីអធិបតេយ្យ ៣ យ៉ាង

ព្រះសាសនមុនី កាម . ភ្នំ រៀបរៀង

អធិបតេយ្យខាងគតិលោក

អត្តាធិបតេយ្យ

ធម្មតាមនុស្សទាំងឡាយដែលកើតមកក្នុងលោក តែងស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ ឬជាងវត្ថុអ្វី ។ ទាំងអស់ មិនចាំបាច់និយាយថ្លែងពោះមនុស្សដែលមានកាយល្អម៉ាមួនោះ ដោយហោចទៅ សូម្បីមនុស្សដែលមានកាយពិកពិការ ក៏តែងតែស្រឡាញ់ខ្លួនឯងជាងអ្នកដទៃដែរ ព្រោះហេតុនោះ មនុស្សម្នាក់ ។ បើស្រឡាញ់ខ្លួនពិតមែន គួរតែយកខ្លួនជាធំក្នុងកិច្ចការគ្រប់យ៉ាងដែលត្រូវធ្វើ ប៉ុន្តែមិនមែនយកខ្លួនជាធំហើយប្រព្រឹត្តឲ្យផ្ទុយទុំសព័ច្បាប់លោកនីតិច្បាប់ធម៌ដែលមានមកហើយនោះទេ គឺយកខ្លួនជាធំឬជាប្រធានឲ្យតឹងប៉ឹង ក្នុងមុខការនោះ ។ ហើយអនុលោមទៅតាមច្បាប់លោកនីតិច្បាប់ធម៌ឲ្យត្រឹមត្រូវតែងដែរ ទើបហៅថា អត្តាធិបតេយ្យ ។

អត្តភាពតឹតួខ្លួនរបស់យើងនីមួយ ។ ប្រៀបដូចជាកាជនៈ សម្រាប់ខ្ចប់រងនូវរបស់ទាំងល្អទាំងអាក្រក់ ឬថា ជាទីប្រជុំកើតនៃសេចក្តីល្អនិងសេចក្តីអាក្រក់ក៏ថាន សមដូចព្រះពុទ្ធសាសនាថា «អត្រដំ អត្តសម្ភវំ» ប្រែថា « សេចក្តីល្អ និង សេចក្តីអាក្រក់ឬសុខ និងទុក្ខ រមែងកើតអំពីខ្លួន

មានខ្លួនជាដៃនកើត ។ ។ អត្ថៈឬអត្ថា ដែលប្រែថាខ្លួនក្នុងទីនេះ សំដៅយកអត្តភាពតឺរូបកាយទាំងមូល ព្រមទាំងចិត្តរួមចូលផង ទើបហៅថាខ្លួន ព្រោះហេតុនោះ បុគ្គលគប្បីសំឡឹងពិនិត្យមើលដំណើរការណ៍ប្រព្រឹត្តទៅរបស់ខ្លួន ទាំងចំណែកខាងល្អ ទាំងចំណែងខាងអាក្រក់ ថើជាដឹងថាខ្លួនប្រព្រឹត្តសេចក្តីអាក្រក់ហើយ គួរលះបង់ចោលចេញ ហើយគប្បីប្រព្រឹត្តសេចក្តីល្អតទៅ បើខ្លួនបានប្រព្រឹត្តសេចក្តីល្អស្រាប់ហើយ ក៏គួរតែប្រព្រឹត្តសេចក្តីល្អនោះ ឲ្យរឹងតែតែក្រែលែងខ្ជាប់ខ្ជួនតទៅទៀត ។ មួយយ៉ាងទៀត ធម្មតាធ្វើជាមនុស្សនៃមួយ ។ មិនត្រូវប្រតល់ខ្លួនទាំងស្រុងដល់អ្នកដទៃ ហើយដេកចាំយកសេចក្តីសុខអំពីគេដោយងាយ ។ នោះឡើយ មិនត្រូវបណ្តោយខ្លួនឲ្យភ្លាក់ចុះកន្លងហួសដំរៀកពាបទៅជាអាយ័តឬជាពាសកាតនៃជនដទៃឡើយ មិនត្រូវបណ្តោយខ្លួនឲ្យលង់ភ្លាក់ចុះក្នុងមាទធម៌តឺសេចក្តីប្រមាទ ឬ សេចក្តីធ្វេសប្រហែស ក្នុងតតិលោក ឬក្នុងតតិធម៌ណាមួយឡើយ ព្រោះថា សេចក្តីប្រមាទ ឬ សេចក្តីធ្វេសប្រហែសនេះ ជាមូលហេតុនៃសេចក្តីវិនាស ហិនហោចគ្រប់យ៉ាង ទាំងក្នុងផ្លូវលោក ទាំងក្នុងផ្លូវធម៌ ។ មនុស្សណា មានសេចក្តីប្រមាទ ឬ ធ្វើខ្លួនឲ្យលុះក្នុងអំណាចនៃសេចក្តីប្រមាទជានិច្ចហើយ មនុស្សនោះ ពុកដូចជាបើកទ្វារចំហឲ្យទុកាសដល់សត្រូវ ពោលគឺសេចក្តីអន្តរាយគ្រប់យ៉ាង ហូរចូលជានិច្ចផង ពុកដូចជាស្ទាប់ជាត់ទៅហើយផង សូម្បីមាន

ជីវិតកំពុងរស់នៅ កំពុងដូចជាស្លាប់ហើយដែរ អ្នកណាមិនប្រមាទ អ្នកនោះពុំកដូចជារស់នៅ សូម្បីស្លាប់ចាត់ទៅហើយ ក៏ពុំកដូចជារស់នៅដែរ ។

សេចក្តីស្លាប់របស់មនុស្សមានពីរយ៉ាងគឺ ស្លាប់ដាវិត១ ស្លាប់គំនិត១។ បណ្តាសេចក្តីស្លាប់ទាំងពីរយ៉ាងនេះ ឯសេចក្តីស្លាប់គឺអស់ឮស់ចេញនឹងឮស់ចូល ទាំងវិញ្ញាណក៏ច្រាសចេញផុតចាកកាយទៅហើយ ហៅថា ស្លាប់ដាវិត ស្លាប់បែបនេះជាការប្រសើរល្អជាងស្លាប់គំនិត ។ មនុស្សណា ដែលធ្វេសប្រហែសបណ្តែតបណ្តោយគំនិតស្មារតីឲ្យលង់លុះក្នុងកាមគុណា ឬក្នុងអំពើឥតប្រយោជន៍ ឬក៏ក្នុងអំពើអាក្រក់ណាមួយ ដោយកាយ វាចា ចិត្ត ដែលជាអំពើឃ្លាងផុតស្រឡះពីសេចក្តីល្អ សេចក្តីចម្រើនខាងផ្លូវលោក ឥងខាងផ្លូវធម៌ ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក មនុស្សនោះឯង ហៅថា មនុស្សស្លាប់គំនិត ។ ជម្មតាមនុស្សស្លាប់មែន ។ ដែលមានវិញ្ញាណឥងឥសប្បាសឬស្បាសៈច្រាសចេញផុតពីកាយទៅហើយ តាំងដែលមានគំនិតគិតថា អាត្មាអញឥងឲ្យទានរក្សាសីល ឬឥងធ្វើកិច្ចការណាមួយជាសាធារណៈ ប្រយោជន៍សម្រាប់ជាតិឬសម្រាប់ស្រុកទេសសោះឡើយ យ៉ាងណាមិញ ឯមនុស្សប្រមាទគឺមនុស្សស្លាប់គំនិតក៏គ្មានដូច្នោះដែរ ។ មនុស្សប្រភេទណាក៏ដោយ នោះជាបព្វជិតក្តី គ្រហស្ថក្តី ដែលជាអ្នកប្រកបដោយសេចក្តីប្រមាទ

ហើយ ពុកដូចជាដង្កូតក្នុងលោក ឬជាមនុស្សប៉ប៉ែត្រលោក ។ វដ្ត-
សង្សារបស់មនុស្សប្រមាទនេះ សូម្បីញាណរបស់ព្រះពុទ្ធក៏ពុំអាច
កំណត់ចាន់ឡើយ ។ មនុស្សប្រមាទនេះ បើនិយាយឲ្យឆាក់មក ចាន
ដល់មនុស្សណាមួយ សូម្បីនៅក្នុងស្រុកភូមិ ប្រទេសណា ឥតដែល
មានធ្វើសេចក្តីល្អឲ្យកើតឡើងដល់ខ្លួន ឬដល់អ្នកដទៃឬធ្វើអ្វីពុំជាប្រ-
យោជន៍ខាងផ្លូវលោក ឬ ខាងផ្លូវធម៌ក្នុងស្រុកភូមិប្រទេសនោះឡើយ
មានតែបង្កហេតុអាក្រក់ គឺពុក្លួសអតមង្គល បំផ្ទិចបំផ្លាញ ពាក់ព័ន្ធ-
ប្រយោជន៍ នឹងសេចក្តីចម្រើនរបស់គេ ឲ្យវិនាសហិនហោច ដោយសារ
ខ្លួនតែម្នាក់ឯងប៉ុណ្ណោះ មានតែកេរ្តិ៍ឈ្មោះស្អុយអាក្រក់ នឹងអំពើអាក្រក់របស់
ខ្លួនដែលធ្វើនោះ ពុកជាប្រវត្តិ ឬជាស្នាដៃ ជាកេរ្តិ៍ដំណែលឲ្យអ្នកឯងស្អប់
ខ្ពើមចាំពុកមិនភ្លេច ។ មនុស្សប្រមាទគឺមនុស្សស្ងាប់តំនិតឬស្ងាប់ស្មារ-
តីនេះ ជាទោសមួយដ៏ធំក្រៃលែងជាងទោសឯទៀតទាំងអស់ ព្រោះជា
ហេតុនាំឲ្យវិនាសខូចប្រយោជន៍ច្រើនប្រការណាស់ សូម្បីដើរឈរអង្គុយ
ដេក ក៏ឥតដឹងថាការគួរពុំគួរ ឬធ្វើអ្វីក៏ឥតដឹងខុស-ត្រូវ ឥតដឹងកាល:
ទេស:របស់លោកនិយមឡើយ ។ សម័យដែលគេត្រូវរៀនចំណេះវិជ្ជា
ក៏មិនគិតរៀន សម័យដែលគេត្រូវប្រកបការងារកេរ្តិ៍ឈ្មោះសម្បត្តិ ក៏មិន
គិតកេ បើពុកជាមានគេរៀនសូត្រចេះដឹងច្រើនដល់ថ្នាក់ណា ឬគេរកស៊ី
កាត់មុខ ដណ្តើមយកផលប្រយោជន៍ចំពោះមុខខ្លួន ឬានកើតការល់ល

តុម្ព ទៅជាអ្នកមានកោតសម្បុកស្តុកស្តម្ភយ៉ាំងណា ក៏មិនកោតសរសើរ
មិនស្បើមនឹងគេ ចេះតែចំអៀកខម្រេន ត្រេះត្រុះអីកអាក ពាល់តែគេ
ពាក្យយកផលប្រយោជន៍ដុំវិញខ្លួនបានចាំងអស់ ម្ល៉ោះហើយ ក៏ខ្ជាត់ខ្ជាយ
ចេញទៅនៅក្រៃក្រៃផ្សេ ចុងក្រាត់មាត់ញាកឯណាឆ្ងាយទៅ ។ បើខាងបព្វជិត
វិញ សម័យដែលគេត្រូវសិក្សារៀនបរិយត្តិ-ធម៌អាថ៌ប្តូរគេត្រូវធ្វើអ្វីឲ្យចម្រើន
ដល់ព្រះពុទ្ធសាសនា ក៏មិនគិតរៀនមិនគិតធ្វើនឹងគេ ទោះបីមានគេណែ
នាំជាស់គឿនញុកយ៉ាំងណា ក៏មិនរវៃស្តាប់ មិនយកចិត្តទុកដាក់ធ្វើតាម។

កាលបើគេមានវប្បធម៌ចេះតែចម្រើនខ្ពស់ត្រដែតឡើងកាលថ្ងៃ មនុស្ស
ស្លាប់គំនិត សឹតយកកែកមើល សឹតយកគ្រចៀតស្តាប់ ព័ដើមភ្ជាប់
ធ្វើយ៉ាំងណា ក៏នៅតែចេះប្រកាន់ធ្វើយ៉ាំងនោះដដែល ។ មិនព្រមលះ
ចោល ខ្លួនឯង បើបានជាលូនំទៅហើយ ក៏លូនំតែម្នាក់ឯងទៅចុះ ថែម
ចាំងរកាំងគេឯទៀត មិនឲ្យគេសិក្សារៀនសូត្រទេ បណ្តោយឲ្យគេនៅ
លូនំដូចជាខ្លួនផងដែរ ។ ប៉ើប៉ំព្រួញសេចក្តីឲ្យខ្លីមកថា មនុស្សស្លាប់
គំនិត ឈ្មោះថាស្លាប់ចាំងអស់ គឺស្លាប់ប្រយោជន៍បច្ចុប្បន្នទើងប្រយោជន៍
បរលោក ជាមនុស្សមិនចាន់សម័យនិយម មិនអនុវត្តទៅតាមកាល:
ទេស: ឈ្មោះថាជាមនុស្សរកាំងប្រយោជន៍នឹងសេចក្តីចម្រើនរបស់លោក
មានតែខ្យល់ដង្ហើមចេញចូល ដូចជាស្លាប់ឥតដឹងអ្វី រស់នៅគ្រាន់តែបរិភោគ

អាហារ ឬគ្រានតែរាប់ថ្ងៃ យប់ ខែ ឆ្នាំមួយ ។ ដែលកន្លងទៅហើយប៉ុណ្ណោះ

មនុស្សស្ងាប់គំនិតដូចបានពោលមកនេះ ឈ្មោះថាសូន្យចាកប្រយោជន៍ត្រង់យ៉ាង៣ សមដូចសុភាសិតក្នុងលោកន៍តិថា ៖

អលាសស្ស កុតោ សិប្បំ អសិប្បស្ស កុតោ ធនំ
អធនស្ស កុតោ មិត្តំ អមិត្តស្ស កុតោ សុខំ
អសុខស្ស កុតោ បុញ្ញំ អបុញ្ញស្ស កុតោ សិរិ ។

មនុស្សខ្វិល នឹងបានបំណោះមកអំពីណា មនុស្សគ្មានបំណោះ នឹងបានទ្រព្យមកអំពីណា មនុស្សគ្មានទ្រព្យ នឹងបានមិត្តមកអំពីណា មនុស្សគ្មានមិត្ត នឹងបានសុខមកអំពីណា មនុស្សគ្មានសុខ នឹងបានបុណ្យមកពីណា មនុស្សគ្មានបុណ្យ នឹងបានសួគ៌និព្វានមកអំពីណា ។

ព្រោះហេតុនោះ មនុស្សខ្វិលក៏មានឈ្មោះថាជាមនុស្សប្រមាទ ជាមនុស្សស្ងាប់គំនិត មនុស្សបែបនេះ ឈ្មោះថាឃ្លត់ក្រ កំព្រាសូន្យសត្វចាំនអស់ តីសូន្យចាកប្រយោជន៍បច្ចុប្បន្នទីដ៏ប្រយោជន៍បរលោក សូម្បីស្ងាប់ទៅក៏សូន្យនាមនឹងគេត្រកើ្តឈ្មោះចាំងអស់ផងខ្លៅត ឥតមានគេនឹកនាស្តាយអាឡោះអាល័យឡើយ ព្រោះគ្មានបានធ្វើសេចក្តីល្អ ឬសេចក្តី

សង្គ្រោះដល់អ្នកណាមួយ គ្មានបានសោះអ្វីជាប្រយោជន៍សម្រាប់ខ្លួនក្រៅពីការដែលបានផ្គរលោក ឬខាងផ្លូវធម៌ ខ្លួនជាកេរ្តិ៍ដំណែលជាស្នាដៃ ដើម្បីឲ្យអ្នកផងគេទួលស្គាល់ខ្លួនតទាំ ចាប់អារម្មណ៍ចំពោះខ្លួនសោះឡើយ ។

ចំណែកខាងមនុស្សដែលមានអាកប្បកិរិយាផ្ទុយពីមនុស្ស ដូចជាខ្លួនពណ៌នាមកហើយ ក្នុងខាងលើនោះ ហៅថាមនុស្សមិនប្រមាទ មនុស្សមិនស្លាប់គ្មានទីតាំង ។ ធម្មតាមនុស្សមិនស្លាប់គ្មានទីតាំង តែងមានគំនិតរស់រវើកដើរជានិច្ច ដូចខ្លួនបានឡើកា តែងពិចារណាថា ថ្ងៃមួយ យប់មួយ ដែលកន្លងទៅហើយ តើអាត្មាអញ បានធ្វើអ្វីខ្លះ ខ្លួនជាប្រយោជន៍ខ្លួនឬជាប្រយោជន៍អ្នកដទៃ ? កាលបើគិតឃើញហើយ មិនខ្ជិលអត់ខ្ជម្ងល់តែងស្ទុះស្ទារ នេះរាងចំពេញកិច្ចការនោះ ។ តាមកម្លាំងនឹងសមត្ថភាពរបស់ខ្លួនត្រាតែបានសម្រេចដល់ទីបំផុត ។ មនុស្សមិនស្លាប់គ្មានទីតាំង សម័យដែលគេត្រូវរៀន ក៏ខំប្រឹងរៀន សម័យដែលគេត្រូវរកទ្រព្យសម្បត្តិ ក៏ខំរក ធ្វើការអ្វី តែងមានសតិសម្បជញ្ញៈកង់ការនោះ គឺដឹងថាគួរឬមិនគួរ មានប្រយោជន៍ឬឥតប្រយោជន៍ភ្លាម ។ ។ មនុស្សបែបនេះ បើរៀនចំណេះវិជ្ជាអ្វី ក៏ងាប់ចេះ ងាប់យល់ បើស្វែងរកទ្រព្យសម្បត្តិ មានទ្រព្យសម្បត្តិជាដើម ក៏ច្រើនងាប់ដួចប្រុះនឹងសេចក្តីចម្រើន បើស្វែងរកប្រយោជន៍ឋរលោក គឺបុណ្យកុសលផ្សេង។ ក៏តែងបានបុណ្យកុសលច្រើនលើសគេជាដរាប ឈ្មោះថាជាមនុស្សមានការងដ៏វិត្តន៍លឿនពន់សម័យ

សមដូចពុទ្ធភាសិថា ៖

អប្បមត្តោ បមត្តេសុ

សុត្តេសុ ពហុជាគរោ

អពលស្សំវ សីឃស្សោ

ហិត្វា យាតិ សុមេធសោ ។

មនុស្សអ្នកមានប្រាជ្ញាល្អ កាលបើអ្នកដទៃប្រមាទ ធ្វេសប្រហែស ភ្លេចស្មារតី គេមិនប្រមាទ មិនធ្វេសប្រហែស មិនភ្លេចស្មារតី កាលបើអ្នកដទៃដេកលក់ ស្លាប់គំនិតស្មារតី គេភ្ញាក់រឭកដឹងខ្លួន **មាន**គំនិតស្មារតីរស់រវើក ដើរលឿនទៅមុខឆ្ងាយដាច់ស្រយាល លះបាលមនុស្សកំសោយ គឺមនុស្សប្រមាទដេកលក់ ស្លាប់គំនិតនោះស្រឡះ ដូចសេះមានល្បឿន លឿនដាយចោលសេះកំសោយជើងខ្លក តាមមិនទាន់ ក៏ដូច្នោះឯង ។

មនុស្សមានប្រាជ្ញារមែងមិនប្រមាទ តែងមានយោបល់ត្រូវដំណើរ ធ្វើប្រយោជន៍បច្ចុប្បន្ន ធ្វើប្រយោជន៍បរលោក ធ្វើប្រយោជន៍ឲ្យដល់អ្នកដទៃ តែងជួយសង្គ្រោះចំនុកបំរុងតាមមាន តាមបាន ឲ្យគេបានសុខ បានបម្រើន

ដោយសារខ្លួន ។ មនុស្សប្រៃបនេះ កាលបើមានជីវិតរស់នៅ អ្នកផង
រមែងចូលចិត្តស្រឡាញ់កប់អាន មានក្តីឈ្មោះពីពេះក្រអូបផ្សាយខ្ចរ
សព្វទិសទី សូម្បីរូបកាយស្អាប់ជាត់បង់ទៅហើយក៏ដោយ ឯនាម
និងគេត្រតឹក្តីឈ្មោះនៅរស់រវើក មិនចេះស្អាប់រលាយជាត់សូន្យទៅឯង
ឡើយ តែតែងកត់ចំណាំចាំខុក អស់កាលជាយូរអង្វែង ព្រោះហេតុនោះ
ជាន់ជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ៖

មនុស្សប្រមាទ សូម្បីមានជីវិតរស់នៅ
ក៏ទុកដូចជាស្លាប់ទៅហើយ
ឯមនុស្សមិនប្រមាទ សូម្បីស្លាប់បាត់ហើយ
ក៏ទុកដូចជាមានជីវិតរស់នៅដែរ ។

មួយយ៉ាងទៀត ពួករុក្ខជាតផ្សេង ។ មាន បេង ក្រញូង នានិងទួន
ជាដើម ដែលគេនិយមកប់អានថាជាឈើមានសាច់ជាប់ល្អ តែតែងយកមក
ធ្វើជាសម្ភារៈគ្រឿងឧបករណ៍ប្រើប្រាស មានតុ ខ្ទូ ទីនគ្រឿងតាំងសំកប់
លំអជាដើម ប៉ុន្តែឈើទាំងនោះ ដែលដុះកើតឡើងហើយ មិនមែនដុះ
កើតចេញលេចមកជាតុ ជាខ្ទូ ជាសៀវ ។ល។ ស្រេចស្រាប់សម្រាប់
ឲ្យគេយកទៅប្រើការបានតែម្តងនោះទេ បើតាមធម្មតា ជាតិរបស់ឈើ
ទាំងនោះ រាងរតើតរពើង ប្រឡេងប្រឡាង មើលទៅពុំគួរឲ្យជ្រះថ្លា ពុំគួរឲ្យ

ចង់ចាន់សោះ ប៉ុន្តែបើគេយកមកបានលៃលកធ្វើជារបស់ប្រើប្រាស់មានតុ ខ្លួកៅអីជាដើម ឈើនោះក៏ក្លាយទៅជារបស់មានប្រយោជន៍ គួឲ្យគេជ្រះថ្លា ចង់មើល គួឲ្យគេចូលចិត្តស្រឡាញ់ ចង់ចាន់ទៅវិញ យ៉ាងណាមិញ ធម្មតាមនុស្សយើងនីមួយ ។ ដែលកើតមកហើយ បើខ្វះការសិក្សា ខ្វះការអប់រំ ខ្វះការណែនាំអំពីបុគ្គលដទៃ ហើយបណ្តាយខ្លួនឲ្យទៅតាមធម្មជាតដើម ពីកំណើតមកនោះ មិនខុសអំពីដើមឈើ ឬអំពីសត្វតិរច្ឆានប៉ុន្មានឡើយ ។ ព្រោះហេតុនោះ ការសិក្សា ការអប់រំ ទំនាក់ការណែនាំអំពីបុគ្គលដទៃនេះឯង ជាគុណសម្បត្តិដ៏វិសេស អាចផ្លាស់ប្តូរចរាធម្មជាតដើមរបស់មនុស្សនោះ ឲ្យក្លាយទៅជាអរិយមនុស្ស គួឲ្យគេស្រឡាញ់ គួឲ្យគេសេពគប់ រាប់រកយកជាគ្នាទៅបាន ក៏ដូច្នោះដែរ ។

សេចក្តីដែលបានពណ៌នាមកហើយអំពីពាក្យថា អត្តាធិបតេយ្យ ដែលប្រែថាយកខ្លួនជាធំនោះ គឺមិនមែនយកខ្លួនលើកតម្កើងឲ្យជាធំ ដោយស័ក្តិយសបរិវារ ឬបង្ខំខ្លួនឯងឲ្យធំ ឲ្យគ្រាន់បើលើសអ្នកដទៃនោះទេ ត្រូវតាំងចិត្តជាធំគឺធ្វើចិត្តឲ្យមោះមុតអង់អាច ឲ្យរឹងប៉ឹង ឲ្យក្លៀវក្លា តស៊ូមិនរួញរាក្នុងមុខការណាមួយដែលខ្លួនត្រូវធ្វើ ត្រូវប្រព្រឹត្ត ហើយអនុលោមគោរពទៅតាមច្បាប់លោកនិងច្បាប់ធម៌ផង ទើបហៅថា អត្តាធិបតេយ្យ ។

លោកាធិបតេយ្យ

មនុស្សម្នាក់ ។ ដែលកើតមកក្នុងលោក គួរតែធ្វើលោកគឺមនុស្សផង

គ្នាឲ្យជាធំក្នុងកិច្ចការគ្រប់យ៉ាងដែលខ្លួនត្រូវធ្វើ ប៉ុន្តែមិនមែនលើកយក
លោកមកឲ្យជាធំ ហើយប្រព្រឹត្តឲ្យខុសផ្ទុយពីច្បាប់លោកនឹងច្បាប់ធម៌
នោះទេ គឺគ្រាន់តែធ្វើសេចក្តីគោរព ចំពោះលោកឬយកលោកជាប្រមាណ
ក្នុងមុខការនោះ ។ ហើយគប្បីអនុលោមគោរពតាមច្បាប់លោកនឹងច្បាប់
ធម៌ឲ្យបានត្រឹមត្រូវផង ទើបហៅថា លោកធិបតេយ្យ ។ មនុស្សនីមួយ ។
ពោះជាគ្រហស្ថក្តី ជាបព្វជិតក្តី មិនត្រូវបណ្តោយគំនិតឲ្យស្ងាប់ស្ងុតដូច
ជាបុគ្គលស្ងាប់ដែលអស់ឱ្យលំចេញនឹងឱ្យលំចូលនោះទេ ត្រូវតែឲ្យមាន
សតិសម្បជញ្ញៈជានិច្ច ចើតកែកសម្ងឹងមើលអ្នកដទៃដែលគេខៅដុំវិញ
ខ្លួនយើងផង តើគេយ៉ាងណា ? អាត្មាអញយ៉ាងណា ?

ចើនែកខាងគ្រហស្ថដែលប្រាថ្នានឹងធ្វើការអ្វីមួយ ដោយកាយក្តី
ដោយវាចាក្តី ដោយចិត្តក្តី គួរគិត គួរត្រែងវែងដល់អ្នកដទៃជាដរាប
ព្រោះថាមនុស្សខ្លះទៀតនឹងលោក មិនមែនសុទ្ធតែលួងលំទៀងជួចគ្នាទាំងអស់ទេ
តង់មានអ្នកប្រាជ្ញជួបស្ទាត់ គេមានប្រាថ្នាជ្រាបដឹង មានយោបល់យល់ហេតុ
ការណ៍ពាក់ព្រៀ ឃើញកាលវែងឆ្ងាយទាំងក្នុងតតិយោក ទាំងក្នុងតតិយមិកំ
មាន ។

ចើអាត្មាអញជាមនុស្សប្រព្រឹត្តអំពើលាមកកខ្វក់ មានកាយទុច្ចរិតជា
ដើមយ៉ាងនេះ ចើគេបានដឹងឃើញហើយ គេនឹងមើលងាយ គួរតែរៀស

ដល់អាត្មាអញដែរឬទេ ? បើអាត្មាអញជាមនុស្សមានកង់តាយម៉ាំមួន ហើយត្រូវបង្ខំធ្វើជាមនុស្សខ្វិលច្រអូសមិនប្រកបការងារអេសុ៊ បណ្តាយឲ្យដីវាគាត់ចុះដុនជាបក្រុះហាមរហាមយ៉ាំងនេះ តើគេនឹងមើលងាយគ្នះតិះដៀលដល់អាត្មាអញដែរឬទេ? បើអាត្មាអញជាមនុស្សល្មោកលោភលន់អត់ត្រាំពុំបាន ហើយទៅលួចប្លន់ចោកប្រាសធន់ដណ្តើមយកទ្រព្យសម្បត្តិរបស់អ្នកដទៃ បើជួនជាអ្នកពាក់ការចាប់បានយកទៅធ្វើទណ្ឌកម្ម ជាក់ខោសតាមកំហុសដូច្នេះឬដូច្នោះទៅ តើអ្នកធង់គេនឹងមើលងាយគ្នះតិះដៀលដល់អាត្មាអញដែរឬទេ ? បើអាត្មាអញមិនតិតសិក្សារៀនសូត្រចំណេះវិជ្ជាខាងផ្លូវលោកឬខាងផ្លូវធម៌ទេ បណ្តាយឲ្យខ្លួនឲ្យទៅជាមនុស្សល្ងង់ខ្លៅយ៉ាំងនេះ តើគេនឹងមើលងាយគ្នះតិះដៀលអាត្មាអញដែរឬទេ ? បើអាត្មាអញជាមនុស្សគ្មានហិរិឧត្តប្បៈ គឺគ្មានសេចក្តីខ្មាសឃ្លាត គ្មានសេចក្តីតក់ស្លុតខ្លាចឃ្លាត ជាមនុស្សមានចរិយាឫកពារថោកទាប តាំងពីប្រើនវិយោបថគឺដើរឈរគង្គុយ ដេកជាដើមទៅ គ្មាន អបចាយនធម៌ គោរពកោតក្រែងដល់ចាស់ទុំព្រឹទ្ធាចារ្យ មានមាតាបិតាជាដើមទេ តើគេនឹងមើលងាយ គ្នះតិះដៀលដល់អាត្មាអញដែរឬទេ ? ។ ល ។

ពុំនោះសោត អាត្មាអញត្រូវចោលភ្នែកក្រឡេកមើលទៅដុំវិញខ្លួនអាត្មាអញ ដូចអ្នកដែលមានទ្រព្យសម្បត្តិច្រើន ចាំងភ្លឺឈ្នោះគេកិល្ល ឬ

អ្នកដែលមានចំណេះចេះដឹងច្រើនតាំងផ្លូវលោកតាំងផ្លូវធម៌ តើមូលហេតុ
ដែលនាំឲ្យគេតស៊ាងខ្លួនបានឡើងកាន់ដីវិភាពនឹងឋានៈដ៏ខ្ពង់ខ្ពស់ ដែល
គួរឲ្យអ្នកផងគេស្ញើចសរសើរដូច្នោះ ដោយសម្គាល់បែបណា? លុះ
ត្រិះរិះគិតឃើញផ្លូវ ឃើញចំនងសមហេតុសមផលហើយ កំត្រូវតែ
ព្យាយាមលះលងដំណើរការណ៍នោះឲ្យអស់រលីងទៅតាមគំនិត ដែលបាន
គិតឃើញនោះជាបាច ពាល់តែបានសម្រេច ពុំត្រូវខំលាក់គំនិតនោះចោះបង់
ចោលឡើយ ត្រូវតែតស៊ូឲ្យដល់ទីបំផុត សមនឹងព្រះសាស្តាថា «ភាយមេ-
ធេវ បុរិសោ យោវ អត្ថស្ស និប្ផន្នោ» តើតមកជាកូនប្រុស ត្រូវ
តែព្យាយាមតស៊ូក្នុងការងារ ជាបាច ពាល់តែបានសម្រេចប្រយោជន៍សឹមឈប់
មួយយ៉ាងខ្លៅ ត្រូវតែជាជ្ញានចិត្តឲ្យរឹងប៉ឹងថា គេម៉ែច អញម៉ែច តើតមក
ជាមនុស្សដូចគ្នា គេម៉ែចកំរៀនចេះ អញម៉ែចកំរៀនមិនចេះ គេម៉ែចកំប្រ
កបការរកស៊ីធ្វើជាអ្នកមានកើត អញម៉ែចកំប្រកបការរកស៊ីធ្វើជាអ្នកមាន
មិនកើត ព្រោះហេតុអ្វី? បើគេរៀនចេះ អញក៏រៀនចេះ បើគេរកស៊ីធ្វើ
ជាអ្នកមានកើត អញក៏រកស៊ីធ្វើជាអ្នកមានដូចគេកើតដែរ បើមិនបានដូច
គេ កំតង់ត្រប់ត្រាន់ដែរ មិនត្រូវដេកស្ទើមបណ្តោយទៅតាមយថាកម្ម
ទេ ប្រៀបដូចសត្វខ្លា ជាសត្វមានឥទ្ធានុភាពខ្លាំងពូកែ ឯពួកសត្វខ្លែ
ជាទ ចតុប្បជាទ ឯទៀត គ្រាន់តែត្រឡែកមើលខ្លា ក៏កិតក៏យតក់ស្លុត
ស្ទើរតែក្បាយដីវិត ប៉ុន្តែ បើខ្លា ដោយគាន់ថា អញជាអ្នកខ្លាំងពូកែ

ហើយដកសម្ងំស្ងៀម ហាមាត់ចង្រ្កឹងដើម្បីឲ្យសត្វឯទៀតចាស់មកចូលកន្ទាមាត់ឲ្យជាអាហារបស់ខ្លួននោះ ប្រាកដជាគ្មានសត្វណាមួយត្រមុះចិត្តគេចចូលកន្ទាមាត់ខ្លាឲ្យស្លាប់ខ្លួនឯងទេ ។ នោះឡើយ ខ្លានោះ លុះតែមានកាយវិការប្រកបដោយឫទ្ធានុភាពខ្លាំងក្លាជាង ទើបបានសត្វនោះៗមកជាអាហារបស់ខ្លួន យ៉ាងណាមិញ ឯចំណេះវិជ្ជាគ្មី កោតទ្រព្យក្តី កំដរភ្នែដែរ លុះតែយើងខំរៀន ខំស្វែងរកផង ទើបអាចសម្រេចប្រយោជន៍ត្រចំយ៉ាងដូចគេទៅបាន ។

ម៉ើទាងចតូដតវិញ ដែលបួសហើយត្រូវគិតថា កន្ទុសាសនាមានធុរៈ ២ គឺ គន្ថធុរៈ ១ វិបស្សនាធុរៈ ១ ធុរៈទាំង ២ នេះ បតូដតត្រូវតែចំពេញនឹងទាងពុំបាន ។ គន្ថធុរៈ បានទាងបរិយត្តិដែលហៅថាព្រះត្រៃបិដកហ្នឹងឯង វិបស្សនាធុរៈ បានទាងសមថកម្មដ្ឋាន នឹងវិបស្សនាកម្មដ្ឋាន ។ អាត្មាអញបានលះបង់គេចឃាវាស ហើយចូលមកធ្វើជាគេបតូដត (អ្នកបួស) យ៉ាងនេះ តើអាត្មាអញ បានរៀនគន្ថធុរៈហើយឬទេ ទាំងវិបស្សនាធុរៈសោតទៀត បានចំពេញហើយឬនៅទេ ។ ម៉ើអាត្មាអញមិនបានចំពេញធុរៈទាំង ២ នោះ ធុរៈណាមួយសោះទេ បណ្តាយខ្លួនឲ្យនៅទំនេរ ជាមនុស្សល្ងង់ខ្លៅដូច្នេះ ហើយក្រាញនៅធ្វើជាអ្នកបួសល្ងង់បែបនេះតទៅទៀត ក្រែងមានលោកអ្នករៀនសូត្រចេះដឹងច្រើនទាំងបតូដតទាំងគ្រហស្ថ គេម៉ើលមកឃើញ ដឹងថាអាត្មាអញជាមនុស្សល្ងង់មិនដឹង

ការខុសត្រូវ តើអាត្មាអញគួរអៀនខ្មាសគេដែរឬទេ ? សីលចាំង ៤ មាន
ចាតិមោក្ខ សំវរសីលជាដើម សិក្ខាបទក្នុងចាតិមោក្ខ ២២៧ សិក្ខាបទ មាន
ចាកដែកសិក្ខាបទ ៤ ជាដើម ព្រមចាំងសិក្ខាបទក្រៅពីចាតិមោក្ខខ្លះទៀត
ជាទីរបស់បព្វជិត ។ ត្រូវតែចេះចាំ ត្រូវតែការពារប្រព្រឹត្តតាម បើអាត្មាអញ
មិនចាំនរៀនសូត្រឲ្យចេះចាំទេ មិនស្គាល់សីល មិនស្គាល់សិក្ខាបទរបស់
ខ្លួនទោះថាជួបម្តេចខ្លះទេ តើអាត្មាអញគួរអៀនខ្មាសគេដែរឬទេ បណ្តា
បច្ច័យចាំង ៤ មានចីវរបច្ច័យជាដើម បច្ច័យណាមួយដែលបព្វជិតចាំនមក
អំពីចាបធម៌ ៥ យ៉ាង មានកុហនាជាដើមក្តី ចាំនមកអំពីអនេសនៈ ២១
យ៉ាង មានវេជ្ជកម្ម (ធ្វើពេទ្យមើលជម្ងឺ ឱសថ ។ល។) ជាដើមក្តី បច្ច័យ
ទោះឈ្មោះថាជារបស់មិនបរិសុទ្ធ ព្រោះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តហាមជាដាច់
ខាត មិនឲ្យបព្វជិតប្រព្រឹត្តធ្វើសោះឡើយ បើអាត្មាអញនៅតែប្រព្រឹត្តធ្វើឲ្យ
កន្លងព្រះបញ្ញត្តដូច្នោះ តើអាត្មាអញគួរអៀនខ្មាសគេអ្នកចេះដឹងដែរឬទេ
បព្វជិត ទោះជាកិក្ខុសាមណេរប្រើប្រាស់ចីវរគឺស្បែកដណ្តប់ ឲ្យជាបរិ-
មណ្ឌល រៀលទៅកន្លែងវត្តត្រូវត្រង រៀលចេញពីវត្តចូលទៅកាន់ភូមិគ្រ-
ហស្ថ ត្រូវតែយ៉ាំឲ្យជាបរិមណ្ឌល ព្រមចាំងត្រូវពាក់កុំឲ្យធង ខ្ទិងខានពុំបាន
បើអាត្មាអញមិនបានអើតើ យកចិត្តខុកជាក់ប្រព្រឹត្តតាមពុទ្ធបញ្ញត្តទោះទេ
តើអាត្មាអញគួរអៀនខ្មាសចំពោះគេអ្នកចេះដឹងដែរឬទេ ? ។

ការសិក្សារៀនសូត្រធម្មវិន័យឲ្យចេះដឹងដើម្បីប្រតិបត្តិតាមផ្លូវខ្លួន
ទាំងជួយដឹកនាំអ្នកដទៃមាន១ចាស់ក-១ចាស់កា ៣យក-៣យ៉ាកាដើងវត្ត
ជាដើមឲ្យគេចេះដឹង ដើម្បីប្រតិបត្តិតាមផង នេះដាការណ៍យកចិត្តរបស់
បព្វជិត។ ត្រូវតែធ្វើឲ្យមានខានតុំបាន បើអាត្មាអញមិនបានសិក្សារៀនសូត្រ
ដោយខ្លួនឯងទាំងមិនបានដឹកនាំអ្នកដទៃឲ្យរៀនចេះដឹងផងទេ នាំគ្នាស្លប់
ហើយប្រកាន់តាមខំទៀមទម្ងាប់ដែលចាំត ។ មកចាំងខុសចាំងត្រូវ តើ
អាត្មាអញដែលធ្វើជាមេបាគេកងទ័ពវត្តអាចមនិមួយ ។ គួរអៀនខ្មាស់ចំពោះ
លោកអ្នកចេះដឹងចាំងឡាយដែរឬទេ ? នៅទីវត្តអាចមគេឯទៀត ខ្លះមាន
សាលារៀនធម្មវិន័យ ខ្លះមានសាលារៀនចាលីព្រះត្រៃបិដក ខ្លះមាន
ចាំងសាលារៀនធម្មវិន័យ មានចាំងសាលារៀនចាលីព្រះត្រៃបិដកផង ឯ
ទីវត្តអាចមរបស់អាត្មា គ្មានសាលារៀនណាមួយឡើងគេសោះ តើអាត្មា
អញ គួរអៀនខ្មាសចំពោះជនដទៃដែលគេមើលមកឃើញដែរឬទេ ?
អគោចរ គឺទីដែលបព្វជិតមិនគួរចូលទៅរក មានវេសិយាគោចរជាដើម
ឡើងទីផ្សារ ព្រោះផ្សារជាទីប្រជុំសាធារណជនចរទេសជាដើម ឯជនចរ
ទេសច្រើនជាអ្នកមិនជ្រះថ្លា មិនជឿមិនគោរពពុទ្ធសាសនាទេ យើងជា
បព្វជិតកាន់ពុទ្ធសាសនា ត្រូវតែមានសំវរៈការសង្រួមប្រុងប្រយ័ត្នឲ្យដឹងថា
ទីនេះគួរទៅ ទីនោះពុំគួរទៅ ទីកន្លែងណាដែលមានគេមើលងាយ គេ
មិនគោរព គេមិនជ្រះថ្លាចំពោះខ្លួនផងទេ ទីកន្លែងនោះពុំគួរបព្វជិតចូល

ទៅរកឡើយ បើអាត្មាអញចេះតែដើរទៅកាន់ទីពុំគួរមានទីផ្សារជាដើម គឺដើរជ្រៀតជ្រែកក្នុងហ្វូងជនប្រុសស្រី អើតងើតផ្លៀងផ្លងសំឡឹងមើលរបស់នេះប្តូរបស់នោះ ជួនកាលក៏មានទិញដូរបស់នេះនោះខ្លះ មានទំប៉ុងជាដើម យូរៗឃុងរឃាំងដោយខ្លួនឯងតាំងថ្ងៃរសៀល បើមានជនសប្បុរសតាំងឡាយចេះធម៌វិន័យដឹងការគួរពុំគួរ គេឃើញអាត្មាអញប្រព្រឹត្តធ្វើដូច្នេះ តើអាត្មាអញគួរគៀនខ្មាសគេខ្លះដែរឬទេ ! ។ ល ។

សេចក្តីដែលបានអធិប្បាយមកតាំងផ្តែតគ្រហស្តតាំងផ្តែតបព្វជិតអំពីបទលោកាធិបតេយ្យដែលថាយកលោកជាធំ ឬ ជាប្រធានក្នុងមុខការប្រព្រឹត្តរបស់ខ្លួនដូចខាងលើនោះ ជាសេចក្តីបរិយាយជាសង្ខេប គួរឲ្យបរិស័ទតាំងគ្រហស្តតាំងបព្វជិត ពិចារណាក្នុងវេលាដែលរៀបនឹងធ្វើអ្វី ឬកំពុងធ្វើអ្វីនីមួយ ត្រូវនឹកគិតទៅដល់អ្នកដទៃជាមុនថា អំពើរបស់អាត្មាអញនេះ គេតិះដៀលឬគេសរសើរ សេចក្តីនេះសមនឹងភាសិតបុរាណថា « ចេះឯងឲ្យត្រែងចេះគេផង » ដើម្បីកិច្ចការនោះ ។ អាចឈានទៅរកសេចក្តីត្រូវ សេចក្តីចម្រើនរុងរឿង ។

ធម្មាធិបតេយ្យ

ធម្មាធិបតេយ្យ ប្រែថា ភាពនៃបុគ្គលយកធម៌ជាអធិបតី ជាធំ ។ ភាគ្យថាធម៌ក្នុងទីនេះ សំដៅយកច្បាប់គឺច្បាប់ខាងផ្លូវលោក និងច្បាប់

ខាងផ្លូវធម៌ ។ បញ្ជាប់ខាងផ្លូវលោក បានដល់បញ្ជាប់ដែលពាដង្ហាក់ថាលមានព្រះមហាក្សត្រ័យជាប្រមុខ បានតែងតាំងបញ្ជាត្តខ្លឹងសម្រាប់ប្រទេសដើម្បីឲ្យប្រជាពលរដ្ឋគោរពប្រតិបត្តិតាម ឲ្យមានសណ្តាប់ធ្នាប់រៀបរយ ។ បញ្ជាប់ខាងផ្លូវធម៌ បានដល់ពុទ្ធោវាទ គឺធម៌និងវិន័យ ដែលព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់ដឹងខ្លឹងក្នុងលោក ហើយទ្រង់បានបញ្ញត្តបានសម្តែងតែងតាំងទុកមក ដើម្បីឲ្យសត្វលោកទូទៅគោរពប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍ នឹងសេចក្តីសុខ ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ។

សូមអធិប្បាយសេចក្តីកងឹបទធម្មាធិប្បាតេយ្យដោយសេចក្តីរួបរួមដូចតទៅនេះ ៖

បុគ្គលជាគ្រហស្តក្តី ជាបព្វជិតក្តី កាលបើប្រារព្ធធ្វើកិច្ចការអ្វីនីមួយត្រូវគោរពជល់ធម៌ គឺបញ្ជាប់ឲ្យដឹងថា ការនេះគួរឬមិនគួរ ត្រូវឬខុសជាមុនសិន ដើម្បីកុំឲ្យទុកនូវសេចក្តីស្តាយក្រោយ កុំឲ្យសាបសាបរលាបរលាសចាត់ទៅ ប្រៀបដូចជាអំបិល ធម្មតាអំបិល ជាធម្មជាតិមានរស់ប្រៃតែម៉្យាង បើទុកជាគេយកទៅលាយឡំប្របូកប្របល់ជាមួយនឹងវត្ថុផ្សេង ។ មានរស់ផ្អែម ល្វីង ជូរ ចត់ ជាដើម អំបិលក៏មិនត្រឡប់ប្រែក្លាយទៅតាមវត្ថុទាំងនោះឡើយ គឺទៅតែរក្សាសេរីប្រៃរបស់ខ្លួនទុកជាដែល យ៉ាងណាមិញបុគ្គលណាមួយ នោះធ្វើកិច្ចការអ្វីដែលជាប្រយោជន៍សាធារណៈក្តី ជា

ប្រយោជន៍ចំពោះខ្លួនក្តី ត្រូវចេះពិនិត្យពិចារណាឲ្យដិតដល់តម្រង់ទៅតាមច្បាប់ មិនឲ្យឃ្លៀងឃ្លាត ពាំនាំមិនអើពើដល់ពាក្យទន្ទឹង ឧទ្ធច្ចកុក្កុច្ចរបស់អ្នកដទៃផងទេ បុគ្គលនោះ ទើបហៅថាជាអ្នករក្សាសេចក្តីល្អរបស់ខ្លួនពុំមានឲ្យសាបរលាបឡើយ ក៏ដូច្នោះដែរ ។ មួយយ៉ាងទៀត បុគ្គលអ្នកប្រាថ្នាតែសេចក្តីល្អ ដើម្បីខ្លួន ឧទ្ធច្ចកុក្កុច្ចរបស់អ្នកដទៃ ត្រូវតែញ៉ាំងកាយ វាចា ចិត្ត ឲ្យប្រព្រឹត្តទៅតាមច្បាប់ ហើយពុំញាប់ញ័ត កុំតក់ស្លុតខ្លាចចំពោះទុច្ចរិតផ្សេង ។ ដែលកំពុងកើតឡើង ឬដែលប្រឹងនឹងកើតឡើងក្នុងកាលខាងមុខក៏ដោយ ត្រូវតែអត់ធ្មត់តស៊ូជាជាងប ទើបរកសេចក្តីល្អនោះឃើញ ព្រោះថា ធម្មតា ការធ្វើសេចក្តីល្អឬការស្វែងរកសេចក្តីល្អ ជួនកាលតំប្រព្រឹត្តទៅបានដោយស្រួល ជួនកាលតំពុំបានដោយស្រួល តែរមែងជួបប្រទះនឹងទុច្ចរិតអ្វីនីមួយពុំខាន នេះជាធម្មតារបស់អ្នកធ្វើសេចក្តីល្អ ត្រូវតែអធិដ្ឋានតាំងចិត្តទុកជាមុនថា អាត្មាអញបើទុកណាជាគេយកទ្រព្យ ឬយកយស័ក្តិជាដើមមកប្រលោមប្រតាល់ឲ្យក្តី តុំនោះសោត គេយកអណាចមកប្រើគម្រាមផ្តាញ់ផ្តាសាក្តី ដើម្បីបំបែរឲ្យឆ្ងាកចេញពីសេចក្តីល្អរបស់ខ្លួននោះក៏ដោយ បុគ្គលអ្នករក្សាសេចក្តីល្អ កុំគប្បីរៃលាស់ភ័ន្តភាន់ភាំត ទៅត្រូកអានើងរបស់ពាំងនេះ ឬតក់ស្លុតខ្លាចអំណាចនោះឡើយ ត្រូវតែដំនះឈានកន្លងទុច្ចរិតផ្សេង ។ នោះឲ្យបានដកប ទើបបានឈ្មោះថាជាអ្នករក្សាសេចក្តីល្អរបស់ខ្លួនពុកបាន បើមិនដូច្នោះទេ ឧទ្ធរក្សាសេចក្តីល្អ

របស់ខ្លួនពុកឱ្យបានគ្រប់គ្រាន់តាមកាលកំណត់ពុំបានឡើយ ប្រៀប
ដូចជាឈ្លួក ធម្មតាជាឈ្លួត ពុកជាជូរចេញមកពីកក់ជ្រាំគ្រឿងសំអុយ
ស្មោកគ្រោកយ៉ាងណាក៏ដោយ ជាឈ្លួកនៅតែក្សាលំអនឹងខ្លួនក្រអូប
របស់ខ្លួនពុកដដែល មិនត្រមៃប្រែក្លាយទៅតាមគ្រឿងសំអុយនោះឡើយ
យ៉ាងណាមិញ បុគ្គលដែលមានទុត្តមតិយល់ច្បាស់នូវសេចក្តីល្អ នឹង
សេចក្តីអាក្រក់ហើយ បើពុកជាទៅនៅក្នុងចំណោមមនុស្សពុួចតែប្រព្រឹត្ត
អាក្រក់យ៉ាងណា ក៏មិនត្រមៃលះបង់សុចរិត (ការប្រព្រឹត្តល្អ) របស់ខ្លួន
ចោលហើយក្លាយទៅតាមមនុស្សពុួចតែនោះឡើយ គឺនៅតែក្សាទុត្តមតិ
របស់ខ្លួន ពុកឱ្យគង់វង់នៅដដែលកំដូចោះដែរ ។

សេចក្តីអធិប្បាយអំពីអធិបតេយ្យ ៣ យ៉ាង

ចាំងខាងតតិធម៌ ចាំងខាងតតិលោក ចប់ដោយសង្ខេប ។

ព្រះអភិធម្មបិដក

(កម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ូ រៀបរៀង

ពមក

កតត្តាកម្ម

ឯតេហិ បន តីហិ វិមុត្តិំ អញ្ញាណាវសេន កតំ កតត្តា ច បន កតំ ជាម តំ យថា ជាម ឧម្មត្តកេន បិត្តំ ឧណ្ហំ យត្ថ ច តត្ថ ច កច្ឆតិ ឯ វមេវ តេសំ ករុណាទីនំ អភាវេន យត្តកត្តចិ វិបាកំ នេតិ ។

លំដាប់នេះ សូមវិសជ្ជនាកថ៌ក្នុងកម្មប្បច្ច័យ អធិប្បាយនូវកតត្តាកម្ម តទៅ ដំណើរសេចក្តីថា ឯតេហិ បន តីហិ វិមុត្តិំ កម្មដែលឈ្មោះថា „កតត្តាកម្ម„ នោះ សំដៅយកចំណែកពាក់ព័ន្ធ នឹង ចំណែកកុសល ចំណែកអកុសល ដែលផុតអំពីកម្ម ៣ ប្រការ គឺ គរុកម្ម ១ ពហុលកម្ម ១ យថាសន្នកម្ម ១ ។

កតត្តាកម្មនោះ សំដៅយកតែត្រង់ការធ្វើ មិនបានដឹងថាជាកម្ម ខាងកុសល ឬ ខាងអកុសលទេ ប្រៀបដូចកំណាត់ឈើដែលមនុស្សឆ្អែត ត្រវែងចោលទៅ ធម្មតាកំណាត់ឈើដែលមនុស្សឆ្អែតត្រវែងចោលទៅ

នោះ រមែងភ្លាត់ចុះចំណាមួយមិនខាន ប៉ុន្តែ គប្បីដឹងថានឹងភ្លាត់ចុះ
លើប្រុសពីរ គ្រាន់តែមិនអាចកំណត់បានថានឹងភ្លាត់ចុះក្នុងទីនោះប្តូទីនេះ
ប៉ុណ្ណោះ សេចក្តីនេះមាន១បមាដូចម្តេច គតត្តាភម្មនោះ កំណត់កាល
ដែលនឹងឲ្យផលមិនបាន គប្បីកំណត់បាន តែថានឹងឲ្យផលក្នុងភពណា
មួយប៉ុណ្ណោះ ដូចជាកំណាត់ឈើដែលមនុស្សឆ្កួតគ្រវែងចោលទៅ
ដូច្នោះ ។ បុគ្គលអកតធ្វើកតត្តាភម្មនោះ មិនដឹងថាជាកុសលឬជាអកុ-
សលទេ ដូចពាក្យមិនទាន់ដឹងក្តី មាតាបង្គំនូនប្រាប់ឲ្យសំគាល់ឲ្យ
ប្តូចាប់ដៃឲ្យដាក់ចូលត្រ ប្រាប់ឲ្យកាវនាជមិ ពាក្យនោះកំណើតាមមាតា ។
បើមិនធ្វើដូច្នោះទេ ១បមាដូចសុវបោតកៈកូនសេកឬ កូនសារិកាម្ចាស់វា
បង្ហាត់ឲ្យពាក្យនោ ពាក្យថាទៅតាមម្ចាស់ ពាក្យមិនដឹងថាជាចុបឬជាបុណ្យ
សោះឡើយ ។ បើនិយាយពីខាងអកុសលវិញ ដូចកូនក្មេងតូចដែល
ម្តាយពាក្យនៅចង្កើះ ដូនតាលាក់ក្តិចភ្នាក់ភ្នាក់ឲ្យម្តាយវាក់ ។ មិនដឹងថាជាចុបឬ
ជាបុណ្យទេ ប៉ុន្តែ អកុសលកម្មដែលវាធ្វើរួចហើយនោះ រមែងឲ្យផល
ដែលថាចុបធ្វើរួចហើយ គ្មានឲ្យផលនោះពុំមែនទេ គឺឲ្យផលជាមិនខាន
គ្រាន់តែកំណត់កាលដែលនឹងឲ្យផលនោះ មិនបានប៉ុណ្ណោះ ព្រោះថាកម្ម
នោះមិនស្រួលភ្លាំងភ្លាំ មិនស្រួលធ្ងន់ពេក ។

មានតាក្យបុច្ឆាថា កិំ ជាឧទ្ទេ ករតំ វា កុសលនឹង
អកុសលខាងពីរប្រការនេះ បើអ្នកដឹងហើយធ្វើ ឧទ្ទេអ្នកមិនដឹងធ្វើនោះ

តើទាន៦ណាទើបមានផលច្រើនជាងទាន៦ណា ទាន៦អ្នកដឹងហើយធ្វើ មានផលច្រើន ឬក៏ទាន៦អ្នកមិនដឹង ធ្វើ មានផលច្រើន ?

មានពាក្យវិសជ្ជនាថា ចំណែកទាន៦បុណ្យកុសលនោះ អ្នកដឹងហើយធ្វើ ចានផលានិសង្សច្រើន បើអ្នកមិនដឹងធ្វើ ចានផលានិសង្សតិច។ ចំណែកទាន៦ចាបអកុសលវិញ អ្នកមិនដឹង ធ្វើចាប ចានចាបច្រើន បើអ្នកដឹង ធ្វើចាប ចានចាបតិច ។

មានពាក្យបុច្ឆាថា ចំណែកទាន៦បុណ្យកុសល ហេតុអ្វីចានជាអ្នកដឹង៦ាបុណ្យកុសល ហើយធ្វើ ចានផលានិសង្សច្រើន ព្រោះហេតុដូចម្តេច បើអ្នកមិនដឹង ធ្វើ ចានផលានិសង្សតិច ព្រោះហេតុដូចម្តេច ?

មានពាក្យវិសជ្ជនាថា អ្នកដឹង៦ាជាបុណ្យកុសលហើយធ្វើ ចានផលានិសង្សច្រើននោះ ព្រោះហេតុថា មនុស្សចូលចិត្តនឹង៦ាឲ្យទានរបស់អ្វី តំឲ្យជាសប្បុរិសទាន ហើយញ៉ាំង៦ិត្តឲ្យជ្រះថ្លាក្នុង៦ាលពាន់ដងមើបើនឹង៦ាឲ្យភោជនាហារ តំឲ្យតែវត្ថុដែលល្អថ្លៃថ្លា ឲ្យតែវត្ថុដែលខ្ជួនគេញចិត្ត ហើយធ្វើឲ្យជាសាមីទាន ប្រសើរ ជាងរបស់ដែលខ្ជួនបរិភោគ។

ពាក្យដែលថា ឲ្យជាសប្បុរិសទាននោះ គឺឲ្យដោយដៃនៃខ្ជួន មិនបាននាំឲ្យ ឲ្យសមគួរដល់សមណៈ។ ធាន់គ្មានអាបត្តិ ទឹង៦ឲ្យដោយសទ្ធាជឿកម្មជឿផល កាលទឹង៦ធ្វើកុសល តែងយកព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណជាអារម្មណ៍ កាលទឹង៦ចំតេញទាន មិនបាន

សង្ឃ័ត់សង្ឃិនប្រមាថមើលងាយ អ្នកខ្ជួលម្ចាប់ចិត្តឲ្យផុតចាកសោកៈ ភោសៈ ទីឆ៌មោហៈតែឆ៌គោរតាមានបេះខ្លួន ទីឆ៌គោរតអ្នកខ្ជួលមាន ។

ពាក្យដែលថាឲ្យមាន ដោយចិត្តជ្រះថ្លាក្នុងកាលតាំងបីនោះគឺ បុព្វចេតនា មុនពីពេលមិនទាន់ឲ្យ បេះតែគិតទីឆ៌ឲ្យ ក៏មានចិត្តជ្រះថ្លា ១ មុញ្ចនចេតនា កាលកំពុងឆ៌ឲ្យ ក៏មានចិត្តជ្រះថ្លា ១ អបរចេតនា ឲ្យរួចហើយ ទីតរលឹកយើញ ក៏មានចិត្តជ្រះថ្លា ១ ។

បុគ្គលធ្វើការកុសលគឺឲ្យជាសប្បុរិសទាន ក៏មានផលានិសង្សច្រើនទីឆ៌បំតេញទាន ការកុសល ដោយអំណាចនៃចេតនាតាំងបីនោះ ក៏រមែងមានផលជាអស្ចារ្យ ។ ឯបុគ្គលអ្នកមានបញ្ញា ដោយហោចទៅ សូម្បីត្រាន់តែស្តាប់ព្រះធម៌ទេសនា ក៏ប្រកបដោយចេតនាតាំងបីដែរ គឺតិតទីឆ៌ស្តាប់ក៏មានចិត្តជ្រះថ្លា ១ កំពុងឆ៌ស្តាប់ក៏មានចិត្តជ្រះថ្លា ១ ស្តាប់រួចហើយ ទីតរឭកយើញវិលាណា ក៏មានចិត្តជ្រះថ្លា ១ ។ ហេតុនោះ ឋានជាឆ្នើយថា បុគ្គលអ្នកស្គាល់បុណ្យស្គាល់ឋាប ធ្វើបុណ្យ ឋានបុណ្យច្រើន ធ្វើឋាប ឋានឋាបតិច ។

បុគ្គលអ្នកស្គាល់ឋាប ធ្វើឋាប ហើយឋានឋាបតិចនោះគឺថា មនុស្សតាំងឡាយបញ្ចូលគ្នាទៅធ្វើឋាប មានសូចត្រីជាដើម អ្នកចេះដឹង ស្គាល់ឋាបជួនកាល មិនត្រមៅជាមួយទីឆ៌គេទេ ប៉ុន្តែសូមឲ្យឋានចំណែកខ្លះ មិនសម្ងាប់ទីឆ៌ដៃខ្លួនឯង ត្រាន់តែគោលពាក យើញតែសម្ងាប់ ក៏សម្ងាប់

តែសត្វតូច ។ ចាបតិច ប្រៀបដូចអ្នកដឹងថាក្ងើនក្តៅ បើនឹងចាប់
កិច្ចម ច្បាចចាប់មិនប្រមាទ ។ ហេតុនោះ អ្នកដឹងថាចាប ហើយធ្វើចាប
ទើបចាបតិច ព្រោះមានបញ្ញា ។

មនុស្សមិនស្គាល់បុណ្យនឹងចាប ធ្វើបុណ្យចានបុណ្យតិចនោះ
ព្រោះហេតុថានឹងធ្វើបុណ្យឲ្យទាន តំណាអសប្បុរសទានគឺបោះឲ្យ ត្រវែង
ចោលទៅឲ្យ ប្រើឲ្យអ្នកបម្រើធ្វើ មិនជឿកម្ម មិនជឿផល មិន
គោរពអ្នកទទួលទាន មិនគោរពចំពោះវត្ថុទានរបស់ខ្លួន បើនឹងរក្សា
សីល តំរក្សាសីលរបស់បុគ្គលជាពួកតិរ្ថីយ៍នឹងគ្រន្ថ បើនឹងស្តាប់ព្រះធម៌
ទេសនាក៏ឥតគោរព តឹអ្នកខ្វះសណ្តូកដើងស្តាប់ នឹងចិត្តមិនតាំងមាំ អង្គុយ
និយាយគ្នាបណ្តើរស្តាប់បណ្តើរ អ្នកខ្វះយកទានន័យគោជនីយាហារទៅ
បរិភោគ នៅពេលកំពុងស្តាប់ធម៌ទេសនា ។ ការស្តាប់ដោយកិរិយាដូច្នេះ
ឈ្មោះថាញុំងព្រះសទ្ធម្មឲ្យអន្តរធាន ព្រោះគ្មានបញ្ញា មិនដឹងការបុណ្យ
នឹងការចាប ។ ហេតុនោះ ចានជាធ្វើយថា បុគ្គលមិនដឹងថាបុណ្យនឹងចាប
នោះ ធ្វើបុណ្យចានបុណ្យតិច ព្រោះប្រព្រឹត្តកិរិយាដូចពោលខាងដើម ។

បុគ្គលមិនស្គាល់ចាប ធ្វើចាបចានចាបច្រើននោះ ព្រោះហេតុមិន
ដឹងជាចាប មិនដឹងអំពើណាថាជាកម្មធ្ងន់ កំនឹងធ្វើនូវកម្មដ៏ធ្ងន់នោះ ប្រៀប
ដូចសត្វមមាច មិនដឹងថាក្ងើនហើយ ហើរចូលគំនរក្ងើន កំស្លាប់ទៅ ។

ម្យ៉ាងទៀត បុគ្គលមិនដឹងថាចាបនោះ ប្រៀបដូចជាមនុស្សមិន
ដឹងថាគំនរក្ងើនទៅកណ្តាលផ្លូវ ខ្លួនដើរទៅជាន់លើគំនរក្ងើននោះពេញ

ដើន ។ ក៏រលាកលួយ តុតេនវៅជាដំណៅឲ្យបានវេទនាវេទនា ។
ហេតុនោះ បានជាត្វើយថា បុគ្គលមិនដឹងបាប ត្វើបាបបានបាបច្រើន។
ឯអកុសលនោះរមែងឲ្យផល តឹញ្ចាំងសត្វឲ្យបានសោយទុក្ខក្នុងអបាយ
ចំណួន មានឧបមាដើម ។ កុសលកម្មរមែងឲ្យផលប្រកបដោយ
សេចក្តីសុខ គឺសេចក្តីសុខក្នុងមនុស្ស សេចក្តីសុខក្នុងស្ថានសួគ៌ ឧត្ត
សេចក្តីសុខក្នុងព្រះនិព្វាន ។

មានពាក្យប្តឹងថា បើបុគ្គលកំពុងតែសោយផលនៃកុសលកម្ម
ចុះផលនៃអកុសលកម្ម វៅនៅចាំក្នុងទីណា ទើបថាបុគ្គលបានត្វើកុសល
ឧត្តអកុសលរួចហើយ មិនដែលមានសោយផលនៃកុសលឧត្តអកុសល
កម្មនោះទេ ។ ម្យ៉ាងទៀត កាលបុគ្គលកំពុងសោយផលនៃអកុសល
កម្ម ចុះផលនៃកុសលនោះ តើវៅនៅចាំក្នុងទីណា ?

មានពាក្យវិសជ្ជនាថា ប្រៀបដូចដើមឈើមានមែក មានស្លឹក
ល្អបរិបូណ៌ហើយត្រូវតែមានផ្លែ បុគ្គលមិនអាចចង្អុលប្រាប់ថាផ្លែវៅត្រង់
មែកនេះឬមែកនោះបានទេ មានឧបមាដូចម្តេច ឯផលនៃកុសលឧត្ត
អកុសលកម្មនោះ បើបុគ្គលបានត្វើរួចហើយ ក៏ត្រូវតែមាន មិនដែល
គ្មានផលទេ មានឧបមេយ្យដូច្នោះ ។

កតត្តាកម្មនោះ សំដៅយកត្រង់បុគ្គលត្វើ គឺត្វើកុសលកម្មឧត្តអកុ
សលកម្មចាំងពីរចំណែក ប៉ុន្តែ ក្នុងពេលត្វើនោះ មិនដឹងថាខ្លួនត្វើកុសល
កម្មឬអកុសលកម្មទេ ផលក៏មាន ប៉ុន្តែ កំណត់កាលមិនបាន លុះតែ

កាលណាគ្មានតរុកកម្ម គ្មានពហុលូកម្ម ឧដ្ឋគ្មានយថាសន្នកម្ម ពាំងបីប្រការនេះទេ កតត្តាកម្មទើបឲ្យជដ្ឋិសម្រេចផល ។ ហេតុនោះកម្មនោះ សម្តេចព្រះបរមទសពល ទើបត្រាស់ទេសនាថាជាបច្ច័យក្នុងបច្ច័យ ២៤ ប្រការ ។

កតត្តាកម្ម សង្ខេបប៉ុណ្ណោះ ។

៨ - ជនកកម្ម

លំដាប់នេះ សូមវិសជ្ជនាក្នុងកម្មបច្ច័យ អធិប្បាយនូវជនកកម្មត ៧ មានសេចក្តីថា កម្មឯណាញ៉ាំងបដិសន្ធិឲ្យកើត គឺញ៉ាំងលំដាប់នៃបញ្ចក្ខន្ធឲ្យកើតតែម្យ៉ាងប៉ុណ្ណោះ ជាគ្នាក់ជាវតែខាងញ៉ាំងបដិសន្ធិឲ្យកើតម្យ៉ាង កម្មនោះឈ្មោះថា ជនកកម្ម ។

បរិត្តេ អញ្ញំ កម្មដទៃក៏ឲ្យផលក្នុងបវត្តិកាលត ៧ យ៉ាងមានា ជនកកម្មនោះប្រៀបដូចមាតា ។ តែងញ៉ាំងបុត្រធីតាឲ្យកើតតែម្យ៉ាងប៉ុណ្ណោះ លុះបុត្រធីតាកើតរួចហើយ ស្រេចម្រេចយកទៅចិញ្ចឹមខុសៗ ស្រេចម្រេចយកចិត្តខុកជាក់ខុតបម្រុងថែរក្សា សេចក្តីនេះមានឧមាដូចម្តេច ។ ជនកកម្ម ជាគ្នាក់ជាវឲ្យកើតតែម្យ៉ាង មិនមែនជាគ្នាក់ជាវចិញ្ចឹមថែរក្សាទេ មានឧបមេយ្យដូច្នោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានយ៉ាងនេះចុះ ។

ជនកកម្ម សង្ខេបប៉ុណ្ណោះ

អំពីអ្នកបរិភោគកាម ១០ ពួក

[ទុតិយសកវគ្គ ៥ ធិតរ ៤៩ អង្គុត្តរនិកាយ]

ឧបសកនិទាន

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក៏អង្គុយ ក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី បានអង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី អ្នកបរិភោគកាមនេះ មាន ១០ពួក ក្នុងលោក ។ ១០ពួក តើដូចម្តេចខ្លះ ? ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកខ្លួរកោគទាំងឡាយ មិនត្រូវតាមគន្ធង់ធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកកោគទាំងឡាយនោះបានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែកវិលក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកកោគទាំងឡាយ មិនត្រូវតាមគន្ធង់ធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកខ្លួរកោគទាំងឡាយ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែមិនចែកវិលក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកកោគទាំងឡាយ ក្នុង

មិនត្រូវតាមគន្ធធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្លះស្វែងរកកោគ
ចាំងឡាយ មិនត្រូវតាមគន្ធធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខឲ្យផ្លែត
ចាំងចែករំលែក ធ្វើបុណ្យចាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ
មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកកោគចាំងឡាយ ត្រូវតាមគន្ធធម៌ខ្លះ
មិនត្រូវតាមគន្ធធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេ ក៏មាន មិនកំហែងសង្កត់
សង្កិនគេក៏មាន លុះស្លះស្វែងរកកោគចាំងឡាយ ត្រូវតាមគន្ធធម៌ខ្លះ
មិនត្រូវត្រូវតាមគន្ធធម៌ខ្លះ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យ
ផ្លែត មិនចែករំលែក មិនធ្វើបុណ្យចាំងឡាយ ១ ។ ម្នាលគហបតីក្នុងលោក
នេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកកោគចាំងឡាយ ត្រូវតាមគន្ធ
ធម៌ខ្លះ មិនត្រូវតាមគន្ធធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែង
សង្កត់សង្កិនគេក៏មាន លុះស្លះស្វែងរកកោគចាំងឡាយ ត្រូវតាមគន្ធ
ធម៌ខ្លះ មិនត្រូវតាមគន្ធធម៌ខ្លះ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យផ្លែត
តែងាស់មិនចែករំលែក មិនធ្វើបុណ្យចាំងឡាយ ១ ។ ម្នាលគហបតី
ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកកោគចាំងឡាយ ត្រូវ
តាមគន្ធធម៌ខ្លះ មិនត្រូវតាមគន្ធធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន
មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្លះស្វែងរកកោគចាំងឡាយ ត្រូវតាម
គន្ធធម៌ខ្លះ មិនត្រូវតាមគន្ធធម៌ខ្លះ បានមកហើយ ធ្វើខ្លួនឲ្យបាន
សុខ ឲ្យផ្លែត ចែករំលែក ធ្វើបុណ្យចាំងឡាយ ១ ។ ម្នាលគហបតី

កន្លះលោកនេះ មានអ្នកបរិភោគតាមខ្លះ ស្រុះស្រែងរកភោគទាំងឡាយ ត្រូវតាមគន្ធធម៌តឹមិនកំហែងសង្កត់សង្កិនគេ លុះស្រែងរកភោគទាំងឡាយ ត្រូវតាមគន្ធធម៌ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ម្នាលគហបតី កន្លះលោកនេះ មានអ្នកបរិភោគតាមខ្លះ ស្រុះស្រែងរកភោគទាំងឡាយ ត្រូវតាមគន្ធធម៌ តឹមិនកំហែងសង្កត់សង្កិនគេ លុះស្រុះស្រែងរកភោគទាំងឡាយ ត្រូវតាមគន្ធធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែថាស់ មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី កន្លះលោកនេះ មានអ្នកបរិភោគតាមខ្លះ ស្រុះស្រែងរកភោគទាំងឡាយ ត្រូវតាមគន្ធធម៌ តឹមិនកំហែងសង្កត់សង្កិនគេ លុះស្រុះស្រែងរកភោគទាំងឡាយ ត្រូវតាមគន្ធធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ តែនៅ ជាប់ ជ្រប់ ល្អក់ចិត្តនឹងភោគទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរៃខ្លួន ហើយចេះតែបរិភោគ។ ម្នាលគហបតី កន្លះលោកនេះ មានអ្នកបរិភោគតាមខ្លះ ស្រុះស្រែងរកភោគទាំងឡាយ ត្រូវតាមគន្ធធម៌ តឹមិនកំហែងសង្កត់សង្កិនគេ លុះស្រុះស្រែងរកភោគទាំងឡាយ ត្រូវតាមគន្ធធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជាប់ មិនជ្រប់ មិនល្អក់ចិត្តនឹងភោគទាំងនោះទេ ឃើញទោស មានបញ្ញា

ជាគ្រឿងរំខួន ហើយបរិភោគ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគ
កាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកកោគទាំងឡាយ
មិនត្រូវតាមគន្ធង៌ធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វែងរកកោគទាំង
ឡាយ មិនត្រូវតាមគន្ធង៌ធម៌ បានមកហើយ មិនធ្វើខ្លួន ឲ្យបានសុខ
ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នក
បរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ៣ ប្រការ គឺគេតិះដៀល
ដោយហេតុទី ១ ថាស្វះស្វែងរកកោគទាំងឡាយ មិនត្រូវតាមគន្ធង៌ធម៌
គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ ថា មិនធ្វើខ្លួនឲ្យ
បានសុខ ឲ្យឆ្អែត គួរគេតិះដៀល ដោយហេតុទី ៣ ថា មិនចែក
រំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគ
កាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកកោគទាំងឡាយ មិន
ត្រូវតាមគន្ធង៌ធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកកោគទាំង
ឡាយ មិនត្រូវតាមគន្ធង៌ធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត
តែតាស់ មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី
អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ២ ប្រការ គេសរសើរ
ដោយហេតុ ១ ប្រការ គឺគេតិះដៀល ដោយហេតុទី ១ ថា ស្វែងរកកោគ
ទាំងឡាយ មិនត្រូវតាមគន្ធង៌ធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរ
ដោយហេតុ ១ ប្រការថា បើធ្វើខ្លួន ឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀល

ដោយហេតុ ២ ថា មិនចែករំលែក មិនធ្វើបុណ្យតាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមតាំងនោះ អ្នកបរិភោគកាមណា សូរៈស្វែងរកភោគតាំងឡាយ មិនត្រូវតាមគន្ធង៍ធម៌ គឺកំហែងសង្កត់សង្កិនគេ លុះសូរស្វែងរកភោគតាំងឡាយ មិនត្រូវតាមគន្ធង៍ធម៌ បានមកហើយ ធ្វើខ្លួនឲ្យឆ្អែនស្រេច ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យតាំងឡាយ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ១ ប្រការ គេសរសើរដោយហេតុ ២ ប្រការ គឺគេតិះដៀល ដោយហេតុ ១ ប្រការថា សូរស្វែងរកភោគតាំងឡាយ មិនត្រូវតាមគន្ធង៍ធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុថា ១ ថា ធ្វើខ្លួនឲ្យឆ្អែនស្រេច ឲ្យឆ្អែត គេសរសើរ ដោយហេតុថា ២ ថា ចេះចែករំលែកធ្វើបុណ្យតាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមតាំងនោះ អ្នកបរិភោគកាមណា សូរស្វែងរកភោគតាំងឡាយ ត្រូវតាមគន្ធង៍ធម៌ខ្លះ មិនត្រូវតាមគន្ធង៍ធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះសូរស្វែងរកភោគតាំងឡាយ ត្រូវតាមគន្ធង៍ធម៌ខ្លះ មិនត្រូវតាមគន្ធង៍ធម៌ខ្លះ បានមកហើយ មិនធ្វើខ្លួនឲ្យឆ្អែនស្រេច ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យតាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ១ ប្រការ គេតិះដៀល ដោយហេតុ ៣ ប្រការ គឺគេសរសើរដោយហេតុ ១ ប្រការ

ថា ស្មុះស្មៃងរកកោតចាំងឡាយ ត្រូវតាមគន្ថធម៌ តើមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ ថា ស្មុះស្មៃងរកកោតចាំងឡាយ មិនត្រូវតាមគន្ថធម៌ តើកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ ថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀលដោយហេតុទី ៣ ថា មិនចេះចែករំលែក មិនធ្វើបុណ្យចាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគតាមចាំងនោះ អ្នកបរិភោគតាមណាស្មៃងរកកោតចាំងឡាយ ត្រូវតាមគន្ថធម៌ខ្លះ មិនត្រូវតាមគន្ថធម៌ តើកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្មុះស្មៃងរកកោតចាំងឡាយ ត្រូវតាមគន្ថធម៌ខ្លះ មិនត្រូវតាមគន្ថធម៌ខ្លះ ខ្លះ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែងាស់មិនចែករំលែក មិនធ្វើបុណ្យចាំងឡាយ ម្នាលគហបតី អ្នកបរិភោគតាមនេះ គេសរសើរដោយហេតុ ២ ប្រការ គេតិះដៀលដោយហេតុ ២ ប្រការ តើគេសរសើរដោយហេតុទី ១ ថា ស្មុះស្មៃងរកកោតចាំងឡាយ ត្រូវតាមគន្ថធម៌ តើមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ ថា ស្មុះស្មៃងរកកោតចាំងឡាយ មិនត្រូវតាមគន្ថធម៌ តើកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ ថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀល ដោយហេតុទី ២ ថា មិនចែករំលែក មិនធ្វើបុណ្យចាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគតាមចាំងនោះ អ្នកបរិភោគ

កាមណា សូរស្រែកកោគចាំងឡាយ ត្រូវតាមគន្ធង់ជមិ្ងះ មិនត្រូវ
តាមគន្ធង់ជមិ្ងះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិន
គេក៏មាន លុះសូរស្រែងរកកោគចាំងឡាយ ត្រូវតាមគន្ធង់ជមិ្ងះ មិន
ត្រូវតាមគន្ធង់ជមិ្ងះ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែក
រំលែកធ្វើបុណ្យចាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរ
គេសរសើរ ដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ
គឺគេសរសើរ ដោយហេតុនី ១ ថា សូរស្រែងរកកោគចាំងឡាយ ត្រូវ
តាមគន្ធង់ជមិ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុនី ១
ថា សូរស្រែងរកកោគចាំងឡាយ មិនត្រូវតាមគន្ធង់ជមិ គឺកំហែង
សង្កត់សង្កិនគេ គេសរសើរដោយហេតុនី ២ ថា ធ្វើខ្លួនឲ្យបានសុខ
ឲ្យឆ្អែត គេសរសើរដោយហេតុនី ៣ ថា ចេះចែករំលែក ធ្វើបុណ្យ
ចាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមចាំងនោះ អ្នក
បរិភោគកាមណា លុះសូរស្រែងរកកោគចាំងឡាយ ត្រូវតាមគន្ធង់ជមិ
គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត
តែមិនចែករំលែក មិនធ្វើបុណ្យចាំងឡាយ ម្នាលគហបតី អ្នកបរិភោគ
កាមនេះ គួរគេសរសើរដោយហេតុ ២ ប្រការ គេតិះដៀល ដោយ
ហេតុ ១ ប្រការ គឺគេសរសើរដោយហេតុនី ១ ថា សូរស្រែងរកកោគ
ចាំងឡាយ ត្រូវតាមគន្ធង់ជមិ គឺមិនកំហែងសង្កត់សង្កិនគេ គេសរ

សើរដោយហេតុទី ២ ថា ចេះធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត គេតិះដៀល ដោយហេតុ ១ ប្រការថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគតាមទាំងនោះ អ្នកបរិភោគតាមណា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្ធឬធម្មិ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឱ្យបានសុខ ឱ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ តែនៅជក់ជ្រប់ ល្អក់ចិត្តនឹងភោគទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរៃខ្លួន ហើយចេះតែបរិភោគ ម្នាលគហបតី អ្នកបរិភោគតាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរ ដោយហេតុទី ១ ថា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្ធឬធម្មិ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ២ ថា ចេះធ្វើខ្លួន ឱ្យបានសុខ ឱ្យឆ្អែត គេសរសើរ ដោយហេតុទី ៣ នេះថា ចេះចែករំលែកធ្វើបុណ្យទាំងឡាយ គេតិះដៀល ដោយហេតុ ១ ប្រការថា ជក់ជ្រប់ល្អក់ចិត្តនឹងភោគទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរៃខ្លួន ហើយចេះតែបរិភោគ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគតាមទាំងនោះ អ្នកបរិភោគតាមណា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្ធឬធម្មិ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្ធឬធម្មិ គឺមិនកំហែង សង្កត់សង្កិនគេ បានមក

ហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែកធ្វើបុណ្យតាំងពីដើម
ថែមតាំងមិនដាច់ មិនជ្រប់ មិនឈប់ចិត្តនឹងកោតតាំងនោះ ឃើញទោស
មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ម្នាលគហបតី អ្នកបរិភោគ
តាមនេះ គួរគេសរសើរ ដោយហេតុ ៤ ប្រការ គឺគេសរសើរ ដោយ
ហេតុទី ១ ថា ស្ទះស្វែងរកកោតតាំងពីដើម ត្រូវតាមគន្ធធម៌ គឺមិន
កំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ២ ថា ធ្វើខ្លួនឲ្យ
បានសុខ ឲ្យឆ្អែត គេសរសើរដោយហេតុទី ៣ ថា ចែករំលែក ធ្វើ
បុណ្យតាំងពីដើម គេសរសើរ ដោយហេតុទី ៤ ថា មិនដាច់ មិនជ្រប់
មិនឈប់ចិត្តនឹងកោតតាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន
ហើយបរិភោគ ③ ម្នាលគហបតី អ្នកបរិភោគតាមតាំង ១០ ពួកនេះ
មានកង្វល់លោក ។ ម្នាលគហបតី បណ្តាអ្នកបរិភោគតាមតាំង ១០ ពួកនេះ
អ្នកបរិភោគតាមណា ស្ទះស្វែងរកកោតតាំងពីដើម ត្រូវតាមគន្ធធម៌
គឺមិនកំហែងសង្កត់សង្កិនគេ លុះស្ទះស្វែងរកកោតតាំងពីដើម ត្រូវតាម
គន្ធធម៌ បានមកហើយ ធ្វើខ្លួនឲ្យសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យ
តាំងពីដើម ថែមតាំងមិនដាច់ មិនជ្រប់ មិនឈប់ចិត្ត នឹង កោតតាំងនោះ
ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ បណ្តាអ្នក
បរិភោគតាមតាំង ១០ ពួកនេះ អ្នកបរិភោគតាមនេះ ឈ្មោះថាជាកំពូល
ធង់ ប្រសើរផង បម្សាធង់ ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង ។ ម្នាលគហបតី

ដូចជាទឹកដោះស្រស់ កើតពីមេគោ ទឹកដោះជូរ ក្លាយពីទឹកដោះស្រស់ ទឹកដោះខាប់ ក្លាយពីទឹកដោះជូរ ទឹកដោះកាវ ក្លាយពីទឹកដោះខាប់ ទឹកដោះថ្លា ក្លាយពីទឹកដោះកាវ ទឹកដោះថ្លា ច្រាកជ ប្រសើរជាងទឹកដោះពាំងនោះ យ៉ាងណាមិញ ម្នាលគហបតី បណ្តាអ្នកបរិភោគតាមពាំង ១០ ពួកនេះ អ្នកបរិភោគតាមណា ស្មះស្មែងរកភោគពាំងឲ្យាយ ត្រូវតាមគន្ធង៌ធម៌ តឹមិនកំហែងសង្កត់សង្កិនគេ លុះស្មះស្មែងរកភោគ ត្រូវតាមគន្ធង៌ធម៌ តឹមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែកវិលក ធ្វើបុណ្យពាំងឲ្យាយ ចិត្តមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគពាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរំលើងខ្លួន ហើយបរិភោគ ឈ្មោះថាជាកំពូលធន ប្រសើរធន ចម្បងធន ខ្ពង់ខ្ពស់ធន ក្តីថ្លាធន យ៉ាងនោះឯង ។

នរជនដែលធ្វើកំណត់ខ្លួន ទៅក្នុងគ្រោះកាច
តែងតែបន្ទោស ព្រួយរាល់ទាំង មនុស្ស
ល្ងង់ មិនត្រមៃខ្លួលកំហុស ដែល
ខ្លួនធ្វើទេ

ហិតោបទេស

សេរីភាព (វិចារណកថា)

ដោយលោក ជេង-ស្រីវ

សេរីភាព គឺភាពដែលមានសេរី ដែលអាចធ្វើអ្វីបានតាមចំណង់តាមសេចក្តីត្រូវការរបស់ខ្លួន ។ អ្វីក៏ដោយ ដែលមានជីវិត សុទ្ធសឹងមានសេរីភាព : មនុស្សមានសេរីភាព តិរច្ឆានមានសេរីភាព រុក្ខជាតិក៏មានសេរីភាពដែរ ។ ប៉ុន្តែ សេរីភាពមានធំ មានតូច មានក្បៀបអាស្រ័យទៅតាមសមត្ថភាពនៃបុគ្គលម្នាក់ ។ នៃគ្រួសារ នៃសង្គម នៃប្រទេសនីមួយ ។ ។ នេះឯងហើយ ជាសេរីភាពធម្មជាតិ ។

ដើម្បីការពារកុំឲ្យសេរីភាពមួយរំកិលទៅជាន់លើសេរីភាពមួយ ទើបបង្កើតច្បាប់មួយហៅថាជ្ឈមន្ទញ សម្រាប់ប្រទេស ។ មានអត្ថាមួយក្នុងជ្ឈមន្ទញចែងថា គ្រប់មនុស្សត្រូវមានសេរីភាព គឺថាមនុស្សគ្រប់ធ្វើអ្វីបានតាមចំណង់ តែសូមកុំឲ្យតែ អំពើនេះផ្ទុយនឹងច្បាប់សាធារណៈ ហើយធ្វើឲ្យប៉ះពាល់ដល់សេរីភាពនៃជនដទៃ ។ ដូច្នេះហើយ ទើបមនុស្សសម័យឥឡូវ មានសភាពផ្សេងពីមនុស្សសម័យមុន។ ទិដ្ឋភាពនឹងចិត្តគំនិតនៃមនុស្សជំនាន់មុនដោយយ៉ាងណា ទិដ្ឋភាពនឹងចិត្តគំនិតនៃមនុស្សជំនាន់នេះដោយយ៉ាងណា ។ ឯការប្លែក ទៅត្រង់មនុស្សសម័យមុន មិនសូវមានចរិយាភាសដ៏ជ្រួលច្របល់ខ្លាំងដូចមនុស្សបច្ចុប្បន្ន ។ ដូចការសិក្សា កាលពីដើម មនុស្សគ្រាន់ប្រើខណៈស់

ដែលមិនចេះអានទឹងសរសេរអក្សរ ។ ឯការមិនចេះនេះ បណ្តាលមកពីការខ្ជិលឬដូចម្តេច ? តាមការសង្កេត ចំពោះសំនួរនេះ ទឹងជាមកពីការខ្ជិលក៏ច្បាស ជាមកពីមិនសូវមានសេរីភាពក៏ច្បាស ជាមកពីខ្វះសាលារៀនក៏ច្បាស បើពោលដោយសរុប ជាមកពីការខ្វះខាតចិត្ត ច្បាសសេចក្តីថា មនុស្សភាគច្រើន ឥយមចូលចិត្តថា បើរៀនចេះទៅ មិនដឹងច្បាសទៅជាអ្វីៗ អំពីមុខការរកជការវិញ ប្រសិនបើខ្លួនចង់ធ្វើ ក៏មិនងាយទឹងអាចធ្វើច្បាសលុះតែជាប់សែស្រឡាយខាងនាម៉ឺន ឬទៅផ្គាប់គុណនាម៉ឺននោះ ទើបមានផ្លូវសង្ឃឹមខ្លះ ។ ម្ល៉ោះហើយ ត្រូវដាក់ឈ្មោះថា ធ្វើការរកខ្លួលមានតែម្តងទៅ ជាការស្រេច ។

ចំណែក សម័យបច្ចុប្បន្ន ទំដ្ឋភាពផ្ទុយស្រឡះពីសម័យមុន : សាលារៀនមានចំរូណើ មនុស្សមានសេរីភាពគេញចំហឹង ចេះចង់ចូលធ្វើអ្វីក្នុងវិស័យណា គឺចូលបានតាមចិត្ត ឲ្យតែខ្លួនមានសមត្ថភាពគ្រប់គ្រាន់ ហើយគេត្រូវការផង ។ ដូច្នេះហើយ ទើបទេសភាពទឹងទំដ្ឋភាពឥឡូវ ជាទីចាប់អារម្មណ៍ពន់ពេក ។

សួរថាទំដ្ឋភាពដ៏ជាទីចាប់អារម្មណ៍នេះ មានហូរហែគ្រប់មជ្ឈដ្ឋានទាំងអស់ ឬដូចម្តេច ?

ឆ្លើយថា បើតាមការសង្កេត មិនមែនមានគ្រប់មជ្ឈដ្ឋានទាំងអស់ឡើយ ព្រោះប៉ុន្មានជនម្នាក់ញឹកដោយ ដ្បិតសេរីភាពលេបសេរីភាព ។

ដែលថា « សេរីភាពលើសសេរីភាព » សំដៅយកត្រង់ចំណុចសេរីភាពម្នាក់ មានអានុភាពខ្លាំង តែត្រូវប្រឈមនឹងសេរីភាពម្នាក់ទៀតដែលមានអានុភាពខ្លាំងដូចដើមឈើតូច ជុះក្បែរដើមឈើធំ ដើមឈើតូចនេះត្រូវតែទៅរេញតទៅ ។

គេអាចប្រឹក្សាមកទៀតថា ហេតុដូចម្តេចក៏ខ្លួនមិនប្រឹងប៉ះប៉ាំងឲ្យកែងដូចគេ ? ឆ្លើយថា ទំប្រឹងណាស់ដែរ តែកែទៅមិនរួច មកពីខ្លះដំនួយ។ សេរីភាពមានហើយ តែបើខ្លះដំនួយ ទឹងអាចកែទៅមិនបានឡើយ ។ អាស្រ័យហេតុនេះ ដំនួយនេះទៀត ចើមានចំណាត់ កំមិនអាចញ៉ាំងឲ្យអ្នកតូចកែងដំបានឡើយ ។ ដើមមានសេរីភាពថ្មោស សេរីភាពក្តៀច សេរីភាពស្ងួត ។ កាលបើមានយ៉ាងនេះ ដំណើរជីវភាពនៃប្រទេសរមែងមានការអាក់អួល ឮដងាងកង្វះជាមិនខាន ។

តាមការសង្កេត ចំពោះរឿងនេះ មានតែសង្គមពុទ្ធសាសនាមួយទេដែលបានរៀកគ្រោកកន្លងមកចេញបានស្រួល ។ ដែលថាសង្គមពុទ្ធសាសនានេះ សំដៅយកសង្គមបព្វជិតពុទ្ធសាសនា ។ ព្រះសាស្តាមុនីបានរៀបចំច្បាប់ទម្លាប់ចំពោះរឿងនេះដ៏ល្អត់ចត់ពន់ពេកណាស់ ។

សួរថាតួរឆ្លើយ៉ាងណា ដើម្បីចៀសវាងកុំឲ្យមានការអាក់អួលកង្វះដំណើរជីវភាពនៃមនុស្ស ?

ឆ្លើយថា : បើតាមលទ្ធផលនៃការត្រិះរិះ ការពិភាក្សា គួរតម្រូវចែក-

សេរីភាពជាពីរ: សេរីភាពខាងបញ្ញា សេរីភាពខាងសម្ភារៈ ។

បណ្តាសេរីភាពទាំងពីរនេះ ត្រូវជ្រើសរើស ហើយពិនិត្យឲ្យដិតដល់ បើមួយណាមិនសូវល្អ ត្រូវធ្វើចុតមួយអន្លើ រួចយកមួយដទៃមកអនុវត្តល្បងមើល ! ។

សេរីភាពខាងបញ្ញានោះដូចម្តេច ? គឺបណ្តាយឲ្យប្រាជ្ញា បើកឲ្យប្រាជ្ញា ត្រូវការពន្រីកខ្លួនឲ្យធំប៉ុណ្ណា តាមចំណង់ ចង់ចេះវិជ្ជាមែកខាងខាងណា ត្រូវផ្តល់មធ្យោបាយឲ្យទៅបានទាំងអស់ មិនត្រូវទាញបង្ហៀរទុកឡើយ ។ ដូចយ៉ាងកងសង្គមបព្វជិតខាងពុទ្ធសាសនា អង្គណាត្រូវការឲ្យប្រាជ្ញាលោកដំនាញខាងព្រះត្រៃបិដកក្តី ខាងព្រះកម្មដ្ឋានក្តី ឬវាប់ព្រះពុទ្ធបើកឲ្យធ្វើតាមចិត្តចង់ អង្គណាខ្លះ បេះតែធម៌ធ៌ាន័យបន្តិចបន្តួច ទុកជាការស្រេច ចំណែកសេរីភាពខាងសម្ភារៈវិញ ព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យតែត្រៃចីវរប៉ុណ្ណោះ ។ យ៉ាងនេះ ហៅថាសេរីភាពខាងបញ្ញា ។

សេរីភាពខាងសម្ភារៈដូចម្តេច ? គឺបណ្តាយឲ្យសម្ភារៈនៃបុគ្គលរកចម្រើនគ្មានព្រំដែន តាមសត្តភាពដែលខ្លួនមាន ។ ដូចឃើញស្រាប់ អ្នកខ្លះមានផ្ទះជួនជាប់ស្លែងតែម្នាក់ឯង ហួតដល់ ១ រយផង អ្នកខ្លះមានដីកប់រយហិកតាតែម្នាក់ឯង អ្នកខ្លះខ្លួលពានកងមួយពេលតែម្នាក់ឯង អស់ប្រាក់កប់រយ . . . . . ស្មៀកពាក់អោតមួយប្រជាប់តែម្នាក់ឯង មានតម្លៃកប់ពាន់ . . . . ។ ល ។ ផ្ទុយទៅវិញ អ្នកខ្លះមាន

តែមួយសម្រាប់ទៅ ហើយយ៉ាងដូនជាប មានតែស្រែអម្ពកមួយ ម្ជុល
ខ្វួលមានក្តងមួយគោល បើគិតជាតម្លៃ មិនដល់ទាំងតម្លៃថ្មារ ១ កញ្ចប់
របស់គេ សំលៀកបំពាក់ មិនដល់ទាំងសំពត់សម្រាប់ដូតរថយន្តរបស់គេ
ៗលៗ យ៉ាងនេះហៅសេរីភាពខាងសម្ភារៈ ។

តាមការត្រិះរិះនឹងពិចារណាឲ្យជ្រៅទៅ ឃើញថា ចំហាបញ្ញា ទោះ
បីតែប៉ុណ្ណា តំមិនជាឧបសគ្គដ៏ធ្ងន់ធ្ង ដល់ចិត្តដទៃដែលមានអាត្មាភាព
ខ្សោយ ព្រោះបញ្ញាជាអរូបធម៌ ដូចជាឃើញគេមានសញ្ញាច័ត្រជាន់ខ្ពស់
មិនដែលឃើញឬឮអ្នកណាក្តៅក្រហាយ បើសរសើរនឹងគោត ទោះ
ឃើញមានធ្ងាកដ ។ ផ្ទុយទៅវិញ បើចំហាខាងសម្ភារៈ គឺពិតជា
មានធ្វើឲ្យក្តៅក្រហាយ ដូច្នេះហើយ ឋានជាមានចោរកម្មទំនឹងឃាដកម្មជា
ហូរហែ ស្ទើរតែគ្រប់តំបន់ ។

ចំពោះសេរីភាពទាំងពីរបែប ដូចពណ៌នាមកខាងលើ សូមមិត្តអ្នក
អានទាំងឡាយ ដោះស្រាយហើយវិនិច្ឆ័យ ថាតើគួរយកណា គួរលះបង់
ណា ព្រោះបើតាមការយល់ឃើញ ផ្លូវកែងលោកមានតែពីរប៉ុណ្ណេះ ។

វិបតានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង-ខាត់ រៀបរៀង

(តមក)

អធិរោបណា ន ប៉ុ. ការយាំឡើងក្រៃលែង ការយាត់ងនៅ ។

អធិរោហ គុ. ដែលឡើងក្រៃលែង ដែលធំរសេះ ។ ប៉ុ. ហ្នង់រ ។

អធិរោហណា ន ប៉ុ. ការយាឡើងក្រៃលែង ការឡើង ។

អធិរោហិនី គុ. (ផ្ទះ) ដែលឡើងទៅកាន់ ។ រោហិណី ស្ត្រី ដណ្តើរ ។

អធិលង្កិម ក្រ វិ ឲ្យធខាងលើនៃក្រុងលង្កា ។

អធិលវង្គិម ក្រ. វិ. ឲ្យធខាងបុងនៃផ្លាភាន់ភ្ញ ឬ ផ្លាច័ន្ទន ។

អធិលោក ប៉ុ. អធិលោក លោកក្រៃលែង ។

អធិវក្សស ក្រ. វិ. ឲ្យធក្រែង ។

អធិវាស នៅក្រៃលែង តាំងទីលំនៅ ទីតាំង ។

អធិវិហ ក្រ. ឥ ដឹកនាំ ។

អធិវាស ប៉ុ. អ្នកនៅ អ្នកដឹកខាង ទីស្នាក់ការ លំនៅ ។

អធិវាស នុ. ទ្វិនក្រអូប ទ្វិន ។ -សាទ ឬ -សិទ្ធ ស្ត្រី. ការនៃការយក
អប់ទ្វិន ។

អធិវាសន ន ប្ដុ. ការយកអប់ទ្វិន ។

អធិវិជ្ញាន ន ប្ដុ. វិទ្យាក្រៃលែង ។

អធិវិទ្ធ ក្រ. ចាន់ក្រៃលែង យកថ្នា ចាន់ថ្នា ។ អធិវិជ្ញា ស្ត្រី. ប្រពន្ធដែលថ្នី
យកប្រពន្ធទៀត ប្រពន្ធមិនដាច់ប្រោសប្រាណ ។

អធិវិទ្យមិ ក្រ. វិ ដំហើយដោយវិជ្ជាក្រៃលែង ។

អធិវិរាជ ក្រ. ខែក រំលែក ។

អធិវិវិជ ក្រ. ចូលក្រៃលែង តាំងនៅ ។

អធិវិមក្ខ គុ. ដែលដាច់ក្រៃលែង ដែលតាំងនៅ ។

អធិវ្រូត ក្រ. ប្រព្រឹត្តទៅក្រៃលែង កម្រើក ។

អធិវេត្តវ្យា ស្ត្រី. ប្រពន្ធថ្នីលែង ។ -វ៌ា ស្ត្រី ប្រពន្ធដែលថ្នីលែង ។

អធិវេលមិ ក្រ. វិ. តាមត្រើយ លើត្រើយ ។

អធិវេត្ម ក្រ. វិ. ក្នុងផ្ទះ ។

រឿងសាមកុក

ខេត្តវិបុលរាជសេនា ឬ-ភាន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកពុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសចេះជានអាន
> ទំនៀបបេះខួបយកលច់ណាន
> ទាំងមានសន្តានស្នេហាជាតិ ។
>
> ———— ឃួរ-អ៊ុន ————

ខណៈកាលខ្លៅពីភ័យឃោះហៅខ្លែវហ៊ុយឲ្យថយទៅនោះ ម៉ាឈៀវក៏ត្រឡប់ចូលមកបន្ទាយ គិតខឹងក្តៅនឹងខ្លែវហ៊ុយជាខ្លាំងណាស់ ក៏ពាក់ក្រោះខ្លើងសេះថ្មី នាំទាហានទៅដល់មុខបន្ទាយ ហើយស្រែកដោយគោរសាថា ពេលយប់នេះ ខ្លែវហ៊ុយត្រូវចេញមកច្បាំងនឹងអញខ្លែត ខ្លែវហ៊ុយឮដូច្នោះក៏ខឹងណាស់ ប្តូរយកសេះខ្លៅពីមកដិះ ហើយនាំទាហានចេញទៅស្រែកថា ពេលយប់នេះបើអញមិនចាប់ខ្លួនម៉ាឈៀវឯងឲ្យបានទេ អញក៏មិនវិលត្រឡប់ចូលបន្ទាយវិញឡើយ ម៉ាឈៀវស្រែកតបថា កុំពេលយប់នេះ បើអញមិនមានជ័យដំនេះលើឯងទេ អញក៏មិនវិលចូលបន្ទាយ ។

កុំខណៈនោះ ទាហានទាំងសងខាងអុជគប់ភ្លើងខ្លើងភ្លឺស្វាងចាំ

ដូចវិញ្ញ មាំឈៀវនឹងខៀវហ៊ុយចាំងគ្នាបាន ២០ ភ្លេង មាំឈៀវធ្វើជា ៥យរត់ ខៀវហ៊ុយក៏ញាក់សេះដេញតាមទៅភ្លាម ក៏គិតថា មាំឈៀវមិនគាន់ភ្លាត់ភ្លាំងក្នុងភ្លេងអាវុធត្រង់ណា ហើយគាញសេះវ៉ះរត់ទៅដូច្នោះ មុខជាធ្វើកលៗបាយអ្វីជាប្រាកដ ខៀវហ៊ុយក៏គិតរពាំងខ្លួន មិនចូលទៅឲ្យជ្រុលការ ។ មាំឈៀវឃើញខៀវហ៊ុយដេញចូលមកជិត ក៏លើកដំបងដែកវាយខៀវហ៊ុយ ។ យកលំពែងរងំខ្លាតចេញ ហើយគាញញាក់សេះរត់ មាំឈៀវក៏ដេញតាមពីក្រោយទៅ ខៀវហ៊ុយក៏ត្រឡប់បែរមុខមកវិញ យឺតធ្វើបាញ់មាំឈៀវ ។ ក៏យកលំពែងរងំគាន់ព្រួញខ្លាតចេញ ខ្លួលដល់ពេលយាម ២ ជាយ មាំឈៀវក៏ត្រឡប់ចូលទៅកាន់ប្រជុំគាហាន ខៀវហ៊ុយក៏ត្រឡប់ទៅវាគេឡៅពីឯបន្ទាយ ។

ឡៅពីកំបរសេះចេញទៅមុខគាហាន ហើយស្រែកប្រកាស ប្រាប់ថ្នាទីឯយកចិត្តមាំឈៀវថា វៀលក៏យប់ឯងឯតណាស់ទៅហើយ ចូរអ្នកត្រឡប់ទៅឈប់សម្រាកក្នុងបន្ទាយសិនចុះ ព្រឹកស្អែក សឹមចេញមកចាំងគ្នាទីឯមាំឈៀវទៀត មាំឈៀវឮដូច្នោះ ក៏នាំគាហានត្រឡប់ចូលបន្ទាយឡៅពីទីឯខៀវហ៊ុយក៏វិលចូលមកបន្ទាយវិញ ។ លុះព្រឹកឡើងខៀវហ៊ុយក៏ចាត់ចែងគាហានទីឯចេញទៅចាំងទីឯមាំឈៀវម្តងទៀត ។ ខ្លួលបំរើសេះមកប្រាប់ឡៅពីថា ឥឡូវខុងចេងតាមមកដល់ហើយ ។ ឡៅពីឮដូច្នោះ ក៏មានអំណរណាស់ ទើបចេញទៅទទួលខុងចេងចូលមក ។ ខុង

បេនថា មាំឈៀវនោះមានថ្លៃដែរខ្លាំងតែណាស់ បើចង់ទិនេវៀហ៊ុយ នេះ កំបីដូចខ្លា ២ តន្លា តន់តែនឹងក្លាត់មួយ ។ មិនមាន ខ្ញុំនឹងសុំធ្វើកល ។ ជាយឲ្យមាំឈៀវចូលមកទៅនឹងលោកដោយស្រួល ។ ឡៅពីថា ខ្ញុំបាន ឃើញថ្លៃដែរមាំឈៀវហើយ ខ្ញុំក៏គិតណាស់ដែរ តែចង់បានមកធ្វើការជា មួយ ដែលលោកថានេះ ខ្ញុំពេញចិត្តណាស់ តែលោកនឹងគិតឲ្យជាយ ដោយប្រការម្តេច នឹងឲ្យបានខ្លួនមាំឈៀវដោយស្រួល ។

ខុនបេនថា ខេវៀឡនោះ មានចិត្តកំរើបនឹងចង់តាំងខ្លួនឡើង ជា ស្តេចក្នុងស្រុកហ៊ានគុង មានទីប្រឹក្សាម្នាក់ឈ្មោះអៀវសុង ឯអៀវសុង នោះជាមនុស្សលោភ ប្រាថ្នាចង់បានតែរបស់ឡើង ។ ពុកជាប្រយោជន៍ របស់ខ្លួន បើដូច្នោះ សុំឲ្យលោកចាត់របស់ដែលមានតម្លៃត្រកាលនឹងសំ បុត្រឲ្យបំរើលបចូលទៅឲ្យអៀវសុង ឲ្យអៀវសុងនាំយកសំបុត្រនោះទៅ ឲ្យខេវៀឡជាសេចក្តីថា ខ្លួនលោកលើ-កងចំតមកនេះនឹងរាយយកស្រុក សៃឈួនប្រាថ្នានឹងជួយសងសឹកដែលឡៅជៀងសម្លាប់មាតាខេវៀឡនោះ បើឡៅជៀងចៅហ្វាយស្រុកសៃឈួន នឹងឲ្យមកនិយាយសម្រួលពីការអ្វី ដល់ខេវៀឡ ក៏កុំយកជាធ្ងរឡើយ បើលោករាយបានស្រុកសៃឈួនហើយ នឹងតាំងចិត្តបំរុងឲ្យខេវៀឡឡើងជាស្តេចក្នុងស្រុកហ៊ានគុងឲ្យបាន ហើយ ឲ្យខេវៀឡមានសំបុត្រទៅហៅខ្លួនមាំឈៀវឲ្យវិលចូលទៅវិញ កាលបើ មាំឈៀវនឹងលើកទ័ពត្រឡប់ទៅវិញនោះ ខ្ញុំនឹងចាត់មនុស្សឲ្យទៅស្កាត់

ឫកញ្ចាះបញ្ចាលមាំឈៀវឲ្យមកនៅធ្វើការជាមួយនឹងលោកឲ្យបាន ។

ឡៅតីបានស្តាប់មានអំណរណាស់ ទើបតែងសំបុត្រតាមពាក្យខុងមេនឲយ ហើយបានតាំមាសប្រាក់នឹងព្រៃយ៉ាងល្អ ដែលជាដំនួនអៀវសុងនោះ ឲ្យស៊ុនខៀនជាបំរែនាំចូលទៅតាមផ្លូវគាត់ ទៅឲ្យអៀវសុងឯស្រុកហ៊ានតុង ។ លុះស៊ុនខៀនបានទៅដល់ ក៏ចូលទៅគំនាប់អៀវសុងរួចហើយដំកបថា បេស់មាសប្រាក់ទាំងនេះឡៅតីឲ្យខ្ញុំបានាំមកជូនលោក លោកចូរយើញដោយផ្លូវមេត្រីជួយឈឺផ្ទាល់យកសំបុត្រនេះ ចូលទៅឲ្យខៀវឡងផង អៀវសុងយើញបេស់ទាំងពួងមានតម្លៃកំរែតអណាស់ ព្រោះជាមនុស្សលោក ទទួលយកហើយក៏នាំខ្លួនស៊ុនខៀនទៅឯសំបុត្រ ចូលទៅគំនាប់ខៀវឡងហើយដំកបថា ឥឡូវឡៅតីឲ្យមានសំបុត្រជាផ្លូវមេត្រីមកជល់លោក ។ ខៀវឡងទទួលយកសំបុត្រនោះមកមើល លុះដឹងក្តីសេចក្តីហើយក៏ថា ខ្លួនឡៅតីគ្រាន់តែជានាយខាហានខាងក្រៅ ហេតុម្តេចមកបង្អាចកន្ធឹងថា ខឹងជួយទំនុកបំរុងយើងឲ្យធ្វើស្តេចបាន លើសតម្លាំងនឹងគំនិតគិតនូវយសសក្តិណាស់ ។

អៀវសុងថា ឡៅតីនោះជានាយខាហានកំមែន តែជាពូជព្រះកងវង្ស ព្រះចៅហៀនតេ ។ គ្រង់កប់គានហៅថាមា ហើយឡៅតីឆឹងពិតទូលអំពីរឿងអ្វី ។ ព្រះចៅហៀនតេក៏ត្រូវព្រះពរជអធ្យាស្រ័យ ខ្ញុំបានយើញថា ឡៅតីបានចេញពាក្យថាប៉ុណ្ណេះ ហើយក៏គង់ឆឹងជួយទំនុបំរុងលោក

ឲ្យឡើងជាស្តេចបាន ខៀវឡូវដូច្នោះកំមានអំណរណាស់ ព្រោះចិត្តកំរើប ទើបឲ្យតែងសំបុត្រទៅហៅខ្លួនម៉ាឈៀវឲ្យចូលមកវិញ ។ ស៊ុនខៀនកិលាខៀវឡូវចេញទៅអាស្រ័យទៅផ្ទះអៀវសុង ប្រាប់ថានឹងចាំស្តាប់សេចក្តីដែលម៉ាឈៀវនឹងត្រឡប់មកវិញឬទេ ។

ចំរើសេះដែលទៅហៅម៉ាឈៀវនោះ ត្រឡប់មកប្តឹងខៀវឡូវិញថា ម៉ាឈៀវឲ្យដំរាបលោកថា នឹងសុំធ្វើការសន្ធ្រាមឲ្យបានសេចក្តីតាប់ប្រសើរសិន ទើបនឹងលើកកងទ័ពត្រឡប់វិលវិញ ។ ខៀវឡូកំប្រើចំរើសេះ ឲ្យទៅហៅម៉ាឈៀវម្តងទៀត ដល់ ២ គ្រា ៣ គ្រា ម៉ាឈៀវកំនៅតែនិយាយដដែល ។ អៀវសុងដឹងសេចក្តីដូច្នោះ កំចូលទៅដំរាបខៀវឡូថា ឯចិត្តម៉ាឈៀវនោះជាមនុស្សអកតញ្ញូអាក្រក់ណាស់ ដែលលោកឲ្យទៅហៅខ្លួនមិនព្រមចូលមកតាមប្រសាសន៍នោះ ខ្ញុំថាឃើញថា ម៉ាឈៀវនឹងប្រែចិត្តចេញពីលោកជាប្រាកដហើយ គួរឲ្យលោកប្រុងប្រយ័ត្នខ្លួនឲ្យមួនម៉ា ហើយអៀវសុងកំលាត្រឡប់មកវិញ ទើបប្រាប់មនុស្សខំនុកពុកចិត្តឲ្យចេញទៅលបស្តាប់ដំណឹង ហើយឲ្យនិយាយប្រាប់អ្នកស្រុកទាំងពួងថា ម៉ាឈៀវនោះប្រែចិត្តចេញពីខៀវឡូហើយ ។ តំពូងគិតនឹងទៅកាយយកស្រុកហ៊ូគោ ប្រាប់ថានឹងសងសឹកចូរដែលសម្លាប់ម៉ាថេងជាបិតា នោះកិត្តិសព្ទនេះ ក៏រន្ធឺឮទៅដល់ខៀវឡូ ។ ក៏មិនដឹងកល់ឧបាយអៀវសុង ប្រុងតែគិតថា ម៉ាឈៀវកាយបានស្រុកសែឈួនហើយ កិនឹង

លើកមកវាយយកស្រុកហ៊ានគុងម្ដងទៀត ខៀវឡុកឱ្យហៅប្អូនអៀវសុង
ចូលទៅនិយាយថា ដែលយើងឱ្យហៅប្អូនម៉ាឈៀវមិនព្រមត្រឡប់នោះ
អាណាប្រជាទុក្ខស្ដុកស្ដម្ភឡើងខ្ទើអស់ហើយ អ្នកនឹងគិតយល់ប្រការម្ដេច ។
អៀវសុងថា ម៉ាឈៀវមិនព្រមមកនេះ ត្រូវលោកឱ្យមានសំបុត្រ
ទៅកាត់ទោសម៉ាឈៀវទុកជាសេចក្ដីរឹងទទឹង ត្រូវធ្វើការបាន ៣ ១:១
មួយឱ្យម៉ាឈៀវទំនើការឲ្យកងទ័ពឡៅតីបែកឱ្យខាងតែបាន ១ពីរ
ឱ្យម៉ាឈៀវទំលើកទៅវាយស្រុកសែឈួនឱ្យខាងតែបាន ១បី ទោះបើថា
ឡៅជៀងតុងបញ្ជូនតីស្រុក ក៏ឱ្យម៉ាឈៀវទំដេញតាមចាប់សម្លាប់ចេញ
ហើយកាត់ក្បាលបញ្ជូនមកឱ្យយើង ។ សេចក្ដីខាង ៣ ១ នេះ បើម៉ា
ឈៀវធ្វើបានក៏នឹងឱ្យបំណាច់ភ្លើងឱ្យដល់ខ្លួន បើខ្លះតែ១ឯណាមួយ
ត្រូវយកទោសប្រហារជីវិត ហើយឱ្យខៀវអួយជាប្អូនលោកនឹងមានទៅ
តាំងស្ដាត់ទ័ពឱ្យត្រង់កន្ទែងតយខាង ៤ អន្ទឹ ខ្លាចក្រែងម៉ាឈៀវនឹង
មានចិត្តរឹង លើកទ័ពត្រឡប់មកវាយយកស្រុកយើងវិញ កងទ័ពខាង
អស់នេះ ក៏នឹងបានជួយគ្នាការពារតែខាងក្រៅ ។ ខៀវឡុកឃើញត្រូវ
ផង ក៏ចាត់ចែងតាមានលើកទៅតាំងទៅទីតយខាង ៤ ដំបន់ ហើយ
សំបុត្រកាត់ទោសឱ្យចំរើសេះគាន់យកទៅឱ្យម៉ាឈៀវ សេចក្ដីដូចអៀវ
សុងនិយាយនោះ ។

ឯម៉ាឈៀវ លុះឃើញសំបុត្រដូច្នោះហើយ ក៏ប្រឹក្សានឹងម៉ាតាយថា

ប្អូនថា ខៀវឡៃនឹងយើងមិនលើកកងទ័ពត្រឡប់ទៅវិញតាមសេចក្តី
ដើម ជាន់ជាកាត់ទោស ទុកឲ្យយើងធ្វើការឲ្យជានត្រចំពាំង ៣ ខនេះឲ្យ
រហូត បើមិនសម្រេចនឹងយកទោសយើងដល់ស្លាប់ ឯការពាំង ៣ ខនេះ
យើងនឹងធ្វើទៅរហូតឬ ។ ត្រូវតែគិតលើកទ័ពត្រឡប់ទៅស្រុកហ៊ានគុង
វិញតាមពាក្យខៀវឡៃទើបនឹងរួចខ្លួន មាំតាយយល់ឃើញត្រូវផង មាំ-
ឈៀនឹងលើកទ័ពត្រឡប់វិលវិញ ។

អៀវសុង លុះដឹងថា មាំឈៀនឹងលើកទ័ពត្រឡប់វិលដូច្នោះ គិតឥតមនុស្ស
ឲ្យដើរទៅបរិហារនិយាយប្រាប់អ្នកស្រុកពាំងពួនថា ឥឡូវមាំឈៀតែត
នឹងលើកទៅវាយយកស្រុកហ៊ានគុនហើយ ឥឡូវខៀវឡៃឲ្យគេណ្តាមហាន
ទៅតាំងស្នាក់ទ័ពថែមទៀត ពាំងពាស់ពាំងថ្មី ៨ អន្លើ ហើយបង្គាប់កំជាប់
ពាហានថា កុំឲ្យពាហានមាំឈៀវឆ្លងឆ្លងចូលបាន ។ ឯមាំឈៀ
នោះ លុះលើកទ័ពត្រឡប់មកវិញ ឃើញពាហានខៀវឡៃលើកទៅស្នាក់
គ្រប់តយតាមផ្លូវ នឹងចូលទៅក្នុងស្រុកក៏មិនបាន នឹងថយត្រឡប់មក
ក្រោយក៏ក្រែងខៀវឡៃ តែតែមានសេចក្តីសង្ស័យខ្លាំងទៅទៀត មាំឈៀ
មិនដឹងគិតប្រការម្តេច ក៏មានសេចក្តីបរិតូកកើតទុក្ខខ្លាំងណាស់ ។

ខុងបេងដឹងថា មាំឈៀវជាទុក្ខពេមនស្សដូច្នោះ ក៏មានចិត្តក្រែង
អាណាស់ ទើបនិយាយនឹងឡៅតីថា ឥឡូវមាំឈៀវនឹងចូលទៅគេខៀវ
ឡៃក៏មិនបាន នឹងថយត្រឡប់មកវិញក៏ជាអ្ន ខ្លាចក្រែងខៀវឡៃសង្ស័យ

ម៉ាឈៀតែអស់សេចក្តីគិតទៅហើយ ខ្ញុំនឹងសុំអាសាទៅនិយាយបញ្ចុះ
បញ្ចូលម៉ាឈៀ ឲ្យចូលទៅជាមួយនឹងលោកឲ្យបាន ។ ឡៅ
តឹតបថា ខ្លួនលោកឧបមាដូចជួងចិត្តរបស់ខ្ញុំ ដែលលោកនឹងទៅបញ្ចុះ
បញ្ចូលម៉ាឈៀនោះ ទាំងនឹងមានសេចក្តីអន្ទះអន្ទែងអ្វីក៏មិនដឹងឡើយ ឯ
ខ្ញុំនឹងមានសេចក្តីព្រួយណាស់ ។ ខណៈកាលឡៅតឹនឹងខុងបេនិយាយ
គ្នានោះ ខ្លួលមានបំរើសេះកាន់សំបុត្រជូនឡៅប្តីឯមកថា លីអ៊ុនពួកស្រុក
សៃឈួនស្គាល់កប់អានគ្នាតាំដើម ឥឡូវមានចិត្តស្មគ្រចូលមកទៅធ្វើការជា
មួយនឹងលោក ខ្ញុំបានកំខ្លួលខ្លួនឲ្យទៅជាមួយនឹងខ្ញុំបានទៅហើយ ឡៅ
តាយើញសេចក្តីសំបុត្រជូនោះក៏មានអំណរណាស់ ទើបឲ្យទៅហៅយកខ្លួន
លីអ៊ុនឲ្យចូលមក ហើយសួរថា កាលឡៅជឿនឹងឲ្យខ្លួលយើងចូលទៅ
ប្រឹក្សាការសង្គ្រាមដងនោះ ខ្លួនអ្នកបានហាមឃាត់ឡៅជឿន មិនឲ្យខ
ខ្លួលយើងចូលទៅ ឥឡូវបែរចិត្តចេញពីឡៅជឿន ស្មគ្រមកទៅនឹងយើង
វិញនោះ ដោយឃើញហេតុប្រការអ្វី ? ។

លីអ៊ុនឆ្លើយថា ពាក្យបុរាណពោលទុកថា ធម្មតាសត្វបក្សីបក្ស
បើនឹងធ្វើសំបុកអាស្រ័យទៅលើដើមឈើណា គឺត្រូវឲ្យមើលមែកសន្ធឹក
ដែលមានមូលដ្ឋានមាំល្អ សឹមឲ្យសំណាក់ទៅ ទើបបានសុខនិរទុក្ខចាកភយ-
ន្តរាយទាំងពួង ឥឡូវកើតមកជាមនុស្សប្រុស គឺត្រូវពិគ្រោះមើលនាយ
ទៅហ្វាយដែលមានចិត្តអធ្យាស្រ័យល្អសុចរិតប្រាកដ ទើបលោកឲ្យចូល

នៅផង ដើម្បីនឹងជួយឲ្យបានសេចក្តីសុខតទៅ ដូចខ្លួនខ្ញុំបានជាជាវិញ្ញូលមានជាយក្រហមរបស់នាយចៅហ្វាយហើយ ដូចជាឡៅដៀនគេតំ មានគុណូបការៈលើខ្លួនខ្ញុំបាទ ខ្ញុំបាទក៏ត្រូវជួយរំលឹកឃាត់ហាមតាមសតិបញ្ញាដោយសេចក្តីគតញ្ញូ លុះឡៅដៀនមិនត្រមស្តាប់តាមពាក្យខ្ញុំបាទហើយ ខ្ញុំបាទក៏បានសេចក្តីតូចចិត្តគិតអៀនខ្មាសនៅដែរ បើនឹងមិនប្រែចិត្តគិតសារជាថ្មី ទំនៃនៅតែនឹងមានទុក្ខភ័យដល់ខ្លួន បានជាខ្ញុំបាទបួលមកជ្រកកោននៅនឹងលោកវិញដូច្នេះ ព្រោះបានឮគេរ៉ែរឈ្មោះពីរោះពិសាថា លោកមានចិត្តមេត្តាករុណាដោយសត្យពិតត្រង់ល្អណាស់ សូម្បីមនុស្សទាំងក្មេងចាស់ក្នុងស្រុកសែលួន តែងស្រឡាញ់លោកជាច្រើនការទាំងឮដែលលោកចំណាងនឹងធ្វើតែងចំរើនដូចប្រាថ្នាជាប្រាកដ។

ឡៅពីសួរថា ដែលអ្នកតាំងចិត្តមកនៅធ្វើការកសិការនឹងយើងនេះ អ្នកនឹងជួយរិះគិតធ្វើការប្រការម្តេចខ្លះ ? ដើម្បីឲ្យបានជាប្រយោជន៍ដូចប្រាថ្នានោះ ។ លីអុនថា ឥឡូវនេះកិត្តិសព្ទថា មាំឈៀនឹងចង់បួលទៅរកខៀវឡៃវិញក៏ពុំបាន នឹងថយត្រឡប់មកក្រោយក៏ឲ្យបាម្តងភ្លាម ទើបមិនអាចនឹងរិះគិតយ៉ាងណា ដូចជាគាល់ប្រាជ្ញាទៅហើយ ឯមាំឈៀនោះនឹងខ្ញុំបាទ កំឡាចក់ចង់អាន បានស្គាល់ចិត្តគ្នាមកយូរហើយ ខ្ញុំបាទនឹងចង់សុំយកអាសាចេញទៅបញ្ចុះបញ្ចូលមាំឈៀនឲ្យប្រែចិត្ត គិតមកនៅធ្វើកសិការនឹងលោកឲ្យគាល់តែបាន ។ ខុងជេងថា យើងក៏ទំរកតែអ្នក

ឯណា ដែលមានសត្វបញ្ញើនឯទៅនិយាយបញ្ចុះបញ្ចូលម៉ាឈៀវជាយូរ ថ្ងៃមកហើយ មិនទាន់ចាន បើអ្នកអាចហ៊ានខ្ជួលធ្វើដូច្នេះ គឺជាការប្រពៃណាស់ ចូរទុំប្រើឯតែទៅទៅនិយាយឲ្យចានការចុះ ទើបនឹងចានសេចក្តីតាមប្រសើរតទៅ ។

លីអ៊ុនខ្ជួលពាក្យនឹងខ្លួនបេងខ្លាតហើយ គឺស្រួតចេញទៅ ដល់កងទ័ពម៉ាឈៀវ គឺប្តាប់ពួកទាហានយាមថា ខ្ញុំឈ្មោះលីអ៊ុននឹងសុំចូលទៅរកម៉ាឈៀវ ។ ទាហានក៏ចូលទៅដំណឹងការតាមដំណើរនេះ ។ ម៉ាឈៀវដឹងដូច្នោះទើបថា ឯលីអ៊ុនោះ ជាមនុស្សពូកែខាងសំដីណាស់ ការដែលមកនេះ មានប្រាថ្នានឹងមកបញ្ចុះបញ្ចូលយើងហើយ ទើបរៀបទាហានឲ្យមានកាន់សាស្ត្រាវុធត្រប់ដៃចំនួន ២០ នាក់ ហើយគិតថ្លាប់ថា បើលីអ៊ុនចូលមកនិយាយការនឹងយើង បើឮយើងថាឲ្យចុះដៃវេលាណា ឲ្យអ្នកកាល់គ្នាចូលព្រួតចាប់លីអ៊ុនសម្លាប់ចោលទៅចុះ ហើយតាប់ចិត្តាំសាច់ឲ្យល្អិត លុះបង្គាប់ការរួចហើយ គឺប្រើទាហានឲ្យចេញទៅហៅលីអ៊ុនចូលមក ។

ម៉ាឈៀវគឺសួរលីអ៊ុនដោយសម្លេងគំហកយ៉ាងខ្លាំងថា ខ្ញុំនមកពីណាយើងវេលានេះ ដោយត្រូវការអ្វី ? ។ លីអ៊ុនឆ្លើយថា យើងមកនេះដើម្បីមកបញ្ចុះបញ្ចូល ម៉ាឈៀវ ។ អ្នកនឹងបញ្ចុះបញ្ចូលប្រការម្តេច ត្រូវថាទៅឲ្យល្អចុះ ព្រោះក្រចើដែលយើងកាន់នេះ ទើបនឹងសំលៀងថ្មី ប៉ើថា

មិនត្រូវចិត្តយើង ។ ទីឯយកក្រប៉ាំនេះល្បងក្បាលអ្នកលមើល ។

លំអុនឮដូច្នោះ ក៏អស់សំណើចហើយថា វេលានេះយើងដឹងច្បាស់ជាកំឃនឹងមកដល់អ្នកហើយ ប្រាជ្ញាយើងមកការពារឲ្យផុតអំពីកំឃនោះ ម្តេចអ្នកត្រឡប់ថាយកក្រប៉ាំល្បងក្បាលយើងវិញដូច្នេះ ឯក្រប៉ារបស់អ្នកនោះ បើខុសជាខើបទឹងសំលៀងថ្ម កំមិនតប្បីទឹងសម្រាប់កាប់ក្បាលយើងបានទេ ថប់តែអ្នកជាខែទឹងតែកាប់ក្បាលអ្នកវិញទេដឹង ។ មាំឈ្មៀវសួរថា អ្នកឯងដឹងថា នរណាទឹងប្រាថ្នាកាប់ក្បាលយើងនោះ ។ លំអុនតបថា ធម្មតាស្រីរូបល្អ តោះប៉ាទឹងយកគ្រឿងអំពាវដែលខុតូលកាតមកបំពាក់ ក៏មិនមែនធ្វើឲ្យរូបនោះអបលក្សណ៍ទៅវិញបាន បើស្រីនោះមានរូបកាយអាក្រក់សាមាន្យ សូម្បីទឹងយកគ្រឿងប្រដាប់ដ៏ល្អកំផាន់មកបំពាក់យ៉ាំងណា រូបកាយដែលអាក្រក់ក៏នៅជាអាក្រក់តាមធម្មតាពាំងអស់ពុំនោះដូចដួងព្រះអាទិត្យ បើដល់កំណត់ដើរត្រង់ណា រស្មីក៏ភ្លៅបរិភ្លាខ្លាំងណាស់ ឬដូចដួងព្រះចន្ទ ដែលរឿងរះស្រឡះពពកក្នុងវេលាថ្ងៃពេញបូណ៌មី ក៏មានរស្មីភ្លឺស្វាងរុងរឿងជ្រះថ្លា បើដល់ទៅរនោចកាលណា ក៏តែងអាប់មន់ពន្លឺអស់ទៅតាមធម្មតាលោកដូច្នោះ ដូចយ៉ាងខ្លួនអ្នកនៅកំពុងពេញពាល ដូចព្រះចន្ទពេញបូណ៌មី ឬដូចព្រះអាទិត្យកំពុងថ្ងៃត្រង់ ត្រមាំឯងរូបអង្គខ្ទង់ខ្ទាយតណ្ហាយល្អ សមគួរជាទាហានឯកក្នុងផែនដី តប្បីទឹងរិះគិតធ្វើសឹកសង្គ្រាមតាមដែលមានមកពីអតីត ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន

លោក ដេង - ទ្រីវ ប្រែរៀបរៀង

(១)

៨៣- មាន់ព្រៃយកស្លាបក្អែកមកពាក់

មានក្អែកមួយជម្រុះស្លាប មាន់ព្រៃរើសយកស្លាបនោះមកបំពាក់អាត្មា រួចដើរគាប់កន្ទក់យ៉ាងសង្ហា នៅបណ្តាពួកក្អែកដទៃ ដោយនឹកស្មានថាខ្លួនជាតួមួយដ៏ប្រពៃដែរ ។

(ជាអកុសល) ស្រាប់តែមានក្អែកមួយស្គាល់ឮៗស់ : ម្ល៉ោះហើយមាន់ព្រៃបានត្រូវទទួលការស្តីបន្ទោស ឱនការពេបជ្រាយរ៉ែនន់ត្រប់បែបយ៉ាង ហើយត្រូវពួកក្អែកចាប់ចោចកន្ត្រាក់យកស្លាបចេញយ៉ាងខ្លាំង ។ មាន់ព្រៃត្រូវគេបណ្តេញចេញ ហើយសូម្បីមាន់ព្រៃដូចគ្នា ក៏ឈប់លែងឲ្យចូលជិតជាមួយ ។

(សព្វថ្ងៃ)មានមាន់ព្រៃរបៀបដូចមាន់ព្រៃខាងលើច្រើនអនេក ដែលនិយមយកជាញឹកញាយខ្លះកំអែលអ្នកដទៃ មកតាក់តែងលំអអាត្មា ហើយដែលគេឲ្យឈ្មោះថា បោរធិពន្ធ

ចំពោះរឿងនេះ ខ្ញុំនៅស្ងៀម ខ្ញុំមិនប្រាថ្នាធ្វើឲ្យរំខានដល់អ្នកខាងនោះឡើយ ព្រោះរឿងនោះមិនមែនជាកិច្ចការរបស់ខ្ញុំ ។

១-ពាក្យបារាំងថា (geai) ជាសត្វសត្តានបាប ខ្ញុំយល់ឃើញថា បាបនឹងក្អែកមានទំហំខុសគ្នាឆ្ងាយ បានជាខ្ញុំយកមាន់ព្រៃមកជាក់ជំនួស ដើម្បីឲ្យមានទំហំស្រដៀងគ្នាបន្តិច ។

៨៤- សត្វកង្រែងនឹងរូបបដិមា

អ្នកធំភាគច្រើន សុទ្ធសឹងជាមុខពាក់របស់ស្មោន អាការខាងក្រៅ
របស់អ្នកធំ តែងធ្វើឲ្យមនុស្សសាមញ្ញជាអ្នកគោរពកោតខ្លាចខ្លួន ។

សត្វសាចេះវិនិច្ឆ័យមនុស្សតែតាមអាការ ដែលកវាយឃើញនឹងក្អែក
ផ្ទុយទៅវិញ សត្វកង្រែងពិនិត្យមើលមនុស្សដល់ខាងក្នុង គិចាពិនិត្យចុះ
ឡើងគ្រប់សព្វ ហើយភាលណាវាយល់ច្បាស់ថា រូបអ្នកធំនោះ គ្រាន់
តែជាអាការខាងក្រៅ វាតែងប្រើពាក្យមួយ ចំពោះរូបនោះ ដូចជារូបបដិមា
អ្នកហាវហានម្នាក់ ធ្វើឲ្យវានិយាយដូចតទៅ ៖

គឺជារូបបដិមាមួយប្រហោងក្នុង តែខំហ៊ានជាងធម្មតា ។

សត្វកង្រែង លុះសរសើរការខំព្យាយាម កន្ត័រចម្ងាត់រួចហើយ
ទើបពោលថា : »ក្បាលនេះល្អពិត តែឥតមានខួរសោះ » ។

ចំពោះចំណុចនេះមានស្តេចគ្រាញ់ធំៗជាច្រើនដែលសុទ្ធសឹងជារូបបដិមា ។

៨៥- បបក ម្ចាស់នឹងក្អួន

គ្រួសារមួយសង់ផ្ទះជាប់ភ្នាយពីគេ ។ បបកមួយឃើញស្រួល ទើប
មកចាំនៅក្បែរទ្វារ រាសន៍រឹមថា មុខជានឹងបានជួបសត្វជាចំណីគ្រប់យ៉ាង
មិនខាន ដូចក្អួនគោនៅចុងដោះ ក្អួនចៀម ពពែ ហ្នឹងមានជាំនដុង (១)រួម
សេចក្តី គឺអាហារគ្រប់មុខ ។ ក៏ប៉ុន្តែ (ដោយវានិចាំយូរ) អាចារខ្លួចកើត

១- ខ្មែរនិយមហៅជាំងដុង (Dindon) ថា មាន់ជាំង ។

អង្គុយក្បែរភ្លើង ហើយក្មេងឃំ : ម្តាយស្រែកស្តីបន្ទោសទឹងគម្រាមឲ្យថា បើមិនចាត់យំទឹងឲ្យវាទៅចចកស៊ី ។ ចចកកំប្រុងខ្លួនចាំខ្លួល ដោយអត្តុណាដល់ខ្លាអំពីកសានេះ ។ លុះម្តាយដែលចង់លួងកូនខ្លួនឲ្យស្ងៀម ទើបនិយាយទឹងកូនថា : កូនឯងកុំស្រែកឲ្យសោះ ប្រសិនបើវាមក យើងទឹងសម្លាប់វាឥឡូវ ។

ចចកស្រែកថា ចុះហេតុម្តេចក៏អ៊ីចឹង ? ម្តងថាឯងចេះ ម្តងថាឯងចុះ ! តើគេតែងតែនិយមមើលជាយញ្ជក អញដូច្នេះឬ ? គេខុកអញជាឆ្កួត ឬ ? ចាំមើលថ្ងៃណាមួយ ឲ្យតែអាតូចប្រមាត់ហ្នឹងទៅក្នុងព្រៃរកបេះផ្លែណាវ៉ែត (Noisette) !

ឃាត់ឮសំដីដូច្នោះ គេស្ទុះចេញមកពីក្នុងផ្ទះភ្លាម : ខ្ចែវត់ស្អុក ដំបងនឹងប្លុកតួយវឹងញ៉ាំងទៅលើចចក ។

គេសួរចចកថា ឯងមករកអ្វីកន្លែងនេះ ?

ចចកកំនិយាយរឿងច្រាប់សព្វគ្រប់ ។ នាងម្តាយពោលថា : ខ្ញុំព្រះអើយ តើអញមានបំណងបំពេញក្រពះឯងដោយកូនអញក្នុងថ្ងៃណាមួយឬ ? ។

រួចគេសម្លាប់ចចកនោះទៅ ។ អ្នកស្រុកម្នាក់កាប់ដើងស្តាំនឹងក្បាលចចក ហើយពាក្យអួសចោះចោលទៅ ទើបគេចាំតែជាពាក្យស្មោកខុកនៅស្បែកគូមិថា ។ លោកចចកអើយ ចូរកុំស្តាប់ម្តាយដេរកូនយំ ។

(នៅមានត)

១១ – រឿងក្អែកត្រូវទោស

11e - le Corbeau puni

រឿងព្រេងចិន

ដោយលោក ភ៉ាយ-ស៊ុកគ

ក្រោយដែលផែនដីស្ងាបនារួចហើយ ទើបគេបង្កើតឲ្យមានរដូវ ចាំងបួន គឺ: ខែងាយរដូវ រសៀនរដូវ សរទរដូវ នឹង សិសិរដូវ ក្រោយដែលស្ងាបនា រដូវចាំងបួនរួចហើយ មានបុប្ផាត្រប់យ៉ាង ធញ្ញជាតិជុះ ផលានុផលមានគ្រប់មុខ ។ គឺដីរកាពសត្វ មនុស្សលោក ក៏ចាប្រព្រឹត្តទៅដោយស្រួល ។ តែគេចនឹងបានសុខស្រួលជាងនេះទៅទៀត ។ ព្រោះហេតុដូចនេះ បានជាគេធ្វើនំមួយ ដោយប្រមូលផ្សំគ្រោមគោមេតម័យ (Buerre) ទឹកដោះគោ ទឹកឃ្មុំ មៀល ហើយគេបានយកនំនោះ ទៅឲ្យក្អែក សូមឲ្យក្អែកយកទៅថ្វាយព្រះអាទិទេពមហាមេឃ សូមឲ្យព្រះអង្គទ្រង់ព្រះពរជាន នូវសំណូមពរប្រាំប្រការគឺ:

ពរទី ១ សុំព្រះអង្គមេត្តាបន្ថា រដូវចាំងបួន ទៅជារដូវមួយ គឺខែងាយរដូវ ព្រោះរដូវនេះអាចធ្វើឲ្យសត្វលោកមានវិញ្ញូនភាព សម្បូណ៌ភាពព្រមទាំងរាងកាមនុស្ស មិនសូវឲ្យមានរោគ ដូចរដូវក្តៅណាស់ ត្រជាក់ណាស់នោះឡើយ ។

ពរទីពីរ សុំឲ្យធញ្ញជាតិចាំងឡាយ ព្រោះសាបតែម្តងជាការស្រួច

ហើយផ្ទៃ ផ្កា ពស់ផ្ចាំ មកប្រតកាត់រៀងពស់ផ្ចាំតទៅ ដើម្បីចៀសវាងកុំឲ្យមនុស្សខឿយលំបាក ទំនឹក ភ្ញាក់តទៅទៀត ។

ពរទី៥ : សុំកុំឲ្យមានគង្គាភ័យ ភយោឫសង្ឃភ័យ ព្រលឹងភ្ញាក់ នាំឲ្យមនុស្សវៃឱសក្នុងសម្បត្តិ ផ្ទះសំបែង ។ ល ។

ពរទី៦ : សុំឲ្យមនុស្សចាំងឡាយនៅលើផែនដី ឲ្យមានសមភាព កុំបីមានយោបល់ផ្សេងគ្នា រវាងអ្នកមានអ្នកក្រ អ្នកក្រមិនអាចឲ្យអ្នកមានជិះជាន់បានឥតគ្រាប្រណី ។

ពរទី៧ : ទៅតង់ពិភពលោក កុំឲ្យមានការបែកបាក់គ្នារវាងមនុស្ស កុំឲ្យមានមន្ត្រី មានពស្ត្រ ជាហេតុ កុំឲ្យមន្ត្រីធ្វើបាបពស្ត្របាន។

ក្រោយដែលបានស្តាប់សេចក្តីសព្វគ្រប់ហើយ ក្អែកកំហើរទៅលើនភាពល័យ យកនំនោះ ទៅថ្វាយព្រះអាទិទេព ហើយសូមពរប្រាំប្រការវាងវៃ ។ ព្រះអាទិទេពទ្រង់ព្រះតម្រិះថា សំណូមពរនេះមានសភាពបរិសុទ្ធល្អ ក៏ទ្រង់ព្រមអនុញ្ញាតសំណូមពរនេះ បានសម្រេចទៅតាមសេចក្តីប៉ងប៉ិនរបស់ក្អែកលោក តែព្រះអាទិទេពទ្រង់បានដាក់កំហិតដល់ក្អែកថា :

ចំអ្នកក្អែក	អ្នកយកពរ	ប្រាំប្រការ
ទៅឲ្យសត្វ	ជាតិសង្ហារ	មនុស្សលោក
ឯងត្រូវហើរ	តម្រង់ចំ	កបដ័យដោត

ឯងទៅដល់ ផុតភ័យពេត យកសុខសាន្ត ។
រួចឯងថា ពារមួយម្ដង កថសម្រេច
ថាច្រាំជង ទើបធុតកិច្ច ឲ្យចាំបាន
តែកុំអួត ឈប់ខំណា រំហើយច្រណា
រួចកុំពោល ពាក្យរើងថ្ពាន ខកខានអើយ ។

ក្អែកខ្លួលព្រះពាជនុង្ការព្រះអាទិទេព កំហើរវិលត្រឡប់មកវិញ តែក្នុងចិត្តគិតមមៃថា «អញជាបក្សីវិសេសវិសាលជាងបក្សាទាំងឡាយ អញបានបំពេញបេសកកម្ម ដ៏ប្រសើរថ្លៃថ្លាឲ្យមនុស្សជាតិ នេះជាបេសកកម្មថ្លៃកអស្ចារ្យ គ្មានអ្នកណាធ្វើបានដូចអញ! អញជាបក្សាគួរឲ្យស្ងប់ស្ងែងពន់ពេក!» ។

ក្អែកនោះ កំពុងតំលើផ្នាំងថ្ពន់សំមួយ ដែលខ្លួនធ្លាប់តំសម្រាកពីដើមរៀងពាយដកាយមក ។ ក្អែកឆើយក្បាលហើយខះស្ងាប ដើម្បីបង្ហាញនូវអាកប្បកិរិយាទឿយហាត់កន្ងែបេសកកម្មនោះ ។

ផ្នាំងថ្ពន់សំនោះ គឺសំដែងតាវគាពចំពោះក្អែក ហើយពោលពាក្យថា : «ខុសំឡាញ់ក្អែកអើយ ក្អែកឯងបានបរិភោគអាហារដែលលាបខ្លាញ់ប៊ើរ (Beurre) ដែលជាអាហារទិព្យ ដែលជាព្រះអំណាយដ៏ថ្លៃថ្លានៃព្រះដ៏វាតុទ្ធ (Boudha Vivant) ឬ? បើមិនដូច្នោះ ម្ដេចក៏បងក្អែកឯងមានសាខរភាពអ្វីខ្លាំងម្ល៉ះ! ។

ក្អែកមិនតបទៅនឹងផ្កាំងថ្ពស់ឡើយ ព្រោះបានទឹកយើញព្រះ-បណ្តាំនៃព្រះអាទិទេព ថាកុំឲ្យពោលពាក្យអ្វីឲ្យសោះ!

ហើយផ្កាំងថ្ពស់ក៏ថ្លែងទំ ។ ថា:

ទុំឲ្យាញ់! ឯងដូចជាមានសាទរភាពភ្ញាំងក្នុងស្មារ្យណាស់! អ្នកឯងមិនចង់ស្តី ខ្ញុំយយ នឹងខ្ញុំផង! អ្នកឯងយល់ថាខ្ញុំជាបុគ្គលថោកថយ មិនសមនឹងអ្នកជាធំ មកមានការប្រាស្រ័យគ្នាឬ! អ្នកឯងមើលមកខ្ញុំគ្មានសំលៀកបំពាក់ គ្មានគេហដ្ឋានស្រែក បានជាអ្នកឯងហ៊ានប្រមាថមើលងាយខ្ញុំ!

ក្អែកឮបន្ទាត់មិនបាន ឈឺចិត្តភ្ញាំងណាស់ ហើយពោលថា:

«ទុំឲ្យាញ់ផ្កាំងសិលាថ្ពស់អើយ! អ្នកឯងប្រហែលជាវង្វាហើយដោយអ្នកនៅអាស្រាតកណ្តាលព្រៃពាយព្រះពិរុណដូច្នេះ ។ តើអ្នកឯងស្ថិតនៅក្នុងផ្លូវវង្វាយ៉ាងណាបាន!» ក្អែកកំឆ័ត់ក្បាល តិតបន្តិចតំពោលថា:

«ខ្ញុំបានយកសំណូមពរនៃព្រះអាទិទេពជាប់មកជាមួយនឹងខ្ញុំ ។ បងផ្កាំងសិលាថ្ពស់នេះឯងដែលត្រូវបានជាលើកដំបូងនូវសំណូមពរនេះ តាំងពីថ្ងៃនេះតទៅ កុំឲ្យមានផ្លូវប្លែក ។ គ្នា ។ អ្នកឯងលែងស្គាល់ងាវ លែងជួបប្រទះនឹងក្តៅត្រជាក់ ហើយអ្នកឯងលែងមានពេលាត្បាធិមកបៀតបៀនសោះឡើយ ដូចជាកេតផ្កាសាយ ក្អកជាដើម ។

ក្រោយដែលក្អែកពោលដូច្នេះ ស្រាប់តែសំណូមពរនៃព្រះអាទិទេព

ជាលើកដំបូង គឺបានសម្រេចជាសមិទ្ធិពេញបរិបូណ៌ គឺ: នៅលើផ្ទាំងសិលាខ្ពស់ចាំងឡាយ មានដុះស្មៅមានពណ៌គ្រប់បែបយ៉ាង ពណ៌ក្រហមស្វាយ ប្រផេះ ហើយស្មៅនោះស្ថិតនៅស្រស់បំព្រងជានិច្ចរហូត ។ តាំងពីថ្ងៃនោះមក ផ្ទាំងសិលាខ្ពស់ចាំងនោះ លែងមានក្តៅរងាអ្វីសោះឡើយ គ្មានភេគាព្យាធិទេ ។

ក្អែកដល់បានសម្រេច ខ្លួនសំណូមពរទីមួយហើយ គឺមានចិត្តត្រេកអរខ្លាំងក្លាពន់ពេក ទើបបន្តដំណើរទៅទៀត ។ ក្អែកហើរទៅទំលើមែកវក្ខជាតិមួយដើម ដែលខ្លួនធ្លាប់ទំសម្រាកពីអតីតកាលមក ។ ក្អែកឆើយក្បាលហើយខ្ទេះស្ងាបគឹប ។ បង្ហាញអាកប្បកិរិយាថ្លែកគួរឆ្ងល់ ។

វក្ខជាតិសំដែងខ្លួនវិតារវាត ចំពោះក្អែក ហើយសួរថា:

«បងក្អែក! បងឯងមានបានបរិភោគនូវអាហារ ដ៏ប្រសើរដែលគេហៅថាសម័ម្ភា (Samba) (អាហារនេះមិនដឹងជាធ្វើបែបណា គ្មានន័យនៅទីណាសោះឡើយ ប្រហែលជាពាក្យទំបេតាំង . . .» ឬ?)

ក្អែកឥតឥតបតទៅនឹងវក្ខជាតិសោះឡើយ ។ ក្អែកគ្រាន់តែងក់ក្បាលហើយខ្ទេះស្ងាបតទៅទៀត ។

ហើយវក្ខជាតិក៏ថ្លែងថា: «បងក្អែក យើងភាំងតែនាក់ជាមិត្តភក្តីនឹងគ្នា អ្នកឯងប្រហែលជាមានជ្រាបនូវរឿងពិភពណាមួយមិនខាន ចាំជាមិនពោលមកសោះ ។ អ្នកឯងមើលដាយមិត្តភក្តីដូចខ្ញុំដែលជាអ្នករស់

ទៅដោយលំបាកតែកយ៉ាក

ខ្លែកអត់ទ្រាំពុំបាននឹងរាចារក្កជាតិផ្តោះផ្តងឲ្យ ក៏តបថា :

„ទិមិត្តសំឡាញ់អើយ ! ខ្ញុំនៅតែមានចិត្តស្មោះស្ម័គ្រ ដោយមិត្តភាពចំពោះអ្នក ! អ្នកមានជីវិតតិចតួចស្ងួចស្តើងណាស់ បានជាខ្ញុំមិនដែលឆ្លុះសោះក្នុងមួយថ្នាំ ។ ក្រោយដែលបានឮលដូច្នេះ ខ្លែកក៏នៅស្ងាល់ហើយគិតក្នុងចិត្ត រួចក៏សម្រេចថា :

„ទុបនឹរក្កជាតិ ! ខ្ញុំបានមាឋណ្ដាំព្រះអាទិទេពមកដូនអ្នក ដោយអ្នកមានចិត្តស្មោះស្ម័គ្រនឹងខ្ញុំ ។ តាំងពីបច្ចុប្បន្នកាលនេះទៅ ខ្ញុំសូមឲ្យរក្កជាតិតាំងឡាយដុះ ហើយមានផ្កាផ្លែកល់ធ្នាំកុំឲ្យដាច់ ហើយសូមឲ្យមួយថ្នាំធំបន្តិច ។ រួចយូរ ។ ទៅ អ្នកឯងនឹងមានអាយុវែង គ្រួសារអ្នកឯងនឹងប្រកបដោយសម្បូណ៌ភាព „ ។

ក្រោយដែលខ្លែកឆោលមិនបានផុតពីមាត់ផង បណ្ដាំនៃព្រះអាទិទេព ក៏សម្រេចដូចបំណង ។ តាំងពីនោះមក រក្កជាតិតាំងឡាយ មានជីវិតរស់នៅក្នុងមួយថ្នាំ ។ មានផ្កាផ្លែជានិរន្តរ៍ ។ រក្កជាតិតាំងឡាយ ក៏ដុះតាសតេឡាជ្រោះបព្វត បែកមែកត្រសុំសាខា ក្លាយទៅជាព្រៃក្រាស់ ។

ខ្លែកក្រឡេកទៅឃើញទេសភាពបែបនេះ ក៏មានទម្ងោះសោមនស្សជាយ៉ាងក្រៃពេក ហើយខ្លែកក៏ហើរទៅកាន់មនុស្សជាតិ ដែលរង់ចាំខ្នុនត្រៀបត្រា ។

កាលណាក្អែកទៅដល់ពួកមនុស្សជាតិ ហើយបានត្រឡប់ទៅ
ឃើញក្អែកត្រង់ ។ គ្នា មានសេចក្តីសង្ស័យយ៉ាងម៉ាំ ក្អែកគិតមនោ
រញ្ជួយដោយយល់ឃើញថា បណ្តាំអាទិទេពដែលខ្លួនបានបែកទៅសិលា
ធីងវ៉ុក្តា ជាបណ្តាំមានសារៈសំខាន់ពន់ពេក តែពាក់ព័ន្ធនឹងបុរស
ប្រយោជន៍ ហើយពាក្យដែលមនុស្សជាតិសុំ មិនបានសម្រេចដូចបំណង ។
ហេតុនេះ ក្អែកក៏តតួតកួតពួកមនុស្សជាតិថា :

«ព្រះអាទិទេព មិនព្រមប្រទានពរមកលោកអ្នកទេ ព្រះអង្គទ្រង់
មានព្រះបន្ទូលថា នៅពិភពលោកនេះ មានសេចក្តីសុខស្រួលសប្បាយ
ហើយ » ។

ក្រោយដែលក្អែកពោលដូច្នេះ ពួកមនុស្សជាតិ ក៏មានចិត្តតប់
ប្រម៉ល់ជាយ៉ាងខ្លាំង ហើយក៏សំដែងអាកប្បកិរិយាអស់សង្ឃឹម ហើយ
ស្រែកថា : « បើដូច្នេះហើយ យើងត្រូវតែរស់នៅដោយទុក្ខទោសភ័យ
លំបាកតោកយ៉ាកជាមិនខាន » ។

បន្តិចទៀត ព្រះអាទិទេពបានទឹកទៅដល់ទំដែលពួកមនុស្សជាតិបាន
យកមកថ្វាយព្រះអង្គ ។ ពួកមនុស្សជាតិនោះ បានជ្រាបក្អែកថាឲ្យ
ពន្យល់ព្រះអាទិទេពថា មុនទឹងសោយទូទំនេះ សូមព្រះអង្គទ្រង់យកទំ
នោះទៅចំអឹនទឹងចំហាយក្តៅសិន តែក្អែកនោះភ្លេចសូន្យឈឹង ឥតបាន
ជំពាកព្រះអាទិទេព ។ ព្រះអាទិទេព ព្រះអង្គទ្រង់បានយកទំនោះទៅចំអឹន

ទំនងអណ្តាតភ្លើង ទំនោះក៏រលាយបាត់ ។ ព្រះអាទិទេពទ្រង់ព្រះក្រោធខ្លាំង ហើយមានទេវាចាថា :

..មនុស្សដែលស្ថិតនៅកងជម្ពូទ្វីបជាមនុស្សពុំចូរតែ ។ ខ្ញុំបានឲ្យពរសព្វសាធុការ ចំពោះមនុស្សជាតិ ហើយមនុស្សនេះ វាយកនំដែលបរិភោគមិនកើតមកឲ្យអញ ។ ទំនងដូន្នាះគេសមមនុស្សលោក កុំឲ្យវាមើលងាយអញដល់ថ្នាក់នេះ ។ មានព្រះឧក្កាវដូច្នេះ ទ្រង់ក៏គ្រាស់បង្គាប់ឲ្យទេវតាកូរស្រូវប្រាំ (dieu de cinq Epis) ឲ្យបុះមកជម្ពូទ្វីបយកគ្រាប់ធញ្ញជាតិតាំងអស់ ដែលស្ថិតនៅលើផែនដី ។

ក្នុងពេលនោះ គ្រាន់តែស្រូវសាឡី ផ្លៅ ស្រវឹង សណ្តែកវែង សណ្តែកថ្ពាក់ង ស្ថិតនៅតាំងពីឫសរហូតដល់ចុង ។ រួចទេវតា ដាកទៅបេះគ្រាប់ស្រូវ ដែលស្ថិតនៅខាងចុង ស្រាប់តែបក្សាបក្សីតាំងឡាយចូលទៅក្រាបថ្វាយបង្គំអង្វរទេវតាថា :

បពិត្រទេវតាអើយ! ម្តេចក៏ព្រះអង្គមិនទុកគ្រាប់ធញ្ញជាតិខ្លះឲ្យយើងខ្ញុំតាំងឡាយបានបរិភោគផង ហើយខ្ញុំតាំងឡាយនឹងស្លាប់ដោយសារអត់អាហារ! ។ ទេវតាក៏មានព្រះហឫទ័យសោមនស្សពន់ពេក ក៏ទុកគ្រាប់ស្រូវសាឡីខ្លះទៅខាងចុងដើម ។ រួចបក្សាបក្សីតាំងឡាយ ក៏ថ្វាយតតិមានអំពីក្អែកពុំចូរតែ ។

ព្រះអាទិទេពមហាមេឃ ក៏កោះហៅក្អែកទៅបណ្តាសាថា :

សូម្បីតែមកុកជមកផ្តាច់ជីវិតអាឯង កំមិនសមនឹងកំហុសរបស់អាឯងដែរ ។ កំហុសរបស់អាឯងធំណាស់ ។ អញឲ្យអាឯងរស់នៅលើដើមប៉ុព្លីយ (peuplier) គ្មានស្លឹក ផ្លែ ផ្កាសោះឡើយ ។ នៅខិតយរដូវនឹងវស្សានរដូវ ទើបឯងនឹងរកអាហារបានតែនៅសិសិរដូវ ឯងនឹងគ្មានសំបុកជ្រក ។ កល់យប់ សេចក្តីរងា ដោយភាយោនឹងធ្វើបាកបក់ឯងធ្លាក់មកដីជាមិនខ្លះ ។ នៅមុនបច្ចុសសម័យ ឯងនឹងរងាញ័រចង្កប់នៅលើចុងឈើ ៩ ដង ។ ស្លាបឯងនឹងជ្រុសអស់ ហើយមនុស្សជាតិគេនឹងចុកឯងជាបក្សាលំបាកគោកយ៉ាក

ម្ល៉ោះហើយ តាំងពីនោះមក មនុស្សជាតិរស់នៅដោយខ្លួន ។ ឯងបានចំណែកគ្រាប់ស្រូវឯញ្ញជាតិ ដែលខែតាកូរស្រូវប្រាំ លោកបានចុកឲ្យ ។

តាំងពីថ្ងៃនោះមក គ្រាប់ធញ្ញជាតិតាំងឡើយកំដុះនៅតែខាងចុង លើដើមប៉ុណ្ណោះ ក្អែកគ្មានសំបុកនៅសិសិរដូវ រស់នៅតែលើដើមប៉ុព្លីយគ្មានស្លឹក ផ្កា ផ្លែហើយធ្លាក់មកពីលើចុងឈើ ៩ ដង នៅព្រះអរុណរះបេះតែជ្រុសស្លាប ។

សំបុត្រទីប្រាំបី

ប្រកែកធម្មតាសព្វដែរឬ ? ចាំឆកកើតឆ្មើងខ្លួនម្តេច ?

ឧបាសក ឈឹង អៀម ប្រែពីភាសាអង់គ្លេស

យើងបានដាក់នៅក្នុងសំបុត្រមុនៗ អំពីមនុស្សនៃយុគថ្មីៗ ដែលគ្មានចេះស្តាប់នរណាយ៉ាងច្រើនក្នុងលំនៅចំណែក ។ យើងបានឃើញថាគេមានសេចក្តីចំរើនយ៉ាងខ្លាំងក្នុងផ្លូវជាច្រើន ។ គេបានកែឃើញកសិកម្ម ហើយបានចេះស្វែងរកធ្យូងសម្រាប់ប្រើប្រាស់យ៉ាងជួបមួយផង ។ រឿងចាស់អស់នេះ បានកន្ទុះទៅច្រើនពាន់ឆ្ងាយហើយ ហើយយើងក៏ពុំបានដឹងអ្វីច្រើនអំពីរឿងចាស់នោះដែរ ។ ប៉ុន្តែ តាមស្មាន ភាគច្រើននៃអម្បូរចេះមនុស្ស ដែលមានមោក្ខធម៌តាតលោកសព្វថ្ងៃ បានជាប់តំណមកអំពីប្រជាជននៃយុគថ្មីៗ ។ ដូចកូនដីធ្លាស្រាប់ សព្វថ្ងៃនេះយើងឃើញមានមនុស្សស្បែកស មនុស្សស្បែកលឿង ស្បែកត្នោតដែងខ្មៅស្បែកខ្មៅ ។ ប៉ុន្តែតាមពិត ពិភាកទឹងចែកគ្នាជាអម្បូរចេះមនុស្សជាបួនផ្នែកយ៉ាងនេះ ។ តួជអម្បូរទាំងឡាយបានច្របូកច្របល់គ្នា ហើយពិភាកទឹងនិយាយឲ្យច្បាស់លាស់ថាតួជទាំងនេះជាចេះផ្នែកណា ។ អ្នកវិទ្យាសាស្ត្រពុំសូវសប្បាយមនុស្សទាំងឡាយ ហើយដោយសារហ្នឹងនេះ ដូនតាលោកអាចរកឃើញតួជអម្បូរបាន ។ មានមធ្យោបាយដទៃទៀតដែរ សម្រាប់រកឲ្យឃើញតួជអម្បូរនេះ ។

តើពួជអម្បូរផ្សេង ។ ទាំងនេះ បានកកើតឡើង យ៉ាងម្តេច ? ប៉ើជា ពួជអម្បូរទាំងអស់មានតំណមកពីប្រជាជនតែមួយពួក តើព្រោះហេតុអ្វីគឺ មនុស្សទាំងនោះ ប្លែកគ្នាពីមួយៅមួយទាំងម្ល៉ះ ? កូនដឹងថាជនជាតិ អាល្លឺម៉ង់ ប្លែកអំពីជនស្បែកខ្មៅណាស់ ។ ម្នាក់មានសម្បុរខ្មៅដែង ឯម្នាក់ទៀតសម្បុរខ្មៅ ។ សក់របស់ជនជាតិអាល្លឺម៉ង មានពណ៌ថា ហើយវែង សក់របស់ជនស្បែកខ្មៅខ្លី ហើយក្រញាញ់ ។ ជនជាតិចិន ក៏ប្លែកអំពីជនទាំងពីរនេះដែរ ។ នេះពីឪកនិយាយថា តើការប្លែកគ្នានេះ បានជ្រៀតចូលមកយ៉ាងដូចម្តេច តែថាយើងដឹងខ្លះ នូវបុព្វហេតុនៃការ ផ្លែកគ្នានេះ ។ ឥឪកបាននិយាយប្រាប់កូនហើយថា សត្វទាំងឡាយបាន ផ្ទាស់ប្រែបន្តិចម្តងៗ យ៉ាងដូចម្តេចខ្លះ នៅពេលដែលកអនុលោមខ្លួនក ឲ្យស្របទៅនឹងសភាពទាំងឡាយនៅជុំវិញខ្លួនក ។ ឥឡូវនេះ គឺគេអាច ស្មានបានថាជនជាតិអាល្លឺម៉ង់ នឹងជនស្បែកខ្មៅមានតំណចុះមកពីប្រភេទ ទាំងឡាយ (Types) ផ្សេងគ្នានៃមនុស្ស ប៉ុន្តែពេលពីមុន ជនទាំងនោះ ប្លាស់ជាមានបុព្វបុរសតែមួយ ។ តែថាការផ្សេងគ្នា ត្រូវបានចូលមកតាម ប្រភេទនៃការអនុលោមឲ្យស្របទៅនឹងសភាពទាំងឡាយនៅជុំវិញ ឬក៏អាច និយាយថា មនុស្សពួកខ្លះ ដូចជាសត្វពួកខ្លះដែរ អាចសម្របខ្លួនគេ បានស្រួលជាងមនុស្សពួកដទៃទៀត ។

ដូច្នេះ មនុស្សភ្លាប់រស់នៅក្នុងកូមិភាគទឹកកក ដែលត្រជាក់ខ្លាំង

នៃតំបន់ឆ្ងាយៗទៅខាងជើង អាចបង្កើនខ្យល់កំដៅសម្រាប់ត្រាំទ្រូនឹងត្រជាក់បាន ។ ជនជាតិអេស្គីម៉ូ (Eskimos) សព្វថ្ងៃនេះ ក៏រស់នៅបានក្នុងភូមិភាគនឹកកកនៃតំបន់ខាងជើង ហើយគេអាចត្រាំទ្រូនឹងត្រជាក់យ៉ាងខ្លាំងបាន ។ ប្រហែលជាគេត្រូវស្លាប់ទៅវិញ បើសិនជាកូនខាំគេមកនៅក្នុងប្រទេសក្តៅដូចជាប្រទេសយើង (ឥណ្ឌា) ។ ហើយដោយគេនៅឆ្ងាយជាច់ពីផ្នែកឯទៀតនៃពិភពលោក ទឹងត្រូវរស់នៅក្នុងដំណាក់កាលយ៉ាងតឹងតែង ទើបគេមិនបានចេះដឹងអ្វីច្រើនដូចជាប្រជាជននៅក្នុងផ្នែកឯទៀតនៃពិភពលោកឡើយ ។ ប្រជាជននៅទ្វីបអាហ្វ្រិក ឬ ប្រជាជនដែលរស់នៅក្នុងតំបន់ជិតសុរិយាបថ (Equator) ដែលជាភូមិភាគក្តៅណាស់ រមែងញាប់ខ្លឹងកំដៅនេះបាន ។ ហើយកំដៅយ៉ាងខ្លាំងរបស់ព្រះអាទិត្យ ធ្វើឲ្យគេមានសម្បុរស្បែកក្រមៅ ។ កូនដឹងថា បើកូនទៅហាលថ្ងៃអស់ពេលយ៉ាងយូរ នៅឆ្នេរខ្លះចំមាត់សមុទ្រ ឬ កន្លែងណាមួយ កូននឹងត្រឡប់ជាមានសម្បុរក្រហមលឿងឬលឿងក្រមៅជាងសម្បុរកូនពីមុន ។ ម៉ែប្រសិនជាកូនទៅពីម៉ែអាទិត្យ ក្រោយពីការហាលថ្ងៃមក កូនត្រឡប់ជាមានសម្បុរក្រមៅ តើមនុស្សដែលរស់នៅជានិច្ចជាកាលក្រោមកំដៅថ្ងៃនឹងមានសម្បុរក្រមៅយ៉ាងណាទៅ ? ហើយប្រសិនបើប្រជាជនរស់នៅក្នុងប្រទេសយ៉ាងក្តៅក៏ដោយ តាំងតែពីតាំងកូនតាំងចៅខ្លួនឯងតគ្នាទៅ គេមុខជាក្លាយទៅជាមានសម្បុរក្រមៅឡើង ។ រហូតដល់គេមាន

សម្បូរសែ្បកស្មៅខ្ចៅសុទ្ធ ។ កូនបានឃើញអ្នកស្រុកស្រែចំការជាតិឥណ្ឌៀ ដែលធ្វើការនៅក្នុងស្រែចំការ ក្រោមកំដៅព្រះអាទិត្យ កណ្តាលថ្ងៃត្រង់ ។ គេជាមនុស្សក្រីក្រពេកណាស់ គ្មានសំលៀកបំពាក់ច្រើនទេ មានតែបន្ទះបន្ទួចត្រឹមតែមួយ ។ ភាគកាយខាំងមូលត្រូវនៅហាលថ្ងៃហើយមួយដងវិតវេសតេ ។ រស់នៅរបៀបនេះ ។ គេក៏មានសម្បូរក្រមៅឡើង ។

ដូច្នេះ យើងឃើញជាសម្បូរសែ្បករបស់មនុស្សគឺជាលទ្ធផលនៃអាកាសធាតុដែលគេរស់នៅ ។ សម្បូរសែ្បកពុំមានតាក់ទងអ្វីទៅនឹងគុណសម្បត្តិឬសប្បុរសធម៌ ឬក៏សោភណភាពនៃបុគ្គលឡើយ ។ មនុស្សសែ្បកស រស់នៅឃ្លាតឆ្ងាយក្នុងប្រទេសក្តៅណាមួយ គង់ទំនងជាមានសម្បូរក្រមៅមិនខាន ប្រសិនជាគេមិនលាក់បំពួនអាត្មាអំពីកំដៅថ្ងៃ នៅក្នុងម្លប់ទំនងក្រោមកន្ទាររេ ។ កូនដឹងថា យើងជាអ្នកស្រុកកស្មីរ ហើយជាង ២០០ ឆ្នាំមកហើយ ដីដូនជីតាវេសរបស់យើង ធ្លាន់រស់នៅក្នុងស្រុកកស្មីរ ។ នៅស្រុកកស្មីរ កូនឃើញមនុស្សគ្រប់គ្នា មានសម្បូរសែ្បកតណ្ហាសណ្តែកបាយ ទាំងអ្នកស្រុកស្រែចំការទាំងកសិករ ។ នេះក៏ព្រោះតែអាកាសធាតុនៅស្រុកកស្មីរត្រជាក់ ។ តែថា អ្នកស្រុកកស្មីរនេះឯង ប្រសិនជាចុះទៅតាន់ដំបន់ឯទៀតនៃប្រទេសឥណ្ឌៀ ដែលជាប្រទេសក្តៅជាងមុខជាក្លាយទៅជាមានសម្បូរក្រមៅឡើង ក្រោយពីរបីតំណមក ។ មិត្រ

តគ្គនៅស្រុកកស្ទឹរបេស់យើងជាច្រើន មានសម្បុរសែ្អតពណ៌សំណែក ចាយសុទ្ធសាធ ខ្លះទៀតមានសម្បុរក្រមៅ ។ គ្រួសារអ្នកស្រុកកស្ទឹរណា ចាននៅទៀកូមិកាតនេះ នៃប្រទេសឥណ្ឌៀយូរៅ គ្រួសារនោះ ហាក់ដូចជាមានសម្បុរសែ្អកតែតែក្រមៅខ្លឹង ។

យ៉ាងដូច្នេះ អាកាសជាតុ គឺជាបុព្វហេតុសំខាន់នៃពណ៌ទឹងសម្បុរសែ្អក ។ ពិតមែន គឺអាចមានមនុស្សខ្លះ សូម្បីតែរស់នៅក្នុងប្រទេសត្តៅណាមួយក៏ដោយ តង់មិនធ្វើការនៅកណ្តាលថ្ងៃ ហើយជាមនុស្សមានទ្រព្យគ្រប់គ្រាន់ រស់នៅតែក្នុងផ្ទះយ៉ាងធំ ហើយថែទាំតែខ្លួនប្រាណទឹងសម្បុរសែ្អកបេស់គេ ។ គ្រួសារអ្នកមាន អាចរស់នៅយ៉ាងនេះរាប់តំណ ក៏អាកាសជាតុពុំមានអានុភាពប៉ុន្មានទៅលើគេឡើយ ។ តែថាមិនធ្វើការងារដោយខ្លួនឯង ហើយចាំតែរស់នៅដោយសារការងារអ្នកដទៃ ក៏ពុំមានអ្វីគួរឲ្យខ្លឹងចាន់ឡើយ ។

នៅប្រទេសឥណ្ឌៀ កូនយើញថា ក្នុងភាគខាងដើង ក្នុងស្រុកកស្ទឹរ ទឹងតន្ធាប ប្រជាជន តាមធម្មតា មានសម្បុរពណ៌សំណែកចាយ។ ប៉ុន្តែ ដល់កូនទៅភាគខាងត្បូងវិញ ប្រជាជនទៅជាមានសម្បុរក្រមៅទៅម៉ាដ្រាស ទឹង សីឡង់ ដូចកូនយើញស្រាប់ គេតែតែមានសម្បុរក្រមៅមែនទែន ។ ពិតមែន កូនមុខជានិយាយថា នេះបណ្តាលមកពីអាកាសជាតុ ព្រោះថានៅពេលដែលកូនទៅភាគខាងត្បូង កូន

រឹតតែខ្លាំងជាង សុរិយបថឡើង ហើយអាកាសជាតុរឹតតែក្តៅឡើងដែរ ។ នេះ ពិតជាដូច្នោះមែនហើយ ហើយជាវិចារណញ្ញាណសំខាន់សម្រាប់ការប្លែកគ្នានៃពណ៌កូនកូមិកាតខុសគ្នា នៃប្រទេសឥណ្ឌា ។ ម្យ៉ាងទៀត យើងនឹងឃើញទៅពេលក្រោយថា ការផ្សងគ្នានេះ បណ្តាលមកពីការខុសគ្នាខ្លះ នៃពូជដើមដែលបានមកកាន់ប្រទេសឥណ្ឌា មួយចំណែកដែរ ។ មានពូជអម្បូរជាច្រើន បានមកកាន់ប្រទេសឥណ្ឌាក្នុងសតវត្សរ៍ពាក់ព័ន្ធ ដែលកន្លងទៅហើយ ហើយពេះបីជាគេនឹងរស់នៅដោយឡែកពីគេអស់រយៈពេលយ៉ាងយូរក៏ដោយ គេក៏ពុំគាបគេចឲ្យផុតពីការលាយឡំគ្នាបានដែរ ។ សព្វថ្ងៃនេះ ពិបាកនឹងនិយាយថា ជនជាតិឥណ្ឌាណាម្នាក់ មានដើមកំណើតខាងស្រុង មកពីពូជអម្បូរដើមមួយ ។

> បុគ្គលឥតការសិក្សា មិនត្រូវធ្វើការប្រញាប់ប្រញាល់ទេ ព្រោះការខ្វះខាតការពិចារណាត្រឹមត្រូវ ជាប្រភពនៃសេចក្តីវិនាស ។ ការពិចារណាត្រឹមត្រូវហើយសឹមធ្វើ គឺបុគ្គលត្រូវការចង់ជាន ព្រោះសម្បត្តិគឺសេចក្តីចំរើន បុគ្គលដែលមានគុណសម្បត្តិល្អ ត្រូវបានដោយខ្លួនឯង ។
>
> —ហិតោបទេស

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់ នៃទេមៈជាតិ
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេម:ជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ក.

របាំស្នែងទន្សោង

នៅតាមស្រុកកំពុង ក្នុងព្រះរាជអាណាចក្រ ជាតិសេសកូមិភាគ ដែលស្ថិតនៅត្រើយខាងត្បូងបឹងទន្លេសាប គេឃើញមានសេសសល់របាំប្រជាប្រិយមួយបែប ដែលអ្នកស្រុកសន្មតហៅរត់មាត់ថា « កាំស្នែងទន្សោង » ។ សព្វថ្ងៃយើញមានទៅតាមខែត្រកំពង់ធំជាដើម តំពន់ស្ថិតនៅពោធិសាត់ ។ បានជាឈ្មោះថា « កាំស្នែងទន្សោង » ព្រោះរបៀបកាន់នេះអាស្រ័យដោយស្នែងទន្សោង ទើបមានក្បាច់គ្រាប់តាមកាយវិការរបស់សត្វទន្សោង ។

ដើម្បីនឹងជូនអ្នកអានឱ្យបានយល់ច្បាស់ អំពីរបាំប្រជាប្រិយនេះ យើងសូមធ្វើជាសេចក្តីកត់រៀបរៀងអំពីបន្ទូបជូនតទៅ ៖

១ - អំពីប្រជាប់ប្រជា

ក - គ្រឿងភ្លេង . - ប្រជាប់ដន្ត្រីសំរាប់ប្រគំបរាំនេះមានតិចណាស់ គឺមានតែស្គរ ២កញ្ចា ១ ទឹងគូយ ១ ។

ស្ពៃរ . – ស្ពៃរនេះធ្វើពីឈើធ្នង់ គឺលុងឈើមួយកន្ទុយឲ្យខៅសល់តែសាច់ខាងក្រៅស្តើងល្មម គេតាសស្បែកគោដែលហាលស្ងួតស្ងាប់សាច់តាំងសងខាង ។ អន្ទុងក៏យស្ពៃរនេះ គេយកគល់ព្រួចស្ងួត មកកាត់ល្មម ឲ្យស្រួលកាន់ក៏យ ។

កញ្ជ្រែ . – ដូចកញ្ជ្រែត្រដាវដែរ គឺយកដងឫស្សីប្រវែង ២ ម៉ែត្រមកធ្វើ ហើយខាងចុងមានពត់ចន្ទុះឫស្សីដែលចិតស្តើងជាដងធ្នង់ខ្វែងគ្នា ទំនញ្ជរគ្រាប់អង្គញ់ខៅកណ្តាល សំរាប់បុកឲ្យស្អូរ ។

ភ្លុយ . – ដែលហៅថាភ្លុយនេះ គឺជាប្រដាប់ផ្ទុំជាសូរសំខៀនពិរោះដូចខ្លុយដែរ តែភ្លុយធំជាង ។ គេធ្វើភ្លុយពីសំបកឃ្មោកមួលដោយបង្ខាំភ្លាប់ឫស្សីពីកច្រាំកន់ទំនឃ្មោកនោះ សំរាប់ជាក់អណ្តាតបន្លោញ្យល់ ហើយគេផ្ទុំសំបកឃ្មោក តាមបុងឫស្សីពីកបន្តឲ្យចេញសូរតាមរន្ធទាំង ៥ ដោយយកម្រាមដៃបុចបិទបើករន្ធទាំងនោះ ធ្វើឲ្យមានសព្ទសូរផ្សេក ។ ជាបទបែបឡើង មានសណ្ឋានប្រហែលតែនខៅស្រុកលាវ ។

ឧ – ក្រឿងតែង . – ចំពោះក្រឿងតែងកាយនៃអ្នកប៉ាំនេះវិញ ពុំមានអ្វីជាពិបាកទេ ព្រោះពីដើមគេពុំបាច់តែងខ្លួន គេរស់ក្បាក់តែតាមទំលាប់ខ្មែរអ្នកស្រុកសាមញ្ញខៅតាមជនបទ គឺស្លៀកសំពត់ចងក្បាច់តាក់អាវបំពង់កមូលដៃខ្លី ហើជាមនុស្សស្រី មានក្រមាបង់កជាបុរស មានក្រមាក្រពត់ចង្កេះ ។ ឯប្រដាប់ប្លែកនោះ មានតែស្នែង-

ខ្នេកឯពីរ គឺយកស្នែងខ្នេកឯមែនខែន មកចងភ្ជាប់នឹងផ្តៅដែលពតជាវង់មូលល្មមពាក់ជាប់នឹងក្បាលមនុស្សក្រែត ។ ដួនកាលបើគ្មានស្នែងមែនខែនទេ គេយកផ្តៅពាត់ឲ្យមានសណ្ឋានជាស្នែងខ្នេកឯក៏ជាន ។ កន្ទុយកូកវែង ។ ចងក្រងតម្រៀបគ្នា ហើយមានខ្សែក្របួចទៅភ្ជាប់នឹងក្បាលមនុស្ស អ្នកពាក់ស្នែងមានពីរនាក់ ។ ក្បាលសេះពីរទៀតគេធ្វើតក្រដាសទុកសំរាប់សឹកពីលើក្បាលមនុស្សឲ្យល្មមជាប់ជាន ។

២ – អំពីរបៀបលេង

សមាជិកនៃវង់ជុំនេះ មានតែ ៧ នាក់ប៉ុណ្ណោះ គឺប្រុសបីនាក់តាន់គ្រឿងភ្លេង ស្ត្រីពីរនាក់ពាក់ស្នែងខ្នេកឯ ស្ត្រីពីរនាក់ទៀតជាអ្នកប្រឹងបើកបរ នឹងជាអ្នកបន្ទរ (១) ។

ឯរបៀបវាជុំនេះ មានដូចតទៅ ៖

អ្នកវាយស្គរចាប់ផ្តើមវាយស្គរឡើងកេះបីបទមុនគេ សំរាប់ឲ្យអ្នកតាំងអស់គ្នា បង្ហោនកាយលើកដៃប្រណម្យថ្វាយបង្គំគ្រូ ។ រួចហើយក្មួយតិចាប់ផ្តើមឡើងស្របជាមួយ ស្គរកិច្ចរសំឡេងជាចង្វាក់រន្ធើល ។ ឡើងវិញ ។ រីឯអ្នកឆ្កែក្មួយ ផ្តើមធ្វើកំធង់ តែវាំដំបូងគ្រាន់តែយោលខ្លួនបន្តិច ។ រួចបង្កើត

---

១ – ត្រង់ជាមានស្ត្រីវាំនេះ តាមឯកសារឈ្មោះទីថាតំការសិក្សា ដែលជានៅមើលឃើញនៅភូមិអណ្តូងរុង (កំពង់ឆ្នាំង) ឯឯ សារណាការ.ជាវាតំក្នុង BEFEO វិញ ថាប្រុសវាំតាំងអស់ សុទ្ធតែជាមនុស្សពេញវ័យ ហើយមានចំនួនមនុស្សច្រើន ដូចជាមានថែមអ្នកពាក់កន្ទុយក្លោកនឹងក្បាលសេះជាដើម ។

ជាចង្វាក់កាន់តែញាប់ឡើង ។ រហូតបានទៅជាការយាការត្រាន់ត្រម្ងាត់ យ៉ាងស្វាហាប់ ដោយមានបំបះបុងក្មួយផ្អៀងផ្អង ខំនឹងជាត្រាន់រុករកមើលអម្រឹត ទឹងមានទឹកមុខមាំហាក់ដូចគាចសាហាវណាស់ ។

បន្ទាប់មកអ្នកពាក់ស្នែងខន្ធោងចាប់ចេញពាំ ធ្វើការយាការត្រាប់ដំណើរសត្វខន្ធោង ប្រកបដោយក្បាច់ខន់ភ្ញន់តែក្រាយ ហើយប្រកៀងគ្នារេចុះរេរឡើង ។

ឯអ្នកប្រគឹងបោកបទ គាន់ជួបមួយសរសៃចាប់ចេញពាំចាក់ក្បាច់រំពើតរំពើងតាមបង្វាក់ក្មេង ហើយប្រគឹងបោកបទឮក្រឌុ ពាប់រៀបតាំលនាខៃសត្វខន្ធោង ព្រមពាំងម្នាក់ទៀតពាក់ពីក្រោយជួយស្រែកបន្ទរតាមផង ។

ដូច្នេះយើញថាអ្នកលេងរបាំនេះពាំងអស់គ្នា សុទ្ធតែជាខាជករពាំងអស់ ទោះជាអ្នកវាយស្គរតែរេរាំដែរ ។ ឯរបៀបធ្វើជាឈុតនោះគឺ៖ ដំបូងឡើងចេញត្រាន់ត្រៃ (អ្នកកាន់ក្មួយ) ដើរវាបមស្វាច ។ ដើងក្អែកក្រឡៃបក្រឡាចធ្វេងស្តាំ ដើរវង់ជុំវិញក្នុងវាលដែលលេងរបាំ ។ បន្ទាប់មកចេញខន្ធោងមួយគូមកដើរវាបបន្ទើល ។ អង្គុញដើង តន្ទែកក្បាលដង្គន់ ហើយឈានវាបធំធាង ។ ។ ដៃពាំងពីរជួនសំយុងទៅមុខធ្វើវាបជាដើងមុខ ជួនប្រតាំចង្កេះពាំងសង់ខាង ហើយយូរ ។ ម្តងធ្វើជាដល់ក្បាលគ្នាលេង ។ បុងបំផុតមានខ្លាចេញមកវាបលប ។ ដៃរឈប់ ។ ទៅកៀនវង់លេងរបាំ ហើយអើតកសំឡក់ទៅខន្ធោងពាំងពីរ

ចង់ដើរក្រវែលពីក្រោយទន្សាយ ពីក្រោយត្រានោះវាវៀតៗ ។

បើគាត់អ្នកធ្វើជាក្មេងជាស្រះបន្ទួមកន្លែងនេះទៀត អ្នកនោះត្រូវចេញមកបន្ទាប់ពីទន្សាយ ហើយធ្វើតាមវាគ្រប់ហាលទន្សាយដែរ ។ ឯអ្នកត្រៀងនេះពិតមែនតែមិនដើរទេ តែគំជួយកំរេចន្លែងដែរ ។

៣- អំពីទំនុកច្រៀង

ចំនងមើលទៅ បទត្រៀងពិតជាមានច្រើនមែនប្រែនយ៉ាងណា តាមការគាត់តែងនៃអ្នកស្រុកផ្សេងៗគ្នា ប៉ុន្តែ កន្លងទៅនេះយើងលើកយកតែចំនុកណាដែលគេស្គាល់ច្រើន មកធ្វើជាឧទាហរណ៍ ។

« ... ទន្សាយស្មែនចង់ រកស៊ីតែយប់
ទន្សាយស្មែនចង់ ថ្ងៃឡើងជួនវាត្រ ។
ទន្សាយស្មែនតែក ស៊ីបែកតីហ្នឹង
ទន្សាយស្មែនច្រែង រឹតហ្នឹងបែកក្តាយ ។
ទន្សាយគាជា ស៊ីបន្លាដង្កូ
ទន្សាយតែក្រកុំ លេបក្រមុំតាំងមួល ។

តាមឯកសារលេខ ១ - ចាបាដាត (១)


1— R. BABADAT, Les Samré ou Pear, BEFEO Tome XLI, 1941 P. 97 .

ពិធីសម្ពោធឆ្លងគ្រែស្នានពុទ្ធិកសិក្សា

សម្តេចព្រះនរោត្តម សីហនុ

ក្រុងភ្នំពេញ

ដើម្បីធ្វើឲ្យព្រះពុទ្ធសាសនាបានរីកចំរើន សម្តេចព្រះប្រមុខរដ្ឋជាព្រះបិតាឯកភាពជាតិ កងវាន:ព្រះអង្គជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ព្រះអង្គបានស្តេចយាងទៅជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធឆ្លងគ្រែស្នានពុទ្ធិកសិក្សាមួយខ្នងនៅក្នុងបរិវេណ ក្រសួងធម្មការ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ព្រះនាមហៅថា « គ្រែស្នានសម្តេចព្រះនរោត្តម សីហនុ » ។ ពិធីសម្ពោធនេះ គឺធ្វើឡើងតាមផ្លូវការ ទន្ទឹងតាមរបៀបព្រះពុទ្ធសាសនា ដែលបានចាត់ចែងធ្វើឡើង ដើម្បីថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះប្រមុខរដ្ឋ កំណត់ទុកជាបុណ្យ ចំរើនព្រះជន្មវស្សានៃសម្តេចព្រះប្រមុខរដ្ឋ គំរប់ ៤១ ឆាន់ចូល ៤២ ព្រះវស្សា ដោយព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា ទន្ទឹងបុគ្គលិកនៅអគ្គាធិការដ្ឋាន នៅពុទ្ធិកវិទ្យាល័យព្រះសុកម្រិត ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ទន្ទឹងពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងព្រះសង្ឃ គ្រហស្ថ សាស្ត្រាចារ្យ ទន្ទឹងសមណនិស្សិតទាំងអស់ ក្នុងការឧបត្ថម្ភ នៃក្រសួងធម្មការ អស់រយៈពេលចំនួន ២ ថ្ងៃ ១ យប់ គឺចាប់តាំងពីថ្ងៃសុក្រ ១៤ កេីត ដល់ថ្ងៃសៅរ៍ ១៥ កេីត ខែកត្តិក ឆ្នាំថោះបញ្ចស័ក ត្រូវនឹងថ្ងៃទី ១៥



សម្តេចសហជិវិនព្រះប្រមុខរាជ្ឋាភិបាលកម្ពុជា ទ្រង់ទទួលផ្ទាំងបុប្ផាពីស្ត្រីពីរនាក់ ជំរើសរៀប ច្រើនប្រើយ ជាតំណាងឱ្យនៃការថ្វាយប្រពាស្ងាគមន៍ នៅឯកាសពិធីសម្ពោធគ្រឹះស្ថានព្រះនរោត្តម-សីហនុ (វិទ្យាល័យព្រះស៊ុរាម្រិត) នៅថ្ងៃទី ១៥-១១-៦៣

ទី៥ ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៦៣ ។

ថ្ងៃនេះជាថ្ងៃចាប់ផ្តើមបុណ្យ: ចាប់តាំងពីម៉ោង ៨ ព្រឹកទៅ ក្រុមពុទ្ធបរិស័ទ ចាំឯបព្វជិត ចាំឯត្រហស្ថ ជាច្រើនពាន់នាក់ ចាន់ទីមន្តីទីឆ្ងាយ អញ្ជើញមកជួបជុំ ដោយគ្រឹងចិត្តសេក្តីសមតាមសមណសារូប ចំណែកឯត្រហស្ថវិញ ស្ទើរតែពាក់តាមបែបជាឧបាសក ឧបាសិកា មានចាំងនាំកូនចៅទៅផងដែរ យ៉ាងអ៊ូអរ គឹកកង ប្រកបដោយភក្តីប្រឹមប្រើយ ។ នៅពេលម៉ោង ៨,៣០ សម្តេចព្រះសង្ឃនាយកចាំង ២ គណៈ: ប្រធានសភាចាំង ២ នាយករដ្ឋមន្ត្រី ចាំងហ្វាំងតុលាការជាន់ខ្ពស់ សមាជិកពហុដ្ឋកិច្ចាល អនុរដ្ឋលេខាធិការ សមាជិកសភាចាំង ២ ព្រមចាំងមន្ត្រីអ្នកពហុការគ្រប់ដំណាំង ទីមន្ត្រី ស្តេចយាង ទីងអញ្ជើញដល់ ។

ក្នុងម៉ោងក្រោយមក គឺម៉ោង ៩ តត់ សម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដោយមានឯកឧត្តមញឹក ផ្លូវ្យង អនុប្រធានក្រុមប្រឹក្សាព្រះពហុបល្ល័ង្គ ទីងឯកឧត្តមជាសមាជិក ព្រមចាំងព្រះពហុបរិវារជាច្រើនទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយតុំបានពាប់នាមកងចំនួន ចានដង្ហែព្រះអង្គជាផ្លូវការ តាមព្រះពហុទីនាំងវេយ្យន្ត ឆ្ពោះទៅកាន់ត្រើសស្ថានថ្មីនេះ ។ នៅពេលនោះ សម្តេចទ្រង់ចានឧទ្ទិសគាវេតិច្ចតីតាចានក្រុមភក្តីព្រះអង្គ ដែលលើកគាំពុងតែថ្នាក់ថ្នាយជាព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់ ចំពោះព្រះអង្គ ។ នៅពេលដែលសម្តេចទ្រង់យាងចុះពីព្រះទីនាំងវេយ្យន្ត ទ្រង់

ជានខ្លួលឆ្នងឆ្ងាជានិមិត្តរូប នៃការថ្វាយព្រះពរស្វាគមន៍ ព័ស្តើពីរូប ប្រកបដោយរូបសម្បត្តិ ខឹងសំលៀកបំពាក់គួរជាទីជាប់អារម្មណ៍ពន់ពេក ។ តមក ទ្រង់ខ្លួលការគោរពពីនាំម៉ឺនសព្វមុខមន្ត្រី មានសម្តេចជហ្វាកំដរវៀនជ័យ ចៃន ខុត ឯកឧត្តមសឺន.សាន ទំប្រែក្សត្តាល់ព្រះអង្គជាដើម ដែលរង់ចាំខ្លួលព្រះអង្គនៅទ្វារចូល ។ នោអមតៈមន្ទីរនៃព្រះពជដំណើរទៅកាន់ទីសម្ភោធ ក្រុមយុវនពជសង្គមនិយមខ្មែរ ស្មៀកពាក់ជាឯកសណ្ឋាន ស្រែកជយយោសន៍ យ៉ាងកងរំពងថា !

ជយោ ព្រះអគ្គព្រះសាសនូបត្ថម្ភក៍

ជយោ ព្រះបិតាឯកពជ្យជាតិ !

ជយោ សេដ្ឋកិច្ចជាតិ !

លុះសម្តេចឥន្ទ្រជល់យ៉ាងនៃពុទ្ធកវិទ្យាល័យព្រះសុរាម្រិត ក្រុមតន្ត្រីព្រះពជទ្រព្យក៏ចាប់ខ្ទឹបខ នគរពជ តាមព្រះប្រពៃណីថ្វាយសម្តេចឥ ជាទីគោរពចប់ហើយ ទើបសម្តេចឥ ទ្រង់ក្រាបថ្វាយបង្គំយ៉ាងគោរពចំពោះព្រះសង្ឃ មានសម្តេចព្រះសង្ឃនាយកតាំងតំណែងជាប្រធាន រួចទើបព្រះសង្ឃ ចាប់សូត្រធម្មជយន្តោ ប្រសិទ្ធីពរថ្វាយព្រះអង្គ ។ លុះព្រះសង្ឃស្វាធ្យាយន៍ព្រះធម្មចប់ហើយ សម្តេចព្រះប្រមុខរដ្ឋជាទីស្នេហាស្មើដោយជីវិត ទ្រង់ស្តេចប្រថាប់លើស៊ុវណ្ណគោច្ចៈ ប្រកបដោយព្រះគុណដ៏ប្រមប្រិយក្រៃលែង ។ សហជីវិន ម៉ែន.ឈុំ អនុរដ្ឋលេខាធិការ ក្រសួង




សម្តេចសហជាតិវីរៈ ព្រះប្រមុខរដ្ឋ ទ្រង់ប្រណម្យពោរពព្រះសង្ឃដែលស្ថាធ្យាយ
ព្រះពុទ្ធមន្តប្រសិទ្ធិពរជ័យ ក្នុងឧកាសពិធីសម្ពោធត្រុះស្ថានព្រះនភេត្តម-សីហនុ
(វិទ្យាល័យព្រះស៊ុរាម្រិត) នៅថ្ងៃទី ១៥-១១-៦៧

ធម្មការ ក៏ចាប់ផ្តើមសុន្ទរកថាថ្វាយព្រះពរស្វាគមន៍ បន្ទាប់មកគឺជាសុន្ទរកថានៃព្រះពោធិវង្ស ហួត-តាត ផ្តែផ្តំពីប្រវត្តិសង្ខេបនៃពុទ្ធិកវិទ្យាល័យ និងអំពីការស្ថាបនា គ្រិះស្ថានសម្តេចព្រះនរោត្តម-សីហនុ ថ្មីនេះ(១) ហើយសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ដែលជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ព្រះអង្គទ្រង់សព្វព្រះកដហ្ឫទ័យ មានព្រះរាជបន្ទូលទៅយតប ប្រកបដោយព្រះសូរសៀងយ៉ាងពិរោះក្បោះក្បាយ និងមានសារៈសំខាន់ គួរជាទីពេញចិត្តពន់ពេក ហើយដែលយើងដកស្រង់ខ្លះមកផ្សាយជូនដូចតទៅ ៖

ជាបឋម សម្តេចទ្រង់សរសើរចំពោះព្រះគេជព្រះគុណព្រះពោធិវង្ស ហួត តាត ដែលមានទត្តមគតិដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចស្ថាបនាអគារសំរាប់ពុទ្ធិកសិក្សាក្នុងព្រះពុទ្ធសាសនា ព្រមទាំងបានតស៊ូបានល្អមាំង ហើយអស់សោហ៊ុយយ៉ាងតិចជាអតិបរមា តួយ៉ាងដូចជាគ្រិះស្ថាន ព្រះនរោត្តម សីហនុ នេះ បើជាពាក្យរាប់វិញ យ៉ាងតិចណាស់ក៏ត្រូវចំណាយអស់ ២ លានរៀល នេះមិនដូច្នោះ អស់មិនដល់ទាំង ១ លានរៀលផង ដែលជាព្រះរាជទ្រព្យផ្ទាល់ទ្រង់ប្រគេនមក ។ រួចទ្រង់គោលបញ្ជាក់ដូនកូនចៅស្តាប់ កុំឲ្យការខ្ជិលច្រអូសតាមពាក្យយោសនាអកុសលនៃជនក្បត់ជាតិ ខ្លួ

(១) ឯសុន្ទរកថា សហជីវិនអនុម្ពីលេខាធិការក្រសួងធម្មការ និងសាលនសិក្សាធិការ និងសុន្ទរកថាព្រះពោធិវង្ស ដែលថ្លែងក្នុងពេលនោះ យើងនឹងចុះផ្សាយនៅខាងក្រោយ ។

ការកែទម្រង់សេដ្ឋកិច្ចជាតិ ឯការធ្វើនេះ គឺដើម្បីស្រោចស្រង់ដំណាំជាតិ ដែលចេះតែជួបប្រទះនឹងឧបសគ្គជាច្រើនកាលណាៗ ឲ្យរួចផុតពីអំពើខុសឆ្គង នៃពួកមូលធនកាន់តែច ដែលគិតតែស្រុះស្រែងរកប្រយោជន៍ផ្ទាល់ខ្លួន ហើយនឹងដើម្បីលើកស្ទួយដំណាំជាតិជាលំដាប់ទៅមុខទៀត ដែលតែងតែជួលគ្រោះថ្នាក់អំពីពួកនាយទុនតែប៉ុណ្ណោះ ។ ទ្រង់បញ្ជាក់ថា ក្នុងឆ្នាំ ១៩៦៤ ព្រះអង្គនឹងប្រគេនចំពោះព្រះតេជព្រះគុណព្រះពោធិវង្ស ទូវបច្ច័យចំនួន ២ លានរៀល ដើម្បីរុះរើកសាងជាថ្មី ទូរទស្សន៍វិទ្យាល័យព្រះសុកម្រិត ដែលមានកន្លែងសិក្សាមិនគ្រប់គ្រាន់ផង ហើយមានសភាពចាស់ទ្រុឌទ្រោមផងនោះ ។ ទ្រង់បន្ថែមថា ប្រសិនបើការកែទម្រង់សេដ្ឋកិច្ចនេះរីកចំរើនក្នុងឆ្នាំ ១៩៦៥ ទ្រង់នឹងប្រគេនចំពោះ ព្រះពោធិវង្ស ហួត តាត ទៀត ទូវបច្ច័យទ្វេឡើងជា ៣-៤ លាន ក្នុងកិច្ចស្ថាបនាអគារពុទ្ធិកសិក្សា ។ នៅទីអវសាន ទ្រង់ថ្លែងបញ្ជាក់ អំពីព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជា ព្រោះជនក្បត់ជាតិថាព្រះអង្គបំបាត់ពុទ្ធសាសនា ទ្រង់ប្រកាសថា គ្មានជនណាកាន់ព្រះពុទ្ធសាសនាជាងព្រះអង្គទេ ពោះបីប្រទេសយើង មានឈ្មោះថាសង្គមរាស្ត្រនិយម គឺសង្គមរាស្ត្រនិយម ខាងព្រះពុទ្ធសាសនា ។ ដើម្បីបញ្ជាក់យ៉ាងច្បាស់អំពីទឹកព្រះទ័យព្រះអង្គ ចំពោះព្រះពុទ្ធសាសនា ទ្រង់ប្រកាសជាមហាឧបាសក សូមដង្ហែនហន្តុះសមណៈសក្តិ ជាសម្តេចព្រះសង្ឃរាជ ថ្វាយចំពោះសម្តេចព្រះសង្ឃនាយកខាងគណៈ



សម្តេចសហជីវិនទ្រង់បង្ហាញជំរំមហាសន្តិភាព នូវមីង «សាឡី» ជាមេដំបៅព្រះអង្គ
កាលទ្រង់នៅពីក្មេង ក្នុងឱកាសពិធីសម្ពោធត្រែះស្ពាន ព្រះនរោត្តម-សីហនុ
(វិទ្យាល័យព្រះស៊ុកាម្រិត) នៅថ្ងៃ ទី ១៩-១១ ៦៣

ដែលគង់នៅចំពោះព្រះភក្ត្រព្រះអង្គនេះ ។

នៅពេលចប់ព្រះសូរសៀង ដែលគង់កន្តោះនោះមក ព្រះអង្គស្តេចយាងគាត់ខ្សែប្រយ៉ា ជានិមន្តរួបនៃការបើកគ្រែស្នានថ្មីឲ្យថ្លៃថ្លាសាធុវិការនេះ ស្តេចទ្រង់យាងគង់គ្រែស្នានថ្មីនេះ ប្រកបដោយព្រះភក្ត្រញញឹមប្រឹមប្រិយ ដោយមានតាមីនមុខមន្ត្រីតាំងខ្លាយ តាមហែហមព្រះអង្គផង ។ បន្ទាប់ពីព្រះរាជទេស្សនកិច្ចគ្រែស្នានថ្មី ប្រកបដោយយសវិយាសាដែលកាយនេះមក ព្រះអង្គទ្រង់ថ្វាយបង្គំលាព្រះសង្ឃទីដ៏ពលរដ្ឋ ក្នុងចៅព្រះអង្គ និវត្តចូលព្រះបរមរាជវាំងវិញ នៅម៉ោង ១១.៣០ ដោយព្រះសុវត្ថិភាព ។

ពេលល្ងាច ម៉ោង ១៨.៣០ មានទិមន្តព្រះសង្ឃ ៤៣ អង្គចំរើនព្រះបរិត្ត នៅវិស្សមសាលានៃពុទ្ធិតាំលាល័យ លុះដល់ម៉ោង ២០.៣០ ទិមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ សំដែងធម៌ទេសនា ។ បន្ទាប់មក មានបញ្ចាំងភាពយន្តដើម្បីកំដរបុណ្យនេះជូនដល់ទស្សនជនគំសាន្តផង ។

ថ្ងៃសៅរ៍ ១៩ រោច ខែកត្តិក ឆ្នាំថោះបញ្ចស័ក (១៦.១១.៦៣)

ថ្ងៃនេះជាថ្ងៃបង្ហើយបុណ្យ បរិយាកាសត្រជាក់នេះ គឺមានភ្លៀងបាំសឹងជ្រើងជាអនេក ។ ម៉ោង ៨.៣០ សម្តេចព្រះសង្ឃនាយកទាំង ៤ គណៈ ទិមន្តដល់ ពេលនោះព្រះពោធិវង្ស

តំណាងខ្ញុំស ព្រះរាជកុសលថ្វាយចំពោះសម្តេចព្រះមហាក្សត្រីយានី នឹង
សម្តេចព្រះប្រមុខរដ្ឋ រួចចាប់ផ្តើមធ្វើពិធីសមាទានសីល ៥ បន្ទាប់មកព្រះ
សង្ឃក៏សូត្រនមិតហូរទៅឆ្ងន់ លុះចប់ហើយ ទាសក-ទាសិកាទាំង
អស់ ក្រោករៀបចំខ្លួនដៃកាន់ផ្តិលថ្វាយ ដើម្បីប្រារព្ធធ្វើពិធីដាក់ថ្វាយ
អស់រយៈពេល ប្រហែល ៣០ នាទី ។ ក្រោយមក ព្រះសង្ឃក៏ថានអនុមោ
ទនា ជាកិច្ចបង្ហើយបុណ្យ ។

សុន្ទរកថានៃសហជីវិន ម៉ែន - ឈុំ អនុរដ្ឋលេខាធិការក្រសួង
ធម្មការ :

សូមព្រះតេជៈដ៏កល់លើត្បូន

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ សម្តេចព្រះទេបយុវរាជព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ

ក្នុងនាមនៃសមណានិស្សិត នៃព្រះសង្ឃមានសម្តេចពាំងពីរព្រះអង្គជា
ប្រធាន នៃពុទ្ធបរិស័ទពាំងឡាយ នឹងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ
ទូលព្រះបង្គំជាខ្ញុំ សូមបង្អោនកាយក្រោមល្អងធូលីព្រះបាទ ក្រាបបង្គំ
ទូលថ្វាយ ដោយសេចក្តីគោរពដ៏ជ្រាលជ្រៅ ខ្ញុំព្រះពុទ្ធស្វាគមន៍ដ៏សក្តិសិទ្ធិ
ខ្ញុំបាទសោមនស្សរីករាយយ៉ាងក្រៃលែង នឹងខ្ញុំពុទ្ធភ្ញាតាជាអតិបរមា ចំពោះ
សម្តេចព្រះបិតាឯករាជ្យជាតិ ជាព្រះឯករដ្ឋភក្តីសាសនូបត្ថម្ភក៍ ដែលព្រះ
អង្គទ្រង់សព្វព្រះហឫទ័យព្រះរាជសព្រមោ ទៀតសោតយាងមកជាព្រះអធិប
តីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដ៏មហាឱឡារិក នៃគ្រឹះស្ថានសម្តេចព្រះនរោត្តម



សហជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ថ្វៃងសុន្ទរកថា នៅឧកាស
ពិធីសម្ពោធត្រើះស្ពានព្រះនរោត្តម–សីហនុ នៅថ្ងៃ ទី ១៥–១១–៦៣

ស៊ីហនុ ទើបនឹងស្តាបនាច្នៃនេះ ។ ព្រះហឫទ័យសន្តោសរបស់ព្រះអង្គក្នុងកាលនេះ ធ្វើឲ្យខ្ញុំព្រះបង្គំជាខ្ញុំតាំងឡាយជាកូនចៅ តាំងបព្វជិត តាំងគ្រហស្ថ មានមនោសញ្ចេតនាពោរពេញដោយសេចក្តីគ្រេកអរ នឹងអំណរព្រះមហាករុណាគុណរកទីបំផុតគ្មាន ព្រោះខ្ញុំព្រះបង្គំតាំងឡាយជាកូនចៅ មិនឆ្អែតចាល់តែសោះ ក្នុងការចង់ឃើញព្រះភក្ត្រដ៏ប្រឹមប្រិយ ប្រកបដោយសេរីស្មុស្តី នឹងមេត្តាករុណានៃព្រះអង្គ ។

ឯគ្រឹះស្ថានសម្តេចព្រះនរោត្តម សីហនុដែលលេចត្រដែតឡើងនៅចំពោះព្រះភក្ត្រ ប្រកបដោយសោភណភាព នឹងសម្រស់ដ៏ឆ្ងាស្នេហានេះ ចាត់ទុកជាព្រះទំនិត្តរូបដ៏ថ្លៃថ្លា នៃព្រះកាយវិការដ៏សែនសប្បុរស នៃសម្តេចឪជាទីគោរព នឹងជាទីស្នេហាស្មើដោយជីវិត ចំពោះព្រះពុទ្ធសាសនា នឹងចំពោះសមណនិស្សិតតាំងឡាយ ដែលកន្លងពេលមុន រមែងមានការចង្អៀតចង្អល់ក្នុងការសិក្សាព្រះបរិយត្តិធម៌ នឹងវិជ្ជាជនៃផ្សេង ។ ដ្បិតការរីកចំរើនហើយធាប់រហ័សនៃវិជ្ជាតាំងនេះ ក៏ត្រូវតែពឹងផ្អែកយ៉ាងពេញបន្ទុកលើទីសេនាសនៈ មានសភាពដ៏ទូលំទូលាយនឹងសមរម្យ។ កាលបើគ្រឹះស្ថានដ៏ជាទីមនោរម្យបែបនេះ ដែលជាផលនៃព្រះកដអំណោយដ៏ថ្លៃថ្លានៃព្រះអង្គបានផុះឡើងហើយ នោះមានសង្ឃឹមយ៉ាងម៉ាំទុកក្នុងចិត្តថា គុណសម្បត្តិខាងការចេះដឹងនៃសមណនិស្សិតតាំងឡាយ ដែលកាលពីដើម មានការរីកចំរើនដោយលំបាក មកពីមានថ្នាក់រៀនមិនសូវគ្រប់គ្រាន់

នោះ ទីដ៏មានវិប្ផុនភាពយ៉ាងធួ ហើយធាប់រហ័សជាតិត្រូវតែជាមិនខាន ។

ជាអវសាន តាដ៏នាមនៃសមណានិស្សិតទាំងអស់ ខ្ញុលព្រះបង្គំជាខ្ញុំ សូមសំដែងថ្វាយ ចំពោះសម្តេចឥ ជាព្រះឯកអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទូវសេចក្តីសោមនស្សយ៉ាងធំជាអនេកប្បការ ទីដ៏អំណរព្រះមហាករុណាគុណដ៏លើសលប់ជាថ្មី ព្រមទាំងសូមលើកព្រះកុសលវិផលកើតមកពីការសិក្សាព្រះបរិយត្តិធម៌ ជាព្រះឧត្តរនៃព្រះបរមគ្រូសម្មាសម្ពុទ្ធ ថ្វាយដោយសេចក្តីគោរព ចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ចម្រើនជាអតិបរមា ដោយព្រះសុខភាពដ៏បរិបូណ៌ ដោយព្រះសុភមង្គលគ្រប់ទីពីរភក្រ្តី មានព្រះជ័យាយុយឺនយូរជាដរាយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់នៃកូនចៅក្នុងព្រះកិច្ចដឹកនាំនាពេលអនាគតជាទីស្នេហា ខ្ពោះខ្ញុំគាន់ត្រើយសន្តិភាពវឌ្ឍនភាព សម្បូរសប្បាយ សូមឲ្យសត្រូវគ្រប់ទិស បាក់បែក ខ្ចប់ខ្ចាយព្រះចេស្តាបារមី ហើយឲ្យក្លាយមកជាមិត្តស្និទ្ធិស្នេហា តំបន់ឃ្លាំងហ្វូតរឿយ ។

សុទ្ធរភាបា

ថ្ងៃនិងនឹងកាសាខែតាំងបុណ្យសម្ពោធគ្រឹះស្ថានសម្តេចព្រះ
នរោត្តម សីហនុ នៅថ្ងៃទី ១៧ ខែធ្នូ ១៩៦៣ ដោយព្រះគុណ
ព្រះគុណព្រះពោធិវង្ស ហ្វូង គាត អគ្គាធិការ នៃពុទ្ធិកសិក្សា ។

សូមថ្វាយព្រះពរ

សម្តេចព្រះទេបយុវរាជ ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

កន្លងមានៃបុគ្គលិក សាស្ត្រាចារ្យ សមណនិស្សិតចាំងពួយ ខ្ញុំ
កន្លងមាំលាំនៃអាត្មាភាព អាត្មាភាពមានបំតិះសោមនស្សរីករាយយ៉ាងក្រៃ
លែង ចំពោះសម្តេចព្រះអគ្គសាសនូបត្ថម្ភកជាអម្ចាស់ ដែលបានធ្វើត
យកព្រះពរវរកាសស្តេចយាងមក ជាព្រះពរជាធំបតីនឹងជាព្រះពរកិត្តិ-
យសដ៏ខ្ពង់ខ្ពស់ កន្លងកាសាខែតាំងសម្ពោធគ្រឹះស្ថានសម្តេចព្រះ នរោត្តម-
សីហនុ ដែលទើបនឹងស្ថាបនាហើយថ្មី ។ នេះ ដោយព្រះពរអំណាច
ដ៏ថ្លៃថ្លានៃសម្តេចជាអម្ចាស់ ។

ចំពោះសម្តេចព្រះសង្ឃនាយកចាំងពីព្រះអង្គ ទ្រង់ ឯកទត្តម ខ្ញុំន
តស់លោកចាំងពួយ ដែលបានខិមខ្ជួ ស្តេចយាង អញ្ជើញមកជាកិត្តិ-
យស ដ៏ប្រសើរក្នុងពិធីសម្ពោធគ្រឹះស្ថានថ្មីនេះ ។

អម្បាញ់មិញនេះ លោកអនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសេចក្តីថ្វាយព្រះពរស្វាគមន៍ ចំពោះសម្តេចជាអម្ចាស់ ទទឹងអំពីការស្តាបនានៃគ្រឹះស្ថានថ្មីនេះ ដោយសង្ខេបរួចហើយ ។

ឥឡូវនេះ អាត្មាភាព សូមព្រះពជ្ឈាន ព្រះពជ្ឈារកាសចន្ទិចថ្លែងអំពីប្រវត្តិសង្ខេបនៃពុទ្ធិកវិទ្យាល័យព្រះសុកម្រិតនេះ ទទឹងអំពីការស្តាបនាគ្រឹះស្ថានថ្មី ដែលភ្ជាប់ជាយប្រៈបវេសនាមថា គ្រឹះស្ថានសម្តែងព្រះធម្មវត្តម-សីហឬ ដើម្បីទ្រង់ជ្រាប ដូចមានសេចក្តីតទៅនេះ

សូមថ្វាយព្រះពរ ពុទ្ធិកវិទ្យាល័យនេះ កាលកើតដំបូងមានឈ្មោះថា «សាលាបាលី» ក្នុងព្រះបរមរាជូបត្ថម្ភក៍ នៃព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ តាមអំណាចព្រះពជប្រកាសលេខ ៨៥ ចុះថ្ងៃទី ២៤ វិច្ឆិកា ១៩១៤ ។ នៅពេលនោះ ពុំមានអគារសម្រាប់សិក្សានៅឡើយ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់សព្វព្រះពជហឫទ័យប្រោសព្រះពជទានឲ្យបើកការសិក្សានៅដើមឆ្នាំ ១៩១៥ ដោយយកមន្ទីរព្រះសង្ឃម្ន ទទឹងថែវគាតខ្លះ នៃវត្តព្រះកែវមេរកត ធ្វើជាកន្លែងសិក្សាបណ្តោះអាសន្ន ។

លុះដល់គ.ស. ១៩២០ ពជការបានចាប់ផ្តើមកសាងអគារ ១ ខ្នង មានតំលូសម្រួចសម្រាប់សាលាបាលីនៅត្រង់ឆ្ការស្ពួន ។

ដល់មកគ.ស. ១៩២២ បានរើសាលាបាលីពីវត្តព្រះកែវមេរកតយក



ព្រះតេជគុណព្រះពោធិវង្ស ហ្សត - ភាត អគ្គាធិការនៃពុទ្ធិកសិក្សាថ្នៃងសុន្ទរកថាក្នុងទិវាសពិធីសម្ពោធគ្រែងស្ថានព្រះនរោត្តម - សីហនុ (វិទ្យាល័យព្រះសុរាម្រិត)
នៅថ្ងៃទី ១៩-១១-៦៣

មករៀបចំការសិក្សាទៅអាគារថ្មី ដែលសព្វថ្ងៃបានរៀបចំធ្វើជាមន្ទីរពុទ្ធ-
សាសនបណ្ឌិត្យ នឹងក្រសួងធម្មការ ។ នៅពេលនោះ សាលាចាស់
បានប្រែឈ្មោះថា «សាលាបាលីជាន់ខ្ពស់» ដោយបានកែប្រែរបៀប
ការសិក្សាខ្លះ តាមអំណាចព្រះរាជក្រឹត្យលេខ ៧៥ ចុះថ្ងៃទី ១៣ មេ
សា ១៨២២ ។

ដល់មកគ.ស. ១៨២៥ រាជការបានបង្កើតព្រះរាជបណ្ណាល័យ
កម្ពុជា តែឥតមានទីសំណាក់ការ រាជការក៏បានសុំយកអាគារនៃសាលា
បាលីជាន់ខ្ពស់ ឲ្យទៅជាទីសំណាក់ការនៃព្រះរាជបណ្ណាល័យកម្ពុជា ។
សាលាបាលីជាន់ខ្ពស់ ត្រូវលើកត្រឡប់ទៅឯវត្តព្រះកែវមរកតម្ពង់ខៀត ។

ដល់មក គ.ស. ១៨២៦ រាជការបានយកសាលាបឋមសិក្សាចាក់ង-
វែង សម្រាប់កុមារកុមារី ដែលហៅថាសាលាផ្សារស្លួន គឺសាលានេះ
បង្វែរឲ្យមកធ្វើជាអាគារសម្រាប់សាលាបាលីជាន់ខ្ពស់ ជាប់រហូតមកដល់
សព្វថ្ងៃនេះ ។ រីឯអាគារនេះដែលស្ថាបនាតាំងពី គ.ស. ១៩១៦ ដរាប
ដល់មកឥឡូវនេះចំនួន ៤៧ ឆ្នាំហើយ សព្វថ្ងៃនេះចាស់ទ្រុឌទ្រោមពុកផុយ
ស្ទើរតែត្រូវរលំអន្ទឹង ។ សាលានេះ ត្រូវមានការជួសជុលកាលំនាំ ប៉ុន្តែ
ទោះបីជួសជុលយ៉ាំងណា ក៏ពុំបានជាប់ជាំមួនឡើងវិញដែរ ព្រោះគ្រឿង
ឈើចាស់អស់សុទ្ធតែជាឈើពាល ទោះបីជញ្ជាំងដែលធ្វើដោយឥដ្ឋដែល
ពុំមានស៊ីម៉ង់ត៍សោះ ក្នុងពេលនោះ ឥឡូវនេះ ទៅជាសម្បុកនៃសត្វ

ការណ្បៀស្ទើរតែគ្រប់អន្ទឹ ។

លុះដល់មកគ.ស. ១៩៥៥ ក្រោយពេលដែលពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជកើតឡើង សាលាចាស់ជាន់ខ្ពស់ បានប្រែឈ្មោះថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត តាមព្រះរាជក្រឹត្យលេខ ៣៩៩ ន.ស. ចុះថ្ងៃទី៤ កក្កដា ១៩៥៥ ព្រមទាំងមានការរើរៀបចំជាថ្មីផង ទាំងកម្មវិធីសិក្សាក៏បានរើរៀបចំជាថ្មីដែរ តាមព្រះរាជក្រឹត្យ លេខ ៦៦៥ ន.ស. ចុះថ្ងៃទី ១៨ ឧសភា ១៩៥៥ ដើម្បីជាកន្លែងសមណនិស្សិតឲ្យមានសមត្ថភាពអាចចូលទៅសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជបាន ។

រីឯសាលាចាស់វិញដែលកើតឡើងក្នុងគ.ស ១៩៣៣ ក៏ត្រូវបានកែប្រែឈ្មោះថា « សាលាពុទ្ធិកបឋមសិក្សា » ព្រមទាំងបានកែប្រែកម្មវិធីសិក្សាផង តាមព្រះរាជក្រឹត្យលេខ ៦០៧ ន.ស. ចុះថ្ងៃទី ១២ ធ្នូ ១៩៥៧ ដើម្បីញុំាងសមណនិស្សិតទាំងឡាយ ឲ្យមានសមត្ថភាពអាចចូលមកសិក្សានៅពុទ្ធិកវិទ្យាល័យបាន ព្រោះសាលាពុទ្ធិកបឋមសិក្សាជាមូលដ្ឋានដែលមធ្យមសិក្សា និងឧត្តមសិក្សា ប៉ុន្តែការរើរៀបចំសាលាពុទ្ធិកបឋមសិក្សាក្នុងឆ្នាំ ១៩៥៧ នោះ មិនបានប្រកបដោយលក្ខណៈសព្វគ្រប់ នាំឲ្យសាលានេះជួបនឹងឧបសគ្គខ្លះ ក្នុងរឿងសំបុត្រកាកអាចារ្យទៅបង្រៀន ប្តូរគ្នាបានហើយ ក៏បង្រៀនពុំបានដិតដល់ ជាហេតុនាំឲ្យមូលដ្ឋានដែលពុទ្ធិកសិក្សា ពុំសូវរុំងប៉ុន្មាន ពុំសូវមានកម្លាំងដូច្នេះ ក្នុងឆ្នាំ ១៩៦៤ ខាង

មុខនេះ ទើបសូមព្រះបរមរាជានុញ្ញាត រើរៀបចំកែទម្រង់សាលាពុទ្ធិកឧបាសិក្សាក្នុងព្រះរាជអាណាចក្រ ឲ្យមានទម្រង់វិសេសឡើង ដើម្បីញ៉ាំងការសិក្សាក្នុងសាលានេះឲ្យមានដំណើរលូតលាស់ចំរើនល្អឡើងជាងមុន ល្មមឲ្យសង្ឃឹមបានថាជាមូលដ្ឋានដ៏រុងរឹងមាំមួនៃពុទ្ធិកសិក្សាទៅក្នុងអនាគតៗ

សូមថ្វាយព្រះពរ ចំពោះពុទ្ធិកវិទ្យាល័យព្រះសុកម្រិតនេះ បើគិតតាំងពីឆ្នាំ ១៩១៩ ដល់ឆ្នាំ ១៩៦៣ នេះ ឃើញថាមានអាយុកាល ៤៤ ឆ្នាំហើយ ប៉ុន្តែ កាលនៅក្នុងអំណាចនៃរាជការអាណាព្យាបាលបារាំងវិសេសនៅឡើយ សាលានោះបានកែចំរើនឡើងយ៉ាងស្ទុះស្ទើរណាស់ អស់ពេលដប់ឆ្នាំរួចទៅ លុះដល់ពេលដែលប្រទេសកម្ពុជា បានទទួលឯករាជ្យ ជាប្រទេសឯករាជ្យ ដោយសារបុណ្យបារមីនៃសម្តេចជាម្ចាស់ សាលានេះក៏បានធ្វើដំណើរដំលៀនទៅតាន់សេចក្តីចំរើន គឺចំរើនទាំងចំនួនសមណនិស្សិត ដោយបានពង្រីកថ្នាក់សិក្សាឲ្យមានច្រើនឡើងផង ចំរើនទាំងវិជ្ជាសិក្សា ដោយបានកែប្រែកម្មវិធីសិក្សាឲ្យសមតាមកាលៈទេសៈ ប៉ុន្តែ ចំពោះការសិក្សាវិញ ថតទៅជាដែល នាំឲ្យមានការចង្អៀតចង្អល់ខ្វះគ្រោះគ្នាច្រើន ផ្នែកគួប តែការចង្អៀតការយក៏ចេះតែប្រព្រឹត្តទៅបានស្រួលមិនជាអ្វីប៉ុន្មាន ព្រោះមានការកែកយដំទូលំទូលាយខាងផ្លូវចិត្ត ។

លុះដល់មកត្រឹមឆ្នាំសកពស ១៩៦២ អគ្គាភាពបានផ្ញើនគំនិតបម្រុងនឹងស្នើទៅក្រសួងធម្មការ សុំឲ្យជួយរកមធ្យោបាយដើម្បីនឹងពង្រីកការ

នៃពុទ្ធិកវិទ្យាល័យនេះ ឲ្យបានខូលាយជាមួយនឹងជាងមុន ។ ការស្នើនេះពុំ
ទាន់ពាំងបានធ្វើផង កំស្រាប់តែសម្តេចជាអម្ចាស់ ក្នុងពេលដែលស្តេច
យាងមកជាព្រះរាជាធិបតីក្នុងពិធីប្រោសព្រះរាជទានឧត្តមសិក្ខាប័ត្រ ដល់
សមណនិស្សិតនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ព្រះអង្គទ្រង់បាន
ប្រោសព្រះរាជទានបច្ច័យចំនួន ១ លានរៀល ដោយព្រះរាជសទ្ធាទ្រង់ថ្វាយ
ក្នុងការជួយឧបត្ថម្ភពុទ្ធិកវិទ្យាល័យនៅថ្ងៃទី ៥ មេសា ១៩៦២ ។ នៅ
ពេលនោះ អាត្មាភាពមានសោមនស្សរីករាយជាអតិបរមា សេចក្តីរីករាយ
នោះដិតជាប់នៅក្នុងចិត្តរហូតដល់ថ្ងៃនេះ ។ មិនមែនតែអាត្មាភាព ឬបុរេ
មជ្ឈដ្ឋាននៃព្រះសង្ឃទាំងអស់ មានសម្តេចព្រះសង្ឃនាយកទាំងពីរព្រះ
អង្គជាដើម ក៏មានព្រះទ័យរីករាយណាស់ ទាំងពុទ្ធបរិស័ទទាំងឡាយក៏
មានចិត្តត្រេកអរគ្រប់គ្នា ។

សូមថ្វាយព្រះពរ ឥឡូវនេះ ព្រះរាជអំណោយ ១ លានរៀលនោះ
បានបង្កើតជាទ្រព្យផល គឺគ្រឹះស្ថាន ១ ខ្នង ដែលបិតនៅចំពោះព្រះភក្ត្រនេះ។
គ្រឹះស្ថាននេះ ក្រោយដែលបានទទួលព្រះបរមរាជានុញ្ញាត បានថ្វាយ
ព្រះបរមនាមថា « គ្រឹះស្ថានសម្តេចព្រះនរោត្តម-សីហនុ » ដើម្បីជាអ
នុស្សាវរីយ៍ សម្រាប់សមណនិស្សិតទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត ឲ្យ
រលឹកយើញជានិច្ច នូវព្រះបរមនាមរបស់ព្រះអង្គដែលជាព្រះអគ្គពុទ្ធសាស
នូបត្ថម្ភក៍ ព្រមទាំងមានឧបការគុណដ៏ខ្ពង់ខ្ពស់មិនអាចនឹងបំភ្លេចបាន ។

ត្រើះស្ពានថ្មនេះ មានទំហំទទឹង ១០ ម៉ែត្រ បណ្តោយ ៦៤ ម៉ែត្រ មានជាន់តែ ចែកជាបន្ទប់មាន ៦ គឺមានក្រោម ៣ បន្ទប់ កណ្តាលទទឹងខាងលិច ធ្វើជាកន្លែងសំរាក្ស ។ ខាងលើ បន្ទប់ខាងកើត ធ្វើជាការិយាល័យសម្រាប់ចាត់ការ បន្ទប់កណ្តាលធ្វើជាកន្លែងសម្រាប់ប្រជុំសាន្តិភាព បន្ទប់ខាងលិច ធ្វើជាបណ្ណាល័យ ព្រោះជាពុទ្ធិកវិទ្យាល័យនេះ ឥតដែលមានបណ្ណាល័យសោះទេ ។ តម្លើងរៀបរៀបតាមជញ្ជាំងខាងចេញពីទ្វារចូលវិទ្យាល័យសម្រាប់ត្រួតពិនិត្យសៀវភៅ ជាទីយកទៅផ្ញើទុកនៅក្នុងសាលាបណ្តាំក្សេរ ទុកនៅត្រង់នេះខ្លះ ត្រង់នោះខ្លះ ដែលជាហេតុនាំឲ្យលំបាកថែរក្សាពន្លឹង លំបាកពន្លឹងចាត់ការផង ។


លុះមកដល់ព្រះពុទ្ធ ការកើសាងត្រើះស្ពានថ្មនេះ ដោយរួបរួមគ្នាជួសជុលសាលាចាស់ផង ការចាក់ស៊ីម៉ង់ត៍នៅមុខត្រើះស្ពានថ្មនេះផង ការរៀបចំខាងក្នុងបន្ទប់ ១ ធ្វើជាតិលាន្តដ្ឋានផង ការលាបពណ៌កំបោរនៅសាលាចាស់ផង អស់តម្លៃ ៧៧៦ ដុល្លារ ក្នុងបច្ចុប្បន្នមុនប្តូរមួយភាគ ប្តូរមួយរយសាមសិបប៊ីរៀល (៤៨៦.៦៣) ក្នុងបច្ចុប្បន្នព្រះពុទ្ធសំណោយ ១ លានរៀលនោះ នៅសល់ប៊ីភាគ ប៊ីរយហុកសិបប្តូរតែរៀល (៧៣៦.៣៧) បច្ចុប្បន្នដែលនៅសល់នេះ បម្រុងទុកសំរាប់ចំណាយនៅក្នុងកិច្ចការអ្វីដែលខ្វះខាតក្នុងខាងមុខ ។

លុះមកដល់ព្រះពុទ្ធ តាំងពីថ្ងៃនេះតទៅ ដោយមានត្រើះស្ពាន ១ ខ្នង

នេះកើតឡើង ពុទ្ធិកវិទ្យាល័យព្រះសុភម្រិត មានទីកន្លែងសម្រាប់ចាត់
ការ សម្រាប់ប្រជុំសាស្ត្រាចារ្យ សម្រាប់ធ្វើជាបណ្ណាល័យ ទើបសម្រាប់
ធ្វើជាថ្នាក់គ្រប់គ្រាន់ៗ ប៉ុន្តែ ចំពោះកន្លែងសិក្សាដែលអាគ្នាភាពបានថ្វាយ
ពតិមានគ្រប់គ្រាន់នោះ ដោយបានពីឯផ្នែកទៅលើគ្រឹះស្ថានទៃពុទ្ធិកមហា
វិទ្យាល័យព្រះសីហនុរាជ ព្រោះសព្វថ្ងៃនេះ បានសុំខ្ចីគ្រឹះស្ថានពុទ្ធិកមហា
វិទ្យាល័យ ចំនួន៤បន្ទប់ ឲ្យសមណនិស្សិតនៃពុទ្ធិកវិទ្យាល័យទៅសិក្សា។
ប្រសិនបើតទៅមុខ ពុទ្ធិកមហាវិទ្យាល័យកែចំរើនឡើង ហើយត្រូវការ
យកបន្ទប់សិក្សាទាំងនោះទៅវិញ ពុទ្ធិកវិទ្យាល័យនេះ ទើបត្រូវចូលួស
ការខ្លះភាគ ១ លើកទៀតមិនខាន ។

ដើម្បីសម្រួលឲ្យពុទ្ធិកវិទ្យាល័យព្រះសុភម្រិតនេះ មានកន្លែងសិក្សា
គ្រប់គ្រាន់ទៅក្នុងអនាគតនោះ អាគ្នាភាពមានយោបល់ថា គប្បីទាន
មុខ ប្រសិនបើមានសម្ភារៈគ្រប់គ្រាន់ក្នុងពេលណា ក្នុងពេលនោះ គួរតែ
រុះរើសាលាចាស់ដែលស្ថាបនាប្រហែល ៥០ ឆ្នាំមកហើយ។ បំពេញក្នុង
សភាពទ្រុឌទ្រោមនេះ ហើយស្ថាបនាជាពីរជាន់ឡើង នោះទើបអាចប្រ
មូលថ្នាក់រៀនពីពុទ្ធិកវិទ្យាល័យចំនួន ៤ បន្ទប់មកមួគ្នា ក្នុងពុទ្ធិកវិទ្យា-
ល័យនេះបាន ព្រោះក្នុងពេលនេះ ឥតមានទីដ៏ល្មមនឹងសង់អគារថ្មីបានទៀត
ឡើយ ។

សូមថ្វាយព្រះពរ បន្ទាប់អំពីនេះ អាគ្នាភាពសូមព្រះរាជគាន់ថ្វាយពតិ-



នេះជាត្រើះស្ថានព្រះនរោត្តម-សីហនុ នៅវិទ្យាល័យ ព្រះសុរាម្រិត សម្ពោធកាលពី
ថ្ងៃទី ១៥ - ១១-៦៣ ក្រោមព្រះអធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចសហដ្ឋិនៃ
ព្រះប្រមុខរដ្ឋកម្ពុជា

មានអំពីពិធីបុណ្យក្នុងទីកាសនេះសូមទ្រង់ជ្រាបដូចតទៅ ។

ឧត្តលិក សាស្ត្រាចារ្យ និងសមណនិស្សិតទាំងអស់នៅអគ្គាធិការដ្ឋាន នៃពុទ្ធិកសិក្សា នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ នៅពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត នៅពុទ្ធសាសនបណ្ឌិត្យ រួមទាំងក្រសួងធម្មការផង បានព្រម ព្រៀងគ្នា ធ្វើពិធីបុណ្យចំរើនព្រះជន្មសម្តេចជាម្ចាស់ គឺកងឹកត្រីនៃថ្ងៃនេះ ដើម្បីនិមន្តព្រះសង្ឃ ៤៣ អង្គ មានសម្តេចទាំងពីរព្រះអង្គជាប្រធាន មកចំ រើនព្រះបរិត្តនៅទីនេះ រួចនិមន្តសម្តេចប្រធានធម្មទេសនា ទុកជាធម្មទាន រួមជាមួយនឹងភេសជ្ជទាន ថ្វាយព្រះភជកុសល ១ លើក លុះដល់ព្រឹក ស្អែកនឹងនិមន្តព្រះសង្ឃ ៤៣ អង្គដែលចំរើនព្រះបរិត្តពីល្ងាច មកចំរើនធម្ម ចក្កប្បវត្តសូត្រ រួចដាក់ជាត្រប្រគេនទេយ្យទានទៀតលើកទៀត។ ពិធីបុណ្យទាំង ពីរលើកនេះ សូមលើកថ្វាយជាព្រះភជកុសល ចំពោះសម្តេចជាម្ចាស់ដើម្បី ព្រះអង្គបានចំរើន ព្រះជន្មាយុយឺនយូរជាង៩យ៉ាងសព្វ ប្រកបដោយសេច- ក្តីសុខសាន្ត កុំបីមានសត្រូវមកពាលាយាយីព្រះអង្គបានឡើយ ទាំងកិច្ចការ ទាំងឡាយណាដែលមានសារៈប្រយោជន៍ ដល់ប្រទេសជាតិដល់ព្រះពុទ្ធ សាសនា ដែលសម្តេចជាម្ចាស់បានផ្តើមធ្វើឡើង សូមឲ្យកិច្ចការទាំង នោះបានសម្រេចដោយប្រពៃ កុំបីមានឧបសគ្គអ្វីមកកាំងកាបានឡើយ ។

នៅអវសានេះ អាត្មាភាពសូមលើកចំពោះគុណព្រះរតនត្រ័យ សូមសំបូងសង្រួង អស់ពួកទេព្តាក្នុងសែនកោដិចក្រវាឡ ដែលមានចិត្ត

ល្អជាសម្ងាត់ដ្ឋ ជួយអភិបាលរក្សាសម្តេចព្រះមហាក្សត្រិយានីជាម្ចាស់ជីវិត ខ្ញុំសម្តេចព្រះប្រមុខរដ្ឋជាម្ចាស់ សូមព្រះអង្គបានប្រកបដោយព្រះសុភមង្គលវិបុលសុខ សិរីសួស្តីជោគជ័យ ឈ្នះអស់មាសត្រូវត្រង់ទិសទីអស់កាលជានិច្ច ត្រង់ពាក្យ កុំបីឃ្លាត ។

សូមប្រគេន ថ្វាយដួន ចំពោះសម្តេចសង្ឃនាយកទាំងពីរព្រះអង្គ ព្រះពជវង្សាខុវង្ស ឯកទត្តម ខ្ញុំអស់លោក ព្រមទាំងពុទ្ធបរិស័ទទាំងឡាយ ខ្ញុំពុទ្ធតទាំង៩ ប្រការ តើ អាយុ វណ្ណៈ សុខៈ ពលៈ ខ្ញុំបាទដីកាណៈ តរៀងទៅ ។